# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៧០

បាលីប្រែ ៨៣

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# បរមត្ថទីបនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ធាតុកថា និង បុគ្គលបញ្ញត្តិ

# ៧០

## បាលីប្រែ ៨៣



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៧០

# ធាតុកថា

## *សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## មាតិកា

[ ១ ] *ការសង្គ្រោះ ការមិនសង្គ្រោះ ការមិនសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ការសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ការសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ការមិនសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ការប្រកបព្រម ការប្រាសចេញ ការប្រាសចេញ មួយអន្ទើដោយការប្រកបព្រម ការប្រកបព្រម មួយអន្ទើដោយការប្រាសចេញ ការប្រកបព្រម មួយអន្ទើដោយការប្រកបព្រម ការប្រាសចេញ មួយអន្ទើដោយការប្រាសចេញ ការប្រកបព្រម និងការប្រាសចេញ មួយអន្ទើដោយការសង្គ្រោះ ការសង្គ្រោះ និងការមិនសង្គ្រោះ មួយអន្ទើដោយការប្រកបព្រម ការប្រកបព្រម និងការប្រាសចេញ មួយអន្ទើដោយការមិនសង្គ្រោះ ការសង្គ្រោះ និងការមិនសង្គ្រោះ មួយអន្ទើដោយការប្រាសចេញ ។ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៤ ឥន្ទ្រិយ ២២ បដិច្ចសមុប្បាទ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឈាន ៤ អប្បមញ្ញា ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ*

៨ ដ៏ប្រសើរ ផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត អធិមោក្ខ ( ការជឿស៊ប់ ) មនសិការ ( ការធ្វើទុកក្នុងចិត្ត ) ។ ការសង្គ្រោះដោយបទ ៣ ការមិនសង្គ្រោះដោយបទ ៣ ការសម្រកបដោយបទ ៤ ការប្រាសចេញចាកបទ ៤ ។ ធម៌មានចំណែកស្មើ ធម៌មានចំណែកមិនស្មើ ។ ធម្មសង្គណិទាំងអស់ ជាមាតិកានៃធាតុកថា ។

**មាតិកា ចប់**

# អដ្ឋកថា

## បរមត្ថទីបនី បញ្ចប្បករណ៍

## អដ្ឋកថា ធាតុកថា

## អារម្ភកថា

*ព្រះមហាវីរៈទ្រង់ឈ្មោះមារ កាលទ្រង់សម្តែងវិភង្គប្បករណ៍ ដោយវិភង្គ ១៨ ចប់ហើយ កាលទ្រង់ប្រកាសការផ្សេងគ្នានៃធាតុ ទើបត្រាស់ធាតុកថា-បករណ៍ ក្នុងលំដាប់នៃវិភង្គប្បករណ៍នោះឯង ខ្ញុំពុទ្ធឃោសាចារ្យ នឹងសម្តែងអត្ថនៃធាតុកថាបករណ៍នោះ សូមសាធុជនទាំងឡាយ មានចិត្តតាំងមាំស្តាប់ព្រះធម៌ហោង ។*

## អដ្ឋកថា មាតិកា

## នយមាតិកា

[ ១ ] *ព្រះធម្មសង្គាហកាចារ្យបានពោលថា បករណ៍នេះ ព្រះមានព្រះភាគ ទ្រង់ចែក ១៤ ន័យ ដោយអំណាចនៃបទថា* **សង្គហោ អសង្គហោ** *ជាដើម ពាក្យទាំងអស់លោកតាំង ២ យ៉ាង គឺដោយឧទ្ទេស និងនិទ្ទេស ។ ឧទ្ទេសនៃធម៌ មានខន្ធជាដើម ឈ្មោះថា* **មាតិកា ។** *មាតិកានេះ ព្រះមានព្រះភាគទ្រង់តាំងជា ៥ យ៉ាង គឺនយមាតិកា ១ អព្ភន្តរមាតិកា ១ នយមុខមាតិកា ១ លក្ខណមាតិកា ១ ពាហិរមាតិកា ១ ។*

បណ្ដាមាតិកាទាំងនោះ មាតិកាដែលទ្រង់តាំង ១៤ បទ មានបទថា **សង្គហោ អសង្គហោ ។បេ។ វិប្បយុត្តេន សង្គហិតំ អសង្គហិតំ** នេះ ឈ្មោះថា នយមាតិកា ។ ពិតហើយ មាតិកានេះ ទ្រង់ត្រាស់ហៅថា នយ-មាតិកា ព្រោះភាពដែលមាតិកានេះ ទ្រង់តាំងទុកដើម្បីសម្ដែងថា ធម៌ទាំងឡាយ ក្នុងធាតុកថាដែលទ្រង់ចែកហើយ ដោយន័យដែលសង្គ្រោះចូលគ្នាបានជាដើមនេះ ។ នយមាតិកានេះ ទោះបីហៅថា មូលមាតិកាក៏គួរ ព្រោះជាមូលនៃបទទាំងឡាយនោះ ។

# អព្ភន្តរមាតិកា

មាតិកាដែលទ្រង់តាំងទុក ១២៥ បទថា **បញ្ចក្ខន្ធា ។បេ។ មនសិការោ** នេះ ឈ្មោះថា អព្ភន្តរមាតិកា ។ ពិតហើយ មាតិកានេះ លោកហៅថា អព្ភន្តរមាតិកា ព្រោះមាតិកានេះ ទ្រង់មិនត្រាស់យ៉ាងនេះថា ធម្មសង្គណីទាំងអស់ជាមាតិកាក្នុងធាតុកថា ដូច្នេះ តែទ្រង់សម្ដែងធម៌ មានខន្ធជាដើម ដែលគួរចែកដោយន័យមានការសង្គ្រោះចូលគ្នាបានជាដើម ដោយសង្ខេបហើយតាំងទុកខាងក្នុងនៃធាតុកថានោះឯង ។ សេចក្ដីនេះ ទោះបីពោលថា ជាបកិណ្ណកមាតិកាដូច្នេះក៏បាន ព្រោះពាក្យទាំងឡាយ មានខន្ធជាដើម មិនបានសង្គ្រោះទុកក្នុងធម្មសង្គណីមាតិកា ។

# នយមុខមាតិកា

មាតិកាដែលទ្រង់តាំងទុកដោយបទទាំងឡាយ ៤ គឺ **តីហិ សង្គហោ**

**តីហិ អសង្គហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ** នេះឈ្មោះថា នយមុខមាតិកា ។ ពិតហើយ ធម៌ដែលសង្គ្រោះចូលគ្នាបាន និងធម៌ដែលសង្គ្រោះចូលគ្នាមិនបាននេះ ព្រះមានព្រះភាគ ទ្រង់ប្រកបក្នុងធម៌ទាំងឡាយ មានបញ្ចក្ខន្ធជាដើមទាំងអស់ និងក្នុងធម៌នៃមាតិកាទាំងឡាយ មានកុសលត្តិកៈជាដើម ដោយបទទាំង ៣ គឺខន្ធ អាយតនៈ និងធាតុនោះឯង ។ ដោយទំនងដូចគ្នា ធម៌ដែលប្រកបចូលគ្នាបានក្តី ធម៌ដែលប្រកបចូលគ្នាមិនបានក្តី ក៏ទ្រង់ប្រកបដោយអរូបក្ខន្ធទាំង ៤ ។ ដែលហៅថា នយមុខមាតិកា ព្រោះតាំងដើម្បីសម្តែងថា ធម៌ទាំង ៤ នេះ ជាប្រធានរបស់ន័យទាំងនេះ មានធម៌ដែលសង្គ្រោះចូលគ្នាបានជាដើម ។

## លក្ខណមាតិកា

មាតិកាដែលទ្រង់តាំងដោយបទទាំង ២ គឺ **សភាគោ វិសភាគោ** ឈ្មោះថា លក្ខណមាតិកា ។ ពិតហើយ ន័យរបស់ធម៌ដែលសង្គ្រោះចូលគ្នាបាន ព្រះមានព្រះភាគ ទ្រង់ប្រកបដោយធម៌ទាំងឡាយ ដែលមានលក្ខណៈស្មើគ្នា ន័យរបស់ធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ទ្រង់ប្រកបដោយធម៌ទាំងឡាយ ដែលមានលក្ខណៈមិនស្មើគ្នា ន័យរបស់ធម៌ ដែលប្រកបចូលគ្នាបាន និងធម៌ដែលប្រកបចូលគ្នាមិនបាន ក៏ដូចគ្នា ។ ដែលហៅថា លក្ខណមាតិកា ព្រោះតាំងដើម្បីសម្តែងលក្ខណៈនៃធម៌ដែលសង្គ្រោះចូលគ្នាបានជាដើម ដោយអំណាចលក្ខណៈនៃធម៌ ដែលមានចំណែកស្មើគ្នា និងមានចំណែកមិនស្មើគ្នា ។

# ពាហិរមាតិកា

មាតិកាដែលទ្រង់សង្ខេបបទតិកៈ ៦៦ និងបទទុកៈ ២០០ តាំងទុកថា ធម្មសង្គណីទាំងអស់ ជាមាតិកានៃធាតុកថា នេះឈ្មោះថា ពាហិរមាតិកា ។ ពិតហើយ មាតិកានេះ ហៅថា ពាហិរមាតិកា ព្រោះព្រះមានព្រះភាគ មិនត្រាស់ក្នុងធាតុកថាយ៉ាងនេះថា **បញ្ចក្ខន្ធា ។បេ។ មនសិការោ** ដូច្នេះឡើយ តែទ្រង់តាំងទុកខាងក្រៅ ចាកមាតិកានៃធាតុកថា យ៉ាងនេះថា **សព្វាបិ ធម្មសង្គណិ** ធម្មសង្គណីទាំងអស់ ដូច្នេះ ។

បណ្ឌិតកាលជ្រាបភាពដែលមាតិកា ជាសភាវៈ ដែលព្រះមានព្រះភាគត្រាស់ទុក ៥ យ៉ាង ដោយប្រការដូច្នេះហើយ ឥឡូវនេះ គប្បីជ្រាបធម៌ដែលសង្គ្រោះចូលគ្នាបាន ៤ យ៉ាង ក្នុងបទទាំងឡាយ មានបទថា **សង្គហោ អសង្គហោ** ជាដើម ដោយអំណាចនៃជាតិសង្គហៈ សញ្ជាតិសង្គហៈ កិរិយាសង្គហៈ និងគណនសង្គហៈ ។

ក្នុងធម៌ដែលសង្គ្រោះចូលគ្នាបានទាំងនោះ ការសង្គ្រោះដែលពោលថា ពួកក្សត្រទាំងពួង ចូរមក ពួកព្រាហ្មណ៍ទាំងពួង ពួកវេស្សៈទាំងពួង ពួកសូទ្រៈទាំងពួង ចូរមក និងពាក្យថា ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ នេះឈ្មោះថា ជាតិសង្គហៈ ។ ព្រោះថា ក្នុងអធិការនេះ ធម៌ទាំងពួងដល់នូវការសង្គ្រោះតែមួយដូចគ្នាដោយជាតិ ហាក់បីដូចក្នុងឋានៈដែលលោកពោលហើយថា ជនទាំងឡាយដែលមានជាតិដូចគ្នាចូរមក ដូច្នេះ ។

ការសង្គ្រោះដែលពោលថា អ្នកកោសលទាំងពួងចូរមក អ្នកមគធៈទាំងពួងចូរមក អ្នកការុកច្ឆៈទាំងពួងចូរមក និងពាក្យថា ម្នាលអាវុសោ វិសាខ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ ដូច្នេះ នេះឈ្មោះថា សញ្ជាតិសង្គហៈ ។ ពិតហើយ ក្នុងទីនេះ ជនទាំងអស់ដល់ហើយនូវការសង្គ្រោះតែមួយជាមួយគ្នាក្នុងស្ថានទីកើត គឺដោយឱកាសដែលនៅអាស្រ័យ ហាក់បីដូចក្នុងទីដែលលោកពោលហើយថា ជនទាំងឡាយដែលទាក់ទងគ្នាដោយជាតិតែមួយ ចូរមក ដូច្នេះ ។

ការសង្គ្រោះដែលលោកពោលហើយថា ទាហានដំរីចូរមក ទាហានសេះចូរមក ទាហានរថចូរមក និងពាក្យថា ម្នាលអាវុសោវិសាខ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ដូច្នេះ នេះឈ្មោះថា កិរិយាសង្គហៈ គឺការសង្គ្រោះចូលគ្នាដោយការធ្វើ ។ ព្រោះជនទាំងអស់នោះ ដល់ហើយនូវការសង្គ្រោះចូលជាមួយគ្នា ដោយការធ្វើរបស់ខ្លួន ។

សួរថា អាយតនៈ គឺចក្ខុ ដល់នូវការរាប់ដោយខន្ធណា ឆ្លើយថា ដល់នូវការរាប់ដោយរូបក្ខន្ធ ដូច្នេះ ។ ការសង្គ្រោះដែលលោកពោលថា បើអាយតនៈ គឺចក្ខុ ដល់នូវការរាប់ដោយរូបក្ខន្ធ ( យ៉ាងនេះ ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អាយតនៈ គឺចក្ខុ សង្គ្រោះដោយរូបក្ខន្ធ ដូច្នេះ នេះឈ្មោះថា គណនសង្គហៈ គឺការសង្គ្រោះចូលគ្នាដោយការរាប់ ។

គណនសង្គហៈនេះ លោកបំណងយកក្នុងទីនេះ ។ បណ្ឌិតគប្បីជ្រាបធម៌ដែលរាប់សង្គ្រោះចូលគ្នាមិនបាន ព្រោះជាបដិបក្ខចំពោះធម៌នោះ ។ គប្បីជ្រាបបទថា **សង្គហិតេន អសង្គហិតំ** ជាដើម ដោយការកំណត់នូវធម៌ទាំងនោះ ។ គប្បីជ្រាបការប្រកបចូលគ្នាបាន ដោយអំណាចនៃភាពជាឯកុប្បាទៈ ឯកនិរោធៈ ឯកវត្ថុកៈ ឯការម្មណៈ ។ គប្បីជ្រាបការប្រកបចូលគ្នាមិនបាន ដោយភាពជាបដិបក្ខ ចំពោះការប្រកបចូលគ្នាបាននោះ ។ គប្បីជ្រាបបទថា **សម្បយុត្តេន វិប្បយុត្តំ** ជាដើមដោយការកំណត់នូវធម៌ទាំងនោះ ។ គប្បីជ្រាបបទថា **សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ** ជាដើម ដោយការកំណត់នូវធម៌ដែលទាក់ទងគ្នាទាំង ២ បទនោះ ។ ឯបទថា **បញ្ចក្ខន្ធា** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងខន្ធវិភង្គជាដើមនោះឯង ។ តែធម៌ទាំងឡាយ មានផស្សៈជាដើមក្នុងទីនេះត្រាស់ជាសាធារណៈដល់ចិត្តុប្បាទគ្រប់ដួង ដែលពោលហើយដោយអំណាចចូលគ្នាបាន ដូច្នេះ ។៙

## អដ្ឋកថាមាតិកា ចប់

# អភិធម្មបិដក

## សង្គហាសង្គហបទនិទ្ទេស

[ ២ ] រូបក្ខន្ធសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ រូបក្ខន្ធសង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៣ ] វេទនាខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ វេទនាខន្ធ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤ ] សញ្ញាខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ សញ្ញាខន្ធ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៥ ] សង្ខារក្ខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ សង្ខារក្ខន្ធ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៦ ] វិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ វិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ៧ ] រូបក្ខន្ធ និងវេទនាខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ រូបក្ខន្ធ និងវេទនាខន្ធ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ។

[ ៨ ] រូបក្ខន្ធ និងសញ្ញាខន្ធ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ។

[ ៩ ] រូបក្ខន្ធ និងសង្ខារក្ខន្ធ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ។

[ ១០ ] រូបក្ខន្ធ និងវិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១១ ] រូបក្ខន្ធ វេទនា និងសញ្ញាខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ រូបក្ខន្ធ វេទនាខន្ធ និងសញ្ញាខន្ធ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ៧ ។

[ ១២ ] រូបក្ខន្ធ វេទនាខន្ធ និងសង្ខារក្ខន្ធ សង្គ្រោះដោយខន្ធ ៣

អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ៧ ។

[ ១៣ ] រូបក្ខន្ធ វេទនាខន្ធ និងវិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៤ ] រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ១៥ ] រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៦ ] រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយ

ខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៧ ] បញ្ចក្ខន្ធ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ បញ្ចក្ខន្ធសង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

# អដ្ឋកថា

## និទ្ទេស សង្គហាសង្គហបទ

## ខន្ធបទនិទ្ទេស

[ ២-១៧ ] ឥឡូវនេះ ដើម្បីសម្តែងមាតិកាតាមដែលព្រះមានព្រះភាគទ្រង់តាំងដោយអំណាចនៃខន្ធ ៥ ជាដើម ប្រកបជាមួយបទ នយមាតិកាទាំងឡាយ មានបទថា **សង្គហោ អសង្គហោ** ជាដើម ព្រះមានព្រះភាគទ្រង់ផ្តើមនិទ្ទេសវារ ដោយន័យជាដើមថា **រូបក្ខន្ធោ កតីហិ ខន្ធេហិ** ដូច្នេះ ។ បណ្តាមាតិកាទាំងនោះ ព្រោះនយមុខមាតិកា ព្រះមានព្រះភាគទ្រង់តាំងទុកថា **តីហិ សង្គហោ** គឺការសង្គ្រោះចូលគ្នាបានជាមួយធម៌ ៣ គឺដោយខន្ធ អាយតនៈ និងធាតុ **តីហិ អសង្គហោ** គឺការសង្គ្រោះចូលគ្នាមិនបានជាមួយធម៌ ៣ ដោយនយមាតិកាថា **សង្គហោ អសង្គហោ** ជាដើម ដូច្នេះ ដើម្បីសម្តែងការរាប់សង្គ្រោះរូបក្ខន្ធជាដើម ទើបទ្រង់លើកបទទាំង ៣ គឺខន្ធ អាយតនៈ និងធាតុនោះឯងសម្តែងថា ធម៌ទាំងនេះរាប់សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ដូច្នេះ ។ បណ្តាធម៌ទាំងឡាយ មានសច្ចៈ ៤ ជាដើមណាមួយ មិនជាបរាមដ្ឋៈ គឺមិនជាអារម្មណ៍របស់បរាមាស ។

លក្ខណមាតិកា ព្រះមានព្រះភាគ ទ្រង់តាំងយ៉ាងនេះថា **សភាគោ វិសភាគោ** ដូច្នេះ ក្នុងការវិសជ្ជនាបញ្ហានេះ ទើបទ្រង់ត្រាស់ថា **រូបក្ខន្ធោ ឯកេន ខន្ធេន** រូបក្ខន្ធ សង្គ្រោះដោយខន្ធ ១ ជាដើម ព្រោះថា ធម៌ មានខន្ធជាដើមនេះ ជាសភាគៈរបស់រូបក្ខន្ធនោះ ។ បណ្តាបទទាំងនោះ បទថា

**ឯកេន ខន្ធេន** បានដល់ រូបក្ខន្ធនោះឯង ។ ពិតហើយ រូបឯណាមួយរមែង ដល់នូវការរាប់សង្គ្រោះថាជារូបក្ខន្ធនោះឯង ព្រោះជាធម៌ស្មើនឹងរូបក្ខន្ធ ព្រោះហេតុនោះ ទើបរូប ទ្រង់កាន់យកដោយរូបក្ខន្ធនោះឯង គឺកំណត់យកដោយរូបក្ខន្ធនោះឯង ។ បទថា **ឯកាទសហាយតនេហិ** បានដល់ វៀរចាកមនាយតនៈ ព្រោះរូបក្ខន្ធទាំងពួងជាអាយតនៈ ១០ និងជាចំណែកមួយនៃធម្មាយតនៈ ព្រោះហេតុនោះ ទើបរូបក្ខន្ធនោះលោករាប់យកហើយ កំណត់យកហើយដោយអាយតនៈ ១១ ។ បទថា **ឯកាទសហិ ធាតូហិ** បានដល់ធាតុ ១១ វៀរវិញ្ញាណធាតុ ៧ ព្រោះថា ធម្មតារូបដែលមិនបានរាប់បញ្ចូលក្នុងធាតុទាំងនោះមិនមាន ។

ក្នុងនិទ្ទេសរបស់អសង្គហន័យ ទ្រង់ធ្វើពាក្យសួរដោយសង្ខេបថា **កតីហិ អសង្គហិតោ** មិនសង្គ្រោះដោយធម៌ប៉ុន្មាន ដូច្នេះ តែព្រោះក្នុងការវិសជ្ជនានៃបញ្ហានោះ អរូបក្ខន្ធ ៤ មនាយតនៈ ១ វិញ្ញាណធាតុ ៧ ជាវិសភាគនៃរូបក្ខន្ធ ព្រោះហេតុនោះ ទើបត្រាស់ថា **ចតូហិ ខន្ធេហិ** ដោយខន្ធ ៤ ជាដើម ។ បណ្ឌិតគប្បីជ្រាបបទថា **សង្គហោ អសង្គហោ** ក្នុងបទទាំងពួងដោយន័យនេះ ។

មួយវិញទៀត ក្នុងបទថា **រូបក្ខន្ធោ កតីហិ ខន្ធេហិ** ជាដើម ក្នុងខន្ធនិទ្ទេសនេះ ទ្រង់សម្តែងពាក្យបុច្ឆា ៥ និងវិសជ្ជនា ៥ ក្នុងសង្គហន័យដែលជាឯកមូល ដោយសង្ខេប ។ ក្នុងអសង្គហន័យ ក៏សម្តែងបុច្ឆា ៥ និងវិសជ្ជនា ៥ ដោយសង្ខេប សូម្បីក្នុងមូលទាំងឡាយ មានទុកមូលជាដើម

*បណ្ឌិតគប្បីជ្រាបបុច្ឆា និងវិសជ្ជនាទាំងឡាយដោយឧបាយនេះ ។ ក្នុងនិទ្ទេសនេះ ទ្រង់សម្តែងទុកមូល តិកមូល និងចតុក្កមូលដែលមានរូបក្ខន្ធជាមូលនោះឯង ។ តែក្នុងបញ្ចកមូល ទ្រង់ធ្វើបុច្ឆាវិសជ្ជនា ២ យ៉ាង គឺដោយការបែកយ៉ាងនេះថា* **រូបក្ខន្ធោ ច ។បេ។ វិញ្ញាណក្ខន្ធោ ច** *និងដោយមិនញែកគ្នាយ៉ាងនេះថា* **បញ្ចក្ខន្ធា កតីហិ ខន្ធេហិ** *ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះបាលីដូចពណ៌នាមកនេះ ។*

## អដ្ឋកថាខន្ធបទ ចប់

# អភិធម្មបិដក

## អាយតនបទនិទ្ទេស

[ ១៨ ] ចក្ខាយតនៈ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ចក្ខាយតនៈ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៩ ] សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ២០ ] មនាយតនៈ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ២១ ] ធម្មាយតនៈ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១៧ ។

[ ២២ ] ចក្ខាយតនៈ និងសោតាយតនៈ សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ២៣ ] ចក្ខាយតនៈ និងឃានាយតនៈ ១ ចក្ខាយតនៈ និងជិវ្ហាយតនៈ ១ ចក្ខាយតនៈ និងកាយាយតនៈ ១ ចក្ខាយតនៈ និងរូបាយតនៈ ១ ចក្ខាយតនៈ និងសទ្ទាយតនៈ ១ ចក្ខាយតនៈ និងគន្ធាយតនៈ ១ ចក្ខាយតនៈ និងរសាយតនៈ ១ ចក្ខាយតនៈ និងផោដ្ឋព្វាយតនៈ ១ សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ២៤ ] ចក្ខាយតនៈ និងមនាយតនៈ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១០ ។

[ ២៥ ] ចក្ខាយតន :និងធម្មាយតនៈ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ២៦ ] អាយតនៈ ១២ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ អាយតនៈ ១២ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

# ធាតុនិទ្ទេស

[ ២៧ ] ចក្ខុធាតុសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ចក្ខុធាតុសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ២៨ ] សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ មនោធាតុ មនោវិញ្ញាណធាតុ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ២៩ ] ធម្មធាតុ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១៧ ។

[ ៣០ ] ចក្ខុធាតុ និងសោតធាតុ សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ៣១ ] ចក្ខុធាតុ និងឃានធាតុ ១ ចក្ខុធាតុ និងជិវ្ហាធាតុ ១ ចក្ខុធាតុ និងកាយធាតុ ១ ចក្ខុធាតុ និងរូបធាតុ ១ ចក្ខុធាតុ និងសទ្ទធាតុ ១ ចក្ខុធាតុ និងគន្ធធាតុ ១ ចក្ខុធាតុ និងរសធាតុ ១ ចក្ខុធាតុ និងផោដ្ឋព្វធាតុ ១ សង្គ្រោះ

ដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ៣២ ] ចក្ខុធាតុ និងចក្ខុវិញ្ញាណធាតុ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១៦ ។

[ ៣៣ ] ចក្ខុធាតុ និងសោតវិញ្ញាណធាតុ ១ ចក្ខុធាតុ និងឃានវិញ្ញាណ-ធាតុ ១ ចក្ខុធាតុ និងជិវ្ហាវិញ្ញាណធាតុ ១ ចក្ខុធាតុ និងកាយវិញ្ញាណធាតុ ១ ចក្ខុធាតុ និងមនោធាតុ ១ ចក្ខុធាតុ និងមនោវិញ្ញាណធាតុ ១ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១៦ ។

[ ៣៤ ] ចក្ខុធាតុ និងធម្មធាតុ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៣៥ ] ធាតុទាំង ១៨ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ធាតុទាំង ១៨ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

# អដ្ឋកថា

## អាយតនបទជាដើម

[ ១៨-៣៥ ] ក្នុងនិទ្ទេសទាំងឡាយ មានអាយតនបទនិទ្ទេសជាដើម គប្បីជ្រាបអាយតនបទនិទ្ទេសមុន ។ បទថា **ចក្ខាយតនំ ឯកេន ខន្ធេន** សេចក្ដីថា ចក្ខាយតនៈ គប្បីជ្រាបថា រាប់សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ ១ ជាមួយចក្ខាយតនៈ ១ ជាមួយចក្ខុធាតុ ១ ។ ក្នុងសោតាយតនៈជាដើម ក៏គប្បីជ្រាបការសង្គ្រោះចូលបាន និងការសង្គ្រោះចូលគ្នាមិនបានដោយន័យនេះឯង តែក្នុងបទថា **អសង្ខតំ ខន្ធតោ ឋបេត្វា** នេះ ព្រោះអសង្ខតៈ គឺនិព្វាន ឈ្មោះថា ធម្មាយតនៈ ធម្មាយតនៈ គឺនិព្វាននោះ មិនដល់នូវការសង្គ្រោះថាជាខន្ធ ព្រោះហេតុនោះ ទើបត្រាស់ថា **ខន្ធតោ ឋបេត្វា** ដូច្នេះ ។ បទថា **ចតូហិ ខន្ធេហិ** បានដល់ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ព្រោះថា ធម្មាយតនៈ វៀរនិព្វានហើយ សង្គ្រោះចូលគ្នាបានជាមួយខន្ធទាំងឡាយ មានរូបក្ខន្ធជាដើមនេះ ។ ឯអាយតនៈនោះវៀរធម្មាយតនៈ និងធម្មធាតុហើយ សង្គ្រោះចូលគ្នាមិនបានជាមួយវិញ្ញាណក្ខន្ធ អាយតនៈ និងធាតុដ៏សេស ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ធម្មាយតនៈ សង្គ្រោះចូលគ្នាមិនបានជាមួយខន្ធ ១ ( វិញ្ញាណក្ខន្ធ ) ជាមួយអាយតនៈ ១១ ( ឱឡារិកាយតនៈ ១០ និងមនាយតនៈ ១ ) ជាមួយធាតុ ១៧ ( ឱឡារិកធាតុ ១០ និងវិញ្ញាណធាតុ ៧ ) ដូច្នេះ ។ ន័យទាំងឡាយដែលមានរូបក្ខន្ធ ជាមូលខាងដើមយ៉ាងណា គប្បីជ្រាបន័យទាំងឡាយ ដែលមានចក្ខាយតនៈជា

មូលក្នុងទីនេះ ក៏យ៉ាងនោះ ។ ព្រះមានព្រះភាគកាលទ្រង់សម្ដែងបាលីទុកៈ គឺភេទសុទ្ធ និងភេទឯកមូលាទិ សមគួរហើយ ទើបធ្វើបុច្ឆាវិសជ្ជនាដោយការមិនបែក គឺ **ធ្វាទសាយតនានិ** ដូច្នេះ ។ សូម្បីក្នុងធាតុនិទ្ទេស ក៏មានន័យដូច្នេះឯង ។៚

## អដ្ឋកថាអាយតនបទជាដើម ចប់

# អភិធម្មបិដក

## សច្ចនិទ្ទេស

[ ៣៦ ] ទុក្ខសច្ចសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ទុក្ខសច្ចសង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៣៧ ] សមុទយសច្ច និងមគ្គសច្ច សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៣៨ ] និរោធសច្ច មិនសង្គ្រោះដោយខន្ធណានីមួយឡើយ សង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។

[ ៣៩ ] ទុក្ខសច្ច និងសមុទយសច្ច សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤០ ] ទុក្ខសច្ច និងមគ្គសច្ច សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធ

ណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤១ ] ទុក្ខសច្ច និងនិរោធសច្ច វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៤២ ] ទុក្ខសច្ច សមុទយសច្ច និងមគ្គសច្ច សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៣ ] ទុក្ខសច្ច សមុទយសច្ច និងនិរោធសច្ច វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៤ ] ទុក្ខសច្ច សមុទយសច្ច មគ្គសច្ច និងនិរោធសច្ច វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ

ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៥ ] សច្ចៈ ៤ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ សច្ចៈ ៤ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

# អដ្ឋកថា

## សច្ចបទ

[ ៣៦-៤៥ ] ក្នុងសច្ចនិទ្ទេស ទុកៈ តិកៈ ចតុក្កៈទាំងពួង ទ្រង់សម្ដែងជាក់ច្បាស់ហើយក្នុងព្រះបាលី តែព្រោះពាក្យវិសជ្ជនាក្នុងមគ្គសច្ច ក្នុងទុកៈ តិកៈទាំងឡាយ ក៏ដូចគ្នានឹងសមុទយសច្ចនោះឯង ព្រោះហេតុនោះ ទើបទ្រង់ត្រាស់មគ្គសច្ចនោះ ក្នុងលំដាប់នៃសមុទយសច្ច ។

**អដ្ឋកថាសច្ចបទ ចប់**

# អភិធម្មបិដក

## ឥន្ទ្រិយនិទ្ទេស

[ ៤៦ ] ចក្ខុន្ទ្រិយ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ចក្ខុន្ទ្រិយ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៧ ] សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៨ ] មនិន្ទ្រិយ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ៤៩ ] ជីវិតិន្ទ្រិយ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១១ ធាតុ ១១ ។

[ ៥០ ] សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៥១ ] ចក្ខុន្ទ្រិយ និងសោតិន្ទ្រិយ សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥២ ] ចក្ខុន្ទ្រិយ និងឃានិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងជិវ្ហិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងកាយិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងឥត្ថិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងបុរិសិន្ទ្រិយ ១ សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥៣ ] ចក្ខុន្ទ្រិយ និងមនិន្ទ្រិយ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១០ ។

[ ៥៤ ] ចក្ខុន្ទ្រិយ និងជីវិតិន្ទ្រិយ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥៥ ] ចក្ខុន្ទ្រិយ និងសុខិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងទុក្ខិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងសោមនស្សិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងទោមនស្សិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងឧបេក្ខិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងសទ្ធិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងវីរិយិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងសតិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងសមាធិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងបញ្ញិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងអញ្ញិន្ទ្រិយ ១ ចក្ខុន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ១ សង្គ្រោះដោយខន្ធ ២ អាយតនៈ

២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥៦ ] ឥន្ទ្រិយ ២២ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ឥន្ទ្រិយ ២២ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ៧ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ៥ ធាតុ ៥ ។

# អដ្ឋកថា

## ឥន្ទ្រិយបទ

[ ៤៦-៥៦ ] ក្នុងឥន្ទ្រិយនិទ្ទេស បទថា **ជីវិតិន្ទ្រិយំ ទ្វីហិ ខន្ធេហិ** សេចក្តីថា រូបជីវិតិន្ទ្រិយ សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ អរូបជីវិតិន្ទ្រិយ សង្គ្រោះចូលគ្នាបាន ជាមួយសង្ខារក្ខន្ធ ។ គប្បីជ្រាបឥន្ទ្រិយដ៏សេសដោយទំនងន័យដែលពោលហើយនោះឯង ។ ឯការកំណត់ព្រះបាលី ក្នុងនិទ្ទេសនេះ ដូចគ្នានឹងអាយតននិទ្ទេស និងធាតុនិទ្ទេសនោះឯង ៕

**អដ្ឋកថាឥន្ទ្រិយបទ ចប់**

# អភិធម្មបិដក

## បដិច្ចសមុប្បាទនិទ្ទេសជាដើម

[ ៥៧ ] អវិជ្ជា សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៥៨ ] សង្ខារ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៥៩ ] វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ៦០ ] នាមរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ៦១ ] សឡាយតនៈ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ សង្គ្រោះដោយខន្ធ ២ អាយតនៈ ៦ ធាតុ ១២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ៦ ធាតុ ៦ ។

[ ៦២ ] ផស្សៈ ( កើតមាន ) ព្រោះសឡាយតនៈជាបច្ច័យ វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ កម្មភព ( កើតមាន )

ព្រោះឧបាទានជាបច្ច័យ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៦៣ ] ឧបបត្តិភព កាមភព សញ្ញាភព បញ្ចវោការភព សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ទេ ។

[ ៦៤ ] រូបភព សង្គ្រោះដោយខន្ធ ៥ អាយតនៈ ៥ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ៧ ធាតុ ១០ ទេ ។

[ ៦៥ ] អរូបភព នេវសញ្ញានាសញ្ញាភព ចតុវោការភព សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៦៦ ] អសញ្ញាភព និងឯកវោការភព សង្គ្រោះដោយខន្ធ ១ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ៦៧ ] ជាតិ សង្គ្រោះដោយខន្ធ ២ ជរា សង្គ្រោះដោយខន្ធ ២ មរណៈ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១១ ធាតុ ១៧ ។

[ ៦៨ ] សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខទោមនស្ស ឧបាយាស សតិប្បដ្ឋាន សម្មប្បធាន សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

## ឥទ្ធិបាទនិទ្ទេស

[ ៦៩ ] ឥទ្ធិបាទ សង្គ្រោះដោយខន្ធ ២ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១០ ធាតុ ១៦ ។

## ឈាននិទ្ទេស

[ ៧០ ] ឈាន សង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១១ ធាតុ ១៧ ។

## អប្បមញ្ញានិទ្ទេស

[ ៧១ ] អប្បមញ្ញា ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ ដ៏ប្រសើរ ផស្សៈ វេទនា សញ្ញា ចេតនា អធិមោក្ខ មនសិការ

សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

## ចិត្តនិទ្ទេស

[ ៧២ ] ចិត្ត សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

# អដ្ឋកថា

## បដិច្ចសមុប្បាទជាដើម

[ ៥៧ ] ក្នុងបដិច្ចសមុប្បាទនិទ្ទេស ព្រះមានព្រះភាគ ទ្រង់មិនបានផ្ដើមពាក្យបុច្ឆាថា **អវិជ្ជា កតីហិ ខន្ធេហិ** អវិជ្ជាសង្គ្រោះដោយខន្ធប៉ុន្មាន តែទ្រង់សម្ដែងពាក្យវិសជ្ជនាតែម្ដង យ៉ាងនេះថា **អវិជ្ជា ឯកេន ខន្ធេន** អវិជ្ជាសង្គ្រោះដោយខន្ធ ១ ជាដើម ។ ក្នុងបទទាំងនោះ បទថា **សង្ខារប្បច្ចយា វិញ្ញាណំ** បានដល់ វិបាកវិញ្ញាណទាំងអស់ក្នុងបដិសន្ធិកាល និងក្នុងបវត្តិកាល ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **សត្តហិ ធាតូហិ សង្គហិតំ** សង្គ្រោះដោយធាតុ ៧ ដូច្នេះ ។ ក្នុងនាមរូបក៏គប្បីជ្រាបដោយអំណាចបដិសន្ធិកាល និងបវត្តិកាលនោះឯង ដោយហេតុនោះ ទើបទ្រង់សង្គ្រោះ សូម្បីសឡាយតនៈ ហើយសម្ដែងការសង្គ្រោះចូលគ្នាបានជាមួយអាយតនៈ ១១ ក្នុងបដិច្ចសមុប្បាទនិទ្ទេសនេះ ។

គប្បីជ្រាបការចែកខន្ធក្នុងធម៌ទាំងឡាយ មានផស្សៈជាដើម ដូចតទៅនេះថា ពិតហើយ ផស្សៈ សង្គ្រោះចូលគ្នាបានជាមួយខន្ធ ១ ដោយឡែក វេទនាខន្ធ ក៏សង្គ្រោះចូលគ្នាបានជាមួយខន្ធ ១ ដោយឡែក ។ ចំណែកតណ្ហា ឧបាទាន កម្មភព សង្គ្រោះចូលគ្នាបានចំពោះសង្ខារក្ខន្ធតែម្យ៉ាង ។ ម្យ៉ាងទៀត បទនៃភពទ្រង់ចែក ១១ យ៉ាង ដោយអំណាចនៃកម្មភពជាដើមក្នុងនិទ្ទេសនេះ ។ បណ្ដាភពទាំងនោះ កម្មភព ទ្រង់សម្ដែងរួមជាមួយភពទាំងនោះ ព្រោះជាពាក្យវិសជ្ជនា ដូចគ្នានឹងផស្សៈជាដើម ។ ឧបបត្តិភព

កាមភព សញ្ញាភព បញ្ចវោការភពទាំងឡាយ ទ្រង់សម្តែងរួមគ្នា ព្រោះជាពាក្យវិសជ្ជនាដូចគ្នានិងគ្នា តែព្រោះសភាវធម៌ទាំងនេះជាធម៌ដែលមានតណ្ហាទិដ្ឋិ ចូលទៅប្រកាន់ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា **ឯកាទសហាយតនេហិ សត្តរសហិ ធាតូហិ** សង្គ្រោះដោយអាយតនៈ ១១ ធាតុ ១៧ ដូច្នេះ ។ ពិតហើយ សទ្ទាយតនៈដែលតណ្ហា ទិដ្ឋិមិនបានប្រកាន់ ទើបសទ្ទាយតនៈនោះ ទ្រង់មិនកាន់យកក្នុងទីនេះ ។

[ ៦៤ ] ក្នុងរូបភវនិទ្ទេស បទថា **បញ្ចហាយតនេហិ** បានដល់ ជាមួយ ចក្ខាយតនៈ សោតាយតនៈ មនាយតនៈ រូបាយតនៈ និងធម្មាយតនៈ ។

បទថា **អដ្ឋហិ ធាតូហិ** បានដល់ ចក្ខុធាតុ សោតធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ រូបធាតុ ធម្មធាតុ មនោធាតុ មនោវិញ្ញាណធាតុ ។ ភពទាំង ៣ មានអរូបភពជាដើម សម្តែងរួមគ្នា ព្រោះជាពាក្យវិសជ្ជនាទំនងតែមួយ ។ អសញ្ញីភព ឯកវោការភពក៏យ៉ាងនោះ ។

[ ៦៦ ] ក្នុងបទទាំងនោះ បទថា **ទ្វីហាយតនេហិ** បានដល់ រូបាយតនៈ និងធម្មាយតនៈ ។ ក្នុងធាតុទាំងឡាយ ក៏ន័យនេះឯង ។ មួយវិញទៀត ក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគ ទ្រង់លើកយករូបាយតនៈមកសម្តែង ព្រោះរូបាយតនៈនៃព្រហ្មនោះ ជាអារម្មណ៍ដល់ព្រហ្មទាំងឡាយដ៏សេស ដែលនៅក្នុងជាន់ជាមួយគ្នា មានការកើតឡើងនៃចក្ខុ ។

[ ៦៧ ] បទថា **ជាតិ ទ្វីហិ ខន្ធេហិ** បានដល់ រូបជាតិ សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ អរូបជាតិសង្គ្រោះចូលគ្នាបានជាមួយសង្ខារក្ខន្ធ ។

ក្នុងជរានិងមរណៈក៏មានន័យនេះ ។

[ ៦៨ ] ក្នុងធម៌ មានសោកជាដើម ដោយបទថា **ឯកេន ១ទ្វេន** បណ្ឌិតគប្បីជ្រាបខន្ធដែលប្លែកគ្នា យ៉ាងនេះថា សោក ទុក្ខ ទោមនស្ស សង្គ្រោះចូលគ្នាបានជាមួយវេទនាខន្ធ បរិទេវៈ សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ ឧបាយាសជាដើម សង្គ្រោះចូលគ្នាបានជាមួយសង្ខារក្ខន្ធ ។

[ ៦៩ ] បទថា **ឥទ្ធិបាទោ ទ្វីហិ ១ទ្វេហិ** ជាដើម បានដល់ សង្គ្រោះចូលគ្នាបានជាមួយសង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ជាមួយមនាយតនៈ និងធម្មាយតនៈ ជាមួយធម្មធាតុ និងមនោវិញ្ញាណធាតុ ។

[ ៧០ ] បទថា **ឈានំ ទ្វីហិ ១ទ្វេហិ** បានដល់ ជាមួយវេទនាខន្ធ និងសង្ខារក្ខន្ធ ។ ធម៌ទាំងឡាយ មានអប្បមញ្ញាជាដើម អធិប្បាយរួមគ្នា ព្រោះជាពាក្យវិសជ្ជនាដោយទំនងតែមួយ តែចិត្តុប្បាទតាំងទុកក្នុងលំដាប់នៃចេតនា ក៏ទ្រង់សម្តែងជាខាងក្រោយ ព្រោះមានពាក្យវិសជ្ជនាមិនដូចគ្នា ។

[ ៧១ ] បណ្តាបទទាំងឡាយ មានអប្បមញ្ញាជាដើមនោះ បទថា **ឯកេន ១ទ្វេន** បណ្ឌិតគប្បីជ្រាបខន្ធដែលប្លែកគ្នាយ៉ាងនេះថា វេទនា សង្គ្រោះចូលគ្នាបានជាមួយវេទនាខន្ធ សញ្ញា សង្គ្រោះចូលគ្នាបានជាមួយសញ្ញាខន្ធ ធម៌ដ៏សេសសង្គ្រោះចូលគ្នាបានជាមួយសង្ខារក្ខន្ធ ។

## អដ្ឋកថាបដិច្ចសមុប្បាទជាដើម ចប់

# អភិធម្មបិដក

## តិកមាតិកានិទ្ទេស

[ ៧៣ ] ពួកធម៌ជាកុសល និងពួកធម៌ជាអកុសល សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌ជាកុសល និងពួកធម៌ជាអកុសល សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៧៤ ] ពួកធម៌ជាអព្យាក្រឹត វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៧៥ ] ពួកធម៌ប្រកបដោយសុខវេទនា ពួកធម៌ប្រកបដោយទុក្ខវេទនា សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៥ ។

[ ៧៦ ] ពួកធម៌ប្រកបដោយអទុក្ខមសុខវេទនា សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១១ ។

[ ៧៧ ] ពួកធម៌ជាវិបាក សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៧៨ ] ពួកធម៌មានវិបាកធម៌ជាប្រក្រតី និងពួកធម៌ដែលសៅហ្មងហើយ ទាំងគួរដល់នូវសេចក្ដីសៅហ្មង សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៧៩ ] ពួកធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ តែមិនសង្គ្រោះដោយធាតុ ៥ ទេ ។

[ ៨០ ] ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទាន សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ទេ ។

[ ៨១ ] ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន សង្គ្រោះដោយខន្ធ ៥ អាយតនៈ ៧ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ៥ ធាតុ ១០ ទេ ។

[ ៨២ ] ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌មិនសៅហ្មង ទាំងមិន

គួរដល់នូវសេចក្តីសៅហ្មង វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៨៣ ] ពួកធម៌មិនសៅហ្មង តែគួរដល់នូវសេចក្តីសៅហ្មង សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៨៤ ] ពួកធម៌ប្រកបដោយវិតក្ក និងប្រកបដោយវិចារ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៨៥ ] ពួកធម៌មិនមានវិតក្ក មានត្រឹមតែវិចារ និងពួកធម៌ប្រកបដោយបីតិ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៨៦ ] ពួកធម៌មិនមានវិតក្ក មិនមានវិចារ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ៨៧ ] ពួកធម៌ប្រកបដោយសុខ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២

ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៥ ។

[ ៨៨ ] ពួកធម៌ប្រកបដោយឧបេក្ខា សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១១ ។

[ ៨៩ ] ពួកធម៌គួរលះដោយទស្សនៈ ពួកធម៌គួរលះដោយភាវនា ពួកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ដល់នូវការសន្សំកពូនឡើង ពួកធម៌ដល់នូវការមិនសន្សំកពូនឡើង ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ដល់នូវសភាពធំ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៩០ ] ពួកធម៌មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ពួកធម៌មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៩១ ] ពួកធម៌មានសភាពតូចឆ្មារ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៩២ ] ពួកធម៌មិនមានប្រមាណ និងពួកធម៌ដ៏ឧត្តម វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៩៣ ] ពួកធម៌មានអារម្មណ៍តូចឆ្មារ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៩៤ ] ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍មិនមានប្រមាណ ពួកធម៌ថោកទាប ពួកធម៌មានសភាពខុស និងទៀង ពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គជាអធិបតី សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៩៥ ] ពួកធម៌ជាកណ្តាល សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធ

ណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៩៦ ] ពួកធម៌មិនទៀង វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៩៧ ] ពួកធម៌ដែលកើតឡើងហើយ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៩៨ ] ពួកធម៌ដែលមិនទាន់កើតឡើង សង្គ្រោះដោយខន្ធ ៥ អាយតនៈ ៧ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ៥ ធាតុ ១០ ទេ ។

[ ៩៩ ] ពួកធម៌ដែលប្រុងនឹងកើតឡើង សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ទេ ។

[ ១០០ ] ពួកធម៌ជាអតីត ពួកធម៌ជាអនាគត ពួកធម៌ជាបច្ចុប្បន្ន ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ទាំងខាងក្នុងទាំងខាងក្រៅ សង្គ្រោះ

ដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១០១ ] ពួកធម៌ខាងក្រៅ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១០២ ] ពួកធម៌មានអារម្មណ៍ជាអតីត និងពួកធម៌មានអារម្មណ៍ជាអនាគត សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១០៣ ] ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌មានអារម្មណ៍ខាងក្នុង និងខាងក្រៅ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ១០៤ ] ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១០៥ ] ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះ

ពាល់ សង្គ្រោះដោយខន្ធ ១ អាយតនៈ ៩ ធាតុ ៩ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ៣ ធាតុ ៩ ។

[ ១០៦ ] ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១០ ធាតុ ១០ ទេ ។

[ ១០៧ ] ពួកធម៌ជាហេតុ ពួកធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ជាហេតុ ទាំងប្រកបដោយហេតុ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១០៨ ] ពួកធម៌មិនមែនហេតុ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ប្រាសចាកហេតុ ពួកធម៌មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១០៩ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ប្រកបដោយហេតុ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌គ្រាន់តែ

ប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១១០ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ពួកធម៌ជាសង្ខតៈ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១១១ ] ពួកធម៌មិនមានបច្ច័យ ពួកធម៌ជាអសង្ខតៈ មិនសង្គ្រោះដោយខន្ធណាមួយឡើយ តែសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។

[ ១១២ ] ពួកធម៌ប្រកបដោយការឃើញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១១៣ ] ពួកធម៌មិនប្រកបដោយការឃើញ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ទេ ។

[ ១១៤ ] ពួកធម៌ប្រកបដោយការប៉ះពាល់ សង្គ្រោះដោយខន្ធ ១

អាយតនៈ ១០ ធាតុ ១០ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១១៥ ] ពួកធម៌មិនប្រកបដោយការប៉ះពាល់ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១០ ធាតុ ១០ ទេ ។

[ ១១៦ ] ពួកធម៌មានរូប សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ១១៧ ] ពួកធម៌មិនមានរូប វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ១១៨ ] ពួកធម៌ជាលោកិយ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១១៩ ] ពួកធម៌ជាលោកុត្តរ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១២០ ] ពួកធម៌ដែលគប្បីដឹងដោយវិញ្ញាណណានីមួយ ពួកធម៌ដែលមិនគប្បីដឹងដោយវិញ្ញាណណានីមួយ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១២១ ] ពួកធម៌ជាអាសវៈ ពួកធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ទេ ។

[ ១២២ ] ពួកធម៌មិនមែនអាសវៈ ពួកធម៌ប្រាសចាកអាសវៈ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១២៣ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណា

មួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ១២៤ ] ពួកធម៌មិនមែនអាសវៈ ពួកធម៌ប្រាសចាកអាសវៈ ទាំងមិនមែនជាអាសវៈ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១២៥ ] ពួកធម៌ប្រកបដោយអាសវៈ ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១២៦ ] ពួកធម៌ជាសញ្ញោជនៈ ពួកធម៌ជាគន្ថៈ ពួកធម៌ជាឱឃៈ ពួកធម៌ជាយោគៈ ពួកធម៌ជានីវរណៈ ពួកធម៌ជាបរាមាស ពួកធម៌ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលផង សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១២៧ ] ពួកធម៌មិនមែនបរាមាស ពួកធម៌ប្រាសចាកបរាមាស វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ

មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១២៨ ] ពួកធម៌ដែលបរាមាសស្ទាបអង្អែល ពួកធម៌ដែលគ្រាន់តែបរាមាសស្ទាបអង្អែល តែមិនមែនជាបរាមាស ពួកធម៌ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែល សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១២៩ ] ពួកធម៌ដែលបរាមាស មិនស្ទាបអង្អែល ពួកធម៌ប្រាសចាកបរាមាស ពួកធម៌ដែលបរាមាសមិនស្ទាបអង្អែល វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៣០ ] ពួកធម៌ប្រកបដោយបរាមាស សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៣១ ] ពួកធម៌ប្រកបដោយអារម្មណ៍ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ១៣២ ] ពួកធម៌មិនមានអារម្មណ៍ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ

ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ១៣៣ ] ពួកធម៌ គឺចិត្ត សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ១៣៤ ] ពួកធម៌មិនមែនចិត្ត វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ១៣៥ ] ពួកធម៌ គឺចេតសិក ពួកធម៌ប្រកបដោយចិត្ត ពួកធម៌ប្រឡំដោយចិត្ត សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៣៦ ] ពួកធម៌មិនមែនចេតសិក វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ តែមិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៣៧ ] ពួកធម៌ប្រាសចាកចិត្ត ពួកធម៌មិនប្រឡំដោយចិត្ត វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ

១១ ធាតុ ១១ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ១៣៨ ] ពួកធម៌មានចិត្តជាសមុដ្ឋាន សង្រ្គោះដោយខន្ធ ៤ អាយតនៈ ៦ ធាតុ ៦ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ១ អាយតនៈ ៦ ធាតុ ១២ ។

[ ១៣៩ ] ពួកធម៌មិនមែនតាំងឡើងដោយចិត្ត ពួកធម៌មិនកើតជាមួយនឹងចិត្ត ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្រ្គោះដោយខន្ធ ២ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ៣ តែមិនមែនមិនសង្រ្គោះដោយអាយតនៈណាមួយ មិនមែនមិនសង្រ្គោះដោយធាតុណាមួយឡើយ ។

[ ១៤០ ] ពួកធម៌កើតជាមួយនឹងចិត្ត ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងចិត្ត សង្រ្គោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ១ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៤១ ] ពួកធម៌ដែលប្រឡំ ទាំងតាំងឡើងដោយចិត្ត ពួកធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត សង្រ្គោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៤២ ] ពួកធម៌ដែលមិនប្រឡំ ទាំងមិនតាំងឡើងដោយចិត្ត ពួកធម៌

ដែលមិនប្រទូ្យំ ទាំងមិនតាំងឡើង ទាំងមិនកើតជាមួយនឹងចិត្ត ពួកធម៌ដែលប្រទូ្យំ ទាំងមិនតាំងឡើង ទាំងមិនប្រព្រឹត្តទៅតាមចិត្ត វៀរលែងព្រះនិព្វានជាអសង្ខត: ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ២ អាយតន: ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ តែមិនមែនមិនសង្គ្រោះ ដោយអាយតន:ណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ១៤៣ ] ពួកធម៌ខាងក្នុង សង្គ្រោះដោយខន្ធ ២ អាយតន: ៦ ធាតុ ១២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៣ អាយតន: ៦ ធាតុ ៦ ។

[ ១៤៤ ] ពួកធម៌ខាងក្រៅ វៀរលែងព្រះនិព្វានជាអសង្ខត: ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតន: ៦ ធាតុ ៦ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតន: ៦ ធាតុ ១២ ។

[ ១៤៥ ] ពួកធម៌ដែលប្រកាន់មាំ សង្គ្រោះដោយខន្ធ ១ អាយតន: ១០ ធាតុ ១០ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតន: ២ ធាតុ ៨ ។

[ ១៤៦ ] ពួកធម៌ដែលមិនប្រកាន់មាំ វៀរលែងព្រះនិព្វានជាអសង្ខត: ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតន: ៣ ធាតុ ៩ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះ ដោយអាយតន: ៩ ធាតុ ៩ ទេ ។

[ ១៤៧ ] ពួកធម៌ដែលកម្មក្កិលេស មានតណ្ហាជាដើមកាន់យក សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១១ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ទេ ។

[ ១៤៨ ] ពួកធម៌ដែលកម្មក្កិលេស មានតណ្ហាជាដើម មិនកាន់យក វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ៧ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយឡើយ តែមិនសង្គ្រោះដោយអាយតនៈ ៥ ធាតុ ១០ ទេ ។

[ ១៤៩ ] ពួកធម៌ដែលប្រកាន់មាំ ពួកធម៌ជាកិលេស ពួកធម៌ជាកិលេសទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ជាកិលេស ទាំងជាសភាវៈសៅហ្មងហើយ ពួកធម៌ជាកិលេស ទាំងប្រកបដោយកិលេស សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៥០ ] ពួកធម៌មិនមែនកិលេស ពួកធម៌មិនសៅហ្មងហើយ ពួកធម៌ប្រាសចាកកិលេស វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៥១ ] ពួកធម៌គួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌គ្រាន់តែគួរដល់នូវសេចក្ដីសៅហ្មង តែមិនមែនកិលេស ពួកធម៌ប្រាសចាកកិលេស តែគួរដល់នូវសេចក្ដីសៅហ្មង សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ១៥២ ] ពួកធម៌មិនគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ប្រាសចាកកិលេស ពួកធម៌មិនគួរដល់នូវសេចក្ដីសៅហ្មង វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៥៣ ] ពួកធម៌ដែលសៅហ្មងហើយ ពួកធម៌ប្រកបដោយកិលេស ពួកធម៌ដែលសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ដែលគ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ ដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៥៤ ] ពួកធម៌ គួរលះដោយទស្សនៈ ( ការឃើញនូវព្រះនិព្វានជាដំបូង គឺសោតាបត្តិមគ្គ ) ពួកធម៌គួរលះដោយភាវនា គឺមគ្គ ៣ ខាងលើ ពួកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌មានហេតុគួរលះដោយភាវនា

សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៥៥ ] ពួកធម៌មិនគួរលះដោយទស្សនៈ ពួកធម៌មិនគួរលះដោយភាវនា ពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ ពួកធម៌មានហេតុមិនគួរលះដោយភាវនា វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៥៦ ] ពួកធម៌ប្រកបដោយវិតក្កៈ ពួកធម៌ប្រកបដោយវិចារ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ១៥៧ ] ពួកធម៌មិនមានវិតក្កៈ ពួកធម៌មិនមានវិចារ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ១៥៨ ] ពួកធម៌ប្រកបដោយបីតិ ពួកធម៌ប្រទាំដោយបីតិ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៥៩ ] ពួកធម៌មិនមានបីតិ ពួកធម៌មិនប្រកបដោយបីតិ ពួកធម៌មិនប្រកបដោយសុខ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្រ្គោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្រ្គោះដោយខន្ធណាមួយ មិនមែនមិនសង្រ្គោះដោយអាយតនៈណាមួយ មិនមែនមិនសង្រ្គោះដោយធាតុណាមួយឡើយ ។

[ ១៦០ ] ពួកធម៌ប្រកបដោយសុខ សង្រ្គោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៣ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៥ ។

[ ១៦១ ] ពួកធម៌ប្រកបដោយឧបេក្ខា សង្រ្គោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៧ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនសង្រ្គោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១១ ។

[ ១៦២ ] ពួកធម៌មិនប្រកបដោយឧបេក្ខា វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្រ្គោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្រ្គោះដោយខន្ធណាមួយ មិនមែនមិនសង្រ្គោះដោយអាយតនៈណាមួយឡើយ តែមិនសង្រ្គោះដោយធាតុ ៥ទេ ។

[ ១៦៣ ] ពួកធម៌ជាកាមាវចរ ពួកធម៌ជាបរិយាបន្ន ( រាប់បញ្ចូលក្នុងវដ្តៈ ) ពួកធម៌ជាសឧត្តរៈ ( ប្រកបដោយការវិវដ្ដខ្ពស់ឡើង ) សង្រ្គោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្រ្គោះដោយធម៌ប៉ុន្មាន ។

មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ១៦៤ ] ពួកធម៌មិនមែនកាមាវចរ ពួកធម៌ជាអបរិយាបន្ន ( មិនរាប់បញ្ចូលក្នុងវដ្តៈ ) ពួកធម៌ជាអនុត្តរៈ ( មិនប្រកបដោយការរើខ្លួនឡើង ) វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៦៥ ] ពួកធម៌ជារូបាវចរ ពួកធម៌ជាអរូបាវចរ ពួកធម៌ជាគ្រឿងចេញចាកវដ្តៈ ពួកធម៌ទៀង ពួកធម៌ដែលប្រកបដោយសត្រូវ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៦៦ ] ពួកធម៌មិនមែនរូបាវចរ ពួកធម៌មិនមែនជាអរូបាវចរ ពួកធម៌មិនមែនជាគ្រឿងចេញចាកវដ្តៈ ពួកធម៌មិនទៀង ពួកធម៌មិនមែនជាសត្រូវ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌មិនមែនជាសត្រូវ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

**សង្គហាសង្គហបទនិទ្ទេស ចប់**

# អដ្ឋកថា

## តិកបទ

[ ៧៣-១៦៦ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងសង្គហាសង្គហបទ ក្នុងអព្ភន្តរមាតិកាយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងធម៌ដែលសង្គ្រោះចូលគ្នាបានក្នុងពាហិរមាតិកា ទើបទ្រង់ផ្តើមបទថា **កុសលា ធម្មា** ជាដើម ។

បណ្តាមាតិកាទាំងនោះ ក្នុងវេទនាតិកៈ បទថា **តីហិ ធាតូហិ** បានដល់ជាមួយកាយវិញ្ញាណធាតុ មនោវិញ្ញាណធាតុ និងធម្មធាតុ ។ បទថា **សត្តហិ ធាតូហិ** បានដល់ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ និងមនោវិញ្ញាណធាតុ ។ ក្នុងវិបាកត្តិកៈ បទថា **អដ្ឋហិ ធាតូហិ** បានដល់ ធាតុទាំង ៧ នោះឯង មួយអន្លើដោយកាយវិញ្ញាណធាតុ ១ តែវិបាកធម្មធម្មាកាន់យករួមគ្នា ព្រោះពាក្យវិសជ្ជនាដូចគ្នានឹងសង្កិលិដ្ឋសង្កិលេសិកទាំងឡាយ ។ ឯនិទ្ទេសទាំងនោះ សម្តែងទុកយ៉ាងណា ក្នុងបទតិកៈ និងទុកៈទាំងពួងក៏យ៉ាងនោះ គឺបទណាមួយជាពាក្យវិសជ្ជនារួមជាមួយបទណាមួយ បទនោះៗ សូម្បីមិនប្រព្រឹត្តទៅតាមលំដាប់លោកក៏វិសជ្ជនា ដោយកាន់យករួមជាមួយបទនោះៗ ។ សង្គហាសង្គហន័យក្នុងទីនេះ គប្បីជ្រាបដោយទំនងដែលខ្ញុំពោលហើយនោះឯង ៕៚

**អដ្ឋកថាសង្គហាសង្គហបទ ចប់**

# អភិធម្មបិដក

## សង្គហិតេន អសង្គហិតបទនិទ្ទេស

[ ១៦៧ ] ពួកធម៌ណា សង្គ្រោះដោយចក្ខាយតនៈ ។បេ។ ពួកធម៌ណា សង្គ្រោះដោយផោដ្ឋព្វាយតនៈ ពួកធម៌ណា សង្គ្រោះដោយចក្ខុធាតុ ។បេ។ ពួកធម៌ណា សង្គ្រោះដោយផោដ្ឋព្វធាតុ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះមិនសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះមិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៦៨ ] ពួកធម៌ណា សង្គ្រោះដោយចក្ខុវិញ្ញាណធាតុ ពួកធម៌ណា សង្គ្រោះដោយសោតវិញ្ញាណធាតុ ពួកធម៌ណាសង្គ្រោះដោយឃានវិញ្ញាណ-ធាតុ ពួកធម៌ណាសង្គ្រោះដោយជិវ្ហាវិញ្ញាណធាតុ ពួកធម៌ណាសង្គ្រោះដោយកាយវិញ្ញាណធាតុ ពួកធម៌ណាសង្គ្រោះដោយមនោធាតុ ពួកធម៌ណាសង្គ្រោះដោយមនោវិញ្ញាណធាតុ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះមិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១២ ។

[ ១៦៩ ] ពួកធម៌ណាសង្គ្រោះដោយចក្ខុន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយសោតិន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយឃានិន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយជិវ្ហិន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយកាយិន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណាសង្គ្រោះដោយបុរិសិន្ទ្រិយ ដោយខន្ធសង្គហៈ

មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះមិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៧០ ] ពួកធម៌ណា សង្គ្រោះដោយអសញ្ញាភព ពួកធម៌ណា សង្គ្រោះដោយភពមានខន្ធ ១ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះមិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ៣ ធាតុ ៩ ។

[ ១៧១ ] ពួកធម៌ណា សង្គ្រោះដោយសេចក្ដីវិក្ខម្ភ ពួកធម៌ណា សង្គ្រោះដោយពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៧២ ] ពួកធម៌ណា សង្គ្រោះដោយពួកធម៌ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១០ ធាតុ ១៦ ។

[ ១៧៣ ] ពួកធម៌ណា សង្គ្រោះដោយពួកធម៌ ប្រកបដោយការឃើញ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៧៤ ] ពួកធម៌ណា សង្គ្រោះដោយពួកធម៌ ប្រកបដោយការប៉ះពាល់ ពួកធម៌ណា សង្គ្រោះដោយពួកឧបាទាធម៌ ដោយខន្ធសង្គហៈ មិនសង្គ្រោះ

ដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌ទាំងនោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

អាយតនៈ ១០ ធាតុ ១៧ ឥន្ទ្រិយ ៧ អសញ្ញាភព ឯកវោការភព សេចក្តីខ្សឹកខ្សួល ធម្មជាតប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ និងធម្មជាតមិនប្រកបដោយការឃើញ ឈ្មោះថា សប្បដិឃធម៌ ឈ្មោះថា ឧបាទាធម៌ទៀតផង ។

## សង្គហិតេន អសង្គហិតបទនិទ្ទេស ចប់

# អដ្ឋកថា

## សង្គហិតេនអសង្គហិតបទ

[ ១៦៧ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលសង្គ្រោះចូលគ្នាមិនបាន និងធម៌ដែលសង្គ្រោះចូលគ្នាបាន ទើបព្រះមានព្រះភាគទ្រង់ផ្តើមពាក្យថា **ចក្ខាយតនេន** ជាដើម ។ ក្នុងបទនេះ គប្បីជ្រាបលក្ខណៈដូចតទៅនេះ ក្នុងវារៈនេះ បទណា ( សំដៅដល់រូប ២៧ វៀរចក្ខាយតនៈ ) សង្គ្រោះចូលគ្នាបានជាមួយខន្ធបទ តែសង្គ្រោះចូលគ្នាមិនបាន ជាមួយអាយតនបទ និងធាតុបទ ឬបទណា ( វិញ្ញាណធាតុ ៧ វៀរចក្ខុវិញ្ញាណធាតុ ) សង្គ្រោះចូលគ្នាបានជាមួយខន្ធបទ និងអាយតនបទ តែសង្គ្រោះចូលគ្នាមិនបានជាមួយធាតុបទ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាធម៌ ដែលសង្គ្រោះចូលគ្នាមិនបានជាមួយខន្ធជាដើមនៃពាក្យនោះ ពាក្យនោះរមែងមិនគួរក្នុងធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ព្រោះថា រូបក្ខន្ធសង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធប៉ុណ្ណោះ តែរូបក្ខន្ធនោះ ឈ្មោះថា សង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈ និងធាតុ ១១ ខ្វះកន្លះក៏មិនមាន ចំពោះវេទនាប៉ុណ្ណោះសង្គ្រោះចូលគ្នាបានជាមួយវេទនាខន្ធ សូម្បីវេទនាខន្ធនោះ ឈ្មោះថា សង្គ្រោះចូលគ្នាមិនបានជាមួយធម្មាយតនៈ និងធម្មធាតុទាំងឡាយ ក៏មិនមាន ព្រោះមិនមានធម៌ដែលសង្គ្រោះចូលគ្នាមិនបានយ៉ាងនេះ ពាក្យទាំងឡាយដទៃនោះ និងបទមានមនាយតនៈ ធម្មាយតនៈជាដើម ដែលមានសភាពយ៉ាងនេះ ក៏ព្រះមានព្រះភាគ ទ្រង់មិនសង្គ្រោះទុកក្នុងវារៈនេះ តែពាក្យទាំងឡាយណា ធ្វុះ

បញ្ចាំង ដល់ឯកទេសនៃរូប ដែលមិនលាយឡំដោយរូប និងឯកទេសនៃវិញ្ញាណ ដែលមិនលាយឡំដោយធម៌ដទៃ បទទាំងនោះ ព្រះមានព្រះភាគទ្រង់សង្គ្រោះ ក្នុងនិទ្ទេសនៃបទនេះ ។ ក្នុងទីបំផុត ទ្រង់សម្តែងធម៌ទាំងនោះសង្គ្រោះជាគាថាយ៉ាងនេះថា

និទ្ទេសនេះ មាន ៤២ បទ គឺអាយតនៈ ១០ ធាតុ ១៧ ( វៀរធម្មធាតុ ) រូបឥន្ទ្រិយ ៧ ( ចក្ខុន្ទ្រិយជាដើម រហូតដល់បុរិសិន្ទ្រិយជាទីបំផុត ) អសញ្ញាភព ១ ឯកវោការភព ១ បរិទេវៈ ១ សនិទស្សនសប្បដិឃធម៌ ១ អនិទស្សនសប្បដិឃធម៌ ១ សនិទស្សនធម៌ ១ សប្បដិឃធម៌ ១ ឧបាទាធម៌ ១ ដូច្នេះ ។

ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបធម៌ដែលសង្គ្រោះចូលគ្នាបាន និងធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ដោយអំណាចនៃបទទាំងនោះឯង ។ បើពោលដោយអំណាចនៃបញ្ហាក្នុងវារៈនេះ ទ្រង់ធ្វើ ៨ បញ្ហា គឺបញ្ហា ១ ទ្រង់ធ្វើព្រោះសង្គ្រោះធម៌ ២០ ដែលមានវិសជ្ជនាទំនងដូចគ្នា ដោយអំណាចនៃអាយតនៈ និងធាតុ ។ បញ្ហា ១ ទ្រង់ធ្វើ ព្រោះរួបរួមវិញ្ញាណធាតុ ៧ ។ បញ្ហា ១ ទ្រង់ធ្វើ ព្រោះរួបរួមឥន្ទ្រិយ ៧ បញ្ហា ១ ទ្រង់ធ្វើ ព្រោះរួមភព ២ បញ្ហា ១ ទ្រង់ធ្វើ ដោយបរិទេវធម៌ និងសនិទស្សនសប្បដិឃធម៌ ។ បញ្ហា ១ ទ្រង់ធ្វើ ដោយអនិទស្សនសប្បដិឃធម៌ ។ បញ្ហា ១ ទ្រង់ធ្វើ ដោយសនិទស្សនធម៌ ។ បញ្ហា ១ ទ្រង់ធ្វើ ដោយសប្បដិឃធម៌ និង

*ឧបាទាធម៌ ។*

*បណ្ដាបញ្ហាទាំងនោះ គប្បីជ្រាបការចែកខន្ធជាដើមយ៉ាងនេះ គឺក្នុងបញ្ហាទី ១ មុន ។ បទថា* **ចតូហិ ខន្ធេហិ** *បានដល់ អរូបក្ខន្ធ ។ បទថា* **ទ្វីហាយតនេហិ** *បានដល់ មនាយតនៈ ១ និងបណ្ដាចក្ខាយតនៈជាដើមណាមួយ ១ ។ បទថា* **អដ្ឋហិ ធាតូហិ** *បានដល់ វិញ្ញាណធាតុ ៧ និងបណ្ដាចក្ខុធាតុជាដើមណាមួយ ១ ។ ក្នុងនិទ្ទេសនេះ គប្បីជ្រាបន័យដូច្នេះថា រូបក្ខន្ធសង្គ្រោះចូលគ្នាបានជាមួយចក្ខាយតនៈ ដោយខន្ធសង្គហៈ ក្នុងរូបក្ខន្ធដែលសង្គ្រោះចូលគ្នាបាននោះ ចក្ខាយតនៈ ១ ប៉ុណ្ណោះ សង្គ្រោះចូលគ្នាបានដោយអាយតនសង្គហៈ ឯអាយតនៈ ១០ ដ៏សេស សង្គ្រោះចូលគ្នាមិនបាន ។ ដោយធាតុសង្គហៈ ចក្ខុធាតុ ១ ប៉ុណ្ណោះ សង្គ្រោះចូលគ្នាបានជាមួយចក្ខាយតនៈនោះ ធាតុ ១០ ដ៏សេស សង្គ្រោះចូលគ្នាមិនបាន ព្រោះហេតុនេះ អាយតនៈ ១០ ពួកណា ដែលសង្គ្រោះចូលគ្នាមិនបាន ជាមួយចក្ខាយតនៈនោះ អាយតនៈទាំងនោះ សង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈ ២ គឺចក្ខាយតនៈ និងមនាយតនៈ ។ ធាតុ ១០ ពួកណាដែលសង្គ្រោះចូលគ្នាមិនបានជាមួយចក្ខាយតនៈនោះ ក៏សង្គ្រោះចូលគ្នាមិនបានជាមួយចក្ខុធាតុ និងវិញ្ញាណធាតុ ៧ ។ សូម្បីក្នុងរូបាយតនៈជាដើមក៏មានន័យនេះឯង ។*

*ក្នុងបញ្ហាទី ២ ព្រោះវិញ្ញាណក្ខន្ធ ដែលសង្គ្រោះចូលគ្នាបានជាមួយវិញ្ញាណធាតុណាមួយ ឈ្មោះថា សង្គ្រោះចូលគ្នាមិនបានជាមួយមនាយតនៈមិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **អាយតនសង្គ-**

**ហោន សង្គហិតា** *សង្គ្រោះដោយអាយតនសង្គហៈ ដូច្នេះ ។ ក្នុងកាលវិសជ្ជនាបញ្ហាទី ២ នេះ បទថា* **ចតូហិ ខន្ធេហិ** *បានដល់ ជាមួយខន្ធ ៤ មានរូបជាដើម ។ បទថា* **ឯកាទសហាយតនេហិ** *បានដល់ វៀរមនាយតនៈ ។ បទថា* **ទ្វាទសហិ ធាតូហិ** *បានដល់ ធាតុ ១២ ដ៏សេសដោយនាំវិញ្ញាណធាតុ ៦ ចេញតាមសមគួរ ព្រោះថា ចក្ខុវិញ្ញាណធាតុ សង្គ្រោះចូលគ្នាបានជាមួយចក្ខុវិញ្ញាណធាតុនោះឯង ធាតុក្រៅអំពីនេះ សង្គ្រោះចូលគ្នាមិនបាន ។ សូម្បីក្នុងសោតវិញ្ញាណធាតុជាដើម ក៏មានន័យនេះដូចគ្នា ។*

*ក្នុងបញ្ហាទី ៣ ការវិសជ្ជនាចក្ខុន្ទ្រិយជាដើម ដូចគ្នានឹងចក្ខាយតនៈជាដើមនោះឯង តែក្នុងឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ គប្បីជ្រាបអាយតនៈ ២ គឺមនាយតនៈ និងធម្មាយតនៈ មួយអន្លើដោយធាតុ ៨ គឺវិញ្ញាណធាតុ ៧ និងធម្មធាតុ ១ ។*

*ក្នុងបញ្ហាទី ៤ បទថា* **តីហាយតនេហិ** *បានដល់ រូបាយតនៈ ធម្មាយតនៈ មនាយតនៈ ព្រោះថា ក្នុងភពទាំងនោះ អាយតនៈ ២ គឺរូបាយតនៈ និងធម្មាយតនៈ សង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈទាំង ៣ នោះឯង ។ រូបាយតនៈ ៩ ដ៏សេស ឈ្មោះថា សង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈ ៣ គឺអាយតនៈទាំង ២ នោះឯង និងមនាយតនៈ ។ បទថា* **នវហិ ធាតូហិ** *បានដល់ វិញ្ញាណធាតុ ៧ រូបធាតុ និងធម្មធាតុ ។*

*ក្នុងបញ្ហាទី ៥ បទថា* **ទ្វីហាយតនេហិ** *សំដៅយកបទទី ១ ( បរិទេវធម៌ ) ដែលសង្គ្រោះចូលគ្នាមិនបានជាមួយសទ្ទាយតនៈ និងមនាយតនៈ ។*

សាំដោយកបទទី ២ ( សនិទស្សនសប្បដិឃធម៌ ) ដែលសង្គ្រោះចូលគ្នាមិនបាន ជាមួយរូបាយតនៈ និងមនាយតនៈ ។ សូម្បីធាតុទាំងឡាយ ក៏គប្បីជ្រាបថា បានដល់ វិញ្ញាណធាតុ ៧ និងអាយតនៈណាមួយ ១ បណ្តាអាយតនៈទាំងនោះឯង ។

ក្នុងបញ្ហាទី ៦ បទថា **ទសហាយតនេហិ** បានដល់ អាយតនៈ ១០ វៀររូបាយតនៈ និងធម្មាយតនៈ ។ បទថា **សោឡសហិ ធាតូហិ** បានដល់ធាតុ ១៦ វៀររូបធាតុ និងធម្មធាតុ ។

សួរថា សេចក្តីនេះ មានអធិប្បាយដូចម្តេច ឆ្លើយថា ព្រោះឱឡារិកាយតនៈ ៩ ឈ្មោះថា អនិទស្សនសប្បដិឃធម៌ ។ ក្នុងរូបក្ខន្ធ ដែលសង្គ្រោះចូលគ្នាបានជាមួយអាយតនៈទាំងនោះ ដោយខន្ធសង្គហៈ អាយតនៈទាំងនោះឯង ក៏សង្គ្រោះចូលគ្នាបាន តែរូបាយតនៈ និងធម្មាយតនៈ សង្គ្រោះចូលគ្នាមិនបានដោយអាយតនសង្គហៈ ។ ពោលដោយធាតុសង្គហៈ ឱឡារិកធាតុទាំង ៩ នោះឯង សង្គ្រោះចូលគ្នាបាន តែរូបធាតុ និងធម្មធាតុ សង្គ្រោះចូលគ្នាមិនបាន ដោយហេតុនេះ អាយតនៈ ២ ណា ដែលសង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈទាំងនោះ អាយតនៈទាំងនោះគប្បីជ្រាបថា សង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈ ១០ គឺឱឡារិកាយតនៈ ៩ និងមនាយតនៈ ១ វៀររូបាយតនៈ និងធម្មាយតនៈ ។ ធាតុ ២ ពួកណាដែលសង្គ្រោះចូលគ្នាមិនបានជាមួយអាយតនៈទាំងនោះ ធាតុទាំងនោះ គប្បីជ្រាបថា សង្គ្រោះចូលគ្នាមិនបានជាមួយធាតុ ១៦ គឺឱឡារិកធាតុ ៩ និងវិញ្ញាណធាតុ ៧ វៀរ

រូបធាតុ និងធម្មធាតុ ។

ក្នុងបញ្ហាទី ៧ បទថា **ទ្វីហាយតនេហិ** បានដល់ រូបាយតនៈ និង មនាយតនៈ ។ បទថា **អដ្ឋហិ ធាតូហិ** បានដល់ រូបធាតុ និងវិញ្ញាណធាតុ ៧ ។

ក្នុងបញ្ហាទី ៨ បទថា **ឯកាទសហាយតនេហិ** ( បើ ) សំដៅដល់ សប្បដិឃធម៌ទាំងឡាយ បានដល់ អាយតនៈទាំងឡាយ វៀរធម្មាយតនៈ ( បើ ) សំដៅដល់ ឧបាទាធម៌ទាំងឡាយ បានដល់ អាយតនៈទាំងឡាយ វៀរផោដ្ឋព្វាយតនៈ សូម្បីក្នុងធាតុទាំងឡាយ ក៏មានន័យនេះឯង ។ ការប្រកបអត្ថក្នុងនិទ្ទេសនៃបទនេះ បណ្ឌិតគប្បីជ្រាបដោយន័យ ដែលខ្ញុំបានពោលហើយខាងដើមនោះឯង ។៚

## អដ្ឋកថាសង្គហិតេនអសង្គហិតបទ ចប់

# អភិធម្មបិដក

## អសង្គហិតេន សង្គហិតបទនិទ្ទេស

[ ១៧៥ ] ពួកធម៌ណា មិនសង្គ្រោះដោយវេទនាខន្ធ ពួកធម៌ណាមិនសង្គ្រោះដោយសញ្ញាខន្ធ ពួកធម៌ណាមិនសង្គ្រោះដោយសង្ខារក្ខន្ធ ពួកធម៌ណាមិនសង្គ្រោះដោយសមុទយសច្ច ពួកធម៌ណាមិនសង្គ្រោះដោយមគ្គសច្ច ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ធម៌ទាំងនោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ១៧៦ ] ពួកធម៌ណា មិនសង្គ្រោះដោយនិរោធសច្ច ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ១ ។

[ ១៧៧ ] ពួកធម៌ណា មិនសង្គ្រោះដោយជីវិតិន្ទ្រិយ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ។

[ ១៧៨ ] ពួកធម៌ណា មិនសង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយបុរិសិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសុខិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយទុក្ខិន្ទ្រិយ ពួកធម៌ណាមិនសង្គ្រោះដោយសោមនស្សិន្ទ្រិយ ពួកធម៌ណាមិនសង្គ្រោះដោយទោមនស្សិន្ទ្រិយ ពួកធម៌ណាមិន

សង្គ្រោះដោយឧបេក្ខិន្ទ្រិយ ពួកធម៌ណាមិនសង្គ្រោះដោយសទ្ធិន្ទ្រិយ ពួកធម៌ណាមិនសង្គ្រោះដោយវីរិយិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសតិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសមាធិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយបញ្ញិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអញ្ញិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអវិជ្ជា ពួកធម៌ណា មិនសង្គ្រោះដោយសង្ខារ ព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយវេទនា ព្រោះផស្សៈជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយឧបាទាន ព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយកម្មភព ព្រោះឧបាទានជាបច្ច័យ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ទាំងនោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ១៧៩ ] ពួកធម៌ណា មិនសង្គ្រោះដោយជាតិ ពួកធម៌ណា មិនសង្គ្រោះដោយជរា ពួកធម៌ណា មិនសង្គ្រោះដោយមរណៈ ពួកធម៌ណា មិនសង្គ្រោះដោយឈាន ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ។

[ ១៨០ ] ពួកធម៌ណា មិនសង្គ្រោះដោយសេចក្ដីសោក ពួកធម៌ណា មិនសង្គ្រោះដោយទុក្ខ ពួកធម៌ណា មិនសង្គ្រោះដោយទោមនស្ស ពួកធម៌ណា មិនសង្គ្រោះដោយឧបាយាស ( សេចក្ដីតានតឹងចិត្ត ) ពួកធម៌ណា មិនសង្គ្រោះដោយសតិប្បដ្ឋាន ពួកធម៌ណា មិនសង្គ្រោះដោយសម្មប្បធាន ពួកធម៌ណា មិនសង្គ្រោះដោយអប្បមញ្ញា ពួកធម៌ណា មិនសង្គ្រោះដោយឥន្ទ្រិយ ៥ ពួកធម៌ណា មិនសង្គ្រោះដោយពល ៥ ពួកធម៌ណា មិនសង្គ្រោះដោយពោជ្ឈង្គ ៧ ពួកធម៌ណា មិនសង្គ្រោះដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា មិនសង្គ្រោះដោយផស្សៈ ពួកធម៌ណា មិនសង្គ្រោះដោយវេទនា ពួកធម៌ណា មិនសង្គ្រោះដោយសញ្ញា ពួកធម៌ណា មិនសង្គ្រោះដោយចេតនា ពួកធម៌ណា មិនសង្គ្រោះដោយអធិមោក្ខ ( ការជឿស៊ប់ ) ពួកធម៌ណា មិនសង្គ្រោះដោយមនសិការ ( ការធ្វើទុកក្នុងចិត្ត ) ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ១៨១ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមានបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមានបច្ច័យតាក់តែង ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ សង្គ្រោះ

ដោយខន្ធ ៤ អាយតនៈ ១ ធាតុ ១ ។

[ ១៨២ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ១៨៣ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាសញ្ញោជនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាគន្ថៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាឱឃៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាយោគៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជានីវរណៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាបរាមាស ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាបរាមាស ទាំងជាធម្មជាតដែលបរាមាស ស្ទាបអង្អែលហើយ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ១៨៤ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាចេតសិក ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រឡំដោយចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណាមិនសង្គ្រោះដោយធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងកើត

ជាមួយនឹងចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ វៀរលែងព្រះនិព្វាន ជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។

[ ១៨៥ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលកើតជាមួយនឹងចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រព្រឹត្តទៅតាមចិត្ត ដោយខន្ធសង្គហៈ តែសង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធណានីមួយ តែសង្គ្រោះដោយអាយតនៈ ១ ធាតុ ១ ។

[ ១៨៦ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាកិលេស ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាកិលេស ទាំងគួរដល់សេចក្ដីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាកិលេស ទាំងជាធម៌សៅហ្មងហើយ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាកិលេស ទាំងប្រកបដោយកិលេស ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈ ប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពី ខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

**អសង្គហិតេន សង្គហិតបទនិទ្ទេស ចប់**

# អដ្ឋកថា

## អសង្គហិតេនសង្គហិតបទ

[ ១៧៥-១៨៦ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលសង្គ្រោះចូលគ្នាបាន និងធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **វេទនាក្ខន្ធេន** ជាដើម ។ ក្នុងបទនេះ គប្បីជ្រាបលក្ខណៈដូចតទៅនេះ ក្នុងវារៈនេះ ពាក្យណា សង្គ្រោះចូលគ្នាមិនបានជាមួយខន្ធបទ តែសង្គ្រោះចូលគ្នាបានជាមួយអាយតនបទ និងធាតុបទ ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាធម៌ដែលសង្គ្រោះចូលគ្នាបានជាមួយខន្ធជាដើម នៃបទនោះ ៗ ពាក្យនោះរមែងមិនគួរក្នុងធម៌មានរូបក្ខន្ធ វិញ្ញាណក្ខន្ធ និងចក្ខាយតនៈជាដើម ព្រោះថានាមក្ខន្ធ ៤ សង្គ្រោះចូលគ្នាមិនបានជាមួយរូបក្ខន្ធ ដោយខន្ធសង្គហៈ ។ ក្នុងនាមក្ខន្ធទាំងនោះ ធម៌ ១ ឈ្មោះថា សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធនោះដោយអាយតនសង្គហៈ និងធាតុសង្គហៈ រមែងមិនមាន ។ សួរថា វេទនាជាដើម សង្គ្រោះចូលគ្នាបានជាមួយធម្មាយតនៈ មិនមែនឬ ឆ្លើយថា វេទនាជាដើម សង្គ្រោះចូលគ្នាបានជាមួយធម្មាយតនៈពិត តែរូបក្ខន្ធទាំងអស់មិនជាធម្មាយតនៈ ព្រោះត្រឹមតែសុខុមរូប អំពីរូបក្ខន្ធ រាប់បញ្ចូលក្នុងធម្មាយតនៈព្រោះហេតុនោះ ធម៌ទាំងឡាយណា សង្គ្រោះចូលគ្នាបានជាមួយធម្មាយតនៈធម៌ទាំងឡាយនោះ មិនឈ្មោះថា សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ ។ ខន្ធ ៤ ក្រៅអំពីនេះ ក៏សង្គ្រោះចូលគ្នាមិនបាន សូម្បីជាមួយនឹងវិញ្ញាណក្ខន្ធ ។ ក្នុងនាមក្ខន្ធទាំង ៤ នោះ ខន្ធ ១ ឈ្មោះថា សង្គ្រោះចូលគ្នាបានជាមួយ

វិញ្ញាណក្ខន្ធនោះ ដោយអាយតនសង្គហៈ និងធាតុសង្គហៈ មិនមាន ព្រោះមិនមានធម៌ ដែលសង្គ្រោះចូលគ្នាបាន យ៉ាងនេះ បទទាំងនេះ និងបទដទៃមានចក្ខាយតនៈជាដើមបែបនេះ ទើបសង្គ្រោះចូលគ្នាមិនបានក្នុងវារៈនេះ ។ ចំណែកបទទាំងឡាយណា សម្តែងត្រឹមចំណែកមួយនៃធម្មាយតនៈដែលមិនលាយឡំដោយវិញ្ញាណ ឬឱឡារិករូប បទទាំងនោះ ទើបព្រះមានព្រះភាគកាន់យកក្នុងទីនេះ ។ គប្បីជ្រាបការរួបរួមពាក្យទាំងនោះដូចតទៅ

ខន្ធ ៣ ( ចេតសិកក្ខន្ធ ៣ ) សច្ចៈ ៣ ( សមុទយៈ និរោធ និងមគ្គ ) ឥន្ទ្រិយ ១៦ ( វៀរបសាទឥន្ទ្រិយ ៥ និងមនិន្ទ្រិយ ១ ) បច្ចយាការ ១៤ ( បដិច្ចសមុប្បាទ ១៤ វៀរវិញ្ញាណ នាមរូប សឡាយតនៈ ឧបបត្តិភព និងបរិទេវៈ ) បទដែលបន្តអំពីបច្ចយាការ ១៤ បទទៀត ( សតិប្បដ្ឋានជាដើម វៀរឥទ្ធិបាទ ) បទទាំងឡាយ ៣០ ក្នុងគោច្ឆកៈ ១០ ចូឡន្តរទុកៈ ២ ( អបច្ចយបទ និងអសង្ខតបទ ) មហន្តរទុកៈ ៨ រួមជា ៩០ បទ ដូច្នេះ ។

បណ្តាបទទាំងនោះ ព្រះមានព្រះភាគ ត្រាស់បញ្ហាទាំងអស់ ១២ បញ្ហា ដោយរួម ៦ បទ ដែលមានវិសជ្ជនាដូចគ្នា ។ បណ្ឌិតគប្បីជ្រាបការចែកខន្ធក្នុងបទទាំងនោះ យ៉ាងនេះ តែក្នុងអាយតនសង្គហៈ និងធាតុសង្គហៈ មិនមានការផ្សេងគ្នា ។

ក្នុងបញ្ហាទី ១ បទថា **តីហិ ខន្ធេហិ** បានដល់ រូបក្ខន្ធ សញ្ញាខន្ធ

សង្ខារក្ខន្ធ ។ ឯអាយតនៈ និងធាតុ គប្បីជ្រាបដោយអំណាចធម្មាយតនៈ និង ធម្មធាតុ ។ ក្នុងនិទ្ទេសនេះ គប្បីជ្រាបន័យដូច្នេះថា និព្វាន សុខុមរូប សញ្ញា និងសង្ខារ សង្គ្រោះចូលគ្នាមិនបានជាមួយវេទនាខន្ធ ដោយខន្ធសង្គហៈ សង្គ្រោះចូលគ្នាបាន ដោយអាយតនសង្គហៈ ធាតុសង្គហៈ ។ បណ្តាធម៌ទាំង នោះ និព្វាន មិនសង្គ្រោះចូលក្នុងខន្ធ ។ ធម៌ដ៏សេស សង្គ្រោះចូលគ្នាបាន ជាមួយរូបក្ខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ សូម្បីនិព្វានក៏ដល់នូវការសង្គ្រោះ ចូលក្នុងអាយតនៈ និងធាតុនោះឯង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ដូច្នេះ តែក្នុងទីនេះ ក្នុង ចំណែកសញ្ញាខន្ធ ដកសញ្ញាខន្ធចេញហើយ គប្បីជ្រាបថា ជាខន្ធ ៣ មួយ អន្លើដោយវេទនាខន្ធ ក្នុងសង្ខារក្ខន្ធជាដើម ដកសង្ខារក្ខន្ធចេញហើយ គប្បី ជ្រាបថា ជាខន្ធ ៣ ដោយអំណាចរូបក្ខន្ធ វេទនាខន្ធ និងសញ្ញាខន្ធ ។

ក្នុងបញ្ហាទី ២ បទថា **ចតូហិ ខន្ធេហិ** បានដល់ ខន្ធ ៤ វៀរ វិញ្ញាណក្ខន្ធ ។ ដ្បិតថា ធម៌ទាំងនោះ សង្គ្រោះចូលគ្នាមិនបានជាមួយនិរោធ ដោយខន្ធសង្គហៈ តែសង្គ្រោះចូលគ្នាបាន ដោយអាយតនសង្គហៈ និង ធាតុសង្គហៈ ។

ក្នុងបញ្ហាទី ៣ បទថា **ទ្វីហិ** បានដល់ **វេទនាខន្ធ និងសញ្ញាខន្ធ** ។ ព្រោះថា វេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណខន្ធ សង្គ្រោះចូលគ្នាមិនបានជាមួយ រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយ ដោយខន្ធសង្គហៈ តែក្នុងធម៌ទាំងនោះ វេទនា

និងសញ្ញា សង្គ្រោះចូលគ្នាបាន ដោយអាយតនសង្គហៈ និងធាតុសង្គហៈ ។ ដោយហេតុនោះ ទើបខ្ញុំពោលថា **វេទនាខន្ធ និងសញ្ញាខន្ធ** ។ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃខន្ធ ក្នុងទីទាំងពួងដោយឧបាយនេះ ។

ខាងមុខអំពីនេះ ខ្ញុំនឹងពោលត្រឹមតែឈ្មោះរបស់ខន្ធប៉ុណ្ណោះ ។

ក្នុងបញ្ហាទី ៤ បទថា **តីហិ ខន្ធេហិ** បានដល់ ក្នុងឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ សង្គ្រោះចូលគ្នាបានជាមួយខន្ធ ៣ គឺវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ ក្នុងពួក ៥ នៃវេទនា សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ សញ្ញា-ខន្ធ និងសង្ខារក្ខន្ធ ។ ក្នុងសទ្ធិន្ទ្រិយជាដើម មានផស្សៈជាទីបំផុត សង្គ្រោះចូលគ្នាបានជាមួយរូបក្ខន្ធ វេទនាខន្ធ និងសញ្ញាខន្ធ ។ ក្នុងវេទនាមានវិនិច្ឆ័យដូចគ្នានឹងវេទនាខន្ធនោះឯង ។ ក្នុងតណ្ហា ឧបាទាន កម្មភព មានវិនិច្ឆ័យដូចគ្នានឹងសង្ខារក្ខន្ធនោះឯង ។

ក្នុងបញ្ហាទី ៥ ក្នុងជាតិ ជរា មរណៈ មានវិនិច្ឆ័យដូចគ្នានឹងជីវិតិន្ទ្រិយ ។ និព្វាន សុខុមរូប និងសញ្ញា សង្គ្រោះចូលគ្នាមិនបានជាមួយឈាន ដោយខន្ធសង្គហៈ តែសង្គ្រោះចូលគ្នាបានដោយអាយតនសង្គហៈ និងធាតុសង្គហៈ ព្រោះហេតុនោះ សំដៅដល់ពាក្យនោះ គប្បីជ្រាបថា ខន្ធ ២ គឺរូបក្ខន្ធ និងសញ្ញាខន្ធ ។

ក្នុងបញ្ហាទី ៦ ក្នុងធម៌ ៣ មានសោកជាដើម មានវិនិច្ឆ័យដូចគ្នានឹងវេទនា ក្នុងឧបាយាសជាដើម មានវិនិច្ឆ័យដូចគ្នានឹងសង្ខារក្ខន្ធ ក្នុងវេទនាដដែលទៀត មានវិនិច្ឆ័យដូចគ្នានឹងវេទនាខន្ធ ក្នុងសញ្ញា មានវិនិច្ឆ័យដូចគ្នា

នឹងសញ្ញាខន្ធ ក្នុងចេតនាជាដើម មានវិនិច្ឆ័យដូចគ្នានឹងសង្ខារក្ខន្ធ ។

ក្នុងបញ្ហាទី ៧ ជាដើម ក៏គប្បីជ្រាបធម៌ដែលសង្គ្រោះចូលគ្នាបាន និងសង្គ្រោះចូលគ្នាមិនបាន ដោយឧបាយនេះឯង ។ល។

## អដ្ឋកថាអសង្គហិតេនសង្គហិតបទ ចប់

# អភិធម្មបិដក

## សង្គហិតេន សង្គហិតបទនិទ្ទេស

[ ១៨៧ ] ពួកធម៌ណា សង្គ្រោះដោយសមុទយសច្ច ពួកធម៌ណា សង្គ្រោះដោយមគ្គសច្ច ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា សង្គ្រោះដោយធម៌ទាំងនោះ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។

[ ១៨៨ ] ពួកធម៌ណា សង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយបុរិសិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសុខិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយទុក្ខិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសោមនស្សិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយទោមនស្សិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយឧបេក្ខិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសទ្ធិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយវីរិយិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសតិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសមាធិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយបញ្ញិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអញ្ញិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអវិជ្ជា ពួកធម៌ណា សង្គ្រោះដោយសង្ខារ ព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយឧបាទាន ព្រោះតណ្ហាជាបច្ច័យ ពួកធម៌

ណា សង្គ្រោះដោយកម្មភព ព្រោះឧបាទានជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយសោក ពួកធម៌ណា សង្គ្រោះដោយបរិទេវៈ ពួកធម៌ណា សង្គ្រោះដោយទុក្ខ ពួកធម៌ណា សង្គ្រោះដោយទោមនស្ស ពួកធម៌ណា សង្គ្រោះដោយឧបាយាស ពួកធម៌ណា សង្គ្រោះដោយសតិប្បដ្ឋាន ពួកធម៌ណា សង្គ្រោះដោយសម្មប្បធាន ពួកធម៌ណា សង្គ្រោះដោយអប្បមញ្ញា ពួកធម៌ណា សង្គ្រោះដោយឥន្ទ្រិយ ៥ ពួកធម៌ណា សង្គ្រោះដោយពល ៥ ពួក ធម៌ណា សង្គ្រោះដោយពោជ្ឈង្គ ៧ ពួកធម៌ណា សង្គ្រោះដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា សង្គ្រោះដោយផស្សៈ ពួកធម៌ណា សង្គ្រោះដោយចេតនា ពួកធម៌ណា សង្គ្រោះដោយអធិមោក្ខ ពួកធម៌ណា សង្គ្រោះដោយមនសិការ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាអាសវៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាសញ្ញោជនៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាគន្ថៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាឱឃៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាយោគៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជានីវរណៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាបរាមាស ពួកធម៌ណា សង្គ្រោះដោយធម៌ជាឧបាទាន ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងគួរដល់សេចក្តីសៅហ្មង ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងជាធម៌សៅហ្មងហើយ ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងប្រកបដោយកិលេស ដោយ

ខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា សង្គ្រោះដោយធម៌ទាំងនោះ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។

## សង្គហិតេន សង្គហិតបទនិទ្ទេស ចប់

# អដ្ឋកថា

## សង្គហិតេនសង្គហិតបទ

[ ១៨៧-១៨៨ ] ឥឡូវនេះ ដើម្បីចែកធម៌ ដែលសង្គ្រោះចូលគ្នាបាន ជាមួយធម៌ដែលសង្គ្រោះចូលគ្នាបាន ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **សមុទយសច្ចេន** ជាដើម ។ ក្នុងនិទ្ទេសនោះ បទណា សង្គ្រោះចូលគ្នាបាន ដោយអំណាចខន្ធជាដើម និងធម៌ដែលសង្គ្រោះចូលគ្នាបានជាមួយខន្ធជាដើម ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាធម៌ដែលសង្គ្រោះចូលគ្នាបានជាមួយខន្ធជាដើម នៃពាក្យនោះឯងទៀត ។ ពាក្យនោះ រមែងមិនគួរក្នុងពាក្យទាំងឡាយ ដែលកាន់យកចំណែកទាំងអស់ណាមួយក្នុងខន្ធ អាយតនៈ និងធាតុតាំងទុក ព្រោះថា បទដទៃ ឈ្មោះថា សង្គ្រោះចូលគ្នាបានដោយអំណាចខន្ធជាដើម និងបទ មានខន្ធជាដើមទាំងអស់មិនមាន ។ ពាក្យណារួមពាក្យដែលសង្គ្រោះចូលគ្នាបានជាមួយខ្លួនហើយ គប្បីដល់នូវការសង្គ្រោះចូលគ្នាបានជាមួយពាក្យនោះទៀតដោយអំណាចខន្ធជាដើម ព្រោះហេតុនោះ ទើបពាក្យទាំងឡាយបែបនោះ ព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្នុងវារៈនេះ ។ ឯបទទាំងឡាយណា សម្ដែងចំណែកមួយនៃសង្ខារក្ខន្ធ ចំណែកមួយនៃវេទនាខន្ធ សុខុមរូប ឬចំណែកមួយនៃសច្ចៈ ដែលមិនលាយឡំដោយពាក្យដទៃ ពាក្យទាំងនោះ ទ្រង់កាន់យកក្នុងវារៈនេះ ។ គប្បីជ្រាបការរួបរួមពាក្យទាំងនោះដូចតទៅ

សច្ចៈ ២ ( សមុទយសច្ចនិងមគ្គសច្ច ) ឥន្ទ្រិយ ១៥ ( វៀរ

បសាទិន្ទ្រិយ ៥ ជីវិតិន្ទ្រិយ ១ មនិន្ទ្រិយ ១ ) បដិច្ច-

សមុប្បាទ ១១ ( វៀរនាមរូប សឡាយតនៈ វេទនា ឧបបត្តិ-
ភព ជាតិ ជរា មរណៈ ) បទបន្ទអំពីបដិច្ចសមុប្បាទ ១១
ទៀត ( សតិប្បដ្ឋាន សម្មប្បធាន អប្បមញ្ញា បញ្ចិន្ទ្រិយ
ពល ពោជ្ឈង្គ មគ្គង្គៈ ផស្សៈ ចេតនា អធិមោក្ខ
មនសិការ ) បទក្នុងគោច្ឆកៈ ៣០ ( រួមជា ៦៩ ) ដូច្នេះ ។

ក្នុងនិទ្ទេសនេះ មាន ២ បញ្ហាប៉ុណ្ណោះ ។ ក្នុងបញ្ហាទាំងនោះ បទណា ដែលព្រះមានព្រះភាគទ្រង់លើកឡើងតាំងបុច្ឆា បទនោះឯង សង្គ្រោះចូលគ្នាបានជាមួយធម៌ពួកណា ដោយអំណាចខន្ធជាដើម ទ្រង់សំដៅយកធម៌ពួកនោះ ទើបត្រាស់បទថា **ឯកេន ខន្ធេន** ជាដើម ក្នុងទីទាំងពួង ។ ក្នុងបញ្ហានោះ គប្បីជ្រាបន័យដូចតទៅនេះ សង្ខារដ៏សេស វៀរតណ្ហាហើយ សង្គ្រោះចូលគ្នាបានជាមួយសមុទយសច្ចដោយខន្ធសង្គហៈ ។ តណ្ហានោះឯងសង្គ្រោះចូលគ្នាបានជាមួយសង្ខារទាំងនោះទៀត គឺតណ្ហានោះ សង្គ្រោះចូលគ្នាបានជាមួយសង្ខារទាំងឡាយនោះឯងទៀត ដោយខន្ធសង្គហៈជាដើម ។ ក្នុងទីទាំងពួង ក៏ន័យនេះឯង ។ ក្នុងនិទ្ទេសនេះ ក្នុងបុច្ឆានៃអរូបធម៌ សង្ខារក្ខន្ធ ឬវេទនាខន្ធ ឈ្មោះថា ខន្ធ ១ ។ ក្នុងបុច្ឆានៃរូបធម៌ រូបក្ខន្ធ ឈ្មោះថា ខន្ធ ១ ។ ក្នុងបុច្ឆានៃបរិទេវៈ សទ្ទាយតនៈ ឈ្មោះថា អាយតនៈ ១ សទ្ទធាតុនោះឯង ឈ្មោះថា ធាតុ ១ ។ បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងឋានៈដ៏សេស ដោយអំណាចធម្មាយតនៈ និងធម្មធាតុ ដូច្នេះឯង ៕

**អដ្ឋកថាសង្គហិតេនសង្គហិតបទ ចប់**

# អភិធម្មបិដក

## អសង្គហិតេន អសង្គហិតបទនិទ្ទេស

[ ១៨៩ ] ពួកធម៌ណា មិនសង្រ្គោះដោយរូបក្ខន្ធ ដោយខន្ធសង្គហៈ មិនសង្រ្គោះដោយអាយតនសង្គហៈ មិនសង្រ្គោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្រ្គោះដោយធម៌ទាំងនោះ ដោយខន្ធសង្គហៈ មិនសង្រ្គោះដោយអាយតនសង្គហៈ មិនសង្រ្គោះដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្រ្គោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ មិនសង្រ្គោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ១៩០ ] ពួកធម៌ណា មិនសង្រ្គោះដោយវេទនាខន្ធ ពួកធម៌ណា មិនសង្រ្គោះដោយសញ្ញាខន្ធ ពួកធម៌ណា មិនសង្រ្គោះដោយសង្ខារក្ខន្ធ ដោយខន្ធសង្គហៈ មិនសង្រ្គោះដោយអាយតនសង្គហៈ មិនសង្រ្គោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្រ្គោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្រ្គោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៩១ ] ពួកធម៌ណា មិនសង្រ្គោះដោយវិញ្ញាណក្ខន្ធ ពួកធម៌ណា មិនសង្រ្គោះដោយមនាយតនៈ ពួកធម៌ណា មិនសង្រ្គោះដោយចក្ខុវិញ្ញាណធាតុ ។បេ។ ពួកធម៌ណា មិនសង្រ្គោះដោយមនោធាតុ ពួកធម៌ណា មិនសង្រ្គោះដោយមនោវិញ្ញាណធាតុ ពួកធម៌ណា មិនសង្រ្គោះដោយមនិន្រ្ទិយ ដោយខន្ធសង្គហៈ មិនសង្រ្គោះដោយអាយតនសង្គហៈ មិនសង្រ្គោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្រ្គោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្រ្គោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ១៩២ ] ពួកធម៌ណា មិនសង្គ្រោះដោយចក្ខាយតនៈ ។បេ។ ពួកធម៌ណា មិនសង្គ្រោះដោយផោដ្ឋព្វាយតនៈ ពួកធម៌ណា មិនសង្គ្រោះដោយចក្ខុ-ធាតុ ។បេ។ ពួកធម៌ណា មិនសង្គ្រោះដោយផោដ្ឋព្វធាតុ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៩៣ ] ពួកធម៌ណា មិនសង្គ្រោះដោយធម្មាយតនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម្មធាតុ ពួកធម៌ណា មិនសង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយបុរិសិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយជីវិតិន្ទ្រិយ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ១៩៤ ] ពួកធម៌ណា មិនសង្គ្រោះដោយសមុទយសច្ច ពួកធម៌ណា មិនសង្គ្រោះដោយមគ្គសច្ច ពួកធម៌ណា មិនសង្គ្រោះដោយនិរោធសច្ច ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុ-សង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៩៥ ] ពួកធម៌ណា មិនសង្គ្រោះដោយចក្ខុន្ទ្រិយ ។បេ។ ពួកធម៌ណា មិនសង្គ្រោះដោយកាយិន្ទ្រិយ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយ

អាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ១៩៦ ] ពួកធម៌ណា មិនសង្គ្រោះដោយសុខិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយទុក្ខិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសោមនស្សិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយទោមនស្សិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយឧបេក្ខិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសទ្ធិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយវីរិយិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសតិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយសមាធិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយបញ្ញិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអនញ្ញតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអញ្ញិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយអវិជ្ជា ពួកធម៌ណា មិនសង្គ្រោះដោយសង្ខារ ព្រោះអវិជ្ជាជាបច្ច័យ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ១៩៧ ] ពួកធម៌ណា មិនសង្គ្រោះដោយវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ១៩៨ ] ពួកធម៌ណា មិនសង្គ្រោះដោយនាមរូប ព្រោះវិញ្ញាណជាបច្ច័យ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ១៩៩ ] ពួកធម៌ណា មិនសង្គ្រោះដោយសឡាយតនៈ ព្រោះនាមរូបជាបច្ច័យ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ២០០ ] ពួកធម៌ណា មិនសង្គ្រោះដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយវេទនា ព្រោះផស្សៈជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយតណ្ហាព្រោះវេទនាជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយឧបាទាន ព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយកម្មភព ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២០១ ] ពួកធម៌ណា មិនសង្គ្រោះដោយអរូបភព ពួកធម៌ណា មិនសង្គ្រោះដោយនេវសញ្ញានាសញ្ញាភព ពួកធម៌ណា មិនសង្គ្រោះដោយចតុវោ-ការភព ពួកធម៌ណា មិនសង្គ្រោះដោយឥទ្ធិបាទ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិន

សង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២០២ ] ពួកធម៌ណា មិនសង្គ្រោះដោយអសញ្ញាភព ពួកធម៌ណា មិនសង្គ្រោះដោយឯកវោការភព ពួកធម៌ណា មិនសង្គ្រោះដោយជាតិ ពួកធម៌ណា មិនសង្គ្រោះដោយជរា ពួកធម៌ណា មិនសង្គ្រោះដោយមរណៈ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុ-សង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ២០៣ ] ពួកធម៌ណា មិនសង្គ្រោះដោយបរិទេវៈ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ២០៤ ] ពួកធម៌ណា មិនសង្គ្រោះដោយសោក ពួកធម៌ណា មិនសង្គ្រោះដោយទុក្ខ ពួកធម៌ណា មិនសង្គ្រោះដោយទោមនស្ស ពួកធម៌ណា មិនសង្គ្រោះដោយឧបាយាស ពួកធម៌ណា មិនសង្គ្រោះដោយសតិប្បដ្ឋាន ពួកធម៌ណា មិនសង្គ្រោះដោយសម្មប្បធាន ពួកធម៌ណា មិនសង្គ្រោះដោយឈាន ពួកធម៌ណា មិនសង្គ្រោះដោយអប្បមញ្ញា ពួកធម៌ណា មិនសង្គ្រោះដោយឥន្ទ្រិយ ៥ ពួកធម៌ណា មិនសង្គ្រោះដោយពល ៥ ពួកធម៌ណា មិនសង្គ្រោះដោយពោជ្ឈង្គ ៧ ពួកធម៌ណា មិនសង្គ្រោះដោយមគ្គ មានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា

មិនសង្គ្រោះដោយផស្សៈ ពួកធម៌ណា មិនសង្គ្រោះដោយវេទនា ពួកធម៌ណា មិនសង្គ្រោះដោយសញ្ញា ពួកធម៌ណា មិនសង្គ្រោះដោយចេតនា ពួកធម៌ណា មិនសង្គ្រោះដោយអធិមោក្ខ ពួកធម៌ណា មិនសង្គ្រោះដោយមនសិការ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុ-សង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២០៥ ] ពួកធម៌ណា មិនសង្គ្រោះដោយចិត្ត ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ២០៦ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាកុសល ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអកុសល ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រកបដោយសុខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាវិបាក ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានវិបាកជាប្រក្រតី ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌សៅហ្មង ទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌

មិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយបីតិ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយសុខ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយឧបេក្ខា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលដល់នូវការសន្សំ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលដល់នូវការមិនសន្សំ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ ជារបស់សេក្ខបុគ្គល ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដល់នូវសភាពជាធំ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រមាណមិនបាន ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍តូចឆ្មារ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ថោកទាប ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ថ្លៃថ្លា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានសភាពខុស និងទៀង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌ណា

មិនសង្គ្រោះដោយពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានមគ្គជាហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានមគ្គជាអធិបតី ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ជាអធិបតី ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ មានអារម្មណ៍ខាងក្រៅ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២០៧ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយការឃើញទាំងប្រកបដោយការប៉ះពាល់ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ២០៨ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាហេតុ ទាំងប្រកបដោយហេតុ ដោយខន្ធ-

សង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២០៩ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមែនហេតុ ដោយពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២១០ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមានបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ មិនមានបច្ច័យតាក់តែង ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២១១ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយការឃើញ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយការប៉ះពាល់ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ

ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។

[ ២១២ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានរូប ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ២១៣ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមានរូប ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាលោកុត្តរ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២១៤ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២១៥ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមានអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយអាសវៈ ពួកធម៌ណា មិន

សង្គ្រោះដោយពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២១៦ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាសញ្ញោជនៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាគន្ថៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាឱឃៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាយោគៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជានីវរណៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាបរាមាស ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាបរាមាស ទាំងជាធម៌ដែលបរាមាសស្ទាបអង្អែលហើយ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២១៧ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលបរាមាសមិនស្ទាបអង្អែលហើយ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយបរាមាស ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែល ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយអារម្មណ៍ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិន

សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ២១៨ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមានអារម្មណ៍ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមែនជាចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រាសចាកចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនច្រឡំដោយចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលតាំងឡើងអំពីចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលកើតជាមួយនឹងចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ខាងក្រៅ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាឧបាទា ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ២១៩ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ គឺចិត្ត ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ២២០ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាចេតសិក ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលច្រឡំដោយចិត្ត ពួកធម៌ណាមិនសង្គ្រោះដោយពួកធម៌ដែលច្រឡំ

ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២២១ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ខាងក្នុង ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។

[ ២២២ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាកិលេស ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាកិលេស ទាំងជាធម៌សៅហ្មងហើយ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាកិលេស ទាំងប្រកបដោយកិលេស ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ២២៣ ] ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ មិនគួរដល់សេចក្តី

សៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលសៅហ្មងហើយ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយកិលេស តែមិនមែនជាកិលេស ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយវិតក្ក ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយវិចារ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយបីតិ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយសុខ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ប្រកបដោយឧបេក្ខា ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនមែនជាកាមាវចរ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជារូបាវចរ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអរូបាវចរ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាអបរិយាបន្ន ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ជាគ្រឿងចេញចាកវដ្តៈ ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មានសភាពទៀង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌មិនប្រកបដោយការរើខួន ពួកធម៌ណា មិនសង្គ្រោះ

ដោយពួកធម៌ប្រកបដោយសត្រូវ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ទាំងនោះ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះ ដោយធាតុសង្គហៈ ពួកធម៌នោះ មិនសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ធម៌ទាំងនោះ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

ធម៌ ២២ គឺរូប ១ ធម្មាយតនៈ ១ ធម្មធាតុ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ នាមរូប ១ ភព ២ ជាតិ ១ ជរា ១ មច្ចុ ១ រូប ១ ធម្មជាតមិនមានអារម្មណ៍ ១ ធម្មជាតមិនមែនចិត្ត ១ ធម្មជាតប្រាសចាក ១ ធម្មជាតមិនប្រកបដោយចិត្ត ១ ធម្មជាតតាំងឡើងអំពីចិត្ត ១ ធម្មជាតកើតជាមួយនឹងចិត្ត ១ ធម្មជាតប្រព្រឹត្តទៅតាមចិត្ត ១ ធម្មជាតខាងក្រៅ ១ ឧបាទា ១ ន័យនុ៎ះ ព្រះសាស្តា ទ្រង់ត្រាស់ដឹងដោយប្រពៃហើយ ។

## អសង្គហិតេន អសង្គហិតបទនិទ្ទេស ចប់

# អដ្ឋកថា

## អសង្គហិតេនអសង្គហិតបទ

[ ១៨៩-២២៣ ] ឥឡូវនេះ ដើម្បីចែកពាក្យនៃធម៌ ដែលសង្គ្រោះចូលគ្នាមិនបាន ជាមួយធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ទើបព្រះមានព្រះភាគទ្រង់ផ្ដើមពាក្យថា **រូបក្ខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ បទណាសង្គ្រោះចូលគ្នាមិនបានជាមួយធម៌ដែលសង្គ្រោះចូលគ្នាមិនបានជាមួយខន្ធជាដើម ដោយអំណាចខន្ធជាដើម ព្រះមានព្រះភាគ ទ្រង់ធ្វើបុច្ឆា និងវិសជ្ជនាធម៌ដែលសង្គ្រោះចូលគ្នាមិនបានជាមួយខន្ធជាដើម នៃពាក្យនោះឯងទៀត ។ បទនោះ រមែងមិនគួរក្នុងបទទាំងឡាយ មានទុក្ខសច្ចជាដើម ដែលរួបរួមខន្ធ ៥ និងក្នុងបទទាំងឡាយ ដែលមានអនិទស្សនអប្បដិឃៈជាដើម ដែលរួបរួមសុខុមរូបព្រមទាំងវិញ្ញាណ ។ ដោយពាក្យបែបនោះ ព្រះនិព្វានមិនបានត្រឹមតែខន្ធ-សង្គហៈ ។ ចំណែកធម៌ដ៏សេស ឈ្មោះថា ជាធម៌ដែលសង្គ្រោះចូលគ្នាមិនបានជាមួយខន្ធជាដើម រមែងមិនមាន ព្រោះហេតុនោះ ពាក្យបែបនោះ ព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្នុងវារៈនេះ ។ តែបទទាំងឡាយណា មិនសម្ដែងបញ្ចក្ខន្ធ និងវិញ្ញាណ ដោយរួមជាមួយសុខុមរូប បទទាំងនោះ ទ្រង់កាន់យកក្នុងទីនេះ ។ គប្បីជ្រាបការរួបរួមពាក្យទាំងនោះដូចតទៅ

ខន្ធទាំងអស់ អាយតនៈទាំងអស់ ធាតុទាំងអស់ សច្ចៈ ៣
( សមុទយសច្ច និរោធសច្ច និងមគ្គសច្ច ) ឥន្ទ្រិយទាំងអស់
បដិច្ចសមុប្បាទ ២៣ ( វៀរឧបបត្តិភព កាមភព រូបភព
សញ្ញីភព បញ្ចវោការភព ) បន្ទាប់អំពីបដិច្ចសមុប្បាទមក

ទៀត ១៦ បទ ( មានសតិប្បដ្ឋានជាដើម រហូតដល់មនសិការជាទីបំផុត ) ក្នុងតិកៈ ៤៣ ក្នុងគោច្ឆកៈ ៧២ ក្នុងចូឡន្តរទុកៈ ៧ ក្នុងមហន្តរទុកៈ ១៨ ខាងមុខអំពីនោះទៀត ១៨ បទ ( បិដ្ឋិទុកៈ ) រួមទាំងអស់ជា ២៥៧ បទដ៏សេស ព្រះមានព្រះភាគទ្រង់មិនសម្តែងក្នុងនិទ្ទេសនេះ ដូច្នេះ ។

ក្នុងនិទ្ទេសនេះ បញ្ហាទាំងអស់ មាន ៣៤ មួយអន្លើដោយបទដែលទ្រង់រួបរួមដោយអំណាចនៃពាក្យវិសជ្ជនាទំនងដូចគ្នា ។ ក្នុងនិទ្ទេសនៃបទទាំងនោះ បទណា ព្រះមានព្រះភាគ ទ្រង់លើកឡើងតាំងជាសំណួរ បទទាំងអស់នោះឯង សង្គ្រោះចូលគ្នាមិនបាន ជាមួយធម៌ពួកណា មានខន្ធជាដើម ទ្រង់សំដៅយកធម៌ទាំងនោះ ទើបត្រាស់ថា **ឯកេន ខន្ធេន** ជាដើម ។

ក្នុងសេចក្តីនេះ គប្បីជ្រាបន័យ ដូចតទៅនេះថា ខន្ធ ៤ និព្វាន ១ សង្គ្រោះចូលគ្នាមិនបានជាមួយរូបក្ខន្ធ ដោយខន្ធសង្គហៈ វៀរវិញ្ញាណហើយ ធម៌ដ៏សេសសង្គ្រោះចូលគ្នាបានដោយអាយតនៈ និងធាតុសង្គហៈ ព្រោះហេតុនោះ វិញ្ញាណនោះឯង ឈ្មោះថា សង្គ្រោះចូលគ្នាមិនបានដោយការសង្គ្រោះទាំង ៣ មានខន្ធសង្គហៈជាដើម ។ ខន្ធ ៤ និងនិព្វាន សង្គ្រោះចូលគ្នាមិនបានជាមួយវិញ្ញាណនោះ ដោយខន្ធសង្គហៈជាដើម ។ ធម៌ទាំងអស់នោះសង្គ្រោះចូលគ្នាមិនបាន ជាមួយវិញ្ញាណនោះឯង ដោយខន្ធសង្គហៈជាដើមទៀត ព្រោះហេតុនោះ ទើបឈ្មោះថា សង្គ្រោះចូលគ្នាមិនបានជាមួយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ ន័យម្យ៉ាងទៀត វិញ្ញាណណា សង្គ្រោះចូលគ្នា

មិនបានជាមួយរូបក្ខន្ធ ដោយការសង្គ្រោះទាំង ៣ មានខន្ធសង្គហៈជាដើម រូបធម៌ទាំងនោះឯង ក៏សង្គ្រោះចូលគ្នាមិនបាន ជាមួយវិញ្ញាណធម៌ទាំងនោះ ដោយសង្គហៈទាំង ៣ ។ ម្យ៉ាងទៀត រូបធម៌ទាំងនោះ សង្គ្រោះចូលគ្នាមិនបានជាមួយវិញ្ញាណដោយសង្គហៈទាំង ៣ ទៀត ។ ដ្បិតថា វិញ្ញាណ បើពោលដោយខន្ធជាវិញ្ញាណក្ខន្ធ ១ បើពោលដោយអាយតនៈ ជាមនាយតនៈ ១ បើពោលដោយធាតុ ជាវិញ្ញាណធាតុ ៧ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯកេន ខន្ធេន** ជាដើម ។ ដោយឧបាយនេះ ក្នុងបទទាំងពួង បទណា ព្រះមានព្រះភាគទ្រង់លើកឡើងតាំងជាសំណួរ បទនោះឯង សង្គ្រោះចូលគ្នាមិនបាន ជាមួយធម៌ពួកណា ដោយអំណាចនៃខន្ធជាដើម បណ្ឌិតគប្បីជ្រាបខន្ធជាដើម ដែលសង្គ្រោះចូលគ្នាមិនបានដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងនិទ្ទេសនោះ បញ្ហាទី ២ គប្បីជ្រាបដោយអំណាចនៃរូប និងវិញ្ញាណមុន ព្រោះថា វេទនាជាដើម សង្គ្រោះចូលគ្នាមិនបានជាមួយរូប និងវិញ្ញាណនោះឯង ដោយខន្ធសង្គហៈជាដើម ដ្បិតថា ខន្ធទាំង ២ នោះ ជាអាយតនៈ ១១ ជាធាតុ ១៧ ។

ក្នុងបញ្ហាទី ៣ វិញ្ញាណសង្គ្រោះចូលគ្នាមិនបាន ជាមួយខន្ធ ៤ មានរូបក្ខន្ធជាដើម ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបនូវធម៌ទាំងឡាយ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងបញ្ហាទី ៤ គប្បីជ្រាបធម៌ទាំងឡាយ មានខន្ធជាដើម ក្នុងបញ្ហាទាំង

ពួន ដោយន័យនេះថា ចក្ខ្វាយតនៈ សង្គ្រោះចូលគ្នាមិនបានជាមួយខន្ធ ៤ មានវេទនាខន្ធជាដើម ។ ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងខាងចុង ក្នុងឧទានគាថាថា **រូបញ្ច ធម្មាយតនំ** ជាដើម ជាការសម្តែងសង្ខេបដោយអាការដទៃ ដូច្នេះឯង ៕

# អភិធម្មបិដក

## សម្បយោគវិប្បយោគបទនិទ្ទេស

[ ២២៤ ] រូបក្ខន្ធប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ គឺមនាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ គឺមនាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ គឺវេទនា សញ្ញា សង្ខារក៏មាន ។

[ ២២៥ ] វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ គឺសញ្ញាខន្ធ សង្ខារក្ខន្ធក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ គឺរូប និងនិព្វានក៏មាន ។

[ ២២៦ ] វិញ្ញាណក្ខន្ធ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២២៧ ] ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២២៨ ] មនាយតនៈ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយនតៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាស

បាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២២៩ ] ចក្ខុធាតុ ។បេ។ ផោដ្ឋព្វធាតុ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣០ ] ចក្ខុវិញ្ញាណធាតុ ។បេ។ មនោធាតុ មនោវិញ្ញាណធាតុ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣១ ] សមុទយសច្ច មគ្គសច្ច ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣២ ] និរោធសច្ច ចក្ខុន្ទ្រិយ ។បេ។ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិ-សិន្ទ្រិយ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៣ ] មនិន្ទ្រិយ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ

១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៤ ] សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៥ ] ឧបេក្ខិន្ទ្រិយ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៦ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៦ ] សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៧ ] វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ

ក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៨ ] ផស្សៈ ( កើតមាន ) ព្រោះសឡាយតនៈជាបច្ច័យ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៣៩ ] វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ក៏មាន ។

[ ២៤០ ] តណ្ហា ( កើតមាន ) ព្រោះវេទនា ជាបច្ច័យ ឧបាទាន ( កើតមាន ) ព្រោះតណ្ហា ជាបច្ច័យ កម្មភព ( កើតមាន ) ព្រោះឧបាទាន ជាបច្ច័យ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៤១ ] រូបភព ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌

ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៣ ។

[ ២៨២ ] អរូបកព នេវសញ្ញានាសញ្ញាយតនកព ចតុវោការកព ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៣ ] អសញ្ញាកព ឯកវោការកព បរិទេវៈ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៤ ] សេចក្តីសោក ទុក្ខ ទោមនស្ស ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៥ ] ឧបាយាស សតិប្បដ្ឋាន សម្មប្បធាន ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៦ ] ឥទ្ធិបាទ ប្រកបដោយខន្ធ ២ ក៏មាន ប្រកបដោយខន្ធ ១

អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៤៧ ] ឈាន ប្រកបដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៤៨ ] អប្បមញ្ញា ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ ដ៏ប្រសើរ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៤៩ ] ផស្សៈ ចេតនា មនសិការ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥០ ] វេទនា សញ្ញា ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន

ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥១ ] ចិត្ត ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥២ ] អធិមោក្ខ ( ការជឿស៊ប់ ) ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ២ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៣ ] ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៤ ] ពួកធម៌ប្រកបដោយសុខវេទនា ពួកធម៌ប្រកបដោយទុក្ខវេទនា ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៥ ] ពួកធម៌ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាស

ចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៦ ] ពួកធម៌ជាវិបាក ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៧ ] ពួកធម៌មានវិបាកធម៌ជាប្រក្រតី ពួកធម៌ដែលសៅហ្មង ទាំងគួរដល់នូវសេចក្តីសៅហ្មង ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៥៨ ] ពួកធម៌មិនមែនវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ២៥៩ ] ពួកធម៌ដែលកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៦០ ] ពួកធម៌ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦១ ] ពួកធម៌មិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ប្រឡំដោយបីតិ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦២ ] ពួកធម៌មិនមានវិតក្ក មិនមានវិចារ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ២៦៣ ] ពួកធម៌ប្រឡំដោយសុខ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦៤ ] ពួកធម៌ប្រឡំដោយឧបេក្ខា ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ:

១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦៥ ] ពួកធម៌គួរលះដោយទស្សនៈ ពួកធម៌គួរលះដោយភាវនា ពួកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ដល់នូវការសន្សំ ពួកធម៌ដល់នូវការមិនសន្សំ ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ដល់នូវសភាពធំ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦៦ ] ពួកធម៌មានប្រមាណមិនបាន ពួកធម៌ដ៏ឧត្តម ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៦៧ ] ពួកធម៌មានអារម្មណ៍តូចឆ្មារ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦៨ ] ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ថោកទាប ពួកធម៌មានសភាពខុស និងទៀង ពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គជាអធិបតី ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន

ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៦៩ ] ពួកធម៌មិនទាន់កើតឡើង ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ២៧០ ] ពួកធម៌មានអារម្មណ៍ ជាអតីត ពួកធម៌មានអារម្មណ៍ ជាអនាគត ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧១ ] ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧២ ] ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៣ ] ពួកធម៌ជាហេតុ ពួកធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ជាហេតុ ទាំងប្រកបដោយហេតុ ប្រកបដោយខន្ធ ៣

អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៤ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ប្រកបដោយហេតុ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៥ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៦ ] ពួកធម៌មិនមានបច្ច័យ ពួកធម៌មិនមានបច្ច័យតាក់តែង ពួកធម៌ប្រកបដោយការឃើញ ពួកធម៌ប្រកបដោយការប៉ះពាល់ ពួកធម៌មានរូប ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៧ ] ពួកធម៌ជាលោកុត្តរ ប្រកបដែរឬទេ ។ មិនមានទេ ។

ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៧៨ ] ពួកធម៌ជាអាសវៈ ពួកធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៧៩ ] ពួកធម៌មិនមានអាសវៈ ពួកធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៨០ ] ពួកធម៌ប្រកបដោយអាសវៈ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨១ ] ពួកធម៌ប្រកបដោយអាសវៈ តែមិនមែនអាសវៈ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨២ ] ពួកធម៌ជាសញ្ញោជនៈ ពួកធម៌ជាគន្ថៈ ពួកធម៌ជាឱឃៈ ពួកធម៌ជាយោគៈ ពួកធម៌ជានីវរណៈ ពួកធម៌ជាបរាមាស ពួកធម៌ជាបរាមាសទាំងបរាមាសស្ទាបអង្អែលហើយ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៣ ] ពួកធម៌ដែលបរាមាសមិនស្ទាបអង្អែល ពួកធម៌ដែលប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែល ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៨៤ ] ពួកធម៌ប្រកបដោយបរាមាស ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៥ ] ពួកធម៌ប្រកបដោយអារម្មណ៍ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៦ ] ពួកធម៌មិនមានអារម្មណ៍ ពួកធម៌ប្រាសចាកចិត្ត ពួកធម៌ប្រឡំដោយចិត្ត ពួកធម៌ជាឧបាទា ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាស

ចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាស ចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៧ ] ពួកធម៌ គឺចិត្ត ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៨ ] ពួកធម៌ គឺចេតសិក ពួកធម៌ប្រកបដោយចិត្ត ពួកធម៌ច្រឡំ ដោយចិត្ត ពួកធម៌ច្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាម ចិត្ត ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៨៩ ] ពួកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិន កាន់យក ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិន មែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ២៩០ ] ពួកធម៌ជាឧបាទាន ពួកធម៌ជាកិលេស ពួកធម៌ជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ជាកិលេស ទាំងសៅហ្មងហើយ ពួក ធម៌ជាកិលេស ទាំងប្រកបដោយកិលេស ប្រកបដោយខន្ធ ៣ អាយតនៈ

១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩១ ] ពួកធម៌មិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ប្រាសចាកកិលេស ពួកធម៌មិនគួរដល់នូវសេចក្តីសៅហ្មង ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ២៩២ ] ពួកធម៌ដែលសៅហ្មងហើយ ពួកធម៌ប្រកបដោយកិលេស ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៣ ] ពួកធម៌សៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ប្រកបដោយកិលេស តែមិនមែនជាកិលេស ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៤ ] ពួកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ដែលគួរលះដោយភាវនា ពួកធម៌មានហេតុ គួរលះដោយទស្សនៈ ពួកធម៌មានហេតុ គួរលះដោយភាវនា ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។

ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៥ ] ពួកធម៌ប្រកបដោយវិតក្ក ពួកធម៌ប្រកបដោយវិចារ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៦ ] ពួកធម៌មិនមានវិតក្ក ពួកធម៌មិនមានវិចារ ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ២៩៧ ] ពួកធម៌ប្រកបដោយបីតិ ពួកធម៌ប្រឡំដោយបីតិ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៨ ] ពួកធម៌ប្រឡំដោយសុខ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ២៩៩ ] ពួកធម៌ប្រឡំដោយឧបេក្ខា ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌

ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣០០ ] ពួកធម៌មិនមែនកាមាវចរ ពួកធម៌ជាអបរិយាបន្ន ពួកធម៌មិនប្រកបដោយការរើខ្លួន ប្រកបដែរឬទេ ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៣០១ ] ពួកធម៌ជារូបាវចរ ពួកធម៌ជាអរូបាវចរ ពួកធម៌ជានិយ្យានិកៈ ពួកធម៌មានសភាពទៀង ពួកធម៌ប្រកបដោយសត្រូវ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

## សម្បយោគវិប្បយោគបទនិទ្ទេស ចប់

# អដ្ឋកថា

## សម្បយោគវិប្បយោគបទ

[ ២២៤-៣០១ ] ឥឡូវនេះ ដើម្បីចែកបទនៃធម៌ដែលប្រកបចូលគ្នាបាន និងធម៌ដែលប្រកបចូលគ្នាមិនបាន ទើបព្រះមានព្រះភាគផ្តើមពាក្យថា **រូបក្ខន្ធោ** ជាដើម ក្នុងនិទ្ទេសនោះ បទណារមែងរកបាន និងបទណារមែងរកមិនបាន បទទាំងអស់នោះ ព្រះមានព្រះភាគ ទ្រង់កាន់យកជាពាក្យសួរ តែក្នុងការឆ្លើយបទណារកមិនបាន បទនោះទ្រង់បដិសេធថា **នត្ថិ** ។ ការប្រកបនូវគ្នា និងគ្នានៃរូបក្ខន្ធទាំងឡាយនោះឯង ដែលកើតឡើងក្នុងសន្តាន ១ ក្នុងខណៈ ១ ដែលមានចំណែកស្មើដោយអរូបក្ខន្ធ ៤ នោះឯង រមែងបាន អំពីព្រះបាលីថា ការសមប្រកបដោយបទ ៤ ការប្រាសចេញចាកបទ ៤ ធម៌មានចំណែកស្មើ ធម៌មានចំណែកមិនស្មើ ដូច្នេះ ។ ឈ្មោះថា ការប្រកបរូបធម៌ទាំងឡាយចូលគ្នាជាមួយរូប ឬនិព្វាន និងការប្រកបនិព្វាន ចូលជាមួយរូប រមែងមិនមាន ។ ដោយទំនងដូចគ្នា ការប្រកបរូប និងនិព្វាន ចូលគ្នាជាមួយអរូបក្ខន្ធទាំងឡាយក៏មិនមាន ដ្បិតថា ធម៌ទាំងនោះ មានចំណែកមិនស្មើគ្នាជាមួយធម៌ទាំងនោះ ។ ការប្រកបអរូបក្ខន្ធទាំងឡាយចូលគ្នាជាមួយរូប ឬនិព្វាន រមែងមិនមានយ៉ាងណា ការប្រកបអរូបក្ខន្ធទាំងឡាយចូលគ្នាជាមួយអរូបធម៌ទាំងឡាយ ដែលមានសន្តានបែកគ្នា មានខណៈផ្សេងៗ គ្នា ក៏មិនមាន យ៉ាងនោះឯង ដ្បិតថា ធម៌ទាំងនេះ មានចំណែកមិនស្មើជាមួយធម៌ទាំងនោះ ព្រោះមានចំណែកមិនស្មើដោយសន្តាន និងខណៈនោះឯង ។ តែ

ការមានចំណែកមិនស្មើគ្នានេះ មិនមានក្នុងសង្គហន័យ គឺន័យដែលសង្គ្រោះចូលគ្នាបាន ព្រោះខុសដោយអត្ថនៃការសង្គ្រោះ ។ ពិតហើយ ហេតុត្រឹមតែការចូលដល់នូវការរាប់ ចាត់ជាអត្ថនៃការសង្គ្រោះ ។ តែក្នុងសម្បយោគន័យ ការមានចំណែកមិនស្មើគ្នាមានព្រោះលក្ខណៈ នៃការកើតឡើងព្រមគ្នាជាដើម ជាអត្ថនៃសម្បយោគ ព្រោះហេតុនោះ លក្ខណៈនៃការប្រកបធម៌ណា ចូលគ្នាបានជាមួយធម៌ណាមួយ រមែងមិនត្រូវក្នុងទីនេះ ដើម្បីសួរដល់ធម៌នោះ សូម្បីធ្វើការសង្គ្រោះបាន ព្រះមានព្រះភាគក៏ទ្រង់បដិសេធថា មិនមាន ។ លក្ខណៈនៃការប្រកបចូលគ្នាមិនបាននៃធម៌ណា រមែងត្រឹមត្រូវ ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងការប្រកបចូលគ្នាមិនបាននៃធម៌នោះ ។ បទទាំងឡាយណា រមែងសម្តែងធម៌ទាំងឡាយ ដែលលាយឡំជាមួយរូប ឬជាមួយនិព្វាន ដែលមិនមែនប្រកបចូលគ្នាមិនបានជាមួយធាតុ សូម្បីមួយក្នុងវិញ្ញាណធាតុ ៧ ពាក្យនោះ រមែងមិនប្រកបក្នុងនិទ្ទេសនេះ ដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់មិនកាន់យក ។ គប្បីជ្រាបឧទាននៃបទទាំងនោះដូចតទៅ

ធម្មាយតនៈ ១ ធម្មធាតុ ១ ទុក្ខសច្ច ១ ជីវិត ១ សឡាយតនៈ ១ នាមរូប ១ ភពធំ ៤ ( ឧបបត្តិភព កាមភព សញ្ញីភព បញ្ចវោការភព ) ជាតិ ជរា មរណៈ ក្នុងតិកៈ ១៩ ក្នុងគោច្ឆកៈ ៥០ ក្នុងចូឡន្តរទុកៈ ៨ ក្នុងមហន្តរទុកៈ ១៥ បន្ទាប់អំពីនោះទៀត ១៨ រួមជា ១២៣ បទ នោះរក

មិនបានក្នុងសម្បយោគ ដូច្នេះ ។

ពិតហើយ ធម្មាយតនៈដែលបុគ្គលណាមួយ មិនអាចពោលថា ប្រកបចូលគ្នាបានជាមួយវិញ្ញាណ ដែលមិនរាប់បញ្ចូលក្នុងធម្មាយតនៈនោះ ព្រោះធម្មាយតនៈនោះ ជាសភាវៈលាយឡំដោយរូប និងនិព្វាន ។ ព្រោះក្នុងនិទ្ទេសនេះ ធម៌ទាំងឡាយ មានវេទនាជាដើម ប្រកបចូលគ្នាបានជាមួយវិញ្ញាណ ហេតុនោះ បុគ្គលណាមួយមិនអាចពោលថា ប្រកបចូលគ្នាមិនបាន ។ ក្នុងបទដ៏សេសទាំងឡាយក៏ន័យនេះឯង ។ បទទាំងនោះ មិនត្រឹមត្រូវក្នុងទីទាំងពួង ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្នុងទីនេះ ។ បទដ៏សេស មានខន្ធជាដើម រមែងត្រឹមត្រូវ ព្រោះហេតុនោះ ទើបទ្រង់កាន់យកបទទាំងនោះ ហើយធ្វើបុច្ឆា និងវិសជ្ជនាដោយអំណាចចែកបទនីមួយៗ និងដោយរួបរួមបទនោះៗ ។

បណ្ដាបញ្ហាទាំងនោះ បញ្ហាទី ១ បទថា **ឯកេនាយតនេន** បានដល់មនាយតនៈ ។ បទថា **កេហិចិ** បានដល់ វេទនា សញ្ញា សង្ខារ ដែលរាប់បញ្ចូលក្នុងធម្មាយតនៈ និងធម្មធាតុ ។

ក្នុងបញ្ហាទី ២ បទថា **តីហិ** បានដល់ ខន្ធដ៏សេសទាំងឡាយ វៀរខន្ធដែលសួរហើយ និងសួរទៀត ។ បទថា **កេហិចិ សម្បយុត្តា** បានដល់វេទនាខន្ធ ប្រកបចូលគ្នាបានជាមួយសញ្ញាខន្ធ និងសង្ខារក្ខន្ធ ។ ខន្ធក្រៅអំពីនេះ វៀរខន្ធឯងហើយ ក៏ប្រកបចូលគ្នាបានជាមួយខន្ធក្រៅអំពីនេះ ។ បទថា **កេហិចិ វិប្បយុត្តា** បានដល់ ជាមួយរូប និងនិព្វាន ។ អរូបក្នុងធម្មាយតនៈ

និងធម្មធាតុ គប្បីឃើញក្នុងការប្រកបចូលគ្នាមិនបានជាមួយរូប ឯរូបក៏គប្បីឃើញក្នុងការប្រកបចូលគ្នាមិនបានជាមួយអរូប ក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។

ក្នុងបញ្ហាទី ៣ មានអត្ថងាយយល់ហើយ ។

ក្នុងបញ្ហាទី ៤ ព្រះមានព្រះភាគមិនបានត្រាស់បទថា **កតីហិ ខន្ធេហិ** ជាដើម តែត្រាស់ថា **សម្បយុត្តំ** និងបទថា **នត្ថិ** ដូច្នេះ ។ បទនោះ គប្បីជ្រាបដោយអំណាចនៃធម៌ទាំងឡាយ មានខន្ធជាដើមនោះឯង ។ ក្នុងបញ្ហាទាំងឡាយដែលមានសភាពយ៉ាងនេះ សូម្បីខាងមុខ ក៏មានន័យនេះឯង ។ ព្រោះព្រះមានព្រះភាគ ទ្រង់សម្ដែងដោយសរុបហើយក្នុងបញ្ហាដើម ទើបខាងមុខទ្រង់សង្ខេបព្រះបាលី ។ បណ្ឌិតគប្បីជ្រាបការប្រកបអត្ថ ក្នុងទីទាំងពួងដោយន័យនេះ តែក្នុងទីណា បញ្ហាមិនទាន់ប្រាកដច្បាស់ ខ្ញុំនឹងអធិប្បាយធ្វើបញ្ហានោះ ឲ្យប្រាកដច្បាស់ក្នុងទីនោះឯង ។

បទថា **សោឡសហិ ធាតូហិ** អធិប្បាយថា ចក្ខុវិញ្ញាណធាតុ វៀរខ្លួនឯងមុនហើយ ប្រកបចូលគ្នាមិនបានជាមួយវិញ្ញាណធាតុ ៦ និងរូបធាតុ ១០ សូម្បីក្នុងធាតុដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។ បទថា **តីហិ ខន្ធេហិ** បានដល់ ខន្ធដ៏សេសទាំងឡាយវៀរសង្ខារក្ខន្ធ ។ បទថា **ឯកាយ ធាតុយា** បានដល់ មនោវិញ្ញាណធាតុ ព្រោះថា ការប្រកបសមុទយសច្ចនិងមគ្គសច្ចចូលគ្នាជាមួយធាតុដទៃ រមែងមិនបាន ។ បទថា **ឯកេន ខន្ធេន** បានដល់ សង្ខារក្ខន្ធ ។ បទថា **ឯកេនាយតនេន** បានដល់ ធម្មាយតនៈ ។

បទថា **ឯកាយ ធាតុយា** បានដល់ ធម្មធាតុ ។ បណ្ដាសច្ចៈទាំងនោះ សច្ចៈទាំង ២ នោះប្រកបចូលគ្នាបានជាមួយខន្ធ អាយតនៈ ធាតុណាមួយ ។

ក្នុងបញ្ហាពោលដោយសុខិន្ទ្រិយជាដើម បទថា **តីហិ** បានដល់ សញ្ញា សង្ខារ និងវិញ្ញាណ ។ បទថា **ឯកាយ ធាតុយា** បានដល់ កាយវិញ្ញាណ-ធាតុ ឬមនោវិញ្ញាណធាតុ ។ បទថា **ឆហិ ធាតូហិ** បានដល់ វៀរលែងតែកាយវិញ្ញាណធាតុ ។

ក្នុងបញ្ហាពោលដោយរូបភព ព្រះមានព្រះភាគ ត្រាស់ថា **ន កេហិចិ** ដូច្នេះ ព្រោះអរូបក្ខន្ធ និងអរូបាយតនៈទាំងអស់មាន តែក្នុងបញ្ហាពោលដោយអរូបភពទ្រង់ត្រាស់ថា **តីហិ ធាតូហិ វិប្បយុត្តោ** ព្រោះឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុទាំងឡាយមិនមាន ។

ក្នុងបញ្ហាពោលដោយអធិមោក្ខ បទថា **ទ្វីហិ ធាតូហិ** បានដល់ មនោ-ធាតុ និងមនោវិញ្ញាណធាតុ ។ បទថា **បន្នរសហិ** បានដល់ រូបធាតុ ១០ ដ៏សេស និងវិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម ។

ក្នុងបញ្ហាពោលអំពីកុសល ព្រះមានព្រះភាគ ទ្រង់បដិសេធការប្រកបចូលគ្នាបាន ព្រោះខន្ធទាំង ៤ ត្រូវកុសលទាំងឡាយកាន់យកហើយ ។

ក្នុងបញ្ហាពោលអំពីវេទនាតិកៈ បទថា **ឯកេន ខន្ធេន** បានដល់ វេទនា-ខន្ធប៉ុណ្ណោះ ។ បទថា **បន្នរសហិ** បានដល់ ចក្ខុវិញ្ញាណធាតុ សោត-វិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ មនោធាតុ និងរូបធាតុទាំងឡាយ ។ បទថា **ឯកាទសហិ** បានដល់ រូបធាតុទាំងឡាយ ( ឱឡា-

វិកធាតុ ១០ ) និងកាយវិញ្ញាណធាតុ ១ ។

ក្នុងបញ្ហាពោលដោយនេវវិបាកនវិបាកធម្មធម្មា បទថា **បញ្ចហិ** បានដល់ ដោយបញ្ចវិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម ។

ក្នុងបញ្ហាពោលអំពីអនុបាទិន្នអនុបាទានិយ បទថា **ឆហិ** បានដល់ ធាតុ ៦ វៀរមនោវិញ្ញាណធាតុ ។

ក្នុងបញ្ហាពោលអំពីសវិតក្កសវិចារ បទថា **បន្នរសហិ** បានដល់ រូបធាតុទាំងឡាយ ( ឱឡារិកធាតុ ១០ ) និងបញ្ចវិញ្ញាណធាតុ ។

ក្នុងបញ្ហាពោលអំពីអវិតក្កវិចារមត្ត បទថា **ឯកេន ខន្ធេន** ជាដើម បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃសង្ខារក្ខន្ធ ។ ពិតហើយ វៀរវិចារក្នុងទុតិយជ្ឈាន ធម៌ដ៏សេស ឈ្មោះថា មិនមានវិតក្ក មានត្រឹមតែវិចារ ។ វៀរបីតិហើយ ធម៌ដ៏សេស ឈ្មោះថា បីតិសហគតធម៌ ។ ក្នុងបញ្ហានេះ វិចារមិនសម្បយុត្តជាមួយវិចារ បីតិក៏មិនសម្បយុត្តជាមួយបីតិ ព្រោះហេតុនោះទើបធម៌ទាំងនេះ ឈ្មោះថា សម្បយុត្តដោយធម៌ណាមួយ ក្នុងសង្ខារក្ខន្ធ ធម្មាយតនៈ និងធម្មធាតុ ។ បទថា **សោឡសហិ** បានដល់ ធាតុទាំងឡាយ ១៦ វៀរលែងតែធម្មធាតុ និងមនោវិញ្ញាណធាតុ ។

ក្នុងបញ្ហាពោលអំពីអវិតក្កអវិចារ បទថា **ឯកាយ ធាតុយា** បានដល់ មនោធាតុ ។ សុខសហគតធម៌ និងឧបេក្ខាសហគតធម៌ ត្រាស់ក្នុងវេទនាត្តិកៈនោះឯង ។ ទស្សនេនបហាតព្វធម៌ជាដើម ក៏ដូចគ្នានឹងកុសលនោះឯង ។ បរិត្តារម្មណ៍ ដូចគ្នានឹងវិបាកធម៌ ។ បទថា **ឯកាយ ធាតុយា** បានដល់

ធម្មធាតុ ។ បទថា **កេហិចិ** សេចក្តីថា ធម៌ទាំងឡាយណាមិនជាបរិត្តារម្មណ៍ក្នុងបទនោះ ប្រកបចូលគ្នាមិនបានជាមួយធម៌ទាំងនោះ តែធម្មធាតុ រមែងចាត់ចូលជាមួយពាក្យដែលបដិសេធក្នុងបទដំបូងនោះឯង ព្រោះសង្គ្រោះចូលគ្នាបានជាមួយខន្ធ ៤ ដោយអំណាចនៃចិត្តុប្បាទ ៦ ដួង ដែលជាបរិត្តា-រម្មណ៍ ។ មហគ្គតារម្មណ៍ជាដើម ដូចគ្នានឹងធម៌ដែលជាកុសលនោះឯង ។ ក្នុងអនុប្បន្នធម៌ទាំងឡាយ បទថា **បញ្ចហិ ធាតូហិ** បានដល់ វិញ្ញាណធាតុ ៥ មានចក្ខុវិញ្ញាណធាតុជាដើម ។ ឯវិញ្ញាណធាតុទាំង ៥ នោះ ជាឧប្បាទិធម៌ដោយចំណែកមួយប៉ុណ្ណោះ តែរាប់បញ្ចូលក្នុងចំណែកនៃឧប្បន្នធម៌បាន ។ ធម៌ដែលជាបច្ចុប្បន្នារម្មណ៍ជាដើម ដូចគ្នានឹងធម៌ដែលជាបរិត្តារម្មណ៍ ។ ធម៌ដែលជាហេតុជាដើម ដូចគ្នានឹងធម៌ដែលជាសមុទយៈនោះឯង ។ សហេតុកៈ អហេតុកធម៌ ក៏ដូចគ្នានឹងបីតិសហគតធម៌នោះឯង ។ បរាមាសសម្បយុត្តធម៌ ក៏ដូចគ្នា ។ អនុបាទិន្នធម៌ ក៏ដូចគ្នានឹងអនុប្បន្នធម៌នោះឯង ។ ធម៌ដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។ល។

## អដ្ឋកថាសម្បយោគវិប្បយោគបទ ចប់

# អភិធម្មបិដក

## សម្បយុត្តេន វិប្បយុត្តបទនិទ្ទេស

[ ៣០២ ] ពួកធម៌ណាប្រកបដោយវេទនាខន្ធ ពួកធម៌ណាប្រកបដោយសញ្ញាខន្ធ ពួកធម៌ណាប្រកបដោយសង្ខារក្ខន្ធ ពួកធម៌ណាប្រកបដោយវិញ្ញាណ ពួកធម៌ណាប្រកបដោយមនាយតនៈ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ ប្រាសចាកខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ធម៌ទាំងនោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣០៣ ] ពួកធម៌ណា ប្រកបដោយចក្ខុវិញ្ញាណធាតុ ។បេ។ ពួកធម៌ណាប្រកបដោយមនោធាតុ ពួកធម៌ណាប្រកបដោយមនោវិញ្ញាណធាតុ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៣០៤ ] ពួកធម៌ណា ប្រកបដោយមនិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣០៥ ] ពួកធម៌ណា ប្រកបដោយឧបេក្ខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ៣០៦ ] ពួកធម៌ណាប្រកបដោយវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ពួកធម៌ណាប្រកបដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណាប្រកប

ដោយវេទនា ព្រោះផស្សៈជាបច្ច័យ ពួកធម៌ណាប្រកបដោយផស្សៈ ពួកធម៌ណាប្រកបដោយវេទនា ពួកធម៌ណាប្រកបដោយសញ្ញា ពួកធម៌ណាប្រកបដោយចេតនា ពួកធម៌ណាប្រកបដោយចិត្ត ពួកធម៌ណាប្រកបដោយមនសិការ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣០៧ ] ពួកធម៌ណាប្រកបដោយអធិមោក្ខ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៣០៨ ] ពួកធម៌ណាប្រកបដោយពួកធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណាប្រកបដោយធម៌ ដែលប្រទ្បំដោយឧបេក្ខា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ៣០៩ ] ពួកធម៌ណាប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៣១០ ] ពួកធម៌ណាប្រកបដោយធម៌ គឺចិត្ត ពួកធម៌ណាប្រកបដោយធម៌ គឺចេតសិក ពួកធម៌ណាប្រកបដោយធម៌ដែលប្រកបដោយចិត្ត ពួកធម៌

ណាប្រកបដោយធម៌ដែលប្រឡំដោយចិត្ត ពួកធម៌ណាប្រកបដោយធម៌ដែលប្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណាប្រកបដោយធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ណាប្រកបដោយធម៌ ដែលប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣១១ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិចារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៣១២ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំដោយឧបេក្ខា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ទាំងនោះ ប្រាសចាកខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌ទាំងនោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

ខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ឥន្ទ្រិយ ២ បដិច្ចសមុប្បាទ ៣ ធម៌ទាំងឡាយ មានផស្សៈជាគម្រប់ ៥ អធិមោក្ខ មនសិការ ពួកធម៌ ៣ ក្នុងតិកៈទាំងឡាយ ពួកធម៌ ៧ និងធម៌ ២ ក្នុងចន្លោះ ប្រកបដោយចិត្ត ប្រកបដោយវិតក្ក វិចារ និងឧបេក្ខា ។

**សម្បយុត្តេន វិប្បយុត្តបទនិទ្ទេស ចប់**

# អដ្ឋកថា

## សម្បយុត្តវិប្បយុត្តបទ

[ ៣០២-៣១២ ] ឥឡូវនេះ ដើម្បីចែកបទនៃធម៌ ដែលប្រកបចូលគ្នាមិនបានជាមួយធម៌ដែលប្រកបចូលគ្នាបាន ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **វេទនាក្ខន្ធេន** ជាដើម ។ ក្នុងបទនេះ មានលក្ខណៈដូចតទៅនេះថា ក្នុងវារៈនេះ ធម៌ទាំងឡាយណា ប្រកបដោយបទដែលលើកឡើងសម្ដែងជាពាក្យសួរ គឺធម៌ពួកណាប្រកបដោយធម៌ទាំងនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើបុច្ឆាវិសជ្ជនានូវការប្រកបធម៌ទាំងនោះ ចូលគ្នាមិនបានជាមួយខន្ធជាដើម ។ បទ ( សម្បយុត្តវិប្បយុត្ត ) នោះ រមែងមិនគួរក្នុងធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ។ ព្រោះធម៌ទាំងឡាយ ឈ្មោះថា ប្រកបចូលគ្នាបានជាមួយរូបក្ខន្ធ រមែងមិនមាន ព្រោះហេតុនោះ ពាក្យនោះផង ពាក្យដទៃមានសភាពយ៉ាងនេះផង ព្រះមានព្រះភាគទ្រង់មិនកាន់យកក្នុងវារៈនេះ ។ ឯបទណាចុះបញ្ចាំងដល់ធម៌ទាំងឡាយ ដែលប្រកបចូលគ្នាបានជាមួយធម្មធាតុ និងដល់វិញ្ញាណដែលមិនលាយឡំដោយធម៌ដទៃ ព្រះមានព្រះភាគទ្រង់កាន់យកធម៌ទាំងនោះក្នុងវារៈនេះ ។ គប្បីជ្រាបការប្រមួលពាក្យទាំងនោះដូចតទៅនេះ

ខន្ធ ៤ អាយតនៈ ១ ( មនាយតនៈ ) ឥន្ទ្រិយ ២ ( មនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ ) បដិច្ចសមុប្បាទ ៣ ( វិញ្ញាណ ផស្សៈ និងវេទនា ) ពួក ៧ នៃធម៌ មានផស្សៈជាដើម តិកមាតិកា ៣ ( អនុក្ខមសុខាយវេទនាយបទ សវិតក្កសវិចារបទ ឧបេក្ខាសហគតបទ ) មហន្តរទុកៈ ៧ ( ចិត្តបទ

ចេតសិកបទ សម្បយុត្តបទ ចិត្តសម្បយុត្តបទ ចិត្តសំសដ្ឋ-
បទ ចិត្តសំសដ្ឋសមុដ្ឋានសហភូបទ ចិត្តសំសដ្ឋានានុបរិវត្តិ-
បទ ) សវិតក្កបទ ១ សវិចារបទ ១ ឧបេក្ខាសហគតបទ
ដែលប្រកបដោយឧបេក្ខាវេទនា ១ ( រួមជា ៣៧ បទ )
ដូច្នេះ ។

ក្នុងវគ្គចុងក្រោយ ទ្រង់សង្គ្រោះអត្ថនោះឯង ដោយបទថា **១ន្ធា ចតុរោ** ជាដើម ។ ក្នុងនិទ្ទេសនោះ បទពួកណា មានពាក្យវិសជ្ជនាទំនង់តែមួយ លោកសង្គ្រោះបទទាំងនោះ ឆ្លាស់លំដាប់គ្នា ធ្វើបញ្ហាដែលមានវេទនាខន្ធជាដើមទុកក្នុងទីនោះ ។ ក្នុងបញ្ហាទាំងនោះ គប្បីជ្រាបការចែកខន្ធជាដើមយ៉ាងនេះ ។

ក្នុងបញ្ហាពោលដោយវេទនាខន្ធជាដើម បទថា **ឯកេន** បានដល់ មនាយតនៈ ។ បទថា **សត្តហិ** បានដល់ វិញ្ញាណធាតុ ៧ ។ បទថា **កេហិចិ** បានដល់ វេទនាក្នុងធម្មាយតនៈជាដើម ។

ក្នុងបញ្ហាពោលដោយវិញ្ញាណធាតុ បទថា **តេ ធម្មា ន កេហិចិ** សេចក្ដីថា ធម៌ គឺវិញ្ញាណធាតុ ៦ ដ៏សេស រូប និងនិព្វានទាំងនោះ វៀរវិញ្ញាណធាតុ ដែលលើកឡើងជាពាក្យសួរ មិនមែនប្រកបចូលគ្នាមិនបានជាមួយខន្ធ ឬអាយតនៈណាមួយ ព្រោះខន្ធ និងអាយតនៈទាំងអស់នោះនៅសង្គ្រោះចូលគ្នាបានជាមួយធម៌ទាំងនោះ ។ បទថា **ឯកាយ ធាតុយា** បានដល់ ធាតុណាមួយដែលលើកឡើងជាពាក្យសួរ ប្រកបចូលគ្នាមិនបានជាមួយ

*ជាតុនោះៗ ។*

*ក្នុងបញ្ហាពោលដោយឧបេក្ខិន្ទ្រិយ បទថា* **បញ្ចហិ** *បានដល់ ចក្ខុ-វិញ្ញាណធាតុដែលសម្បយុត្តដោយឧបេក្ខាជាដើម ។ ដោយន័យនេះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយអំណាចនៃបទទាំងឡាយ ដែលប្រកបជាមួយគ្នាមិនបាន ជាមួយពាក្យដែលលើកឡើងជាពាក្យសួរ ដោយប្រការដូច្នេះឯង ។៚*

**អដ្ឋកថាសម្បយុត្តេនវិប្បយុត្តបទ ចប់**

# អភិធម្មបិដក

## វិប្បយុត្តេន សម្បយុត្តបទនិទ្ទេស

[ ៣១៣ ] ពួកធម៌ណា ប្រាសចាករូបក្ខន្ធ ពួកធម៌ទាំងនោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។

[ ៣១៤ ] ពួកធម៌ណា ប្រាសចាកវេទនាខន្ធ ពួកធម៌ណា ប្រាសចាកសញ្ញាខន្ធ ពួកធម៌ណា ប្រាសចាកសង្ខារក្ខន្ធ ពួកធម៌ណា ប្រាសចាកវិញ្ញាណក្ខន្ធ ។បេ។ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយសត្រូវ ពួកធម៌ណា ប្រាសចាកធម៌មិនប្រកបដោយសត្រូវ ពួកធម៌ទាំងនោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។

*វិប្បយុត្តេន សម្បយុត្តបទនិទ្ទេស ចប់*

# អដ្ឋកថា

## វិប្បយុត្តេនសម្បយុត្តបទ

[ ៣១៣-៣១៤ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលប្រកបចូលគ្នាបានជា-មួយធម៌ដែលប្រកបចូលគ្នាមិនបាន ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **រូបក្ខន្ធេន** ជាដើម ។ បុច្ឆាទាំងអស់ក្នុងបទទាំងនោះ ជាមោឃបុច្ឆានោះឯង ព្រោះថា នាមក្ខន្ធ ៤ ឈ្មោះថា ប្រកបចូលគ្នាមិនបានជាមួយរូបក្ខន្ធ ។ ការប្រកបធម៌ទាំងនោះចូលគ្នាជាមួយធម៌ពួកដទៃរមែងមិនមាន ។ រូប និងនិព្វានប្រកបចូលគ្នាមិនបានជាមួយវេទនាខន្ធ ការប្រកបរូប និងនិព្វានទាំងនោះ ចូលជាមួយធម៌ណាមួយរមែងមិនមាន ។ ក្នុងបទទាំងពួងក៏យ៉ាងនេះ ។ បណ្ឌិតគប្បីជ្រាបការមិនមានការប្រកបចូលគ្នាបាននៃធម៌ ដែលប្រកបចូលគ្នាមិនបាន ( យ៉ាងនេះ ) ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **នត្ថិ នត្ថិ** នោះឯង ។ ក្នុងពាក្យវិសជ្ជនាបញ្ហាទាំងអស់ ព្រោះភាពជាមោឃនៃពាក្យបុច្ឆា ដូចពណ៌នាមក ដូច្នេះឯង ។

**អដ្ឋកថាវិប្បយុត្តេនសម្បយុត្តបទ ចប់**

# អភិធម្មបិដក

## សម្បយុត្តេន សម្បយុត្តបទនិទ្ទេស

[ ៣១៥ ] ពួកធម៌ណាប្រកបដោយវេទនាខន្ធ ពួកធម៌ណាប្រកបដោយសញ្ញាខន្ធ ពួកធម៌ណាប្រកបដោយសង្ខារក្ខន្ធ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣១៦ ] ពួកធម៌ណា ប្រកបដោយវិញ្ញាណក្ខន្ធ ពួកធម៌ណា ប្រកបដោយមនាយតនៈ ពួកធម៌ណា ប្រកបដោយចក្ខុវិញ្ញាណធាតុ ។បេ។ ពួកធម៌ណា ប្រកបដោយមនោធាតុ ពួកធម៌ណា ប្រកបដោយមនោវិញ្ញាណធាតុ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣១៧ ] ពួកធម៌ណា ប្រកបដោយសមុទយសច្ច ពួកធម៌ណា ប្រកបដោយមគ្គសច្ច ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣១៨ ] ពួកធម៌ណាប្រកបដោយមនិន្ទ្រិយ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣១៩ ] ពួកធម៌ណា ប្រកបដោយសុខិន្ទ្រិយ ពួកធម៌ប្រកបដោយទុក្ខិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រកបដោយទោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២០ ] ពួកធម៌ណា ប្រកបដោយឧបេក្ខិន្ទ្រិយ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៦ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២១ ] ពួកធម៌ណា ប្រកបដោយសទ្ធិន្ទ្រិយ ពួកធម៌ណា ប្រកបដោយវីរិយិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសតិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសមាធិន្ទ្រិយ ពួកធម៌ណា ប្រកបដោយបញ្ញិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអញ្ញិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអវិជ្ជា ពួកធម៌ណា ប្រកបដោយសង្ខារព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២២ ] ពួកធម៌ណា ប្រកបដោយវិញ្ញាណព្រោះសង្ខារជាបច្ច័យ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៣ ] ពួកធម៌ណា ប្រកបដោយផស្សៈព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៤ ] ពួកធម៌ណា ប្រកបដោយវេទនាព្រោះផស្សៈជាបច្ច័យ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៥ ] ពួកធម៌ណា ប្រកបដោយតណ្ហាព្រោះវេទនាជាបច្ច័យ ពួកធម៌ណា ប្រកបដោយឧបាទានព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា ប្រកបដោយកម្មភព ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៦ ] ពួកធម៌ណា ប្រកបដោយសោក ពួកធម៌ណា ប្រកបដោយទុក្ខ ពួកធម៌ណា ប្រកបដោយទោមនស្ស ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៧ ] ពួកធម៌ណា ប្រកបដោយឧបាយាស ពួកធម៌ណា ប្រកបដោយសតិប្បដ្ឋាន ពួកធម៌ណា ប្រកបដោយសម្មប្បធាន ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១

ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៨ ] ពួកធម៌ណា ប្រកបដោយឥទ្ធិបាទ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ២ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣២៩ ] ពួកធម៌ណា ប្រកបដោយឈាន ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ២ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣០ ] ពួកធម៌ណា ប្រកបដោយអប្បមញ្ញា ពួកធម៌ណា ប្រកបដោយឥន្ទ្រិយ ៥ ពួកធម៌ណា ប្រកបដោយពល ៥ ពួកធម៌ណា ប្រកបដោយពោជ្ឈង្គ ៧ ពួកធម៌ណា ប្រកបដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា ប្រកបដោយពួកធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣១ ] ពួកធម៌ណា ប្រកបដោយផស្សៈ ពួកធម៌ណា ប្រកបដោយចេតនា ពួកធម៌ណា ប្រកបដោយមនសិការ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣២ ] ពួកធម៌ណា ប្រកបដោយវេទនា ពួកធម៌ណា ប្រកបដោយសញ្ញា ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ

៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និង ធម៌ពួកខ្លះក៏មាន ។

[ ៣៣៣ ] ពួកធម៌ណាប្រកបដោយចិត្ត ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣៤ ] ពួកធម៌ណាប្រកបដោយអធិមោក្ខ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ២ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣៥ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយសុខវេទនា ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣៦ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ពួកធម៌ណា ប្រកបដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។

[ ៣៣៧ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយសុខ ពួកធម៌

ណា ប្រកបដោយធម៌ ដែលប្រឡំដោយឧបេក្ខា ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣៨ ] ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៣៩ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រកបដោយធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។

[ ៣៤០ ] ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៤១ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយអាសវៈ តែ

មិនមែនអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។

[ ៣៤២ ] ពួកធម៌ណា ប្រកបដោយធម៌ជាសញ្ញោជនៈ ជាគន្ថៈ ជាឱឃៈ ជាយោគៈ ជានីវរណៈ ជាបរាមាស ពួកធម៌ណា ប្រកបដោយធម៌ជាបរាមាស ទាំងបរាមាសស្ទាបអង្អែល ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៤៣ ] ពួកធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយបរាមាស ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។

[ ៣៤៤ ] ពួកធម៌ណា ប្រកបដោយធម៌ គឺចិត្ត ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៤៥ ] ពួកធម៌ណា ប្រកបដោយធម៌ គឺចេតសិក ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយចិត្ត ពួកធម៌ណា ប្រកបដោយធម៌ ដែលច្រឡំដោយចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹង

ចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្ត ទៅតាមចិត្ត ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកប ដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។

[ ៣៤៦ ] ពួកធម៌ណាប្រកបដោយធម៌ជាឧបាទាន ពួកធម៌ណាប្រកប ដោយធម៌ជាកិលេស ពួកធម៌ណាប្រកបដោយធម៌ជាកិលេស ទាំងជាធម៌គួរ ដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណាប្រកបដោយធម៌ជាកិលេស ទាំងជាធម៌ សៅហ្មងហើយ ពួកធម៌ណាប្រកបដោយធម៌ជាកិលេស ទាំងប្រកបដោយ កិលេស ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយ ខន្ធ ៣ អាយតនៈ ១ ធាតុ ១ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៤៧ ] ពួកធម៌ណា ប្រកបដោយធម៌ដែលសៅហ្មងហើយ តែមិន មែនកិលេស ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយកិលេស តែ មិនមែនកិលេស ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ពួក ធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយវិចារ ពួកធម៌ណា ប្រកប ដោយធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំ ដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះប្រកបដោយ ខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះ ។

[ ៣៤៨ ] ពួកធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយសុខ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយឧបេក្ខា ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយខន្ធ ១ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

## សម្បយុត្តេន សម្បយុត្តបទនិទ្ទេស ចប់

# អដ្ឋកថា

## សម្បយុត្តេនសម្បយុត្តបទ

[ ៣១៥-៣៤៦ ] ឥឡូវនេះ ដើម្បីចែកបទនៃធម៌ដែលប្រកបចូលគ្នាបាន ជាមួយនឹងធម៌ដែលប្រកបចូលគ្នាបាន ទើបព្រះមានព្រះភាគ ផ្ដើមពាក្យថា **វេទនាខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ បទណាប្រកបចូលគ្នាបានដោយអំណាចនៃខន្ធជាដើម ព្រះមានព្រះភាគទ្រង់ធ្វើបុច្ឆាវិសជ្ជនានូវការប្រកបបទនោះឯង ចូលគ្នាបានជាមួយខន្ធជាដើមទៀត ។ បទនោះរមែងមិនគួរជាមួយរូប ឬបទទាំងឡាយ ដែលលាយឡំដោយរូប ឬបទដែលសង្គ្រោះចូលក្នុងរូបក្ខន្ធទាំងអស់ ព្រោះថា ការប្រកបធម៌ពួកដទៃចូលជាមួយរូប ឬវត្ថុដែលលាយឡំដោយរូប រមែងមិនមាន ។ បទដទៃក៏មិនមានដូចគ្នា ព្រោះខន្ធជាដើម ដែលគួរដល់ការប្រកបចូលគ្នាទាំងអស់ លោកកាន់យកដោយពាក្យដែលសង្គ្រោះចូលក្នុងអរូបក្ខន្ធទាំងអស់ ។ បទណា គប្បីដល់នូវការប្រកបជាមួយបទនោះ ព្រោះហេតុនោះ ទើបបទនោះទ្រង់មិនកាន់យកក្នុងទីនេះ តែបទទាំងឡាយណា ធ្វើបញ្ចាំងដល់ចំណែកខ្លះនៃអរូប ដែលមិនលាយឡំដោយរូប បទទាំងឡាយនោះ ទ្រង់កាន់យកក្នុងនិទ្ទេសនេះ ។ គប្បីជ្រាបការរួបរួមបទទាំងនោះដូចតទៅនេះ

នាមក្ខន្ធ ៤ មនាយតនៈ ១ វិញ្ញាណធាតុ ៧ សច្ចៈ ២ ( សមុទយសច្ច និងមគ្គសច្ច ) ឥន្ទ្រិយ ១៤ ( មនិន្ទ្រិយ ជាដើមរហូតដល់អញ្ញាតាវិន្ទ្រិយជាទីបំផុត ) បដិច្ចសមុប្បាទ ១២ បន្ទាប់អំពីបដិច្ចសមុប្បាទនោះមានធម៌ ១៦ ( សតិប្បដ្ឋាន

ជាដើម រហូតដល់មនសិការជាទីបំផុត ) ក្នុងតិកៈ ៨ ( វេទនាតិកៈ ៣ វិតក្កតិកៈ ២ គឺបឋមបទ និងទុតិយបទ និង បីតិតិកៈ ៣ ) ក្នុងគោច្ឆកៈ ៤៣ បទ ( ហេតុគោច្ឆកៈ ៦ អាសវគោច្ឆកៈ ៤ សញ្ញោជនគោច្ឆកៈ ៤ គន្ថគោច្ឆកៈ ៨ ឱឃគោច្ឆកៈ ៤ យោគគោច្ឆកៈ ៤ នីវរណគោច្ឆកៈ ៤ បរាមាសគោច្ឆកៈ ៣ ឧបាទានគោច្ឆកៈ ៤ កិលេសគោច្ឆកៈ ៦ ) ក្នុងមហន្តរទុកៈ ៧ ( ចិត្តបទ ចេតសិកបទ ចិត្ត-សម្បយុត្តបទ ចិត្តសំសដ្ឋបទ ចិត្តសំសដ្ឋសមុដ្ឋានបទ ចិត្តសំសដ្ឋសមុដ្ឋានសហភូបទ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិបទ ) ក្នុងបិដ្ឋិទុកៈ ៦ ( សវិតក្កបទ សវិចារបទ សប្បីតិកបទ បីតិសហគតបទ សុខសហគតបទ ឧបេក្ខាសហគតបទ ) ធម៌ទាំងឡាយ ( ១២០ បទ ) ដល់នូវការសង្គ្រោះនៃបទទី ៩ ដូច្នេះ ។

ក្នុងបញ្ហាទាំងពួង ធម៌ទាំងឡាយណា ទ្រង់លើកឡើងជាពាក្យសួរ ធម៌ទាំងនោះប្រកបដោយធម៌ពួកណាមាន បណ្ឌិតគប្បីជ្រាបប្រភេទនៃធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ព្រោះថា នាមក្ខន្ធ ៣ ក្រៅអំពីនេះប្រកបចូលគ្នាបានជាមួយវេទនាខន្ធ វេទនាខន្ធក៏ប្រកបចូលគ្នាបានជាមួយ

ខន្ធទាំងនោះវិញ គឺវេទនាខន្ធនោះប្រកបចូលគ្នាបានជាមួយខន្ធទាំង ៣ នោះ មានសញ្ញាខន្ធជាដើម ជាមួយមនាយតនៈ ១ ជាមួយវិញ្ញាណធាតុ ៧ និង ប្រកបចូលគ្នាបានជាមួយសញ្ញា និងសង្ខារទាំងឡាយខ្លះយ៉ាងនោះឯង ក្នុង ធម្មាយតនៈ ១ និងធម្មធាតុ ១ ។ ក្នុងទីទាំងពួង ក៏មានន័យនេះឯង ដូច្នេះ ។ល។

## អដ្ឋកថាសម្បយុត្តេនសម្បយុត្តបទ ចប់

# អភិធម្មបិដក

## វិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស

[ ៣៤៩ ] ពួកធម៌ណា ប្រាសចាករូបក្ខន្ធ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥០ ] ពួកធម៌ណា ប្រាសចាកវេទនាខន្ធ ពួកធម៌ណា ប្រាសចាកសញ្ញាខន្ធ ពួកធម៌ណា ប្រាសចាកសង្ខារក្ខន្ធ ពួកធម៌ណា ប្រាសចាកវិញ្ញាណក្ខន្ធ ពួកធម៌ណា ប្រាសចាកមនាយតនៈ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥១ ] ពួកធម៌ណា ប្រាសចាកចក្ខាយតនៈ ។បេ។ ពួកធម៌ណា ប្រាសចាកផោដ្ឋព្វាយតនៈ ពួកធម៌ណា ប្រាសចាកចក្ខុធាតុ ។បេ។ ពួកធម៌ណា ប្រាសចាកផោដ្ឋព្វធាតុ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥២ ] ពួកធម៌ណា ប្រាសចាកចក្ខុវិញ្ញាណធាតុ ។បេ។ ពួកធម៌ណា ប្រាសចាកមនោធាតុ ពួកធម៌ណា ប្រាសចាកមនោវិញ្ញាណធាតុ ពួកធម៌ណា ប្រាសចាកសមុទយសច្ច ពួកធម៌ណា ប្រាសចាកមគ្គសច្ច ពួកធម៌ណា ប្រាស

ចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៣ ] ពួកធម៌ណា ប្រាសចាកនិរោធសច្ច ពួកធម៌ណា ប្រាសចាកចក្ខុន្ទ្រិយ ។បេ។ ពួកធម៌ណា ប្រាសចាកកាយិន្ទ្រិយ ពួកធម៌ណា ប្រាសចាកឥត្ថិន្ទ្រិយ ពួកធម៌ណា ប្រាសចាកបុរិសិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៤ ] ពួកធម៌ណា ប្រាសចាកមនិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៥ ] ពួកធម៌ណា ប្រាសចាកសុខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកទុក្ខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រាសចាកទោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៦ ] ពួកធម៌ណា ប្រាសចាកឧបេក្ខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៧ ] ពួកធម៌ណា ប្រាសចាកសទ្ធិន្ទ្រិយ ពួកធម៌ណា ប្រាសចាក

វីរិយិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសតិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសមា-ធិន្ទ្រិយ ពួកធម៌ណា ប្រាសចាកបញ្ញិន្ទ្រិយ ពួកធម៌ណា ប្រាសចាកអនញ្ញ-តញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា ប្រាសចាកអញ្ញិន្ទ្រិយ ពួកធម៌ណា ប្រាសចាក អញ្ញាតាវិន្ទ្រិយ ពួកធម៌ណា ប្រាសចាកអវិជ្ជា ពួកធម៌ណា ប្រាសចាកសង្ខារ ទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួក ធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាស ចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៨ ] ពួកធម៌ណា ប្រាសចាកវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ពួក ធម៌ណា ប្រាសចាកផស្សៈព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា ប្រាស ចាកវេទនាព្រោះផស្សៈជាបច្ច័យ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួក ធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាក អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៥៩ ] ពួកធម៌ណា ប្រាសចាកតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ ណា ប្រាសចាកឧបាទានព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា ប្រាសចាក កម្មភព ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦០ ] ពួកធម៌ណា ប្រាសចាករូបភព ពួកធម៌ណា ប្រាសចាកធម៌ ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាក

អាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៣ ។

[ ៣៦១ ] ពួកធម៌ណា ប្រាសចាកអសញ្ញាភព ពួកធម៌ណា ប្រាសចាកឯកវោការភព ពួកធម៌ណា ប្រាសចាកសេចក្ដីខ្សឹកខ្សួល ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦២ ] ពួកធម៌ណា ប្រាសចាកអរូបភព ពួកធម៌ណា ប្រាសចាកនេវសញ្ញានាសញ្ញាភព ពួកធម៌ណា ប្រាសចាកចតុវោការភព ពួកធម៌ណាប្រាសចាកសេចក្ដីសោក ពួកធម៌ណា ប្រាសចាកសេចក្ដីទុក្ខ ពួកធម៌ណាប្រាសចាកទោមនស្ស ពួកធម៌ណាប្រាសចាកឧបាយាស ពួកធម៌ណា ប្រាសចាកសតិប្បដ្ឋាន ពួកធម៌ណា ប្រាសចាកសម្មប្បធាន ពួកធម៌ណា ប្រាសចាកឥទ្ធិបាទ ពួកធម៌ណា ប្រាសចាកឈាន ពួកធម៌ណា ប្រាសចាកអប្បមញ្ញា ពួកធម៌ណា ប្រាសចាកឥន្ទ្រិយ ៥ ពួកធម៌ណា ប្រាសចាកពល ៥ ពួកធម៌ណា ប្រាសចាកពោជ្ឈង្គ ៧ ពួកធម៌ណា ប្រាសចាកមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៣ ] ពួកធម៌ណា ប្រាសចាកផស្សៈ ពួកធម៌ណា ប្រាសចាកវេទនា ពួកធម៌ណា ប្រាសចាកសញ្ញា ពួកធម៌ណា ប្រាសចាកចេតនា ពួកធម៌ណា ប្រាសចាកចិត្ត ពួកធម៌ណា ប្រាសចាកមនសិការ ពួកធម៌ណា ប្រាសចាកធម៌

ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៤ ] ពួកធម៌ណា ប្រាសចាកអធិមោក្ខ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៥ ] ពួកធម៌ណា ប្រាសចាកពួកធម៌ជាកុសល ពួកធម៌ណា ប្រាសចាកពួកធម៌ជាអកុសល ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៦ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយសុខវេទនា ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៨ ] ពួកធម៌ណា ប្រាសចាកធម៌ជាវិបាក ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០

ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៦៩ ] ពួកធម៌ណា ប្រាសចាកធម៌មានវិបាកជាប្រក្រតី ពួកធម៌ណា ប្រាសចាកធម៌ដែលសៅហ្មងហើយ ទាំងគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧០ ] ពួកធម៌ណា ប្រាសចាកធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី ពួកធម៌ណា ប្រាសចាកធម៌ ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ៣៧១ ] ពួកធម៌ណា ប្រាសចាកធម៌ ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា ប្រាសចាកធម៌ដែលមិនសៅហ្មងហើយ ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៣៧២ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១

ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧៣ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧៤ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានវិតក្ក ទាំងមិនមានវិចារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៣៧៥ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយសុខ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧៦ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយឧបេក្ខា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ ដែលគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌ដែលមានហេតុ គួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ដែលមានហេតុ គួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌ជាគ្រឿងដល់នូវការ

សន្សំ ពួកធម៌ណា ប្រាសចាកធម៌ដែលដល់នូវការមិនសន្សំ ពួកធម៌ណា ប្រាសចាកធម៌ ជារបស់សេក្ខបុគ្គល ពួកធម៌ណា ប្រាសចាកធម៌ ជារបស់អសេក្ខបុគ្គល ពួកធម៌ណា ប្រាសចាកធម៌ដែលដល់នូវសភាពធំ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៧៨ ] ពួកធម៌ណា ប្រាសចាកធម៌ប្រមាណមិនបាន ពួកធម៌ណា ប្រាសចាកធម៌ដ៏ឧត្តម ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៣៧៩ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមានអារម្មណ៍តូចឆ្មារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨០ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌ណា ប្រាសចាកធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ណា ប្រាសចាកធម៌ថោកទាប ពួកធម៌ណា ប្រាសចាកធម៌ដែលមានសភាពខុស និងទៀង ពួកធម៌ណា ប្រាសចាកធម៌ដែលមានសភាពត្រូវ និងទៀង ពួកធម៌ណាប្រាសចាកធម៌ដែលមានមគ្គ ជាអារម្មណ៍ ពួកធម៌ណាប្រាសចាកធម៌ ដែលមានមគ្គជាហេតុ ពួកធម៌ណាប្រាសចាកធម៌ ដែលមានមគ្គជាអធិបតី ពួក

ធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨១ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនទាន់កើតឡើង ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ៣៨២ ] ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាអតីត ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៣ ] ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌ណា ប្រាសចាកធម៌ ដែលមានអារម្មណ៍ខាងក្នុង ពួកធម៌ណា ប្រាសចាកធម៌ដែលមានអារម្មណ៍ខាងក្រៅ ពួកធម៌ណា ប្រាសចាកធម៌ដែលមានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៤ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ពួកធម៌ណា ប្រាសចាកធម៌ ដែលមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ

ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៥ ] ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយហេតុ ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយហេតុ តែមិនមែនជាហេតុ ពួកធម៌ណា ប្រាសចាកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៦ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានបច្ច័យ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានបច្ច័យតាក់តែង ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយការឃើញ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយការប៉ះពាល់ ពួកធម៌ណា ប្រាសចាកធម៌ដែលមានរូប ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៧ ] ពួកធម៌ណា ប្រាសចាកធម៌ជាលោកុត្តរ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែន

ប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៣៨៨ ] ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈទាំងប្រកបដោយអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៨៩ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមែនអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៣៩០ ] ពួកធម៌ណា ប្រាសចាកធម៌ជាសំយោជនៈ ពួកធម៌ណា ប្រាសចាកធម៌ជាគន្ថៈ ពួកធម៌ណា ប្រាសចាកធម៌ជាឱឃៈ ពួកធម៌ណា ប្រាសចាកធម៌ជាយោគៈ ពួកធម៌ណា ប្រាសចាកធម៌ជានីវរណៈ ពួកធម៌ណា ប្រាសចាកធម៌ជាបរាមាស ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រកបដោយបរាមាស ពួកធម៌ណា ប្រាសចាកធម៌ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលហើយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏

មាន ៗ

[ ៣៩១ ] ពួកធម៌ណា ប្រាសចាកធម៌ដែលបរាមាស មិនស្ទាបអង្អែលហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលហើយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះមិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយតែប្រាសចាកធាតុ ៦ ៗ

[ ៣៩២ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ពួកធម៌ណា ប្រាសចាកធម៌ គឺចិត្ត ពួកធម៌ណា ប្រាសចាកធម៌ គឺចេតសិក ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំដោយចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ៗ

[ ៣៩៣ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានអារម្មណ៍ ពួកធម៌ណាប្រាសចាកធម៌ដែលប្រាសចាកចិត្ត ពួកធម៌ណាប្រាសចាកធម៌ដែលច្រឡំដោយចិត្ត ពួកធម៌ណាប្រាសចាកធម៌ដែលជាឧបាទា ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន

ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៩៤ ] ពួកធម៌ណា ប្រាសចាកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៥ ។

[ ៣៩៥ ] ពួកធម៌ណា ប្រាសចាកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ពួកធម៌ណា ប្រាសចាកធម៌ដែលសៅហ្មងហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយកិលេស ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ទាំងគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ទាំងសៅហ្មងហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ទាំងប្រកបដោយកិលេស ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយកិលេស តែមិនមែនកិលេស ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៩៦ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែ

ប្រាសចាកធាតុ ៦ ។

[ ៣៩៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ដែលគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៩៨ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយវិតក្ក ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រកបដោយវិចារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៣៩៩ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានវិតក្ក ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានវិចារ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ១ ។

[ ៤០០ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រឡំដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០១ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រឡំដោយសុខ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០២ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រឡំដោយឧបេក្ខា ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១១ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០៣ ] ពួកធម៌ណា ប្រាសចាកធម៌មិនមែនជាកាមាវចរ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនរាប់បញ្ចូលក្នុងវដ្ដៈ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនអាចវៀរខ្លួន ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ មិនមែនប្រាសចាកខន្ធណាមួយ មិនមែនប្រាសចាកអាយតនៈណាមួយឡើយ តែប្រាសចាកធាតុ ៦ ។

[ ៤០៤ ] ពួកធម៌ណា ប្រាសចាកធម៌ជារូបាវចរ ពួកធម៌ណា ប្រាសចាកធម៌ជាអរូបាវចរ ពួកធម៌ណា ប្រាសចាកធម៌ជាគ្រឿងចេញចាកវដ្ដៈ ពួកធម៌ណា ប្រាសចាកធម៌មានសភាពទៀង ពួកធម៌ណា ប្រាសចាកធម៌ជាសត្រូវ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌នោះ ប្រាសចាកខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

## វិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស ចប់

# អដ្ឋកថា
## វិប្បយុត្តេនវិប្បយុត្តបទ

[ ៣៨៩-៤០៤ ] ឥឡូវនេះ ដើម្បីចែកបទនៃធម៌ដែលប្រកបចូលគ្នាមិនបាន ជាមួយធម៌ដែលប្រកបចូលគ្នាមិនបាន ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **រូបក្ខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ពួកណា មានរូបក្ខន្ធជាដើម ដែលទ្រង់លើកឡើងសម្ដែងទុកក្នុងនិទ្ទេសនៃសម្បយោគវិប្បយោគ-បទ ។ ធម៌ទាំងនោះឯង ទ្រង់លើកឡើងសម្ដែងក្នុងពាក្យបុច្ឆាទាំងពួង ។ ឯបទទាំងឡាយដែលមកដោយលំដាប់ដទៃ ព្រោះទ្រង់រួមពាក្យវិសជ្ជនាដែលជាទំនងដូចគ្នា ។ បណ្ដាបទទាំងនោះ បទណា លើកឡើងជាពាក្យសួរ បទនោះ ប្រកបចូលគ្នាមិនបានជាមួយធម៌ពួកណា បណ្ឌិតគប្បីជ្រាបការចែកនូវធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ព្រោះថា ធម៌ទាំងឡាយ មានវេទនាជាដើម ប្រកបចូលគ្នាមិនបានជាមួយរូបក្ខន្ធ ឯរូបក្ខន្ធក៏ប្រកបចូលគ្នាមិនបានជាមួយធម៌ទាំងនោះ ។ សម្រាប់និព្វាន មានគតិដូចសុខុមរូបនោះឯង ។ រូបក្ខន្ធនោះ ប្រកបចូលគ្នាមិនបានជាមួយនាមក្ខន្ធ ៤ មនាយតនៈ ១ វិញ្ញាណធាតុ ៧ និងជាមួយធម៌ទាំងឡាយ មានវេទនាជាដើមណាមួយ ក្នុងធម្មាយតនៈ និងធម្មធាតុ ។ ក្នុងបទទាំងពួងក៏ន័យនេះឯង ។l៚

**អដ្ឋកថាវិប្បយុត្តេនវិប្បយុត្តបទ ចប់**

# អភិធម្មបិដក

## សង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

[ ៤០៥ ] ពួកធម៌ណា សង្គ្រោះដោយសមុទយសច្ច ពួកធម៌ណា សង្គ្រោះដោយមគ្គសច្ច ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០៦ ] ពួកធម៌ណា សង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយបុរិសិន្ទ្រិយ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០៧ ] ពួកធម៌ណា សង្គ្រោះដោយសុខិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយទុក្ខិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសោមនស្សិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយទោមនស្សិន្ទ្រិយ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌

ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០៨ ] ពួកធម៌ណា សង្គ្រោះដោយឧបេក្ខិន្ទ្រិយ ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ២ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤០៩ ] ពួកធម៌ណា សង្គ្រោះដោយសទ្ធិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយវីរិយិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសតិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយសមាធិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយបញ្ញិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអញ្ញិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា សង្គ្រោះដោយអវិជ្ជា ពួកធម៌ណា សង្គ្រោះដោយសង្ខារ ព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយឧបាទាន ព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា សង្គ្រោះដោយកម្មភព ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ

១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន

[ ៤១០ ] ពួកធម៌ណា សង្គ្រោះដោយសេចក្ដីខ្សឹកខ្សួល ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤១១ ] ពួកធម៌ណា សង្គ្រោះដោយសេចក្ដីសោកស្ដាយ ពួកធម៌ណា សង្គ្រោះដោយសេចក្ដីទុក្ខ ពួកធម៌ណា សង្គ្រោះដោយទោមនស្ស ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤១២ ] ពួកធម៌ណា សង្គ្រោះដោយឧបាយាស ពួកធម៌ណា សង្គ្រោះដោយសតិប្បដ្ឋាន ពួកធម៌ណា សង្គ្រោះដោយសម្មប្បធាន ពួកធម៌ណា សង្គ្រោះដោយអប្បមញ្ញា ពួកធម៌ណា សង្គ្រោះដោយឥន្ទ្រិយ ៥ ពួកធម៌ណា សង្គ្រោះដោយពល ៥ ពួកធម៌ណា សង្គ្រោះដោយពោជ្ឈង្គ ៧ ពួកធម៌ណា

សង្គ្រោះដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌ណា សង្គ្រោះដោយផស្សៈ ពួកធម៌ណា សង្គ្រោះដោយចេតនា ពួកធម៌ណា សង្គ្រោះដោយអធិមោក្ខ ពួកធម៌ណា សង្គ្រោះដោយមនសិការ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌ណា សង្គ្រោះដោយធម៌ជាអាសវៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាសញ្ញោជនៈ ពួកធម៌ណា សង្គ្រោះដោយពួកធម៌ជាគន្ថៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាឱឃៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាយោគៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជានីវរណៈ ពួកធម៌ណា សង្គ្រោះដោយធម៌ជាបរាមាស ពួកធម៌ណា សង្គ្រោះដោយធម៌ជាឧបាទាន ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងសៅហ្មងហើយ ពួកធម៌ណា សង្គ្រោះដោយធម៌ជាកិលេស ទាំងប្រកបដោយកិលេស ដោយខន្ធសង្គហៈ សង្គ្រោះដោយអាយតនសង្គហៈ សង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយ

ខន្ធ ៣ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រកបដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

## សង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ចប់

# អដ្ឋកថា

## សង្គហិតេនសម្បយុត្តវិប្បយុត្តបទ

[ ៤០៥-៤១២ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលប្រកបចូលគ្នាបាន ធម៌ដែលប្រកបចូលគ្នាមិនបាន ជាមួយធម៌ដែលសង្គ្រោះចូលគ្នាបាន ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **សមុទយសច្ចេន** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ពួកណា មានសមុទយសច្ចជាដើម ដែលទ្រង់លើកឡើងសម្ដែងហើយ ក្នុងនិទ្ទេសនៃពាក្យថា ការសង្គ្រោះមួយអន្លើដោយការសង្គ្រោះ ធម៌ទាំងនោះឯងទ្រង់លើកឡើងសម្ដែងក្នុងបុច្ឆាទាំងពួង ។ ចំណែកបទទាំងឡាយ ដែលមកដោយលំដាប់ដទៃ ព្រោះទ្រង់រួមពាក្យវិសជ្ជនាជាទំនងដូចគ្នា ។ ក្នុងពាក្យទាំងនោះ ធម៌ទាំងឡាយណា សង្គ្រោះចូលគ្នាបានជាមួយពាក្យ ដែលទ្រង់លើកឡើងសម្ដែងជាពាក្យសួរ ដោយខន្ធសង្គហៈជាដើម ការប្រកបចូលគ្នាបាន ឬការប្រកបចូលគ្នាមិនបាននៃធម៌ទាំងនោះ ជាមួយធម៌ពួកណាមានបណ្ឌិតគប្បីជ្រាបការចែកខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងសេចក្ដីនេះ មានន័យដូចតទៅនេះថា ធម៌ទាំងឡាយដែលទាក់ទងក្នុងសង្ខារក្ខន្ធ សង្គ្រោះចូលគ្នាបានជាមួយសមុទយសច្ច ដោយខន្ធសង្គហៈជាដើមមុន ។ ឯធម៌ទាំងនោះ ឈ្មោះថា ប្រកបចូលគ្នាបានជាមួយខន្ធ ៣ ដ៏សេសអាយតនៈ ១ វិញ្ញាណធាតុ ៧ ជាមួយធម៌ពួកខ្លះ ព្រោះប្រកបចូលគ្នាបានជាមួយធម៌ដ៏សេស វៀរតណ្ហាក្នុងសង្ខារក្ខន្ធ ធម្មាយតនៈ និងធម្មធាតុ និងប្រកបចូលគ្នាមិនបានជាមួយរូបក្ខន្ធ ១ រូបាយតនៈ ១០ រូបធាតុ ១០ ឈ្មោះថា ប្រកបចូលគ្នាមិនបានជាមួយធម៌ពួកខ្លះ ព្រោះប្រកបចូលគ្នាមិនបានជាមួយ

រូប និងនិព្វាន ក្នុងធម្មាយតនៈ ១ ក្នុងធម្មធាតុ ១ ។ បណ្ឌិតគប្បីជ្រាបអត្ថ ក្នុងទីទាំងពួង ដោយន័យនេះឯង ។ល។

## អដ្ឋកថាសង្គហិតេនសម្បយុត្តាវិប្បយុត្តបទ ចប់

# អភិធម្មបិដក

## សម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

[ ៤១៣ ] ពួកធម៌ណា ប្រកបដោយវេទនាខន្ធ ពួកធម៌ណា ប្រកបដោយសញ្ញាខន្ធ ពួកធម៌ណា ប្រកបដោយសង្ខារក្ខន្ធ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១០ ។

[ ៤១៤ ] ពួកធម៌ណា ប្រកបដោយវិញ្ញាណក្ខន្ធ ពួកធម៌ណា ប្រកបដោយមនាយតនៈ ពួកធម៌ណា ប្រកបដោយចក្ខុវិញ្ញាណធាតុ ។បេ។ ពួកធម៌ណា ប្រកបដោយមនោធាតុ ពួកធម៌ណា ប្រកបដោយមនោវិញ្ញាណធាតុ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤១៥ ] ពួកធម៌ណា ប្រកបដោយសមុទយសច្ច ពួកធម៌ណា ប្រកបដោយមគ្គសច្ច ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤១៦ ] ពួកធម៌ណា ប្រកបដោយមនិន្ទ្រិយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤១៧ ] ពួកធម៌ណា ប្រកបដោយសុខិន្ទ្រិយ ពួកធម៌ណា ប្រកបដោយទុក្ខិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រកបដោយទោមនស្សិន្ទ្រិយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ ដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤១៨ ] ពួកធម៌ណា ប្រកបដោយឧបេក្ខិន្ទ្រិយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១១ ។

[ ៤១៩ ] ពួកធម៌ណា ប្រកបដោយសទ្ធិន្ទ្រិយ ពួកធម៌ណា ប្រកបដោយវីរិយិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសតិន្ទ្រិយ ពួកធម៌ណា ប្រកបដោយសមាធិន្ទ្រិយ ពួកធម៌ណា ប្រកបដោយបញ្ញិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអញ្ញិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអញ្ញាតាវិន្ទ្រិយ ពួកធម៌ណា ប្រកបដោយអវិជ្ជា ពួកធម៌ណា ប្រកបដោយសង្ខារ ព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២០ ] ពួកធម៌ណា ប្រកបដោយវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤២១ ] ពួកធម៌ណា ប្រកបដោយផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤២២ ] ពួកធម៌ណា ប្រកបដោយវេទនា ព្រោះផស្សៈជាបច្ច័យ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១០ ។

[ ៤២៣ ] ពួកធម៌ណា ប្រកបដោយតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ណា ប្រកបដោយឧបាទាន ព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា ប្រកបដោយកម្មភព ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២៤ ] ពួកធម៌ណា ប្រកបដោយសេចក្តីសោក ពួកធម៌ណា ប្រកបដោយសេចក្តីទុក្ខ ពួកធម៌ណា ប្រកបដោយទោមនស្ស ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២៥ ] ពួកធម៌ណា ប្រកបដោយឧបាយាស ពួកធម៌ណា ប្រកបដោយសតិប្បដ្ឋាន ពួកធម៌ណា ប្រកបដោយសម្មប្បធាន ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២៦ ] ពួកធម៌ណា ប្រកបដោយឥទ្ធិបាទ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤២៧ ] ពួកធម៌ណា ប្រកបដោយឈាន ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២៨ ] ពួកធម៌ណា ប្រកបដោយអប្បមញ្ញា ពួកធម៌ណា ប្រកបដោយឥន្ទ្រិយ ៥ ពួកធម៌ណា ប្រកបដោយពល ៥ ពួកធម៌ណា ប្រកបដោយពោជ្ឈង្គ ៧ ពួកធម៌ណា ប្រកបដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤២៩ ] ពួកធម៌ណា ប្រកបដោយផស្សៈ ពួកធម៌ណា ប្រកបដោយចេតនា ពួកធម៌ណា ប្រកបដោយមនសិការ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៣០ ] ពួកធម៌ណា ប្រកបដោយវេទនា ពួកធម៌ណា ប្រកបដោយសញ្ញា ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៣១ ] ពួកធម៌ណា ប្រកបដោយចិត្ត ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៣២ ] ពួកធម៌ណា ប្រកបដោយអធិមោក្ខ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៤៣៣ ] ពួកធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយសុខវេទនា ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ពួកធម៌ណា ប្រកបដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំដោយសុខ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រឡំដោយឧបេក្ខា ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៣៤ ] ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រកបដោយធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ

ដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៣៥ ] ពួកធម៌ណា ប្រកបដោយធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រកបដោយធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៣៦ ] ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា ប្រកបដោយធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៣៧ ] ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយអាសវៈ តែមិនមែនអាសវៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៣៨ ] ពួកធម៌ណា ប្រកបដោយធម៌ជាសញ្ញោជនៈ ពួកធម៌ណា ប្រកបដោយធម៌ជាគន្ថៈ ពួកធម៌ណា ប្រកបដោយធម៌ជាឱឃៈ ពួកធម៌ណា ប្រកបដោយធម៌ជាយោគៈ ពួកធម៌ណា ប្រកបដោយធម៌ជានីវរណៈ ពួកធម៌

ណា ប្រកបដោយធម៌ជាបរាមាស ពួកធម៌ណា ប្រកបដោយធម៌ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលហើយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៣៩ ] ពួកធម៌ណា ប្រកបដោយធម៌ ដែលប្រកបដោយបរាមាស ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៤០ ] ពួកធម៌ណា ប្រកបដោយធម៌ គឺចិត្ត ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៣ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ២ អាយតនៈ ១១ ធាតុ ១៧ ។

[ ៤៤១ ] ពួកធម៌ណា ប្រកបដោយធម៌ គឺចេតសិក ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំដោយចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១១ ។

[ ៤៤២ ] ពួកធម៌ណា ប្រកបដោយធម៌ជាឧបាទាន ពួកធម៌ណា ប្រកបដោយធម៌ជាកិលេស ពួកធម៌ណា ប្រកបដោយធម៌ជាកិលេស ទាំងគួរដល់

នូវសេចក្ដីសៅហ្មង ពួកធម៌ណា ប្រកបដោយធម៌ជាកិលេស ទាំងជាធម៌សៅហ្មងហើយ ពួកធម៌ណា ប្រកបដោយធម៌ជាកិលេស ទាំងប្រកបដោយកិលេស ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៤៣ ] ពួកធម៌ណា ប្រកបដោយធម៌ ដែលសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយកិលេស តែមិនមែនកិលេស ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិតក្ក ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយវិចារ ពួកធម៌ណា ប្រកបដោយធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំដោយបីតិ ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំដោយសុខ ពួកធម៌ណា ប្រកបដោយធម៌ដែលច្រឡំដោយឧបេក្ខា ពួកធម៌នោះសង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១ ធាតុ ១ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ ដោយខន្ធ ៤ អាយតនៈ ១១ ធាតុ ១៧ ។

## សម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ចប់

# អដ្ឋកថា

## សម្បយុត្តេនសង្គហិតាសង្គហិតបទ

[ ៤១៣-៤៤៣ ] ឥឡូវនេះ ដើម្បីចែកបទនៃធម៌ដែលសង្គ្រោះចូលគ្នាបាន ធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ជាមួយធម៌ដែលប្រកបចូលគ្នាបាន ព្រះមានព្រះភាគទ្រង់ផ្តើមបទថា **វេទនាក្ខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ពួកណា មានវេទនាខន្ធជាដើម ដែលទ្រង់លើកឡើងសម្តែង ក្នុងនិទ្ទេសនៃពាក្យថា ការប្រកបព្រម មួយអន្លើដោយការប្រកបព្រម ធម៌ទាំងនោះឯងទ្រង់លើកឡើង ក្នុងពាក្យបុច្ឆាទាំងពួង ។ ក្នុងពាក្យទាំងនោះ ធម៌ពួកណាប្រកបចូលគ្នាបានជាមួយបទដែលលើកឡើង តាំងជាពាក្យសួរ ការសង្គ្រោះចូលគ្នាបាន ឬការសង្គ្រោះចូលគ្នាមិនបាន នៃធម៌ទាំងនោះជាមួយធម៌ពួកណាមាន បណ្ឌិតគប្បីជ្រាបប្រភេទនៃខន្ធជាដើមដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងបទទាំងនោះ មានសេចក្តីដូចតទៅនេះ វេទនាខន្ធប្រកបចូលគ្នាបានជាមួយសញ្ញាជាដើម ធម៌ទាំងនោះ មានសញ្ញាជាដើម សង្គ្រោះចូលគ្នាបានជាមួយខន្ធ ៣ មានសញ្ញាខន្ធជាដើម ជាមួយអាយតនៈ ២ គឺធម្មាយតនៈ មនាយតនៈ ជាមួយធាតុ ៨ គឺធម្មធាតុ ១ វិញ្ញាណធាតុ ៧ តែសង្គ្រោះចូលគ្នាមិនបានជាមួយខន្ធ អាយតនៈ និងធាតុដ៏សេស ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីទាំងពួងដោយឧបាយនេះឯង ៕

**អដ្ឋកថាសម្បយុត្តេនសង្គហិតាសង្គហិតបទ ចប់**

# អភិធម្មបិដក

## អសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស

[ ៤៤៤ ] ពួកធម៌ណា មិនសង្គ្រោះដោយរូបក្ខន្ធ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ នឹងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៤៥ ] ពួកធម៌ណា មិនសង្គ្រោះដោយធម្មាយតនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម្មធាតុ ពួកធម៌ណា មិនសង្គ្រោះដោយឥត្ថិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយបុរិសិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយជីវិតិន្ទ្រិយ ពួកធម៌ណា មិនសង្គ្រោះដោយនាមរូប ព្រោះវិញ្ញាណជាបច្ច័យ ពួកធម៌ណា មិនសង្គ្រោះដោយអសញ្ញាភព ពួកធម៌ណា មិនសង្គ្រោះដោយឯកវោការភព ពួកធម៌ណា មិនសង្គ្រោះដោយជាតិ ពួកធម៌ណា មិនសង្គ្រោះដោយជរា ពួកធម៌ណា មិនសង្គ្រោះដោយមរណៈ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៤៦ ] ពួកធម៌ណា មិនសង្គ្រោះដោយអរូបភព ពួកធម៌ណា មិនសង្គ្រោះដោយនេវសញ្ញានាសញ្ញាភព ពួកធម៌ណា មិនសង្គ្រោះដោយចតុវោការភព ពួកធម៌ណា មិនសង្គ្រោះដោយឥទ្ធិបាទ ដោយខន្ធសង្គហៈ មិនសង្គ្រោះ ដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៤៧ ] ពួកធម៌ណា មិនសង្គ្រោះដោយកុសលធម៌ ពួកធម៌ណា មិនសង្គ្រោះដោយអកុសលធម៌ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលប្រកបដោយសុខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាវិបាក ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានវិបាកជាប្រក្រតី ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលសៅហ្មងហើយ ទាំងគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលមិនសៅហ្មងហើយ ទាំងមិនគួរដល់នូវសេចក្ដីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយពួកធម៌ដែលប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលមិនមានវិតក្ក មានត្រឹមតែវិចារ ពួក

ធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយសុខ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលប្រកបដោយឧបេក្ខា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានហេតុគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានហេតុគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលដល់នូវការសន្សំ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលដល់នូវការមិនសន្សំ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលដល់នូវសភាពធំ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រមាណមិនបាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលមានអារម្មណ៍តូចឆ្មារ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលមានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលមានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ថោកទាប ពួកធម៌ណា មិនសង្គ្រោះដោយធម៌ឧត្តម ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានសភាពខុស និងទៀង ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានសភាពត្រូវ និងទៀង ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានមគ្គជាអារម្មណ៍ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ មានមគ្គជាហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានមគ្គជាអធិបតី ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានអារម្មណ៍ជាអតីត ពួកធម៌ណា មិនសង្គ្រោះដោយ

ធម៌មានអារម្មណ៍ជាអនាគត ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៤៨ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានរូប ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៤៩ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមានរូប ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាលោកុត្តរ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមានអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយអាសវៈ តែមិនមែនអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ មិនជាប្រយោជន៍ដល់សញ្ញោជនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលគន្ថៈ មិនគប្បីដោតក្រង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ មិនជាប្រយោជន៍ដល់នីវរណៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលបរាមាសមិនស្ទាបអង្អែល ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយបរាមាស ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលហើយ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៥០ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមានអារម្មណ៍ ពួកធម៌

ណា មិនសង្គ្រោះដោយធម៌មិនមែនចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រាសចាកចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រឡំដោយចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលតាំងឡើងអំពីចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលកើតជាមួយនឹងចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រព្រឹត្តទៅតាមចិត្ត ពួកធម៌ណា មិនសង្គ្រោះដោយធម៌ខាងក្រៅ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ ប្រកបដោយខន្ធ ៣ ក៏មាន ប្រកបដោយអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាសចាកខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

[ ៤៥១ ] ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលប្រកបដោយធម៌មិនមែនឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលប្រកបដោយឧបាទានតែមិនមែនឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រាសចាកឧបាទានទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលមិនសៅហ្មងហើយ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយកិលេស ពួកធម៌

ណា មិនសង្គ្រោះដោយធម៌ដែលសៅហ្មងហើយ តែមិនមែនកិលេស ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយកិលេស តែមិនមែនកិលេស ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានហេតុ ដែលគួរលះដោយទស្សនៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានហេតុដែលគួរលះដោយភាវនា ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយវិតក្កៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយវិចារ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រឡំដោយបីតិ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រឡំដោយសុខ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលប្រឡំដោយឧបេក្ខា ពួកធម៌ណា មិនសង្គ្រោះដោយធម៌មិនមែនកាមាវចរ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជារូបាវចរ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាអរូបាវចរ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ ដែលមិនរាប់បញ្ចូលក្នុងវដ្តៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌ជាគ្រឿងចេញចាកវដ្តៈ ពួកធម៌ណា មិនសង្គ្រោះដោយធម៌មានសភាពទៀង ពួកធម៌ណា មិនសង្គ្រោះដោយធម៌ដែលមិនអាចរើខ្លួន ពួកធម៌ណា មិនសង្គ្រោះដោយធម៌ប្រកបដោយសត្រូវ ដោយខន្ធសង្គហៈ មិនសង្គ្រោះដោយអាយតនសង្គហៈ មិនសង្គ្រោះដោយធាតុសង្គហៈ ពួកធម៌នោះ ប្រកបដោយខន្ធប៉ុន្មាន អាយតនៈ

ប៉ុន្មាន ធាតុប៉ុន្មាន ។ មិនមានទេ ។ ប្រាសចាកធម៌ប៉ុន្មាន ។ ប្រាស ចាកខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ក៏មាន ប្រាសចាកអាយតនៈ ១ ធាតុ ១ និងធម៌ពួកខ្លះក៏មាន ។

## អសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ចប់

# អដ្ឋកថា

## អសង្គហិតេនសម្បយុត្តវិប្បយុត្តបទ

[ ៤៤៤-៤៥១ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលប្រកបចូលគ្នាបាន ធម៌ដែលប្រកបចូលគ្នាមិនបាន ជាមួយធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ទើបព្រះមានព្រះភាគផ្ដើមពាក្យថា **រូបក្ខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ ធម៌ទាំងឡាយណា មានបញ្ហាដូចគ្នានឹងរូបក្ខន្ធ ក្នុងនិទ្ទេសនៃអសង្គហិតេន-អសង្គហិតបទទី ៥ និងធម៌ទាំងឡាយណាមានបញ្ហាដូចគ្នានឹងអរូបភព ធម៌ទាំងនោះឯង ទ្រង់លើកឡើងសម្ដែង ។ ចំណែកបទទាំងឡាយដ៏សេសមិនបានលើកមក ព្រោះហេតុនោះ ទើបបទទាំងនោះ មិនបានលើកឡើងសម្ដែង ព្រោះថា រូបធម៌ និងអរូបធម៌ទាំងឡាយ សង្គ្រោះចូលគ្នាមិនបានជាមួយវេទនាខន្ធ ដោយអំណាចខន្ធជាដើម ទាំងឈ្មោះថា ការប្រកបចូលគ្នាបាននៃធម៌ទាំងនោះក៏មិនមាន ព្រោះហេតុនោះ បទទាំងឡាយណា ដែលមិនបានលើកឡើងសម្ដែង បទទាំងឡាយនោះឯង ទ្រង់លើកឡើងសម្ដែងព្រមជាមួយពាក្យវិសជ្ជនាដែលជាទំនងតែមួយ ។ ក្នុងបទទាំងនោះ ធម៌ពួកណា សង្គ្រោះចូលគ្នាមិនបានជាមួយធម៌ដែលទ្រង់លើកឡើងសម្ដែងជាពាក្យសួរ ដោយអំណាចខន្ធជាដើម ធម៌ទាំងឡាយនោះ ប្រកបចូលគ្នាបាន និងប្រកបចូលគ្នាមិនបានជាមួយធម៌ពួកណា បណ្ឌិតគប្បីជ្រាបការចែកធម៌ មានខន្ធជាដើម ដោយអំណាចនៃធម៌ទាំងនោះ ។

ក្នុងបទទាំងនោះ មានសេចក្ដីដូចតទៅនេះថា វិញ្ញាណណាមួយសង្គ្រោះចូលគ្នាមិនបានជាមួយរូបក្ខន្ធដោយសង្គហៈ ៣ យ៉ាងមុន ។ វិញ្ញាណនោះ

ប្រកបចូលគ្នាបានជាមួយខន្ធ ៣ មានវេទនាខន្ធជាដើម និងជាមួយធម៌ទាំងឡាយ មានវេទនាជាដើម ក្នុងធម្មាយតនៈ និងធម្មធាតុទាំងឡាយ និងប្រកបចូលគ្នាមិនបានជាមួយរូបក្ខន្ធ ១ រូបាយតនៈ ១០ រូបធាតុ ១០ និងធម៌ គឺរូបនិងនិព្វាន ក្នុងធម្មាយតនៈ និងធម្មធាតុ ។ ព្រះមានព្រះភាគទ្រង់សំដៅយកវិញ្ញាណនោះ ទើបត្រាស់ថា **តេ ធម្មា តីហិ ខន្ធេហិ** ជាដើម ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងទីទាំងពួង ដោយន័យនេះឯង ៗល។

## អដ្ឋកថាអសង្គហិតេនសម្បយុត្តវិប្បយុត្តបទ ចប់

# អភិធម្មបិដក

## វិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស

[ ៤៥២ ] ពួកធម៌ណា ប្រាសចាករូបក្ខន្ធ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៥៣ ] ពួកធម៌ណា ប្រាសចាកវេទនាខន្ធ ពួកធម៌ណា ប្រាសចាកសញ្ញាខន្ធ ពួកធម៌ណា ប្រាសចាកសង្ខារក្ខន្ធ ពួកធម៌ណា ប្រាសចាកវិញ្ញាណក្ខន្ធ ពួកធម៌ណា ប្រាសចាកមនាយតនៈ ពួកធម៌ណា ប្រាសចាកមនិន្ទ្រិយ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៤៥៤ ] ពួកធម៌ណា ប្រាសចាកចក្ខាយតនៈ ។បេ។ ពួកធម៌ណា ប្រាសចាកផោដ្ឋព្វាយតនៈ ពួកធម៌ណា ប្រាសចាកចក្ខុធាតុ ។បេ។ ពួកធម៌ណា ប្រាសចាកផោដ្ឋព្វធាតុ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៥៥ ] ពួកធម៌ណា ប្រាសចាកចក្ខុវិញ្ញាណធាតុ ពួកធម៌ណា ប្រាសចាកសោតវិញ្ញាណធាតុ ពួកធម៌ណា ប្រាសចាកឃានវិញ្ញាណធាតុ ពួកធម៌

ណា ប្រាសចាកជិវ្ហាវិញ្ញាណធាតុ ពួកធម៌ណា ប្រាសចាកកាយវិញ្ញាណធាតុ ពួកធម៌ណា ប្រាសចាកមនោធាតុ ពួកធម៌ណា ប្រាសចាកមនោវិញ្ញាណធាតុ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ៤៥៦ ] ពួកធម៌ណា ប្រាសចាកទុក្ខសច្ច ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៥៧ ] ពួកធម៌ណា ប្រាសចាកសមុទយសច្ច ពួកធម៌ណា ប្រាសចាកមគ្គសច្ច ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៥៨ ] ពួកធម៌ណា ប្រាសចាកនិរោធសច្ច ពួកធម៌ណា ប្រាសចាកចក្ខុន្ទ្រិយ ពួកធម៌ណា ប្រាសចាកសោតិន្ទ្រិយ ពួកធម៌ណា ប្រាសចាកឃានិន្ទ្រិយ ពួកធម៌ណា ប្រាសចាកជិវ្ហិន្ទ្រិយ ពួកធម៌ណា ប្រាសចាកកាយិន្ទ្រិយ ពួកធម៌ណា ប្រាសចាកឥត្ថិន្ទ្រិយ ពួកធម៌ណា ប្រាសចាកបុរិសិន្ទ្រិយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌

ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៥៩ ] ពួកធម៌ណា ប្រាសចាកមនិន្ទ្រិយ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៤៦០ ] ពួកធម៌ណា ប្រាសចាកសុខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកទុក្ខិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសោមនស្សិន្ទ្រិយ ពួកធម៌ណា ប្រាសចាកទោមនស្សិន្ទ្រិយ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៦១ ] ពួកធម៌ណា ប្រាសចាកឧបេក្ខិន្ទ្រិយ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៥ ទេ ។

[ ៤៦២ ] ពួកធម៌ណា ប្រាសចាកសទ្ធិន្ទ្រិយ ពួកធម៌ណា ប្រាសចាកវីរិយិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសតិន្ទ្រិយ ពួកធម៌ណា ប្រាសចាកសមា-

ធិន្ទ្រិយ ពួកធម៌ណា ប្រាសចាកបញ្ញិន្ទ្រិយ ពួកធម៌ណា ប្រាសចាកអនញ្ញ-តញ្ញស្សាមីតិន្ទ្រិយ ពួកធម៌ណាប្រាសចាកអញ្ញិន្ទ្រិយ ពួកធម៌ណាប្រាសចាកអញ្ញាតាវិន្ទ្រិយ ពួកធម៌ណាប្រាសចាកអវិជ្ជា ពួកធម៌ណាប្រាសចាកសង្ខារព្រោះអវិជ្ជាជាបច្ច័យ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៤៦៣ ] ពួកធម៌ណាប្រាសចាកវិញ្ញាណ ព្រោះសង្ខារជាបច្ច័យ ពួកធម៌ណាប្រាសចាកផស្សៈ ព្រោះសឡាយតនៈជាបច្ច័យ ពួកធម៌ណាប្រាសចាកវេទនាព្រោះផស្សៈជាបច្ច័យ ពួកធម៌នោះវៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៤៦៤ ] ពួកធម៌ណា ប្រាសចាកតណ្ហា ព្រោះវេទនាជាបច្ច័យ ពួកធម៌ណា ប្រាសចាកឧបាទានព្រោះតណ្ហាជាបច្ច័យ ពួកធម៌ណា ប្រាសចាកកម្ម-ភព ពួកធម៌នោះវៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈ

ណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៦៥ ] ពួកធម៌ណា ប្រាសចាកឧបបត្តិភព ពួកធម៌ណា ប្រាសចាកសញ្ញាភព ពួកធម៌ណា ប្រាសចាកបញ្ចវោការភព ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៤៦៦ ] ពួកធម៌ណា ប្រាសចាកកាមភព ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៥ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៣ ។

[ ៤៦៧ ] ពួកធម៌ណា ប្រាសចាករូបភព ពួកធម៌ណា ប្រាសចាកអសញ្ញាភព ពួកធម៌ណា ប្រាសចាកឯកវោការភព ពួកធម៌ណា ប្រាសចាកការខ្សឹកខ្សួល ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៦៨ ] ពួកធម៌ណាប្រាសចាកអរូបភព ពួកធម៌ណា ប្រាសចាកនេវ-សញ្ញានាសញ្ញាភព ពួកធម៌ណា ប្រាសចាកចតុវោការភព ពួកធម៌ណា ប្រាសចាកសេចក្តីសោក ពួកធម៌ណាប្រាសចាកទុក្ខ ពួកធម៌ណាប្រាសចាកទោមនស្ស ពួកធម៌ណា ប្រាសចាកឧបាយាស ពួកធម៌ណា ប្រាសចាកសតិប្បដ្ឋាន ពួកធម៌ណា ប្រាសចាកសម្មប្បធាន ពួកធម៌ណា ប្រាសចាកឥទ្ធិបាទ ពួកធម៌ណា ប្រាសចាកឈាន ពួកធម៌ណា ប្រាសចាកអប្បមញ្ញា ពួកធម៌ណា ប្រាស

ចាកឥន្ទ្រិយ ៥ ពួកធម៌ណា ប្រាសចាកពល ៥ ពួកធម៌ណា ប្រាសចាកពោជ្ឈង្គ ៧ ពួកធម៌ណា ប្រាសចាកមគ្គមានអង្គ ៨ ដ៏ប្រសើរ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៤៦៩ ] ពួកធម៌ណា ប្រាសចាកផស្សៈ ពួកធម៌ណា ប្រាសចាកវេទនា ពួកធម៌ណា ប្រាសចាកសញ្ញា ពួកធម៌ណា ប្រាសចាកចេតនា ពួកធម៌ណា ប្រាសចាកចិត្ត ពួកធម៌ណា ប្រាសចាកការធ្វើទុកក្នុងចិត្ត ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ ដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៤៧០ ] ពួកធម៌ណា ប្រាសចាកអធិមោក្ខ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ៤៧១ ] ពួកធម៌ណា ប្រាសចាកពួកធម៌ជាកុសល ពួកធម៌ណា ប្រាសចាកពួកធម៌ជាអកុសល ពួកធម៌ណា ប្រាសចាកពួកធម៌ដែលប្រកបដោយ

សុខវេទនា ពួកធម៌ណា ប្រាសចាកពួកធម៌ដែលប្រកបដោយទុក្ខវេទនា ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៧២ ] ពួកធម៌ណា ប្រាសចាកធម៌ជាអព្យាក្រឹត ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៧៣ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយអទុក្ខមសុខវេទនា ពួកធម៌ណា ប្រាសចាកធម៌ជាវិបាក ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៥ ទេ ។

[ ៤៧៤ ] ពួកធម៌ណា ប្រាសចាកធម៌មានវិបាកជាប្រក្រតី ពួកធម៌ណា ប្រាសចាកធម៌សៅហ្មងហើយ ទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ

មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៧៥ ] ពួកធម៌ណា ប្រាសចាកធម៌មិនមែនវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី ពួកធម៌ណា ប្រាសចាកធម៌ ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា ប្រាសចាកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ណា ប្រាសចាកធម៌ដែលមិនសៅហ្មងហើយ ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៧៦ ] ពួកធម៌ណា ប្រាសចាកធម៌ ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៤៧៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនសៅហ្មងហើយ តែគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៧៨ ] ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយវិតក្ក ទាំងប្រកបដោយវិចារ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ

សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ៤៧៩ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានវិតក្ក មានត្រឹមតែវិចារ ពួកធម៌ណា ប្រាសចាកធម៌ប្រឡំដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ប្រឡំដោយសុខ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៨០ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានវិតក្ក ទាំងមិនមានវិចារ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៤៨១ ] ពួកធម៌ណា ប្រាសចាកធម៌ប្រឡំដោយឧបេក្ខា ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៥ ទេ ។

[ ៤៨២ ] ពួកធម៌ណា ប្រាសចាកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ ដែលគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌

មានហេតុ ដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌មានហេតុ ដែលគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌ដែលដល់នូវការសន្សំ ពួកធម៌ណា ប្រាសចាកធម៌ដែលដល់នូវការមិនសន្សំ ពួកធម៌ណា ប្រាសចាកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ណា ប្រាសចាកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌ណា ប្រាសចាកធម៌ដែលដល់នូវសភាពធំ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៨៣ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌មានហេតុដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌ដែលមិនដល់នូវការសន្សំ ទាំងមិនមែនមិនដល់នូវការមិនសន្សំ ពួកធម៌ណា ប្រាសចាកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ពួកធម៌ណា ប្រាសចាកធម៌មានសភាពតូចថ្មារ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៨៤ ] ពួកធម៌ណា ប្រាសចាកធម៌មានប្រមាណមិនបាន ពួកធម៌ណា ប្រាសចាកពួកធម៌ឧត្តម ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២

ធាតុ ៨ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះ ដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៨៥ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានអារម្មណ៍តូចឆ្មារ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៦ ទេ ។

[ ៤៨៦ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ប្រមាណមិនបាន ពួកធម៌ណា ប្រាសចាកធម៌ថោកទាប ពួកធម៌ណា ប្រាសចាកធម៌មានសភាពខុស និងទៀង ពួកធម៌ណា ប្រាសចាកធម៌មានសភាពត្រូវ និងទៀង ពួកធម៌ណា ប្រាសចាកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌ណា ប្រាសចាកធម៌មានមគ្គជាហេតុ ពួកធម៌ណា ប្រាសចាកធម៌មានមគ្គជាអធិបតី ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៨៧ ] ពួកធម៌ណា ប្រាសចាកធម៌ជាកណ្តាល ពួកធម៌ណា ប្រាសចាកធម៌មានសភាពមិនទៀង ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ

២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៨៨ ] ពួកធម៌ណា ប្រាសចាកធម៌ដែលកើតឡើងហើយ ពួកធម៌ណា ប្រាសចាកធម៌ ដែលមិនទាន់កើតឡើង ពួកធម៌ណា ប្រាសចាកធម៌ដែលបម្រុងនឹងកើតឡើង ពួកធម៌ណា ប្រាសចាកធម៌ជាអតីត ពួកធម៌ណា ប្រាសចាកធម៌ជាអនាគត ពួកធម៌ណា ប្រាសចាកធម៌ជាបច្ចុប្បន្ន ពួកធម៌ណា ប្រាសចាកធម៌ជាខាងក្នុង ពួកធម៌ណា ប្រាសចាកធម៌ជាខាងក្រៅ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ពួកធម៌ណា ប្រាសចាកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៨៩ ] ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាអតីត ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៩០ ] ពួកធម៌ណា ប្រាសចាកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ពួកធម៌

ណា ប្រាសចាកធម៌មានអារម្មណ៍ខាងក្នុង និងខាងក្រៅ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១២ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៦ ទេ ។

[ ៤៩១ ] ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយហេតុ ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រាសចាកធម៌ជាហេតុ ទាំងប្រកបដោយហេតុ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយហេតុ តែមិនមែនហេតុ ពួកធម៌ណា ប្រាសចាកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៤៩២ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានហេតុ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកហេតុ ពួកធម៌ណា ប្រាសចាកធម៌មិនមែនហេតុ ទាំងឥតហេតុ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។

មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៩៣ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានបច្ច័យ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានបច្ច័យតាក់តែង ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយការឃើញ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយការប៉ះពាល់ ពួកធម៌ណា ប្រាសចាកធម៌មានរូប ពួកធម៌ណា ប្រាសចាកធម៌ជាលោកុត្តរ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៩៤ ] ពួកធម៌ណា ប្រាសចាកធម៌ជាលោកិយ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៩៥ ] ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ជាអាសវៈ ទាំងប្រកបដោយអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមែនអាសវៈ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៤៩៦ ] ពួកធម៌ណា ប្រាសចាកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៤៩៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនមានអាសវៈ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៤៩៨ ] ពួកធម៌ណា ប្រាសចាកធម៌ជាសញ្ញោជនៈ ពួកធម៌ណា ប្រាសចាកធម៌ជាគន្ថៈ ពួកធម៌ណា ប្រាសចាកធម៌ជាឱឃៈ ពួកធម៌ណា ប្រាសចាកធម៌ជាយោគៈ ពួកធម៌ណា ប្រាសចាកធម៌ជានីវរណៈ ពួកធម៌ណា ប្រាសចាកធម៌ជាបរាមាស ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយបរាមាស ពួកធម៌ណា ប្រាសចាកធម៌ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលហើយ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៤៩៩ ] ពួកធម៌ណា ប្រាសចាកធម៌ដែលបរាមាសស្ទាបអង្អែលហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកបរាមាស ពួកធម៌ណា ប្រាសចាកធម៌ដែលបរាមាសស្ទាបអង្អែលហើយ តែមិនមែនបរាមាស ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលហើយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥០០ ] ពួកធម៌ណា ប្រាសចាកធម៌ដែលបរាមាសមិនស្ទាបអង្អែលហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលហើយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៥០១ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ពួកធម៌ណា ប្រាសចាកធម៌គឺចិត្ត ពួកធម៌ណា ប្រាសចាកធម៌គឺចេតសិក ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយចិត្ត ពួកធម៌ណា ប្រាសចាកធម៌ច្រឡំដោយចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើងអំពីចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ១ អាយតនៈ ១១ ធាតុ ១១ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិន

សង្គ្រោះដោយខន្ធ ៤ អាយតនៈ ១ ធាតុ ៧ ។

[ ៥០២ ] ពួកធម៌ណា ប្រាសចាកធម៌មិនមានអារម្មណ៍ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រាសចាកចិត្ត ពួកធម៌ណា ប្រាសចាកធម៌ដែលមិនច្រឡំដោយចិត្ត ពួកធម៌ណា ប្រាសចាកធម៌ជាឧបាទា ពួកធម៌ណា ប្រាសចាកធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៥០៣ ] ពួកធម៌ណា ប្រាសចាកធម៌ ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ពួកធម៌នោះសង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៥ ។

[ ៥០៤ ] ពួកធម៌ណា ប្រាសចាកធម៌ជាឧបាទាន ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ពួកធម៌ណា ប្រាសចាកធម៌ដែលសៅហ្មងហើយ ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយកិលេស ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ជាកិលេស ទាំងជាធម៌សៅហ្មងហើយ ពួកធម៌ណា ប្រាសចាកធម៌ ដែលសៅហ្មងហើយ តែមិនមែនជាកិលេស ពួកធម៌ណា ប្រាសចាកធម៌ជាកិលេល ទាំងប្រកបដោយកិលេស ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយកិលេស តែមិនមែនជាកិលេស ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធ

ចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៥០៥ ] ពួកធម៌ណា ប្រាសចាកធម៌គួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ ដែលមិនសៅហ្មងហើយ ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រាសចាកកិលេស ពួកធម៌ណា ប្រាសចាកធម៌ គួរដល់នូវសេចក្តីសៅហ្មង តែមិនមែនកិលេស ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះ ដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥០៦ ] ពួកធម៌ណា ប្រាសចាកធម៌មិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១០ ។

[ ៥០៧ ] ពួកធម៌ណា ប្រាសចាកធម៌ដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ ដែលគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌មានហេតុដែលគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌មានហេតុ

ដែលគួរលះដោយភាវនា ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៥០៨ ] ពួកធម៌ណា ប្រាសចាកធម៌ដែលមិនគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនគួរលះដោយភាវនា ពួកធម៌ណា ប្រាសចាកធម៌មានហេតុដែលមិនគួរលះដោយទស្សនៈ ពួកធម៌ណា ប្រាសចាកធម៌មានហេតុដែលមិនគួរលះដោយភាវនា ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥០៩ ] ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយវិតក្ក ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយវិចារ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៧ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ១ ទេ ។

[ ៥១០ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រកបដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ដែលច្រឡំដោយបីតិ ពួកធម៌ណា ប្រាសចាកធម៌ដែល

ប្រឡំដោយសុខ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះ ដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះ ដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះ ដោយធាតុណាមួយឡើយ ។

[ ៥១១ ] ពួកធម៌ណា ប្រាសចាកធម៌ដែលប្រឡំដោយឧបេក្ខា ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៣ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយឡើយ តែមិនសង្គ្រោះដោយធាតុ ៥ ទេ ។

[ ៥១២ ] ពួកធម៌ណា ប្រាសចាកធម៌ជាកាមាវចរ ពួកធម៌ណា ប្រាសចាកធម៌ ដែលរាប់បញ្ចូលក្នុងវដ្តៈ ពួកធម៌ណា ប្រាសចាកធម៌ ដែលប្រកបដោយការវើខួន ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

[ ៥១៣ ] ពួកធម៌ណា ប្រាសចាកធម៌មិនមែនកាមាវចរ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនរាប់បញ្ចូលក្នុងវដ្តៈ ពួកធម៌ណា ប្រាសចាកធម៌ដែលមិនអាចវើខួន ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០

ធាតុ ១០ ។

[ ៥១៤ ] ពួកធម៌ណា ប្រាសចាកធម៌ជារូបាវចរ ពួកធម៌ណា ប្រាសចាកធម៌ជាអរូបាវចរ ពួកធម៌ណា ប្រាសចាកធម៌ជាគ្រឿងចេញចាកវដ្ដៈ ពួកធម៌ណា ប្រាសចាកធម៌ទៀង ពួកធម៌ណា ប្រាសចាកធម៌ប្រកបដោយសត្រូវ ពួកធម៌នោះ វៀរលែងព្រះនិព្វានជាអសង្ខតៈ ក្រៅអំពីខន្ធចេញ សង្គ្រោះដោយខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនមែនមិនសង្គ្រោះដោយខន្ធណាមួយ មិនមែនមិនសង្គ្រោះដោយអាយតនៈណាមួយ មិនមែនមិនសង្គ្រោះដោយធាតុណាមួយឡើយ ។

[ ៥១៥ ] ពួកធម៌ណា ប្រាសចាកធម៌មិនមែនជារូបាវចរ ពួកធម៌ណា ប្រាសចាកធម៌មិនមែនជាអរូបាវចរ ពួកធម៌ណា ប្រាសចាកធម៌មិនមែនជាគ្រឿងចេញចាកវដ្ដៈ ពួកធម៌ណា ប្រាសចាកធម៌មិនទៀង ពួកធម៌ណា ប្រាសចាកធម៌មិនប្រកបដោយសត្រូវ ពួកធម៌នោះ សង្គ្រោះដោយខន្ធប៉ុន្មាន អាយតនៈប៉ុន្មាន ធាតុប៉ុន្មាន ។ ពួកធម៌នោះ សង្គ្រោះដោយខន្ធ ៤ អាយតនៈ ២ ធាតុ ២ ។ មិនសង្គ្រោះដោយធម៌ប៉ុន្មាន ។ មិនសង្គ្រោះដោយខន្ធ ១ អាយតនៈ ១០ ធាតុ ១៦ ។

ធម្មាយតនៈ ១ ធម្មធាតុ ១ ជីវិត ១ នាមរូប ១
សឡាយតនៈ ១ ជាតិ ១ ជរា ១ មរណៈ ១ និងធម៌ ២
តែមិនមានក្នុងតិកៈឡើយ
ធម៌ ៧ មានក្នុងចន្លោះជាដំបូង ធម៌ ១០ មានក្នុងគោច្ឆកៈ

ធម៌ ១៤ មានក្នុងចន្លោះខាងចុង ធម៌ ៦ មានក្នុងទីបំផុត ធម៌ ៤៧ នេះ រមែងមានដោយសមុច្ឆេទផង ដោយមោឃ-បុច្ឆកៈផង ។

## វិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ចប់

## ធាតុកថាបករណៈ ចប់

# អដ្ឋកថា

## វិប្បយុត្តេនសង្គហិតាសង្គហិតបទ

[ ៤៥២-៥១៥ ] ឥឡូវនេះ ដើម្បីចែកធម៌ដែលសង្គ្រោះចូលគ្នាបាន ធម៌ដែលសង្គ្រោះចូលគ្នាមិនបាន ជាមួយធម៌ដែលប្រកបចូលគ្នាមិនបាន ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមពាក្យថា **រូបក្ខន្ធេន** ជាដើម ។ ក្នុងនិទ្ទេសនោះ ការប្រកបចូលគ្នាមិនបាននៃបទទាំងឡាយណា មិនបានលើកឡើងមក បទទាំងឡាយនោះ ព្រះមានព្រះភាគទ្រង់មិនបានកាន់យកក្នុងវារៈនេះ ។ សួរថា បទទាំងនោះ ជាបទអ្វី ឆ្លើយថា ជាបទធម្មាយតនៈជាដើម ព្រោះថា ការប្រកបចូលគ្នាមិនបាននៃធម្មាយតនៈជាមួយធម៌ណាមួយ ក្នុងខន្ធជាដើម មិនបានលើកមក ( ក្នុងទីនេះ ) ។ ក្នុងធម្មធាតុជាដើម ក៏មានន័យនេះឯង ។ បណ្ឌិតគប្បីជ្រាបឧទ្ទានទាំងនោះដូចតទៅ

> ធម្មាយតនៈ ធម្មធាតុ ជីវិតិន្ទ្រិយ នាមរូប សឡាយតនៈ ធម៌ទាំង ៣ មានជាតិជាដើម ( ជាតិ ជរា មរណៈ ) ក្នុងតិកៈទី ២០ មួយបទ ( អជ្ឈត្តពហិទ្ធបទ ) បទចុងក្រោយរបស់តិកៈ ១ បទ ( អនិទស្សនអប្បដិឃបទ ) ក្នុងចូឡន្តរទុកៈ ៧ ក្នុងគោច្ឆកៈ ១០ ក្នុងមហន្តរទុកៈ ១៤ បន្ទាប់ពីនោះទៀត ៦ ( បិដ្ឋិទុកៈ ៦ ) បទទាំងអស់នេះ លោកសម្ដែងដោយសង្ខេប រួមជា ៤៧ បទ រមែងប្រកបមិនបាន ដូច្នេះ ។

*គាថាចុងក្រោយ មានបទថា* **ធម្មាយតនំ ធម្មធាតុ** *ជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្ដែងអត្ថនេះឯង តែវៀរបទទាំងនេះហើយ បទដ៏សេសទាំងអស់ រមែងបាន គឺសង្គ្រោះចូលគ្នាបាន ។ ការចែកដោយភាពជាខន្ធជាដើម ក្នុងបទទាំងនោះ បណ្ឌិតគប្បីជ្រាបដោយទំនងន័យ ដែលពោលហើយនោះឯង ។៚*

## អដ្ឋកថាវិប្បយុត្តេនសង្គហិតាសង្គហិតបទ ចប់

## និគមនកថា

ដោយពាក្យមានប្រមាណប៉ុណ្ណោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ជាអ្នកឈ្លាសក្នុងការចែកធាតុ ត្រាស់គម្ពីរធាតុកថាណា ឥឡូវនេះ ការប្រកាសចំណែកនយមុខ គឺមាតិកាដែលជាប្រធាននៃគម្ពីរនោះចប់ហើយ ឯន័យទាំងអស់នោះ ខ្ញុំពោលជាកថាដោយសង្ខេបប៉ុណ្ណោះ បុគ្គលដែលឈ្លាសអាចដឹង ដោយនយមុខនេះបាន ។ បើខ្ញុំគប្បីពោលគ្រប់ៗ បទ ឲ្យពិស្តារសោតពាក្យនោះ គប្បីច្រើនពន់ពេក ទាំងអត្ថក៏មិនផ្សេងគ្នា ។ បុណ្យឯណាដែលខ្ញុំរចនាគម្ពីរនេះ ដើម្បីជាបែបផែន មានប្រមាណ ២ ភាណវារ សម្រេចហើយដោយប្រការដូច្នេះ សូមបុណ្យនោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់សត្វលោកហោង ៕៚

### បរមត្ថទីបនី អដ្ឋកថាធាតុកថា ចប់

# អភិធម្មបិដក

# បុគ្គលបញ្ញត្តិ

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## ឧទ្ទេសវារ

[ ១ ] *បញ្ញត្តិ ៦ គឺខន្ធបញ្ញត្តិ ១ អាយតនបញ្ញត្តិ ១ ធាតុបញ្ញត្តិ ១ សច្ចបញ្ញត្តិ ១ ឥន្ទ្រិយបញ្ញត្តិ ១ បុគ្គលបញ្ញត្តិ ១ ។*

## ខន្ធបញ្ញត្តិ

[ ២ ] *ខន្ធបញ្ញត្តិរបស់ខន្ធទាំងឡាយ មានប៉ុន្មាន ។ ខន្ធ ៥ គឺរូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ មានប្រមាណប៉ុនណា ខន្ធបញ្ញត្តិរបស់ខន្ធទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។*

## អាយតនបញ្ញត្តិ

[ ៣ ] *អាយតនបញ្ញត្តិ របស់អាយតនៈទាំងឡាយ មានប៉ុន្មាន ។ អាយតនៈ ១២ គឺចក្ខាយតនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ មានប្រមាណប៉ុនណា អាយតនបញ្ញត្តិរបស់អាយតនៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។*

# ធាតុបញ្ញត្តិ

[ ៤ ] ធាតុបញ្ញត្តិរបស់ធាតុទាំងឡាយ មានប៉ុន្មាន ។ ធាតុ ១៨ គឺ ចក្ខុធាតុ ១ រូបធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតធាតុ ១ សទ្ទធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានធាតុ ១ គន្ធធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាធាតុ ១ រសធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយធាតុ ១ ផោដ្ឋព្វធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ ធម្មធាតុ ១ មនោវិញ្ញាណធាតុ ១ មានប្រមាណប៉ុនណា ធាតុបញ្ញត្តិរបស់ធាតុទាំងឡាយមានប្រមាណប៉ុណ្ណោះ ។

# សច្ចបញ្ញត្តិ

[ ៥ ] សច្ចបញ្ញត្តិរបស់សច្ចៈទាំងឡាយ មានប៉ុន្មាន ។ សច្ចៈ ៤ គឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ មានប្រមាណប៉ុនណា សច្ចបញ្ញត្តិរបស់សច្ចៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

# ឥន្ទ្រិយបញ្ញត្តិ

[ ៦ ] ឥន្ទ្រិយបញ្ញត្តិរបស់ឥន្ទ្រិយទាំងឡាយ មានប៉ុន្មាន ។ ឥន្ទ្រិយ ២២ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតា-

វិន្ទ្រិយ ១ មានប្រមាណប៉ុនណា ឥន្ទ្រិយប្បញ្ញត្តិរបស់ឥន្ទ្រិយទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

# បុគ្គលប្បញ្ញត្តិ

បុគ្គលប្បញ្ញត្តិរបស់បុគ្គលទាំងឡាយ មានប៉ុន្មាន ។

## ឯកកមាតិកា

[ ៧ ] បុគ្គលជាសមយវិមុត្ត ( អ្នករួចស្រឡះតាមកាលគួរ ) បុគ្គលជាអសមយវិមុត្ត ( អ្នករួចស្រឡះចាកអាសវៈតាមកាលមិនគួរ ) បុគ្គលជាកុប្បធម្មៈ ( មានធម៌កម្រើក ) បុគ្គលជាអកុប្បធម្មៈ ( មានធម៌មិនកម្រើក ) បុគ្គលជាបរិហានធម្មៈ ( មានធម៌សាបសូន្យ ) បុគ្គលជាអបរិហានធម្មៈ ( មានធម៌មិនសាបសូន្យ ) បុគ្គលជាចេតនាភព្វៈ ( គួរដោយចេតនា ) បុគ្គលជាអនុរក្ខនាភព្វៈ ( គួរដោយការរក្សា ) បុគ្គលជាបុថុជ្ជន បុគ្គលជាគោត្រភូ បុគ្គលជាភយូបរតៈ ( វៀរចាកបាបដោយភ័យ ) បុគ្គលជាអភយូបរតៈ ( វៀរចាកបាបដោយមិនមានភ័យ ) បុគ្គលជាភព្វាគមនៈ ( គួរដល់កិរិយាមកកាន់សម្មត្តនិយាម គឺមគ្គ ) បុគ្គលជាអភព្វាគមនៈ ( មិនគួរដល់កិរិយាមកកាន់សម្មត្តនិយាម ) បុគ្គលជានិយតៈ ( បុគ្គលទៀង ) បុគ្គលជាអនិយតៈ ( បុគ្គលមិនទៀង ) បុគ្គលជាបដិបន្នកៈ ( បុគ្គលប្រតិបត្តិព្រមព្រៀងដោយមគ្គ ) បុគ្គលជាផលេដ្ឋិតៈ ( បុគ្គលស្ថិតនៅក្នុងផល ) បុគ្គលជាសមសីសី ( មានធម៌ជាប្រធានស្មើគ្នា ) បុគ្គលជាឋិត-

កប្បី ( ញុំាងកប្បឲ្យស្ថិតនៅ ) បុគ្គលជាអរិយៈ បុគ្គលមិនមែនជាអរិយៈ បុគ្គលជាសេក្ខៈ បុគ្គលជាអសេក្ខៈ បុគ្គលមិនមែនសេក្ខៈ ទាំងមិនមែនអសេក្ខៈ បុគ្គលមានវិជ្ជា ៣ បុគ្គលមានអភិញ្ញា ៦ បុគ្គលជាព្រះសម្មាសម្ពុទ្ធ បុគ្គលជាព្រះបច្ចេកពុទ្ធ បុគ្គលជាឧភតោភាគវិមុត្ត ( រួចស្រឡះដោយចំណែកទាំងពីរ ) បុគ្គលជាបញ្ញាវិមុត្ត ( រួចស្រឡះដោយបញ្ញា ) បុគ្គលជាកាយសក្ខី ( មានកាយជាបន្ទាល់ ) បុគ្គលជាទិដ្ឋិប្បត្តៈ ( សម្រេចដោយទិដ្ឋិ ) បុគ្គលជាសទ្ធាវិមុត្ត ( រួចស្រឡះដោយសទ្ធា ) បុគ្គលជាធម្មានុសារី ( រឭកតាមធម៌ ) បុគ្គលជាសទ្ធានុសារី ( រឭកតាមសទ្ធា ) បុគ្គលជាសត្តក្ខត្តុំបរមៈ ( កើតអស់វារៈ ៧ ដង ) បុគ្គលជាកោលំកោលៈ ( ចេញពីត្រកូលទៅកាន់ត្រកូល ) បុគ្គលជាឯកពីជី ( មានពូជ គឺខន្ធតែមួយ ) បុគ្គលជាសកទាគាមី ( មកកាន់លោកនេះម្តងទៀត ) បុគ្គលជាអនាគាមី ( មិនមកកាន់លោកនេះទៀត ) បុគ្គលជាអន្តរាបរិនិព្វាយី ( បរិនិព្វានពាក់កណ្តាលអាយុ ) បុគ្គលជាឧបហច្ចបរិនិព្វាយី ( កន្លងហួសពាក់កណ្តាលអាយុទើបបរិនិព្វាន ) បុគ្គលជាអសង្ខារបរិនិព្វាយី ( បរិនិព្វានដោយមិនបាច់ព្យាយាមខ្លាំង ) បុគ្គលជាសសង្ខារបរិនិព្វាយី ( បរិនិព្វានដោយព្យាយាមខ្លាំង ) បុគ្គលជាឧទ្ធំសោតអកនិដ្ឋគាមី ( មានខ្សែនៃមគ្គទៅខាងលើដរាបដល់អកនិដ្ឋព្រហ្មហើយបរិនិព្វាន ) បុគ្គលជាសោតាបន្នៈ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល បុគ្គលជាសកទាគាមី ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បុគ្គលជាអនាគាមី ប្រតិបត្តិដើម្បីធ្វើឲ្យ

ជាក់ច្បាស់នូវអនាគាមិផល បុគ្គលជាអរហន្ត ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

ឯកកមាតិកា ចប់

# ទុកមាតិកា

[ ៨ ] បុគ្គលពីរពួក ។ គឺបុគ្គលមានសេចក្ដីក្រោធ ១ បុគ្គលចងសេចក្ដីក្រោធទុក ១ ។ បុគ្គលអ្នកលុបគុណគេ ១ បុគ្គលអ្នកប្រណាំងវាសនា ១ ។ បុគ្គលមានសេចក្ដីច្រណែន ១ បុគ្គលមានសេចក្ដីកំណាញ់ ១ ។ បុគ្គលមានសេចក្ដីអួតអាង ១ បុគ្គលមានមាយា ១ ។ បុគ្គលមិនខ្មាសបាប ១ បុគ្គលមិនខ្លាចបាប ១ ។ បុគ្គលប្រដៅក្រ ១ បុគ្គលមានមិត្តអាក្រក់ ១ ។ បុគ្គលមានទ្វារមិនរក្សាក្នុងឥន្ទ្រិយទាំងឡាយ ១ បុគ្គលមិនដឹងប្រមាណក្នុងភោជន ១ ។ បុគ្គលភ្លេចស្មារតី ១ បុគ្គលមិនដឹងខ្លួន ១ ។ បុគ្គលវិបត្តិសីល ១ បុគ្គលវិបត្តិទិដ្ឋិ ១ ។ បុគ្គលមានសញ្ញោជនៈខាងក្នុង ១ បុគ្គលមានសញ្ញោជនៈខាងក្រៅ ១ ។ បុគ្គលមិនមានសេចក្ដីក្រោធ ១ បុគ្គលមិនចងសេចក្ដីក្រោធទុក ១ ។ បុគ្គលមិនលុបគុណគេ ១ បុគ្គលមិនប្រណាំងវាសនា ១ ។ បុគ្គលមិនមានសេចក្ដីច្រណែន ១ បុគ្គលមិនមានសេចក្ដីកំណាញ់ ១ ។ បុគ្គលមិនមានអំនួត ១ បុគ្គលមិនមានមាយា ១ ។ បុគ្គលមានសេចក្ដីខ្មាសបាប ១ បុគ្គលមានសេចក្ដីខ្លាចបាប ១ ។ បុគ្គលប្រដៅងាយ ១ បុគ្គលមានមិត្តល្អ ១ ។ បុគ្គលមានទ្វាររក្សាហើយក្នុងឥន្ទ្រិយ

ទាំងឡាយ ១ បុគ្គលអ្នកដឹងប្រមាណក្នុងភោជន ១ ។ បុគ្គលមានស្មារតីតម្កល់មាំ ១ បុគ្គលអ្នកដឹងខ្លួន ១ ។ បុគ្គលបរិបូរណ៍ដោយសីល ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ ១ ។ បុគ្គលពីរពួករកបានដោយក្រក្នុងលោក ។ បុគ្គលពីរពួក គេចំអែតបានដោយក្រ ។ បុគ្គលពីរពួក គេចំអែតបានដោយងាយ ។ អាសវៈរបស់បុគ្គលពីរពួករមែងចម្រើន ។ អាសវៈរបស់បុគ្គលពីរពួករមែងមិនចម្រើន ។ បុគ្គលមានអធ្យាស្រ័យថោកទាប ១ បុគ្គលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ១ ។ បុគ្គលឆ្អែតដោយខ្លួនឯង ១ បុគ្គលញ៉ាំងគេឲ្យឆ្អែត ១ ។

ទុកមាតិកា ចប់

## តិកមាតិកា

[ ៩ ] បុគ្គល ៣ ពួក ។ គឺបុគ្គលមិនមានបំណង ១ បុគ្គលមានបំណង ១ បុគ្គលប្រាសចាកបំណង ១ ។ បុគ្គល ៣ ពួក ប្រៀបដោយបុគ្គលមានជំងឺ ។ បុគ្គលជាកាយសក្ខី ( មានកាយជាបន្ទាល់ ) ១ បុគ្គលជាទិដ្ឋិប្បត្តៈ ( សម្រេចដោយទិដ្ឋិ ) ១ បុគ្គលជាសទ្ធាវិមុត្ត ( រួចស្រឡះចាកអាសវៈដោយសទ្ធា ) ។ បុគ្គលមានសម្តីដូចលាមក ១ បុគ្គលមានសម្តីដូចផ្កា ១ បុគ្គលមានសម្តីដូចទឹកឃ្មុំ ១ ។ បុគ្គលមានចិត្តប្រៀបដោយដំបៅ ១ បុគ្គលមានចិត្ត ប្រៀបដោយផ្លេកបន្ទោរ ១ បុគ្គលមានចិត្តប្រៀបដោយពេជ្រ ១ ។ បុគ្គលខ្វាក់ ១ បុគ្គលមានភ្នែកម្ខាង ១ បុគ្គលមានភ្នែកទាំងពីរ

១ ។ បុគ្គលមានបញ្ញាដូចក្អមផ្កាប់ ១ បុគ្គលមានបញ្ញាដូចថ្នក់លេច ១ បុគ្គលមានបញ្ញាក្រាស់ ១ ។ បុគ្គលខ្លះមិនប្រាសចាកតម្រេកក្នុងកាម និងភព ក៏មាន ១ បុគ្គលខ្លះប្រាសចាកតម្រេកក្នុងកាម តែមិនទាន់ប្រាសចាកតម្រេក ក្នុងភពក៏មាន ១ បុគ្គលខ្លះប្រាសចាកតម្រេកក្នុងកាមផង ក្នុងភពផងក៏មាន ១ ។ បុគ្គលប្រៀបដោយគំនូសថ្ម ១ បុគ្គលប្រៀបដោយគំនូសដី ១ បុគ្គល ប្រៀបដោយគំនូសទឹក ១ ។ បុគ្គល ៣ ពួកប្រៀបដោយសំពត់សម្បកឈើ ។ បុគ្គល ៣ ពួកប្រៀបដោយសំពត់កាសិកៈ ។ បុគ្គលដែលគេប្រមាណបាន ដោយងាយ ១ បុគ្គលដែលគេប្រមាណបានដោយក្រ ១ បុគ្គលដែលគេ ប្រមាណមិនបាន ១ ។ បុគ្គលខ្លះមិនគួរគេសេព មិនគួរគប់ មិនគួរចូលទៅ អង្គុយជិតក៏មាន ១ បុគ្គលខ្លះគួរគេសេព គួរគប់ គួរចូលទៅអង្គុយជិតក៏ មាន ១ បុគ្គលខ្លះគួរធ្វើសក្ការៈ គោរព ហើយសេពគប់ ចូលទៅអង្គុយជិត ក៏មាន ១ ។ បុគ្គលខ្លះគួរគេខ្ពើម មិនគួរសេព មិនគួរគប់ មិនគួរចូលទៅ អង្គុយជិតក៏មាន ១ បុគ្គលខ្លះគួរគេមិលមើល តែមិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិតក៏មាន ១ បុគ្គលខ្លះគួរគេសេព គួរគប់ គួរចូលទៅ អង្គុយជិតក៏មាន ១ ។ បុគ្គលខ្លះធ្វើពេញលេញក្នុងសីល តែធ្វើបន្តិចបន្តួច ក្នុងសមាធិ ធ្វើបន្តិចបន្តួចក្នុងបញ្ញាក៏មាន ១ បុគ្គលខ្លះធ្វើពេញលេញក្នុង សីលផង ធ្វើពេញលេញក្នុងសមាធិផង តែធ្វើបន្តិចបន្តួចក្នុងបញ្ញាក៏មាន ១ បុគ្គលខ្លះធ្វើពេញលេញក្នុងសីលផង ធ្វើពេញលេញក្នុងសមាធិផង ធ្វើពេញ លេញក្នុងបញ្ញាផងក៏មាន ១ ។ បុគ្គលជាគ្រូមាន ៣ ពួក បុគ្គលជាគ្រូ ៣

ពួកដទៃទៀត ។

**តិកមាតិកា ចប់**

## ចតុក្កមាតិកា

[ ១០ ] បុគ្គល ៤ ពួក ។ គឺបុគ្គលជាអសប្បុរស ១ បុគ្គលជាអសប្បុរសក្រៃលែងជាងអសប្បុរស ១ បុគ្គលជាសប្បុរស ១ បុគ្គលជាសប្បុរសក្រៃលែងជាងសប្បុរស ១ ។ បុគ្គលអាក្រក់ ១ បុគ្គលអាក្រក់ក្រៃលែងជាងបុគ្គលអាក្រក់ ១ បុគ្គលល្អ ១ បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ១ ។ បុគ្គលមានធម៌អាក្រក់ ១ បុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ ១ បុគ្គលមានធម៌ល្អ ១ បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ ១ ។ បុគ្គលប្រកបដោយទោស ១ បុគ្គលច្រើនដោយទោស ១ បុគ្គលប្រកបដោយទោសតិច ១ បុគ្គលមិនមានទោស ១ ។ បុគ្គលជាឧគ្ឃដិតញ្ញូ ១ បុគ្គលជាវិបចិតញ្ញូ ១ បុគ្គលជានេយ្យៈ ១ បុគ្គលជាបទបរមៈ ១ ។ បុគ្គលមានប្រាជ្ញាគួរ តែមានប្រាជ្ញាមិនរួសរាន់ ១ បុគ្គលមានប្រាជ្ញារួសរាន់ តែមានប្រាជ្ញាមិនគួរ ១ បុគ្គលមានប្រាជ្ញាគួរ ទាំងមានប្រាជ្ញារួសរាន់ ១ ។ បុគ្គលមានប្រាជ្ញាមិនគួរ ទាំងមានប្រាជ្ញាមិនរួសរាន់ ១ ។ បុគ្គលជាធម្មកថិក ៤ ពួក ។ បុគ្គល ៤ ពួកប្រៀបដោយមេឃ ។ បុគ្គល ៤ ពួកប្រៀបដោយកណ្តុរ ។ បុគ្គល ៤ ពួកប្រៀបដោយផ្លែស្វាយ ។ បុគ្គល ៤ ពួកប្រៀបដោយក្អម ។ បុគ្គល ៤ ពួកប្រៀបដោយអន្លង់ទឹក ។

បុគ្គល ៤ ពួកប្រៀបដោយគោបម្រើ ។ បុគ្គល ៤ ពួកប្រៀបដោយសត្វអាសិរពិស ។ បុគ្គលខ្លះមិនពិចារណា មិនស្ទង់មើល ហើយពោលសរសើរបុគ្គលដែលគួរតិះដៀលក៏មាន ១ បុគ្គលខ្លះមិនពិចារណា មិនស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរសរសើរក៏មាន ១ បុគ្គលខ្លះមិនពិចារណា មិនស្ទង់មើល ហើយសម្តែងសេចក្តីជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លាក៏មាន ១ បុគ្គលខ្លះមិនពិចារណា មិនស្ទង់មើល ហើយសម្តែងសេចក្តីមិនជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លាក៏មាន ១ ។ បុគ្គលខ្លះពិចារណា ស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរតិះដៀលក៏មាន ១ បុគ្គលខ្លះពិចារណា ស្ទង់មើល ហើយពោលសរសើរបុគ្គលដែលគួរសរសើរក៏មាន ១ បុគ្គលខ្លះពិចារណា ស្ទង់មើល ហើយសម្តែងសេចក្តីមិនជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លាក៏មាន ១ បុគ្គលខ្លះពិចារណា ស្ទង់មើល ហើយសម្តែងសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លាក៏មាន ១ ។ បុគ្គលខ្លះពោលតិះដៀលបុគ្គល ដែលមិនគួរតិះដៀលពិតប្រាកដតាមកាលគួរ តែមិនពោលសរសើរបុគ្គល ដែលគួរសរសើរពិតប្រាកដ តាមកាលគួរក៏មាន ១ បុគ្គលខ្លះ ពោលសរសើរបុគ្គលដែលគួរសរសើរពិតប្រាកដតាមកាលគួរ តែមិនពោលតិះដៀលបុគ្គល ដែលគួរតិះដៀលពិតប្រាកដតាមកាលគួរក៏មាន ១ បុគ្គលខ្លះពោលតិះដៀលបុគ្គលដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរផង ពោលសរសើរបុគ្គល ដែលគួរសរសើរពិតប្រាកដ តាមកាលគួរផងក៏មាន ។ បុគ្គលខ្លះ មិនពោលតិះដៀលបុគ្គលដែលគួរតិះដៀលពិតប្រាកដតាមកាលគួរផង មិនពោលសរសើរបុគ្គល

ដែលគួរសរសើរពិតប្រាកដតាមកាលគួរផងក៏មាន ១ ។ បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម មិនចិញ្ចឹមជីវិតដោយផលនៃបុណ្យ ១ បុគ្គលចិញ្ចឹមជីវិតដោយផលនៃបុណ្យ មិនចិញ្ចឹមជីវិត ដោយផលនៃការព្យាយាម ១ បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងចិញ្ចឹមជីវិតដោយផលនៃបុណ្យ ១ បុគ្គលមិនចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងមិនចិញ្ចឹមជីវិតដោយផលនៃបុណ្យ ១ ។ បុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខ ១ បុគ្គលងងឹត មានពន្លឺប្រព្រឹត្តទៅខាងមុខ ១ បុគ្គលភ្លឺ មានងងឹតប្រព្រឹត្តទៅខាងមុខ ១ បុគ្គលភ្លឺ មានពន្លឺប្រព្រឹត្តទៅខាងមុខ ១ ។ បុគ្គលឱនចុះហើយឱនចុះទៀត ១ បុគ្គលឱនចុះហើយងើបឡើង ១ បុគ្គលងើបឡើងហើយឱនចុះទៅវិញ ១ បុគ្គលងើបឡើងហើយ ងើបឡើងទៀត ១ ។ បុគ្គល ៤ ពួកប្រៀបដោយដើមឈើ ។ បុគ្គលមានរូបជាប្រមាណ ជ្រះថ្លាព្រោះរូប ១ បុគ្គលមានសំឡេងជាប្រមាណ ជ្រះថ្លាព្រោះសំឡេង ១ បុគ្គលមានវត្ថុសៅហ្មងជាប្រមាណ ជ្រះថ្លាព្រោះវត្ថុសៅហ្មង ១ បុគ្គលមានធម៌ជាប្រមាណ ជ្រះថ្លាព្រោះធម៌ ១ ។ បុគ្គលខ្លះប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃក៏មាន ១ បុគ្គលខ្លះ ប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ តែមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនក៏មាន ១ បុគ្គលខ្លះប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ដើម្បីប្រយោជន៍បុគ្គលដទៃផងក៏មាន ១ បុគ្គលខ្លះ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃក៏មាន ១ ។ បុគ្គលខ្លះដុតកម្តៅខ្លួនឯង ប្រកបការព្យាយាមដើម្បីដុត

កម្តៅខ្លួនឯងក៏មាន ១ បុគ្គលខ្លះ ដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ដើម្បីដុតកម្តៅបុគ្គលដទៃក៏មាន ១ បុគ្គលខ្លះ ដុតកម្តៅខ្លួនឯង ប្រកបការ ព្យាយាមដើម្បីដុតកម្តៅខ្លួនឯងផង ដុតកម្តៅបុគ្គលដទៃ ប្រកបការព្យាយាម ដើម្បីដុតកម្តៅបុគ្គលដទៃផងក៏មាន ១ បុគ្គលខ្លះ មិនដុតកម្តៅខ្លួនឯង មិន ប្រកបព្យាយាម ដើម្បីដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅបុគ្គលដទៃ មិនប្រកប ព្យាយាមដើម្បីដុតកម្តៅបុគ្គលដទៃ បុគ្គលនោះមិនដុតកម្តៅខ្លួនឯង មិនដុត កម្តៅបុគ្គលដទៃ ជាអ្នកមិនស្រេកឃ្លាន ជាអ្នករលត់ទុក្ខ ត្រជាក់ត្រជុំ ទទួល សេចក្តីសុខ មានខ្លួនដ៏ប្រសើរ សម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្នក៏មាន ១ ។ បុគ្គលប្រកបដោយរាគៈ ១ បុគ្គលប្រកបដោយទោសៈ ១ បុគ្គលប្រកប ដោយមោហៈ ១ បុគ្គលប្រកបដោយមានះ ១ ។ បុគ្គលខ្លះ ជាអ្នកបាន ចេតោសមថៈក្នុងសន្តាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនាក៏មាន ១ បុគ្គល ខ្លះ ជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនា មិនបានចេតោសមថៈ ក្នុងសន្តានក៏ មាន ១ បុគ្គលខ្លះជាអ្នកបានចេតោសមថៈក្នុងសន្តាន ទាំងបានអធិប្បញ្ញា- ធម្មវិបស្សនាក៏មាន ១ បុគ្គលខ្លះ ជាអ្នកមិនបានចេតោសមថៈ ក្នុងសន្តាន ទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនាក៏មាន ១ ។ បុគ្គលទៅបណ្តោយតាមខ្សែ ទឹក គឺវដ្តៈ ១ បុគ្គលទៅច្រាសខ្សែទឹក គឺវដ្តៈ ១ បុគ្គលមានខ្លួនតាំងនៅនឹង ១ បុគ្គលឆ្លងទៅដល់ត្រើយ ជាព្រាហ្មណ៍ស្ថិតនៅលើគោក ១ ។ បុគ្គល ជាអ្នកចេះដឹងតិច មិនប្រតិបត្តិតាមដោយសេចក្តីចេះដឹង ១ បុគ្គលជាអ្នកចេះ ដឹងតិច តែប្រតិបត្តិតាមសេចក្តីចេះដឹង ១ បុគ្គលជាអ្នកចេះដឹងច្រើន មិន

ប្រតិបត្តិតាមសេចក្តីចេះដឹង ១ បុគ្គលចេះដឹងច្រើន ប្រតិបត្តិតាមសេចក្តីចេះដឹង ១ ។ បុគ្គលជាសមណៈ មិនកម្រើក ១ បុគ្គលជាសមណៈផ្កាឈូកក្រហម ១ បុគ្គលជាសមណៈផ្កាឈូក-ស ១ បុគ្គលជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ១ ។

ចតុក្កមាតិកា ចប់

# បញ្ចកមាតិកា

[ ១១ ] បុគ្គល ៥ ពួក ។ គឺបុគ្គលខ្លះប្រព្រឹត្តល្មើស ( ត្រូវអាបត្តិ ) ផង មានសេចក្តីក្តៅក្រហាយផង មិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះរបស់បុគ្គលនោះដែលកើតឡើងហើយ ឲ្យរលត់ទៅវិញ មិនមានសេសសល់ផងក៏មាន ១ បុគ្គលខ្លះប្រព្រឹត្តល្មើស មិនមានសេចក្តីក្តៅក្រហាយ ទាំងមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះដែលកើតឡើងហើយ ឲ្យរលត់ទៅវិញមិនមានសេសសល់ក៏មាន ១ បុគ្គលខ្លះ មិនប្រព្រឹត្តល្មើសទេ មានសេចក្តីក្តៅក្រហាយ ទាំងមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិនោះ ដែលជាហេតុធ្វើឲ្យអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះដែលកើតឡើងហើយ ឲ្យរលត់ទៅវិញមិនមានសេសសល់ក៏មាន ១ បុគ្គលខ្លះ មិនប្រព្រឹត្តល្មើស មិនមានសេចក្តីក្តៅក្រហាយទេ មិនដឹងច្បាស់

តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើឲ្យអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើងហើយ ឲ្យរលត់ទៅវិញមិនមានសេសសល់ក៏មាន ១ បុគ្គលខ្លះមិនប្រព្រឹត្តល្មើស មិនមានសេចក្តីក្តៅក្រហាយផង ដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើងហើយ ឲ្យរលត់ទៅវិញមិនមានសេសសល់ផងក៏មាន ១ ។ បុគ្គលឲ្យហើយត្រឡប់មើលងាយវិញ ១ បុគ្គលមើលងាយព្រោះការនៅរួម ១ បុគ្គលមានមាត់តាំងទុកក្លាម ១ បុគ្គលឡេះឡោះ ១ បុគ្គលទន់អន់ ល្ងង់ខ្លៅ ១ ។ បុគ្គល ៥ ពួក ប្រៀបដោយទាហាន ។ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ។ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកធុតង្គ ។ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តឯកាសនិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តរុក្ខមូលិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តអព្ភោកាសិកធុតង្គ ។ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គ ។ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តសោសានិកធុតង្គ ។

**បញ្ចកមាតិកា ចប់**

# ឆក្កមាតិកា

[ ១២ ] បុគ្គល ៦ ពួក ។ គឺបុគ្គលខ្លះត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន ក៏ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងនោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផងក៏មាន ១ បុគ្គលខ្លះត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន មិនដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង មិនដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផងក៏មាន ១ បុគ្គលខ្លះមិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន ក៏ធ្វើនូវទីបំផុតទុក្ខក្នុងបច្ចុប្បន្នផងដល់នូវសាវកបារមីញាណផងក៏មាន ១ បុគ្គលខ្លះ មិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈ ក្នុងធម៌ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន ក៏ធ្វើនូវទីបំផុតទុក្ខក្នុងបច្ចុប្បន្ន មិនដល់នូវសាវកបារមីញាណក៏មាន ១ បុគ្គលខ្លះ មិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន មិនធ្វើនូវទីបំផុតទុក្ខក្នុងបច្ចុប្បន្នទេ ជាអនាគាមិបុគ្គល មិនមកកាន់មនុស្សលោកនេះក៏មាន ១ បុគ្គលខ្លះ មិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន មិនធ្វើនូវទីបំផុតទុក្ខក្នុងបច្ចុប្បន្នទេ ជាសោតាបន្នបុគ្គល និងសកទាគាមិបុគ្គល មកកាន់មនុស្សលោកនេះទៀតក៏មាន ១ ។

ឆក្កមាតិកា ចប់

## សត្តកមាតិកា

[ ១៣ ] បុគ្គល ៧ ពួក ។ គឺបុគ្គល ៧ ពួក ប្រៀបដោយទឹក គឺ បុគ្គលមុជចុះតែម្តងហើយ ចេះតែមុជចុះទៅទៀត ១ បុគ្គលងើបឡើងហើយ មុជចុះទៅវិញ ១ បុគ្គលងើបឡើងហើយស្ថិតនៅ ១ បុគ្គលងើបឡើងហើយ រមិលមើលក្រឡេកមើល ១ បុគ្គលងើបឡើង ហើយហែលទៅ ១ បុគ្គល ងើបឡើងដល់កំពង់ ហើយស្ថិតនៅ ១ បុគ្គលងើបឡើង ឆ្លងដល់ត្រើយជា ព្រាហ្មណ៍ ស្ថិតនៅលើគោក ១ ។ បុគ្គលជាឧភតោភាគវិមុត្ត ១ បុគ្គលជា បញ្ញាវិមុត្ត ១ បុគ្គលជាកាយសក្ខី ១ បុគ្គលជាទិដ្ឋិប្បត្តៈ ១ បុគ្គលជាសទ្ធា- វិមុត្ត ១ បុគ្គលជាធម្មានុសារី ១ បុគ្គលជាសទ្ធានុសារី ១ ។

*សត្តកមាតិកា ចប់*

## អដ្ឋកមាតិកា

[ ១៤ ] បុគ្គល ៨ ពួក ។ គឺបុគ្គល ៤ ពួក ព្រមព្រៀងដោយមគ្គ បុគ្គល ៤ ពួក ព្រមព្រៀងដោយផល ។

*អដ្ឋកមាតិកា ចប់*

## នវកមាតិកា

[ ១៥ ] បុគ្គល ៩ ពួក ។ គឺបុគ្គលជាព្រះសម្មាសម្ពុទ្ធ ១ បុគ្គលជា ព្រះបច្ចេកសម្ពុទ្ធ ១ បុគ្គលជាឧភតោភាគវិមុត្ត ១ បុគ្គលជាបញ្ញាវិមុត្ត ១ បុគ្គលជាកាយសក្ខី ១ បុគ្គលជាទិដ្ឋិប្បត្តៈ ១ បុគ្គលជាសទ្ធាវិមុត្ត ១ បុគ្គល

ជាធម្មានុសារី ១ បុគ្គលជាសទ្ធានុសារី ១ ។

នវកមាតិកា ចប់

## ទសកមាតិកា

[ ១៦ ] បុគ្គល ១០ ពួក ។ គឺបុគ្គល ៥ ពួក មានការសម្រេចក្នុងកាមាវចរភូមិនេះ បុគ្គល ៥ ពួក មានការសម្រេចព្រោះលះបង់អត្តភាពក្នុងកាមាវចរភូមិនេះ ។

ទសកមាតិកា ចប់

បុគ្គលប្បញ្ញត្តិមាតិកា ចប់

# អដ្ឋកថា

## បរមត្ថទីបនី បញ្ចបករណ៍
## អដ្ឋកថា បុគ្គលប្បញ្ញត្តិប្បករណ៍

### អារម្ភកថា

ព្រះសាស្តា ទ្រង់ប្រកាសប្រភេទនៃធាតុ កាលទ្រង់សម្តែងធាតុកថាបករណ៍ ដែលមានអត្ថល្អិតល្អន់ក្នុងសុរាល័យទេវលោកចប់ហើយ ព្រះជិនស្រី ដែលជាអគ្គបុគ្គលក្នុងលោក ត្រាស់គម្ពីរបុគ្គលប្បញ្ញត្តិណា ដែលសម្តែងដល់ប្រភេទនៃបញ្ញត្តិ ក្នុងលំដាប់នៃធាតុកថានោះ ។

ឥឡូវនេះ ដល់ឱកាសនៃកិច្ចពណ៌នាគម្ពីរបុគ្គលប្បញ្ញត្តិនោះហើយ ព្រោះហេតុនោះ ខ្ញុំពុទ្ធឃោសាចារ្យ នឹងពណ៌នាបករណ៍នោះ អ្នកទាំងឡាយ ចូរមានចិត្តតាំងមាំ ស្តាប់ព្រះសទ្ធម្មនោះហោង ៕

# មាតិកា

## ឧទ្ទេសវារៈ

[ ១-១៦ ] ឧទ្ទេសនៃបុគ្គលប្បញ្ញត្តិថា **ឆ បញ្ញត្តិយោ ខន្ធប្បញ្ញត្តិ** ។បេ។ **បុគ្គលប្បញ្ញត្តិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឆ** ជាការកំណត់ចំនួន ។ ដោយបទនោះ ព្រះមានព្រះភាគ ទ្រង់បំណងនឹងបញ្ញត្តធម៌ពួកណាក្នុងបករណ៍នេះ ទើបទ្រង់សម្ដែងការកំណត់បញ្ញត្តិធម៌ទាំងនោះ ដោយការរាប់ដោយសង្ខេប ។ បទថា **បញ្ញត្តិយោ** ជាពាក្យសម្ដែងលម្អិតធម៌ ដែលព្រះមានព្រះភាគ ទ្រង់កំណត់ទុក ។ ក្នុងមាតិកាទាំងនោះ ការបញ្ញត្ត ការសម្ដែង ការប្រកាសក្នុងអាគតដ្ឋាន ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ទើបប្រាប់ សម្ដែង ពន្យល់ តែងតាំង ដូច្នេះ ឈ្មោះថា បញ្ញត្តិ ។ ការតែងតាំង ការដាក់ក្នុងអាគតដ្ឋាន ( វិនយបិដក តេរសកណ្ឌ ) ថា ត្រៃតាំង ក៏រៀបចំល្អ ដូច្នេះ ក៏ឈ្មោះថា បញ្ញត្តិ ។ បញ្ញត្តិទាំង ២ នេះ រមែងសមគួរ ។

ពិតហើយ បទថា **ឆ បញ្ញត្តិយោ** បានដល់ ការបញ្ញត្ត ៦ ការសម្ដែង ៦ ការប្រកាស ៦ ដូច្នេះក្ដី ការតាំងទុក ៦ ការដាក់ទុក ៦ ដូច្នេះក្ដី ព្រះមានព្រះភាគ ទ្រង់បំណងយកហើយ ក្នុងទីនេះ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ទាំងនោះ ប្រកបដោយនាមប្បញ្ញត្តិខ្លះ ទ្រង់តាំងធម៌ទាំងនោះដោយកោដ្ឋាសនោះៗ ខ្លះ ។

បទថា **ខន្ធប្បញ្ញត្តិ** ជាដើម ជាបទសម្ដែងសរុបបញ្ញត្តិទាំងនោះ

ដោយសង្ខេប ។ បណ្តាបញ្ញត្តិ ៦ នោះ ការបញ្ញត្ត ការសម្តែង ការប្រកាស ការតែងតាំង ការដាក់ទុកនូវធម៌ទាំងឡាយដែលជាពួកជាមួយគ្នាជាខន្ធ ឈ្មោះថា ខន្ធប្បញ្ញត្តិ ។ ការបញ្ញត្ត ការសម្តែង ការប្រកាស ការតែងតាំង ការដាក់ទុកនូវធម៌ទាំងឡាយដែលជាប្រកពកើត ថាជាអាយតនៈ ឈ្មោះថា អាយតនប្បញ្ញត្តិ ។ ការបញ្ញត្ត ... នូវធម៌ទាំងឡាយ ដែលជាសភាវៈទ្រទ្រង់ ថាជាធាតុ ឈ្មោះថា ធាតុប្បញ្ញត្តិ ។ ការបញ្ញត្ត ... នូវធម៌ទាំងឡាយដែលពិត ឈ្មោះថា សច្ចប្បញ្ញត្តិ ។ ការបញ្ញត្ត ... នូវធម៌ដែលជាធំទាំងឡាយថាជាឥន្ទ្រិយ ឈ្មោះថា ឥន្ទ្រិយប្បញ្ញត្តិ ។ ការបញ្ញត្ត ... នូវបុគ្គលទាំងឡាយ ថាជាបុគ្គល ឈ្មោះថា បុគ្គលប្បញ្ញត្តិ ។

ពោលដោយន័យនៃអដ្ឋកថាបាលីមុត្តកៈ គឺក្រៅអំពីព្រះបាលី មានបញ្ញត្តិ ៦ ដទៃទៀត គឺវិជ្ជមានប្បញ្ញត្តិ ១ អវិជ្ជមានប្បញ្ញត្តិ ១ វិជ្ជមានេនអវិជ្ជមានប្បញ្ញត្តិ ១ អវិជ្ជមានេនវិជ្ជមានប្បញ្ញត្តិ ១ វិជ្ជមានេនវិជ្ជមានប្បញ្ញត្តិ ១ អវិជ្ជមានេនអវិជ្ជមានប្បញ្ញត្តិ ១ ។

បណ្តាបញ្ញត្តិទាំង ៦ នោះ ការបញ្ញត្តធម៌ដែលជាកុសល និងអកុសលជារបស់មាន កើត កើតតាមសេចក្តីពិតនេះឯង ដោយអំណាចនៃសច្ចិកត្ថនិងបរមត្ថ ឈ្មោះថា វិជ្ជមានប្បញ្ញត្តិ ។ ម្យ៉ាងទៀត ការបញ្ញត្តពាក្យមានពាក្យថា ស្រី ប្រុសជាដើម ដែលសម្រេចត្រឹមតែជាភាសារបស់សត្វលោកដែលមិនមានពិត ឈ្មោះថា អវិជ្ជមានប្បញ្ញត្តិ ។

ការបញ្ញត្តពាក្យថា សច្ចៈទី ៥ ជាដើម ឬបញ្ញត្តពាក្យថា អណុ បកតិ

បុរសជាដើម របស់ពួកតិរ្ថិយ ដែលគ្រាន់តែជាពាក្យ និងវត្ថុ ដែលត្រិះរិះមិនបាន ដោយប្រការទាំងពួង ក៏ឈ្មោះថា អវិជ្ជមានបញ្ញត្តិ ។ បញ្ញត្តិដែលពោលនេះ មិនមានក្នុងព្រះពុទ្ធសាសនា ព្រោះហេតុនោះ ទើបមិនកាន់យកក្នុងទីនេះ ។ គប្បីជ្រាបបញ្ញត្តិដ៏សេស ៤ ទៀត ដោយអំណាចការកំណត់នូវវិជ្ជមាន និងអវិជ្ជមានទាំងនេះដូចតទៅនេះ

ពិតហើយ ដូចក្នុងប្រយោគថា **តេវិជ្ជោ** បុគ្គលមានវិជ្ជា ៣ **ឆឡភិញ្ញោ** បុគ្គលមានអភិញ្ញា ៦ ជាដើម វិជ្ជា ៣ និងអភិញ្ញា ៦ មានពិតឯបុគ្គលមិនមាន ព្រោះហេតុនោះ ទើបបញ្ញត្តិបែបនេះ ឈ្មោះថា **វិជ្ជមានេនអវិជ្ជមានបញ្ញត្តិ** ព្រោះបញ្ញត្តិវត្ថុដែលមិនមាន ជាមួយវត្ថុដែលមានយ៉ាងនេះថា បុគ្គលឈ្មោះថា មានវិជ្ជា ៣ ព្រោះអត្ថថា វិជ្ជា ៣ របស់បុគ្គលនោះមាន បុគ្គលឈ្មោះថាមានអភិញ្ញា ៦ ព្រោះអត្ថថា អភិញ្ញា ៦ របស់បុគ្គលនោះមានជាដើម ។

ក្នុងពាក្យថា **ឥត្ថីរូបំ** រូបស្រី **បុរិសរូបំ** រូបប្រុសជាដើម ស្រី និងប្រុសមិនមាន រូបមាន ព្រោះហេតុនោះ បញ្ញត្តិបែបនេះ ឈ្មោះថា **អវិជ្ជមានេនវិជ្ជមានបញ្ញត្តិ** ព្រោះបញ្ញត្តិវត្ថុដែលមាន ជាមួយវត្ថុដែលមិនមាន យ៉ាងនេះថា រូបរបស់ស្ត្រី ឈ្មោះថា រូបស្ត្រី រូបរបស់បុរស ឈ្មោះថា រូបបុរសជាដើម ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា **ចក្ខុសម្ផស្សោ សោតសម្ផស្សោ** ជាដើម ធម៌ទាំងឡាយ មានចក្ខុជាដើមក្តី ផស្សចេតសិកក្តី មានដោយពិត

ព្រោះហេតុនោះ ទើបបញ្ញត្តិបែបនេះ ឈ្មោះថា **វិជ្ជមានេនវិជ្ជមានប្បញ្ញត្តិ** ព្រោះបញ្ញត្តិវត្ថុដែលមានជាមួយវត្ថុដែលមាន យ៉ាងនេះថា សម្ផស្សក្នុងចក្ខុ សម្ផស្សកើតអំពីចក្ខុ សម្ផស្សដែលជាផលរបស់ចក្ខុ ឈ្មោះថា ចក្ខុសម្ផស្ស ជាដើម ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា **ខត្តិយបុត្តោ** កូនស្តេច **ព្រាហ្មណ-បុត្តោ** កូនព្រាហ្មណ៍ **សេដ្ឋិបុត្តោ** កូនសេដ្ឋីជាដើម ឥស្សរជនទាំងឡាយ មានក្សត្រជាដើមក្តី មិនមានពិត បុត្តរបស់ជនទាំងនោះក្តីក៏មិនមានពិត ព្រោះហេតុនោះ ទើបបញ្ញត្តិបែបនេះ ឈ្មោះថា **អវិជ្ជមានេនអវិជ្ជមានប្បញ្ញត្តិ** ព្រោះបញ្ញត្តិវត្ថុដែលមិនមាន ជាមួយវត្ថុដែលមិនមាន យ៉ាងនេះថា កូនរបស់ស្តេច ឈ្មោះថា ខត្តិយបុត្តជាដើម ។

បណ្តាបញ្ញត្តិទាំង ៦ នោះ បញ្ញត្តិ ៣ ខាងដើមប៉ុណ្ណោះ ប្រើបានក្នុងបុគ្គលប្បញ្ញត្តិប្បករណ៍នេះ ។

ពិតហើយ ក្នុងឋានៈនេះថា **ខន្ធប្បញ្ញត្តិ ។បេ។ ឥន្ទ្រិយប្បញ្ញត្តិ** បានឈ្មោះថា វិជ្ជមានប្បញ្ញត្តិ ព្រោះបញ្ញត្តិសភាវៈដែលមានពិតប៉ុណ្ណោះ ។ ក្នុងបទថា **បុគ្គលប្បញ្ញត្តិ** បានឈ្មោះថា អវិជ្ជមានប្បញ្ញត្តិ តែក្នុងពាក្យទាំងឡាយ មានបទថា **តេវិជ្ជោ** បុគ្គលមានវិជ្ជា ៣ **ឆឡភិញ្ញោ** បុគ្គលមានអភិញ្ញា ៦ ជាដើមខាងមុខ បានឈ្មោះថា **វិជ្ជមានេនអវិជ្ជមានប្បញ្ញត្តិ** ។

ពោលដោយន័យរបស់អាចារ្យ ដែលជាអដ្ឋកថាមុត្តកៈ មានបញ្ញត្តិ ៦ ដទៃទៀត គឺឧបាទាបញ្ញត្តិ ១ ឧបនិធាបញ្ញត្តិ ១ សមោធានប្បញ្ញត្តិ ១

ឧបនិក្ខិត្តប្បញ្ញត្តិ ១ តជ្ជាបញ្ញត្តិ ១ សន្តតិប្បញ្ញត្តិ ១ ។

បណ្តាបញ្ញត្តិទាំង ៦ នោះ បញ្ញត្តិបែបនេះថា ធម៌ណាជាសភាវៈដែលស្វែងរកមិនបាន ដោយសច្ចិកត្ថ និងបរមត្ថ ដូចធម៌ទាំងឡាយ មានរូប និងវេទនាជាដើម ដោយភាពជារបស់តែមួយ ឬមួយបែបម្យ៉ាង ដោយជារូប និងវេទនាជាដើម សន្មតថាជាសត្វ ព្រោះចូលទៅអាស្រ័យ គឺអាស្រ័យខន្ធទាំងឡាយ មានរូប និងវេទនាជាដើម ធ្វើឲ្យជាហេតុ សន្មតថាជារថ ផ្ទះ កងដៃ ជើងក្រាន ព្រោះអាស្រ័យចំណែកទាំងឡាយនោះៗ សន្មតថាជាក្អម សំពត់ ( បដា ) ព្រោះអាស្រ័យធម៌ទាំងឡាយ មានរូប និងរសជាដើមនោះៗ ឯងសន្មតថាជាកាលវេលា ទិសទាំងឡាយ ព្រោះអាស្រ័យការគោចរនៃព្រះចន្ទ និងព្រះអាទិត្យជាដើម សន្មតថាជាឧគ្គហនិមិត្ត និងបដិភាគនិមិត្ត ដែលប្រាកដដោយអាការនោះៗ ព្រោះចូលទៅអាស្រ័យ គឺអាស្រ័យនូវនិមិត្តនៃភូតរូបនោះៗ និងអានិសង្សនៃភាវនាធ្វើឲ្យជាហេតុ ឈ្មោះថា ឧបាទាបញ្ញត្តិ ។ ម្យ៉ាងទៀត បញ្ញត្តិនេះ ឈ្មោះថា បញ្ញត្តិ ព្រោះអត្ថថា ដែលបុគ្គលគួរដឹង មិនឈ្មោះថា បញ្ញត្តិ ព្រោះអត្ថថា បញ្ញត្តិ ។ បញ្ញត្តអត្ថនេះ ក៏គឺអវិជ្ជ-មានប្បញ្ញត្តិនោះឯង ។

បញ្ញត្តិឯណា មានពាក្យជាដើមថា ទី ២ ទី ៣ ដូច្នេះ ព្រោះតាំងនូវឈានទី ១ និងទី ២ ជាដើម និងមានពាក្យជាដើមថា វែង ខ្លី ជិត ឆ្ងាយ ដូច្នេះ ព្រោះការតាំង អាស្រ័យនូវគ្នានិងគ្នា បញ្ញត្តិនេះ ឈ្មោះថា ឧបនិធាបញ្ញត្តិ ។ ម្យ៉ាងទៀត ឧបនិធាបញ្ញត្តិនេះ មានច្រើនប្រការដោយ

ប្រភេទជាដើមថា តទញ្ញាបេក្ខូបនិធាបញ្ញត្តិ ហត្ថគតូបនិធាបញ្ញត្តិ សម្បយុត្តូបនិធាបញ្ញត្តិ សមារោបិតូបនិធាបញ្ញត្តិ អវិទូរគតូបនិធាបញ្ញត្តិ បដិភាគូបនិធាបញ្ញត្តិ តព្វហុលូបនិធាបញ្ញត្តិ តព្វិសិដ្ឋូបនិធាបញ្ញត្តិ ។

បណ្ដាបញ្ញត្តិទាំងនោះ ពាក្យថាទី ២ ទី ៣ ជាដើមនោះឯង ឈ្មោះថា **តទញ្ញាបេក្ខូបនិធាបញ្ញត្តិ** ព្រោះពោលសម្ងឹងធម៌ដទៃអំពីនោះ ។

បញ្ញត្តិ មានពាក្យថា បុគ្គលមានឆត្រក្នុងដៃ មានសស្ត្រាក្នុងដៃជាដើម ឈ្មោះថា **ហត្ថគតូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅដល់ការប្រើដៃ ។

បញ្ញត្តិ មានពាក្យថា បុគ្គលមានកុណ្ឌល មានផ្កាប្រដាប់សីសៈ មានមកុដជាដើម ឈ្មោះថា **សម្បយុត្តូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅយករបស់ដែលប្រកបជាមួយបុគ្គល ។

បញ្ញត្តិ មានពាក្យថា រទេះស្រូវសាលី ឆ្នាំងសប្បិជាដើម ឈ្មោះថា **សមារោបិតូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅយកវត្ថុដែលលើកឡើង ។

បញ្ញត្តិ មានពាក្យថា គុហាក្បែរដើមឥន្ទសាល ( ដើមពោនស្វា ) គុហាក្បែរដើមបយគ្គុ វិមានក្បែរដើមច្រេសជាដើម ឈ្មោះថា **អវិទូរគតូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅដល់វត្ថុដែលនៅមិនឆ្ងាយ ។

បញ្ញត្តិ មានពាក្យថា មានសម្បុរដូចមាស មេគោដូចបាគោជាដើម ឈ្មោះថា **បដិភាគូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅយកចំណែកប្រៀបធៀប ។

បញ្ញត្តិ មានពាក្យថា ស្រះឈូក ស្រុកព្រាហ្មណ៍ជាដើម ឈ្មោះថា

**តព្ពហុលូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅយកវត្ថុមានច្រើនរបស់វត្ថុនោះ ។

បញ្ញត្តិ មានពាក្យថា កងដៃ កែវមណី និងកងដៃពេជ្រជាដើម ឈ្មោះថា **តព្វិសិដ្ឋូបនិធាបញ្ញត្តិ** ព្រោះពោលសំដៅយកការប្រសើររបស់វត្ថុនោះ ។

បញ្ញត្តិណាមានពាក្យថា ឈើ ៣ កំណាត់ បទ ៨ បទ គំនរស្រូវ គំនរផ្កាជាដើម ព្រោះសំដៅយកការប្រជុំនៃវត្ថុនោះៗ បញ្ញត្តិនេះ ឈ្មោះថា **សមោធានប្បញ្ញត្តិ** ។

បញ្ញត្តិណា មានពាក្យថា ២ , ៣ , ៤ ជាដើម ព្រោះសំដៅយកបទដើមជាមុនហើយបញ្ញត្តិ នេះឈ្មោះថា **ឧបនិក្ខិត្តប្បញ្ញត្តិ** ។

បញ្ញត្តិណា មានពាក្យថា ដី ភ្លើង រឹង ក្តៅជាដើម ព្រោះសម្លឹងដល់សភាវធម៌នោះៗ បញ្ញត្តិនេះ ឈ្មោះថា **តជ្ជាបញ្ញត្តិ** ។

បញ្ញត្តិណា មានពាក្យថា មនុស្សមានអាយុ ៨០ ឆ្នាំ មនុស្សមានអាយុ ៩០ ឆ្នាំជាដើម ព្រោះសម្លឹងភាពជារបស់បន្តគ្នាមិនដាច់ បញ្ញត្តិនេះ ឈ្មោះថា **សន្តតិបញ្ញត្តិ** ។

ម្យ៉ាងទៀត បណ្តាបញ្ញត្តិទាំង ៦ នោះ តជ្ជាបញ្ញត្តិ គឺវិជ្ជមានប្បញ្ញត្តិនោះឯង បញ្ញត្តិដ៏សេសរមែងរួមជាពួកអវិជ្ជមានប្បញ្ញត្តិ និងអវិជ្ជមានេន-អវិជ្ជមានប្បញ្ញត្តិ ។

ន័យម្យ៉ាងទៀត បញ្ញត្តិ ៦ តាមន័យរបស់អាចារ្យ ក្រៅអំពីអដ្ឋកថា គឺកិច្ចប្បញ្ញត្តិ ១ សណ្ឋានប្បញ្ញត្តិ ១ លិង្គប្បញ្ញត្តិ ១ ភូមិប្បញ្ញត្តិ ១ បច្ចត្តប្បញ្ញត្តិ ១ អសង្ខតប្បញ្ញត្តិ ១ ។

បណ្ដាបញ្ញត្តិ ៦ នោះ ការបញ្ញត្តដោយអំណាចនៃកិច្ចមានពាក្យថា អ្នកពោល អ្នកសម្ដែងធម៌ជាដើម ឈ្មោះថា **កិច្ចប្បញ្ញត្តិ** ។

ការបញ្ញត្តដោយអំណាចនៃទ្រង់ទ្រាយ មានពាក្យថា ស្គម ធាត់ មូល ៤ ជ្រុង ជាដើម ឈ្មោះថា **សណ្ឋានប្បញ្ញត្តិ** ។

ការបញ្ញត្តដោយអំណាចនៃភេទ មានពាក្យថា ស្រីប្រុសជាដើម ឈ្មោះថា **លិង្គប្បញ្ញត្តិ** ។

ការបញ្ញត្តដោយអំណាចនៃភូមិ មានពាក្យថា កាមាវចរ រូបាវចរ អរូបាវចរ អ្នកកោសល អ្នកមគធៈជាដើម ឈ្មោះថា **ភូមិប្បញ្ញត្តិ** ។

ការបញ្ញត្តដោយអំណាចត្រឹមតែការដាក់ឈ្មោះចំពោះ មានពាក្យថា តិស្សៈ នាគៈ សុមនៈ ជាដើម ឈ្មោះថា **បច្ចត្តប្បញ្ញត្តិ** ។

ការបញ្ញត្តអសង្ខតធម៌ មានពាក្យថា និរោធ និព្វានជាដើម ឈ្មោះថា **អសង្ខតប្បញ្ញត្តិ** ។

បណ្ដាបញ្ញត្តិទាំងនោះ ភូមិប្បញ្ញត្តិណាមួយ និងអសង្ខតប្បញ្ញត្តិ ក៏គឺវិជ្ជមានប្បញ្ញត្តិនោះឯង ។ កិច្ចប្បញ្ញត្តិ ចាត់ចូលជាមួយពួកវិជ្ជមានេនអវិជ្ជមានប្បញ្ញត្តិ បញ្ញត្តិដ៏សេស ឈ្មោះថា អវិជ្ជមានប្បញ្ញត្តិ ។

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីចែកបញ្ញត្តិដែលទ្រង់សម្ដែងដោយសង្ខេប ក្នុងឧទ្ទេសវារ ដោយអំណាចការចែកវត្ថុនៃបញ្ញត្តិទាំងនោះ ទើបត្រាស់បទថា **កិត្តាវតា** ជាដើម ។ ក្នុងឧទ្ទេសវារនោះ បណ្ឌិតគប្បីជ្រាបអត្ថនៃពាក្យសួរយ៉ាងនេះមុនថា ការបញ្ញត្ត ការសម្ដែង ការតែងតាំងនូវធម៌

ដែលជាគំនរទាំងឡាយថា ជាខន្ធនេះឯណា ការបញ្ញត្ត ការសម្តែង ការតែងតាំងនោះ មានប្រមាណប៉ុនណា ដូច្នេះ ជាកថេតុកម្យតាបុច្ឆា គឺសួរឯង ឆ្លើយឯង ។ ក្នុងបទទាំងឡាយ មានបទថា **កិត្តាវតា អាយតនានំ** ជាដើម ខាងមុខក៏ន័យនេះឯង ។

ឯក្នុងពាក្យវិសជ្ជនា បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា បញ្ញត្តិបែបនេះថា ខន្ធ ៥ ដោយសង្ខេប ឬរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដោយការចែកប្រភេទ ឬក្នុងខន្ធ ៥ នោះ រូបក្ខន្ធជាកាមាវចរ ខន្ធ ៤ ដ៏សេស ប្រព្រឹត្តទៅក្នុងភូមិ ៤ ដូច្នេះ មានដោយបញ្ញត្តិ មានប្រមាណប៉ុនណា ការបញ្ញត្តធម៌ទាំងឡាយដែលជាគំនរ ថាជាខន្ធ មានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិបែបនេះថា អាយតនៈមាន ១២ ដោយសង្ខេប ឬចក្ខាយតនៈ ។បេ។ ធម្មាយតនៈ ដោយការចែកប្រភេទ ឬក្នុងអាយតនៈទាំងនោះ អាយតនៈ ១០ ជាកាមាវចរ អាយតនៈ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤ ដូច្នេះ មានដោយបញ្ញត្តិ មានប្រមាណប៉ុនណា ការបញ្ញត្តធម៌ទាំងឡាយ ដែលជាប្រភពកើត ថាជាអាយតនៈ មានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិបែបនេះថា ធាតុ ១៨ ដោយសង្ខេប ឬចក្ខុធាតុ ។បេ។ មនោវិញ្ញាណធាតុ ដោយការចែកប្រភេទ ឬបណ្ដាធាតុទាំងនោះ ធាតុ ១៦ ជាកាមាវចរ ធាតុ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤ ដូច្នេះ មានដោយបញ្ញត្តិ មានប្រមាណប៉ុនណា ការបញ្ញត្តធម៌ទាំងឡាយ ដែលជាសភាវៈទ្រទ្រង់ ថាជាធាតុ មានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិបែបនេះថា សច្ចៈមាន ៤ ដោយសង្ខេប ឬទុក្ខសច្ច ។បេ។ និរោធសច្ច ឬបណ្ដាសច្ចៈទាំងនោះ សច្ចៈ ២ ជាលោកិយ សច្ចៈ ២ ជាលោកុត្តរ ដូច្នេះ មានដោយបញ្ញត្តិ មានប្រមាណប៉ុន្មាន ការបញ្ញត្តធម៌ទាំងឡាយដែលជារបស់ពិតថាសច្ចៈ មានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

បញ្ញត្តិបែបនេះថា ឥន្ទ្រិយមាន ២២ ដោយសង្ខេប ឬចក្ខុន្ទ្រិយ ។បេ។ អញ្ញាតាវិន្ទ្រិយ ដោយការចែកប្រភេទ ឬបណ្ដាឥន្ទ្រិយទាំងនោះ ឥន្ទ្រិយ ១០ ជាកាមាវចរ ឥន្ទ្រិយ ៩ លាយឡំគ្នា ( ទាំងកាមាវចរ និងលោកុត្តរ ) ឥន្ទ្រិយ ៣ ជាលោកុត្តរ ដូច្នេះ មានដោយបញ្ញត្តិ មានប្រមាណប៉ុន្មាន ការបញ្ញត្តធម៌ទាំងឡាយដែលជាធំ ជាឥន្ទ្រិយ មានដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ព្រះមានព្រះភាគទ្រង់សម្ដែងបញ្ញត្តិ ៥ ទ្រង់សម្ដែងចែកវត្ថុដោយសង្ខេបដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្ដែងបុគ្គលប្បញ្ញត្តិដោយអំណាចការចែកសម្ដែងវត្ថុដោយពិស្ដារហើយ ទើបត្រាស់ថា **សមយវិមុត្តោ អសមយវិមុត្តោ** ជាដើម ព្រះសម្មាសម្ពុទ្ធ ដូចជាបុគ្គលដែលត្រាច់ទៅក្នុងទីផ្សេងៗ និងបុគ្គលដែលកំពុងនាំទៅ ធ្លាប់ត្រាស់ខន្ធជាដើម ដែលជាទីតាំងដែលកើតនៃបញ្ញត្តិ ៥ ទាំងនេះ ទុកដោយពិស្ដារ ក្នុងវិភង្គប្បករណ៍ហើយ ព្រោះហេតុនោះ ទើបក្នុងបុគ្គលប្បញ្ញត្តិបករណ៍នេះ ត្រាស់ធម៌ មានខន្ធជាដើមនោះ ដោយចំណែកខ្លះប៉ុណ្ណោះ ។ បុគ្គលប្បញ្ញត្តិទី ៦ មិនធ្លាប់

*ត្រាស់ទុកឡើយ ក្នុងឧទ្ទេសវារនេះ ក៏ត្រាស់ទុកដោយចំណែកខ្លះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់បំណងនឹងត្រាស់បុគ្គលបញ្ញត្តិ ដែលជាបញ្ញត្តិទី ៦ នោះដោយពិស្តារ ទើបទ្រង់តាំងមាតិកាថា* **សមយ-វិមុត្តោ អសមយវិមុត្តោ** *ជាដើម ចាប់តាំងអំពីបុគ្គលពួក ១ រហូតដល់បុគ្គលពួក ១០ ដូច្នេះ ។*

## អដ្ឋកថាមាតិកា ចប់

# អភិធម្មបិដក

## ឯកកនិទ្ទេស

[ ១៧ ] បុគ្គលជាសមយវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ តាមកាលគួរ តាមសម័យគួរ អាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏បានអស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាសមយវិមុត្ត ។

[ ១៨ ] បុគ្គលជាអសមយវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបានវិមោក្ខ ៨ ដោយនាមកាយ តាមកាលគួរ តាមសម័យគួរទេ អាសវៈរបស់បុគ្គលនោះ បានអស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាអសមយវិមុត្ត ។ សូម្បីពួកអរិយបុគ្គលទាំងអស់ ក៏ឈ្មោះថា អសមយវិមុត្ត ក្នុងអរិយវិមោក្ខ ( លោកុត្តរវិមោក្ខដែរ ) ។

[ ១៩ ] បុគ្គលជាកុប្បធម្មៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានសមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលនោះឯងមិនបាន តាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នាទេ ដំណើរនុ៎ះឯងរមែងមាន ត្រង់ដែលសមាបត្តិទាំងនោះកម្រើក ព្រោះអាស្រ័យសេចក្តីប្រមាទ របស់បុគ្គលនោះ នេះហៅថា បុគ្គលជាកុប្បធម្មៈ ។

[ ២០ ] បុគ្គលជាអកុប្បធម្មៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានសមាបត្តិទាំងឡាយ ប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលនោះ

ឯងបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ ចូលផង ចេញផងតាម ឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នា ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាឱកាសទេ ត្រង់ដែលសមាបត្តិទាំង នោះកម្រើក ព្រោះអាស្រ័យសេចក្តីប្រមាទ របស់បុគ្គលនោះ នេះហៅថា បុគ្គលជាអកុប្បធម្មៈ ។ សូម្បីពួកអរិយបុគ្គលទាំងអស់ ក៏ឈ្មោះថា អកុប្បធម្មៈ ក្នុងអរិយវិមោក្ខដែរ ។

[ ២១ ] បុគ្គលជាបរិហានធម្មៈ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ បានសមាបត្តិទាំងឡាយ ប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលនោះ ឯងមិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូល មិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែល ប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នាទេ ដំណើរនុ៎ះឯងរមែងមាន ត្រង់ដែល បុគ្គលនោះ សាបសូន្យចាកសមាបត្តិទាំងនោះ ព្រោះអាស្រ័យសេចក្តីប្រមាទ នេះហៅថា បុគ្គលជាបរិហានធម្មៈ ។

[ ២២ ] បុគ្គលជាអបរិហានធម្មៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោក នេះ បានសមាបត្តិទាំងឡាយ ប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គល នោះឯង បានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ ចូលផង ចេញផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ ដែលប្រាថ្នា ដំណើរនុ៎ះឯងមិនមែនជាហេតុ មិនមែនជាឱកាសទេ ត្រង់ដែល បុគ្គលនោះ សាបសូន្យចាកសមាបត្តិទាំងនោះ ព្រោះអាស្រ័យសេចក្តីប្រមាទ

នេះហៅថា បុគ្គលជាអបរិហានធម្មៈ ។ សូម្បីពួកព្រះអរិយបុគ្គលទាំងអស់ ក៏ឈ្មោះថា អបរិហានធម្មៈ ក្នុងអរិយវិមោក្ខដែរ ។

[ ២៣ ] បុគ្គលជាចេតនាភព្វៈ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ បានសមាបត្តិទាំងឡាយ ប្រកបដោយរូបក្ដី ប្រកបដោយអរូបក្ដី បុគ្គលនោះឯង មិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នា បើចូល ( សមាធិ ) ក៏មិនសាបសូន្យចាកសមាបត្តិទាំងនោះ បើមិនចូលទេ ក៏សាបសូន្យចាកសមាបត្តិទាំងនោះ នេះហៅថា បុគ្គលជាចេតនាភព្វៈ ។

[ ២៤ ] បុគ្គលជាអនុរក្ខនាភព្វៈ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានសមាបត្តិទាំងឡាយ ប្រកបដោយរូបក្ដី ប្រកបដោយអរូបក្ដី បុគ្គលនោះឯងមិនបានតាមប្រាថ្នា មិនបានដោយមិនលំបាក មិនបានដោយងាយ ចូលមិនបានផង ចេញមិនបានផង តាមឱកាសដែលប្រាថ្នា តាមសមាបត្តិដែលប្រាថ្នា តាមកាលកំណត់ដែលប្រាថ្នា បើរក្សា គឺសេពនូវឧបការធម៌ហើយចូលសមាបត្តិ រមែងមិនសាបសូន្យ ចាកសមាបត្តិទាំងនោះ បើមិនរក្សាទេ រមែងសាបសូន្យចាកសមាបត្តិទាំងនោះ នេះហៅថា បុគ្គលជាអនុរក្ខនាភព្វៈ ។

[ ២៥ ] បុគ្គលជាបុថុជ្ជន តើដូចម្ដេច ។ បុគ្គលណាមិនទាន់លះបង់សញ្ញោជនៈ ៣ ទាំងមិនប្រតិបត្តិដើម្បីលះបង់ធម៌ទាំងនោះ នេះហៅថា បុគ្គលជាបុថុជ្ជន ។

[ ២៦ ] បុគ្គលជាគោត្រភូ តើដូចម្តេច ។ ការយាងចុះ គឺការកើតប្រាកដនៃអរិយធម៌ ( លោកុត្តរមគ្គ ) ក្នុងលំដាប់ស្មើនៃពួកធម៌ណា បុគ្គលប្រកបព្រមដោយធម៌ទាំងនោះ នេះហៅថា បុគ្គលជាគោត្រភូ ។

[ ២៧ ] បុគ្គលជាភយូបរតៈ តើដូចម្តេច ។ សេក្ខបុគ្គល ៧ ពួក និងបុគ្គលជាបុថុជ្ជន ដែលមានសីល ឈ្មោះថា ភយូបរតបុគ្គល ។ ព្រះអរហន្តឈ្មោះថា អភយូបរតបុគ្គល ។

[ ២៨ ] បុគ្គលជាអភព្វាគមនៈ តើដូចម្តេច ។ បុគ្គលណាប្រកបដោយគ្រឿងរារាំង គឺកម្ម ប្រកបដោយគ្រឿងរារាំង គឺកិលេស ប្រកបដោយគ្រឿងរារាំង គឺវិបាក ជាអ្នកមិនមានសទ្ធា មិនមានឆន្ទៈ មានបញ្ញាអាប់អន់ ល្ងង់ខ្លៅ មិនគួរឈានចុះកាន់សម្មត្តនិយាម ក្នុងធម៌ជាកុសលទាំងឡាយ នេះហៅថា បុគ្គលជាអភព្វាគមនៈ ។

[ ២៩ ] បុគ្គលជាភព្វាគមនៈ តើដូចម្តេច ។ បុគ្គលណា មិនប្រកបដោយគ្រឿងរារាំង គឺកម្ម មិនប្រកបដោយគ្រឿងរារាំង គឺកិលេស មិនប្រកបដោយគ្រឿងរារាំង គឺវិបាក ជាអ្នកមានសទ្ធា មានឆន្ទៈ មានបញ្ញា មិនល្ងង់ខ្លៅ គួរឈានចុះកាន់សម្មត្តនិយាម ក្នុងធម៌ជាកុសលទាំងឡាយ នេះហៅថា បុគ្គលជាភព្វាគមនៈ ។

[ ៣០ ] បុគ្គលជានិយតៈ តើដូចម្តេច ។ បុគ្គលប្រកបដោយអនន្តរិយកម្ម ៥ ពួក បុគ្គលប្រកបដោយនិយតមិច្ឆាទិដ្ឋិ និងអរិយបុគ្គល ៨ ពួក ឈ្មោះថា និយតបុគ្គល ។ បុគ្គលក្រៅពីនេះ ឈ្មោះថា អនិយតបុគ្គល ។

[ ៣១ ] បុគ្គលជាបដិបន្នកៈ តើដូចម្ដេច ។ បុគ្គល ៤ ពួកដែលព្រមព្រៀងដោយមគ្គ ឈ្មោះថា បដិបន្នកបុគ្គល ។ បុគ្គល ៤ ពួកដែលព្រមព្រៀងដោយផល ឈ្មោះថា ផលេដ្ឋិតបុគ្គល ។

[ ៣២ ] បុគ្គលជាសមសីសី តើដូចម្ដេច ។ បុគ្គលណា មានការអស់ទៅនៃអាសវៈ និងការអស់ទៅនៃជីវិត មិនមុនមិនក្រោយ នេះហៅថា បុគ្គលជាសមសីសី ។

[ ៣៣ ] បុគ្គលជាឋិតកប្បី តើដូចម្ដេច ។ បុគ្គលនេះ ជាអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ទុកជាវេលាភ្លើងឆេះកប្ប នឹងមាន បើបុគ្គលនេះមិនបានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលដរាបណា ភ្លើងក៏មិនគប្បីឆេះកប្បដរាបនោះដែរ នេះហៅថា បុគ្គលជាឋិតកប្បី ។ បុគ្គលដែលព្រមព្រៀងដោយមគ្គទាំងអស់ ក៏ឈ្មោះថា ឋិតកប្បីដែរ ។

[ ៣៤ ] បុគ្គលជាអរិយៈ តើដូចម្ដេច ។ អរិយបុគ្គលទាំង ៨ ពួក ឈ្មោះថា អរិយៈ ។ បុគ្គលក្រៅពីនេះ ឈ្មោះថា អនរិយៈ ។

[ ៣៥ ] បុគ្គលជាសេក្ខៈ តើដូចម្ដេច ។ បុគ្គល ៤ ពួក ព្រមព្រៀងដោយមគ្គ បុគ្គល ៣ ពួក ព្រមព្រៀងដោយផល ឈ្មោះថា សេក្ខៈ ។ ព្រះអរហន្ត ឈ្មោះថា អសេក្ខៈ ។ បុគ្គលក្រៅពីនេះ ឈ្មោះថា មិនមែនសេក្ខៈ ទាំងមិនមែនអសេក្ខៈ ។

[ ៣៦ ] បុគ្គលបានវិជ្ជា ៣ តើដូចម្ដេច ។ បុគ្គលប្រកបដោយវិជ្ជា ៣ យ៉ាង ឈ្មោះថា បុគ្គលបានវិជ្ជា ៣ ។

[ ៣៧ ] បុគ្គលបានអភិញ្ញា ៦ តើដូចម្តេច ។ បុគ្គលប្រកបដោយអភិញ្ញា ៦ ឈ្មោះថា បានអភិញ្ញា ៦ ។

[ ៣៨ ] បុគ្គលជាព្រះសម្មាសម្ពុទ្ធ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ត្រាស់ដឹងចំពោះខ្លួននូវសច្ចៈ ក្នុងធម៌ដែលខ្លួនមិនធ្លាប់ស្តាប់ក្នុងកាលមុន ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌នោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង នេះហៅថា បុគ្គលជាព្រះសម្មាសម្ពុទ្ធ ។

[ ៣៩ ] បុគ្គលជាព្រះបច្ចេកសម្ពុទ្ធ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ត្រាស់ដឹងចំពោះខ្លួននូវសច្ចៈ ក្នុងធម៌ដែលខ្លួនមិនធ្លាប់ស្តាប់ ក្នុងកាលមុន មិនដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌នោះផង មិនដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង នេះហៅថា បុគ្គលជាព្រះបច្ចេកសម្ពុទ្ធ ។

[ ៤០ ] បុគ្គលជាឧភតោភាគវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្តិ ។

[ ៤១ ] បុគ្គលជាបញ្ញាវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបានវិមោក្ខ ៨ ដោយនាមកាយទេ អាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាបញ្ញាវិមុត្ត ។

[ ៤២ ] បុគ្គលជាកាយសក្ខី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាកាយសក្ខី ។

[ ៤៣ ] បុគ្គលជាទិដ្ឋិប្បត្តៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិត ថានេះទុក្ខ ដឹងច្បាស់តាមពិត ថានេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិត ថានេះធម៌រលត់ទុក្ខ ដឹងច្បាស់តាមពិត ថានេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយ ដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះបានឃើញដោយល្អ បានប្រព្រឹត្តដោយល្អដោយបញ្ញាផង អាសវៈពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង នេះហៅថា បុគ្គលជាទិដ្ឋិប្បត្តៈ ។

[ ៤៤ ] បុគ្គលជាសទ្ធាវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិត ថានេះទុក្ខ ដឹងច្បាស់តាមពិត ថានេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិត ថានេះធម៌រលត់ទុក្ខ ដឹងច្បាស់តាមពិត ថានេះជាបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះបានឃើញដោយល្អ បានប្រព្រឹត្តដោយល្អដោយបញ្ញាផង អាសវៈពួកខ្លះរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង តែមិនដូចជាទិដ្ឋិប្បត្តបុគ្គលទេ នេះហៅថា បុគ្គលជាសទ្ធាវិមុត្តិ ។

[ ៤៥ ] បុគ្គលជាធម្មានុសារី តើដូចម្តេច ។ បុគ្គលណា កំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតបត្តិផល មានឥន្ទ្រិយ គឺបញ្ញាដ៏ក្រៃលែងចម្រើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ មានបញ្ញាជាប្រធាន នេះហៅថា បុគ្គលជាធម្មានុសារី ។ បុគ្គលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា ធម្មានុសារី ។ ឯបុគ្គលឋិតនៅក្នុងផល ឈ្មោះថា

ទិដ្ឋិប្បត្តៈ ។

[ ៤៦ ] បុគ្គលជាសទ្ធានុសារី តើដូចម្តេច ។ បុគ្គលណា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឥន្ទ្រិយ គឺសទ្ធាដ៏ក្រៃលែងចម្រើនអរិយមគ្គ មានសទ្ធាជាគ្រឿងនាំ មានសទ្ធាជាប្រធាន នេះហៅថា បុគ្គលជាសទ្ធានុសារី ។ បុគ្គលកំពុងប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា សទ្ធានុសារី ។ ឯបុគ្គលស្ថិតនៅក្នុងផល ឈ្មោះថា សទ្ធាវិមុត្ត ។

[ ៤៧ ] បុគ្គលជាសត្តក្ខត្តុំបរមៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ ស្ទុះទៅ អន្ទោលទៅ ក្នុងទេវតា និងមនុស្សអស់វារៈ ៧ ដង ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាសត្តក្ខត្តុំបរមៈ ។

[ ៤៨ ] បុគ្គលជាកោលំកោលៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដល់នូវសោតៈ ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះស្ទុះទៅ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាកោលំកោលៈ ។

[ ៤៩ ] បុគ្គលជាឯកពីជី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះដល់នូវសោតៈព្រោះអស់ទៅនៃសញ្ញោជនៈ ៣ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលនោះ កើតក្នុងភព

ជារបស់មនុស្សតែម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាឯកពីជី ។

[ ៥០ ] បុគ្គលជាសកទាគាមី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសញ្ញោជនៈ ៣ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ មោហៈ មកកាន់លោកនេះអស់វារៈម្តងទៀត ហើយធ្វើនូវទីបំផុតនៃវដ្តទុក្ខ នេះហៅថា បុគ្គលជាសកទាគាមី ។

[ ៥១ ] បុគ្គលជាអនាគាមី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ នេះហៅថា បុគ្គលជាអនាគាមី ។

[ ៥២ ] បុគ្គលជាអន្តរាបរិនិព្វាយី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ជាអ្នកបរិនិព្វានក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ បុគ្គលនោះញ៉ាំងអរិយមគ្គឲ្យកើតឡើងក្នុងប្រមាណនៃអាយុដែលកើតក្នុងលំដាប់ ឬដែលមិនទាន់ដល់ពាក់កណ្តាល ដើម្បីលះបង់នូវសញ្ញោជនៈខាងលើ នេះហៅថា បុគ្គលជាអន្តរាបរិនិព្វាយី ។

[ ៥៣ ] បុគ្គលជាឧបហច្ចបរិនិព្វាយី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយជាអ្នកបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មាន

សភាពមិនត្រឡប់ចាកលោកនោះវិញ បុគ្គលនោះ កន្លងពាក់កណ្ដាលអាយុជាប្រមាណ ឬទល់នឹងកាលកិរិយា ហើយទើបញ៉ាំងអរិយមគ្គឲ្យកើតឡើង ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា បុគ្គលជាឧបហច្ចបរិនិព្វាយី ។

[ ៥៤ ] បុគ្គលជាអសង្ខារបរិនិព្វាយី តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយជាអ្នកបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ បុគ្គលនោះ ញ៉ាំងអរិយមគ្គ ឲ្យកើតឡើងដោយអសង្ខារ គឺដោយព្យាយាមបន្តិចបន្តួច ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា បុគ្គលជាអសង្ខារបរិនិព្វាយី ។

[ ៥៥ ] បុគ្គលជាសសង្ខារបរិនិព្វាយី តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ហើយជាអ្នកបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ បុគ្គលនោះ ញ៉ាំងអរិយមគ្គឲ្យកើតឡើងដោយសសង្ខារ គឺដោយព្យាយាមតឹង ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា បុគ្គលជាសសង្ខារបរិនិព្វាយី ។

[ ៥៦ ] បុគ្គលជាឧទ្ធំសោតអកនិដ្ឋគាមី តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ហើយជាអ្នកបរិនិព្វាន ក្នុងសុទ្ធាវាសទេវលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ បុគ្គលនោះច្យុតចាកអវិហា ទៅកាន់អតប្បា

ច្យុតចាកអតប្បា ទៅកាន់សុទស្សា ច្យុតចាកសុទស្សា ទៅកាន់សុទស្សី ច្យុតចាកសុទស្សី ទៅកាន់អកនិដ្ឋ ហើយញ៉ាំងអរិយមគ្គ ឲ្យកើតឡើងក្នុងជាន់អកនិដ្ឋ ដើម្បីលះបង់សញ្ញោជនៈខាងលើ នេះហៅថា បុគ្គលជា ឧទ្ធំ-សោតអកនិដ្ឋគាមី ។

[ ៥៧ ] បុគ្គលជាសោតាបន្ន ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតា-បត្តិផល តើដូចម្ដេច ។ បុគ្គលប្រតិបត្តិដើម្បីលះបង់សញ្ញោជនៈ ៣ ប្រតិ-បត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល បានដល់ បុគ្គលដែលលះបង់សញ្ញោជនៈ ៣ នេះហៅថា បុគ្គលជាសោតាបន្ន ។ បុគ្គលប្រតិបត្តិដើម្បីឲ្យស្រាលស្តើងកាមរាគ និងព្យាបាទ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសក-ទាគាមិផល បានដល់ បុគ្គលដែលមានកាមរាគ និងព្យាបាទស្រាលស្តើង នេះហៅថា បុគ្គលជាសកទាគាមី ។ បុគ្គលប្រតិបត្តិ ដើម្បីលះបង់កាមរាគ និងព្យាបាទមិនឲ្យសេសសល់ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានដល់ បុគ្គលដែលលះបង់កាមរាគ និងព្យាបាទមិនឲ្យសេសសល់ នេះហៅថា បុគ្គលជាអនាគាមី ។ បុគ្គលប្រតិបត្តិ ដើម្បីលះបង់រូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជាមិនឲ្យសេសសល់ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល បានដល់ បុគ្គលដែលលះបង់រូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជាមិនឲ្យសេសសល់ នេះហៅថា បុគ្គលជាអរហន្ត ។

**ឯកកនិទ្ទេស ចប់**

# អដ្ឋកថា

## ឯកកនិទ្ទេស

[ ១៧ ] ឥឡូវនេះ ដើម្បីចែកមាតិកាតាមដែលបានតាំងទុក អំពីដើម ទើបព្រះមានព្រះភាគទ្រង់ត្រាស់បទថា **កតមោ ច បុគ្គលោ សមយវិមុត្តោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឥធ** បានដល់ ក្នុងសត្វលោក ។ បទថា **ឯកច្ចោ បុគ្គលោ** បានដល់ បុគ្គលមួយ ។ បទថា **កាលេន កាលំ** នេះ គប្បីជ្រាបអត្ថជាសត្តមីវិភត្តិ អធិប្បាយថា ក្នុងគ្រាម្តងម្កាល ។ បទថា **សមយេន សមយំ** នេះ ជាវេវចនៈនៃពាក្យមុននោះឯង ។ បទថា **អដ្ឋ វិមោក្ខេ** បានដល់ សមាបត្តិ ៨ ដែលជារូបាវចរ និងអរូបាវចរ ។ ពិតហើយ ពាក្យថា វិមោក្ខនេះ ជាឈ្មោះនៃសមាបត្តិទាំង ៨ នោះ ព្រោះផុតចាកធម៌ ដែលជាសត្រូវទាំងឡាយ ។ បទថា **កាយេន** បានដល់ ដោយនាមកាយ ដែលកើតព្រមជាមួយវិមោក្ខ ។ បទថា **ផុសិត្វា វិហរតិ** បានដល់ បាននូវសមាបត្តិហើយ ទើបប្តូរឥរិយាបថ ។

សួរថា សមយវិមុត្តបុគ្គលនេះ ពាល់ត្រូវវិមោក្ខហើយ ក្នុងកាលណា ឆ្លើយថា ធម្មតាសម្រាប់បុគ្គល ដែលប្រាថ្នានឹងចូលសមាបត្តិ វេលាចូលសមាបត្តិមាន មិនមែនវេលាចូលសមាបត្តិក៏មាន ។

បណ្តាកាល និងអកាល ទាំង ២ យ៉ាងនេះ កាលដែលកំពុងបដិបត្តិសរីរៈអំពីព្រលឹម ១ កាលដែលកំពុងធ្វើវត្ត ១ ឈ្មោះថា មិនមែនកាលចូលសមាបត្តិ ។ កាលភិក្ខុជម្រះសរីរៈ និងធ្វើវត្តស្រេចហើយ ចូលទៅកាន់

លំនៅអន្តុយសម្រាក មិនទាន់ដល់កាលទៅបិណ្ឌបាតដរាបណា ក្នុងចន្លោះនេះ ឈ្មោះថា កាល ( ដែលត្រូវ ) ចូលសមាបត្តិ ។

កាលដែលជាថ្ងៃលាបព្រះចេតិយរបស់ភិក្ខុ ដែលកំណត់កាលទៅបិណ្ឌបាតហើយចេញទៅ ១ កាលដែលឈរក្នុងរោងវិតក្ក[1] របស់ភិក្ខុដែលចោមរោមដោយពួកនៃភិក្ខុ ១ កាលជាទីត្រាច់ទៅដើម្បីបិណ្ឌបាត ១ កាលជាទីត្រាច់ទៅក្នុងស្រុក ១ កាលជាទីឆាន់បបរក្នុងរោងភត្ត ១ កាលជាទីធ្វើវត្ត ១ កាលទាំងអស់នេះ ឈ្មោះថា មិនមែនកាល ( ដែលត្រូវ ) ចូលសមាបត្តិ ។ កាលឱកាសដែលស្ងាត់ក្នុងរោងឆាន់មាន និងមិនទាន់ដល់ពេលឆាន់ភត្តាហារ ក្នុងចន្លោះពេលនេះ ក៏ឈ្មោះថា កាល ( ដែលត្រូវ ) ចូលសមាបត្តិ ។

ម្យ៉ាងទៀត កាលឆាន់ភត្តាហារ ១ កាលទៅកាន់វិហារ ១ កាលទុកដាក់បាត្រ និងចីវរ ១ កាលធ្វើវត្តក្នុងពេលថ្ងៃ ១ កាលក្នុងការសាកសួរ ១ កាលទាំងអស់នេះ ក៏ឈ្មោះថា មិនមែនកាល ( ដែលត្រូវ ) ចូលសមាបត្តិ ។ កាលណាមិនមែនកាល កាលនោះឯង មិនមែនសម័យ ។

កាលដ៏សេស ក្នុងសម័យដ៏សេស វៀរកាលដែលមិនមែនកាលចូលសមាបត្តិទាំងអស់នោះ បុគ្គលដែលបាននូវវិមោក្ខ ៨ មានប្រការដូចពោលហើយនៅដោយសហជាតនាមកាយ ហៅថា បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ។បេ។ ហើយសម្រេចឥរិយាបថ ។

ម្យ៉ាងទៀត បុគ្គលនេះ ឈ្មោះថា ពាល់ត្រូវសហជាតធម៌ទាំងឡាយ

---

១- រោងសម្រាប់ត្រិះរិះថា ថ្ងៃនេះ យើងទៅបិណ្ឌបាតក្នុងទីណាហ្ន៎ ( ដីកាវិសុទ្ធិមគ្គ ) ។

ដោយសហជាតនាមធម៌ទាំងឡាយ មួយអន្លើដោយផស្សៈ ឈ្មោះថា ពាល់ត្រូវអប្បនាដោយឧបចារៈ ។ ឈ្មោះថា រមែងពាល់ត្រូវអប្បនាដទៃទៀតដោយអប្បនាដំបូង ។ ធម៌ពួកណា កើតព្រមជាមួយធម៌ពួកណា ធម៌ទាំងនោះ ឈ្មោះថា ជាធម៌ដែលលោកបានហើយជាមួយធម៌នោះ ឈ្មោះថា ជាធម៌ដែលពាល់ត្រូវហើយដោយផស្សៈ ។ សូម្បីឧបចារៈក៏ជាហេតុនៃការបានអប្បនានោះឯង ។ អប្បនាដំបូងក៏ជាហេតុឲ្យបានអប្បនាដទៃៗ ទៀតដូចគ្នា ។ ក្នុងឧបចារៈ និងអប្បនាទាំងនោះ គប្បីជ្រាបការពាល់ត្រូវសហជាតធម៌ទាំងឡាយ ដោយសហជាតធម៌ទាំងឡាយ របស់ព្រះយោគីបុគ្គលនោះ ដោយប្រការដូច្នេះ ។

បឋមជ្ឈានមានអង្គ ៥ មានវិតក្កជាដើម វៀរអង្គឈានទាំង ៥ ចេញហើយ ធម៌ដ៏សេសជាង ៥០ ក្នុងបឋមជ្ឈាននោះ ហៅថា នាមក្ខន្ធ ៤ ។ ព្រះយោគីបុគ្គល ពាល់ត្រូវ គឺបានចំពោះនូវវិមោក្ខ គឺបឋមជ្ឈានសមាបត្តិដោយនាមកាយនោះហើយ ទើបនៅ ។

ទុតិយជ្ឈានមានអង្គ ៣ គឺបីតិ សុខ និងចិត្តេកគ្គតា ។ តតិយជ្ឈានមានអង្គ ២ គឺសុខ និងចិត្តេកគ្គតា ។ ចតុត្ថជ្ឈានមានអង្គ ២ គឺឧបេក្ខា និងចិត្តេកគ្គតា ។ ម្យ៉ាងទៀត អាកាសានញ្ចាយតនជ្ឈាន ។បេ។ នេវសញ្ញានាសញ្ញាយតនជ្ឈាន មានអង្គ ២ ដូចគ្នានឹងចតុត្ថជ្ឈានដែរ ។ ក្នុងឈានទាំងនោះ គឺតាំងអំពីបឋមជ្ឈាន ដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន វៀរអង្គឈានទាំងនោះចេញហើយ ធម៌ដ៏សេសទាំងឡាយជាង ៥០ ក្នុងឈានទាំង

នោះ ហៅថា នាមកូន្ទ ៤ ។ ព្រះយោគីបុគ្គល ពាល់ត្រូវ គឺបានចំពោះនូវនេវសញ្ញានាសញ្ញាយតនសមាបត្តិដោយនាមកាយនោះហើយ ទើបនៅ ។

បទថា **បញ្ញាយ ចស្ស ទិស្វា** អធិប្បាយថា ព្រោះឃើញសង្ខារដោយវិបស្សនាបញ្ញា ឃើញនូវសច្ចធម៌ទាំង ៤ ដោយមគ្គប្បញ្ញា ។ បទថា **ឯកច្ចេ អាសវា បរិក្ខីណា ហោន្តិ** អធិប្បាយថា អាសវៈទាំងឡាយដែលបឋមមគ្គជាដើមគប្បីសម្លាប់ចំណែកនីមួយៗ អស់ទៅហើយ ។ ក្នុងបទនេះថា **អយំ វុច្ចតិ បុគ្គលោ សមយវិមុត្តោ** បានដល់ គួរពោលបានថា បុថុជ្ជនដែលបានសមាបត្តិ ៨ ពាល់ត្រូវវិមោក្ខ ដោយនាមកាយនោះហើយសម្រាកសម្រាន្តនៅ តែក្នុងព្រះបាលីត្រាស់ថា អាសវៈពួកខ្លះរបស់បុគ្គលនោះ ក៏បានអស់ទៅ ។ ឈ្មោះថា អាសវៈទាំងឡាយរបស់បុថុជ្ជនអស់ទៅហើយ រមែងមិនមាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់មិនបំណាងយកបុថុជ្ជន ។ គួរពោលថា ព្រះខីណាស្រពដែលបានសមាបត្តិ ៨ ពាល់ត្រូវវិមោក្ខដោយនាមកាយនោះហើយ សម្ងំនៅ តែធម្មតាអាសវៈទាំងឡាយរបស់ព្រះខីណាស្រពនោះមិនទាន់អស់ទៅ មិនមាន ព្រោះហេតុនោះ ទើបព្រះខីណាស្រពនោះ ព្រះមានព្រះភាគទ្រង់មិនបានបំណាងយក ។ បទថា **សមយវិមុត្តោ** នេះ គប្បីជ្រាបថា ជាឈ្មោះនៃព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រួមជា ៣ ពួកប៉ុណ្ណោះ ។

[ ១៨ ] ក្នុងនិទ្ទេសថា **អសមយវិមុត្តោ** គប្បីជ្រាបដូចគ្នានឹងពាក្យមុន ដោយន័យដែលពោលហើយនោះឯង ។ ម្យ៉ាងទៀត បទថា **អស–**

**មយាវិមុត្តោ** នេះ ក្នុងទីនេះ ជាឈ្មោះរបស់ព្រះអរហន្តសុក្ខវិបស្សក: តែព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះសុក្ខវិបស្សក: ដែលជាព្រះអរហន្តបានសមាបត្តិ ៨ និងបុថុជ្ជន រមែងមិនបានក្នុងទុក:នេះ ទើបជនទាំងនេះ ឈ្មោះថា ទុកមុត្តកបុគ្គល ព្រោះហេតុនោះ ទើបព្រះសាស្តា ទ្រង់រួបរួមបុគ្គលទាំងឡាយ ដែលទ្រង់កាន់យក និងមិនកាន់យកខាងដើម ហើយលើកឡើងកាន់បែបផែន មួយអន្ទើដោយបិដ្ឋិវដ្តកបុគ្គល ( បុគ្គលដែលវិលទៅខាងក្រោយ ) ទាំងឡាយ ព្រោះទ្រង់ជាអ្នកមានបញ្ញា ជាគ្រឿងត្រាស់ដឹងហើយដោយល្អ ទើបត្រាស់បទថា **សត្តេបិ អរិយបុគ្គលា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អរិយេ វិមោក្ខេ** បានដល់ វិមោក្ខដែលជាលោកុត្តរ ដែលដល់នូវការរាប់ថា ជាអរិយ: ព្រោះឆ្ងាយចាកកិលេសទាំងឡាយ សេចក្តីនេះ មានពាក្យអធិប្បាយថា សម័យក្តី អសម័យក្តី នៃបុគ្គល ដែលចូលសមាបត្តិ ៨ ខាងក្រៅ ( អំពីលោកុត្តរ ) មានសម័យឬអសម័យនៃការរួចផុតដោយមគ្គវិមោក្ខរមែងមិនមាន ។ សទ្ធារបស់បុគ្គលណា មានកម្លាំង វិបស្សនាដែលបុគ្គលណាប្រារព្ធហើយ តែការចាក់ធ្លុះមគ្គនិងផលរបស់បុគ្គលនោះ ដែលកំពុងដើរ ឈរ អង្គុយ ដេក ទំពា និងបរិភោគ មិនមាន ព្រោះហេតុនោះ ទើបសម័យ ឬអសម័យរបស់បុគ្គលដែលរួចផុតដោយមគ្គវិមោក្ខ មិនមាន ព្រោះហេតុនោះ ពាក្យថា សម័យក្តីអសម័យក្តីនៃការរួចផុតដោយមគ្គវិមោក្ខ រមែងមិនមាននេះ ព្រះមានព្រះភាគទ្រង់ជាធម្មរាជា ទ្រង់រួបរួមបុគ្គលទាំងឡាយដែលទ្រង់កាន់យក និងមិនកាន់

យកខាងដើមហើយលើកឡើងកាន់បែបផែនដែលជាបិដ្ឋិវដ្ដកៈនេះ ។ បុថុជ្ជន ដែលបានសមាបត្តិ ៨ ទ្រង់ក៏មិនបានបំណាងយក ដោយបែបផែននេះឡើយ តែកាលចាត់ចូលក្នុងទុកៈនោះ ក៏គប្បីចាត់ចូលជាសមយវិមុត្តបុគ្គល ដោយ អំណាចកិលេសដែលសង្កត់ទុកហើយ ដោយសមាបត្តិ ។

[ ១៩ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃកុប្បធម្មបុគ្គលជាដើម មានដូចតទៅនេះ ធម៌ គឺសមាបត្តិដែលបុគ្គលណាសម្រេចហើយរមែងកម្រើក រមែងវិនាស ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា ជាអ្នកមានធម៌កម្រើក ។ បទថា **រូបសហគតានំ** បានដល់ សមាបត្តិដែលសហគតៈដោយរូបនោះ ពោល គឺដែលមានរូបជានិមិត្ត អធិប្បាយថា រូបាវចរជ្ឈានទាំង ៤ ដែលមានរូប ជាអារម្មណ៍ ដែលប្រព្រឹត្តទៅជាមួយរូបនោះ គឺមិនវៀរ ( រូបនោះ ) ។ បទថា **អរូបសហគតានំ** បានដល់ វត្ថុដទៃ វៀរចាករូប មិនឈ្មោះថា រូប ព្រោះហេតុនោះ ទើបឈ្មោះថា អរូប សមាបត្តិដែលសហគតៈដោយអរូប អធិប្បាយថា អរូបាវចរជ្ឈានទាំង ៤ ដែលមានអរូបជាអារម្មណ៍ ដែល ប្រព្រឹត្តទៅព្រមជាមួយអរូបនោះ គឺមិនវៀរ ( រូបនោះ ) ។ បទថា **ន និកាមលាភី** បានដល់ ឈ្មោះថា មិនមែនជាបុគ្គល ដែលបានតាមសេចក្ដី ប្រាថ្នា ព្រោះមិនបានដោយអាការតាមដែលប្រាថ្នា ព្រោះមិនបានប្រព្រឹត្តវសី ដោយអាការ ៥ យ៉ាង អធិប្បាយថា ជាអ្នកមិនជំនាញចូលសមាបត្តិ ។ បទថា **ន អកិច្ឆលាភី** បានដល់ បានដោយក្រ គឺបានដោយលំបាក អធិប្បាយថា បុគ្គលណា សង្កត់កិលេសទាំងឡាយទុកបាន ព្រោះអាគម គឺ

បរិយត្តិ និងបដិបត្តិ សម្រេចឧបចារៈ ដល់នូវអប្បនា បាននូវចិត្តមញ្ជូសា ( ចិត្តបាននូវបន្ទប់ ) លំបាកដោយសម្បយោគ គឺសេចក្ដីព្យាយាមដែលជាសសង្ខារដ៏លំបាក ទើបអាចសម្រេចសម្បទានោះ បុគ្គលនោះ ឈ្មោះថាមិនមែនជាបុគ្គលបានដោយមិនលំបាក ។ បទថា **ន អកសិរលាភី** បានដល់ជាអ្នកបានមិនបរិបូណ៌ អធិប្បាយថា ចូលសមាបត្តិហើយមិនអាចនឹងផ្សាយទៅអស់កាលយូរបាន គឺឲ្យប្រព្រឹត្តទៅបានត្រឹមតែមួយវារចិត្ត ឬពីរវារចិត្តហើយក៏ចេញដោយរួសរាន់នោះឯង ។ បទថា **យត្ថិច្ឆកំ** បានដល់ ប្រាថ្នាដើម្បីនឹងអង្គុយចូលសមាបត្តិក្នុងឱកាសណា ។ បទថា **យទិច្ឆកំ** សេចក្ដីថា រមែងប្រាថ្នាដើម្បីនឹងអង្គុយចូលសមាបត្តិណាមួយ គឺឈានមានកសិណជាអារម្មណ៍ ឈានមានខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញជាអារម្មណ៍ ឈានដែលមានព្រហ្មវិហារជាអារម្មណ៍ ឬឈានមានអសុភជាអារម្មណ៍ ។ បទថា **យាវតិច្ឆកំ** សេចក្ដីថា រមែងប្រាថ្នាកាលមានប្រមាណប៉ុនណា ដោយការកំណត់កាលយូរ ។

សេចក្ដីនេះ មានពាក្យអធិប្បាយថា ព្រះយោគី រមែងប្រាថ្នានឹងចូលខ្លះចេញខ្លះ នូវសមាបត្តិណាមួយ ក្នុងទីណាមួយ អស់កាលយូរ មានប្រមាណប៉ុនណា រមែងមិនអាចនឹងចូលខ្លះ ចេញខ្លះ នូវសមាបត្តិនោះ ក្នុងទីនោះៗ អស់កាលយូរ មានប្រមាណប៉ុណ្ណោះ គឺសម្លឹងមើលព្រះចន្ទ ឬព្រះអាទិត្យហើយកំណត់ថា កាលព្រះចន្ទ ឬព្រះអាទិត្យគោចរដល់ទីប្រមាណប៉ុណ្ណោះអញនឹងចេញអំពីសមាបត្តិ ហើយចូលឈាន រមែងមិនអាចចេញចាកឈាន

តាមដែលកំណត់ទុក រមែងចេញក្នុងចន្លោះនោះ ព្រោះខ្លួនជាអ្នកមិនជំនាញក្នុងសមាបត្តិ ។

បទថា **បមាទមាគម្ម** បានដល់ អាស្រ័យសេចក្ដីប្រមាទ ។ បទថា **អយំ វុច្ចតិ** បានដល់ បុគ្គល ៣ ពួកនេះឯង ហៅថា **កុប្បធម្មោ**។ បទថា **កុប្បធម្មោ** នេះ ជាឈ្មោះនៃបុគ្គល ៣ ពួក គឺបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមីដែលបានសមាបត្តិ ៨ ។ ឯធម៌ទាំងឡាយ ដែលជាសត្រូវចំពោះសមាធិ និងវិបស្សនារបស់លោកទាំងនោះ លោកសង្កត់សង្កិនមិនល្អជម្រះមិនល្អ ព្រោះហេតុនោះ ទើបសមាបត្តិរបស់លោកទាំងនោះវិនាសទៅ ។ម្យ៉ាងទៀត សមាបត្តិនោះ វិនាសទៅ សាបសូន្យទៅ ព្រោះសីលដាច់ ឬព្រោះការឈានកន្លងអាបត្តិប៉ុណ្ណោះ ក៏មិនមែន ។ គរុកមោក្ខធម៌នេះ រមែងវិនាសទៅ ព្រោះករណីយកិច្ច ឬព្រោះហេតុត្រឹមតែការបែកនៃវត្ត មានប្រមាណបន្តិចបន្តួច ។

ក្នុងសេចក្ដីនោះ មានរឿងដូចតទៅនេះ ជាឧទាហរណ៍

បានឮថា ព្រះថេរៈមួយរូបប្រើប្រាស់សមាបត្តិ ក្នុងទីមួយកន្លែង កាលលោកទៅកាន់ស្រុកដើម្បីបិណ្ឌបាត ពួកក្មេងលេងត្រង់បរិវេណ ហើយនាំគ្នាចៀសចេញទៅ ព្រះថេរៈមកហើយ គិតថា ពួកក្មេងមកហើយ នឹងបោសបរិវេណ ទើបលោកមិនបោស ចូលទៅកាន់វិហារ ដោយគិតថា អញនឹងចូលសមាបត្តិ លោកមិនអាចចូលបាន ទើបគិតថា អ្វីហ្ន៎ ជាគ្រឿងរារាំងពិចារណាដល់សីល មិនឃើញការប្រព្រឹត្តកន្លងសូម្បីមានប្រមាណតិចតួច

ទើបពិចារណាមើលថា វត្តភេទ គឺការបែកនៃវត្តរបស់អញមានឬ ដឹងថា មិនបានបោសបរិវេណ ទើបបោស ហើយក៏ទៅអង្គុយចូលសមាបត្តិ ។

[ ២០ ] និទ្ទេសនៃអកុប្បធម្មបុគ្គល បណ្ឌិតគប្បីជ្រាបដោយអំណាចនៃបដិបក្ខន័យរបស់កុប្បធម្មបុគ្គល ដែលពោលហើយនោះឯង ។ បទថា **អកុប្បធម្មោ** ជាឈ្មោះនៃព្រះអរិយបុគ្គល ២ ពួក គឺព្រះអនាគាមីដែលបានសមាបត្តិ ៨ នេះ និងព្រះខីណាស្រព ។ ពិតហើយ ធម៌ទាំងឡាយជាសត្រូវចំពោះសមាធិ និងវិបស្សនារបស់លោកទាំងនោះ លោកសង្កត់ទុកល្អហើយ ជម្រះល្អហើយ ព្រោះហេតុនោះ កាលលោកទាំងនោះ ញ៉ាំងកាលឲ្យកន្លងទៅ ដោយកិច្ចមានការសន្ទនា និងភាពជាបុគ្គលត្រេកអរដោយពួកគណៈជាដើម ឬដោយការប្រមាទ ដែលមិនសមគួរដល់ខ្លួនណាមួយដទៃៗ សមាបត្តិក៏មិនកម្រើក មិនវិនាស តែព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រព ដែលជាសុខវិបស្សកៈ រមែងមិនបានក្នុងទុកៈនេះ ទើបលោកទាំងនោះ ឈ្មោះថា ទុកមុត្តកបុគ្គល ព្រោះហេតុនោះ ទើបព្រះសាស្ដា ទ្រង់សរុបបុគ្គលទាំងឡាយ ដែលទ្រង់កាន់យក និងមិនកាន់យកខាងដើម ហើយលើកឡើងកាន់មាតិកាដោយបិដ្ឋិវដ្ដកបុគ្គលទាំងឡាយ ទុកក្នុងទុកៈនេះ ព្រោះទ្រង់មានបញ្ញា ជាគ្រឿងត្រាស់ដឹងល្អ ទើបត្រាស់បទថា **សព្ពេបិ អរិយបុគ្គលា** ដូច្នេះជាដើម ។

ម្យ៉ាងទៀត បើការកម្រើក ការវិនាសនៃសមាបត្តិ ៨ របស់លោកគប្បីមាន តែលោកុត្តរធម៌ដែលលោកចាក់ធ្លុះហើយម្ដង មិនកម្រើក និងមិនវិនាស

ទៅឡើយ ពាក្យនេះ លោកពោលសំដៅយកបុគ្គលសម្រេចលោកុត្តរធម៌នោះ ។

[ ២១-២២ ] និទ្ទេសនៃបរិហានធម្មបុគ្គល និងអបរិហានធម្មបុគ្គលទាំងឡាយ បណ្ឌិតគប្បីជ្រាបដោយអំណាចនៃកុប្បធម្មនិទ្ទេស និងអកុប្បធម្មនិទ្ទេសនោះឯង ។ ក្នុងទីនេះ ពាក្យថា ការវិនាសក្តី ការមិនវិនាសនៃធម៌ទាំងឡាយក្តី ទ្រង់បំណងយក ព្រោះអាស្រ័យការប្រមាទនៃបុគ្គលតែម្យ៉ាងទើបមានអត្ថផ្សេងគ្នាត្រឹមតែបរិយាយទេសនាប៉ុណ្ណោះ ។ ធម៌ដ៏សេស ដូចគ្នានោះឯង ។

[ ២៣ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃចេតនាភព្វបុគ្គលដូចតទៅនេះ បទថា **ចេតនាភព្វោ** បានដល់ គួរដល់នូវការមិនវិនាសដោយជុំវិញនៃចេតនា ។ បទថា **សចេ អនុសញ្ចេតេតិ** បានដល់ បើចូលសមាបត្តិ អធិប្បាយថា ព្រះយោគីកាលចូលសមាបត្តិ ឈ្មោះថា រមែងយកចិត្តទុកដាក់ ទើបមិនវិនាស ព្រះយោគីក្រៅអំពីនេះ រមែងវិនាស ។

[ ២៤ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអនុរក្ខណាភព្វបុគ្គលដូចតទៅ បទថា **អនុរក្ខណាភព្វោ** បានដល់ គួរដល់ការមិនវិនាស ដោយជុំវិញ នៃការតាមរក្សា ។ បទថា **សចេ អនុរក្ខតិ** សេចក្តីថា បើព្រះយោគីលះធម៌ដែលមិនមានឧបការៈ សេពធម៌ដែលមានឧបការៈ ចូលសមាបត្តិ កាលលោកបដិបត្តិយ៉ាងនេះ ឈ្មោះថា តាមរក្សា ទើបលោកមិនវិនាស ព្រះយោគីក្រៅអំពីនេះ រមែងវិនាស ។ ព្រះយោគីទាំង ២ ពួកនោះ ជាអ្នក

អាចតាំងសមាបត្តិធ្វើឲ្យមាំទាំ តែព្រះយោគីដែលឈ្មោះថា អនុរក្ខណាកព្វ-
បុគ្គលប៉ុណ្ណោះ មានសមត្ថភាពច្រើនជាងព្រះយោគីឈ្មោះថា ចេតនាកព្វបុគ្គល
ព្រោះថា ចេតនាកព្វបុគ្គលមិនដឹងធម៌ដែលមានឧបការៈ និងមិនមានឧបការៈ
កាលមិនដឹងទើបបន្ទោបង់ គឺនាំធម៌ដែលមានឧបការៈចេញទៅ ហើយសេព
ធម៌ដែលមិនមានឧបការៈ កាលសេពធម៌ ដែលមិនមានឧបការៈទាំងនោះ
លោករមែងវិនាសចាកសមាបត្តិ តែអនុរក្ខណាកព្វបុគ្គលរមែងដឹងធម៌ដែល
មានឧបការៈ និងមិនមានឧបការៈ កាលដឹងក៏រមែងបន្ទោបង់ គឺនាំធម៌ដែល
មិនមានឧបការៈចេញទៅ សេពធម៌ដែលមានឧបការៈទាំងឡាយ កាលលោក
សេពនូវធម៌ដែលមានឧបការៈទាំងនោះ រមែងមិនវិនាសចាកសមាបត្តិ ។

ប្រៀបដូចអ្នកយាមស្រែ ២ នាក់ ជាឧទាហរណ៍ដូច្នេះថា បុរសម្នាក់
មានរោគស្គមលឿង ទ្រាំនឹងរងាជាដើមមិនបាន ម្នាក់ទៀតមិនមានរោគ អត់
ធន់រងាជាដើមបាន បុគ្គលដែលមានរោគ មិនចុះអំពីខ្ទមទៅខាងក្រោម គេ
លះបង់នូវការយាមស្រែ ទាំងថ្ងៃ ទាំងយប់ ពួកសេក ពួកព្រាប និងក្ងោក
ជាដើម នាំគ្នាមកកាន់ស្រែរបស់គាត់ក្នុងពេលថ្ងៃ ចឹកកួរស្រូវសាលី ក្នុង
ពេលយប់ ពួកម្រឹគ និងជ្រូកជាដើមចូលទៅកាន់ស្រែ កាយបំផ្លាញ ហាក់បី
ដូចជាស្រែធ្វើខ្ទនឯង កាលកាយបំផ្លាញហើយក៏ទៅ បុរសអ្នកស្រែមិនសល់
ត្រឹមតែពូជ ព្រោះការប្រមាទរបស់ខ្លួន ។ ឯបុរសមិនមានរោគ មិនលះបង់
ការរក្សាស្រែទាំងពេលថ្ងៃ និងពេលយប់ បុរសនោះរមែងបានស្រូវប្រមាណ
៤ រទេះខ្វះ ៨ រទេះខ្វះ អំពីទីប្រមាណមួយករីសៈ ព្រោះការមិនប្រមាទ

របស់ខ្លួន ។ ព្រះយោគី ២ រូបនោះ បណ្ឌិតគប្បីឃើញព្រះយោគីដែលជាចេតនាកព្វបុគ្គល ដូចគ្នានឹងបុរសមានរោគរក្សាស្រែ គប្បីឃើញព្រះយោគីដែលជាអនុរក្ខណាកព្វបុគ្គល ដូចបុគ្គលមិនមានរោគ ។

បណ្ឌិតគប្បីជ្រាបនូវការវិនាសចាកសមាបត្តិនៃចេតនាកព្វបុគ្គល ដែលមិនដឹងធម៌មានឧបការៈ និងធម៌មិនមានឧបការៈ ហើយលះធម៌ដែលមានឧបការៈ សេពនូវធម៌ដែលមិនមានឧបការៈ ដូចគ្នានឹងការមិនបានគ្រាប់ពូជដើម្បីសាបព្រោះបន្តទៀតរបស់បុរសមានរោគ ព្រោះសេចក្តីប្រមាទរបស់ខ្លួន គប្បីជ្រាបការមិនសាបសូន្យចាកសមាបត្តិ របស់អនុរក្ខណាកព្វបុគ្គលដែលដឹងធម៌មានឧបការៈ និងមិនមានឧបការៈ ហើយលះនូវធម៌ ដែលមិនមានឧបការៈ សេពនូវធម៌ដែលមានឧបការៈ ប្រៀបដូចការបានស្រូវ ៤ ឬ ៨ រទេះ អំពីស្រែទំហំប្រមាណមួយករីសៈរបស់បុរសដែលមិនមានរោគ ព្រោះការមិនប្រមាទរបស់ខ្លួន ។ អនុរក្ខណាកព្វបុគ្គលប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា មានការអាចជាងចេតនាកព្វបុគ្គល ក្នុងការធ្វើសមាបត្តិឲ្យគង់ ដោយប្រការដូច្នេះ ។

[ ២៥ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបុថុជ្ជនបុគ្គល ដូចតទៅនេះ បទថា **តីណិ សំយោជនានិ** បានដល់ ទិដ្ឋិសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ និងវិចិកិច្ឆាសញ្ញោជនៈ សញ្ញោជនៈទាំងនោះ ឈ្មោះថា លោកលះបានហើយ ក្នុងខណៈនៃផលចិត្ត ។ ព្រះសាស្តាទ្រង់សម្តែងថា បុថុជ្ជននេះរមែងមិនមានក្នុងខណៈនៃផលចិត្ត ។ បទថា **តេសំ ធម្មានំ** បានដល់

សញ្ញោជនធម៌ទាំងនោះ ។ បុថុជ្ជន ឈ្មោះថា ជាអ្នកបដិបត្តិហើយ ដើម្បីលះសញ្ញោជនៈទាំងនោះ ក្នុងខណៈនៃមគ្គចិត្ត តែបុថុជ្ជននេះ រមែងមិនមានក្នុងខណៈនៃមគ្គចិត្ត បុថុជ្ជនល្វង់ខ្លៅនោះឯងលះកម្មដ្ឋានហើយ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ទុកក្នុងបុថុជ្ជននិទ្ទេសនេះ ដោយហេតុមានប្រមាណត្រឹមប៉ុណ្ណោះ ។

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេស នៃគោត្រភូបុគ្គល ដូចតទៅនេះ បទថា **យេសំ ធម្មានំ** បានដល់ កុសលធម៌ជាង ៥០ ដែលកើតឡើងមួយអន្លើដោយគោត្រភូញាណពួកណា ។ បទថា **អរិយធម្មស្ស** បានដល់ លោកុត្តរមគ្គ ។ បទថា **អវក្កន្តិ ហោតិ** បានដល់ រមែងឈានចុះ គឺកើតឡើងប្រាកដ ។ បទថា **អយំ វុច្ចតិ** ព្រះមានព្រះភាគត្រាស់ហៅថា គោត្រភូបុគ្គល ព្រោះឈានកន្លងញាណរបស់បុថុជ្ជន គោត្ដរបស់បុថុជ្ជន មណ្ឌលរបស់បុថុជ្ជន និងបញ្ញត្តិរបស់បុថុជ្ជនទាំងពួងហើយ ទើបឈានចុះកាន់អរិយញ្ញាណ អរិយគោត្ត អរិយមណ្ឌល និងអរិយបញ្ញត្តិបាន ដោយញាណដែលមានព្រះនិព្វានជាអារម្មណ៍ ។

[ ២៧ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃភយូបរតបុគ្គល ដូចតទៅនេះ បុគ្គលណាវៀរនូវបាប ព្រោះសេចក្ដីខ្លាច ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ភយូបរតោ** អធិប្បាយថា ព្រះសេក្ខបុគ្គល ៧ ពួក និងបុថុជ្ជនទាំងឡាយដែលមានសីល ភ័យហើយ រមែងវៀរចាកបាប គឺមិនធ្វើបាប ។

ក្នុងជនទាំងនោះ បុថុជ្ជន រមែងខ្លាចភ័យ ៤ យ៉ាង គឺទុគ្គតិភ័យ ១

វដ្តភ័យ ១ កិលេសភ័យ ១ ឧបវាទភ័យ ១ ។

ក្នុងភ័យទាំងនោះ ភ័យ គឺការទៅកាន់ទុគ្គតិ ឈ្មោះថា ទុគ្គតិភយៈ ព្រោះអត្ថថា ដែលបុគ្គលគប្បីខ្លាច ។ ក្នុងភ័យទាំង ៣ ដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងលោកទាំងនោះ បុថុជ្ជនខ្លាចទុគ្គតិភ័យ ដោយគិតថា បើអ្នកធ្វើបាបសោត អបាយទាំង ៤ ដូចជាពស់ថ្លាន់កំពុងឃ្លានហាមាត់រង់ចាំអ្នក អ្នកកាលសោយទុក្ខក្នុងអបាយទាំងនោះនឹងធ្វើអ្វីបាន ទើបមិនធ្វើបាប ។ សង្សារវដ្តមានខាងដើម និងខាងចុង ដែលដឹងមិនបាននោះឯង ឈ្មោះថា វដ្តភយៈ ។ អកុសលទាំងពួង ឈ្មោះថា កិលេសភយៈ ។ ការតិះដៀល ឈ្មោះថា ឧបវាទភយៈ ។

បុថុជ្ជនខ្លាចភ័យទាំងនោះ រមែងមិនធ្វើបាប តែព្រះសេក្ខៈ ៣ ពួក គឺ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ទាំង ៣ នេះ ឆ្លងផុតចាកទុគ្គតិភ័យបានហើយ ទើបនៅខ្លាចភ័យទាំង ៣ ដ៏សេស រមែងមិនធ្វើបាប ។ ព្រះសេក្ខៈដែលតាំងនៅក្នុងមគ្គ ឈ្មោះថា ជាអ្នកវៀរចាកព្រោះខ្លាច ដោយអំណាចនៃការសម្រេច ឬព្រោះភាពជាអ្នកកាត់នូវភ័យមិនទាន់ដាច់ ។

ព្រះខីណាស្រពមិនខ្លាចភ័យ សូម្បីតែមួយក្នុងភ័យទាំង ៤ នេះ ព្រោះលោកកាត់នូវភ័យ បានជាសមុច្ឆេទហើយដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបហៅថា **អភយូបរតោ** ។

សួរថា ព្រះខីណាស្រព មិនខ្លាចសូម្បីតែឧបវាទភ័យ គឺភ័យព្រោះការតិះដៀលឬ ឆ្លើយថា មិនខ្លាច តែមិនគួរពោលថា លោករក្សាឧបវាទភ័យ

សេចក្តីនេះ បណ្ឌិតគប្បីឃើញដូចព្រះវីណាស្រោណថេរៈ ក្នុងស្រុក ទោណុប្បលវាបិ ជាគំរូ ។

[ ២៨-២៩ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអភព្វាគមនបុគ្គល ដូចតទៅនេះ បុគ្គលណា មិនគួរនឹងសម្រេចសម្មត្តនិយាម ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា អភព្វាគមនបុគ្គល ។ បទថា **កម្មាវរណេន** បានដល់ អនន្តរិយកម្ម ៥ យ៉ាង ។ បទថា **កិលេសាវរណេន** បានដល់ និយតមិច្ឆាទិដ្ឋិ ។ បទថា **វិបាកាវរណេន** បានដល់ បដិសន្ធិដោយអហេតុកចិត្ត និងទ្វិហេតុកចិត្ត ។ បទថា **អស្សទ្ធា** បានដល់ ជាអ្នកវៀរចាកការជឿ ក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។ បទថា **អច្ឆន្ទិកា** បានដល់ ជាអ្នកវៀរចាកការពេញចិត្តក្នុងកត្តុកម្យតាកុសល ។ មនុស្សទាំងឡាយ ដែលនៅក្នុងទ្វីបទាំង ៣ ក្រៅអំពីនេះ វៀរជម្ពូទ្វីប គប្បីជ្រាបថា រាប់បញ្ចូលក្នុងបុគ្គលដែលមិនមានឆន្ទៈ ។ បទថា **ទុប្បញ្ញា** បានដល់ វៀរចាកភវង្គប្បញ្ញា ។ បទថា **អភព្វា** បានដល់ មិនបានឧបនិស្ស័យនៃមគ្គ និងផល ។ បទថា **និយាមំ** បានដល់ មគ្គនិយាម ។ បទថា **ឱក្កមិតុំ** សេចក្តីថា មិនគួរនឹងឈានចុះ គឺចូលទៅកាន់និយាម ពោល គឺសម្មត្តៈក្នុងធម៌ទាំងឡាយ ដែលជាកុសល ដើម្បីតាំងមាំក្នុងមគ្គផលនោះបាន ។

និទ្ទេសនៃភព្វាគមនបុគ្គល បណ្ឌិតគប្បីជ្រាបដោយបដិបក្ខន័យ ចាកពាក្យដែលពោលហើយ ។ ព្រះមានព្រះភាគ ត្រាស់ក្នុងទុកៈនេះយ៉ាងនេះថា បុគ្គលណា ធ្វើអនន្តរិយកម្ម ៥ បុគ្គលណាជានិយតមិច្ឆាទិដ្ឋិ បុគ្គលណាជា

*អ្នកបដិសន្ធិដោយអហេតុកចិត្ត និងទ្វិហេតុកចិត្ត បុគ្គលណា មិនជឿព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម បុគ្គលណាមិនមានឆន្ទៈក្នុងកុសល បុគ្គលណាមានកវង្គបញ្ញាមិនបរិបូណ៌ បុគ្គលណា មិនមានឧបនិស្ស័យនៃមគ្គ និងផល បុគ្គលទាំងអស់នោះជាកព្វវិបរិត មិនគប្បីឈានចុះកាន់សម្មត្តនិយាមធម៌ គឺ មគ្គ ផល និងនិព្វាន ។*

*[ ៣០ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃនិយតានិយតបុគ្គល បទថា* **អានន្តរិកា** *បានដល់ អ្នកដល់ព្រមដោយអនន្តរិយកម្ម ។ បទថា* **មិច្ឆាទិដ្ឋិកា** *បានដល់ អ្នកដល់ព្រមដោយនិយតមិច្ឆាទិដ្ឋិ ។ បុគ្គលទាំងនោះ ឈ្មោះថា និយតៈ ព្រោះជាអ្នកទៀងដើម្បីជាប្រយោជន៍ដល់នរក ។ ឯព្រះអរិយបុគ្គល ៨ ពួក ឈ្មោះថា និយតៈ ព្រោះជាបុគ្គលទៀងដើម្បីជាប្រយោជន៍ដល់មគ្គ និងផល ខាងលើ និងដើម្បីជាប្រយោជន៍ ដល់អនុបាទាបរិនិព្វាន ដោយភាវៈដែលពាល់ត្រូវ ។ ឯបុគ្គលដ៏សេសមានគតិមិនទៀង ប្រៀបដូចកំណាត់ឈើដែលបុគ្គលបោះទៅក្នុងអាកាស កាលធ្លាក់ចុះលើផែនដី បុគ្គលណាមួយក៏មិនដឹងថា ខាងចុង កណ្ដាល ឬគល់ធ្លាក់មកមុន យ៉ាងណា បុគ្គលទាំងនោះក៏ដូចគ្នា បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ជាអនិយតៈ ព្រោះកំណត់ពិតប្រាកដមិនបានថា បុគ្គលនេះនឹងកើតក្នុងគតិ ឈ្មោះនោះ ក៏យ៉ាងនោះ ។ អ្នកឧត្តរកុរុទ្វីប មានគតិទៀងតាមដែលលោកពោលទុកនោះ មិនមែនដោយអំណាចនិយតធម៌ឡើយ ពិតហើយ មិច្ឆត្តនិយតធម៌ និងសម្មត្តនិយតធម៌ប៉ុណ្ណោះ ឈ្មោះថា ទៀង ។ លោកពោលកំណត់បុគ្គលនេះ ដោយអំណាចនៃមិច្ឆត្តនិយតធម៌*

និងសម្មត្តនិយតធម៌ទាំងនោះ ដោយប្រការដូច្នេះ ។

[ ៣១ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបដិបន្នកបុគ្គល ដូចតទៅនេះ បទថា **មគ្គសមង្គិនោ** បានដល់ បុគ្គលដែលតាំងនៅក្នុងមគ្គ ។ ឯបុគ្គលតាំងនៅក្នុងមគ្គទាំងនោះ ឈ្មោះថា បដិបន្នកបុគ្គល ព្រោះជាអ្នកបដិបត្តិដើម្បីផល ។ បទថា **ផលសមង្គិនោ** បានដល់ ដល់ព្រមដោយផល ព្រោះជាបុគ្គលដល់ព្រមក្នុងការបានផល ។ សេចក្តីពិត រាប់តាំងអំពីការបានផលហើយ លោកទាំងនោះ មិនចូលផលសមាបត្តិ ក៏ឈ្មោះថា តាំងនៅក្នុងផលនោះឯង ។

[ ៣២ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសមសីសីបុគ្គលដូចតទៅនេះ បទថា **អបុព្វំ អចរិមំ** បានដល់ មិនមុន មិនក្រោយ អធិប្បាយថា ព្រមគ្នានោះឯង ។ បទថា **បរិយាទានំ** បានដល់ ការអស់ទៅដោយជុំវិញ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះព្រះមានព្រះភាគ ត្រាស់ហៅថា **សមសីសី** ។ សមសីសីបុគ្គលនេះ មាន ៣ ពួក គឺឥរិយាបថសមសីសី ១ រោគសមសីសី ១ ជីវិតសមសីសី ១ ។

បណ្តាបុគ្គលទាំងនោះ បុគ្គលណាកំពុងចង្រ្កម ផ្តើមតាំងវិបស្សនាហើយសម្រេចអរហត្តកំពុងចង្រ្កមនោះឯងក៏បរិនិព្វាន ដូចព្រះបទុមត្ថេរ ។ បុគ្គលណា កំពុងឈរ ផ្តើមវិបស្សនា ហើយសម្រេចអរហត្តកំពុងឈរនោះឯងហើយបរិនិព្វាន ដូចព្រះតិស្សត្ថេរនៅក្នុងវិហារ ឈ្មោះកោដបព៌ត ។ បុគ្គលណាកំពុងអង្គុយ ផ្តើមវិបស្សនាហើយសម្រេចអរហត្ត កំពុងអង្គុយនោះឯងហើយបរិនិព្វាន ។ បុគ្គលណា កំពុងដេក ផ្តើមវិបស្សនា ហើយសម្រេច

អរហត្តទាំងកំពុងដេកនោះឯង ក៏បរិនិព្វាន បុគ្គលទាំងអស់ដូចពោលមកនេះ ឈ្មោះថា **ឥរិយាបថសមសីសីបុគ្គល** ។

បុគ្គលណាកើតរោគណាមួយហើយ ផ្តើមវិបស្សនា ទាំងរោគមិនទាន់ជា នោះឯង ហើយសម្រេចអរហត្ត បរិនិព្វានដោយរោគនោះឯង បុគ្គលនេះ ឈ្មោះថា **រោគសមសីសី** ។

សួរថា បុគ្គលដែលឈ្មោះថា **ជីវិតសមសីសី** តើដូចម្តេច ឆ្លើយថា ពាក្យថា **សីស** មាន ១៣ យ៉ាង គឺតណ្ហា ឈ្មោះថា បលិពោធសីសៈ ១ មានះ ឈ្មោះថា ពន្ធនសីសៈ ១ ទិដ្ឋិ ឈ្មោះថា បរាមាសសីសៈ ១ ឧទ្ធច្ចៈ ឈ្មោះថា វិក្ខេបសីសៈ ១ អវិជ្ជា ឈ្មោះថា កិលេសសីសៈ ១ សទ្ធា ឈ្មោះថា អធិមោក្ខសីសៈ ១ វីរិយៈ ឈ្មោះថា បគ្គហសីសៈ ១ សតិ ឈ្មោះថា ឧបដ្ឋានសីសៈ ១ សមាធិ ឈ្មោះថា អវិក្ខេបសីសៈ ១ បញ្ញា ឈ្មោះថា ទស្សនសីសៈ ១ ជីវិតិន្ទ្រិយ ឈ្មោះថា បវត្តសីសៈ ១ វិមោក្ខ ឈ្មោះថា គោចរសីសៈ ១ និរោធ ឈ្មោះថា សង្ខារសីសៈ ១ ៕

បណ្តាសីសៈទាំងនោះ អរហត្តមគ្គ រមែងគ្របសង្កត់អវិជ្ជា គឺកិលេស-សីសៈ ចុតិចិត្ត រមែងគ្របសង្កត់ជីវិតិន្ទ្រិយ គឺបវត្តសីសៈ ចិត្តដែលគ្រប សង្កត់អវិជ្ជា រមែងមិនអាចគ្របសង្កត់ជីវិតិន្ទ្រិយបាន ចិត្តដែលគ្របសង្កត់ ជីវិតិន្ទ្រិយ ក៏មិនអាចគ្របសង្កត់អវិជ្ជាបាន ចិត្តដែលគ្របសង្កត់អវិជ្ជា ក៏ មួយបែប ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រិយក៏មួយបែប ។ សីសៈទាំង ២ យ៉ាង នេះ របស់បុគ្គលណា ដល់នូវការអស់ទៅព្រមៗ គ្នា បុគ្គលនោះ ឈ្មោះថា

**ជីវិតសមសីសី ។**

សួរថា សីសៈទាំង ២ យ៉ាងនេះ មានព្រមគ្នាបានដូចម្តេច ឆ្លើយថា មានព្រមគ្នាបាន ព្រោះការព្រមគ្នាដោយវារៈ អធិប្បាយថា ការចេញចាកមគ្គរមែងមានក្នុងវារៈណា វារៈនោះ ឈ្មោះថា មានព្រមគ្នា គឺបុគ្គលណាតាំងនៅក្នុងបច្ចវេក្ខណញ្ញាណ ១៩ យ៉ាង គឺបច្ចវេក្ខណៈក្នុងសោតាបត្តិមគ្គ ៥ ក្នុងសកទាគាមិមគ្គ ៥ ក្នុងអនាគាមិមគ្គ ៥ ក្នុងអរហត្តមគ្គ ៤ ហើយធ្លាក់ចុះកាន់ភវង្គ ទើបបរិនិព្វាន ការអស់ទៅនៃសីសៈទាំង ២ យ៉ាងនេះ ឈ្មោះថា មានព្រមគ្នា ព្រោះការព្រមគ្នាដោយវារៈទាំងនេះ ព្រោះហេតុនោះ ទើបបុគ្គលនេះ ព្រះមានព្រះភាគត្រាស់ថា **ជីវិតសមសីសី ។** បុគ្គលនេះ ប៉ុណ្ណោះ ព្រះមានព្រះភាគ ទ្រង់បំណងយកក្នុងសមសីសីនិទ្ទេសនេះ ។

[ ៣៣ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃឋិតកប្បីបុគ្គលដូចតទៅនេះ កប្បតាំងនៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ឋិតកប្បោ ។** កប្បតាំងនៅនៃបុគ្គលនោះមាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឋិតកប្បី** អធិប្បាយថា ជាអ្នកអាចឲ្យកប្បតាំងនៅបាន ។

បទថា **ឧឌ្ឍយ្ហនវេលា អស្ស** បានដល់ វេលាជាទីឆេះនៃកប្បនោះមាន ។ បទថា **នេវ តាវ** សេចក្តីថា បុគ្គលដែលដល់ព្រមដោយមគ្គនេះ មិនទាន់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ដរាបណា កប្បមិនត្រូវភ្លើងឆេះ ដរាបនោះ ។ បុគ្គលដែលដល់ព្រមដោយមគ្គនោះ ទោះបីត្រូវភ្លើងឆេះ ក៏មិនឆេះឡើយ គប្បីតាំងនៅបាន ។ ពិតហើយ ឈ្មោះថា កប្បវិនាស ជាវិការធំ

ជាសេចក្ដីព្យាយាមធំ ជាមហាលោកវិនាសដោយអំណាចនៃការឆេះ អស់សែនកោដិចក្កវាឡ ។ លោកពោលថា កប្បវិនាសនេះជាការវិនាសធំ គប្បីប្រាកដយ៉ាងនេះឯង តែកាលសាសនា នៅតាំងនៅ នៅឡើយ ឈ្មោះថា កប្បវិនាសក៏មិនមាន ទាំងសាសនាក៏រមែងមិនមានក្នុងកាលដែលកប្បវិនាស តែឈ្មោះថា កប្បវិនាស រមែងមាន ក្នុងកាលដែលដល់ទីបំផុតហើយ ។ កាលបើយ៉ាងនេះ ព្រះសាស្ដាទ្រង់នាំហេតុនេះមក ដើម្បីសម្ដែងការមិនមានអន្តរាយ ។ ហេតុនេះគប្បីមាន តែអន្តរាយណាមួយ មិនអាចធ្វើអន្តរាយទាំងឡាយចំពោះផលចិត្ត របស់មគ្គបុគ្គលបាន ។ សួរថា បុគ្គលនេះ ឲ្យកប្បតាំងនៅបាន គប្បីតាំងនៅអស់កាលមានប្រមាណប៉ុនណា ឆ្លើយថា ការចេញចាកមគ្គរមែងមានក្នុងវារៈណា ក្នុងវារៈនោះ កាលកវង្គចិត្តផ្លាស់ប្ដូរទៅ មនោទ្វារាវជ្ជនចិត្តក៏កើតឡើង បន្ទាប់អំពីនោះ អនុលោមញាណក៏កើតឡើង ៣ ខណៈ គោត្រភូចិត្តកើតឡើង ១ ខណៈ មគ្គចិត្តកើតឡើង ១ ខណៈ ផលចិត្តកើតឡើង ២ ខណៈ បច្ចវេក្ខណញ្ញាណកើតឡើង ៥ ដង បុគ្គលនេះគប្បីតាំងនៅអស់កាលមានប្រមាណប៉ុណ្ណេះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អាចារ្យទាំងឡាយ សម្ដែងសេចក្ដីនេះយ៉ាងនេះដោយឧបមាជាមួយវត្ថុដែលមកអំពីខាងក្រៅ ។

បើបុគ្គលគប្បីយកខ្សែ ៣ ធ្នុង ចងដុំថ្មកម្រាស់ប្រមាណ ១ យោជន៍ សំយុងលើក្បាលរបស់បុគ្គល ដែលដល់ព្រមដោយសោតាបត្តិមគ្គ កាលខ្សែធ្នុងទី ១ ដាច់ហើយ ដុំថ្មសំយុងដោយខ្សែធ្នុងទី ២ កាលធ្នុងទី ២

ដាច់ហើយ ក៏សំយុងនៅដោយធ្នុង ១ កាលធ្នុង ១ ដាច់ហើយ ដុំថ្មនោះ ក៏អណ្តែតនៅលើអាកាស ដូចដុំពពកព្យុះបក់ឲ្យអណ្តែត ថ្មនោះមិនបានធ្វើអន្តរាយ ដល់លំដាប់នៃមគ្គរបស់បុគ្គលនោះឡើយ ។ ការសម្តែងនេះ ជាការសម្តែងត្រឹមបន្តិចបន្តួច ការសម្តែងពេលមុននោះឯង ជាការសម្តែងធំ ។ មិនមែនត្រឹមតែបុគ្គលតាំងនៅក្នុងសោតាបត្តិមគ្គប៉ុណ្ណោះ ឈ្មោះថា តាំងនៅអស់កប្ប សូម្បីបុគ្គលដល់ព្រមដោយមគ្គក្រៅអំពីនេះ ក៏តាំងនៅអស់កប្បដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់លើកយកបុគ្គលដែលទ្រង់កាន់យក និងមិនកាន់យកខាងដើមមកហើយ ទ្រង់លើកឡើងកាន់បែបផែននេះ ព្រមជាមួយបិដ្ឋិវដ្តកបុគ្គលទាំងឡាយ ។ បុគ្គលដល់ព្រមដោយមគ្គទាំងអស់ ឈ្មោះថា **ឋិតកប្បី** ដូច្នេះ ។

[ ៣៤ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអរិយបុគ្គល ដូចតទៅនេះ ឈ្មោះថា **អរិយា** ព្រោះជាអ្នកឆ្ងាយអំពីកិលេសទាំងឡាយ ។ ឈ្មោះថា អរិយៈ ព្រោះលោក ព្រមទាំងទេវលោកគប្បីចូលទៅរក ។ អត្ថថា បរិសុទ្ធ ឈ្មោះថា អត្ថនៃអរិយៈ ព្រោះហេតុនោះ ទើបឈ្មោះថា អរិយៈ ព្រោះជាអ្នកបរិសុទ្ធ ។ ជនទាំងឡាយដ៏សេស ឈ្មោះថា **អនរិយា** ព្រោះជាអ្នកមិនបរិសុទ្ធ ។

[ ៣៥ ] វិនិច្ឆ័យក្នុងនិទ្ទេសនៃសេក្ខបុគ្គល ដូចតទៅនេះ បុគ្គលពួកណា ដល់ព្រមដោយអរិយមគ្គ នៅសិក្សាសិក្ខាទាំង ៣ មានអធិសីលសិក្ខាជាដើម ក្នុងខណៈនៃមគ្គចិត្ត និងបុគ្គលពួកណា ដល់ព្រមដោយអរិយផល

នៅសិក្សាសិក្ខាទាំង ៣ មានអធិសីលសិក្ខាជាដើម ក្នុងខណៈនៃផលចិត្ត បុគ្គលទាំងនោះ ទើបឈ្មោះថា **សេក្ខា** ។ ឯព្រះអរហន្ត លោកសិក្សាសិក្ខាទាំង ៣ ចប់ហើយ ក្នុងខណៈនៃអរហត្តផល កិច្ច គឺការសិក្សាមិនមានដល់លោកទៀតឡើយ ព្រោះហេតុនោះ ទើបព្រះអរហន្ត ឈ្មោះថា **អសេក្ខា** ។ ព្រះអរិយបុគ្គល ៧ ពួក លោកកំពុងសិក្សានៅឡើយ ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកឈ្មោះថា **សេក្ខ** ។ ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា **អសេក្ខ** ជាអ្នកសិក្សាចប់ហើយ ព្រោះថា សីលជាដើមលោកសិក្សាហើយ ក្នុងសម្នាក់នៃបុគ្គលដទៃ ។ ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយឈ្មោះថា **អសេក្ខ** ដែលមិនចាំបាច់សិក្សា ព្រោះលោកជាសយម្ភូ គឺជាអ្នកត្រាស់ដឹងឯង ។ បុគ្គលដ៏សេសទាំងឡាយ កំពុងសិក្សាក៏មិនមែន សិក្សាហើយក៏មិនមែន ព្រោះហេតុនោះ ទើបឈ្មោះថា ជាសេក្ខៈក៏មិនមែន ជាអសេក្ខៈក៏មិនមែន ។

[ ៣៦-៣៧ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃតេវិជ្ជបុគ្គល ដូចតទៅនេះ បុគ្គលដែលញុំាងបុព្វេនិវាសញ្ញាណ និងទិព្វចក្ខុញ្ញាណឲ្យកើតឡើង ហើយសម្រេចអរហត្ត ក្នុងកាលជាខាងក្រោយក្តី បុគ្គលសម្រេចអរហត្តមុន ហើយញុំាងបុព្វេនិវាសញ្ញាណ និងទិព្វចក្ខុញ្ញាណឲ្យកើតឡើងក្តី ឈ្មោះថា **តេវិជ្ជោ** ទាំងអស់ ។ ពាក្យពោលក្នុងព្រះសូត្រ ជាការសម្តែងដោយអម ពាក្យពោលក្នុងព្រះអភិធម្ម ជាការសម្តែងដោយត្រង់ ព្រោះហេតុនោះ ញាណដែលគប្បីសម្រេចនោះឯង ជាការសំខាន់ក្នុងទីនេះ ព្រោះហេតុនោះ បុគ្គលដែលញុំាង

វិជ្ជា ២ ឲ្យកើតឡើងមុន ហើយសម្រេចអរហត្ត ក្នុងកាលជាខាងក្រោយ នោះឯង ទ្រង់បំណានយកក្នុងតេវិជ្ជនិទ្ទេសនេះ សូម្បីបុគ្គលអ្នកមានអភិញ្ញា ៦ ក៏ន័យនេះដូចគ្នា ។

[ ៣៨ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសម្មាសម្ពុទ្ធបុគ្គល ដូចតទៅនេះ បទថា **បុព្វេ អននុស្សុតេសុ** បានដល់ ក្នុងធម៌ដែលមិនធ្លាប់ស្តាប់មកអំពីមុន ក្នុងសម្នាក់នៃបុគ្គលដទៃ ក្នុងកាលមុនអំពីការត្រាស់ដឹងសច្ចធម៌ក្នុងបច្ឆិមភព ។ ក្នុងភពមុនៗ អំពីភពនោះ ព្រះសព្វញ្ញុពោធិសត្វ ទ្រង់ព្រះផ្នួសក្នុងព្រះពុទ្ធ-សាសនា រៀនព្រះត្រៃបិដកហើយលើកឡើងកាន់គតបច្ចាគតវត្ត គឺវត្តដែលនាំកម្មដ្ឋានទៅ និងនាំកម្មដ្ឋានមក ផ្តើមតាំងកម្មដ្ឋានរហូតដល់អនុលោមញាណនិងគោត្រភូញាណ ព្រោះហេតុនោះ បទថា **សម្មាសម្ពុទ្ធោ** នេះ លោកសំដៅដល់ភាពជាបុគ្គល ដែលមិនមានបុគ្គលណាមួយ ជាអាចារ្យក្នុងបច្ឆិមភព គឺភពចុងក្រោយប៉ុណ្ណោះ ។

ពិតហើយ ព្រះតថាគតទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង ៤ ដោយព្រះអង្គឯង ដោយញាណដ៏ប្រចក្សដល់ព្រះអង្គថា នេះទុក្ខ ។បេ។ នេះជាបដិបទាឲ្យដល់នូវការរលត់ទុក្ខ ដូច្នេះ ក្នុងសន្តតធម៌ទាំងឡាយដែលខ្លួនឯងមិនបានស្តាប់មកក្នុងសម្នាក់នៃបុគ្គលដទៃ ព្រោះព្រះអង្គជាអ្នកមានបារមី ពេញបរិបូណ៌ហើយ ។ បទថា **តត្ថ** បានដល់ ក្នុងអរហត្តមគ្គ ពោល គឺបញ្ញាជាគ្រឿងត្រាស់ដឹងសច្ចធម៌ទាំង ៤ នោះ ។ បទថា **សព្វញ្ញុតំ ចាបុណាតិ ពលេសុ ច វសីភាវំ** បានដល់ រមែងដល់នូវភាពជាអ្នកជំនាញក្នុងការសម្រេច

សព្វញ្ញុតញ្ញាណ និងក្នុងទសពលញ្ញាណទាំងឡាយ ។ កិច្ចដទៃដែលឈ្មោះថា គួរធ្វើមិនមានដល់ព្រះពុទ្ធទាំងឡាយ តាំងអំពីការសម្រេចសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណ ដូចឥស្សរិយយសទាំងអស់ បុគ្គលណាមួយ មិនគួរពោលថា ឈ្មោះថា ឥស្សរិយយសនេះ មិនមកដល់ខត្តិយកុមារ ដែលជាឧភតោសុជាត តាំងអំពីការបានអភិសេក ឥស្សរិយយសនេះ រមែងជាធម្មជាតិមកហើយទាំងអស់ យ៉ាងណា ឈ្មោះថា គុណនេះដែលបុគ្គលណាមួយមិនគួរពោលថា មិនមកដល់ហើយដល់ព្រះពុទ្ធទាំងឡាយ ព្រះពុទ្ធទាំងឡាយ មិនត្រាស់ដឹងហើយ និងមិនប្រចក្សដល់ព្រះពុទ្ធទាំងឡាយ ចាប់តាំងអំពីការសម្រេចអរហត្តមគ្គ គុណ គឺសព្វញ្ញុតញ្ញាណទាំងពួង ឈ្មោះថា មកហើយ ព្រះពុទ្ធបានចាក់ធ្លុះហើយ ធ្វើឲ្យប្រចក្សហើយយ៉ាងនោះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលចាក់ធ្លុះសព្វញ្ញុគុណ ដោយអរិយមគ្គ ដោយអានុភាពដែលការសម្រេចមកអំពីការបំពេញបារមី យ៉ាងនេះ នេះហៅថា **សម្មាសម្ពុទ្ធោ** ។

[ ៣៩ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបច្ចេកសម្ពុទ្ធបុគ្គល ដូចតទៅនេះ បណ្ឌិតគប្បីជ្រាបអត្ថនៃបទថា **បុព្វេ អននុស្សុតេសុ** ដោយន័យដែលពោលហើយក្នុងកាលមុននោះឯង ។ ពិតហើយ ព្រះបច្ចេកពុទ្ធក្នុងភពចុងក្រោយ មិនមានបុគ្គលណាមួយ ជាអាចារ្យ លោកចាក់ធ្លុះនូវសច្ចធម៌ទាំង ៤ ដោយអត្តកំសិកញ្ញាណ គឺញាណដែលដឹងចំពោះខ្លួននោះឯង តែមិនបានសម្រេចភាពជាអ្នកសន្សំវសីក្នុងសព្វញ្ញុតញ្ញាណ និងក្នុងទសពលញ្ញាណឡើយ ។

[ ៤០ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃឧភតោភាគវិមុត្តបុគ្គល ដូចតទៅនេះ បទថា **អដ្ឋ វិមោក្ខេ កាយេន ផុសិត្វា វិហរតិ** សេចក្តីថា បាននូវសមាបត្តិ ៨ ដោយសហជាតនាមកាយ សម្រេចសម្រាន្តនៅ ។ បទថា **បញ្ញាយ ចស្ស ទិស្វា** សេចក្តីថា អាសវៈទាំង ៤ អស់ហើយ ព្រោះឃើញសង្ខារដោយវិបស្សនាបញ្ញា ឃើញសច្ចធម៌ទាំង ៤ ដោយមគ្គបញ្ញា ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា ឧភតោ-ភាគវិមុត្ត ។ ក្នុងសេចក្តីនេះ មានវាទៈរបស់ព្រះថេរៈដូចតទៅនេះថា

ព្រះចូឡនាគត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលមុនថា បុគ្គលផុតហើយ ដោយវិក្ខម្ភនវិមោក្ខដោយសមាបត្តិ និងផុតហើយដោយសមុច្ឆេទ-វិមោក្ខដោយមគ្គ ព្រោះហេតុនោះ ទើបហៅថា **ឧភតោភាគវិមុត្ត** ។

ព្រះមហាធម្មរក្ខិតត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា បុគ្គលនេះ អាស្រ័យនាម ហើយពោលថា

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ )
អណ្តាតភ្លើង ដែលត្រូវកម្លាំងខ្យល់បក់ រមែងរលត់ទៅ មិន
ដល់នូវការរាប់ ( ថាទៅក្នុងទីណាទេ ) យ៉ាងណាមិញ មុនី
រួចស្រឡះហើយ ចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវ
ការរាប់ ( ថាទៅក្នុងទីណា ) យ៉ាងនោះដែរ ដូច្នេះ ។

កាលនាំព្រះសូត្រនេះមកហើយ ទើបពោលថា ឈ្មោះថា ឧភតោភាគ-វិមុត្ត ព្រោះរួចផុតវិសេសហើយ ចាកនាមកាយ និងរូបកាយ ។

ឯព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា បុគ្គលដែលផុតវិសេសហើយ ដោយវិក្ខម្ភនវិមោក្ខសមាបត្តិអស់វារៈ ១ ផុតវិសេសហើយដោយសមុច្ឆេទវិមោក្ខដោយមគ្គអស់វារៈ ១ ទើបហៅថា ឧភតោភាគវិមុត្ត ។ ព្រះថេរៈទាំង ៣ រូបនេះ ជាបណ្ឌិត អាចារ្យទាំងឡាយ តាំងវាទៈរបស់ព្រះថេរៈទាំង ៣ ឲ្យជាបែបផែនថា ហេតុក្នុងវាទៈរបស់ព្រះថេរៈទាំង ៣ ប្រាកដ ។

កាលពោលដោយសង្ខេប បុគ្គលណាផុតវិសេសហើយ ចាករូបកាយដោយអរូបសមាបត្តិ ផុតវិសេសហើយ ចាកនាមកាយដោយមគ្គ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា ឧភតោភាគវិមុត្តបុគ្គល ព្រោះផុតវិសេសហើយចាកចំណែកទាំង ២ ។ បុគ្គលដែលឈ្មោះថា ឧភតោភាគវិមុត្តនោះមាន ៥ ពួក គឺបុគ្គលដែលចេញចាកអរូបសមាបត្តិ ៤ នីមួយៗ ហើយពិចារណាសង្ខារទាំងឡាយហើយ ទើបសម្រេចអរហត្ត ៤ ពួក និងព្រះអនាគាមី ដែលចេញចាកនិរោធសមាបត្តិហើយ សម្រេចអរហត្ត ១ ពួក ។ បណ្ដាព្រះអរិយៈទាំង ៥ នោះ ៤ ពួកដំបូង លោកមិនចូលនិរោធដែលមានសមាបត្តិជាប្រធាន ព្រោះហេតុនោះ ទើបឈ្មោះថា **ឧភតោភាគវិមុត្ត** ដោយអម ព្រះអនាគាមី ដែលបានសមាបត្តិ ៨ ចូលសមាបត្តិនោះហើយចេញអំពីសមាបត្តិនោះ ចម្រើនវិបស្សនាហើយសម្រេចអរហត្ត ព្រោះហេតុនោះ ទើបឈ្មោះថា **ឧភតោភាគវិមុត្តសេដ្ឋបុគ្គល** ដោយត្រង់ ។

សួរថា អរូបាវចរជ្ឈានក្តី រូបាវចរចតុត្ថជ្ឈានក្តី មានអង្គ ២ គឺឧបេក្ខា

និងចិត្តេកគ្គតា ព្រោះហេតុនោះ បុគ្គលធ្វើនូវរូបាវចរចតុត្ថជ្ឈាន ដែលមាន អង្គ ២ នោះឲ្យជាបទដ្ឋាន ហើយសម្រេចអរហត្ត ក៏គប្បីជាបុគ្គលឈ្មោះថា **ឧភតោភាគវិមុត្ត** មិនមែនឬ ឆ្លើយថា មិនមែនដូច្នោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលនោះ មិនទាន់ផុតចាករូបកាយ ដ្បិតថា រូបាវចរចតុត្ថជ្ឈាននោះផុតចាកកិលេសកាយប៉ុណ្ណោះ មិនបានផុតចាករូបកាយឡើយ ព្រោះហេតុនោះ បុគ្គលដែលចេញចាកសមាបត្តិនោះ ហើយសម្រេចអរហត្ត ទើបមិនឈ្មោះថា **ឧភតោភាគវិមុត្ត** ឯអរូបាវចរជ្ឈានផុតហើយចាកនាម-កាយផង ចាករូបកាយផង ព្រោះហេតុនោះ បុគ្គលធ្វើអរូបាវចរជ្ឈាននោះឲ្យជាបាទហើយ សម្រេចអរហត្ត គប្បីជ្រាបថា ឈ្មោះថា **ឧភតោភាគវិមុត្ត** ដូច្នេះ ។

[ ៤១ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបញ្ញាវិមុត្តបុគ្គល ដូចតទៅនេះ បុគ្គលណា រួចផុតវិសេសហើយដោយបញ្ញា ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា **បញ្ញាវិមុត្តោ ។** បញ្ញាវិមុត្តបុគ្គលនោះមាន ៥ ពួក គឺអរហន្ត-សុក្ខវិបស្សកៈ ១ បុគ្គលដែលចេញចាកឈានទាំង ៤ ហើយសម្រេចអរហត្ត ៤ ពួកទៀត ។ បណ្ដាព្រះអរហន្តទាំងនោះ មួយអង្គដែលបាន វិមោក្ខ ៨ មិនមាន ដោយហេតុនោះឯង ទើបលោកពោលពាក្យថា **ន ហេវ ខោ អដ្ឋ វិមោក្ខេ** ដូច្នេះជាដើម តែអរូបាវចរជ្ឈានទាំងឡាយ កាលមានត្រឹមតែឈាន ១ ក៏ឈ្មោះថា ឧភតោភាគវិមុត្តបុគ្គលបានដូចគ្នា ។

[ ៤២ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃកាយសក្ខីបុគ្គលដូចតទៅនេះ បទថា

**ឯកាវេ អាសវា** បានដល់ ដែលប្រហារដោយមគ្គ ៣ ខាងក្រោម ។ បទថា **អយំ វុច្ចតិ** បានដល់ បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា កាយសក្ខី ។ បុគ្គលនោះ ឈ្មោះថា កាយសក្ខី ព្រោះធ្វើឲ្យជាក់ច្បាស់នូវវិមោក្ខ ដែលខ្លួនពាល់ត្រូវហើយ ។ បុគ្គលណាពាល់ត្រូវផលដែលកើតអំពីឈានមុន ហើយធ្វើនិរោធ គឺនិព្វានឲ្យជាក់ច្បាស់ខាងក្រោយ បុគ្គលនេះ ក៏ឈ្មោះថា កាយ-សក្ខី ។ កាយសក្ខីបុគ្គលនេះ មាន ៦ ពួក រាប់តាំងអំពីបុគ្គលដែលតាំងនៅក្នុងសោតាបត្តិផលរហូតដល់បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ដូច្នេះ ។

[ ៤៣ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃទិដ្ឋិប្បត្តបុគ្គលដូចតទៅនេះ បទថា **ឥទំ ទុក្ខំ** បានដល់ ទុក្ខមានប្រមាណប៉ុណ្ណេះ មិនលើសអំពីនេះឡើយ ។ ក្នុងហេតុឲ្យកើតទុក្ខជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **យថាភូតំ បជានាតិ** សេចក្តីថា រមែងដឹងឧបាទានក្ខន្ធ ៥ វៀរតណ្ហាចេញដោយកិច្ចតាមសេចក្តីពិតថា ជាទុក្ខសច្ច តណ្ហារមែងញ៉ាំងទុក្ខឲ្យតាំងឡើង ឲ្យកើត ឲ្យកើតឡើងឲ្យចម្រើន ទុក្ខនេះ រមែងកើតអំពីតណ្ហានោះ ព្រោះហេតុនោះ រមែងដឹងច្បាស់នូវតណ្ហានោះ តាមសេចក្តីពិតថា នេះហេតុនាំឲ្យកើតទុក្ខ ព្រោះហេតុដែលទុក្ខនេះផង សមុទយៈនេះផង ដល់ព្រះនិព្វានហើយ រមែងរលត់ទៅ រមែងស្ងប់រម្ងាប់ គឺរមែងដល់ការមិនប្រព្រឹត្តទៅ ព្រោះហេតុនោះ រមែងដឹងច្បាស់នូវព្រះនិព្វាននោះ តាមសេចក្តីពិតថា នេះការរម្ងត់ទុក្ខ ។ មយ៉ាងទៀតអរិយមគ្គមានអង្គ ៨ ព្រោះអរិយមគ្គនោះ ទុក្ខនេះ រមែងដល់នូវការរលត់ទៅដោយមគ្គនោះ ដោយហេតុនោះ រមែងដឹងច្បាស់នូវមគ្គនោះ តាមសេចក្តី

ពិតថា នេះជាបដិបទាឲ្យដល់នូវការរម្ងត់ទុក្ខ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់សម្តែងការកំណត់សច្ចៈក្នុងខណៈផ្សេងៗ គ្នា ។ ឥឡូវនេះ ដើម្បីនឹងសម្តែងអរិយសច្ចទាំង ៤ ក្នុងខណៈតែមួយ ទើបទ្រង់ត្រាស់ពាក្យថា **តថាគតប្បវេទិតា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **តថាគតប្បវេទិតា** សេចក្តីថា សច្ចធម៌ទាំង ៤ ដែលព្រះតថាគតប្រថាប់គង់ត្រង់មហាពោធិមណ្ឌល ចាក់ធ្លុះហើយ គឺទ្រង់ដឹងហើយ បានដល់ ធ្វើឲ្យប្រាកដហើយ ។ បទថា **ធម្មា** បានដល់ ធម៌ គឺអរិយសច្ចទាំង ៤ ។ បទថា **ប៉ាទិដ្ឋា ហោន្តិ** បានដល់ ធម៌ដែលខ្ញុំនឃើញល្អហើយ ។ បទថា **ប៉ា ចរិតា** បានដល់ ប្រព្រឹត្តទៅដោយល្អ អធិប្បាយថា បុគ្គលនេះ ឲ្យបញ្ញាប្រព្រឹត្តទៅដោយល្អក្នុងធម៌ទាំងនោះ ។ បទថា **អយំ វុច្ចតិ** បានដល់ បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **ទិដ្ឋិប្បត្តោ** ។ បុគ្គលនេះ សម្រេចធម៌ដែលខ្ញុំនឃើញហើយ ព្រោះហេតុនោះទើបឈ្មោះថា ទិដ្ឋិប្បត្តៈ ។ ញាណ គឺបញ្ញាពិចារណាថា សង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ ដែលបុគ្គលនោះឃើញហើយ ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា ទិដ្ឋិប្បត្តៈ ។ ទិដ្ឋិប្បត្តបុគ្គលនេះក៏មាន ៦ ពួកដូចព្រះអរិយបុគ្គលដែលឈ្មោះថា កាយសក្ខីដែរ ។

[ ៤៤ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសទ្ធាវិមុត្តបុគ្គល ដូចតទៅនេះ បទថា **នោ ច ខោ យថា ទិដ្ឋិប្បត្តស្ស** អធិប្បាយថា អាសវៈទាំងឡាយ របស់

សទ្ធាវិមុត្តបុគ្គល ជាធម្មជាតអស់ទៅមិនបាន ដូចគ្នានឹងអាសវៈរបស់ទិដ្ឋិប្បត្តបុគ្គលដែរ ។

សួរថា ការផ្សេងគ្នាក្នុងការលះកិលេសនៃព្រះអរិយបុគ្គលទាំង ២ នោះមានឬ ឆ្លើយថា មិនមាន សួរថា កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបសទ្ធាវិមុត្តបុគ្គលមិនជាទិដ្ឋិប្បត្តបុគ្គល ឆ្លើយថា ព្រោះការផ្សេងគ្នានៃញាណដែលគប្បីសម្រេច ។ ឯទិដ្ឋិប្បត្តបុគ្គល ក្នុងកាលសម្រេច កាលសង្កត់កិលេស មិនលំបាកឡើយ អាចសង្កត់សង្កិនបានដោយសេចក្ដីលំបាកបន្តិចបន្តួច តែសទ្ធាវិមុត្តបុគ្គលជាអ្នកលំបាក ទើបអាចសង្កត់សង្កិនកិលេសទាំងឡាយបានដោយលំបាក ព្រោះហេតុនោះ ទើបលោកមិនជាទិដ្ឋិប្បត្តបុគ្គល ។

ម្យ៉ាងទៀត ការផ្សេងគ្នាដោយបញ្ញានៃបុគ្គលទាំង ២ ពួកនោះ ក៏មានដែរ ។ វិបស្សនាញាណនៃមគ្គ ៣ ខាងលើ របស់ទិដ្ឋិប្បត្តៈ ជាគុណជាតមុតស្រួច ក្លៀវក្លា ផូរផង់ ប្រព្រឹត្តទៅ វិបស្សនាញាណរបស់សទ្ធាវិមុត្តមិនមុតស្រួច មិនក្លៀវក្លា មិនផូរផង់ ប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបសទ្ធាវិមុត្តបុគ្គល មិនជាទិដ្ឋិប្បត្តបុគ្គល ។

ដូចបុរសកំលោះ ២ នាក់ កាលនឹងសម្ដែងសិប្បៈ បុរសម្នាក់មានដាវដ៏មុតក្នុងដៃ បុរសម្នាក់មានដាវរិលនៅក្នុងដៃ ដើមចេកកាលត្រូវកាត់ដោយដាវដ៏មុតរមែងមិនឮសំឡេង តែកាលត្រូវកាប់ដោយដាវរិលរមែងឮសំឡេងកដៈ កដៈ យ៉ាងណា ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបពាក្យឧបមេយ្យដូច្នេះថា ភាវៈដែលវិបស្សនាញាណនៃមគ្គ ៣ របស់ទិដ្ឋិប្បត្តបុគ្គល ជាគុណ-

ជាតមុតស្រួច និងផូរផង់វិសេសហើយ គប្បីជ្រាបដូចការកាប់ដើមចេក មិនឮសំឡេង ដោយដាវដ៏មុត និងភាពដែលវិបស្សនាញាណនៃមគ្គទាំង ៣ របស់សទ្ធាវិមុត្តបុគ្គល ជាគុណជាតមិនមុត មិនក្លៀវក្លា មិនផូរផង់វិសេស ហើយគប្បីជ្រាបដូចគ្នានឹងការយកដាវរិល កាប់ដើមចេក មានសំឡេងខ្លាំងកើតឡើងយ៉ាងនោះ ។ លោកអាចារ្យក៏ហាមន័យនេះថា មិនមែន ហើយធ្វើការសន្និដ្ឋានថា សទ្ធាវិមុត្តបុគ្គល មិនជាទិដ្ឋិប្បត្តបុគ្គល ព្រោះញាណដែលលោកគប្បីសម្រេចផ្សេងគ្នាដោយពិត ។

លោកក៏បានពោលក្នុងគម្ពីរអដ្ឋកថាទាំងឡាយ ដែលមកហើយថា

ពិតហើយ ក្នុងបុគ្គលទាំង ២ នោះ ការអស់កិលេសនៃសទ្ធាវិមុត្តបុគ្គល រមែងមានក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម ដូចបុគ្គលដែលកំពុងជឿ កំពុងឈមចុះ និងកំពុងបង្អោនចិត្តជឿ ។ ញាណជាគ្រឿងកាត់កិលេសក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម របស់ទិដ្ឋិប្បត្តបុគ្គល មិនយឺតយូរ ជារបស់មុតស្រួចប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបលោកឧបមាថា ប្រៀបដូចកាលបុគ្គលយកដាវដែលមិនមុត កាប់ដើមចេក ទីដែលត្រូវកាប់នោះមិនរលោង ដាវមិនឆ្លងទៅដោយរហ័ស ទើបធ្វើឲ្យឮសំឡេង គឺត្រូវប្រើសេចក្តីព្យាយាមខ្លាំង យ៉ាងណា មគ្គភាវនាដែលជាចំណែកខាងដើម របស់សទ្ធាវិមុត្តបុគ្គល គប្បីជ្រាបថា មានសភាពយ៉ាងនោះ ។ ញាណ គឺបញ្ញារបស់ទិដ្ឋិប្បត្តបុគ្គលនោះ ប្រៀបដូចកាលបុគ្គលយកដាវដ៏មុតកាប់ដើមចេក ទីដែលត្រូវកាប់ រមែងរលោង ដាវឆ្លងទៅរហ័ស មិនធ្វើឲ្យឮសំឡេង

បុគ្គលនោះ មិនចាំបាច់ប្រើនូវសេចក្តីព្យាយាមខ្លាំង យ៉ាងណា មគ្គភាវនា ដែលជាចំណែកខាងដើមរបស់ទិដ្ឋិប្បត្តបុគ្គល ក៏គប្បីជ្រាបថា មានសភាព យ៉ាងនោះ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **សទ្ធាវិមុត្តោ** ។ ពិតហើយ សទ្ធាវិមុត្តបុគ្គលនេះ កំពុងជឿ ឈ្មោះថា បានរួចផុតហើយ ព្រោះហេតុនោះ ទើបឈ្មោះថា សទ្ធាវិមុត្តៈ ។ សទ្ធាវិមុត្តបុគ្គលនេះ មាន ៦ ពួក ដូចកាយសក្ខីបុគ្គលដែរ ។

[ ៤៥ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃធម្មានុសារីបុគ្គល ដូចតទៅនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងព្រះអរិយបុគ្គល ដែលតាំងនៅក្នុងសោតាបត្តិមគ្គ ដោយបទនេះថា **បដិបន្នស្ស** ។ បទថា **អធិមត្តំ** បានដល់ មានកម្លាំង ។ អរិយមគ្គ ឈ្មោះថា **បញ្ញាវាហី** ព្រោះអត្ថថា ធ្វើបញ្ញាឲ្យនាំទៅ មានពាក្យ អធិប្បាយថា បញ្ញារមែងនាំបុគ្គលនេះទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **បញ្ញាវាហី** ដូច្នេះក៏មាន ។ បទថា **បញ្ញាបុព្វង្គមំ** បានដល់ ធ្វើនូវបញ្ញាឲ្យជាបុរេចារិក ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា ធម្មានុសារី ។ បុគ្គលនោះ ឈ្មោះថា ធម្មានុសារី ព្រោះរឭក គឺតាមរឭកដោយធម៌ ពោល គឺបញ្ញា ។ ពាក្យនេះ ជាឈ្មោះរបស់បុគ្គល ដែលតាំងនៅក្នុងសោតាបត្តិមគ្គ តែកាលលោកសម្រេចផល ឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល ។

[ ៤៦ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសទ្ធានុសារីបុគ្គល ដូចតទៅនេះ អរិយមគ្គ ឈ្មោះថា **សទ្ធាវាហី** ព្រោះអត្ថថា ធ្វើសទ្ធាឲ្យនាំទៅ មានពាក្យ

អធិប្បាយថា សទ្ធារមែងនាំបុគ្គលនេះទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **សទ្ធាវាហី** ដូច្នេះក៏មាន ។ បទថា **សទ្ធាបុព្វង្គមំ** បានដល់ ធ្វើសទ្ធាឲ្យជាបុរេចារិក ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ក៏ហៅថា **សទ្ធានុសារី** ។ បុគ្គលនោះ ឈ្មោះថា សទ្ធានុសារី ព្រោះរឭក គឺតាមរឭកដោយសទ្ធា ។ ពាក្យនេះ ជាឈ្មោះរបស់បុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គ ។ តែបើលោកសម្រេចផលហើយ ឈ្មោះថា ជាសទ្ធាវិមុត្តបុគ្គល ។ ឈ្មោះថា ធុរៈ ២ យ៉ាង ឈ្មោះថា អភិនិវេស ២ យ៉ាង និង ឈ្មោះថា សីសៈ ២ យ៉ាង នៃបុគ្គលដែលញ៉ាំងលោកុត្តរធម៌ ឲ្យកើតឡើង មាន ។

បណ្តាធុរៈជាដើមនោះ ឈ្មោះថា ធុរៈមាន ២ យ៉ាង គឺសទ្ធាធុរៈ ១ បញ្ញាធុរៈ ១ ។

ឈ្មោះថា អភិនិវេស គឺការអាស្រ័យមាន ២ យ៉ាង គឺភិក្ខុមួយរូប រមែងអាស្រ័យដោយអំណាចគ្រឿងអាស្រ័យ គឺសមថៈ មួយរូបទៀត រមែងអាស្រ័យដោយអំណាចគ្រឿងអាស្រ័យ គឺវិបស្សនា ។

ឈ្មោះថា សីសៈ គឺទីបំផុត ក៏មាន ២ យ៉ាង គឺភិក្ខុមួយរូប សម្រេចធម៌ដល់ទីបំផុត ជាឧភតោភាគវិមុត្ត ភិក្ខុមួយរូប កាលសម្រេចធម៌ដល់ទីបំផុត ជាបញ្ញាវិមុត្ត អធិប្បាយថា ភិក្ខុពួកណាមួយ ញ៉ាំងលោកុត្តរធម៌ឲ្យកើតឡើង លោកទាំងនោះរមែងធ្វើនូវធម៌ ២ យ៉ាងនេះ ( សទ្ធា និងបញ្ញា ) ឲ្យជាធុរៈ អាស្រ័យឋានៈទាំង ២ ( សមថាភិនិវេស និងវិបស្សនាភិនិវេស )

ហើយរមែងរួចផុតដោយសីសៈទាំង ២ នេះ ( ឧភតោភាគវិមុត្តសីសៈ និង បញ្ញាវិមុត្តសីសៈ ) ។

បណ្តាលោកទាំងនោះ ភិក្ខុរូបណាបានទូវសមាបត្តិ ៨ ធ្វើបញ្ញាឲ្យជាធុរៈ អាស្រ័យអំណាចសមថៈ ធ្វើអរូបសមាបត្តិណាមួយ ឲ្យជាបទដ្ឋាន ផ្តើមវិបស្សនា សម្រេចអរហត្ត ភិក្ខុរូបនោះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ធម្មានុសារី តែក្នុងឋានៈ ៦ ខាងមុខ ( តាំងអំពីសោតាបត្តិផលដល់អរហត្តមគ្គ ) ឈ្មោះថា កាយសក្ខី កាលសម្រេចអរហត្តផលហើយ ឈ្មោះថា ឧភតោភាគវិមុត្ត ។

ភិក្ខុមួយរូបទៀត ធ្វើបញ្ញាតែម្យ៉ាងប៉ុណ្ណោះឲ្យជាធុរៈ អាស្រ័យអំណាចវិបស្សនា ពិចារណាសង្ខារសុទ្ធៗ ឬរូបាវចរជ្ឈានណាមួយ សម្រេចអរហត្ត ភិក្ខុនេះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា ធម្មានុសារី តែក្នុងឋានៈ ៦ ខាងមុខ ( តាំងអំពីសោតាបត្តិផលដល់អរហត្តមគ្គ ) ឈ្មោះថា ទិដ្ឋិប្បត្តៈ លុះសម្រេចអរហត្តផលហើយ ឈ្មោះថា បញ្ញាវិមុត្ត ។ ក្នុងទីនេះ ឈ្មោះ ២ យ៉ាង ( បញ្ញាវិមុត្ត និងទិដ្ឋិប្បត្តៈ ) មិនធ្លាប់មាន និងរួមជាមួយឈ្មោះមុន ( ៣ ឈ្មោះទៀត គឺធម្មានុសារី កាយសក្ខី និងឧភតោភាគវិមុត្ត ) ទើបជា ៥ ។

ភិក្ខុមួយរូបទៀតបានសមាបត្តិ ៨ ធ្វើសទ្ធាឲ្យជាធុរៈ អាស្រ័យអំណាចសមាបត្តិ ធ្វើអរូបសមាបត្តិណាមួយឲ្យជាបទដ្ឋាន ផ្តើមវិបស្សនា សម្រេចអរហត្ត ភិក្ខុនេះក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា សទ្ធានុសារី តែក្នុង

ឋាន: ៦ ខាងមុខ ឈ្មោះថា កាយសក្ខីដូចគ្នា កាលសម្រេចអរហត្តផល ហើយឈ្មោះថា ឧភតោភាគវិមុត្តនោះឯង ។ ឈ្មោះមួយប៉ុណ្ណោះ ( សទ្ធានុសារី ) មិនធ្លាប់មានក្នុងសេចក្តីនេះ រួមជាមួយឈ្មោះ ៥ ខាងដើម ជា ៦ ។

ភិក្ខុមួយរូបទៀត ធ្វើសទ្ធានោះឯងឲ្យជាធុរៈ អាស្រ័យអំណាចវិបស្សនា ពិចារណាសង្ខារសុទ្ធៗ ឬរូបាវចរជ្ឈានណាមួយហើយសម្រេចអរហត្ត ភិក្ខុនេះ ក្នុងខណៈនៃសោតាបត្តិមគ្គ ឈ្មោះថា សទ្ធានុសារីក្នុងឋានៈ ៦ ខាងមុខ ឈ្មោះថា សទ្ធាវិមុត្ត កាលសម្រេចអរហត្តផលហើយ ឈ្មោះថា បញ្ញាវិមុត្ត ។ ឈ្មោះតែមួយប៉ុណ្ណោះ ( សទ្ធាវិមុត្ត ) មិនធ្លាប់មានក្នុងសេចក្តីនេះ រួមជាមួយឈ្មោះ ៦ ខាងដើមក៏ជា ៧ ។ ព្រះអរិយបុគ្គល ៧ ពួកនេះ ឈ្មោះថា ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរក្នុងលោក ។

[ ៤៧ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសត្តក្ខត្តុបរមបុគ្គល ដូចតទៅនេះ បទថា **សត្តក្ខត្តុំ** បានដល់ អស់វារៈ ៧ ដង ។ ការកើតឡើងក្នុងភព ពោលគឺការកាន់យកអត្តភាពមាន ៧ ជាតិយ៉ាងក្រៃលែងនៃបុគ្គលនោះមាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សត្តក្ខត្តុបរមោ** ព្រោះលោកមិនកាន់យកភពទី ៨ អំពីភពទី ៧ នោះឡើយ ។ អរិយមគ្គ ឈ្មោះថា **សោតោ** ក្នុងបទនេះថា **សោតាបន្នោ ហោតិ** បុគ្គលប្រកបដោយមគ្គដែលឈ្មោះថា សោតោនោះ ឈ្មោះថា សោតាបន្នបុគ្គល ដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យ ពោលទុកថា ព្រះមានព្រះភាគត្រាស់សួរ ( ក្នុងសំយុត្តនិកាយ

មហាវារវគ្គ ) ថា ម្នាលសារីបុត្ត ប្រពៃពេកណាស់ ម្នាលសារីបុត្ត មែនហើយ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសេចក្តីឃើញត្រូវ ១ ។បេ។ ការតម្កល់ចិត្តនឹងត្រូវ ១ ។

ម្នាលសារីបុត្ត គេតែងពោលថា បុគ្គលដល់នូវសោតៈៗ ដូច្នេះ ម្នាលសារីបុត្ត ចុះបុគ្គលដល់នូវសោតៈ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា ប្រកបដោយផ្លូវដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះ ហៅថា បុគ្គលដល់នូវសោតៈ លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ ដូច្នេះ ។

សូម្បីក្នុងខណៈនៃមគ្គ បុគ្គលឈ្មោះថា ព្រះសោតាបន្ន ដោយប្រការដូច្នេះឯង តែក្នុងទីនេះ ឈ្មោះរបស់ផលដែលមគ្គឲ្យហើយ ព្រោះហេតុនោះទើបព្រះសោតាបន្ន ទ្រង់បំណាងយកក្នុងខណៈនៃផល ។

បទថា **អវិនិបាតធម្មោ** បានដល់ ភាវៈគឺការមិនទៅកាន់អបាយ ពោលគឺវិនិបាតដោយអំណាចការចូលដល់ ។ បទថា **និយតោ** បានដល់ ជាអ្នកទៀងដោយនិយាមនៃមគ្គ ។ បទថា **សម្ពោធិបរាយណោ** បានដល់ មានការត្រាស់ដឹងជាទីទៅខាងមុខ ។ ពិតហើយ ព្រះសោតាបន្ននោះ រមែងត្រាស់ដឹងដោយមគ្គដែលខ្លួនបានចំពោះហើយ ព្រោះហេតុនោះ ទើបលោកឈ្មោះថា **សម្ពោធិបរាយណោ ។** ម្យ៉ាងទៀត ព្រះសោតាបន្ននោះ នឹងត្រាស់ដឹងដោយមគ្គខាងលើទាំង ៣ ដោយពិត ព្រោះហេតុនោះ ទើបលោកឈ្មោះថា

**សម្ពោធិបរាយណោ ។** បទថា **ទេវេ ច មនុស្សេ ច** បានដល់ ទៅកាន់ទេវលោក និងមនុស្សលោក ។ បទថា **សន្ធាវិត្វា សំសរិត្វា** បានដល់ ទៅមកៗ ដោយអំណាចបដិសន្ធិ ។ បទថា **ទុក្ខស្សន្តំ ករោតិ** បានដល់ ធ្វើទីបំផុត គឺទីបំផុតផ្លូវនៃវដ្តទុក្ខ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា សត្តក្ខត្តុបរមៈ ។ សត្តក្ខត្តុបរមបុគ្គលនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ដោយភពដែលលាយឡំគ្នា ដោយអំណាចនៃទេវលោក និងមនុស្សលោក តាមកាលដ៏សមគួរ ។

[ ៤៨ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃកោលំកោលបុគ្គលដូចតទៅនេះ បុគ្គលណា ទៅអំពីត្រកូលកាន់ត្រកូល ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **កោលំកោលោ** អធិប្បាយថា ឈ្មោះថា ការកើតក្នុងត្រកូលទាប តាំងអំពីការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលហើយ រមែងមិនមាន លោកតែងកើតក្នុងត្រកូលដែលមានភោគៈច្រើនតែម្យ៉ាងប៉ុណ្ណោះ ។

បទថា **ទ្វេ វា តីណិ វា កុលានិ** បានដល់ ទៅកាន់ភព ២ ឬភព ៣ ដោយអំណាចការកើតជាទេវតា និងមនុស្ស ។ កោលំកោលបុគ្គលនេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចមិស្សកភព គឺភពដែលលាយឡំគ្នានោះឯង ។ ក្នុងបទថា **ទ្វេ វា តីណិ វា** ត្រឹមតែជាទេសនាប៉ុណ្ណោះ ។ កោលំកោលបុគ្គលនោះឯង រមែងត្រាច់ទៅរហូតដល់ភពទី ៦ ក៏មាន ទើបធ្វើទីបំផុត គឺទីបំផុតផ្លូវនៃវដ្តទុក្ខបាន ។

[ ៤៩ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃឯកពីជីបុគ្គល ដូចតទៅនេះ ឈ្មោះថា

ពូជ គឺខន្ធដែលព្រះមានព្រះភាគត្រាស់ហើយ ។ ព្រះសោតាបន្នអង្គណា មាន ពូជ គឺខន្ធមួយប៉ុណ្ណោះ គឺមានការកាន់យកអត្តភាពមួយ ព្រះសោតាបន្ននោះ ឈ្មោះថា **ឯកពីជី** ។ បទថា **មានុសកំ ភវំ** នេះ ត្រឹមតែជាទេសនាក្នុង ទីនេះប៉ុណ្ណោះ តែនឹងពោលថា ញុំាងទេវភពឲ្យកើតដូច្នេះ ក៏សមគួរដូចគ្នា ។ ឈ្មោះទាំងនេះ ជាឈ្មោះនៃព្រះអរិយបុគ្គលទាំងនោះ ដោយអំណាចនៃឈ្មោះ ដែលព្រះមានព្រះភាគទ្រង់ប្រារព្ធហើយនោះឯង ។ ពិតហើយ ព្រះសោតា-បន្នដែលទៅដល់ទីមានប្រមាណប៉ុណ្ណោះ ឈ្មោះថា **សត្តក្ខត្តុបរមបុគ្គល** ដែលទៅដល់ឋានៈ មានប្រមាណប៉ុណ្ណោះ ឈ្មោះថា **កោលំកោលបុគ្គល** ដែលទៅដល់ឋានៈ មានប្រមាណប៉ុណ្ណោះ ឈ្មោះថា **ឯកពីជីបុគ្គល** ព្រោះ ហេតុនោះ ឈ្មោះព្រះសោតាបន្នទាំងនោះ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធ ហើយ ។ ពោលដោយកំណត់ពិតប្រាកដ ពាក្យថា ព្រះសោតាបន្នរូបនេះ ជាសត្តក្ខត្តុបរមៈ រូបនេះជាកោលំកោលៈ រូបនេះជាឯកពីជី រមែងមិនមាន ។

សួរថា បុគ្គលណាមួយ កំណត់ប្រភេទព្រះអរិយបុគ្គលទាំងនោះបាន ។ ឆ្លើយថា ព្រះថេរៈពួកខ្លះ ពោលមុនថា បុព្វហេតុ រមែងកំណត់ ព្រះថេរៈ ពួកខ្លះពោលថា មគ្គទី ១ រមែងកំណត់ ព្រះថេរៈពួកខ្លះពោលថា មគ្គខាង លើ ៣ រមែងកំណត់ ព្រះថេរៈពួកខ្លះ ពោលថា វិបស្សនានៃមគ្គទាំង ៣ រមែងកំណត់ ។

បណ្តាវាទៈនៃព្រះថេរៈទាំងនោះ វាទៈថា បុព្វហេតុរមែងកំណត់ សេចក្តី ថា ឧបនិស្ស័យនៃបឋមមគ្គ ជាគុណជាតដែលបុព្វហេតុធ្វើហើយ មគ្គខាង

លើ ៣ ប្រាសចាកឧបនិស្ស័យកើតឡើង ។ ក្នុងពាក្យថា មគ្គទី ១ រមែង កំណត់ សេចក្តីថា មគ្គ ៣ ជាធម្មជាតឥតប្រយោជន៍ ។ ក្នុងពាក្យថា មគ្គខាងលើ ៣ រមែងកំណត់ សេចក្តីថា កាលបឋមមគ្គមិនទាន់កើតឡើងនោះឯង មគ្គខាងលើ ៣ កើតឡើងហើយ ។ ពាក្យថា វិបស្សនានៃមគ្គទាំង ៣ កំណត់ រមែងត្រឹមត្រូវ ។ បើវិបស្សនានៃមគ្គទាំង ៣ មានកម្លាំង ព្រះសោតាបន្ន ក៏ឈ្មោះថា **ឯកពីជី** បើខ្សោយជាងវិបស្សនារបស់ឯកពីជី ក៏ឈ្មោះថា **កោលំកោល** បើទន់ជាងវិបស្សនានៃកោលំកោលៈនោះ ក៏ឈ្មោះថា **សត្តក្ខត្តុបរម** ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះសោតាបន្នអង្គខ្លះ មានអធ្យាស្រ័យក្នុងវដ្តៈ ជាអ្នកត្រេកអរក្នុងវដ្តៈ រមែងត្រាច់ទៅ ប្រាកដទៅក្នុងវដ្តៈរឿយៗ ដូចគ្នា ។ ជនទាំងនេះ មានប្រមាណប៉ុណ្ណេះ គឺអនាថបិណ្ឌិកសេដ្ឋី ១ វិសាខាឧបាសិកា ១ ចូឡរថទេវបុត្ត ១ មហារថទេវបុត្ត ១ អនេកវណ្ណទេវបុត្ត ១ សក្កទេវរាជ ១ នាគទត្តទេវបុត្ត ១ ជនទាំងនេះ មានអធ្យាស្រ័យក្នុងវដ្តៈ ជាអ្នកត្រេកអរក្នុងវដ្តៈ កើតក្នុងទេវលោក ៦ ជាន់ តាំងអំពីដើម ជម្រះចិត្តឲ្យស្អាតក្នុងទេវលោកនោះឯង ហើយទើបតាំងនៅក្នុងអកនិដ្ឋភព ទើបបរិនិព្វាន ។ មិនមែនត្រឹមតែជនទាំងនេះប៉ុណ្ណោះទេ ព្រះសោតាបន្នអង្គណាអន្ទោលទៅហើយក្នុងមនុស្សលោកនោះឯង អស់ ៧ ដង ហើយទើបសម្រេចអរហត្តក្តី ព្រះសោតាបន្នអង្គណា កើតក្នុងទេវលោកទាំងឡាយ អន្ទោលទៅមកក្នុងទេវ-លោកនោះឯង អស់ ៧ ដង ហើយសម្រេចជាអរហត្តក្តី ព្រះសោតាបន្ន

ទាំងនោះ ព្រះមានព្រះភាគទ្រង់មិនបានកាន់យកក្នុងទីនេះ ។

តែគប្បីជ្រាបថា ក្នុងទីនេះ ទ្រង់កាន់យកព្រះសោតាបន្នដែលឈ្មោះថា សត្តក្ខត្តុបរមៈ និងកោលំកោលៈ ដោយអំណាចនៃភពដែលលាយឡំគ្នា និងព្រះសោតាបន្នដែលឈ្មោះថាឯកពីជី ដែលកើតក្នុងភពរបស់មនុស្សប៉ុណ្ណោះ ។ ក្នុងព្រះសោតាបន្នទាំងនោះ មួយអង្គៗ រមែងដល់នូវភាវៈ ៤ យ៉ាង ដោយអំណាចនៃទុក្ខាបដិបទាជាដើម ។ ពោលដោយសទ្ធាធុរៈ ព្រះសោតាបន្នមាន ១២ ពួក គឺសត្តក្ខត្តុបរមៈ ៤ ពួក កោលំកោលៈ ៤ ពួក ឯកពីជី ៤ ពួក ។ បុគ្គលធ្វើបញ្ញាឲ្យជាធុរៈ ដោយគិតយ៉ាងនេះថា បើបុគ្គលណាមួយ អាចធ្វើលោកុត្តរធម៌ឲ្យកើតបានដោយបញ្ញា អញក៏នឹងធ្វើលោកុត្តរធម៌ឲ្យកើតឡើងបាន ហើយសម្រេចជាព្រះសោតាបន្ន សត្តក្ខត្តុបរមៈជាដើម ក៏មាន ១២ ពួកដូចគ្នានោះឯង ដោយអំណាចបដិបទា ៤ ព្រោះហេតុនោះ ព្រះសោតាបន្នទាំង ២៤ ពួកនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ហើយ ក្នុងឋានៈនេះ ដោយអំណាចនៃព្រះអរិយៈដែលតាំងនៅក្នុងលោកនេះ និងអ្នកបានឈាន ( ខាងក្រោមៗ ) នោះឯង ។

[ ៥០ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃសកទាគាមិបុគ្គលដូចតទៅនេះ បុគ្គលណាមកម្ដងទៀត ដោយអំណាចនៃបដិសន្ធិ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សកទាគាមី** ។

បទថា **សកិំទេវ** បានដល់ ម្ដងប៉ុណ្ណោះ ។

បណ្ដាព្រះសកទាគាមី ៥ ពួក ទ្រង់វៀរ ៤ ពួក តែទ្រង់បំណងយក

ត្រឹមតែ ១ ពួកប៉ុណ្ណោះដោយបទថា **ឥធំ លោកំ អាគន្ត្វា ។** ពិតហើយ ព្រះសកទាគាមីពួកខ្លះ សម្រេចសកទាគាមិផល ក្នុងលោកនេះ ក៏បរិនិព្វាន ក្នុងលោកនេះឯង ពួកខ្លះសម្រេចក្នុងលោកនេះ ទៅបរិនិព្វានក្នុងទេវលោក ពួកខ្លះ សម្រេចក្នុងទេវលោក ក៏បរិនិព្វាន ក្នុងទេវលោកនោះឯង ពួកខ្លះ សម្រេចក្នុងទេវលោកហើយ កើតឡើងក្នុងលោកនេះហើយ ទើបបរិនិព្វាន រួមព្រះសកទាគាមីទាំង ៤ ពួកដូចពោលមកនេះ ទ្រង់មិនបំណងយក ក្នុងសកទាគាមីនិទ្ទេសនេះ តែព្រះសកទាគាមីពួកណា សម្រេចក្នុងលោកនេះ ហើយតម្កល់ជីវិតក្នុងទេវលោក ដរាបដល់អស់អាយុហើយ កើតឡើងក្នុងលោកនេះវិញ ទើបបរិនិព្វាន ព្រះសកទាគាមីពួកមួយនេះប៉ុណ្ណោះ គប្បីជ្រាបថា ទ្រង់កាន់យកក្នុងសកទាគាមីនិទ្ទេសនេះ ។

ពាក្យណានៅសល់ក្នុងទីនេះ ដែលខ្ញុំគប្បីពោល ពាក្យទាំងអស់នោះ ខ្ញុំធ្លាប់ពោលហើយ ក្នុងលោកុត្តរកុសលនិទ្ទេស ក្នុងអដ្ឋកថានៃធម្មសង្គណី ។ សួរថា ព្រះសកទាគាមីនេះ មានការផ្សេងគ្នាជាមួយព្រះសោតាបន្ន ដែលឈ្មោះថា ឯកពីជីដូចម្តេច ឆ្លើយថា ព្រះសោតាបន្នដែលឈ្មោះថា ឯកពីជីលោកមានបដិសន្ធិមួងប៉ុណ្ណោះ ឯព្រះសកទាគាមី មានបដិសន្ធិ ២ ដង សេចក្តីនេះជាការផ្សេងគ្នារវាងព្រះអរិយៈទាំងពីរនោះ ។

[ ៥១ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអនាគាមិបុគ្គល ដូចតទៅនេះ ក្នុងបទថា **ឱរម្ភាគិយានំ សំយោជនានំ** កាមធាតុ ព្រះមានព្រះភាគត្រាស់ហៅថា **ឱរំ ។** ចំណងទាំង ៥ នេះ ដែលបុគ្គលណាមិនទាន់លះបាន បុគ្គលនោះ

សូម្បីកើតក្នុងភវគ្គភូមិ ក៏គង់ត្រូវចំណងទាំងនោះទាញឲ្យធ្លាក់ទៅក្នុងកាមធាតុនោះឯង ដូចត្រីដែលជាប់សន្ទូច និងដូចសត្វក្អែកទឹក ដែលគេយកខ្សែវែងចងត្រង់ជើង ព្រោះហេតុនោះ ទើបចំណងទាំង ៥ ហៅថា **ឱរម្ភាគិយ** អធិប្បាយថា ឱរម្ភាគិយៈនេះជារបស់ខាងក្រោម គឺជាចំណែកខាងក្រោម ។

បទថា **បរិក្ខយា** បានដល់ ព្រោះការអស់ទៅនៃចំណងទាំងនោះ ។ បទថា **ឱបបាតិកោ** បានដល់ ដែលមានកំណើតផុសឡើង ការដេកក្នុងផ្ទៃរបស់ព្រះអនាគាមីនោះ លោកឃាត់ហើយដោយបទថា **ឱបបាតិកោ** នេះ ។

បទថា **តត្ថ បរិនិព្វាយិ** បានដល់ បរិនិព្វានក្នុងសុទ្ធាវាសទេវលោកនោះ ។

បទថា **អនាវត្តិធម្មោ តស្មា លោកា** សេចក្តីថា មានសភាពមិនមកអំពីព្រហ្មលោក កាន់កាមលោកនេះ ដោយអំណាចបដិសន្ធិ ។ ឯការមកនៃព្រះអនាគាមីនោះ ដើម្បីជាប្រយោជន៍ដល់ការចូលគាល់ព្រះពុទ្ធ ចូលរកព្រះថេរៈ និងស្តាប់ព្រះសទ្ធម្ម មិនបានហាម ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលមានសភាវៈយ៉ាងនេះ លោកហៅថា ព្រះអនាគាមី ព្រោះមិនត្រឡប់មកទៀត ដោយអំណាចបដិសន្ធិ ។

[ ៥២ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអន្តរាបរិនិព្វាយិបុគ្គល ដូចតទៅនេះ បទថា **ឧបបន្នំ វា សមនន្តរា** សេចក្តីថា ជាកាលជាប់តគ្នាជាមួយនឹងការកើតឡើងខ្វះ ។ បទថា **អប្បត្តំ វា វេមជ្ឈំ អាយុប្បមាណំ** សេចក្តីថា

មិនដល់ប្រមាណពាក់កណ្តាលអាយុខ្ញុះ ក៏ញ៉ាំងអរិយមគ្គឲ្យកើតឡើងហើយ ។ អត្ថថា ពាក់កណ្តាល ក៏គប្បីជ្រាបដោយការកំណត់ដោយ **វា** សព្ទ ។ ព្រះអនាគាមីដែលជាអន្តរាបរិនិព្វាយី ៣ ពួក ជាការប្រោរព្ធហើយ ដោយប្រការដូច្នេះ ។ បទថា **ឧបរិដ្ឋិមានំ សំយោជនានំ** បានដល់ ឧទ្ធម្ភាគិយសំយោជនៈ ៥ ខាងលើ ឬបានដល់ កិលេស ៨ ។ បទថា **បហានាយ** បានដល់ ញ៉ាំងមគ្គឲ្យកើតឡើង ដើម្បីប្រយោជន៍ដល់ការលះសំយោជនៈទាំងនោះ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អន្តរាបរិនិព្វាយី** ព្រោះបរិនិព្វាន ក្នុងចន្លោះពាក់កណ្តាលនៃអាយុនោះឯង ។

[ ៥៣ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃឧបហច្ចបរិនិព្វាយិបុគ្គល ដូចតទៅនេះ បទថា **អតិក្កមិត្វា វេមជ្ឈំ អាយុប្បមាណំ** បានដល់ កន្លងហួសពាក់កណ្តាលប្រមាណនៃអាយុ ។ បទថា **ឧបហច្ច វា កាលកិរិយំ** បានដល់ កៀកនឹងធ្វើកាលកិរិយា អធិប្បាយថា ជិតនឹងអស់អាយុហើយ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **ឧបហច្ចបរិនិព្វាយី** ព្រោះឈានកន្លងពាក់កណ្តាល គឺ ៥០០ មហាកប្បនៃអាយុដែលមាន ១០០០ មហាកប្បជាប្រមាណក្នុងអវិហាភូមិទាំងឡាយមុន ហើយទើបតាំងនៅក្នុងកប្បទី ៦០០ ឬទី ៧០០ ឬទី ៨០០ ឬទី ៩០០ ឬទី ១០០០ មហាកប្បណាមួយនោះឯង ហើយទើបសម្រេចអរហត្ត ហើយបរិនិព្វានដោយកិលេសបរិនិព្វាន ។

[ ៥៤-៥៥ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃអសង្ខារបរិនិព្វាយី និងសសង្ខារ-បរិនិព្វាយិបុគ្គលដូចតទៅនេះ ព្រះអនាគាមីរូបណា មិនចាំបាច់ធ្វើសេចក្តីព្យាយាមខ្លាំងក្លា ដោយមិនចាំបាច់មានការដឹកនាំ លំបាកបន្តិចបន្តួចក៏បរិនិព្វានដោយកិលេសបរិនិព្វានជាធម្មតា ព្រោះហេតុនោះ ទើបព្រះអនាគាមីរូបនោះឈ្មោះថា **អសង្ខារបរិនិព្វាយី** ។ ឯបុគ្គលរូបណា ធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ដោយមានការដឹកនាំ មានសេចក្តីលំបាក ទើបបរិនិព្វានដោយកិលេសបរិនិព្វានជាធម្មតា ព្រោះហេតុនោះ ទើបព្រះអនាគាមីរូបនោះ ហៅថា **សសង្ខារបរិនិព្វាយី** ។

[ ៥៦ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃឧទ្ធំសោតោបុគ្គល ដូចតទៅនេះ ក្រសែ គឺតណ្ហា ឬក្រសែ គឺវដ្តៈរបស់ព្រះអនាគាមីនោះមានខាងលើ ព្រោះជាធម្មជាតនាំទៅខាងលើ ព្រោះហេតុនោះ ទើបឈ្មោះថា **ឧទ្ធំសោតោ** ។ម្យ៉ាងទៀត ក្រសែ គឺមគ្គរបស់ព្រះអនាគាមីនោះ មានខាងលើ ព្រោះលោកទៅកាន់ភពខាងលើហើយទើបបាន ព្រោះហេតុនោះ ទើបឈ្មោះថា **ឧទ្ធំសោតោ** ។ បទថា **អកនិដ្ឋគាមី** បានដល់ អ្នកមានប្រក្រតីទៅកាន់អកនិដ្ឋភព ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **អវិហា ចុតោ អតប្បំ គច្ឆតិ** ជាដើម ដូចទៅនេះ អធិប្បាយថា ព្រះអនាគាមីកាលនៅក្នុងអវិហាភូមិអស់ ១០០០ មហាកប្ប មិនអាចសម្រេចអរហត្ត ទើបទៅកាន់អតប្បាភូមិ ។ កាលលោកនៅក្នុងអតប្បាភូមិអស់ ២០០០ មហាកប្ប មិនអាចសម្រេចអរហត្ត ទើបទៅកាន់សុទស្សាភូមិ ។ កាលលោកនៅក្នុងសុទស្សាភូមិ អស់ ៤០០០

មហាកប្ប មិនអាចសម្រេចអរហត្ត ទើបទៅកាន់សុទស្សីភូមិ ។ កាលលោកនៅក្នុងសុទស្សីភូមិអស់ ៨០០០ មហាកប្ប មិនអាចសម្រេចអរហត្ត ទើបទៅកាន់អកនិដ្ឋភូមិ ។ កាលលោកនៅក្នុងអកនិដ្ឋភូមិនោះ រមែងឲ្យអរិយមគ្គកើតឡើងបាន ។

ម្យ៉ាងទៀត ដើម្បីជ្រាបប្រភេទរបស់ព្រះអនាគាមីទាំងនេះ អ្នកសិក្សាគប្បីជ្រាបពួក ៤ នៃឧទ្ធំសោតោអកនិដ្ឋគាមីដូចតទៅ

បណ្តាព្រះអនាគាមីទាំងនោះ អង្គណាជម្រះទេវលោកទាំង ៤ ឲ្យស្អាតតាំងអំពីអវិហាភូមិ ហើយទៅកាន់អកនិដ្ឋភូមិ ទើបបរិនិព្វាន អង្គនេះឈ្មោះថា ឧទ្ធំសោតោអកនិដ្ឋគាមី ។

អង្គណាជម្រះទេវលោកទាំង ៣ ខាងក្រោមឲ្យស្អាត ហើយតាំងនៅក្នុងសុទស្សីទេវលោកទើបបរិនិព្វាន អង្គនេះឈ្មោះថា ឧទ្ធំសោតោនអកនិដ្ឋគាមី ។

អង្គណាទៅកាន់អកនិដ្ឋភូមិនោះឯង អំពីសុទស្សីទេវលោកនេះ ហើយទើបបរិនិព្វាន អង្គនេះឈ្មោះថា នឧទ្ធំសោតោអកនិដ្ឋគាមី ។

អង្គណាតាំងនៅក្នុងទេវលោកទាំង ៤ ខាងក្រោម រមែងបរិនិព្វានក្នុងទីនោះៗ អង្គនេះឈ្មោះថា នឧទ្ធំសោតោនអកនិដ្ឋគាមី ព្រោះហេតុនោះ កាលរួមព្រះអនាគាមីទាំងនេះ ក៏បាន ៤៨ ពួក ដោយប្រការដូច្នេះ ។

សួរថា ព្រះអនាគាមីមាន ៤៨ ពួក ដូចម្តេច ឆ្លើយថា ក្នុងអវិហាភូមិ ព្រះអនាគាមីដែលជាអន្តរាបរិនិព្វាយី ៣ ពួក ដែលជាឧបហច្ចបរិនិព្វាយី ១ ពួក ដែលជាឧទ្ធំសោតោ ១ ពួក ព្រះអនាគាមីទាំងនេះ រួមជា ១០ ពួក

គឺជាអសង្ខារបរិនិព្វាយី ៥ ពួក សសង្ខារបរិនិព្វាយី ៥ ពួក ក្នុងអតប្បា សុទស្សា និងសុទស្សីភូមិក៏ដូចគ្នា គឺមាន ៤ ភូមិ ១ ភូមិ ១០ ពួក រួមជា ៤០ ពួក តែព្រះអនាគាមី ដែលឈ្មោះថា **ឧទ្ធំសោតោ** មិនមានក្នុងជាន់ អកនិដ្ឋភូមិ មានតែព្រះអនាគាមីដែលឈ្មោះថា អន្តរាបរិនិព្វាយី ៣ ពួក ឧបហច្ចបរិនិព្វាយី ១ ពួក ព្រះអនាគាមីទាំងនោះជា ៨ ពួក គឺជាអសង្ខារ-បរិនិព្វាយី ៤ ពួក សសង្ខារបរិនិព្វាយី ៤ ពួក ទើបរួមជាព្រះអនាគាមី ៤៨ ពួក ដោយប្រការដូច្នេះ ។ ព្រះអនាគាមីទាំងពួងនោះ ដែលបណ្ឌិតសម្តែងប្រៀបធៀបហើយ ដូចផ្កាភ្លើងដែលកើតអំពីដែក ដូចឧទាហរណ៍តទៅនេះថា

ដូចជាងដែក ដំនូវចុងដែកស្រួចរបស់កាំបិតបត់ និងកាំបិតកាត់ក្រចក ដែលក្តៅអស់ពេញមួយថ្ងៃ ត្រង់កំណាល់ដែក ផ្កាភ្លើងកើតឡើង ហើយក៏រលត់ទៅ គប្បីជ្រាបថា អន្តរាបរិនិព្វាយីពួកទី ១ ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះកិលេសរលត់ទៅមិនមានសេសសល់ក្នុងលំដាប់ដែលកើតឡើងនោះឯង ។

កាលជាងដែកវាយនូវចុងដែកស្រួចជាដើមដែលក្តៅពេញមួយថ្ងៃ ដែលធំជាងនោះ ត្រង់កំណាល់ដែក ផ្កាភ្លើងក៏ខ្ទាតទៅកាន់អាកាសហើយរលត់ទៅ គប្បីជ្រាបថា អន្តរាបរិនិព្វាយីពួកទី ២ ក៏យ៉ាងនោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកមានអាយុមិនដល់ពាក់កណ្តាល ក៏បរិនិព្វាន ។

កាលជាងដែកវាយចុងដែកស្រួចជាដើម ដែលក្តៅពេញមួយថ្ងៃ ដែលធំ

ជាងនោះ ត្រង់កំណល់ដែក ផ្កាភ្លើងខ្ទាតទៅកាន់អាកាស ហើយធ្លាក់ចុះមកកាន់ផែនដី តែមិនទាន់ដល់ដីក៏រលត់ទៅ គប្បីជ្រាបថា អន្តរាបរិនិព្វាយី ពួកទី ៣ ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះដល់ពាក់កណ្តាលនៃអាយុហើយ មិនទាន់ជិតធ្វើកាលកិរិយា ក៏បរិនិព្វាន ។

កាលជាងដែកវាយចុងដែកស្រួចជាដើម ដែលក្តៅពេញមួយថ្ងៃ ដែលធំជាងនោះ ត្រង់កំណល់ដែក ផ្កាភ្លើងខ្ទាតទៅកាន់អាកាស ធ្លាក់ដល់ផែនដី ប៉ះផែនដីហើយក៏រលត់ទៅ គប្បីជ្រាបថា ឧបហច្ចបរិនិព្វាយី ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះចូលជិតការធ្វើកាលកិរិយា ហើយបានញុំាងការប្រព្រឹត្តទៅនៃអាយុ ឲ្យអស់ទៅហើយ ទើបបរិនិព្វាន ។

កាលជាងដែកវាយនូវចុងដែកស្រួចជាដើម ដែលក្តៅអស់មួយថ្ងៃ ដែលធំជាងនោះ ត្រង់កំណល់ដែក ផ្កាភ្លើងក៏ខ្ទាតទៅត្រង់ស្មៅ ឬត្រង់កម្ទេចឈើ ហើយក៏ឆេះស្មៅ ឬកម្ទេចឈើ ហើយរលត់ទៅ គប្បីជ្រាបថា អសង្ខារបរិនិព្វាយី ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបរិនិព្វាន ដោយការប្រកបសេចក្តីព្យាយាម មានប្រមាណតិចតួច គឺដោយការប្រព្រឹត្តទៅយ៉ាងសប្បាយ ។

កាលជាងដែកវាយនូវដែកស្រួចជាដើម ដែលក្តៅអស់មួយថ្ងៃ ដែលធំជាងនោះត្រង់កំណល់ដែក ផ្កាភ្លើងក៏ខ្ទាតទៅត្រង់គុម្ពស្មៅ ឬគំនរឈើធំ ហើយឆេះគុម្ពស្មៅ ឬគំនរឈើធំអស់ហើយក៏រលត់ទៅ គប្បីជ្រាបថា សសង្ខារ-

បរិនិព្វាយី ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបរិនិព្វានហើយដោយការធ្វើសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា គឺប្រព្រឹត្តទៅយ៉ាងធ្ងន់ ។

ផ្កាភ្លើងដទៃទៀត រមែងធ្លាក់ទៅលើគំនរស្មៅ និងគំនរឈើធំនោះ កាលគំនរស្មៅ និងគំនរឈើធំនោះ ត្រូវភ្លើងឆេះក្នុងទីនោះ រងើកភ្លើងដែលប្រាសចាកអណ្តាតក្តី អណ្តាតភ្លើងក្តី កើតឡើងហើយ ឆេះរោងរបស់ជាងដែកហើយក៏រាលទៅឆេះភូមិ ឆេះស្រុក ឆេះនគរ ឆេះដែនរហូតដល់សមុទ្ទ ទើបរលត់ទៅ គប្បីជ្រាបថា ឧទ្ធំសោតោអកនិដ្ឋគាមី ក៏មានលក្ខណៈយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកធ្វើការពង្រីកពូជក្នុងភពជាអនេកហើយទើបធ្វើឲ្យអស់ ដោយការសម្រេចធម៌ដែលពាល់ត្រូវ ហើយទើបបរិ-និព្វាន ។ បទ្ទះដែកនោះឯង តូចខ្លះ ធំខ្លះ មានចុងស្រួចជាដើម ព្រោះហេតុនោះ ទើបលោកពោលក្នុងព្រះសូត្រ នៅក្នុងវារៈទាំងអស់ថា **អយោ-កបាលំ** ដូច្នេះជាដើម ។

ដូចពាក្យដែលទ្រង់ត្រាស់ ( ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបានឧបេក្ខាថា បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអត្តភាពនេះ ) មិនធ្លាប់មានទេ អត្តភាពរបស់អញ ក៏មិនមាន ( ក្នុងកាលឥឡូវនេះដែរ ) បើកម្ម ( ដែលញ៉ាំងសត្វឲ្យកើតក្នុងអនាគត ) របស់អញមិនមាន ( ក្នុងកាលឥឡូវនេះ ) ទេ អត្តភាពរបស់អញ ( ក្នុងអនាគត ) ក៏មិនមានដែរ ខន្ធ-

បញ្ចកៈណាដែលកើតមាន អញលះបង់នូវខន្ធបញ្ចកៈនោះចេញ ។ ភិក្ខុនោះមិនត្រេកអរក្នុងភព មិនជាប់ជំពាក់ក្នុងសម្ភវៈ រមែងឃើញនូវព្រះនិព្វាន ជាចំណែកដ៏ស្ងប់ក្រៃលែងដោយបញ្ញាដ៏ប្រពៃ តែព្រះនិព្វាននោះ ភិក្ខុនោះមិនទាន់បានធ្វើឲ្យជាក់ច្បាស់ដោយសព្វគ្រប់នៅឡើយ ភិក្ខុនោះ មិនទាន់លះបង់មានានុស័យដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់ភវរាគានុស័យដោយសព្វគ្រប់នៅឡើយ មិនទាន់លះបង់អវិជ្ជានុស័យដោយសព្វគ្រប់នៅឡើយ ។ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាតឡើង ហើយរលត់ទៅវិញយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ រមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាពកន្លងមកហើយ ) មិនធ្លាប់មានទេ ។បេ។ ភិក្ខុនោះឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះរមែងបាននូវឧបេក្ខាថា បើកម្ម ( ដែលញុំាងសត្វឲ្យកើតក្នុងអត្តភាពនេះ ) មិនធ្លាប់មានទេ ។បេ។ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាតអណ្តែតឡើង ហើយរលត់បាត់ទៅវិញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះ

ថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមរផ្កាភ្លើងខ្ទាតអណ្តែតឡើងទៅទល់ផ្ទៃ ( ខាងលើ ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមរផ្កាភ្លើងខ្ទាតអណ្តែតឡើង ទៅទល់ផ្ទៃ ( ខាងលើ ) ហើយរលត់បាត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧបហច្ចបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអម្បែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមរផ្កាភ្លើងខ្ទាតអណ្តែតឡើង ហើយធ្លាក់ទៅលើ

គំនរស្មៅ ឬគំនរឧស ដែលមានប្រមាណតិច ផ្កាភ្លើងនោះ គប្បីញ៉ាំងភ្លើងក្នុងគំនរទាំងនោះឲ្យកើតឡើងផង ញ៉ាំងផ្សែងឲ្យកើតឡើងផង លុះញ៉ាំងភ្លើងឲ្យកើត ញ៉ាំងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧសមានប្រមាណតិចនោះឯង ឲ្យទៅជារបស់ខ្ទេចខ្ទី ហើយរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា អសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអំបែងដែកដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលដំ ក្រមរផ្កាភ្លើងខ្ទាតអណ្តែតឡើងទៅ ហើយធ្លាក់ចុះលើគំនរស្មៅ ឬគំនរឧសដ៏ធំ ផ្កាភ្លើងនោះ គប្បីញ៉ាំងភ្លើងក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញ៉ាំងផ្សែងឲ្យកើតឡើងផង លុះញ៉ាំងភ្លើងឲ្យកើត ញ៉ាំងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧសដ៏ធំនោះឯង ឲ្យទៅជារបស់ខ្ទេចខ្ទី ហើយរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា សសង្ខារបរិនិព្វាយី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះឈ្មោះថា ឧទ្ធំសោត-អកនិដ្ឋគាមី ព្រោះអស់ទៅនៃសញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ម្នាល

ភិក្ខុ ប្រៀបដូចអំបែងដែក ដែលក្តៅអស់មួយថ្ងៃ កាលបុគ្គលជំ ក្រមរផ្កា ភ្លើង ខ្ទាតអណ្តែតឡើង ហើយធ្លាក់ចុះលើគំនរស្មៅ ឬគំនរឧសច្រើន ផ្កាភ្លើងនោះ គប្បីញ៉ាំងភ្លើងក្នុងគំនរទាំងនោះ ឲ្យកើតឡើងផង ញ៉ាំងផ្សែងឲ្យកើតឡើងផង លុះញ៉ាំងភ្លើងឲ្យកើតឡើង ញ៉ាំងផ្សែងឲ្យកើតឡើងហើយ ក៏ឆាបឆេះនូវគំនរស្មៅ ឬគំនរឧស គប្បីឆេះគុម្ពឈើ ( ដែលគ្មានគេរក្សា ) ខ្លះ ឆេះព្រៃ ( ដែលគេរក្សា ) ខ្លះ លុះឆេះគុម្ពឈើ ( ដែលគ្មានគេរក្សា ) ឆេះព្រៃ ( ដែលគេរក្សា ) ហើយ ក៏ទៅជារបស់ខ្មួចខ្មី ហើយរលត់ទៅ ព្រោះអាស្រ័យនូវវត្ថុមានពណ៌ខៀវខ្លះ នូវថ្មខ្លះ នូវទឹកខ្លះ នូវចំណែកនៃផែនដីជាទីរីករាយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកប្រតិបត្តិយ៉ាងនេះ ។បេ។ ភិក្ខុនោះ ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ក៏យ៉ាងនោះឯង ដូច្នេះ ។

[ ៥៧ ] និទ្ទេសនៃបុគ្គលដែលបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលជាដើម មានអត្ថងាយយល់ហើយ ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា ព្រះអរហន្ត ។ ពាក្យថា ព្រះអរហន្តក្នុងទីនេះគប្បីជ្រាបថា មាន ១២ ពួក ។

សួរថា មាន ១២ ពួក តើដូចម្តេច ឆ្លើយថា វិមោក្ខមាន ៣ យ៉ាង គឺ សុញ្ញតវិមោក្ខ ១ អនិមិត្តវិមោក្ខ ១ អប្បណិហិតវិមោក្ខ ១ បណ្តាវិមោក្ខទាំងនោះ ព្រះខីណាស្រព ដែលរួចផុតដោយសុញ្ញតវិមោក្ខ មាន ៤ ពួក ដោយអំណាចបដិបទា ៤ យ៉ាង និងព្រះខីណាស្រព ដែលរួចផុតដោយ

អនិមិត្តវិមោក្ខ ឬអប្បណិហិតវិមោក្ខក៏ដូចគ្នា ព្រោះហេតុនោះ បណ្ឌិតគប្បី ជ្រាបថា ព្រះអរហន្តមាន ១២ ពួក ដោយប្រការដូច្នេះ ។

បុគ្គលមានប្រមាណប៉ុណ្ណេះ គឺព្រះសកទាគាមី ១២ ពួក ដែលដូចគ្នា នឹងព្រះអរហន្ត ១២ ពួក ព្រះសោតាបន្ន ២៤ ពួក គឺព្រះសោតាបន្ន ១២ ពួក គុណនឹងធុរៈ ២ គឺសទ្ធាធុរៈ ១ បញ្ញាធុរៈ ១ និងព្រះអនាគាមី ៤៨ ពួក ទាំងអស់នេះ កាលលោកផុតចាកលោកនេះហើយ រមែងមិនកើតក្នុង លទ្ធិខាងក្រៅសាសនា តែងកើតក្នុងសាសនានៃព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ ដូច្នេះ ។៚

## អដ្ឋកថាឯកកនិទ្ទេស ចប់

# អភិធម្មបិដក

## ទុកនិទ្ទេស

[ ៥៨ ] បុគ្គលមានសេចក្តីក្រោធ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ក្រោធ តើដូចម្តេច ។ ការក្រោធ អាការក្រោធ ភាពនៃសេចក្តីក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃសេចក្តីព្យាបាទ ការខឹង ការខឹងខ្លាំង ភាពនៃចិត្តកាច ការព្រហើន ភាពនៃសេចក្តីតូចចិត្តណា នេះហៅថា ក្រោធ ។ បុគ្គលដែលមិនលះបង់ក្រោធនេះ នេះហៅថា បុគ្គលមានសេចក្តីក្រោធ ។ បុគ្គលចងសេចក្តីក្រោធទុក តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការចងសេចក្តីក្រោធទុក តើដូចម្តេច ។ សេចក្តីក្រោធក្នុងកាលខាងដើម ការចងសេចក្តីក្រោធទុកក្នុងកាលជាខាងក្រោយទៀត ការចងសេចក្តីក្រោធទុក អាការចងសេចក្តីក្រោធទុក ភាពនៃការចងសេចក្តីក្រោធទុក ការតាំងទុក អាការតម្កល់ទុក សេចក្តីតម្កល់ព្រម ការតម្កល់ទុករឿយៗ ការចងទុករឿយៗ អំពើដ៏មាំនៃសេចក្តីក្រោធណា ដែលមានសភាពដូច្នេះ នេះហៅថា ការចងសេចក្តីក្រោធទុក ។ បុគ្គលដែលមិនលះបង់ការចងសេចក្តីក្រោធទុកនេះ នេះហៅថា បុគ្គលចងសេចក្តីក្រោធទុក ។

[ ៥៩ ] បុគ្គលអ្នកលុបគុណគេ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការលុបគុណគេ តើដូចម្តេច ។ ការលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ ការវេរឃ្នើ អំពើវេរឃ្នើណា នេះហៅថាការលុបគុណ ។

បុគ្គលដែលមិនលះបង់ការលុបគុណនេះ នេះហៅថា បុគ្គលអ្នកលុបគុណគេ ។ បុគ្គលអ្នកប្រណាំងវាសនា តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការប្រណាំងវាសនា តើដូចម្តេច ។ ការប្រណាំងវាសនា អាការប្រណាំងវាសនា ភាពនៃសេចក្តីប្រណាំងវាសនា ការនាំមកនៃការប្រណាំងវាសនា ហេតុជាទីតាំងនៃវិវាទ ការកាន់យកជាគូ ការមិនលះបង់ណា នេះហៅថា ការប្រណាំងវាសនា ។ បុគ្គលដែលមិនលះបង់ការប្រណាំងវាសនានេះ នេះហៅថា បុគ្គលអ្នកប្រណាំងវាសនា ។

[ ៦០ ] បុគ្គលមានសេចក្តីប្រណែន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រណែន តើដូចម្តេច ។ ការប្រណែន អាការប្រណែន ភាពនៃសេចក្តីប្រណែន ការឈ្នានីស អាការឈ្នានីស ភាពនៃសេចក្តីឈ្នានីស ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់បុគ្គលដទៃណា នេះហៅថា សេចក្តីប្រណែន ។ បុគ្គលដែលមិនលះបង់សេចក្តីប្រណែននេះ នេះហៅថា បុគ្គលមានសេចក្តីប្រណែន ។ បុគ្គលមានសេចក្តីកំណាញ់ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីកំណាញ់ តើដូចម្តេច ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីប្រាថ្នាខ្លាំង សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ចិត្តហួងហែងមិនរើសមុខណាដែលមានសភាពដូច្នេះ នេះហៅថា សេចក្តីកំណាញ់ ។ បុគ្គលដែលមិនលះបង់

សេចក្តីកំណាញ់នេះ នេះហៅថា បុគ្គលមានសេចក្តីកំណាញ់ ។

[ ៦១ ] បុគ្គលមានសេចក្តីអួតអាង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីអួតអាង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកអួតអាង ជាអ្នកឡែបឡប មានការអួតអាង អាការអួតអាង ភាពនៃសេចក្តីអួតអាង សេចក្តីរឹងរូស សេចក្តីរឹងត្អឹង ការបោកប្រាស សេចក្តីបោកប្រាសណា នេះហៅថា សេចក្តីអួតអាង ។ បុគ្គលដែលមិនលះបង់សេចក្តីអួតអាងនេះ នេះហៅថា បុគ្គលមានសេចក្តីអួតអាង ។ បុគ្គលមានមាយា តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ មាយា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តម្កល់ទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុបិទបាំងទុច្ចរិតនោះ ប្រាថ្នាថា កុំឲ្យគេស្គាល់អញ ត្រិះរិះថា កុំឲ្យគេស្គាល់អញ ពោលវាចាថា កុំឲ្យគេស្គាល់អញ ព្យាយាមដោយកាយថា កុំឲ្យគេស្គាល់អញ មាយា ភាពមាយា ការបិទបាំងទោស ការបញ្ឆោត ការបំភ័ន្ត ការបោះបោលនូវបាប ការរក្សាទុកនូវទោស ការលាក់ ការលាក់ក្បិត ការបិទបាំងនូវបាប ការបិទបាំងក្បិត អំពើមិនរាក់ អំពើមិនធ្វើឲ្យប្រាកដ ការបិទបាំងជិត កិរិយាដ៏លាមកណា ដែលមានសភាពដូច្នេះ នេះហៅថា មាយា ។ បុគ្គលដែលមិនលះបង់មាយានេះ នេះហៅថា បុគ្គលមានមាយា ។

[ ៦២ ] បុគ្គលមិនខ្មាសបាប តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការមិនខ្មាសបាប តើដូចម្តេច ។ ធម្មជាតណាដែលបុគ្គលមិនខ្មាស ដោយអំពើ

ដែលគេត្រូវខ្មាស មិនខ្មាសដោយការកប់ប្រសព្វនឹងធម៌ជាអកុសលដ៏លាមក នេះហៅថា ការមិនខ្មាសបាប ។ បុគ្គលប្រកបដោយសេចក្តីមិនខ្មាសបាបនេះ ឈ្មោះថា បុគ្គលមិនខ្មាសបាប ។ បុគ្គលមិនខ្លាចបាប តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការមិនខ្លាចបាប តើដូចម្តេច ។ ធម្មជាតណាដែលបុគ្គលមិនខ្លាចដោយអំពើដែលគេត្រូវខ្លាច មិនខ្លាចដោយការកប់ប្រសព្វនឹងធម៌ជាអកុសលដ៏លាមក នេះហៅថា ការមិនខ្លាចបាប ។ បុគ្គលប្រកបដោយការមិនខ្លាចបាបនេះ ឈ្មោះថា បុគ្គលមិនខ្លាចបាប ។

[ ៦៣ ] បុគ្គលប្រដៅក្រ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលប្រដៅក្រ តើដូចម្តេច ។ ការប្រដៅក្រ សេចក្តីប្រដៅក្រ ភាពដែលគេប្រដៅបានដោយក្រ ភាពនៃបុគ្គលដែលប្រកាន់យកតែខាងខុស ភាពនៃបុគ្គលដែលត្រេកអរក្នុងធម៌ជាសត្រូវ ការមិនអើពើ ភាពនៃបុគ្គលមិនអើពើ ភាពនៃបុគ្គលមិនគោរព ភាពនៃបុគ្គលមិនទទួលស្តាប់បង្គាប់ ចំពោះសហធម្មិកដែលស្តីប្រដៅ នេះហៅថា ភាពនៃបុគ្គលប្រដៅក្រ ។ បុគ្គលប្រកបដោយសេចក្តីប្រដៅក្រនេះ ឈ្មោះថា បុគ្គលប្រដៅក្រ ។ បុគ្គលមានមិត្តអាក្រក់ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានមិត្តអាក្រក់ តើដូចម្តេច ។ បុគ្គលណាមិនមានសទ្ធា ទ្រុស្តសីល ជាអ្នកចេះដឹងតិច មានសេចក្តីកំណាញ់ មិនមានបញ្ញា ការសេព ការសេពដោយស្និទ្ធស្នាល ការសេពដោយត្រូវគំនិតគ្នា ការគប់រកគ្នា ការគប់រកត្រូវគំនិតគ្នា សេចក្តីស្រឡាញ់ សេចក្តីស្រឡាញ់ជិតដិតនឹងគ្នា ភាពនៃបុគ្គលមូលមិត្តជាមួយគ្នា

ចំពោះបុគ្គលទាំងនោះណា នេះហៅថា ភាពនៃបុគ្គលមានមិត្តអាក្រក់ ។ បុគ្គលប្រកបដោយភាពជាអ្នកមានមិត្តអាក្រក់នេះ ឈ្មោះថា បុគ្គលមានមិត្តអាក្រក់ ។

[ ៦៤ ] បុគ្គលមានទ្វារមិនរក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានទ្វារមិនរក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញរូបដោយចក្ខុ ជាអ្នកកាន់យកនិមិត្ត កាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ មិនរក្សាចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធរសដោយអណ្តាត ។បេ។ ពាល់សម្ផស្សដោយកាយ ។បេ។ ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្ត ហើយជាអ្នកកាន់យកនិមិត្ត កាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្សជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយណា មិនប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយនោះ មិនរក្សាមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការមិនគ្រប់គ្រង អាការមិនគ្រប់គ្រង ការមិនរក្សា សេចក្តីមិនសង្រួមនូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ភាពនៃបុគ្គលមានទ្វារមិនរក្សាក្នុងឥន្ទ្រិយ ។ បុគ្គលប្រកបដោយភាពជាអ្នកមានទ្វារមិនរក្សាក្នុងឥន្ទ្រិយ នេះឈ្មោះថា ជា

អ្នកមានទ្វារមិនគ្រប់គ្រងក្នុងឥន្ទ្រិយ ។ បុគ្គលមិនដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមិនដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនពិចារណា មិនធ្វើដោយឧបាយប្រាជ្ញា ក៏បរិភោគអាហារដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង ការមិនសន្តោស ការមិនដឹងប្រមាណ សេចក្តីមិនពិចារណា ក្នុងភោជននោះណា នេះហៅថា ភាពនៃបុគ្គលមិនដឹងប្រមាណ ក្នុងភោជន ។ បុគ្គលប្រកបដោយភាពជាអ្នកមិនដឹងប្រមាណ ក្នុងភោជន នេះឈ្មោះថា ជាអ្នកមិនដឹងប្រមាណក្នុងភោជន ។

[ ៦៥ ] បុគ្គលភ្លេចស្មារតី តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការភ្លេចស្មារតី តើដូចម្តេច ។ ការមិនរឭក ការមិនរឭករឿយៗ សេចក្តីមិនប្រុងស្មារតី ការរឭកមិនឃើញ ការមិនរឭក សេចក្តីមិនចងចាំ ការរវើរវាយក្នុងអារម្មណ៍ ការវង្វេងភ្លេចណា នេះហៅថា ការភ្លេចស្មារតី ។ បុគ្គលប្រកបដោយការភ្លេចស្មារតី នេះឈ្មោះថា បុគ្គលភ្លេចស្មារតី ។ បុគ្គលមិនដឹងខ្លួន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការមិនដឹងខ្លួន តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនត្រាស់ដឹងរឿយៗ ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក ការមិនចុះចិត្តស៊ប់ អាការមិនរំពឹងមើល សេចក្តីមិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់បានដោយក្រ ភាពនៃចិត្តល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា អន្លង់ គឺអវិជ្ជា ការប្រកប គឺអវិជ្ជា អនុស័យ គឺអវិជ្ជា ការស្កាត់ដំណើរ

គឺអវិជ្ជា គន្ទឹះ គឺអវិជ្ជា ការវង្វេង អកុសលមូលណា នេះហៅថា សេចក្តីមិនដឹងខ្លួន ។ បុគ្គលប្រកបដោយសេចក្តីមិនដឹងខ្លួន នេះឈ្មោះថា បុគ្គលមិនដឹងខ្លួន ។

[ ៦៦ ] បុគ្គលវិបត្តិសីល តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ វិបត្តិសីល តើដូចម្តេច ។ ការប្រព្រឹត្តល្មើស ប្រកបដោយកាយ ការប្រព្រឹត្តល្មើសប្រកបដោយវាចា ការប្រព្រឹត្តល្មើសប្រកបដោយកាយ និងវាចា នេះហៅថា វិបត្តិសីល ភាពនៃបុគ្គលទ្រុស្តសីលទាំងអស់ក៏ឈ្មោះថា វិបត្តិសីលដែរ ។ បុគ្គលប្រកបដោយវិបត្តិសីលនេះ ឈ្មោះថា បុគ្គលវិបត្តិសីល ។ បុគ្គលវិបត្តិទិដ្ឋិ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ វិបត្តិទិដ្ឋិ តើដូចម្តេច ។ ( សេចក្តីយល់ ) ថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱបបាតិកកំណើតមិនមាន ពួកសមណ-ព្រាហ្មណ៍ក្នុងលោកប្រព្រឹត្តល្អ ប្រតិបត្តិត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងបានមិនមាន ទិដ្ឋិ ដំណើរនៃទិដ្ឋិ ព្រៃញាតស្បាត គឺទិដ្ឋិ ផ្លូវឆ្ងាយ គឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេង គឺទិដ្ឋិ ការទាក់ទិន គឺទិដ្ឋិ ការកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ ការប្រកាន់ ក្នុងការស្វែងរកខុសណា ដែលមានសភាពដូច្នេះ

នេះហៅថា វិបត្តិទិដ្ឋិ មិច្ឆាទិដ្ឋិទាំងអស់ ក៏ឈ្មោះថា វិបត្តិទិដ្ឋិដែរ ។ បុគ្គលប្រកបដោយវិបត្តិទិដ្ឋិនេះ ឈ្មោះថា បុគ្គលវិបត្តិទិដ្ឋិ ។

[ ៦៧ ] បុគ្គលមានសញ្ញោជនៈខាងក្នុង តើដូចម្តេច ។ បុគ្គលដែលមិនបានលះបង់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ នេះហៅថា បុគ្គលមានសញ្ញោជនៈខាងក្នុង ។ បុគ្គលមានសញ្ញោជនៈខាងក្រៅ តើដូចម្តេច ។ បុគ្គលដែលមិនបានលះបង់សញ្ញោជនៈ ជាចំណែកខាងលើ ៥ នេះហៅថា បុគ្គលមានសញ្ញោជនៈខាងក្រៅ ។

[ ៦៨ ] បុគ្គលមិនមានសេចក្តីក្រោធ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីក្រោធ តើដូចម្តេច ។ ការក្រោធ អាការក្រោធ ភាពនៃសេចក្តីក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃសេចក្តីប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃសេចក្តីព្យាបាទ ការខឹង ការខឹងខ្លាំង ភាពនៃចិត្តកាចការព្រហើន សេចក្តីតូចចិត្តណា នេះហៅថា សេចក្តីក្រោធ ។ បុគ្គលដែលលះបង់សេចក្តីក្រោធនេះ នេះហៅថា បុគ្គលមិនមានសេចក្តីក្រោធ ។ បុគ្គលមិនចងសេចក្តីក្រោធទុក តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការចងសេចក្តីក្រោធទុក តើដូចម្តេច ។ សេចក្តីក្រោធក្នុងកាលមុន សេចក្តីចងក្រោធទុកក្នុងកាលជាខាងក្រោយ ការចងក្រោធទុក អាការចងក្រោធទុក ភាពនៃសេចក្តីចងក្រោធទុក សេចក្តីតាំងទុក អាការតម្កល់ទុក សេចក្តីតម្កល់ព្រមការតម្កល់ទុករឿយៗ អាការចងទុករឿយៗ អំពើដ៏មាំនៃសេចក្តីក្រោធណាដែលមានសភាពដូច្នេះ នេះហៅថា ការចងសេចក្តីក្រោធទុក ។ បុគ្គលដែល

លះបង់ការចងសេចក្តីក្រោធទុកនេះ នេះហៅថា បុគ្គលមិនចងសេចក្តីក្រោធទុក ។

[ ៦៩ ] បុគ្គលមិនលុបគុណគេ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការលុបគុណគេ តើដូចម្តេច ។ ការលុបគុណ អាការលុបគុណ ភាពនៃសេចក្តីលុបគុណ ការវេរឃ្នើ អំពើវេរឃ្នើណា នេះហៅថា ការលុបគុណគេ ។ បុគ្គលដែលលះបង់ការលុបនេះ នេះហៅថា បុគ្គលមិនលុបគុណគេ ។ បុគ្គលអ្នកមិនប្រណាំងវាសនា តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការប្រណាំងវាសនា តើដូចម្តេច ។ ការប្រណាំងវាសនា អាការប្រណាំងវាសនា ភាពនៃសេចក្តីប្រណាំងវាសនា អាការនៃការប្រណាំងវាសនា ហេតុជាទីតាំងនៃវិវាទ សេចក្តីកាន់យកជាគូ ការមិនលះបង់ណា នេះហៅថា ការប្រណាំងវាសនា ។ បុគ្គលដែលលះបង់ការប្រណាំងវាសនានេះ នេះហៅថា បុគ្គលមិនប្រណាំងវាសនា ។

[ ៧០ ] បុគ្គលមិនមានសេចក្តីប្រណែន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីប្រណែន តើដូចម្តេច ។ ការប្រណែន អាការប្រណែន ភាពនៃសេចក្តីប្រណែន ការឈ្នានីស អាការឈ្នានីស ភាពនៃសេចក្តីឈ្នានីសក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់បុគ្គលដទៃណា នេះហៅថា សេចក្តីប្រណែន ។ បុគ្គលដែលលះបង់សេចក្តីប្រណែននេះ នេះហៅថា បុគ្គលមិនមានសេចក្តីប្រណែន ។ បុគ្គលមិនមានសេចក្តីកំណាញ់ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីកំណាញ់ តើ

ដូចម្តេច ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ការកំណាញ់ អាការកំណាញ់ ភាពនៃសេចក្តីកំណាញ់ សេចក្តីប្រាថ្នាខ្លាំង សេចក្តីកំណាញ់រឹង សេចក្តីស្វិតស្វាញ ចិត្តហួងហែងមិនរើសមុខណាដែលមានសភាពដូច្នេះ នេះហៅថា សេចក្តីកំណាញ់ ។ បុគ្គលដែលលះបង់សេចក្តីកំណាញ់នេះ នេះហៅថា បុគ្គលមិនមានសេចក្តីកំណាញ់ ។

[ ៧១ ] បុគ្គលមិនមានសេចក្តីអួតអាង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីអួតអាង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកអួតអាង អែបអប មានការអួតអាង អាការអួតអាង ភាពនៃការអួតអាង សេចក្តីរឹងរូស សេចក្តីរឹងត្អឹង ការបោកប្រាស សេចក្តីបោកប្រាសណា នេះហៅថា សេចក្តីអួតអាង ។ បុគ្គលដែលលះបង់សេចក្តីអួតអាងនេះ នេះហៅថា បុគ្គលជាអ្នកមិនអួតអាង ។ បុគ្គលមិនមានមាយា តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ មាយា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត តាំងទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុបិទបាំងទុច្ចរិតនោះ ប្រាថ្នាថាកុំឲ្យគេស្គាល់អញ ត្រិះរិះថា កុំឲ្យគេស្គាល់អញ ពោលពាក្យថា កុំឲ្យគេស្គាល់អញ ព្យាយាមដោយកាយថា កុំឲ្យគេស្គាល់អញ មាយា ភាពនៃបុគ្គលមានមាយា ការបិទបាំងទោស ការបញ្ឆោត ការបំភាន្ត ការបោះបោលនូវបាប ការរក្សាទុកនូវទោស ការលាក់ ការលាក់ក្បិត ការបិទបាំងនូវបាប ការបិទបាំងក្បិត

អំពើមិនរាក់ អំពើមិនធ្វើឲ្យប្រាកដ ការបិទបាំងជិត កិរិយាដ៏លាមកណា ដែលមានសភាពដូច្នេះ នេះហៅថា មាយា ។ បុគ្គលដែលលះបង់មាយានេះ នេះហៅថា បុគ្គលមិនមានមាយា ។

[ ៧២ ] បុគ្គលមានសេចក្តីខ្មាសបាប តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីខ្មាសបាប តើដូចម្តេច ។ ធម្មជាតណា ដែលបុគ្គលខ្មាសដោយអំពើដែលគេត្រូវខ្មាស ខ្មាសដោយការកប់ប្រសព្វនឹងធម៌ជាអកុសលដ៏លាមក នេះហៅថា សេចក្តីខ្មាសបាប ។ បុគ្គលប្រកបដោយសេចក្តីខ្មាសបាប នេះឈ្មោះថា បុគ្គលមានសេចក្តីខ្មាសបាប ។ បុគ្គលមានសេចក្តីខ្លាចបាប តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីខ្លាចបាប តើដូចម្តេច ។ ធម្មជាតណា ដែលបុគ្គលខ្លាចដោយអំពើដែលគេត្រូវខ្លាច ខ្លាចដោយការកប់ប្រសព្វនឹងធម៌ជាអកុសលដ៏លាមក នេះហៅថា សេចក្តីខ្លាចបាប ។ បុគ្គលប្រកបដោយសេចក្តីខ្លាចបាប នេះឈ្មោះថា បុគ្គលមានសេចក្តីខ្លាចបាប ។

[ ៧៣ ] បុគ្គលប្រដៅងាយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលដែលគេប្រដៅងាយ តើដូចម្តេច ។ ការប្រដៅងាយ សេចក្តីប្រដៅងាយ ភាពដែលគេប្រដៅបានដោយងាយ ភាពនៃបុគ្គលមិនប្រកាន់យកខាងខុស ភាពនៃបុគ្គលត្រេកអរ ក្នុងធម៌មិនជាសត្រូវ សេចក្តីប្រកបដោយការអើពើ ភាពនៃបុគ្គលប្រកបដោយការអើពើ ភាពនៃបុគ្គលប្រកបការគោរព ភាពនៃបុគ្គលប្រកបដោយការទទួលស្តាប់បង្គាប់ ចំពោះសហធម្មិកដែលស្តីប្រដៅ នេះហៅថា ភាពនៃបុគ្គលដែលគេប្រដៅបានដោយងាយ ។ បុគ្គល

ប្រកបដោយភាពដែលគេប្រដៅបានដោយងាយ នេះឈ្មោះថា បុគ្គលប្រដៅងាយ ។ បុគ្គលមានមិត្តល្អ តើដូចម្តេច ។ បណ្តាបុគ្គលទាំងនោះ ភាពនៃបុគ្គលមានមិត្តល្អ តើដូចម្តេច ។ បុគ្គលណា មានសទ្ធា មានសីល ជាពហុស្សូត មានចាគៈ មានបញ្ញា ការសេពគប់ ការសេពដោយស្និទ្ធស្នាល ការសេពដោយត្រូវគំនិតគ្នា ការគប់រកគ្នា ការគប់រកត្រូវគំនិតគ្នា សេចក្តីស្រឡាញ់ សេចក្តីស្រឡាញ់ជិតជិតនឹងគ្នា ភាពនៃបុគ្គលមូលមិត្តជាមួយគ្នា ចំពោះបុគ្គលទាំងនោះណា នេះហៅថា ភាពនៃបុគ្គលមានមិត្តល្អ ។ បុគ្គលប្រកបដោយភាពជាអ្នកមានមិត្តល្អ នេះឈ្មោះថា បុគ្គលមានមិត្តល្អ ។

[ ៧៤ ] បុគ្គលមានទ្វាររក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានទ្វាររក្សាក្នុងឥន្ទ្រិយ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្សជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ ភ្លក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវសម្ផស្សដោយកាយ ។បេ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយជាអ្នកមិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គល ដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមមនិន្ទ្រិយ

ណា ក៏ប្រតិបត្តិដើម្បីសង្រួមមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ការគ្រប់គ្រង អាការគ្រប់គ្រង ការរក្សា ការសង្រួមនូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ភាពនៃបុគ្គលមានទ្វាររក្សាក្នុងឥន្ទ្រិយ ។ បុគ្គលប្រកបដោយភាពជាអ្នកមានទ្វាររក្សាក្នុងឥន្ទ្រិយ នេះឈ្មោះថា អ្នកមានទ្វាររក្សាក្នុងឥន្ទ្រិយ ។ បុគ្គលដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាដោយឧបាយប្រាជ្ញា ហើយបរិភោគអាហារដើម្បីលេងក៏ទេ ដើម្បីស្រវឹងក៏ទេ ដើម្បីប្រដាប់ក៏ទេ ដើម្បីស្អិតស្អាងរាងកាយក៏ទេ ( បរិភោគ ) កំណត់ទុកដើម្បីតាំងនៅនៃកាយនេះ ដើម្បីប្រព្រឹត្តទៅនៃកាយនេះ ដើម្បីនឹងបំបាត់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈថា អញនឹងកម្ចាត់បង់នូវវេទនាចាស់ផង នឹងញុំាងវេទនាថ្មីមិនឲ្យកើតឡើងបានផង ការប្រព្រឹត្តទៅក្តី សេចក្តីមិនមានទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អញ ការសន្តោស ការដឹងប្រមាណ ការពិចារណាក្នុងភោជននោះណា នេះហៅថា ភាពនៃបុគ្គលដឹងប្រមាណក្នុងភោជន ។ បុគ្គលប្រកបដោយភាពជាអ្នកដឹងប្រមាណក្នុងភោជន នេះឈ្មោះថា បុគ្គលដឹងប្រមាណក្នុងភោជន ។

[ ៧៥ ] បុគ្គលមានស្មារតីតម្កល់មាំ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះស្មារតី តើដូចម្តេច ។ ការនឹកឃើញ ការនឹករឿយៗ ស្មារតី ការរឭកឃើញ ការចាំទុក ការមិនរវើរវាយក្នុងអារម្មណ៍ ការមិនវង្វេងភ្លេច ឥន្ទ្រិយ

គឺការទឹក កម្លាំង គឺការទឹក ការទឹកត្រូវណា នេះហៅថា ស្មារតី ។ បុគ្គលប្រកបដោយស្មារតី នេះឈ្មោះថា បុគ្គលមានស្មារតីតម្កល់មាំ ។ បុគ្គលជាអ្នកដឹងខ្លួន តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ សេចក្តីដឹងខ្លួន តើដូចម្តេច ។ ការដឹង ការដឹងច្បាស់ ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកំណត់ទុក ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាស ការពេញប្រៀប ការវាងវៃ ការគិត ការត្រិះរិះ ធម្មជាតដូចជាផែនដី ប្រាជ្ញា ធម្មជាតជាគ្រឿងទម្លុះទម្លាយ ការដឹងច្បាស់ សេចក្តីដឹងព្រមសភាពជាជន្ទញ បញ្ញា ឥន្ទ្រិយ គឺបញ្ញា កម្លាំង គឺបញ្ញា កាំបិត គឺបញ្ញា ប្រាសាទ គឺបញ្ញា រស្មី គឺបញ្ញា ពន្លឺ គឺបញ្ញា ការរុងរឿង គឺបញ្ញា កែវ គឺបញ្ញា ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា នេះហៅថា សេចក្តីដឹងខ្លួន ។ បុគ្គលប្រកបដោយសេចក្តីដឹងខ្លួន នេះឈ្មោះថា បុគ្គលជាអ្នកដឹងខ្លួន ។

[ ៧៦ ] បុគ្គលបរិបូរណ៍ដោយសីល តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការបរិបូរណ៍ដោយសីល តើដូចម្តេច ។ ការមិនប្រព្រឹត្តល្មើស ប្រកបដោយកាយ ការមិនប្រព្រឹត្តល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តល្មើស ប្រកបដោយកាយ និងវាចា នេះហៅថា ការបរិបូរណ៍ដោយសីល ។ ការសង្រួមក្នុងសីលទាំងអស់ ក៏ឈ្មោះថា ការបរិបូរណ៍ដោយសីលដែរ ។ បុគ្គលប្រកបដោយការបរិបូរណ៍ដោយសីលនេះ ឈ្មោះថា អ្នកបរិបូរណ៍ដោយសីល ។ បុគ្គលបរិបូរណ៍ដោយទិដ្ឋិ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ការបរិបូរណ៍

ដោយទិដ្ឋិ តើដូចម្តេច ។ ( ការយល់ ) ថា ទានដែលបុគ្គលឲ្យហើយមាន ផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកម្ម ដែល បុគ្គលធ្វើល្អ និងអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមាន គុណ បិតាមានគុណ ពួកសត្វជាឱបបាតិកកំណើតមាន ពួកសមណ-ព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រូវ ដែលធ្វើឲ្យជាក់ច្បាស់ នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយ សម្តែងបានមាន ការដឹង ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា លែងមានសភាពដូច្នេះ នេះហៅថា ការបរិបូរណ៍ ដោយទិដ្ឋិ ។ ការឃើញត្រូវទាំងអស់ ក៏ឈ្មោះថា ការបរិបូរណ៍ដោយទិដ្ឋិ ដែរ ។ បុគ្គលប្រកបដោយការបរិបូរណ៍ដោយទិដ្ឋិនេះ ឈ្មោះថា អ្នក បរិបូរណ៍ដោយទិដ្ឋិ ។

[ ៧៧ ] បុគ្គល ២ ពួក រកបានដោយក្រក្នុងលោក តើដូចម្តេច ។ បុគ្គលជាបុព្វការី ១ បុគ្គលជាកតញ្ញូកតវេទី ១ បុគ្គល ២ ពួកនេះ រកបាន ដោយក្រក្នុងលោក ។

[ ៧៨ ] បុគ្គល ២ ពួកគេបំពេញបានដោយក្រ តើដូចម្តេច ។ បុគ្គល ដែលទុកនូវរបស់ដែលខ្លួនរកបានហើយ បានហើយ ១ បុគ្គលដែលលះបង់ នូវរបស់ដែលខ្លួនរកបានហើយ បានហើយ ១ បុគ្គល ២ ពួកនេះ គេបំពេញ បានដោយក្រ ។

[ ៧៩ ] បុគ្គល ២ ពួកគេបំពេញបានដោយងាយ តើដូចម្តេច ។ បុគ្គល

ដែលមិនទុកនូវរបស់ដែលខ្ជួនរកបានហើយ បានហើយ ១ បុគ្គលដែលមិនលះបង់នូវរបស់ដែលខ្ជួនរកបានហើយ បានហើយ ១ បុគ្គល ២ ពួកនេះ គេចម្អែតបានដោយងាយ ។

[ ៨០ ] អាសវៈនៃបុគ្គល ២ ពួក រមែងចម្រើន តើដូចម្តេច ។ បុគ្គលដែលរង្កៀសសង្ស័យនូវវត្ថុដែលមិនត្រូវរង្កៀសសង្ស័យ ១ បុគ្គលដែលមិនរង្កៀសសង្ស័យនូវវត្ថុដែលត្រូវរង្កៀសសង្ស័យ ១ អាសវៈនៃបុគ្គល ២ ពួកនេះ រមែងចម្រើន ។

[ ៨១ ] អាសវៈនៃបុគ្គល ២ ពួក រមែងមិនចម្រើន តើដូចម្តេច ។ បុគ្គលដែលមិនរង្កៀសសង្ស័យនូវវត្ថុដែលមិនត្រូវរង្កៀសសង្ស័យ ១ បុគ្គលដែលរង្កៀសសង្ស័យនូវវត្ថុដែលត្រូវរង្កៀសសង្ស័យ ១ អាសវៈនៃបុគ្គល ២ ពួកនេះ រមែងមិនចម្រើន ។

[ ៨២ ] បុគ្គលមានអធ្យាស្រ័យថោកទាប តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌លាមក បុគ្គលនោះតែងសេពគប់ ចូលទៅអង្គុយជិតបុគ្គលដទៃ ដែលទ្រុស្តសីល មានធម៌លាមកដែរ នេះហៅថា បុគ្គលមានអធ្យាស្រ័យថោកទាប ។ បុគ្គលមានអធ្យាស្រ័យខ្ពង់ខ្ពស់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ បុគ្គលនោះតែងសេពគប់ ចូលទៅអង្គុយជិតបុគ្គលដទៃ ដែលមានសីល មានធម៌ល្អ

នេះហៅថា បុគ្គលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ។

[ ៨៣ ] បុគ្គលឆ្អែតដោយខ្លួនឯង តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធ និង ព្រះអរហន្ត ជាសាវករបស់ព្រះតថាគត ឈ្មោះថា ឆ្អែតដោយខ្លួនឯង ឯព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ឆ្អែតដោយព្រះអង្គឯងផង ញុំាងគេឲ្យឆ្អែតផង ។

## ទុកនិទ្ទេស ចប់

# អដ្ឋកថា

## ទុកនិទ្ទេស

[ ៥៨ ] បុគ្គលមានការក្រោធជាប្រក្រតី គឺបុគ្គលក្រោធច្រើន ឈ្មោះថា **កោធនោ** ។ ព្រះមានព្រះភាគ កាលត្រាស់សួរបុគ្គលយ៉ាងនេះហើយ ដើម្បីនឹងសម្ដែងបុគ្គលដោយធម៌ ទើបត្រាស់បទថា **តត្ថ កតមោ កោធោ** ដូច្នេះជាដើម ។

ក្នុងនិទ្ទេសនៃបុគ្គលចងសេចក្ដីក្រោធទុកជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **កោធោ កុជ្ឈនា** មានអត្ថដូចខ្ញុំពោលហើយខាងដើមនោះឯង ។ បទថា **បុព្វកាលំ កោធោ** ជាដើម ក្នុងនិទ្ទេសនៃបុគ្គលចងសេចក្ដីក្រោធទុកជាដើម ក៏យ៉ាងនោះ ។

បទថា **អយំ កោធោ អប្បហីនោ** សេចក្ដីថា សេចក្ដីក្រោធនេះ គឺមានប្រមាណប៉ុណ្ណេះ ដែលបុគ្គលមិនទាន់លះបាន ដោយវិក្ខម្ភនប្បហាន ឬដោយតទង្គប្បហាន ឬដោយសមុច្ឆេទប្បហាន ។ ក្នុង **ឧបនាហោ** ជាដើម ខាងមុខ ក៏ន័យនេះដូចគ្នា ។

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអហិរិកនិទ្ទេស ដូចតទៅនេះ បទថា **ឥមិនា អហិរិកេន** សេចក្ដីថា បុគ្គលដែលប្រកបដោយធម៌ គឺសេចក្ដីមិនខ្មាសនេះ ដែលមានប្រការយ៉ាងនេះ ។ ក្នុងបទថា **ឥមិនា អនោត្តប្បេន** ជាដើម ក៏មានន័យនេះដូចគ្នា ។

[ ៦៧ ] បទថា **អជ្ឈត្តសំយោជនោ** បានដល់ មានចំណងខាងក្នុង ។

បទថា **ពហិទ្ធាសំយោជនោ** បានដល់ មានចំណងខាងក្រៅ ។ ចំណង ទាំងពីរនេះ បណ្ឌិតគប្បីសម្តែងការឧបមាដោយរោងកូនគោ ។ ពិតហើយ ព្រះសោតាបន្ន និងព្រះសកទាគាមីដែលមានជីវិតក្នុងកាមលោកនេះ ក៏ប្រៀប ដូចកូនគោដែលគេចងទុកខាងក្នុង ដេកក្នុងរោងកូនគោនោះឯង ។ ចំណង គឺសញ្ញោជនៈរបស់ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ តាំងនៅក្នុង កាមលោកនេះ សូម្បីខ្លួនលោកក៏តាំងនៅក្នុងភពនេះដូចគ្នា ។ ព្រះសោតាបន្ន និងព្រះសកទាគាមីតាំងនៅក្នុងរូបភព ឬអរូបភព ប្រៀបដូចកូនគោ ដែលគេ ចងទុកក្នុងរោងនៃកូនគោ តែកូនគោដេកខាងក្រៅរោង ព្រោះថា ចំណងនៃ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ តាំងនៅក្នុងកាមលោកនេះ តែ លោកនៅក្នុងព្រហ្មលោក ។ ព្រះអនាគាមី ដែលនៅក្នុងរូបភព ឬអរូបភព ប្រៀបដូចកូនគោ ដែលគេចងទុក ខាងក្រៅរោង ខ្លួនក៏ដេកខាងក្រៅរោង ព្រោះថា ចំណងនៃព្រះអនាគាមីនោះ នៅខាងក្រៅអំពីកាមលោក សូម្បីខ្លួន លោក ក៏តាំងនៅខាងក្រៅ អំពីកាមលោកដូចគ្នា ។ ចំណែកព្រះអនាគាមី ដែលស្ថិតនៅក្នុងកាមលោកនេះ ប្រៀបដូចកូនគោដែលចងទុកខាងក្រៅរោង តែខ្លួនដេកខាងក្នុងរោង ព្រោះថា ចំណងរបស់ព្រះអនាគាមីនោះ នៅក្នុង រូបភព ឬអរូបភព តែលោកនៅក្នុងកាមភពនេះ ។

[ ៦៨ ] ក្នុងនិទ្ទេសនៃបុគ្គលមិនមានសេចក្តីក្រោធជាដើម គប្បីជ្រាប ដូចតទៅនេះ បទថា **បហីនោ** បានដល់ សេចក្តីក្រោធ ដែលបុគ្គលលះ បានហើយ ដោយវិក្ខម្ភនប្បហាន តទង្គប្បហាន និងសមុច្ឆេទប្បហាន ។

[ ៧៧ ] វិនិច្ឆ័យក្នុងឧទ្ទេសនៃបុគ្គល ដែលរកបានដោយក្រ ដូចតទៅនេះ បទថា **ទុល្លភា** បានដល់ មិនមែនរកបានដោយងាយ ។ បទថា **បុព្វការី** បានដល់ បុគ្គលដែលធ្វើឧបការៈមុននោះឯង ។ បទថា **កតវេទី** បានដល់ ប្រកាសឧបការគុណដែលបុគ្គលដទៃធ្វើហើយ គឺធ្វើឧបការគុណឲ្យប្រាកដ ។

បណ្ឌិតគប្បីសម្តែងបុគ្គលទាំង ២ ពួកនោះ ដោយអាគារិយបុគ្គល និងអនាគារិយបុគ្គល បណ្តាគ្រហស្ថទាំងឡាយ មាតា និងបិតា ឈ្មោះថា **បុព្វការី** គឺអ្នកធ្វើឧបការៈមុន ឯកូនប្រុសស្រី ដែលបដិបត្តិមាតាបិតា និងធ្វើការអភិវាទជាដើមដល់មាតាបិតាទាំងនោះ ឈ្មោះថា **កតវេទី** ។ សម្រាប់បព្វជិតទាំងឡាយ អាចារ្យ និងឧបជ្ឈាយ៍ ឈ្មោះថា **បុព្វការី** អន្តេវាសិក និងសទ្ធិវិហារិកទាំងឡាយ ដែលបដិបត្តិអាចារ្យ និងឧបជ្ឈាយ៍ និងធ្វើអភិវាទជាដើម ដល់អាចារ្យ និងឧបជ្ឈាយ៍ទាំងនោះ ឈ្មោះថា **កតវេទី** ។ ដើម្បីប្រកាសបុគ្គលទាំង ២ ពួកនោះ ឲ្យជាក់ច្បាស់ បណ្ឌិតគប្បីពោលដល់រឿងរបស់ព្រះសោណត្ថេរដែលជាអ្នកចិញ្ចឹមឧបជ្ឈាយ៍ជាដើម ។

ម្យ៉ាងទៀត បុគ្គលណាកាលអ្នកដទៃមិនបានធ្វើឧបការៈ មិនសម្លឹងដល់ឧបការៈដែលអ្នកដទៃធ្វើក្នុងខ្លួន ហើយធ្វើឧបការៈ បុគ្គលនោះ ក៏ឈ្មោះថា **បុព្វការី** ដូចមាតាបិតា អាចារ្យ និងឧបជ្ឈាយ៍ ។ បុព្វការីបុគ្គលនោះ ឈ្មោះថា រកបានដោយក្រ ព្រោះសត្វទាំងឡាយ ត្រូវតណ្ហាគ្របសង្កត់ ។

បុគ្គលណាដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើក្នុងខ្លួន ប្រកាសនូវឧបការៈ

ដែលប្រព្រឹត្តទៅតាមសមគួរ ដល់ឧបការៈ ដែលអ្នកដទៃធ្វើហើយ បុគ្គលនោះ ឈ្មោះថា **កតញ្ញូកតវេទី** ដូចបុគ្គលដែលបដិបត្តិប្រពៃក្នុងមាតាបិតា ឬក្នុងអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយ ។ កតញ្ញូកតវេទីបុគ្គលនោះ ឈ្មោះថា រកបានដោយក្រ ព្រោះសត្វទាំងឡាយ ត្រូវអវិជ្ជាគ្របសង្កត់ ។

ម្យ៉ាងទៀត បុគ្គលដែលផ្សាយមេត្តា ដោយមិនមានហេតុ ឈ្មោះថា **បុព្វការី** ។ បុគ្គលដែលផ្សាយមេត្តាដោយមានហេតុ ឈ្មោះថា **កតញ្ញូ-កតវេទី** ។

បុគ្គលដែលធ្វើប្រយោជន៍ ដោយមិនសម្លឹងដល់ហេតុជាដើម យ៉ាងនេះថា បុគ្គលនេះនឹងធ្វើឧបការៈដល់អញ ឈ្មោះថា **បុព្វការី** ។ បុគ្គលដែលធ្វើប្រយោជន៍ ដោយសម្លឹងដល់ហេតុជាដើម យ៉ាងនេះថា បុគ្គលនេះនឹងធ្វើឧបការៈដល់អញ ឈ្មោះថា **កតញ្ញូកតវេទី** ។

បុគ្គលមកងងឹតទៅភ្លឺ ឈ្មោះថា **បុព្វការី** ។ បុគ្គលមកភ្លឺទៅភ្លឺ ឈ្មោះថា **កតញ្ញូកតវេទី** ។ បុគ្គលសម្ដែងធម៌ ឈ្មោះថា **បុព្វការី** ។ បុគ្គលអ្នកបដិបត្តិធម៌ ឈ្មោះថា **កតញ្ញូកតវេទី** ។

ព្រះអរហន្តសម្មាសម្ពុទ្ធ ឈ្មោះថា បុព្វការីក្នុងលោកនេះ ព្រមទាំងទេវលោក ព្រះអរិយសាវ័ក ឈ្មោះថា កតញ្ញូកតវេទី ។

ឯក្នុងគម្ពីរអដ្ឋកថាទុកនិបាត លោកពោលពាក្យមានប្រមាណប៉ុណ្ណេះថា បុគ្គលធ្វើឧបការៈមុន ឈ្មោះថា **បុព្វការី** បុគ្គលដឹងឧបការៈដែលអ្នកដទៃធ្វើ ហើយធ្វើតបខាងក្រោយ ឈ្មោះថា **កតវេទី** ។ បណ្ដាបុគ្គលទាំង ២

ពួកនោះ បុព្វការីជនតែងធ្វើនូវសេចក្តីសម្គាល់ថា អញឲ្យបុល បុគ្គលដែលធ្វើតបក្នុងកាលខាងក្រោយ តែងសម្គាល់ថា អញសងបំណុល ដូច្នេះ ។

[ ៧៨ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបុគ្គលគេចម្អែតបានដោយក្រ ដូចតទៅនេះ បទថា **ទុត្តប្បយោ** បានដល់ ឲ្យឆ្អែតមិនបាន គឺបុគ្គលដែលបុគ្គលណាមួយមិនអាចឲ្យឆ្អែតបាន ។ ភិក្ខុណាអាស្រ័យត្រកូលឧបដ្ឋាក ឬត្រកូលរបស់ញាតិ កាលចីវរចាស់ហើយ ក៏ទុកចីវរដែលត្រកូលទាំងនោះឲ្យ មិនប្រើប្រាស់ ទទួលយកចីវរដែលត្រកូលទាំងនោះ ឲ្យបន្តៗ មក ហើយក៏ទុកទៀត ។ម្យ៉ាងទៀត ភិក្ខុណាលះបង់ចីវរដែលខ្លួនបានហើយ ដោយន័យនោះឯង ឲ្យចីវរដល់ភិក្ខុដទៃសូម្បីបានចីវររឿយៗ ក៏ធ្វើយ៉ាងនោះឯង ។

បុគ្គល ២ ពួកនេះ បុគ្គលណាមួយ បង្អោនបច្ច័យចូលទៅប្រគេនរាប់រទេះ ក៏មិនអាចឲ្យឆ្អែតបាន ព្រោះហេតុនោះ ទើបឈ្មោះថា គេចម្អែតបានដោយក្រ ។

[ ៧៩ ] វិនិច្ឆ័យក្នុងនិទ្ទេស នៃបុគ្គលដែលគេចម្អែតបានដោយងាយ ដូចតទៅនេះ បទថា **ន វិស្សជ្ជេតិ** បានដល់ ធ្វើឲ្យជារបស់ខ្លួន មិនឲ្យដល់អ្នកដទៃ តែកាលមានអតិរេកលាភ របស់ដែលសល់ក៏មិនរក្សាទុក រមែងប្រគេនដល់ភិក្ខុដទៃ សេចក្តីនេះ មានអធិប្បាយដូចតទៅនេះថា

ភិក្ខុណា មានចីវរចាស់ហើយ បានទូវសំពត់សាដកអំពីត្រកូលឧបដ្ឋាក ឬត្រកូលញាតិ ធ្វើឲ្យជាចីវរហើយប្រើប្រាស់ មិនព្រមបោះបោល ទោះបីប៉ះជាបំណះហើយ ក៏នៅតែប្រើប្រាស់ ស្បៀកដណ្តប់ កាលត្រកូលទាំងនោះ

ប្រគេនថ្មី ក៏មិនរួសរាន់ទទួល ។ ភិក្ខុណាប្រើប្រាស់ចីវរដែលខ្លួនឯងរកមក បាន មិនឲ្យដល់ភិក្ខុពួកដទៃ ភិក្ខុទាំង ២ ពួកនេះ បុគ្គលណាមួយក៏អាចធ្វើឲ្យឆ្អែតបានដោយងាយ ព្រោះហេតុនោះ ទើបឈ្មោះថា **សុភរា** ។

[ ៨០ ] បទថា **អាសវា** បានដល់ កិលេសទាំងឡាយ ។ បទថា **ន កុក្កុច្ចាយិតព្វំ កុក្កុច្ចាយតិ** សេចក្តីថា រមែងប្រព្រឹត្តរង្កៀសវត្ថុ ដែលមិនគួររង្កៀស ដូចជាភិក្ខុបានសាច់ជ្រូក ហើយប្រព្រឹត្តរង្កៀសថា ជាសាច់ខ្លាឃ្មុំ បានសាច់ម្រឹគ ហើយប្រព្រឹត្តរង្កៀសថា ជាសាច់ខ្លាដំបង កាលនៃកត្តនៅមាន ប្រព្រឹត្តរង្កៀសថា កាលមិនមាន មិនត្រូវហាម តែប្រព្រឹត្តរង្កៀសថា អញត្រូវហាមហើយ កាលធូលីមិនទាន់ធ្លាក់ទៅក្នុងបាត្រ ប្រព្រឹត្តរង្កៀសថា ធូលីធ្លាក់ទៅហើយ កាលគេមិនទាន់ធ្វើសាច់ ឬត្រីឧទ្ទិសចំពោះខ្លួន ក៏ប្រព្រឹត្តរង្កៀសថា គេធ្វើសាច់ ឬត្រីឧទ្ទិសចំពោះអញ ។

បទថា **កុក្កុច្ចាយិតព្វំ ន កុក្កុច្ចាយតិ** សេចក្តីថា មិនប្រព្រឹត្តរង្កៀសនូវវត្ថុដែលគួរប្រព្រឹត្តរង្កៀស ដូចជាភិក្ខុបានសាច់ខ្លាឃ្មុំហើយ មិនប្រព្រឹត្តរង្កៀសថា ជាសាច់ជ្រូក ។បេ។ កាលគេធ្វើត្រីសាច់ឧទ្ទិសចំពោះខ្លួន ក៏មិនប្រព្រឹត្តរង្កៀសថា គេធ្វើត្រីសាច់ឧទ្ទិសចំពោះអញ ។

ឯក្នុងអដ្ឋកថាអង្គុត្តរនិកាយ លោកពោលពាក្យមានប្រមាណប៉ុណ្ណេះថា បទថា **ន កុក្កុច្ចាយិតព្វំ** បានដល់ ការមិនតាំងទុក ការមិនពិចារណានូវចំណែកដែលជារបស់សង្ឃ ឈ្មោះថា ដែលបុគ្គលណាមួយមិនគប្បីរង្កៀស ក៏រង្កៀសនូវវត្ថុនោះ ។ បទថា **ន កុក្កុច្ចាយិតព្វំ** សេចក្តីថា ការតាំងទុក

ការពិចារណានូវវត្ថុដែលជារបស់សង្ឃនោះឯង ក៏មិនវៀរសរបស់នោះ ។

[ ៨១ ] បទថា **ឥមេសំ** សេចក្តីថា អាសវៈទាំងឡាយ រមែងចម្រើនពិតប្រាកដដល់បុគ្គលទាំង ២ ពួកនេះ ទាំងក្នុងពេលថ្ងៃ ទាំងក្នុងពេលយប់ ដូចស្មៅ និងវល្លិជាដើម ចម្រើនដុះដាលក្នុងភូមិភាគដែលល្អ ។ ក្នុងធម៌សបណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះថា ភិក្ខុណាបានសាច់ម្រឹគ ដែលសមគួរហើយ ក៏ទទួលយកដោយគិតថា សាច់ដែលសមគួរនោះឯង ឈ្មោះថា មិនប្រព្រឹត្តវៀរសក្នុងវត្ថុដែលមិនគួរវៀរស ។

[ ៨២ ] បទថា **ហីនាធិមុត្តោ** បានដល់ បុគ្គលមានអធ្យាស្រ័យអាក្រក់ ។ បទថា **ទុស្សីលោ** បានដល់ ដែលមិនមានសីល ។ បទថា **បាបធម្មោ** បានដល់ ដែលមានធម៌លាមក ។ បទថា **បណីតាធិមុត្តោ** បានដល់ មានអធ្យាស្រ័យប្រណីត ។ បទថា **កល្យាណធម្មោ** បានដល់ ដែលមានធម៌ចម្រើន គឺមានធម៌ស្អាត មានធម៌ល្អ ។

[ ៨៣ ] បទថា **តិណ្ណោ** បានដល់ ឆ្លងគ្រប់គ្រាន់ហើយ គឺដល់ទីបំផុតហើយ ។

បទថា **តារេតា** បានដល់ ដែលធ្វើបុគ្គលដទៃឲ្យឆ្លងផង ។

ក្នុងបទនេះថា **បច្ចេកសម្ពុទ្ធា យេ ច តថាគតសាវកា** គប្បីជ្រាបពាក្យអធិប្បាយថា ព្រះបច្ចេកពុទ្ធទាំងឡាយ លោកឆ្លងហើយ គឺបរិបូរណ៌ហើយដោយលោកុត្តរធម៌ទាំង ៩ ប្រការ តែមិនអាចឲ្យបុគ្គលពួកដទៃឆ្លងបាន ព្រោះថា សត្វទាំងឡាយត្រាស់ដឹងធម៌ដោយធម្មកថារបស់ព្រះបច្ចេកពុទ្ធ

ទាំងឡាយនោះមិនមាន តែទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងធម៌ដោយធម្មកថានៃសាវ័កទាំងឡាយ ប្រមាណមិនបាន ព្រោះថា សាវ័កទាំងឡាយនោះ កាលសម្ដែងធម៌ មិនបានសម្ដែងឲ្យជាពាក្យរបស់ខ្លួន តែសម្ដែងធម្មកថាធ្វើឲ្យជាពាក្យរបស់ព្រះពុទ្ធទាំងឡាយ សូម្បីបរិស័ទដែលអង្គុយប្រជុំគ្នាដើម្បីស្ដាប់ធម៌ ក៏ធ្វើសេចក្ដីគោរពថា ភិក្ខុរូបនេះមិនបានសម្ដែងធម៌ដែលខ្លួនឯងចាក់ធ្លុះហើយ រមែងពោលធម៌ ដែលព្រះពុទ្ធទាំងឡាយ ត្រាស់ដឹងហើយ ព្រោះហេតុនោះ ទើបការធ្វើសេចក្ដីកោតក្រែង មានដល់ព្រះពុទ្ធទាំងឡាយនោះឯង ។ បណ្ដាបុគ្គលទាំងឡាយនោះ ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះឈ្មោះថា ញុំាងគេឲ្យឆ្អែតផង ដោយប្រការដូច្នេះ ដូចកាលព្រះរាជាត្រាស់ថា ចូរអ្នកទាំងឡាយឲ្យរបស់នេះ និងរបស់នេះ ដល់បុគ្គលឈ្មោះនោះ រាជបុរសនាំរបស់មកហើយ ឲ្យដល់បុគ្គលឈ្មោះនោះ ក៏ពិត តែព្រះរាជាប៉ុណ្ណោះឈ្មោះថា ជាអ្នកឲ្យរបស់នោះ ជនទាំងឡាយពួកណា បានរបស់នោះហើយ ជនទាំងនោះ រមែងទទួលយកដោយគិតថា ឋានន្តរដែលព្រះរាជាព្រះរាជទានហើយដល់អញ សម្បត្តិ គឺឥស្សរិយយស ដែលព្រះរាជាទ្រង់ព្រះរាជទានហើយដល់អញដូច្នេះក៏ដូចគ្នា តែមិនបានកាន់យកដោយគិតថា ឋានន្តរជាដើមដែលរាជបុរសទាំងឡាយ ឲ្យដល់ពួកយើងយ៉ាងណា សេចក្ដីឧបមាជាគ្រឿងញុំាងឧបមេយ្យ ឲ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយដោយប្រការដូច្នេះឯង ៕

**អដ្ឋកថាខុទ្ទកនិទ្ទេស ចប់**

# អភិធម្មបិដក

## តិកនិទ្ទេស

[ ៨៤ ] បុគ្គលមិនមានបំណង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌លាមក មានមារយាទ គឺបុគ្គលគប្បីរឭកដោយសេចក្តីរង្កៀស ដោយអំពើមិនស្អាត បិទបាំងអំពើមិនមែនសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនព្រហ្មចារី ប្តេជ្ញាខ្លួនថាជាព្រហ្មចារី ជាអ្នកស្អុយក្នុង មានចិត្តទទឹកដោយរាគៈ ជ្រោកជ្រាកដោយកិលេស បុគ្គលនោះបានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងបានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ នេះហៅថា បុគ្គលមិនមានបំណង ។ បុគ្គលអ្នកមានបំណង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ បុគ្គលនោះ បានឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងបានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅ

នៃអាសវៈទាំងឡាយ នេះហៅថា បុគ្គលអ្នកមានបំណង ។ បុគ្គលអ្នកប្រាស ចាកបំណង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះ ឮ ដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលនោះ មិនមានសេចក្ដីត្រិះរិះយ៉ាង នេះថា កាលណាហ្ន៎ អាត្មាអញនឹងបានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយ ប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិន មានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ។ ដំណើរនោះ តើព្រោះ ហេតុអ្វី ។ ព្រោះថា បំណងក្នុងវិមុត្តិរបស់បុគ្គលនោះ ដែលមានចិត្តមិនទាន់ រួចស្រឡះចាកអាសវៈក្នុងកាលមុន បំណងនោះ ក៏ស្ងប់រម្ងាប់ទៅ នេះហៅ ថា បុគ្គលប្រាសចាកបំណង ។

[ ៨៥ ] បណ្ដាបុគ្គលទាំងនោះ បុគ្គល ៣ ពួក ប្រៀបដោយបុគ្គលឈឺ តើដូចម្ដេច ។ បុគ្គលឈឺមាន ៣ ពួក គឺបុគ្គលឈឺខ្លះ ក្នុងលោកនេះ ទោះ បាននូវភោជនជាទីសប្បាយក្ដី មិនបាននូវភោជនជាទីសប្បាយក្ដី ទោះបាន នូវភេសជ្ជៈជាទីសប្បាយក្ដី មិនបាននូវភេសជ្ជៈជាទីសប្បាយក្ដី ទោះបាននូវ ឧបដ្ឋាកដ៏សមគួរក្ដី មិនបាននូវឧបដ្ឋាកដ៏សមគួរក្ដី ក៏នៅតែមិនសះស្បើយ ចាកអាពាធនោះ ១ ។ មួយទៀត បុគ្គលឈឺខ្លះ ក្នុងលោកនេះ ទោះបាននូវ

ភោជនជាទីសប្បាយក្តី មិនបាននូវភោជនជាទីសប្បាយក្តី ទោះបាននូវភេសជ្ជៈជាទីសប្បាយក្តី មិនបាននូវភេសជ្ជៈជាទីសប្បាយក្តី ទោះបាននូវឧបដ្ឋាកដ៏សមគួរក្តី មិនបាននូវឧបដ្ឋាកដ៏សមគួរក្តី ក៏សះស្បើយចាកអាពាធនោះបាន ១ ។ មួយទៀត បុគ្គលឈឺខ្លះ ក្នុងលោកនេះ លុះតែបាននូវភោជនជាទីសប្បាយ មិនមែនជាមិនបានទេ បាននូវភេសជ្ជៈជាទីសប្បាយ មិនមែនជាមិនបានទេ បាននូវឧបដ្ឋាកដ៏សមគួរ មិនមែនជាមិនបានទេ ទើបសះស្បើយចាកអាពាធនោះបាន ១ ។ បណ្តាបុគ្គលឈឺទាំងបីពួកនោះ បុគ្គលឈឺណាលុះតែបាននូវភោជនជាទីសប្បាយ មិនមែនជាមិនបានទេ បាននូវភេសជ្ជៈជាទីសប្បាយ មិនមែនជាមិនបានទេ បាននូវឧបដ្ឋាកដ៏សមគួរ មិនមែនជាមិនបានទេ ទើបសះស្បើយចាកអាពាធនោះបាន ព្រោះអាស្រ័យបុគ្គលឈឺនេះហើយ បានជាព្រះមានព្រះភាគ ទ្រង់អនុញ្ញាតគិលានភត្ត ទ្រង់អនុញ្ញាតគិលានភេសជ្ជៈ ទ្រង់អនុញ្ញាតគិលានុបដ្ឋាក មួយទៀត ព្រោះអាស្រ័យបុគ្គលឈឺនេះឯង សូម្បីបុគ្គលឈឺឯទៀត ក៏បុគ្គលគួរបម្រើដែរ ។

[ ៨៦ ] បុគ្គល ៣ ពួក ប្រៀបដោយបុគ្គលឈឺ រមែងមានក្នុងលោកក៏យ៉ាងនោះដែរ ។ បុគ្គល ៣ ពួក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ទោះបានឃើញព្រះតថាគតក្តី មិនបានឃើញព្រះតថាគតក្តី ទោះបានស្តាប់ធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយក្តី មិនបានស្តាប់ធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយក្តី ក៏នៅតែមិនបានត្រាច់ចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយឡើយ ។ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ទោះ

បានឃើញព្រះតថាគតក្តី មិនបានឃើញព្រះតថាគតក្តី ទោះបានស្តាប់ធម្ម-វិន័យ ដែលព្រះតថាគតសំដែងហើយក្តី មិនបានស្តាប់ធម្មវិន័យ ដែលព្រះតថាគតសំដែងហើយក្តី ក៏គង់ត្រាច់ចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយបាន ។ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ លុះតែបានឃើញព្រះតថាគត មិនមែនជាមិនបានឃើញទេ បានស្តាប់ធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ មិនមែនជាមិនបានស្តាប់ទេ ទើបត្រាច់ចុះកាន់សម្មត្តនិយាមក្នុងកុសលធម៌ទាំងឡាយបាន ។ បណ្តាបុគ្គលទាំងបីពួកនោះ បុគ្គលណាដែលលុះតែបានឃើញព្រះតថាគត មិនមែនជាមិនបានឃើញទេ បានស្តាប់ធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ មិនមែនជាមិនបានស្តាប់ទេ ទើបត្រាច់ចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយបាន ព្រោះតែអាស្រ័យនូវបុគ្គលនេះ បានជាព្រះមានព្រះភាគទ្រង់អនុញ្ញាតធម្មទេសនា មិនតែប៉ុណ្ណោះសោត ព្រោះតែអាស្រ័យបុគ្គលនេះឯង សូម្បីបុគ្គលឯទៀត ក៏ព្រះមានព្រះភាគ គួរសំដែងធម៌ដែរ ។ នេះបុគ្គល ៣ ពួក ប្រៀបដោយបុគ្គលឈឺរមែងមានក្នុងលោក ។

[ ៨៧ ] ចុះបុគ្គលជាកាយសក្ខី ( មានកាយជាបន្ទាល់ ) តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាននូវវិមោក្ខទាំង ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់រលីង ព្រោះឃើញដោយប្រាជ្ញា នេះហៅថាបុគ្គលជាកាយសក្ខី ។ បុគ្គលជាទិដ្ឋិប្បត្ត ( សម្រេចដោយទិដ្ឋិ ) តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់

តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រម្ងាប់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រម្ងាប់ទុក្ខ ឯពួកធម៌ដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះ បានឃើញច្បាស់ដោយប្រពៃ បានប្រព្រឹត្តដោយប្រពៃដោយប្រាជ្ញា ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់រលីង ព្រោះឃើញដោយប្រាជ្ញា នេះហៅថា បុគ្គលជាទិដ្ឋិប្បត្ត ។ បុគ្គលជាសទ្ធាវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ឯពួកធម៌ដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះ ក៏បានឃើញច្បាស់ដោយប្រពៃ បានប្រព្រឹត្តដោយប្រពៃ ដោយប្រាជ្ញា ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់រលីង ព្រោះឃើញដោយប្រាជ្ញា ប៉ុន្តែមិនដូចគ្នានឹងបុគ្គលជាទិដ្ឋិប្បត្តទេ នេះហៅថា បុគ្គលជាសទ្ធាវិមុត្ត ។

[ ៨៨ ] បុគ្គលមានសម្តីដូចលាមក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ទោះទៅក្នុងទីប្រជុំក្តី ទៅក្នុងបរិស័ទក្តី ទៅក្នុងកណ្តាលនៃញាតិក្តី ទៅក្នុងកណ្តាលនៃពួកសេនាក្តី ទៅក្នុងកណ្តាលនៃរាជ-ត្រកូលក្តី បើមានគេនាំទៅសួរជាសាក្សីថា នែបុរសអើយ ចូរមកអាយ អ្នកដឹងនូវហេតុណា ចូរនិយាយនូវហេតុនោះចុះ បុគ្គលនោះ កាលមិនដឹងសោះ និយាយថាដឹង ឬកាលដឹង និយាយថាមិនដឹងវិញ កាលមិនឃើញ និយាយថាឃើញ ឬកាលឃើញ និយាយថាមិនឃើញវិញ បុគ្គលជាអ្នកពោលពាក្យកុហកដោយដឹងខ្លួន ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះហៅថា បុគ្គលមានសម្តី

ដូចលាមក ។ បុគ្គលមានសម្តីដូចផ្កា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានលះបង់មុសាវាទ វៀរចាកមុសាវាទ ទោះទៅក្នុងទីប្រជុំក្តី ទៅក្នុងបរិស័ទក្តី ទៅក្នុងកណ្តាលនៃពួកញាតិក្តី ទៅក្នុងកណ្តាលនៃពួកសេនាក្តី ទៅក្នុងកណ្តាលនៃរាជត្រកូលក្តី បើមានគេនាំទៅសួរជាសាក្សីថា នែបុរសអើយ ចូរមកអាយ អ្នកដឹងនូវហេតុណា ចូរនិយាយនូវហេតុនោះចុះ បុគ្គលនោះ កាលមិនដឹង និយាយថាមិនដឹង ឬកាលដឹង និយាយថាដឹង កាលមិនឃើញ និយាយថាមិនឃើញ ឬកាលឃើញ និយាយថាឃើញ បុគ្គលមិនពោលមុសាវាទដោយដឹងខ្លួន ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃអាមិសៈបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ នេះហៅថា បុគ្គលមានសម្តីដូចផ្កា ។ បុគ្គលមានសម្តីដូចទឹកឃ្មុំ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកពោលវាចាមិនមានទោស ដែលនាំមកនូវសេចក្តីសុខដល់ត្រចៀក គួរជាទីស្រឡាញ់ពេញហឫទ័យ ជាវាចាអ្នកក្រុង ជាទីត្រេកអរនៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន នេះហៅថា បុគ្គលមានសម្តីដូចទឹកឃ្មុំ ។

[ ៨៩ ] បុគ្គលមានចិត្តប្រៀបដោយដំបៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ ច្រើនដោយការចង្អៀតចង្អល់ សូម្បីគេស្តីថាតែបន្តិចបន្តួច ក៏ខ្នក់ចិត្ត ខឹង ព្យាបាទ **ត**-តប ធ្វើសេចក្តីក្រោធ ការប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ដំបៅចាស់ដែលបុគ្គលឲ្យដល់នឹងឈើ ឬអំបែង តែងហូរទឹករងៃដោយក្រៃលែងជាងប្រមាណ យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ ច្រើនដោយសេចក្តីចង្អៀត

ចង្អល់ សូម្បីគេស្តីថាតែបន្តិចបន្តួច ក៏ខ្នាក់ចិត្ត ខឹង ព្យាបាទ **ត**-តប ធ្វើ សេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដក៏យ៉ាងនោះ ឯង នេះហៅថា បុគ្គលមានចិត្តប្រៀបដោយដំបៅ ។ បុគ្គលមានចិត្តប្រៀប ដោយផ្លេកបន្ទោរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិត ថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិត ថា នេះធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ ធម៌រម្ងត់ទុក្ខ បុរសមានចក្ខុ គប្បីឃើញនូវរូបទាំងឡាយ នាចន្លោះនៃផ្លេក-បន្ទោរ ក្នុងរាត្រីងងឹត យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់ តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់ តាមពិតថា នេះធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរ ទៅកាន់ធម៌រម្ងត់ទុក្ខក៏យ៉ាងនោះឯង នេះហៅថា បុគ្គលមានចិត្តប្រៀបដោយ ផ្លេកបន្ទោរ ។ បុគ្គលមានចិត្តប្រៀបដោយពេជ្រ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួន ឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅដូចជាកែវមណីក្តី ថ្មក្តី ឈ្មោះថា មិនដាច់បន្តិចបន្តួចដោយពេជ្រ មិនមានឡើយ យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ក៏យ៉ាងនោះ

ដែរ នេះហៅថា បុគ្គលមានចិត្តប្រៀបដោយពេជ្រ ។

[ ៩០ ] បុគ្គលខ្វាក់ តើដូចម្តេច ។ បុគ្គលគប្បីបាននូវភោគៈដែលខ្លួនមិនទាន់បាន ឬគប្បីធ្វើនូវភោគៈដែលបានហើយឲ្យកាន់តែចម្រើនឡើងដោយចក្ខុ គឺបញ្ញា មានសភាពបែបណា បុគ្គលខ្លះ ក្នុងលោកនេះ មិនមានចក្ខុមានសភាពបែបនោះផង បុគ្គលគប្បីដឹងនូវធម៌ជាកុសល និងអកុសល គប្បីដឹងនូវធម៌ដែលប្រកបដោយទោស និងមិនមានទោស គប្បីដឹងនូវធម៌ដ៏ថោកទាប និងខ្ពង់ខ្ពស់ គប្បីដឹងនូវធម៌មានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស ដោយចក្ខុ មានសភាពបែបណា បុគ្គលនោះ មិនមានចក្ខុ មានសភាពបែបនោះផងឡើយ នេះហៅថា បុគ្គលខ្វាក់ ។ បុគ្គលមានភ្នែកម្ខាង តើដូចម្តេច ។ បុគ្គលគប្បីបាននូវភោគៈដែលខ្លួនមិនទាន់បាន ឬគប្បីធ្វើនូវភោគៈដែលបានហើយឲ្យកាន់តែចម្រើនឡើងដោយចក្ខុ មានសភាពបែបណា បុគ្គលខ្លះ ក្នុងលោកនេះ មានតែចក្ខុ មានសភាពបែបនោះ បុគ្គលគប្បីដឹងនូវធម៌ជាកុសល និងអកុសល គប្បីដឹងនូវធម៌ប្រកបដោយទោស និងមិនមានទោស គប្បីដឹងនូវធម៌ដ៏ថោកទាប និងខ្ពង់ខ្ពស់ គប្បីដឹងនូវធម៌មានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស ដោយចក្ខុមានសភាពបែបណា បុគ្គលនោះ មិនមានចក្ខុ មានសភាពបែបនោះឡើយ នេះហៅថា បុគ្គលមានភ្នែកម្ខាង ។ បុគ្គលមានភ្នែកពីរ តើដូចម្តេច ។ បុគ្គលគប្បីបាននូវភោគៈដែលខ្លួនមិនទាន់បាន ឬគប្បីធ្វើនូវភោគៈដែលបានហើយ ឲ្យកាន់តែចម្រើនឡើងដោយចក្ខុ មានសភាពបែបណា បុគ្គលខ្លះ ក្នុងលោកនេះ មានចក្ខុមានសភាពបែបនោះផង បុគ្គលគប្បី

ដឹងនូវធម៌ជាកុសល និងអកុសល គប្បីដឹងនូវធម៌ប្រកបដោយទោស និងមិនមានទោស គប្បីដឹងនូវធម៌ដ៏ថោកទាប និងខ្ពង់ខ្ពស់ គប្បីដឹងនូវធម៌មានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស ដោយចក្ខុមានសភាពបែបណា បុគ្គលនោះមានចក្ខុ មានសភាពបែបនោះផង នេះហៅថា បុគ្គលមានភ្នែកពីរ ។

[ ៩១ ] បុគ្គលមានបញ្ញាដូចកាជន៍ផ្កាប់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់អារាមដើម្បីស្តាប់ធម៌ ក្នុងសម្នាក់នៃភិក្ខុរឿយៗ ពួកភិក្ខុសម្តែងធម៌មានពីរោះក្នុងបទខាងដើម មានពីរោះក្នុងបទកណ្តាល មានពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ ចំពោះបុគ្គលនោះ អង្គុយលើអាសនៈនោះ មិនធ្វើទុកក្នុងចិត្តនូវចំណែកខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះទេ បើទុកជាក្រោកចាកអាសនៈនោះហើយ ក៏មិនធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះ ដូចជាក្អមផ្កាប់ បុគ្គលយកទឹក ទៅចាក់ដាក់ក្នុងក្អមនោះតែងកំពប់ ហូរខ្ចាយចេញ ដក់នៅមិនបាន យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់អារាម ដើម្បីស្តាប់ធម៌ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ពួកភិក្ខុសម្តែងធម៌ មានពីរោះក្នុងបទខាងដើម មានពីរោះក្នុងបទកណ្តាល មានពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ចំពោះបុគ្គលនោះ បុគ្គលនោះអង្គុយ

លើអាសនៈនោះ មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល មិនធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងចុងនៃកថានោះទេ បើទុកជាក្រោកចាកអាសនៈនោះហើយ ក៏មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះ ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលមានបញ្ញាដូចភាជន៍ផ្កាប់ ។ បុគ្គលមានបញ្ញាដូចថ្នក់លេច តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ទៅកាន់អារាមដើម្បីស្តាប់ធម៌ ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ពួកភិក្ខុសម្តែងធម៌ មានពីរោះក្នុងបទខាងដើម មានពីរោះក្នុងបទកណ្តាល មានពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ ចំពោះបុគ្គលនោះ បុគ្គលនោះអង្គុយលើអាសនៈនោះ បានធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុង នៃកថានោះ តែលុះក្រោកអាសនៈនោះហើយ មិនធ្វើទុកក្នុងចិត្តនូវចំណែក ជាខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះឡើយ បុរសយកវត្ថុដែលគួរទំពាស៊ីផ្សេងៗ គឺល្ង អង្ករ នំអន្សម ផ្លែពុទ្រា ទៅដាក់ចុះក្នុងថ្នក់ កាលបុរសនោះក្រោកចាកទីអង្គុយនោះ រមែងជ្រុះខ្ចាត់ខ្ចាយព្រោះតែភ្លេចស្មារតី យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ តែងទៅកាន់អារាមដើម្បីស្តាប់ធម៌ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ដែរ ពួកភិក្ខុសម្តែងធម៌ មានពីរោះក្នុងបទខាងដើម មានពីរោះក្នុងបទកណ្តាល មាន

ពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ចំពោះបុគ្គលនោះ បុគ្គលនោះអង្គុយលើអាសនៈនោះ បានធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះ តែលុះក្រោកអាសនៈហើយ មិនធ្វើទុកក្នុងចិត្តនូវចំណែកខាងដើម មិនធ្វើទុកក្នុងចិត្តនូវចំណែកកណ្តាល មិនធ្វើទុកក្នុងចិត្តនូវចំណែកខាងចុងនៃកថានោះឡើយ ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលមានបញ្ញាដូចជាថ្នក់លេច ។ បុគ្គលមានបញ្ញាក្រាស់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់អារាមដើម្បីស្តាប់ធម៌ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ពួកភិក្ខុសម្តែងធម៌ មានពីរោះក្នុងបទខាងដើម មានពីរោះក្នុងបទកណ្តាល មានពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ចំពោះបុគ្គលនោះ បុគ្គលនោះអង្គុយលើអាសនៈនោះ ក៏តែងធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះផង លុះក្រោកអាសនៈនោះហើយ ក៏តែងធ្វើទុកក្នុងចិត្តនូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះផង ក្អមផ្ងារ បុគ្គលយកទឹកទៅចាក់ដាក់ក្នុងក្អមនោះ ( ទឹក ) ក៏ដក់នៅ មិនកំពប់ខ្ចាយចេញឡើយ យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ទៅកាន់អារាមដើម្បីស្តាប់ធម៌ក្នុងសម្នាក់នៃពួកភិក្ខុរឿយៗ ពួកភិក្ខុសម្តែងធម៌ មានពីរោះក្នុងបទខាងដើម មានពីរោះ

ក្នុងបទកណ្តាល មានពីរោះក្នុងបទខាងចុង ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ប្រកាសនូវព្រហ្មចរិយៈដ៏បរិបូណ៌ បរិសុទ្ធសព្វគ្រប់ចំពោះបុគ្គលនោះ បុគ្គលនោះ អង្គុយលើអាសនៈនោះ តែងធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្តនូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្តនូវចំណែកជាខាងចុងនៃកថានោះផង លុះក្រោកចាកអាសនៈនោះហើយ តែងធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងដើម ធ្វើទុកក្នុងចិត្ត នូវចំណែកជាកណ្តាល ធ្វើទុកក្នុងចិត្ត នូវចំណែកជាខាងចុងនៃកថានោះផង ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលមានបញ្ញាក្រាស់ ។

[ ៩២ ] បុគ្គលមិនទាន់ប្រាសចាកតម្រេក ក្នុងកាម និងភព តើដូចម្តេច ។ បុគ្គលជាសោតាបន្ន និងសកទាគាមី នេះហៅថា បុគ្គលមិនទាន់ប្រាសចាកតម្រេកក្នុងកាម និងភព ។ បុគ្គលដែលប្រាសចាកតម្រេកក្នុងកាម តែមិនទាន់ប្រាសចាកតម្រេកក្នុងភព តើដូចម្តេច ។ បុគ្គលជាអនាគាមី នេះហៅថា បុគ្គលប្រាសចាកតម្រេកក្នុងកាម តែមិនទាន់ប្រាសចាកតម្រេកក្នុងភព ។ បុគ្គលប្រាសចាកតម្រេក ក្នុងកាមផង ក្នុងភពផង តើដូចម្តេច ។ បុគ្គលជាព្រះអរហន្ត នេះហៅថា បុគ្គលប្រាសចាកតម្រេកក្នុងកាមផង ក្នុងភពផង ។

[ ៩៣ ] បុគ្គលប្រៀបដោយគំនូសថ្ម តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ក្រោធរឿយៗ ឯសេចក្តីក្រោធនោះ របស់បុគ្គលនោះសោត តែងដេកត្រាំនៅអស់កាលយូរអង្វែង គំនូសថ្មមិនងាយរលុបបាត់ដោយខ្យល់ ឬទឹកឡើយ ជាគំនូសតែងស្ថិតនៅអស់កាលជាយូរអង្វែង យ៉ាងណាមិញ បុគ្គលខ្លះ ក្នុង

លោកនេះ ក្រោធរឿយៗ ឯសេចក្តីក្រោធនោះ របស់បុគ្គលនោះសោត តែង ដេកត្រាំនៅអស់កាលយូរអង្វែង ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលប្រៀប ដោយគំនូសថ្ម ។ បុគ្គលប្រៀបដោយគំនូសដី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុង លោកនេះ ក្រោធរឿយៗ តែសេចក្តីក្រោធនោះ របស់បុគ្គលនោះ មិនបាន ដេកត្រាំនៅ អស់កាលយូរអង្វែងឡើយ គំនូសដី តែងឆាប់រលុបទៅ ដោយ ខ្យល់ ឬទឹក ជាគំនូសមិនស្ថិតនៅអស់កាលជាយូរអង្វែង យ៉ាងណាមិញ បុគ្គល ខ្លះ ក្នុងលោកនេះ ក្រោធរឿយៗ តែសេចក្តីក្រោធនោះ របស់បុគ្គលនោះ មិន ដេកត្រាំនៅអស់កាលយូរអង្វែងឡើយ ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គល ប្រៀបដោយគំនូសដី ។ បុគ្គលប្រៀបដោយគំនូសទឹក តើដូចម្តេច ។ បុគ្គល ខ្លះ ក្នុងលោកនេះ ទុកជាគេនិយាយដោយពាក្យដ៏រឹងរូសក្តី ទុកជាគេនិយាយ ពាក្យអាក្រក់ក្តី ទុកជាគេនិយាយដោយពាក្យមិនជាទីគាប់ចិត្តក្តី ក៏នៅតែ ស្រស់ស្រាយផង រីករាយផង រួសរាយផង គំនូសទឹកតែងឆាប់រលុបទៅ ជាគំនូសមិនស្ថិតនៅ អស់កាលជាយូរអង្វែង យ៉ាងណាមិញ បុគ្គលខ្លះ ក្នុង លោកនេះ ទុកជាគេនិយាយដោយពាក្យដ៏រឹងរូសក្តី ទុកជាគេនិយាយដោយ ពាក្យអាក្រក់ក្តី ទុកជាគេនិយាយ ដោយពាក្យមិនជាទីពេញចិត្តក្តី ក៏នៅតែ ស្រស់ស្រាយផង រីករាយផង រួសរាយផង ក៏យ៉ាងនោះដែរ នេះហៅថា បុគ្គលប្រៀបដោយគំនូសទឹក ។

[ ៩៤ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៣ ពួក ប្រៀបដោយសំពត់ សម្បកឈើ តើដូចម្តេច ។ សំពត់សម្បកឈើ មាន ៣ យ៉ាង គឺសំពត់

សម្បកឈើនៅថ្មី ជាសំពត់មានពណ៌អាក្រក់ផង មានសម្ផស្សរឹងផង មានតម្លៃតិចផង ១ សំពត់សម្បកឈើជាកណ្ដាល ជាសំពត់មានពណ៌អាក្រក់ផង មានសម្ផស្សរឹងផង មានតម្លៃតិចផង ១ សំពត់សម្បកឈើចាស់ ជាសំពត់មានពណ៌អាក្រក់ផង មានសម្ផស្សរឹងផង មានតម្លៃតិចផង ១ ។ ពួកជនតែងយកសំពត់សម្បកឈើដែលចាស់ ទៅជូតឆ្នាំង ឬយកសំពត់សម្បកឈើចាស់នោះ ទៅចោលលើគំនរសំរាម ។

[ ៩៥ ] បុគ្គល ៣ ពួក ប្រៀបដោយសំពត់សម្បកឈើនេះ រមែងមានក្នុងពួកភិក្ខុក៏យ៉ាងនោះឯង ។ បុគ្គល ៣ ពួក តើដូចម្ដេច ។ ប្រសិនបើភិក្ខុថ្មី ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក អំពើនេះព្រោះភិក្ខុនោះមានពណ៌ គឺសីលអាក្រក់ សំពត់សម្បកឈើនោះ មានពណ៌អាក្រក់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ បើពួកជនណាមួយទៅសេពគប់ ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិ របស់បុគ្គលនោះ ការសេពនោះ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាយូរអង្វែងដល់ជនទាំងនោះ អំពើនេះ ព្រោះបុគ្គលនោះ មានសម្ផស្សជាទុក្ខ សំពត់សម្បកឈើនោះ មានសម្ផស្សរឹង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ បុគ្គលនេះ បើទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនពួកណា ការទទួលនោះ ជាអំពើមិនមានផលច្រើន មិនមានអានិសង្សច្រើនដល់ជនពួកនោះឡើយ អំពើនេះព្រោះបុគ្គលនោះ មានតម្លៃតិច សំពត់សម្បកឈើ

មានតម្លៃតិច មានឧបមាយ៉ាងណាមិញ បុគ្គលនេះ មានឧបមេយ្យយ៉ាងនោះដែរ បើភិក្ខុជាកណ្តាល ។បេ។ បើភិក្ខុជាថេរៈ តែជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក អំពើនេះព្រោះភិក្ខុនោះមានពណ៌ គឺសីលអាក្រក់ សំពត់សម្បកឈើមានពណ៌អាក្រក់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ បើពួកជនណាមួយសេពគប់ ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលនោះ ការសេពនោះ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ដល់ជនពួកនោះ អំពើនេះ ព្រោះបុគ្គលនោះ មានសម្ផស្សជាទុក្ខ សំពត់សម្បកឈើ មានសម្ផស្សរឹងនោះ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ បុគ្គលនេះបើទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខាររបស់ជនពួកណា ការទទួលនោះ តែងមិនមានផលច្រើន មិនមានអានិសង្សច្រើន ដល់ជនពួកនោះ អំពើនេះ ព្រោះបុគ្គលនោះមានតម្លៃតិច សំពត់សម្បកឈើមានតម្លៃតិចនោះ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ប្រសិនបើភិក្ខុជាថេរៈ មានសភាពយ៉ាងនេះ និយាយកណ្តាលជំនុំសង្ឃ ពួកភិក្ខុ នាំគ្នានិយាយយ៉ាងនេះនឹងភិក្ខុជាថេរៈនោះថា ប្រយោជន៍អ្វីដោយពាក្យដែលលោកជាមនុស្សល្ងង់ មិនឈ្លាសពោលហើយ លោកសម្គាល់នូវពាក្យដែលគេគប្បីពោលចុះ ភិក្ខុនោះ ក៏ខឹងអន់ចិត្ត ( បើ ) សង្ឃលើកទោសដោយវាចា មានសភាពយ៉ាងណា ក៏បញ្ចេញនូវវាចា មានសភាពយ៉ាងនោះ ដូចជាសំពត់សម្បកឈើ ដែលគេ

បោលលើគំនរសំរាម ។ នេះបុគ្គល ៣ ពួក ប្រៀបដោយសំពត់សម្បកឈើ រមែងមានក្នុងពួកភិក្ខុ ។

[ ៩៦ ] បណ្ដាបុគ្គលទាំងនោះ បុគ្គល ៣ ពួក ប្រៀបដោយសំពត់កាសិកៈ តើដូចម្ដេច ។ សំពត់កាសិកៈមាន ៣ យ៉ាង គឺសំពត់កាសិកៈថ្មី ជាសំពត់មានពណ៌ល្អផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង ១ សំពត់កាសិកៈជាកណ្ដាល ជាសំពត់មានពណ៌ល្អផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង ១ សំពត់កាសិកៈចាស់ ជាសំពត់មានពណ៌ល្អផង មានសម្ផស្សទន់ផង មានតម្លៃច្រើនផង ១ ពួកជនតែងយកសំពត់កាសិកៈដែលចាស់ហើយ ធ្វើជាសំពត់សម្រាប់វេចកែវបាន ឬតម្កល់ទុកនូវសំពត់នោះក្នុងទូ សម្រាប់ដាក់នូវគ្រឿងក្រអូប ។

[ ៩៧ ] បុគ្គល ៣ ពួក ប្រៀបដោយសំពត់កាសិកៈនេះ រមែងមានក្នុងពួកភិក្ខុក៏យ៉ាងនេះឯង ។ បុគ្គល ៣ ពួក តើដូចម្ដេច ។ ប្រសិនបើភិក្ខុបួសថ្មី ជាអ្នកមានសីល មានកល្យាណធម៌ អំពើនេះ ព្រោះភិក្ខុនោះ មានពណ៌ គឺសីលល្អ សំពត់កាសិកៈនោះ មានពណ៌ល្អ មានឧបមាយ៉ាងណា បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ បើពួកជនណាមួយ សេពគប់ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលនោះ ការសេពគប់ជាដើមនោះ តែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនពួកនោះ អស់កាលជាយូរអង្វែង អំពើនេះ ព្រោះបុគ្គលនោះ មានសម្ផស្សជាសុខ សំពត់កាសិកៈនោះមានសម្ផស្សទន់ មានឧបមាយ៉ាងណា

មិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ បុគ្គលនេះ បើទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ជនពួកណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ជនពួកនោះ អំពើនេះ ព្រោះបុគ្គលនោះ មានតម្លៃច្រើន សំពត់កាសិកៈនោះ មានតម្លៃច្រើន មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ បើភិក្ខុជាកណ្តាល ។បេ។ បើភិក្ខុជាថេរៈមានសីល មានកល្យាណធម៌ អំពើនេះ ព្រោះភិក្ខុនោះមានពណ៌ គឺសីលល្អ សំពត់កាសិកៈនោះ មានពណ៌ល្អ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ បើពួកជនណាមួយសេពគប់ ចូលទៅអង្គុយជិត តែងដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលនោះ ការសេពគប់ជាដើមនោះ តែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនពួកនោះ អស់កាលជាអង្វែង អំពើនេះ ព្រោះបុគ្គលនោះមានសម្ផស្សជាសុខ សំពត់កាសិកៈនោះ មានសម្ផស្សទន់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ បុគ្គលនេះបើទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ របស់ជនពួកណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ជនពួកនោះ អំពើនេះព្រោះបុគ្គលនោះមានតម្លៃច្រើន សំពត់កាសិកៈនោះ មានតម្លៃច្រើន មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ បើភិក្ខុជាថេរៈមានសភាពបែបនេះ និយាយក្នុងកណ្តាលជំនុំសង្ឃ ពួកភិក្ខុនាំគ្នានិយាយយ៉ាងនេះ នឹងភិក្ខុជាថេរៈនោះថា បពិត្រលោកមានអាយុ លោកជា

អ្នកមានសទ្ធាតិច ភិក្ខុជាថេរៈ ពោលនូវធម៌ផង នូវវិន័យផង ពាក្យនោះរបស់ភិក្ខុជាថេរៈនោះ គួរយកទុកដាក់ក្នុងចិត្តបាន ដូចជាសំពត់កាសិកៈ គួរយកទុកដាក់ក្នុងទូ សម្រាប់ដាក់នូវវត្ថុមានក្លិនក្រអូប ។ នេះបុគ្គល ៣ ពួក ប្រៀបដោយសំពត់កាសិកៈ រមែងមានក្នុងពួកភិក្ខុ ។

[ ៩៨ ] បុគ្គលដែលគេប្រមាណបាន ដោយងាយ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នករាយមាយ លើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចារាត់រាយ ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនតម្កល់មាំ មានចិត្តក័ន្តប្រឡំ មានឥន្ទ្រិយប្រាកដ នេះហៅថា បុគ្គលដែលគេប្រមាណបានដោយងាយ ។ បុគ្គលដែលគេប្រមាណបានដោយក្រ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនរាយមាយ មិនលើកកម្ពស់ មានចិត្តមិនឃ្លេងឃ្លោង មានមាត់មិនរឹង មានវាចាមិនរាត់រាយ មានស្មារតីតម្កល់ស៊ប់ មានសេចក្តីដឹងខ្លួន មានចិត្តតម្កល់មាំ មានចិត្តមូល ក្នុងអារម្មណ៍តែមួយ មានឥន្ទ្រិយសង្រួមហើយ នេះហៅថា បុគ្គលដែលគេប្រមាណបានដោយក្រ ។ បុគ្គលដែលគេប្រមាណមិនបាន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ នេះហៅថា បុគ្គលដែលគេប្រមាណមិនបាន ។

[ ៩៩ ] បុគ្គលដែលគេមិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយ

ជិត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកថោកទាបជាង ដោយសីល សមាធិ និងបញ្ញា បុគ្គលបែបនេះ គេមិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត វៀរលែងតែមានសេចក្តីអាណិត វៀរលែងតែមានសេចក្តីអនុគ្រោះ ។ បុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកស្មើគ្នាដោយសីល សមាធិ និងបញ្ញា បុគ្គលមានសភាពយ៉ាងនេះ គេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះសីលកថា របស់ពួកសប្បុរសដែលដល់នូវភាពស្មើគ្នាដោយសីល នឹងជាកថាកើតមានដល់ពួកយើងផង សីលកថានោះ នឹងជាទីសប្បាយនៃពួកយើងផង សីលកថានោះ នឹងប្រព្រឹត្តទៅដល់ពួកយើងផង សមាធិកថារបស់ពួកសប្បុរស ដែលដល់នូវភាពស្មើគ្នាដោយសមាធិ នឹងជាកថាកើតមានដល់ពួកយើងផង សមាធិកថានោះ នឹងជាទីសប្បាយនៃពួកយើងផង សមាធិកថានោះ នឹងប្រព្រឹត្តទៅដល់ពួកយើងផង បញ្ញាកថារបស់ពួកសប្បុរស ដែលដល់នូវភាពស្មើគ្នាដោយបញ្ញា នឹងជាកថាកើតមានដល់ពួកយើងផង បញ្ញាកថានោះ នឹងជាទីសប្បាយនៃពួកយើងផង បញ្ញាកថានោះ នឹងប្រព្រឹត្តទៅដល់ពួកយើងផង ព្រោះហេតុនោះ បុគ្គលបែបនេះ គេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ បុគ្គលដែលគួរធ្វើសក្ការៈ គោរព ហើយសេពគប់រក ចូលទៅអង្គុយជិត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះជាអ្នកច្រើនដោយសីល សមាធិ និងបញ្ញា បុគ្គលបែបនេះគេគួរធ្វើសក្ការៈ គោរព ហើយសេពគប់រក ចូល

ទៅអង្គុយជិត ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថា បុគ្គលដែលគិតថា អញនឹងបំពេញនូវសីលក្ខន្ធ ដែលមិនទាន់បរិបូណ៌ ឬនឹងអនុគ្រោះនូវសីលក្ខន្ធដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ អញនឹងបំពេញនូវសមាធិក្ខន្ធដែលមិនទាន់បរិបូណ៌ ឬនឹងអនុគ្រោះនូវសមាធិក្ខន្ធ ដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ អញនឹងបំពេញនូវបញ្ញាខន្ធ ដែលមិនទាន់បរិបូណ៌ ឬនឹងអនុគ្រោះនូវបញ្ញាខន្ធ ដែលបរិបូណ៌ហើយ ដោយបញ្ញាក្នុងទីនោះៗ ព្រោះហេតុនោះ បុគ្គលមានសភាពបែបនេះ គេគួរធ្វើសក្ការៈ គោរពហើយសេពគប់រក ចូលទៅអង្គុយជិត ។

[ ១០០ ] បុគ្គលដែលគេគួរខ្ពើម មិនគួរសេពគប់ មិនគួររាប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្ត-សីល មានធម៌ដ៏លាមក មានមារយាទ គឺបុគ្គលគប្បីរឭក ដោយសេចក្ដីរង្កៀស ដោយអំពើមិនស្អាត បិទបាំងអំពើទុក មិនមែនជាសមណៈ ប្ដេជ្ញាខ្លួនថាសមណៈ មិនមែនជាព្រហ្មចារី ប្ដេជ្ញាខ្លួនថាជាព្រហ្មចារី ជាអ្នកស្អុយក្នុង មានចិត្តទទឹកដោយរាគៈ ជ្រោកជ្រាកដោយកិលេស បុគ្គលបែបនេះគេគប្បីខ្ពើម មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថា បុគ្គលមិនដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលបែបនេះ ក៏ពិតមែនហើយ តែកិត្តិសព្ទដ៏អាក្រក់នៃបុគ្គលនោះរមែងខ្ចរខ្ចាយថា បុរសបុគ្គលនេះ មានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ ឆាកទៅរកបុគ្គលអាក្រក់ ពស់នៅក្នុងរណ្ដៅលាមក មិនចឹកស៊ី ក៏ពិតមែន

ហើយ តែលាមកគង់ប្រឡាក់នូវពស់នោះ យ៉ាងណាមិញ បុគ្គលមិនដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិរបស់បុគ្គលបែបនេះ ក៏ពិតមែនហើយ តែកិត្តិសព្ទដ៏អាក្រក់នៃបុគ្គលនោះ រមែងខ្ចរខ្ចាយថា បុរសបុគ្គលនេះ មានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ ឆាកទៅរកបុគ្គលអាក្រក់ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលបែបនេះ គេគួរខ្ពើម មិនគួរសេព មិនគប់រក មិនគួរចូលទៅអង្គុយជិត ។ បុគ្គលគេគួរសម្លឹងមើល តែមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធច្រើនដោយការចង្អៀតចង្អល់ សូម្បីតែគេស្តីថាបន្តិចបន្តួច ក៏ខ្ទក់ចិត្តខឹងព្យាបាទ ត-តប ធ្វើសេចក្តីក្រោធ ប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ដំបៅរីក ដែលបុគ្គលឲ្យជល់ដោយឈើ ឬអំបែង តែងហូរទឹករងៃដោយក្រៃលែងជាងប្រមាណយ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធច្រើនដោយសេចក្តីចង្អៀតចង្អល់ សូម្បីគេស្តីថា បន្តិចបន្តួច ក៏ខ្ទក់ចិត្តខឹងព្យាបាទ ត-តប ធ្វើសេចក្តីក្រោធ ប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ក៏យ៉ាងនោះដែរ អង្កត់ភ្លើងឧសជន្លោ ដែលគេទង្គិចដោយឈើ ឬអំបែង រមែងបែកព្រាយ ព្លប្រេះៗ ដោយក្រៃលែងជាងប្រមាណ យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ សូម្បីគេស្តីថាបន្តិចបន្តួច ក៏ខ្ទក់ចិត្តខឹង ព្យាបាទ ត-តប ធ្វើសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ក៏យ៉ាងនោះដែរ រណ្តៅលាមកដែលបុគ្គលកូរវីកដោយឈើ ឬអំបែង រមែងមានក្លិនអាក្រក់ដោយក្រៃលែង

ជាងប្រមាណ យ៉ាងណាមិញ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្ដីចង្អៀតចង្អល់ សូម្បីគេស្ដីថាបន្តិចបន្តួច ក៏ខ្ញាក់ចិត្តខឹង ព្យាបាទត-តប ធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីមិនត្រេកអរឲ្យប្រាកដក៏យ៉ាងនោះដែរ បុគ្គលបែបនេះ គេគួរសម្លឹងមើល តែមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ព្រោះថា អ្នកផងតែងគិតថា អ្នកនេះមុខជានឹងជេរអញ នឹងផ្ដាសាអញ ឬនឹងធ្វើនូវអំពើមិនជាប្រយោជន៍ដល់អញពុំខាន ព្រោះហេតុនោះ បុគ្គលបែបនេះ គេគួរសម្លឹងមើល តែមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ បុគ្គលគួរគេសេព គួរគប់រក គួរចូលទៅអង្គុយជិត តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ បុគ្គលបែបនេះ ដែលគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ បុគ្គលមិនដល់នូវការប្រព្រឹត្តតាមនូវទិដ្ឋិ របស់បុគ្គលបែបនេះ ក៏ពិតមែនហើយ តែកិត្តិសព្ទដ៏ល្អនៃបុគ្គលនោះ តែងខ្ចរខ្ចាយល្បីទៅថា បុរសបុគ្គលនេះ មានមិត្តល្អ មានសម្លាញ់ល្អ ឆាកទៅរកបុគ្គលល្អ ព្រោះហេតុនោះ បុគ្គលបែបនេះ គួរគេសេព គួរគប់រក គួរចូលទៅអង្គុយជិត ។

[ ១០១ ] បុគ្គលធ្វើឲ្យពេញលេញក្នុងសីល តែធ្វើបន្តិចបន្តួចក្នុងសមាធិ ធ្វើបន្តិចបន្តួចក្នុងបញ្ញា តើដូចម្ដេច ។ បុគ្គលជាសោតាបន្ន និងសកទាគាមីនេះហៅថា បុគ្គលធ្វើឲ្យពេញលេញក្នុងសីល តែធ្វើបន្តិចបន្តួចក្នុងសមាធិ ធ្វើបន្តិចបន្តួចក្នុងបញ្ញា ។ បុគ្គលធ្វើពេញលេញក្នុងសីលផង ធ្វើពេញលេញ

ក្នុងសមាធិផង តែធ្វើបន្តិចបន្តួចក្នុងបញ្ញា តើដូចម្តេច ។ បុគ្គលជាអនាគាមី នេះហៅថា បុគ្គលធ្វើពេញលេញក្នុងសីលផង ធ្វើពេញលេញក្នុងសមាធិផង តែធ្វើបន្តិចបន្តួចក្នុងបញ្ញា ។ បុគ្គលធ្វើពេញលេញក្នុងសីលផង ធ្វើពេញលេញក្នុងសមាធិផង ធ្វើពេញលេញក្នុងបញ្ញាផង តើដូចម្តេច ។ បុគ្គលជាព្រះអរហន្ត នេះហៅថា បុគ្គលធ្វើពេញលេញក្នុងសីលផង ធ្វើពេញលេញក្នុងសមាធិផង ធ្វើពេញលេញក្នុងបញ្ញាផង ។

[ ១០២ ] បណ្តាបុគ្គលទាំងនោះ បុគ្គលជាគ្រូ ៣ ពួក តើដូចម្តេច ។ គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តនូវការកំណត់កាម មិនបញ្ញត្តនូវការកំណត់រូប មិនបញ្ញត្តនូវការកំណត់វេទនា គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តនូវការកំណត់កាមផង បញ្ញត្តនូវការកំណត់រូបផង តែមិនបញ្ញត្តនូវការកំណត់វេទនា គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តនូវការកំណត់កាមផង បញ្ញត្តនូវការកំណត់រូបផង បញ្ញត្តនូវការកំណត់វេទនាផង ។ បណ្តាគ្រូទាំងនោះ គ្រូណា បញ្ញត្តនូវការកំណត់កាម តែមិនបញ្ញត្តនូវការកំណត់រូប មិនបញ្ញត្តនូវការកំណត់វេទនា បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) បានទូវរូបាវចរសមាបត្តិដោយការបញ្ញត្តនោះ ។ បណ្តាគ្រូទាំងនោះ គ្រូណា ដែលបញ្ញត្តនូវការកំណត់កាមផង បញ្ញត្តនូវការកំណត់រូបផង តែមិនបញ្ញត្តនូវការកំណត់វេទនា បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) បានទូវអរូបាវចរសមាបត្តិដោយការបញ្ញត្តនោះ ។ បណ្តាគ្រូទាំងនោះ គ្រូណា បញ្ញត្តនូវការកំណត់កាមផង បញ្ញត្តនូវការកំណត់រូបផង បញ្ញត្តនូវការកំណត់វេទនាផង បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) ជាព្រះសម្មា-

សម្ពុទ្ធដោយការបញ្ញត្តនោះ ។ នេះបុគ្គលជាគ្រូមានបីពួក ។

[ ១០៣ ] បណ្តាបុគ្គលទាំងនោះ បុគ្គលជាគ្រូ ៣ ពួកដោយឡែកទៀត តើដូចម្តេច ។ គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្នថាទៀង ថាមាំមួនផង បញ្ញត្តនូវខ្លួនក្នុងបរលោកថាទៀង ថាមាំមួនផង គ្រូខ្លះ ក្នុងលោកនេះ បញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្នថាទៀង ថាមាំមួន តែមិនបញ្ញត្តនូវខ្លួនក្នុងបរលោកថាទៀង ថាមាំមួនឡើយ គ្រូខ្លះ ក្នុងលោកនេះ មិនបញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្នថាទៀង ថាមាំមួនផង មិនបញ្ញត្តនូវខ្លួនក្នុងបរលោកថាទៀង ថាមាំមួនផង ។ បណ្តាគ្រូទាំងនោះ គ្រូណា បញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្ន ថាទៀង ថាមាំមួនផង បញ្ញត្តនូវខ្លួនក្នុងបរលោក ថាទៀង ថាមាំមួនផង បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) ជាសស្សតវាទ ( អ្នកពោលថាទៀង ) ដោយការបញ្ញត្តនោះ ។ បណ្តាគ្រូទាំងនោះ គ្រូណា បញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្នថាទៀង ថាមាំមួន តែមិនបញ្ញត្តនូវខ្លួនក្នុងបរលោកថាទៀង ថាមាំមួនឡើយ បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) ជាឧច្ឆេទវាទ ( អ្នកពោលថាសូន្យ ) ដោយការបញ្ញត្តនោះ ។ បណ្តាគ្រូទាំងនោះ គ្រូណា មិនបញ្ញត្តនូវខ្លួនក្នុងបច្ចុប្បន្នថាទៀង ថាមាំមួនផង មិនបញ្ញត្តនូវខ្លួនក្នុងបរលោកថាទៀង ថាមាំមួនផង បណ្ឌិតគប្បីយល់ថា គ្រូ ( នោះ ) ជាព្រះសម្មាសម្ពុទ្ធ ដោយការបញ្ញត្តនោះ ។ នេះគ្រូ ៣ ពួកដោយឡែកទៀត ។

# អដ្ឋកថា

## តិកនិទ្ទេស

[ ៨៤ ] ក្នុងតិកនិទ្ទេស គប្បីជ្រាបដូចតទៅនេះ បទថា **ទុស្សីលោ** បានដល់ ជាអ្នកមិនមានសីល ។ បទថា **ចាបធម្មោ** បានដល់ មានធម៌ដ៏លាមក ម្យ៉ាងទៀត ឈ្មោះថា **ទុស្សីលោ** ព្រោះការវិបត្តិនៃសីល ឈ្មោះថា **ចាបធម្មោ** ព្រោះការវិបត្តិនៃទិដ្ឋិ ។ ម្យ៉ាងទៀត ឈ្មោះថា **ទុស្សីលោ** ព្រោះដាច់នូវការសង្រួម តាមកាយទ្វារ និងវចីទ្វារ ឈ្មោះថា **ចាបធម្មោ** ព្រោះដាច់នូវការសង្រួមតាមមនោទ្វារ ។ ឈ្មោះថា **ទុស្សីលោ** ព្រោះភាពជាបុគ្គលប្រកបដោយការងារដែលមិនស្អាត ។ ឈ្មោះថា **ចាបធម្មោ** ព្រោះភាពជាអ្នកមានអធ្យាស្រ័យមិនស្អាត ។ ឈ្មោះថា **ទុស្សីលោ** ព្រោះវៀរចាកកុសលសីល ឈ្មោះថា **ចាបធម្មោ** ព្រោះប្រកបដោយអកុសលសីល ។

បទថា **អសុចិ** បានដល់ ដែលប្រកបដោយកម្ម ដែលមិនស្អាតទាំងឡាយ មានកាយកម្មជាដើម ។ បទថា **សង្កស្សរសមាចារោ** បានដល់ ជាអ្នកមានសមាចារដែលអ្នកដទៃ គប្បីរឭកបានដោយការសង្ស័យ អធិប្បាយថា ដែលមានសមាចារដែលអ្នកដទៃ ឃើញទោសណាមួយដែលមិនសមគួរ ហើយសង្ស័យ យ៉ាងនេះថា កម្មនេះ នឹងជារបស់ភិក្ខុនេះធ្វើហើយ ឬមានសមាចារដែលខ្លួនគប្បីរឭកបាន ដោយការរង្កៀសរបស់ខ្លួននោះឯង ឈ្មោះថា អ្នកមានសមាចារដែលគួរសង្ស័យ ។ កាលឃើញពួកភិក្ខុប្រជុំ ឬប្រឹក្សាដល់កិច្ចណាមួយនោះឯង ក្នុងទីជាទីសម្រាកក្នុងពេលថ្ងៃជាដើម បុគ្គលមាន

សមាចារដែលគួររង្កៀសសង្ស័យយ៉ាងនេះថា ពួកភិក្ខុទាំងនោះ ដឹងកម្មដែល អញធ្វើឬ ទើបប្រឹក្សាគ្នា ។ បទថា **បដិច្ឆន្នកម្មន្តោ** បានដល់ ដែលប្រកប ដោយធម៌ដ៏លាមក ដែលសមគួរដល់ការបិទបាំង ។ បទថា **អស្សមណោ សមណបដិញ្ញោ** សេចក្ដីថា បុគ្គលមិនបានជាសមណៈ តែប្ដេជ្ញាយ៉ាងនេះ ថា អញជាសមណៈ ព្រោះជាសមណៈក្លែងក្លាយ ។ បទថា **អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ** សេចក្ដីថា ឃើញសព្រហ្មចារី ស្លៀកដណ្ដប់រៀបរយ ទ្រទ្រង់នូវបាត្រ ស្អាតបាតត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងស្រុក និគម ជនបទ និងរាជធានីទាំងឡាយ ហើយសម្រេចការចិញ្ចឹមជីវិត ខ្លួនឯងក៏បដិបត្តិដូច្នោះ ដោយអាការបែបនោះ រមែងដូចឲ្យប្ដេជ្ញាថាខ្ញុំជាព្រហ្មចារី ។ កាលគេពោល ថា ខ្ញុំជាភិក្ខុ ហើយចូលទៅកាន់រោងឧបោសថជាដើម រមែងប្ដេជ្ញាថា ខ្លួនជា ព្រហ្មចារីបុគ្គលនោះឯង ។ កាលកាន់យកលាភរបស់សង្ឃ ក៏បដិបត្តិយ៉ាង នោះ ។

បទថា **អន្តោបូតិ** បានដល់ បុគ្គលដែលមានកម្មស្អុយចូលទៅខាងក្នុង ម្យ៉ាងទៀត ឈ្មោះថា ជាអ្នកស្អុយក្នុង ព្រោះវៀរចាកគុណសារៈ ដោយ ភាពជាអ្នកមិនមានគុណ ។

បទថា **អវស្សុតោ** បានដល់ ដែលរាគៈជាដើម ធ្វើឲ្យទទឹកហើយ ។ បទថា **កសម្ពុជាតោ** បានដល់ មានសំរាម គឺរាគៈជាដើមកើតហើយ ។ ម្យ៉ាងទៀត ទឹកគួរខ្ពើមដែលជ្រួតជ្រាបក្នុងសាកសពដែលរលួយ ក៏ហៅថា **កសម្ពុ** ។ បុគ្គលឈ្មោះថា ទ្រុស្តសីលក្នុងសាសនានេះ ដូចគ្នានឹងខ្ទុះ ក្នុង

សាកសព ព្រោះភាពដែលខ្លួន ជាបុគ្គលដែលបណ្ឌិតគប្បីវៀរ ព្រោះហេតុនោះ បុគ្គលណា ដូចខ្ទះក្នុងសាកសព បុគ្គលនោះ ឈ្មោះថា កសម្ពុជាតៈ ។

បទថា **តស្ស ន ឯវំ ហោតិ** សេចក្តីថា ព្រោះហេតុអ្វី ទើបលោកមិនមានការគិតយ៉ាងនោះ ព្រោះសីលដែលលោកតាំងនៅហើយ អាចនឹងបានអរហត្ត ភិក្ខុនោះ ក៏ទម្លាយហើយ ដូចកូនចណ្ឌាលបានឮថា ខត្តិយកុមារឈ្មោះនោះ អភិសេកក្នុងរាជសម្បត្តិ ព្រោះជនទាំងឡាយ ដែលកើតក្នុងត្រកូលណា រមែងដល់នូវការអភិសេក ខ្លួនមិនបានកើតក្នុងត្រកូលនោះ ទើបមិនបានគិតយ៉ាងនេះថា អញក៏គប្បីដល់នូវការអភិសេក ដូចខត្តិយកុមារឈ្មោះនោះដោយពិត យ៉ាងណា ភិក្ខុដែលទ្រុស្តសីល ទោះបីបានដំណឹងថា ភិក្ខុឈ្មោះនោះ សម្រេចអរហត្ត ព្រោះសីលដែលខ្លួនតាំងនៅហើយ គួរសម្រេចអរហត្តមិនមាន ទើបមិនមានការគិត យ៉ាងនេះថា សូម្បីអញក៏នឹងសម្រេចអរហត្ត ដូចភិក្ខុអ្នកមានសីល ឈ្មោះនោះដោយពិត ក៏យ៉ាងនោះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **និរាសោ** ព្រោះមិនមានសង្ឃឹមនឹងបាននូវអរហត្ត ។

បទថា **តស្ស ឯវំ ហោតិ** សេចក្តីថា ព្រោះសីលរបស់ភិក្ខុនោះ តាំងនៅហើយ អាចសម្រេចអរហត្ត ជាសភាវៈមាំទាំ ដូចកុមារដែលមានជាតិល្អ គឺកើតល្អហើយ បានឮដំណឹងថា ខត្តិយកុមារឈ្មោះនោះ អភិសេកហើយ

ព្រោះខ្លួនកើតក្នុងត្រកូលល្អហើយ នឹងបានការអភិសេក ទើបមានសេចក្តីត្រិះរិះយ៉ាងនេះថា អញក៏គប្បីបាននូវការអភិសេក ដូចកុមារនោះដោយពិតយ៉ាងណា ភិក្ខុអ្នកមានសីល លុះបានឮថា ភិក្ខុឈ្មោះនោះ សម្រេចអរហត្តហើយ ព្រោះសីលដែលលោកតាំងនៅហើយ គួរនឹងសម្រេចអរហត្ត ជាសភាវៈមាំទាំ ទើបមានការគិតយ៉ាងនេះថា សូម្បីអញក៏គប្បីសម្រេចអរហត្តដូចគ្នានឹងភិក្ខុឈ្មោះនោះដោយពិត ក៏យ៉ាងនោះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អាសំសោ** ព្រោះថា ភិក្ខុនោះនៅសង្ឃឹមនៅឡើយ គឺប្រាថ្នានូវអរហត្ត ព្រោះហេតុនោះ ទើបឈ្មោះថា **អាសំសោ** ។

បទថា **យា ហិស្ស បុព្វេ អវិមុត្តស្ស** សេចក្តីថា សេចក្តីសង្ឃឹមក្នុងការរួចផុតឯណា របស់ព្រះខីណាស្រពនោះ ដែលមិនទាន់បានរួចផុតដោយការរួចផុតដោយអរហត្តមគ្គក្នុងកាលមុន ការសង្ឃឹមនោះ របស់លោកស្ងប់រម្ងាប់ហើយ ព្រោះហេតុនោះ ទើបព្រះខីណាស្រពមិនមានការគិតយ៉ាងនោះដូចខត្តិយៈដែលអភិសេកហើយ លុះបានស្តាប់ពាក្យថា ខត្តិយកុមារ ឈ្មោះនោះ អភិសេកក្នុងរាជសម្បត្តិហើយ ព្រោះព្រះរាជាមួយអង្គ មិនបានអភិសេក ២ ដង មិនមានស្វេតច្ឆត្រ ២ ទើបមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា អញក៏គប្បីអភិសេក ដូចខត្តិយកុមារឈ្មោះនោះដោយពិត យ៉ាងណា ព្រះខីណា-ស្រព ទោះបានឮថា ភិក្ខុឈ្មោះនោះ សម្រេចអរហត្តហើយ ព្រោះភាពជាព្រះអរហន្ត ២ ដងមិនមាន ទើបមិនមានការគិតយ៉ាងនេះថា សូម្បីអញក៏

គប្បីសម្រេចអរហត្ត ដូចភិក្ខុឈ្មោះនោះដោយពិត យ៉ាងនោះឯង ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **វិគតាសោ** ព្រោះប្រាសចាកការសង្ឃឹមក្នុងភាពជាព្រះអរហន្ត ។

[ ៨៥-៨៦ ] ជនទាំងនោះក្នុងនិទ្ទេស នៃបុគ្គលដែលប្រៀបដោយអ្នកជំងឺ គប្បីជ្រាបដូចតទៅនេះ ហៅថា បុគ្គលប្រៀបដូចជាអ្នកជំងឺ ដោយឧបមាណា ដើម្បីសម្តែងឧបមានោះមុន ទើបព្រះពុទ្ធអង្គ ត្រាស់បទថា **តយោ គិលានា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សប្បាយានិ** បានដល់ ដែលជាប្រយោជន៍ គឺដែលធ្វើឲ្យចម្រើន ។ បទថា **បដិរូបំ** បានដល់ សមគួរ ។ ដោយបទថា **នេវ វុដ្ឋាតិ តម្ហា អាពាធា** ព្រះមានព្រះភាគ ត្រាស់ដល់អ្នកជំងឺ ដែលប្រកបដោយរោគទាំងឡាយ មានរោគខ្យល់ និងរោគច្អូតជ្រូកជាដើម ដែលព្យាបាលមិនជា ដែលបានទទួលការរក្សា ដល់ទីបំផុតហើយ ។ ដោយបទនេះថា **វុដ្ឋាតិ តម្ហា អាពាធា** ទ្រង់ត្រាស់ដល់អាពាធបន្តិចបន្តួច មានរោគទាំងឡាយ មានរោគផ្តាសាយ រោគរមាស់ រោគអាចម៍រុយ រោគបូស និងរោគជរាជាដើម ។

ផាសុកនៃជនពួកណា រមែងមានដោយការបម្រើ ទើបព្រះមានព្រះភាគត្រាស់ដល់បុគ្គលដែលអាពាធទាំងនោះ ដោយបទនេះថា **លភន្តោ សប្បាយានិ ភោជនានិ នោ អលភន្តោ ។**

ក្នុងទីនេះ បុគ្គលដែលប្រកបដោយអង្គរបស់អ្នកបម្រើអ្នកជំងឺ ជាបណ្ឌិត

១ ជាអ្នកឈ្លាស ១ មិនខ្ជិលច្រអូស ១ គប្បីជ្រាបថា ឈ្មោះថា ឧបដ្ឋាកដ៏សមគួរ ។

បទថា **គិលានុបដ្ឋាកោ អនុញ្ញាតោ** សេចក្តីថា ទ្រង់អនុញ្ញាតថា ភិក្ខុសង្ឃគួរចាត់ភិក្ខុអ្នករក្សាអ្នកជំងឺ កាលបុគ្គលអ្នកឈឺនោះ មិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅតាមធម្មតារបស់ខ្លួន ភិក្ខុសង្ឃគប្បីអបលោក ហើយចាត់ភិក្ខុមួយរូប និងសាមណេរមួយរូប ឲ្យដោយពាក្យថា ពួកលោក ចូរប្រតិបត្តិភិក្ខុឈឺនេះ បើភិក្ខុ ឬសាមណេរនោះនៅបដិបត្តិភិក្ខុឈឺនោះ ដរាបណា ភិក្ខុឈឺក្តី ភិក្ខុ ឬសាមណេរទាំងពីរនោះក្តី មានសេចក្តីត្រូវការដោយវត្ថុណា វត្ថុទាំងនោះជាភារៈដល់សង្ឃដរាបនោះ ។

បទថា **អញ្ញេបិ គិលានា ឧបដ្ឋាតព្វា** សេចក្តីថា បុគ្គលជាអ្នកជំងឺ ២ ពួកក្រៅអំពីនេះ ភិក្ខុសង្ឃក៏គួរឧបដ្ឋាកផងដែរ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា បុគ្គលណាមានជំងឺ បានទទួលការរក្សាដល់ទីបំផុតហើយ បុគ្គលនោះ កាលមិនមានបុគ្គលណា ឧបដ្ឋាកគប្បីទោមនស្សថា បើភិក្ខុ ឬសាមណេរគប្បីបដិបត្តិអញ សេចក្តីសុខគប្បីមានដល់អញ តែពួកជនទាំងនោះមិនបដិបត្តិអញ ដូច្នេះហើយ គប្បីកើតក្នុងអបាយ ។ កាលអ្នកជំងឺនោះ បានទទួលកិច្ចបដិបត្តិ អំពីភិក្ខុសាមណេររមែងមានការគិតយ៉ាងនេះថា កិច្ចណាដែលភិក្ខុសង្ឃគប្បីធ្វើ កិច្ចទាំងអស់នោះ ភិក្ខុសង្ឃក៏ធ្វើហើយ តែកម្មវិបាករបស់អញមានសភាពបែបនេះ ភិក្ខុឈឺនោះ ញ៉ាំងមេត្តាចិត្តឲ្យកើតឡើងក្នុងភិក្ខុសង្ឃហើយ រមែងកើតក្នុងស្ថាន

សួគ៌ ។

ម្យ៉ាងទៀត ភិក្ខុណាមានអាពាធបន្តិចបន្តួច បានឧបដ្ឋាកក្តី មិនបានក្តី រមែងជាសះស្បើយដោយខ្លួនឯង ភិក្ខុអាពាធបន្តិចបន្តួចនោះ ទោះវៀរចាកភេសជ្ជៈ អាពាធក៏ស្ងប់រម្ងាប់បាន តែបើគេធ្វើភេសជ្ជៈឲ្យឆាន់ អាពាធបន្តិចបន្តួចនោះ ក៏រមែងស្ងប់រម្ងាប់បាន ដោយរួសរាន់ ។ លំដាប់នោះ អ្នកជំងឺប្រាសចាករោគ ហើយអាចរៀនពុទ្ធវចនៈ ឬធ្វើសមណធម៌ ដោយហេតុនេះទើបលោកពោលថា សូម្បីបុគ្គលឈឺឯទៀត ក៏បុគ្គលគួរបម្រើដែរ ។

បទថា **នេវ ឱក្កមតិ** បានដល់ មិនចូលទៅ ។ បទថា **និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ** បានដល់ សម្មត្តធម៌ ពោល គឺមគ្គនិយាមក្នុងកុសលធម៌ទាំងឡាយ ព្រះមានព្រះភាគត្រាស់ដល់បុគ្គលដែលមានបទយ៉ាងក្រៃលែង ( បទបរមបុគ្គល ) ដោយព្រះតម្រាស់នេះ ។ ដោយវារៈទី ២ ទ្រង់កាន់យកឧគ្ឃដិតញ្ញូបុគ្គល ដែលដូចគ្នានឹងព្រះនាឡកត្ថេរ ក្នុងសាសនា និងទ្រង់កាន់យកឧគ្ឃដិតញ្ញូបុគ្គល ដែលមានបច្ចេកពោធិញ្ញាណ ដែលបានទទួលឱវាទក្នុងសម្នាក់នៃព្រះបច្ចេកពុទ្ធទាំងឡាយម្តង ក្នុងពុទ្ធន្តរ ហើយចាក់ធ្លុះសច្ចធម៌ ។ ទ្រង់ពោលដល់វិបចិតញ្ញូបុគ្គលដោយវារៈទី ៣ ។ នេយ្យបុគ្គល សង្គ្រោះចូលក្នុងវិបចិតញ្ញូបុគ្គលនោះឯង ។

បទថា **ធម្មទេសនា អនុញ្ញាតា** សេចក្តីថា ទ្រង់អនុញ្ញាតព្រះធម្មទេសនា ១ ខែ ៨ ដង ។

បទថា **អញ្ញេសម្បិ ធម្មោ ទេសេតព្វោ** សេចក្តីថា គួរពោលធម៌ដល់

ជនទាំងឡាយ ក្រៅអំពីនេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា បទបរមបុគ្គលមិនអាចចាក់ធ្លុះធម៌ក្នុងអត្តភាពនេះ តែក៏នឹងជាបច្ច័យក្នុងកាលខាងមុខ ។

ម្យ៉ាងទៀត បុគ្គលណា បានឃើញរូបព្រះតថាគតក្តី មិនបានឃើញក្តី បានស្តាប់ព្រះធម្មវិន័យក្តី មិនបានស្តាប់ក្តី បុគ្គលនោះ រមែងត្រាស់ដឹងធម៌បាន បុគ្គលនោះ កាលមិនបាន ក៏មិនត្រាស់ដឹង តែកាលបាន ក៏នឹងត្រាស់ដឹងដោយឆាប់រួសរាន់នោះឯង ព្រោះហេតុនោះ ព្រះធម្មកថិកទាំងឡាយ គប្បីសម្តែងធម៌ ដល់ជនទាំងឡាយនោះ ព្រោះហេតុដែលពោលមកនេះ តែគួរសម្តែងធម៌ដល់បុគ្គលពួកទី ៣ រឿយៗ នោះឯង ។

[ ៨៧ ] បុគ្គលទាំងឡាយ ដែលឈ្មោះថា កាយសក្ខី ទិដ្ឋិប្បត្ត និងសទ្ធាវិមុត្ត ខ្ញុំបានពោលហើយខាងដើមនោះឯង ។

[ ៨៨ ] បទថា **សភគ្គតោ** បានដល់ នៅក្នុងសភា គឺទីប្រជុំ ។ បទថា **បរិសគ្គតោ** បានដល់ នៅក្នុងបរិស័ទ គឺអ្នកស្រុក ។

បទថា **ញាតិមជ្ឈគតោ** បានដល់ នៅក្នុងកណ្តាលនៃទាយាទ ( ញាតិអ្នកទទួលមត៌ក ) ទាំងឡាយ ។ បទថា **បូគមជ្ឈគតោ** បានដល់ នៅក្នុងកណ្តាលនៃកងទ័ពទាំងឡាយ ។

បទថា **រាជកុលមជ្ឈគតោ** បានដល់ នៅក្នុងរោងមហាវិនិច្ឆ័យ ក្នុងកណ្តាលរាជត្រកូល ។ បទថា **អភិនីតោ** បានដល់ ត្រូវគេនាំទៅដើម្បីជាប្រយោជន៍ដល់ការសាកសួរ ។ បទថា **សក្ខិបុដ្ឋោ** បានដល់ ត្រូវគេធ្វើឲ្យ

ជាសាក្សីហើយទាញមក ។ បទថា **ឯហម្ភោ បុរិស** នេះ ជាពាក្យអាលបណៈ គឺពាក្យសម្រាប់ហៅ ។ បទថា **អត្តហេតុ វា បរហេតុ វា** បានដល់ ព្រោះហេតុនៃអវយវៈ មានដៃ និងជើងជាដើម ឬព្រោះហេតុនៃទ្រព្យរបស់ខ្លួន ឬរបស់អ្នកដទៃ ។ លាភ លោកបំណាងយកថា អាមិសក្នុងបទនេះថា **អាមិសកិញ្ចិក្ខហេតុ វា** ។

បទថា **កិញ្ចិក្ខំ** បានដល់ ទ្រព្យណាមួយតាមដែលមានប្រមាណតិចតួច អធិប្បាយថា ព្រោះហេតុនៃទ្រព្យមានប្រមាណតិចតួច ដោយហោច មានសត្វទទា ក្រួច ដុំសប្បិ និងដុំនវនីតជាដើម ។

បទថា **សម្បជានមុសា ភាសិតា ហោតិ** សេចក្តីថា ធ្វើនូវការពោលមុសាវាទ ទាំងដែលដឹងខ្លួននោះឯង ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា គូថភាណី គឺមានពាក្យសម្តីដូចលាមក ព្រោះមានវាចា ដូចគ្នានឹងដុំលាមក លោកអធិប្បាយថា ឈ្មោះថា លាមក មិនជាទីពេញចិត្តដល់មហាជនយ៉ាងណា សម្តីរបស់បុគ្គលពោលកុហកនេះ រមែងមិនជាទីពេញចិត្ត ដល់ទេវតា និងមនុស្សទាំងឡាយ ក៏យ៉ាងនោះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា បុប្ផភាណី គឺមានវាចាដូចផ្កា ព្រោះមានវាចា ដូចគ្នានឹងផ្កា ដូចផ្កាម្លិះទាំងឡាយ កំពុងក្រពុំ ឬកំពុងរីក រមែងជាទីស្រឡាញ់ ជាទីប្រាថ្នានៃមហាជនយ៉ាងណា វាចារបស់បុគ្គលនេះ ក៏រមែងជាទីស្រឡាញ់ ជាទីប្រាថ្នារបស់

ទេវតា និងមនុស្សទាំងឡាយ ក៏យ៉ាងនោះដូចគ្នា ។

ទោស ហៅថា **ឯល** ក្នុងបទថា **នេលា** មានវិគ្គហៈថា ទោសនៃវាចានោះមិនមាន ព្រោះហេតុនោះ ទើបវាចានោះ ហៅថា **នេលា** អធិប្បាយថា អស់នូវទោស ដូចការមិនមានទោស ដែលត្រាស់ ( ក្នុងខុទ្ទកនិកាយ ឧទាន ) ថា រថ គឺអត្តភាព មានអវយវៈឥតទោស មានដំបូល-ស ដូច្នេះ ។

បទថា **កណ្ណសុខា** បានដល់ ឈ្មោះថា ដែលនាំមកនូវសេចក្តីសុខដល់ត្រចៀកទាំង ២ ព្រោះជាវាចាពីរោះដោយព្យញ្ជនៈ អធិប្បាយថា មិនធ្វើនូវការចាក់ត្រចៀក ដូចការចាក់ដោយម្ជុលទាំងឡាយ ។

វាចាណាមិនញុំាងសេចក្តីក្រោធ ឲ្យកើតឡើងក្នុងសរីរៈទាំងមូល រមែងញុំាងនូវសេចក្តីស្រឡាញ់ឲ្យកើត ព្រោះជាវាចាដែលពីរោះដោយអត្ថ ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **បេមនីយា** ។

វាចាណាទៅកាន់ហទយៈ មិនមានអ្វីរាំង ចូលទៅកាន់ចិត្តដោយងាយ ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **ហទយង្គមា** ។

វាចាណាជារបស់មាននៅក្នុងក្រុង ព្រោះជាវាចាដែលសម្បូរដោយគុណ ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **ពោរី** ។

វាចាដែលទន់ភ្លន់ដូចតរុណនារីក្នុងក្រុង ក៏ឈ្មោះថា **ពោរី** ។ វាចានោះជារបស់អ្នកក្រុង ព្រោះហេតុនោះ ទើបឈ្មោះថា **ពោរី** ។ អធិប្បាយថា ជាពាក្យរបស់អ្នកក្រុង ។ ពិតហើយ អ្នកក្រុងទាំងឡាយ មានពាក្យសមគួរ គឺសមរម្យ រមែងហៅបុគ្គលដែលសមគួរជាឪពុក ថាឪពុក ហៅអ្នកសមគួរ

ជាម៉ែ ថាម៉ែ និងហៅបុគ្គលសមគួរជាបងប្រុស ប្អូនប្រុស ថាបងប្រុស ប្អូនប្រុស ដូច្នេះ ។

ពាក្យណាបែបនេះ រមែងជាពាក្យដែលមហាជនស្រឡាញ់ ព្រោះហេតុនោះ វាចានោះ ឈ្មោះថា **ពហុជនកន្តា** ។

វាចាណាជាទីញុំាងចិត្តឲ្យត្រជាក់ គឺធ្វើនូវការចម្រើនដល់ចិត្តរបស់ជនជាច្រើន ដោយភាពជាវាចា ដែលជនជាច្រើនពេញចិត្តនោះឯង ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **ពហុជនមនាបា** ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **មធុភាណី** ។ បាលីថា **មុធុភាណី** ដូច្នេះក៏មាន ពាក្យទាំងពីរ ក៏មានអត្ថថា មានវាចាផ្អែមល្ហែម ។ ដូចមធុរស ៤ យ៉ាង ជារបស់ប្រណីត យ៉ាងណា ពាក្យរបស់បុគ្គលនេះ ក៏ជារបស់ពីរោះ ដល់ទេវតា និងមនុស្សទាំងឡាយក៏យ៉ាងនោះដូចគ្នា ។

[ ៨៩ ] ក្នុងនិទ្ទេសនៃបុគ្គល ដែលមានចិត្តដូចមុខដំបៅជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អភិសជ្ជតិ** បានដល់ រមែងអាក់អន់ ។ បទថា **កុប្បតិ** បានដល់ រមែងកម្រើក ដោយអំណាចសេចក្តីក្រោធ ។ បទថា **ព្យាបជ្ជតិ** បានដល់ រមែងលះប្រក្រតីភាវៈ គឺជាបុគ្គលស្អុយ ។

បទថា **បតិត្ថីយតិ** បានដល់ រមែងដល់នូវភាពជាអ្នករឹងត្អឹង និងភាពជាអ្នកគ្រោតគ្រាត ។ បទថា **កោបំ** បានដល់ សេចក្តីក្រោធ ដែលមានកម្លាំងខ្សោយ ។ បទថា **ទោសំ** បានដល់ ទោសៈដែលមានកម្លាំងច្រើនជាង

សេចក្ដីក្រោធនោះ ដោយអំណាចការប្រទូស្ត ។

បទថា **អប្បច្ចយំ** បានដល់ អាការដែលមិនពេញចិត្ត គឺទោមនស្ស ។ បទថា **ទុដ្ឋារុកោ** បានដល់ មុខដំបៅចាស់ ។ បទថា **កដ្ឋេន** បានដល់ ដោយចុងកំណាត់ឈើ ។ បទថា **កឋលាយ** បានដល់ ដោយអំបែង ។ បទថា **អាសវំ ទេតិ** បានដល់ រមែងហូរចេញជានិច្ច ។ តាមធម្មតា ដំបៅនោះ រមែងហូរនូវរបស់គួរខ្ពើម ៣ យ៉ាង គឺទឹករងៃ ឈាម ខ្ទុះ ដំបៅនោះត្រូវរបស់ណាមួយប៉ះហើយ របស់បដិកូលទាំងនោះរមែងហូរចេញមកសន្ធឹកសន្ធាប់ ។

បទថា **ឯវមេវំ ខោ** នេះ មានការប្រៀបធៀបដោយឧបមាដូចតទៅនេះ បុគ្គលដែលច្រើនដោយសេចក្ដីក្រោធ លោកប្រៀបប្រដូចមុខដំបៅ ការប្រព្រឹត្តរបស់អ្នកច្រើនដោយសេចក្ដីក្រោធ ប្រៀបដូចការហូរចេញនូវរបស់បដិកូល ៣ យ៉ាង មានខ្ទុះជាដើមតាមធម្មតារបស់ខ្លួន ការប្រព្រឹត្តប្រទូស្តប្រៀបដូចសាកសពហើមតាមធម្មតារបស់ខ្លួន ពាក្យសូម្បីបន្តិចបន្តួចប្រៀបដូចការប៉ះដោយកំណាត់ឈើ ឬអំបែង បណ្ឌិតគប្បីឃើញភាវៈ គឺការហើមដោយប្រមាណច្រើនរបស់បុគ្គលដែលច្រើនដោយសេចក្ដីក្រោធនោះ ដោយគិតថា បុគ្គលនេះ ពោលយ៉ាងនេះជាមួយអញបានដូចម្ដេច ដូចការហូរចេញច្រើននៃវត្ថុបដិកូលទាំងឡាយ ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អរុក្ខូបមចិត្តោ** អធិប្បាយថា បុគ្គលមានចិត្តដូចគ្នានឹងមុខដំបៅចាស់ ។

បទថា **រត្តន្ធការតិមិសាយ** សេចក្តីថា ក្នុងការងងឹត ដែលធ្វើនូវការងងឹត ដោយហាមការកើតឡើងនៃចក្ខុវិញ្ញាណក្នុងវេលាយប់ ។

បទថា **វិជ្ជន្តរិកាយ** បានដល់ ក្នុងខណៈនៃផ្លេកបន្ទោរប្រព្រឹត្តទៅ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបការប្រៀបធៀបដោយឧបមា ដូចតទៅនេះ ព្រះយោគាវចរ បណ្ឌិតគប្បីឃើញ ដូចបុរសដែលមានភ្នែកល្អ កិលេសទាំងឡាយ ដែលសោតាបត្តិមគ្គគប្បីសម្លាប់ ប្រៀបដូចងងឹត ការកើតឡើងនៃសោតាបត្តិមគ្គញាណ ប្រៀបដូចផ្លេកបន្ទោរ ការឃើញព្រះនិព្វានក្នុងខណៈនៃសោតាបត្តិមគ្គ ប្រៀបដូចការឃើញរូបដោយជុំវិញរបស់បុរសដែលមានភ្នែកក្នុងរវាងផ្លេកបន្ទោរ កិលេសទាំងឡាយ ដែលសកទាគាមិមគ្គ គប្បីសម្លាប់ ប្រៀបដូចងងឹតមកគ្របដណ្តប់ទៀត ការកើតឡើងនៃសកទាគាមិ-មគ្គញាណ ប្រៀបដូចផ្លេកបន្ទោរប្រព្រឹត្តទៅទៀត ការឃើញព្រះនិព្វានក្នុងខណៈនៃសកទាគាមិមគ្គ ប្រៀបដូចការឃើញរូបដោយជុំវិញ របស់បុរសដែលមានភ្នែកក្នុងរវាងផ្លេកបន្ទោរ ។ កិលេសទាំងឡាយ ដែលអនាគាមិមគ្គគប្បីសម្លាប់ ប្រៀបដូចងងឹតគ្របដណ្តប់ទៀត ការកើតឡើងនៃអនាគាមិ-មគ្គញាណ ប្រៀបដូចផ្លេកបន្ទោរប្រព្រឹត្តទៅទៀត ការឃើញព្រះនិព្វានក្នុងខណៈនៃអនាគាមិមគ្គ ប្រៀបដូចការឃើញរូបដោយជុំវិញ របស់បុរសដែលមានភ្នែកក្នុងចន្លោះផ្លេកបន្ទោរ ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **វិជ្ជូបមចិត្តោ** អធិប្បាយថា ជាអ្នកមានចិត្ត ដូចផ្លេកបន្ទោរ ព្រោះពន្លឺក្នុង

វេលាដែលផ្ទេកបន្ទោរចាំងមកតិចតួច ។

ក្នុងកាលដែលបុគ្គលមានចិត្តប្រៀបដូចពេជ្រ មានការប្រៀបធៀបដោយឧបមាដូចតទៅ

បណ្ឌិតគប្បីឃើញញាណក្នុងអរហត្តមគ្គ ប្រៀបដូចពេជ្រ កិលេសទាំងឡាយ ដែលអរហត្តគប្បីសម្លាប់ ប្រៀបដូចពន្លកកែវមណី ឬពន្លកដុំថ្ម ។ បណ្ឌិតគប្បីឃើញភាពដែលកិលេសទាំងឡាយ ត្រូវកាត់ផ្តាច់ដោយអរហត្តមគ្គញាណ ប្រៀបដូចពេជ្រ ដែលមិនចោះទម្លាយពន្លកកែវមណី ឬពន្លកដុំថ្មមិនមាន បណ្ឌិតគប្បីឃើញភាពដែលកិលេសទាំងឡាយ ត្រូវអរហត្តមគ្គកាត់ផ្តាច់ហើយ មិនកើតឡើងទៀត ប្រៀបដូចពន្លកកែវមណី ឬពន្លកដុំថ្មដែលត្រូវពេជ្រទម្លាយផ្តាច់ទៅហើយ មិនបរិបូរណ៍ដូចដើមទៀតឡើយ ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ លោកហៅថា **វជិរូបមចិត្តោ** អធិប្បាយថា បុគ្គលមានចិត្តប្រៀបដូចពេជ្រ ព្រោះជាអ្នកអាចជកនូវកិលេសទាំងឡាយ ។

[ ៩០ ] ក្នុងនិទ្ទេសនៃបុគ្គលខ្វាក់ជាដើម គប្បីជ្រាបដូចតទៅនេះថា បទថា **តថារូបំ ចក្ខុ ន ហោតិ** សេចក្តីថា ចក្ខុ គឺបញ្ញាដែលមានជាតិយ៉ាងនោះ មានសភាវៈយ៉ាងនោះ រមែងមិនមានដល់បុគ្គលនោះ ។ បទថា **ផាតិំ ករេយ្យ** បានដល់ គប្បីធ្វើឲ្យមាំទាំ គឺធ្វើឲ្យចម្រើនឡើង ។

បទថា **សាវជ្ជានវជ្ជេ** បានដល់ ធម៌ដែលមានទោស និងមិនមានទោស ។ បទថា **ហីនប្បណីតេ** បានដល់ មិនប្រសើរ និងមិនឧត្តម ។ បទថា **កណ្ហសុក្កសប្បដិភាគេ** សេចក្តីថា ធម៌ចំណែកខ្មៅ និងធម៌ចំណែក

សនោះឯង ហៅថា **សប្បដិភាគ** ដោយអំណាចជាបដិបក្ខ ព្រោះមានការហាមនូវគ្នានិងគ្នា ។ ក្នុងទីនេះ មានសេចក្ដីសង្ខេបដូចតទៅនេះ បុគ្គលគប្បីដឹងកុសលធម៌ទាំងឡាយ ថាជាកុសលធម៌ទាំងឡាយ ដោយបញ្ញាចក្ខុណា គប្បីដឹងអកុសលធម៌ទាំងឡាយ ថាជាអកុសលធម៌ទាំងឡាយ ដោយបញ្ញាចក្ខុណា ក្នុងធម៌មានទោសជាដើម ក៏ន័យនេះដូចគ្នា ។ បណ្ឌិតគប្បីជ្រាបអត្ថក្នុងវារៈដ៏សេសដោយន័យនេះថា បុគ្គលគប្បីជ្រាបដោយបញ្ញាចក្ខុណា បណ្ដាធម៌មានចំណែកប្រៀបដោយធម៌ចំណែកខ្មៅ និងធម៌ចំណែក-ស ធម៌ចំណែកខ្មៅ មានចំណែកប្រៀបដោយធម៌ចំណែក-ស ធម៌ចំណែក-ស មានចំណែកប្រៀបដោយធម៌ចំណែកខ្មៅ ចក្ខុ គឺបញ្ញាបែបនេះ រមែងមិនមានដល់បុគ្គលនោះ ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អន្ធោ** ព្រោះមិនមានបញ្ញាចក្ខុ ជាគ្រឿងរួបរួមភោគទ្រព្យ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងមិនមានបញ្ញាចក្ខុជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេច ក្នុងភពខាងមុខ ។ បុគ្គលពួកទី ២ ហៅថា **ឯកចក្ខុ** ព្រោះមានបញ្ញាចក្ខុ ជាគ្រឿងរួបរួមភោគទ្រព្យដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន តែមិនមានបញ្ញាចក្ខុ ជាគ្រឿងញ៉ាំងប្រយោជន៍ឲ្យសម្រេចក្នុងភពខាងមុខ ។ បុគ្គលពួកទី ៣ ហៅថា **ទ្វិចក្ខុ** ព្រោះមានបញ្ញាចក្ខុទាំងពីរ ។

[ ៩១ ] ក្នុងនិទ្ទេសនៃបុគ្គលដែលមានបញ្ញាដូចក្អមផ្កាប់[១] មានវិនិច្ឆ័យ

---

១- បិដកខ្មែរ ជាភាជន៍ផ្កាប់ ។

ដូចតទៅនេះ បទថា **ធម្មំ ទេសេន្តិ** សេចក្ដីថា ភិក្ខុទាំងឡាយ លះនូវការងាររបស់ខ្លួនហើយ សម្ដែងធម៌ដោយគិតថា ឧបាសកមកដើម្បីស្ដាប់ធម៌ ។

បទថា **អាទិកល្យាណំ** សេចក្ដីថា រមែងសម្ដែងធម៌ឲ្យស្អាត ឲ្យបម្រើន ឲ្យមិនមានទោស ប្រាសចាកទោសខាងដើម ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងបទទាំងនេះ បទថា **អាទិ** បានដល់ ជាពាក្យផ្ដើមគ្រាដំបូង ។

បទថា **មជ្ឈំ** បានដល់ ជាការពោលត្រង់កណ្ដាល ។ បទថា **បរិយោសានំ** បានដល់ ជាពាក្យចុងក្រោយ ។ ភិក្ខុទាំងឡាយកាលសម្ដែងធម៌ដល់បុគ្គលនោះ រមែងសម្ដែងធម៌ឲ្យស្អាត ឲ្យបម្រើន ឲ្យមិនមានទោសនោះឯង ទាំងក្នុងពាក្យផ្ដើមដំបូង ទាំងក្នុងពាក្យដែលមានក្នុងកណ្ដាល ទាំងក្នុងពាក្យដែលពោលក្នុងទីបំផុត ។ម្យ៉ាងទៀត ក្នុងទីនេះ ទេសនាក៏មានខាងដើម កណ្ដាល និងទីបំផុត សាសនាក៏មានខាងដើម កណ្ដាល និងទីបំផុត ។ បណ្ដាទេសនា និងសាសនានោះ គប្បីជ្រាបទេសនាមុនថា គាថា ៤ បទ បទទី ១ ជាបទដើម ២ បទបន្ទាប់មកទៀតជាបទកណ្ដាល បទទី ៤ ជាបទខាងចុង ។ សម្រាប់ព្រះសូត្រដែលមានអនុសន្ធិ ១ និទានជាខាងដើម ការបន្តជាកណ្ដាល វាចាដែលពោលចុងក្រោយថា **ឥទមវោច** ជាខាងចុង ។ សម្រាប់ព្រះសូត្រដែលមានអនុសន្ធិច្រើន អនុសន្ធិដំបូងជាខាងដើម បន្ទាប់អំពីនោះ អនុសន្ធិ ១ ក្ដី អនុសន្ធិច្រើនក្ដីជាកណ្ដាល អនុសន្ធិចុងក្រោយជាខាងចុង ។ គប្បីជ្រាបន័យរបស់ទេសនាត្រឹមប៉ុណ្ណេះ ។

ចំណែកន័យរបស់សាសនា សីល ជាខាងដើម សមាធិ ជាកណ្ដាល

វិបស្សនាជាខាងចុង ។ ម្យ៉ាងទៀត សមាធិជាខាងដើម វិបស្សនាជាកណ្តាល មគ្គជាខាងចុង ។ ម្យ៉ាងទៀត វិបស្សនាជាខាងដើម មគ្គជាកណ្តាល ផល ជាខាងចុង ។ ម្យ៉ាងទៀត មគ្គជាខាងដើម ផលជាកណ្តាល និព្វានជាខាង ចុង ។ ម្យ៉ាងទៀត បើរាប់ជាគូ សីល និងសមាធិជាខាងដើម វិបស្សនា និងមគ្គជាកណ្តាល ផល និងនិព្វានជាខាងចុង ។

បទថា **សាត្ថំ** បានដល់ សម្តែងធម៌ឲ្យប្រព្រឹត្តទៅជាមួយអត្ថ ។ បទថា **សព្យញ្ជនំ** បានដល់ សម្តែងធម៌ឲ្យមានអក្ខរៈបរិបូរណ៍ ។ បទថា **កេវល-បរិបុណ្ណំ** បានដល់ សម្តែងធម៌ធ្វើឲ្យបរិបូរណ៍ដោយឥតសេសសល់ គឺមិន ឲ្យខ្វះខាត ។ បទថា **បរិសុទ្ធំ** បានដល់ សម្តែងធម៌ឲ្យបរិសុទ្ធ ឲ្យប្រាស ចាកភាពស្មុគស្មាញ ឲ្យប្រាសចាកភាពរសេមរសាម ។

បទថា **ព្រហ្មចរិយំ បកាសេន្តិ** សេចក្តីថា កាលសម្តែងធម៌យ៉ាងនោះ ឈ្មោះថា រមែងប្រកាសអដ្ឋង្គិកមគ្គដ៏ប្រសើរ ដែលសង្គ្រោះដោយត្រៃសិក្ខា គឺសីល សមាធិ និងបញ្ញាដែលជាការប្រព្រឹត្តដ៏ប្រសើរ ។

បទថា **នេវ អាទឹ មនសិករោតិ** បានដល់ មិនមនសិការនូវពាក្យ ដែលតាំងទុកខាងដើម ។ បទថា **កុម្ភោ** បានដល់ ក្អម ។ បទថា **និក្កុជ្ជោ** បានដល់ ក្អមដែលគេផ្កាប់ ។ ក្នុងបទនេះថា **ឯវមេវ** គប្បីជ្រាបឧបមា ឧបមេយ្យ ដូចតទៅនេះ បុគ្គលដែលមានបញ្ញាដូចក្អមផ្កាប់ គប្បីឃើញ ដូចគ្នានឹងក្អមដែលគេផ្កាប់ ។ វេលាដែលបុគ្គលនោះ បានស្តាប់ព្រះធម្ម-ទេសនា គប្បីឃើញដូចវេលាដែលចាក់ដោយទឹក ។ ពេលដែលបុគ្គលនោះ

អង្គុយក្នុងអាសនៈនោះ ហើយមិនអាចរៀនធម៌បាន គប្បីឃើញដូចកាល ដែលទឹកហូរកាត់ក្អម ។ វេលាដែលបុគ្គលនោះ ក្រោកឡើងចាកអាសនៈ ហើយកំណត់ធម៌មិនបាន គប្បីជ្រាបដូចវេលាដែលទឹកមិនដក់នៅក្នុងក្អម ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អវ-កុជ្ជបញ្ញោ** អធិប្បាយថា មានបញ្ញាដូចក្អមដែលគេផ្កាប់ ។

បទថា **អាកិណ្ណានិ** បានដល់ ដាក់ចូលហើយ ។ បទថា **សតិ-សម្មោសា បកិរេយ្យ** សេចក្ដីថា ព្រោះមិនមានសតិ ទ្រព្យទាំងឡាយ ក៏ខ្ចាត់ខ្ចាយទៅ ។ បណ្ឌិតគប្បីឃើញបុគ្គលដែលមានបញ្ញាដូចថ្នក់លេច ក៏ដូចគ្នានឹងថ្នក់លេច ដែលលោកពោលក្នុងបទថា **ឯវមេវ** នេះ ។ បណ្ឌិតគប្បីឃើញពុទ្ធវចនៈមានប្រការផ្សេងៗ ដូចរបស់ទំពាស៊ីច្រើនប្រភេទ ។ គប្បីជ្រាបវេលាដែលបុគ្គលនោះអង្គុយក្នុងអាសនៈនោះ ហើយរៀនពុទ្ធវចនៈ ដូចវេលាដែលបុគ្គលនោះអង្គុយទំពាស៊ីរបស់ដែលគួរទំពាផ្សេងៗ ច្រើនប្រភេទដែលដាក់នៅក្នុងថ្នក់ ។ គប្បីជ្រាបពេលដែលបុគ្គលនោះ ក្រោកចាកអាសនៈនោះ ហើយដើរទៅ មិនអាចកំណត់ធម៌បាន ដូចវេលាដែលបុគ្គលនោះ មិនមានសតិក្រោកឡើង ធ្វើឲ្យរបស់ទំពាខ្ចាត់ខ្ចាយទៅ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **ឧច្ឆង្គបញ្ញោ** អធិប្បាយថា មានបញ្ញាដូចគ្នានឹងថ្នក់លេច ។

បទថា **ឧក្កុជ្ជោ** បានដល់ ក្អមដែលគេផ្ងារមាត់ឡើងលើ ។

បទថា **សណ្ឋាតិ** បានដល់ រមែងដក់ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ

បណ្ឌិតគប្បីឃើញបុគ្គលមានបញ្ញាច្រើន ដូចក្អមដែលគេផ្ងារមាត់ឡើងលើ គប្បីជ្រាបវេលាដែលបុគ្គលនោះ បានស្តាប់ធម្មទេសនា ដូចវេលាដែលគេចាក់ទឹក ចូលទៅក្នុងក្អម ។ គប្បីជ្រាបវេលាដែលបុគ្គលនោះ អង្គុយរៀនពុទ្ធវចនៈក្នុងទីនោះ ដូចវេលាដែលទឹកដក់ ។ គប្បីជ្រាបវេលាដែលបុគ្គលនោះក្រោកឡើងចាកអាសនៈដើរទៅ ក៏ញុំាងសមត្ថភាពកំណត់ពុទ្ធវចនៈបាន ដូចវេលាដែលទឹកមិនហូរចេញទៅ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះហៅថា **បុថុប្បញ្ញោ** អធិប្បាយថា មានបញ្ញាទូលាយ ។

[ ៩២ ] ក្នុងនិទ្ទេសនៃបុគ្គលមិនទាន់ប្រាសចាកតម្រេកជាដើម គប្បីជ្រាបដូចតទៅនេះ ព្រះសោតាបន្ន និងព្រះសកទាគាមី មិនទាន់ប្រាសចាកតម្រេក ក្នុងកាមគុណទាំង ៥ និងភពទាំង ៣ យ៉ាងណា បុថុជ្ជនក៏យ៉ាងនោះ ។ តែសម្រាប់បុថុជ្ជន ព្រះមានព្រះភាគ ទ្រង់មិនបានកាន់យក ព្រោះមិនជាទព្វបុគ្គល ( បុគ្គលដែលមិនទ្រទ្រង់នូវគុណ ) ដូចមេជាងឈើដែលឈ្លាសចូលទៅកាន់ព្រៃដើម្បីទព្វសម្ភារ មេជាងមិនកាប់ដើមឈើ ដែលជួបហើយជួបទៀតតាំងអំពីដំបូង តែឈើណាគួរដល់ទព្វសម្ភារ មេជាងរមែងកាប់ដើមឈើទាំងនោះយ៉ាងណា ព្រះអរិយសាវកទាំងឡាយដែលជាទព្វជាតិទាំងនោះ ព្រះមានព្រះភាគ ក៏ទ្រង់កាន់យកហើយក្នុងទីនេះ ក៏យ៉ាងនោះ ឯបុថុជ្ជន បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនកាន់យក ព្រោះជាអ្នកមិនទាន់ទ្រទ្រង់នូវគុណ ។ បទថា **កាមេសុ វីតរាគោ** បានដល់ ដែលប្រាសចាកតម្រេកក្នុងបញ្ចកាមគុណ ។ បទថា **ភវេសុ អវីតរាគោ** បាន

ដល់ ដែលមិនទាន់ប្រាសចាកតម្រេក ក្នុងរូបភព និងអរូបភព ។

[ ៩៣ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយគំនូសថ្មជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អភិសជ្ជតិ** បានដល់ សេចក្តីក្រោធ រមែងដេកត្រាំព្រោះមិនទាន់លះបាន ។ បទថា **ន ចិរំ លុជ្ជតិ** បានដល់ សេចក្តីក្រោធនោះ រមែងមិនសាបសូន្យទៅក្នុងរវាង គឺរមែងសាបសូន្យទៅ ដោយកប្បតាំងឡើងជាថ្មី ។

បទថា **ឯវមេវ** សេចក្តីថា សេចក្តីក្រោធនៃបុគ្គលនោះ រមែងមិនរលត់ទៅក្នុងចន្លោះ គឺក្នុងថ្ងៃស្អែក ឬក្នុងថ្ងៃបន្តទៅខាងមុខ ក៏មិនរលត់ ដូច្នោះ អធិប្បាយថា សេចក្តីក្រោធនោះ រមែងមានអស់កាលយូរ តែរមែងរលត់ទៅព្រោះមរណៈនោះឯង ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **បាសាណលេខូបមោ** ព្រោះជាស្នាមគំនូសដែលជាប់អស់កាលយូរ ដោយភាវៈនៃសេចក្តីក្រោធ ដូចស្នាមគំនូសលើថ្ម ។

បទថា **សោ ច ខ្វស្ស កោធោ** បានដល់ សេចក្តីក្រោធនោះ របស់បុគ្គលដែលក្រោធរហ័សសូម្បីក្នុងហេតុបន្តិចបន្តួច ។ បទថា **ន ចិរំ** សេចក្តីថា រមែងដេកត្រាំព្រោះមិនទាន់លះសេចក្តីក្រោធបាន តែមិនយូរ អធិប្បាយថា ដូចស្នាមគំនូសដែលបុគ្គលគូសត្រង់ផែនដី រមែងរលុបទៅដោយខ្យល់ជាដើមយ៉ាងរហ័ស យ៉ាងណា សេចក្តីក្រោធនៃបុគ្គលនោះ សូម្បីកើតឡើងរហ័ស ក៏រមែងរលត់ទៅដោយរហ័ស ក៏យ៉ាងនោះដូចគ្នា ។ បទថា **អយំ**

**វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **បឋវីលេខូបមោ** ព្រោះជាស្នាមគំនូសនៅមិនយូរ ដោយភាវៈនៃសេចក្តីក្រោធ ដូចស្នាមគំនូសត្រង់ផែនដី ។

បទថា **អាគាឡ្ហេន** បានដល់ ដោយពាក្យដែលគ្រោតគ្រាត គឺពាក្យដែលរឹង ដែលទម្លាយនូវសេចក្តីស្រឡាញ់ ។ បទថា **ផរុសេន** បានដល់ពាក្យដែលមិនសុខ ដល់ត្រចៀក ។ បទថា **អមនាបេន** បានដល់ ពាក្យដែលមិនធ្វើឲ្យចិត្តសប្បាយ ។ បទថា **សំសន្ទតិ** បានដល់ ដូចគ្នាតែមួយ ។ បទថា **សន្ធិយតិ** បានដល់ នៅតែបន្ត ។ បទថា **សម្មោទតិ** បានដល់ មិនមានចន្លោះ ។ ម្យ៉ាងទៀត បទថា **សំសន្ទតិ** អធិប្បាយថា រមែងដល់នូវការប្រជុំចុះ ក្នុងការធ្វើរបស់ចិត្តដោយចិត្ត គឺរមែងចូលដល់ **ឯកីភាវ** គឺភាពតែមួយ ដូចទឹក និងទឹកដោះ ។ បទថា **សន្ធិយតិ** អធិប្បាយថា រមែងដល់នូវការប្រជុំចុះក្នុងការធ្វើតាមកាយដោយកាយជាដើម ដែលមានការឈរ និងការដើរជាដើម គឺតែងចូលដល់នូវភាពជារបស់លាយឡំគ្នា ដូចល្ង និងអង្ករដែលលាយគ្នា ។ បទថា **សម្មោទតិ** អធិប្បាយថា រមែងដល់នូវការប្រជុំ ក្នុងការធ្វើតាមវាចាដោយវាចា មានការសាកសួរឧទ្ទេសជាដើម គឺរមែងចូលដល់នូវភាពជាទីស្រឡាញ់ក្រៃលែង ដូចសម្លាញ់ជាទីស្រឡាញ់ ព្រាត់ប្រាសទៅយូរ ។ ម្យ៉ាងទៀត គប្បីជ្រាបថា កាលចូលដល់នូវភាពជាអ្នកធ្វើដោយភាពតែមួយខាងដើមជាមួយសម្លាញ់ទាំងនោះ ក្នុងកិច្ចដែលគួរធ្វើទាំងឡាយ ឈ្មោះថា ស្រស់ស្រាយ ។ កាលប្រព្រឹត្តទៅរហូតដល់កណ្តាល

ឈ្មោះថា រីករាយ កាលមិនប្រែប្រួលរហូតដល់ទីបំផុត ឈ្មោះថា រួសរាយ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **ឧទកលេខូបមោ** ព្រោះរួមគ្នាបានរហ័ស ដូចគំនូសក្នុងទឹក ។

[ ៩៤ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយសំពត់សម្បកឈើ មានវិនិច្ឆ័យដូចតទៅនេះ បុគ្គលទាំង ៣ ពួកនោះ ហៅថា **ពោត្ថកូបមា** ដោយឧបមាណា ដើម្បីសម្តែងពាក្យឧបមានោះ ទើបទ្រង់ត្រាស់ថា **តយោ ពោត្ថកា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **នវោ** បានដល់ សំពត់ដែលថ្មី ។ បទថា **ពោត្ថកោ** បានដល់ សំពត់ដែលត្បាញដោយសម្បកធ្មៃ ។ បទថា **ទុព្វណ្ណោ** បានដល់ សំពត់ដែលមានពណ៌អាក្រក់ ។ បទថា **ទុក្ខសម្ផស្សោ** បានដល់ សំពត់ដែលមានសម្ផស្សគ្រោតគ្រាត ។ បទថា **អប្បគ្ឃោ** បានដល់ សំពត់ដែលមានតម្លៃមិនថ្លៃ គឺមានតម្លៃប្រមាណ ១ កហាបណៈ ។ បទថា **មជ្ឈិមោ** បានដល់ សំពត់កណ្តាលថ្មី កណ្តាលចាស់ អធិប្បាយថា សំពត់នោះកន្លងភាពជារបស់ថ្មី តែមិនចូលដល់ភាពជារបស់ចាស់ ( សំពត់ជំនុំ ) ក្នុងកាលប្រើប្រាស់ក៏មានពណ៌មិនស្អាត មានសម្ផស្សមិនសប្បាយ មានតម្លៃតិច បើវាយតម្លៃ ក៏បានត្រឹមតែពាក់កណ្តាល តែក្នុងកាលសំពត់នោះចាស់ហើយ ក៏មានតម្លៃត្រឹមតែកន្លះមាសក ឬត្រឹមតែ ១ កាកណិក[១] ។ បទថា **ឧក្ខលិបរិមជ្ជនំ** បានដល់ សំពត់ជូតឆ្នាំងដែលខ្មៅ ។

[ ៩៥ ] បទថា **នវោ** សេចក្តីថា ពោលដោយឧបសម្បទា រាប់ពី ៥

១- មួយកាកណិកអាចទិញសាច់ឲ្យអ្នកស៊ីមួយចម្អែតបាន ។

វស្សាចុះមកភិក្ខុនោះមានអាយុ ៦០ ឆ្នាំ ក៏ឈ្មោះថា **នវ** គឺភិក្ខុថ្មីនោះឯង ។ បទថា **ទុព្វណ្ណតាយ** សេចក្តីថា ព្រោះមានវណ្ណៈមិនស្អាត ដោយវណ្ណៈនៃសរីរៈខ្លះ ដោយវណ្ណៈនៃគុណខ្លះ ។ ឯវណ្ណៈនៃសរីរៈរបស់បុគ្គលទ្រុស្តសីលដែលអង្គុយក្នុងកណ្តាលបរិស័ទ រមែងមិនរុងរឿង ព្រោះភាពដែលខ្លួនមិនមានអំណាចសម្រាប់ក្នុងវណ្ណៈ គឺគុណរបស់បុគ្គលទ្រុស្តសីលនោះ ក៏មិនចាំបាច់ត្រូវពោលដល់ឡើយ ។ បទថា **យេ ខោ បនស្ស** សេចក្តីថា ជនពួកណាជាអ្នកឧបដ្ឋាក ឬជាញាតិ និងជាមិត្តរបស់បុគ្គលទ្រុស្តសីលនោះជាដើម រមែងសេពគប់បុគ្គលនោះ ។ បទថា **តេសំ តំ** សេចក្តីថា ការសេពគប់នោះ រមែងមិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខអស់កាលយូរដល់បុគ្គលទាំងនោះ ដូចពួកមិច្ឆាទិដ្ឋិដែលសេពគប់គ្រូទាំង ៦ ឬដូចកោកាលិកភិក្ខុជាដើម ដែលសេពគប់ជាមួយភិក្ខុទេវទត្ត ដូច្នោះ ។ បទថា **មជ្ឈិមោ** សេចក្តីថា ពោលដោយឧបសម្បទា រាប់តាំងអំពី ៥ វស្សា រហូតដល់ ៩ វស្សា ឈ្មោះថា **មជ្ឈិមភិក្ខុ** ។ បទថា **ថេរោ** សេចក្តីថា តាំងអំពី ១០ វស្សាឡើងទៅ ឈ្មោះថា **ថេរៈ** ។ បទថា **ឯវមាហំសុ** បានដល់ រមែងពោលយ៉ាងនេះ ។ បទថា **កឹ នុ ខោ តុយ្ហំ** មានពាក្យដែលលោកអធិប្បាយថា នឹងមានប្រយោជន៍អ្វី ដោយពាក្យរបស់លោកដែលជាបុគ្គលពាល ។ បទថា **តថារូបំ** បានដល់ ដែលមានជាតិយ៉ាងនោះ មានសភាវៈយ៉ាងនោះ គឺជាហេតុនៃឧក្ខេបនីយកម្ម ( កម្មជាហេតុឲ្យសង្ឃលើកវត្ត ) ។

[ ៩៦ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយសំពត់កាសិកៈ មានវិនិច្ឆ័យដូចតទៅនេះ សំពត់សាច់ម៉ដ្ឋ ដែលគេត្បាញដោយអំបោះកប្បាស ៣ សរសៃ ឈ្មោះថា សំពត់ដែនកាសី ។ សំពត់នោះនៅថ្មី មានតម្លៃរាប់មិនបាន ជំនុំមានតម្លៃ ២ ម៉ឺនខ្លះ ៣ ម៉ឺនខ្លះ តែក្នុងពេលចាស់មានតម្លៃ ៨ ពាន់ក៏មាន ១ ម៉ឺនក៏មាន ។

[ ៩៧ ] បទថា **តេ សំ តំ ហោតិ** សេចក្ដីថា ការសេពគប់នោះរមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលយូរដល់ជនទាំងនោះ ដូចបុគ្គលទាំងឡាយដែលសេពគប់ព្រះសម្មាសម្ពុទ្ធជាដើម ព្រោះថា សត្វទាំងឡាយ ដែលអាស្រ័យព្រះសម្មាសម្ពុទ្ធមួយអង្គ ហើយរួចផុតចាកអាសវក្កិលេស រហូតដល់សម័យសព្វថ្ងៃនេះ រាប់ប្រមាណមិនបាន សត្វទាំងឡាយ ដែលអាស្រ័យព្រះសារីបុត្ត ព្រះមហាមោគ្គល្លានត្ថេរ និងព្រះអសីតិមហាសាវកដ៏សេស ហើយទៅកាន់ស្ថានសួគ៌ ក៏រាប់ប្រមាណមិនបានដូចគ្នា សូម្បីសត្វដែលប្រព្រឹត្តទៅតាមទិដ្ឋានុគតិ គឺតាមលម្អាន របស់ព្រះអរិយៈទាំងនោះ រហូតដល់សម័យសព្វថ្ងៃនេះក៏រាប់ប្រមាណមិនបានដូចគ្នា ។

បទថា **អាធេយ្យំ គច្ឆតិ** សេចក្ដីថា ពាក្យដែលអាស្រ័យប្រយោជន៍នោះរបស់ព្រះថេរៈនោះ រមែងដល់នូវភាពជារបស់ដែលបុគ្គលគប្បីរក្សា គឺដាក់លើសិរសាដែលជាអវយវៈដ៏ឧត្ដម និងក្នុងហទយៈ ដូចគ្នានឹងសំពត់ដែនកាសី ដែលមានតម្លៃកាត់ថ្លៃមិនបាន រមែងដល់នូវភាពជារបស់ដែលបុគ្គលគប្បីថែរក្សា គឺទុកក្នុងប្រអប់សម្រាប់ដាក់គ្រឿងក្រអូប ដូច្នោះ ។

ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបតាមគន្លងន័យ ដែលពោលមក ហើយ ខាងដើមនោះឯង ។

[ ៩៨ ] ក្នុងនិទ្ទេសនៃបុគ្គល ដែលគេប្រមាណបានដោយងាយជាដើម មានដូចតទៅនេះ បុគ្គលណា ដែលគេប្រមាណបានដោយងាយ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សុប្បមេយ្យោ** ។ បទថា **ឥធ** បានដល់ក្នុងសត្វលោកនេះ ។ បទថា **ឧទ្ធតោ** បានដល់ ដែលប្រកបដោយការរាយមាយ ។ បទថា **ឧន្នឡោ** បានដល់ បុគ្គលមានមានះ ដូចដើមបបុសដែលបុគ្គលលើកឡើងហើយ អធិប្បាយថា លើកនូវមានះដែលទទេ ហើយតាំងនៅ ។

បទថា **ចបលោ** បានដល់ ប្រកបដោយការឡេះឡោះ មានការប្រដាប់បាត្រជាដើម ។

បទថា **មុខរោ** បានដល់ មានមាត់រឹង ។ បទថា **វិកិណ្ណវាចោ** បានដល់ មានវាចាដែលបុគ្គលដទៃសង្កេតមិនបាន ។ បទថា **អសមាហិតោ** បានដល់ វៀរចាកភាពជាបុគ្គលមានចិត្ត មានអារម្មណ៍តែមួយ ។ បទថា **វិព្ភន្តចិត្តោ** បានដល់ ជាអ្នកមានចិត្តវិលទៅ គឺជាអ្នកមានចំណែកប្រៀបដូចមេគោដែលស្ទុះទៅ និងមេម្រឹគដែលស្ទុះទៅ ។

បទថា **បាកដិន្ទ្រិយោ** បានដល់ ជាអ្នកមានឥន្ទ្រិយបើកផ្ចារ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **សុប្បមេយ្យោ** ដូចបុគ្គលណាម្នាក់ រមែងកាន់យកប្រមាណនៃទឹកមានចំនួនតិចតួចបានងាយ

យ៉ាងណា បុគ្គលណាមួយ ក៏រមែងកាន់យកប្រមាណ បុគ្គលដែលប្រកប ដោយអង្គ ដែលមិនមែនគុណទាំងនេះ បានដោយងាយ ក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបបុគ្គលនេះ ហៅថា **សុប្បមេយ្យោ** ។

បុគ្គលណា ដែលគេគប្បីប្រមាណបានដោយក្រ ព្រោះហេតុនោះ ទើប បុគ្គលនោះ ឈ្មោះថា **ទុប្បមេយ្យោ** ។ ពាក្យថា **អនុទ្ធតោ**[១] ជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចការផ្ទុយគ្នា នឹងពាក្យដែលពោលហើយ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **ទុប្ប-មេយ្យោ** ដូចបុគ្គលណាមួយ ប្រមាណទឹកក្នុងមហាសមុទ្ទ បានដោយក្រ យ៉ាងណា បុគ្គលណាមួយ រមែងកាន់យកប្រមាណបុគ្គលដែលប្រកបដោយ អង្គនៃគុណទាំងនេះ បានដោយក្រ ក៏យ៉ាងនោះដូចគ្នា គឺរមែងដល់នូវការៈ ដែលបុគ្គលណាមួយ គប្បីពោលថា បុគ្គលនេះ ជាព្រះអនាគាមី ឬជាព្រះ ខីណាស្រពហ្ន៎ ព្រោះហេតុនោះ ទើបបុគ្គលនេះ ហៅថា **ទុប្បមេយ្យោ** ។

បុគ្គលណាមួយ មិនអាចប្រមាណបាន ព្រោះហេតុនោះ ទើបឈ្មោះថា **អប្បមេយ្យោ** ដូចបុគ្គលណាមួយ មិនអាចប្រមាណអាកាសបាន យ៉ាងណា បុគ្គលណាមួយ ក៏មិនអាចកាន់យកប្រមាណព្រះខីណាស្រពបាន ក៏យ៉ាង នោះ ដោយហេតុនោះ ទើបបុគ្គលនេះហៅថា **អប្បមេយ្យោ** ។

[ ៩៩ ] ក្នុងនិទ្ទេសនៃបុគ្គលដែលគេមិនគួរសេពជាដើម គប្បីជ្រាបដូច តទៅនេះ បទថា **ន សេវិតព្វោ** បានដល់ មិនគួរចូលទៅរក ។ បទថា

---

១- ពាក្យនេះ ជាពាក្យដែលផ្ទុយគ្នានឹងពាក្យថា ឧទ្ធតោ ខាងលើ ។

**ន ភជិតព្វោ** បានដល់ មិនគប្បីជាប់ត ។ បទថា **ន បយិរុបាសិតព្វោ** បានដល់ មិនគួរចូលទៅអង្គុយជិតរឿយៗ ដោយអំណាចអង្គុយក្នុងសម្នាក់ ។ បណ្ឌិតគប្បីជ្រាបភាពជាបុគ្គលអាក្រក់ ដោយការកាន់យកអាការប្រៀបធៀបក្នុងបទជាដើមថា **ហីនោ ហោតិ សីលេន** ។ បុគ្គលណា រក្សាសីល ៥ បុគ្គលនោះដែលអ្នករក្សាសីល ១០ មិនគប្បីសេពគប់ ឯបុគ្គលណា រក្សាសីល ១០ បុគ្គលនោះដែលអ្នករក្សាចតុប្បារិសុទ្ធិសីលមិនគប្បីសេពគប់ ។

បទថា **អញ្ញត្រ អនុទ្ទយា អញ្ញត្រ អនុកម្បា** បានដល់ វៀរចាកការអាណិតអាសូរ និងការអនុគ្រោះ អធិប្បាយថា បុគ្គលបែបនេះ ដែលបុគ្គលណាមួយ មិនគួរសេពគប់ដើម្បីជាប្រយោជន៍របស់ខ្លួនឯង តែការចូលទៅរកបុគ្គលនោះដោយអំណាចនៃសេចក្តីករុណា និងសេចក្តីអនុគ្រោះក៏សមគួរ ។

បទថា **សទិសោ ហោតិ** បានដល់ ជាអ្នកស្មើគ្នា ។ បទថា **សីលសាមញ្ញគតានំ សតំ** បានដល់ នៃសប្បុរសទាំងឡាយដល់នូវការស្មើគ្នាដោយសីល ។

បទថា **សីលកថា ច នោ ភវិស្សតិ** សេចក្តីថា ពាក្យដែលប្រារព្ធសីលនោះ នឹងមានដល់ពួកយើងដែលមានសីលស្មើគ្នាយ៉ាងនេះ ។

បទថា **សា ច នោ ផាសុ ភវិស្សតិ** បានដល់ សីលកថានោះនឹងជាការនៅជាផាសុក នឹងជាការនៅយ៉ាងសប្បាយ ដល់ពួកយើង ។ បទថា **សា ច នោ បវត្តិនី ភវិស្សតិ** សេចក្តីថា ពាក្យនោះ របស់ពួកយើង នឹង

ប្រព្រឹត្តទៅដល់ពួកយើង អ្នកពោលអស់មួយថ្ងៃ នឹងមិនរសាយអំពីសេចក្តីក្តៅក្រហាយ ។ ពិតហើយ កាលបុគ្គលទាំង ២ មានសីលស្មើគ្នា កាលបុគ្គលម្នាក់ពណ៌នាដល់សីល ម្នាក់ទៀតរមែងអនុមោទនា ព្រោះហេតុនោះ ពាក្យរបស់ជនទាំងនោះ រមែងជាទីផាសុក និងប្រព្រឹត្តទៅរហូតមិនជំទាស់គ្នា ។ កាលមានបុគ្គលទ្រុស្តសីលម្នាក់ ពាក្យដែលពោលដល់សីលជាមួយបុគ្គលដែលទ្រុស្តសីល រមែងជាពាក្យដែលពោលលំបាក ព្រោះហេតុនោះ សីលកថារមែងមិនមាន ផាសុកក៏មិនមាន រមែងប្រកែកប្រណាំង ។ ពាក្យដែលពោលដល់សមាធិ និងបញ្ញា ក៏ន័យនេះដូចគ្នា ។ ភិក្ខុ ២ រូបដែលបានសមាធិ រមែងពណ៌នាគុណរបស់សមាធិ បុគ្គលដែលមានបញ្ញា ក៏រមែងពណ៌នាគុណនៃបញ្ញា យប់ ឬថ្ងៃកន្លងទៅក៏មិនដឹងខ្លួន ។

បទថា **សក្កត្វា គរុំ កត្វា** បានដល់ ធ្វើសក្ការៈ ឬធ្វើសេចក្តីគោរព ។

បទថា **អធិកោ ហោតិ** បានដល់ ជាបុគ្គលក្រៃលែងជាង ។ បទថា **សីលក្ខន្ធំ** បានដល់ គំនរនៃសីល ។

បទថា **បរិបូរេស្សាមិ** សេចក្តីថា អញអាស្រ័យបុគ្គលដែលមានសីលដែលក្រៃលែងជាងនោះ ហើយនឹងធ្វើសីលក្ខន្ធរបស់ខ្លួនដែលមិនទាន់បរិបូណ៌ឲ្យបរិបូណ៌ ។ បទថា **តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ** នេះ គប្បីជ្រាបអត្ថថា បុគ្គលកាលវៀរធម៌ដែលមិនជាឧបការៈ មិនជាសប្បាយដល់សីល ហើយសេពនូវធម៌ដែលជាឧបការៈ ជាសប្បាយដល់សីល ឈ្មោះថាអនុគ្រោះសីលក្ខន្ធ ក្នុងឋានៈនោះដោយបញ្ញា ។ ក្នុងសមាធិក្ខន្ធ និងបញ្ញាខន្ធ

ទាំងឡាយក៏ន័យនេះដូចគ្នា ។

[ ១០០ ] ក្នុងនិទ្ទេសនៃបុគ្គលដែលគេគួរខ្ពើមជាដើម គប្បីជ្រាបដូចតទៅ បទថា **ជិគុច្ឆិតព្វោ** បានដល់ គួររង្កៀសដូចលាមក ។ បទថា **អជ ទោ ធំ** កែជា **អជ ទោ អស្ស** ដូច្នេះ ។

បទថា **កិត្តិសទ្ទោ** បានដល់ សំឡេងដែលពោលចរចា បណ្ឌិតគប្បីឃើញបុគ្គលទ្រុស្តសីលដូចរណ្តៅលាមកក្នុងពាក្យថា **ឯវមេវំ** នេះ ។ គប្បីឃើញបុគ្គលដែលទ្រុស្តសីលដូចគ្នានឹងពស់ដែលគួរខ្ពើម ដែលធ្លាក់ទៅក្នុងរណ្តៅលាមក ។ គប្បីឃើញការៈដែលបុគ្គលសេពគប់នូវបុគ្គលទ្រុស្តសីលក៏មិនធ្វើតាមទង្វើរបស់បុគ្គលនោះ ដូចការៈដែលបុរសមិនត្រូវពស់ដែលគេលើកឡើងអំពីរណ្តៅលាមក ហើយលូនលើរាងកាយចឹក ។ គប្បីឃើញការផ្សាយទៅនៃកិត្តិសព្ទដ៏អាក្រក់របស់បុគ្គលដែលសេពបុគ្គលទ្រុស្តសីល ដូចគ្នានឹងវេលាដែលពស់យកលាមកមកប្រឡាក់រាងកាយ ហើយគេចទៅ ។

បទថា **តិន្ទុកាលាតំ** បានដល់ ស្ទឹកស្ងួតនៃដើមទន្លាប់ ។ បទថា **ភិយ្យោសោ មត្តាយ ចិច្ចិដាយតិ** សេចក្តីថា ក្នុងស្ទឹកនៃដើមទន្លាប់[១] នោះកាលត្រូវដុតតាមធម្មតា រមែងមានសំឡេងផ្ទុះខ្លាំងថា ចិដិ ចិដៈ អធិប្បាយថា បន្ទឺសំឡេងខ្លាំង ។ បទថា **ឯវមេវំ** សេចក្តីថា បុគ្គលដែលច្រើនដោយសេចក្តីក្រោធតាមធម្មតារបស់ខ្លួន ក៏ធ្វើខ្លួនជាអ្នកកាយមាយ ជាអ្នកប្រទូស្តយ៉ាងនោះឯង តែកាលអ្នកដទៃ ពោលពាក្យបន្តិចបន្តួច បុគ្គលច្រើនដោយ

---

១- បិដកខ្មែរ ជាដើមជន្លោ ។

សេចក្តីក្រោធនោះ ក៏ធ្វើខ្លួនជាអ្នកវាយមាយ ជាអ្នកប្រទូស្តខ្លាំងឡើងថា បុគ្គលនេះ រមែងពោលយ៉ាងនេះ នឹងបុគ្គលដូចអញ បានដូចម្តេច ។

បទថា **គូថក្ខុរោ** បានដល់ រណ្តៅដែលពេញដោយលាមក ។ ម្យ៉ាងទៀត បានដល់ គំនរលាមកនោះឯង បណ្ឌិតគប្បីជ្រាបការប្រៀបធៀបដោយឧបមា ក្នុងបទថា **គូថក្ខុរោ** នេះ ដោយន័យមុននោះឯង ព្រោះហេតុនោះ បុគ្គលបែបនេះដែលបុគ្គលគប្បីព្រងើយ មិនគួរសេពគប់ ព្រោះបុគ្គលដែលច្រើនដោយការក្រោធនោះ កាលអ្នកដទៃ សេពគប់ច្រើនពេក ចូលទៅរកច្រើនពេក រមែងក្រោធទាំងអស់ កាលបុគ្គលដទៃចៀសចេញទៅ ក៏ក្រោធទៀតនោះឯងថា ប្រយោជន៍អ្វីដោយបុគ្គលទាំងនេះ ដូច្នោះ បុគ្គលដែលច្រើនដោយសេចក្តីក្រោធនោះ បុគ្គលគប្បីព្រងើយ មិនគួរសេពគប់ ដូចភ្លើងឆេះចំបើង ។ សេចក្តីនេះ មានពាក្យអធិប្បាយដូចម្តេច មានពាក្យអធិប្បាយថា បុគ្គលណាចូលទៅជិតភ្លើង ដែលឆេះចំបើងខ្លាំង រមែងក្តៅក្រហាយ សរីរៈរបស់ខ្លួនក៏ត្រូវភ្លើងឆេះ បុគ្គលណា ថយចេញឆ្ងាយពេក រមែងមិនកក់ក្តៅ បុគ្គលនោះរមែងមិនបាត់រងា កាលបុគ្គលនោះមិនចូលទៅជិតពេក មិនថយចេញឆ្ងាយពេក ទទួលយកកម្តៅល្មមប្រមាណ ភាពរងាឬត្រជាក់ របស់បុគ្គលនោះ រមែងបាត់ទៅ កាយរបស់បុគ្គលនោះក៏មិនត្រូវភ្លើងឆេះ ព្រោះហេតុនោះ បុគ្គលដែលច្រើនដោយសេចក្តីក្រោធដូចភ្លើងឆេះចំបើង ដែលបុគ្គលគប្បីព្រងើយ ដោយភាពជាកណ្តាល មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអន្ទយជិត ដូច្នេះឯង ។

បទថា **កល្យាណមិត្តោ** បានដល់ មានមិត្តល្អ ។ បទថា **កល្យាណសហាយោ** បានដល់ មានសម្លាញ់ល្អ ។ បទថា **សហាយោ** បានដល់ ដែលទៅព្រមគ្នា គឺត្រាច់ទៅជាមួយគ្នា ។ បទថា **កល្យាណសម្បវង្កោ** បានដល់ អ្នកចូលក្នុងវង្វង់បុគ្គលដែលល្អ បុគ្គលដែលមានធម៌ចម្រើន អធិប្បាយថា បុគ្គលមានចិត្តបង្អោនទៅ គឺត្រេកអរពេញចិត្តក្នុងមិត្តដែលមានកល្យាណធម៌នោះ ។

[ ១០១ ] ក្នុងនិទ្ទេសនៃបុគ្គលធ្វើឲ្យពេញលេញក្នុងសីលជាដើម គប្បីជ្រាបដូចតទៅ បទថា **សីលេសុ បរិបូរការិនោ** សេចក្តីថា ព្រះអរិយសាវកទាំងឡាយនេះ ហៅថា បុគ្គលធ្វើឲ្យពេញលេញក្នុងសីល ព្រោះមិនឈានកន្លងសិក្ខាបទ គឺមហាសីល ៤ គឺអាបត្តិបារាជិកដែលជាខាងដើមនៃមគ្គព្រហ្មចរិយៈ គឺដែលជាអាទិព្រហ្មចរិយៈ ព្រោះចេញចាកអាបត្តិតូចតាចដែលលោកត្រូវ និងព្រោះធ្វើវត្ថុដែលខ្ទួនគួរធ្វើក្នុងសីលទាំងឡាយ ឲ្យបរិបូណ៌ គឺឲ្យពេញលេញ ។ ព្រោះហេតុដែលលោកដកនូវកាមរាគៈ និងព្យាបាទទាំងឡាយ ដែលជាសត្រូវចំពោះសមាធិ និងដកមោហៈ ដែលបិទបាំងនូវសច្ចធម៌ដែលជាសត្រូវចំពោះបញ្ញាមិនទាន់បាន លោកទាំងនោះ ទោះបីកំពុងចម្រើននូវសមាធិ និងបញ្ញា រមែងធ្វើកិច្ចដែលបុគ្គលគប្បីធ្វើក្នុងសមាធិ និងបញ្ញាទាំងឡាយបានល្មមប្រមាណ ល្មមសមគួរ បានត្រឹមតែចំណែកខ្លះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបព្រះអរិយសាវកទាំងនោះ ហៅថា ធ្វើបន្តិចបន្តួចក្នុងសមាធិ ធ្វើបន្តិចបន្តួចក្នុងបញ្ញា បណ្ឌិតគប្បីជ្រាបអត្ថក្នុងន័យទាំង

២ ក្រៅអំពីនេះ ដោយឧបាយនេះ ។

ក្នុងន័យទាំង ២ នោះ មានន័យរបស់ព្រះសូត្រដទៃទៀត គឺព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះនៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ នៅចេញចាក ( អាបត្តិ ) ខ្លះ ។ ហេតុនោះ នឹងទៅជាអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថា ជាអភព្វក្នុងការត្រូវអាបត្តិ ហើយចេញចាកអាបត្តិនុ៎ះទេ ។ ពួកសិក្ខាបទណាជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យទី ៤ ភិក្ខុនោះ ជាអ្នកមានសីលជាប់មិនដាច់ផង មានសីលតាំងនៅផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ នៅតែបានសោតៈ ព្រោះការអស់សំយោជនៈ ៣ មានសភាព ជាអ្នកមិនបានធ្លាក់ចុះក្នុងអបាយ ជាអ្នកទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ។បេ។ ព្រោះអស់សញ្ញោជនៈ ៣ ព្រោះតែស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះម្តងទៀត ក៏ធ្វើនូវទីបំផុតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ។បេ។ សមាទាន សិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ ជាឱបបាតិកៈ ព្រោះអស់សំយោជនៈ ជាចំណែកខាងក្រោម ៥ បរិនិព្វានក្នុងស្ថានសុទ្ធាវាសនោះទៀត តែមិនត្រឡប់

មកពីលោកនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ។បេ។ សមាទាន សិក្សា ក្នុងសិក្ខាបទទាំងនោះ ភិក្ខុនោះនៅតែធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ដូច្នេះ ។

[ ១០២ ] ក្នុងនិទ្ទេសពោលអំពីបុគ្គលជាគ្រូ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ បទថា **បរិញ្ញំ បញ្ញបេតិ** បានដល់ រមែងបញ្ញត្តការលះ គឺការឈានកន្លង ។

បទថា **តត្រ**[១] បានដល់ ក្នុងគ្រូ ៣ ពួកនោះ ។

បទថា **តេន ឧដ្ឋព្វោ** សេចក្តីថា សាស្តានោះ គប្បីឃើញថា ជាអ្នកមានប្រក្រតីបាននូវរូបាវចរសមាបត្តិ ដោយបញ្ញត្តិនោះ ។ ក្នុងវារៈទី ២ ក៏មានន័យនេះដូចគ្នា ។

បទថា **សម្មាសម្ពុទ្ធោ សត្ថា តេន ឧដ្ឋព្វោ** សេចក្តីថា ព្រះសាស្តាអង្គទី ៣ ដែលជាព្រះសម្មាសម្ពុទ្ធនេះ បណ្ឌិតគប្បីឃើញដោយបញ្ញត្តិនោះ ដែលមិនសាធារណៈជាមួយតិរ្ថិយទាំងឡាយ ។ ពិតហើយ ពួកតិរ្ថិយ កាលបញ្ញត្តនូវការលះកាមទាំងឡាយ រមែងពោលអាងដល់រូបភព កាលបញ្ញត្តការលះនូវរូបទាំងឡាយ រមែងពោលអាងដល់អរូបភព កាលបញ្ញត្តនូវការលះវេទនាទាំងឡាយ រមែងពោលអាងដល់អសញ្ញីភព កាលនឹងបញ្ញត្តឲ្យ

---

១- បទនេះ បិដកខ្មែរមិនមាន តែអដ្ឋកថាមាន ទើបយើងរក្សាទុក ។

ត្រឹមត្រូវក៏គប្បីបញ្ញត្តយ៉ាងនេះ តែក៏មិនអាចបញ្ញត្តិឲ្យត្រឹមត្រូវបាន ។ ឯព្រះសម្មាសម្ពុទ្ធ រមែងបញ្ញត្តនូវការលះនូវកាមទាំងឡាយ ដោយអនាគាមិមគ្គ បញ្ញត្តការលះរូប និងវេទនាទាំងឡាយ ដោយអរហត្តមគ្គ ។ បទថា **ឥមេ តយោ សត្ថារោ** សេចក្តីថា ជនទាំង ២ ពួកនេះ ជាគ្រូខាងក្រៅ ព្រះពុទ្ធសាសនា និងព្រះសម្មាសម្ពុទ្ធមួយពួក ព្រោះហេតុនោះ ទើបក្នុងលោកនេះ មានគ្រូ ៣ ពួក ។

[ ១០៣ ] ក្នុងនិទ្ទេសនៃគ្រូពួកទី ២ បទថា **ទិដ្ឋេ ចេវ ធម្មេ** បានដល់ក្នុងអត្តភាពនេះឯង ។ បទថា **អត្តានំ សច្ចតោ ថេតតោ បញ្ញបេតិ** សេចក្តីថា រមែងបញ្ញត្តដោយការមានពិតដោយភាពជារបស់ទៀងថា ឈ្មោះថា អត្តា ១ ជារបស់ទៀង ជារបស់ស្ថិតស្ថេរ ជារបស់ពិតប្រាកដមាន ។

បទថា **អភិសម្បរាយញ្ច** បានដល់ រមែងបញ្ញត្តក្នុងអត្តភាពដទៃទៀតយ៉ាងនេះឯង ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យរបស់ពាក្យដែលពោលទុកហើយ ដូច្នេះ ៕

**អដ្ឋកថាតិកនិទ្ទេស ចប់**

# អភិធម្មបិដក

## ចតុក្កនិទ្ទេស

[ ១០៤ ] បុគ្គលជាអសប្បុរស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក តាំងនៅក្នុងសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ នេះហៅថា បុគ្គលជាអសប្បុរស ។ បុគ្គលជាអសប្បុរស ក្រៃលែងជាងអសប្បុរស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ សម្លាប់សត្វដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យសម្លាប់សត្វផង លួចទ្រព្យគេដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យលួចទ្រព្យគេផង ប្រព្រឹត្តខុសក្នុងកាមដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យប្រព្រឹត្តខុសក្នុងកាមផង និយាយកុហកដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យនិយាយកុហកផង តាំងនៅក្នុងសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យតាំងនៅក្នុងសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យផង នេះហៅថា បុគ្គលជាអសប្បុរសក្រៃលែងជាងអសប្បុរស ។ បុគ្គលជាសប្បុរស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន នេះហៅថា បុគ្គលជាសប្បុរស ។ បុគ្គលជាសប្បុរស ក្រៃលែងជាងសប្បុរស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកបាណាតិបាតផង វៀរចាកអទិន្នាទានដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកអទិន្នាទានផង វៀរចាកកាមេ-

សុមិច្ឆាចារដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យវៀរចាកកាមេសុមិច្ឆាចារផង វៀរចាកមុសាវាទដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកមុសាវាទផង វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានផង នេះហៅថា បុគ្គលជាសប្បុរសក្រៃលែងជាងសប្បុរស ។

[ ១០៥ ] បុគ្គលអាក្រក់ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យរោយរាយ មានចិត្តសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ មានចិត្តព្យាបាទ មានទិដ្ឋិខុស នេះហៅថា បុគ្គលអាក្រក់ ។ បុគ្គលអាក្រក់ក្រៃលែងជាងបុគ្គលអាក្រក់ តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យសម្លាប់សត្វផង លួចទ្រព្យគេដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យលួចទ្រព្យគេផង ប្រព្រឹត្តខុសក្នុងកាមដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យប្រព្រឹត្តខុសក្នុងកាមផង ពោលពាក្យកុហកដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យពោលពាក្យកុហកផង ពោលពាក្យញុះញង់ដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យពោលពាក្យញុះញង់ផង ពោលពាក្យអាក្រក់ដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យពោលពាក្យអាក្រក់ផង ពោលពាក្យរោយរាយដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យពោលពាក្យរោយរាយផង មានចិត្តសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យមានចិត្តសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃផង មាន

ចិត្តព្យាបាទដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យព្យាបាទផង មានទិដ្ឋិខុស ដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យមានទិដ្ឋិខុសផង នេះហៅថា បុគ្គលអាក្រក់ ក្រៃលែងជាងបុគ្គលអាក្រក់ ។ បុគ្គលល្អ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោក នេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាក សម្ផប្បលាបៈ ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ នេះ ហៅថា បុគ្គលល្អ ។ បុគ្គលល្អ ក្រៃលែងជាងបុគ្គលល្អ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯងផង បបួល អ្នកដទៃឲ្យវៀរចាកបាណាតិបាតផង វៀរចាកអទិន្នាទាន ដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកអទិន្នាទានផង វៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួន ឯងផង បបួលអ្នកដទៃឲ្យវៀរចាកកាមេសុមិច្ឆាចារផង វៀរចាកមុសាវាទ ដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកមុសាវាទផង វៀរចាកបិសុណវាចា ដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យវៀរចាកបិសុណវាចាផង វៀរចាក ផរុសវាចាដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកផរុសវាចាផង វៀរចាក សម្ផប្បលាបៈដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកសម្ផប្បលាបៈផង មិនមានអភិជ្ឈាដោយខ្លួនឯងផង បបួលអ្នកដទៃមិនឲ្យមានអភិជ្ឈាផង មិន មានចិត្តព្យាបាទ ដោយខ្លួនផង បបួលអ្នកដទៃ មិនឲ្យមានព្យាបាទផង ជា សម្មាទិដ្ឋិដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យជាសម្មាទិដ្ឋិផង នេះហៅថា បុគ្គលល្អក្រៃលែងជាងបុគ្គលល្អ ។

[ ១០៦ ] បុគ្គលមានធម៌អាក្រក់ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ។បេ។ មានទិដ្ឋិខុស នេះហៅថា បុគ្គលមានធម៌អាក្រក់ ។ បុគ្គលមានធម៌អាក្រក់ ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យសម្លាប់សត្វផង លួចទ្រព្យគេដោយខ្លួនឯងផង បបួលអ្នកដទៃ ឲ្យលួចទ្រព្យគេផង ។បេ។ មានទិដ្ឋិខុសដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យមានទិដ្ឋិខុសផង នេះហៅថា បុគ្គលមានធម៌អាក្រក់ក្រៃលែងជាងបុគ្គលមានធម៌អាក្រក់ ។ បុគ្គលមានធម៌ល្អ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន ។បេ។ ជាសម្មាទិដ្ឋិ នេះហៅថា បុគ្គលមានធម៌ល្អ ។ បុគ្គលមានធម៌ល្អក្រៃលែងជាងបុគ្គលមានធម៌ល្អ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យវៀរចាកបាណាតិបាតផង ។បេ។ ជាសម្មាទិដ្ឋិដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យជាសម្មាទិដ្ឋិផង នេះហៅថា បុគ្គលមានធម៌ល្អ ក្រៃលែងជាងបុគ្គលមានធម៌ល្អ ។

[ ១០៧ ] បុគ្គលប្រកបដោយទោស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយកាយកម្មមានទោស ប្រកបដោយវចីកម្មមានទោស ប្រកបដោយមនោកម្មមានទោស នេះហៅថា បុគ្គលប្រកបដោយទោស ។ បុគ្គលច្រើនដោយទោស តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបច្រើនដោយកាយកម្មមានទោស ប្រកបតិចដោយកាយកម្ម មិនមាន

ទោស ជាអ្នកប្រកបច្រើនដោយវចីកម្មមានទោស ប្រកបតិចដោយវចីកម្មមិនមានទោស ជាអ្នកប្រកបច្រើនដោយមនោកម្មមានទោស ប្រកបតិចដោយមនោកម្ម មិនមានទោស នេះហៅថា បុគ្គលច្រើនដោយទោស ។ បុគ្គលប្រកបដោយទោសតិច តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបច្រើនដោយកាយកម្មមិនមានទោស ប្រកបតិចដោយកាយកម្មមានទោស ជាអ្នកប្រកបច្រើន ដោយវចីកម្មមិនមានទោស ប្រកបតិចដោយវចីកម្ម មានទោស ជាអ្នកប្រកបច្រើនដោយមនោកម្មមិនមានទោស ប្រកបតិចដោយមនោកម្មមានទោស នេះហៅថា បុគ្គលប្រកបដោយទោសតិច ។ បុគ្គលមិនមានទោស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយកាយកម្មមិនមានទោស ប្រកបដោយវចីកម្មមិនមានទោស ប្រកបដោយមនោកម្ម មិនមានទោស នេះហៅថា បុគ្គលមិនមានទោស ។

[ ១០៨ ] បុគ្គលជាឧគ្ឃដិតញ្ញូ តើដូចម្តេច ។ បុគ្គលណា មានការត្រាស់ដឹងនូវមគ្គ និងផល ដំណាលគ្នានឹងវេលានៃធម៌ ដែលធម្មកថិកបង្ហើបសម្តែងហើយ នេះហៅថា បុគ្គលជាឧគ្ឃដិតញ្ញូ ។ បុគ្គលជាវិបចិតញ្ញូ តើដូចម្តេច ។ បុគ្គលណា កាលធម្មកថិកសម្តែងចែកអត្ថនៃភាសិត ដែលសង្ខេបឲ្យពិស្តារ ទើបមានការត្រាស់ដឹងនូវមគ្គ និងផល នេះហៅថា បុគ្គលវិបចិតញ្ញូ ។ បុគ្គលជានេយ្យៈ តើដូចម្តេច ។ បុគ្គលណាលុះតែរៀនបាលី រៀនអដ្ឋកថា ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា សេពគប់រក ចូលទៅអង្គុយជិតនឹងពួកកល្យាណមិត្តតាមលំដាប់យ៉ាងនេះ ទើបមានការត្រាស់ដឹងនូវមគ្គ

និងផលបាន នេះហៅថា បុគ្គលជានេយ្យៈ ។ បុគ្គលជាបទបរមៈ តើដូចម្តេច ។ បុគ្គលណា ទុកជាស្តាប់ច្រើនក៏ដោយ ពោលច្រើនក៏ដោយ ចងចាំច្រើនក៏ដោយ បង្រៀនច្រើនក៏ដោយ ក៏មិនមានការត្រាស់ដឹងនូវមគ្គ និងផលក្នុងជាតិនោះ នេះហៅថា បុគ្គលជាបទបរមៈ ។

[ ១០៩ ] បុគ្គលមានប្រាជ្ញាគួរ តែមានប្រាជ្ញាមិនរួសរាន់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើគេសួរប្រស្នា ក៏ពោលពាក្យដោះស្រាយដ៏គួរ គឺសមហេតុផល តែមិនរួសរាន់ នេះហៅថា បុគ្គលមានប្រាជ្ញាគួរ តែមានប្រាជ្ញាមិនរួសរាន់ ។ បុគ្គលមានប្រាជ្ញារួសរាន់ តែមានប្រាជ្ញាមិនគួរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើគេសួរប្រស្នា ក៏ពោលពាក្យដោះស្រាយដោយរួសរាន់តែមិនគួរ គឺមិនសមហេតុផល នេះហៅថា បុគ្គលមានប្រាជ្ញារួសរាន់ តែមានប្រាជ្ញាមិនគួរ ។ បុគ្គលមានប្រាជ្ញាគួរ ទាំងមានប្រាជ្ញារួសរាន់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើគេសួរប្រស្នា ក៏ពោលដោះស្រាយគួរផង រួសរាន់ផង នេះហៅថា បុគ្គលមានប្រាជ្ញាគួរផង មានប្រាជ្ញារួសរាន់ផង ។ បុគ្គលមានប្រាជ្ញាមិនគួរ ទាំងមានប្រាជ្ញាមិនរួសរាន់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើគេសួរប្រស្នា ក៏ពោលពាក្យដោះស្រាយមិនគួរផង មិនរួសរាន់ផង នេះហៅថា បុគ្គលមានប្រាជ្ញាមិនគួរ ទាំងមានប្រាជ្ញាមិនរួសរាន់ ។

[ ១១០ ] បណ្តាបុគ្គលទាំងនោះ បុគ្គលជាធម្មកថិក ៤ ពួក តើដូចម្តេច ។ ធម្មកថិកខ្លះ ក្នុងលោកនេះ សម្តែងធម៌តិចទេ តែប្រកបដោយ

ប្រយោជន៍ ឯបរិស័ទរបស់ធម្មកថិកនោះ ជាអ្នកមិនឈ្លាសចំពោះធម៌ប្រកប ដោយប្រយោជន៍ ទាំងមិនប្រកបដោយប្រយោជន៍ ធម្មកថិកបែបនេះ របស់ បរិស័ទបែបនេះ ក៏ដល់នូវការរាប់ថាជាធម្មកថិកដែរ ។ ធម្មកថិកខ្លះ ក្នុង លោកនេះ សម្តែងធម៌តិចទេ តែប្រកបដោយប្រយោជន៍ ឯបរិស័ទរបស់ ធម្មកថិកនោះ ជាអ្នកឈ្លាសចំពោះធម៌ប្រកបដោយប្រយោជន៍ ទាំងមិនប្រកប ដោយប្រយោជន៍ ធម្មកថិកបែបនេះរបស់បរិស័ទបែបនេះ ក៏ដល់នូវការរាប់ ថាជាធម្មកថិកដែរ ។ ធម្មកថិកខ្លះ ក្នុងលោកនេះ សម្តែងធម៌ច្រើន តែមិន ប្រកបដោយប្រយោជន៍ ឯបរិស័ទរបស់ធម្មកថិកនោះជាអ្នកមិនឈ្លាសចំពោះ ធម៌ប្រកបដោយប្រយោជន៍ ទាំងមិនប្រកបដោយប្រយោជន៍ ធម្មកថិកបែប នេះ របស់បរិស័ទបែបនេះ ក៏ដល់នូវការរាប់ថាជាធម្មកថិកដែរ ។ ធម្មកថិក ខ្លះ ក្នុងលោកនេះ សម្តែងធម៌ច្រើន ទាំងជាធម៌ប្រកបដោយប្រយោជន៍ ឯ បរិស័ទរបស់ធម្មកថិកនោះ ជាអ្នកឈ្លាសចំពោះធម៌ប្រកបដោយប្រយោជន៍ ទាំងមិនប្រកបដោយប្រយោជន៍ ធម្មកថិកបែបនេះ របស់បរិស័ទបែបនេះ ក៏ ដល់នូវការរាប់ថា ជាធម្មកថិកដែរ ។ នេះបុគ្គលជាធម្មកថិក ៤ ពួក ។

[ ១១១ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួក ប្រៀបដោយមេឃ តើដូចម្តេច ។ មេឃមាន ៤ យ៉ាង គឺ ( មេឃ ) គ្រាន់តែផ្គរតែឥតភ្លៀង ១ មានភ្លៀងតែឥតផ្គរ ១ មានទាំងផ្គរមានទាំងភ្លៀង ១ មិនមានទាំងផ្គរ មិន មានទាំងភ្លៀង ១ ។

[ ១១២ ] បុគ្គលទាំង ៤ ពួក ប្រៀបដោយមេឃនេះ តែងមានក្នុងលោក

យ៉ាងនេះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចមេឃគ្រាន់តែផ្គរ តែឥតភ្លៀង ១ បុគ្គលដូចមេឃមានភ្លៀង តែឥតផ្គរ ១ បុគ្គលដូចមេឃមានទាំងផ្គរមានទាំងភ្លៀង ១ បុគ្គលដូចមេឃមិនមានទាំងផ្គរ មិនមានទាំងភ្លៀង ១ ។ បុគ្គលដូចមេឃគ្រាន់តែផ្គរ តែឥតភ្លៀង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបានតែខាងពោល តែមិនធ្វើ បុគ្គលដូចមេឃគ្រាន់តែផ្គរ តែឥតភ្លៀងយ៉ាងនេះឯង មេឃនោះ គ្រាន់តែផ្គរតែឥតភ្លៀង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចមេឃមានភ្លៀង តែឥតផ្គរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកធ្វើ តែជាអ្នកមិនពោលឡើយ បុគ្គលដូចមេឃមានភ្លៀងតែឥតផ្គរយ៉ាងនេះឯង មេឃនោះមានភ្លៀងតែឥតផ្គរ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចមេឃ មានទាំងផ្គរ មានទាំងភ្លៀង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកពោលផង ធ្វើផង បុគ្គលដូចមេឃមានទាំងផ្គរ មានទាំងភ្លៀងយ៉ាងនេះឯង មេឃនោះ មានទាំងផ្គរ មានទាំងភ្លៀង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចមេឃមិនមានទាំងផ្គរ មិនមានទាំងភ្លៀង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនពោលផង មិនធ្វើផង បុគ្គលដូចមេឃមិនមានទាំងផ្គរ មិនមានទាំងភ្លៀង យ៉ាងនេះឯង មេឃនោះ ដែលមិនមានទាំងផ្គរ មិនមានទាំងភ្លៀង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយមេឃតែងមានក្នុងលោក ។

[ ១១៣ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួក ប្រៀបដោយសត្វកណ្តុរ តើដូចម្តេច ។ កណ្តុរមាន ៤ ពួក គឺកណ្តុរគ្រាន់តែធ្វើរន្ធ តែមិននៅ ១ គ្រាន់តែនៅ តែមិនធ្វើរន្ធ ១ ធ្វើរន្ធផង នៅផង ១ រន្ធក៏មិនធ្វើ នៅក៏មិននៅ ១ ។

[ ១១៤ ] បុគ្គល ៤ ពួក ប្រៀបដោយកណ្តុរនេះ តែងមានក្នុងលោក យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចកណ្តុរ គ្រាន់តែធ្វើរន្ធ តែមិននៅ ១ បុគ្គលដូចកណ្តុរ គ្រាន់តែនៅ តែមិនធ្វើរន្ធ ១ បុគ្គលដូចកណ្តុរធ្វើរន្ធផង នៅផង ១ បុគ្គលដូចកណ្តុររន្ធក៏មិនធ្វើ នៅក៏មិននៅ ១ ។ បុគ្គលដូចកណ្តុរគ្រាន់តែធ្វើរន្ធតែមិននៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បានរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ តែបុគ្គលនោះមិនដឹងច្បាស់តាមពិតថា នេះទុក្ខ មិនដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ មិនដឹងច្បាស់តាមពិតថា នេះធម៌រលត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រលត់ទុក្ខ បុគ្គលដូចកណ្តុរ គ្រាន់តែធ្វើរន្ធតែមិននៅ យ៉ាងនេះឯង កណ្តុរនោះធ្វើរន្ធហើយ តែមិននៅ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចកណ្តុរគ្រាន់តែនៅ តែមិនធ្វើរន្ធ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈទេ តែបុគ្គលនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើត

ទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចកណ្តុរគ្រាន់តែនៅ តែមិនធ្វើរន្ធយ៉ាងនេះឯង កណ្តុរនោះគ្រាន់តែនៅតែមិនធ្វើរន្ធ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចកណ្តុរធ្វើរន្ធផង នៅផង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ថែមទាំងបុគ្គលនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចកណ្តុរធ្វើរន្ធផង នៅផង យ៉ាងនេះឯង កណ្តុរនោះធ្វើរន្ធផង នៅផង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចកណ្តុរ រន្ធក៏មិនធ្វើ នៅក៏មិននៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ បុគ្គលនោះ ទាំងមិនដឹងច្បាស់តាមពិតថា នេះទុក្ខ មិនដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ មិនដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចកណ្តុរ រន្ធក៏មិនធ្វើនៅ ក៏មិននៅយ៉ាងនេះឯង កណ្តុរនោះ រន្ធក៏មិនធ្វើ នៅក៏មិននៅ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយសត្វកណ្តុរតែងមានក្នុងលោក ។

[ ១១៥ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួកប្រៀបដោយផ្លែស្វាយ តើដូចម្តេច ។ ផ្លែស្វាយមាន ៤ យ៉ាង គឺស្វាយខ្ចី តែមានសម្បុរទុំ ១ ស្វាយទុំ តែមានសម្បុរខ្ចី ១ ស្វាយខ្ចី មានសម្បុរខ្ចី ១ ស្វាយទុំមានសម្បុរទុំ ១ ។

[ ១១៦ ] បុគ្គល ៤ ពួក ប្រៀបដោយផ្លែស្វាយនេះ តែងមានក្នុងលោកក៏យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចស្វាយខ្ចី តែមានសម្បុរទុំ ១ បុគ្គលដូចស្វាយទុំ តែមានសម្បុរខ្ចី ១ បុគ្គលដូចស្វាយខ្ចី មានសម្បុរខ្ចី ១ បុគ្គលដូចស្វាយទុំ មានសម្បុរទុំ ១ ។ បុគ្គលដូចស្វាយខ្ចី តែមានសម្បុរទុំ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរប្រកបដោយសេចក្តីជ្រះថ្លា តែបុគ្គលនោះ មិនដឹងតាមពិតថា នេះទុក្ខ មិនដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ មិនដឹងច្បាស់តាមពិតថា នេះធម៌រលត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រលត់ទុក្ខ បុគ្គលដូចស្វាយខ្ចី តែមានសម្បុរទុំយ៉ាងនេះឯង ផ្លែស្វាយនោះខ្ចី តែមានសម្បុរទុំមានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចស្វាយទុំ តែមានសម្បុរខ្ចី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និង

ចីវរមិនប្រកបដោយសេចក្ដីជ្រះថ្លាទេ តែបុគ្គលនោះដឹងតាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌រលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ បុគ្គលដូចស្វាយទុំ តែមានសម្បុរខ្ចីយ៉ាងនេះឯង ផ្លែស្វាយនោះទុំ តែមានសម្បុរខ្ចី មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចស្វាយខ្ចីមានសម្បុរខ្ចី តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ មិនជាទីជ្រះថ្លា ថែមទាំងបុគ្គលនោះ មិនដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ មិនដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រលត់ទុក្ខ បុគ្គលដូចស្វាយខ្ចី មានសម្បុរខ្ចីយ៉ាងនេះឯង ផ្លែស្វាយនោះខ្ចី មានសម្បុរខ្ចី មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចស្វាយទុំ មានសម្បុរទុំ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ប្រកបដោយសេចក្ដីជ្រះថ្លា ថែមទាំងបុគ្គលនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ បុគ្គលដូចស្វាយទុំ មានសម្បុរទុំយ៉ាងនេះឯង ផ្លែស្វាយនោះទុំ មានសម្បុរទុំ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មាន

ឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយផ្លៃស្វាយ តែង មានក្នុងលោក ។

[ ១១៧ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួក ប្រៀបដោយក្អម តើ ដូចម្តេច ។ ក្អមមាន ៤ យ៉ាង គឺក្អមទទេ តែគ្របជិត ១ ក្អមមានទឹកពេញ តែបើកចំហ ១ ក្អមទទេ ហើយបើកចំហ ១ ក្អមមានទឹកពេញ ហើយគ្រប ជិត ១ ។

[ ១១៨ ] បុគ្គល ៤ ពួក ប្រៀបដោយក្អមនេះ តែងមានក្នុងលោក ក៏ យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចក្អមទទេ តែគ្រប ជិត ១ បុគ្គលដូចក្អមមានទឹកពេញតែបើកចំហ ១ បុគ្គលដូចក្អមទទេហើយ បើកចំហ ១ បុគ្គលដូចក្អមមានទឹកពេញហើយគ្របជិត ១ ។ បុគ្គលដូច ក្អមទទេ តែគ្របជិត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈាន ដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរប្រកប ដោយសេចក្តីជ្រះថ្លា តែបុគ្គលនោះ មិនដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ មិនដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងាប់ទុក្ខ បុគ្គល ដូចក្អមទទេ តែគ្របជិតយ៉ាងនេះឯង ក្អមនោះទទេ តែគ្របជិត មានឧបមា យ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចក្អម មានទឹកពេញ តែបើកចំហ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការ ឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើល

ចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និង ចីវរ មិនប្រកបដោយសេចក្ដីជ្រះថ្លាឡើយ តែបុគ្គលនោះ ដឹងច្បាស់តាមពិត ថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌ រម្ងត់ទុក្ខ បុគ្គលដូចក្អមមានទឹកពេញ តែបើកចំហយ៉ាងនេះឯង ក្អមនោះ មានទឹកពេញតែបើកចំហ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧប-មេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចក្អមទទេ ហើយបើកចំហ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ មិនប្រកបដោយសេចក្ដីជ្រះថ្លាទេ ថែមទាំង បុគ្គលនោះមិនដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ មិនដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចក្អមទទេ ហើយបើក ចំហយ៉ាងនេះឯង ក្អមនោះទទេ ហើយបើកចំហ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចក្អមមានទឹកពេញ ហើយ គ្របជិត តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការដើរឈានទៅមុខ ការ ឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ប្រកបដោយសេចក្ដី ជ្រះថ្លា ថែមទាំងបុគ្គលនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់ តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចក្អមមាន ទឹកពេញ ហើយគ្របជិតយ៉ាងនេះឯង ក្អមនោះមានទឹកពេញ ហើយគ្របជិត

មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួកប្រៀបដោយក្អម តែងមានក្នុងលោក ។

[ ១១៩ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួក ប្រៀបដោយអន្លង់ទឹក តើដូចម្តេច ។ អន្លង់ទឹកមាន ៤ យ៉ាង គឺអន្លង់ទឹករាក់ តែមានស្មើជ្រៅ ១ អន្លង់ទឹកជ្រៅ តែមានស្មើរាក់ ១ អន្លង់ទឹករាក់ មានស្មើរាក់ ១ អន្លង់ទឹកជ្រៅ មានស្មើជ្រៅ ១ ។

[ ១២០ ] បុគ្គល ៤ ពួក ប្រៀបដោយអន្លង់ទឹកនេះ តែងមានក្នុងលោកក៏យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចអន្លង់ទឹករាក់ តែមានស្មើជ្រៅ ១ បុគ្គលដូចអន្លង់ទឹកជ្រៅ តែមានស្មើរាក់ ១ បុគ្គលដូចអន្លង់ទឹករាក់ មានស្មើរាក់ ១ បុគ្គលដូចអន្លង់ទឹកជ្រៅ មានស្មើជ្រៅ ១ ។ បុគ្គលដូចអន្លង់ទឹករាក់ តែមានស្មើជ្រៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិបាត្រ និងចីវរ ប្រកបដោយសេចក្តីជ្រះថ្លា តែបុគ្គលនោះ មិនដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ មិនដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចអន្លង់ទឹករាក់ តែមានស្មើជ្រៅ យ៉ាងនេះឯង អន្លង់ទឹកនោះរាក់ តែមានស្មើជ្រៅ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចអន្លង់ទឹកជ្រៅ តែមានស្មើរាក់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈាន

ថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ មិនប្រកបដោយសេចក្តីជ្រះថ្លាឡើយ តែបុគ្គលនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ បុគ្គលដូចអន្លង់ទឹកជ្រៅតែមានរស្មីរាក់យ៉ាងនេះឯង អន្លង់ទឹកនោះជ្រៅ តែមានរស្មីរាក់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចអន្លង់ទឹករាក់ មានរស្មីរាក់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ មិនប្រកបដោយសេចក្តីជ្រះថ្លា ថែមទាំងបុគ្គលនោះ មិនដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ មិនដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចអន្លង់ទឹករាក់ មានរស្មីរាក់យ៉ាងនេះឯង អន្លង់ទឹកនោះរាក់ មានរស្មីរាក់មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចអន្លង់ទឹកជ្រៅ មានរស្មីជ្រៅ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មានការឈានដើរទៅមុខ ការឈានថយក្រោយ ក្រឡេកមើលចំ ក្រឡេកមើលចំហៀង បត់អវយវៈចូល លាអវយវៈចេញ ទ្រទ្រង់នូវសង្ឃាដិ បាត្រ និងចីវរ ប្រកបដោយសេចក្តីជ្រះថ្លា ថែមទាំងបុគ្គលនោះបានដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ បានដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ធម៌រម្ងត់ទុក្ខ បុគ្គលដូចអន្លង់ទឹកជ្រៅ មានរស្មីក៏

ជ្រៅយ៉ាងនេះឯង អន្លង់ទឹកនោះជ្រៅ មានរស្មីក៏ជ្រៅ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួកប្រៀបដោយអន្លង់ទឹក តែងមានក្នុងលោក ។

[ ១២១ ] បណ្ដាបុគ្គលទាំងនោះ បុគ្គល ៤ ពួកប្រៀបដោយគោបម្រើ តើដូចម្ដេច ។ គោបម្រើមាន ៤ ពួក គឺគោបម្រើកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ១ កាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ កាចក្នុងហ្វូងគោរបស់ខ្លួន ទាំងកាចក្នុងហ្វូងគោដទៃ ១ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។

[ ១២២ ] បុគ្គល ៤ ពួក ប្រៀបដោយគោបម្រើនេះ តែងមានក្នុងលោកក៏យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្ដេច ។ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ១ បុគ្គលដូចគោកាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ១ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងកាចក្នុងហ្វូងគោដទៃ ១ បុគ្គលដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ ១ ។ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកញ៉ាំងបរិស័ទរបស់ខ្លួនឲ្យតក់ស្លុត មិនញ៉ាំងបរិស័ទអ្នកដទៃឲ្យតក់ស្លុត បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃយ៉ាងនេះឯង គោបម្រើនោះ កាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចគោកាចក្នុង

ហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកញ៉ាំងបរិស័ទអ្នកដទៃ ឲ្យតក់ស្លុត មិនញ៉ាំងបរិស័ទរបស់ខ្លួនឲ្យតក់ស្លុត បុគ្គលដូចគោកាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួនយ៉ាងនេះឯង គោបម្រើនោះ កាចក្នុងហ្វូងគោដទៃ មិនកាចក្នុងហ្វូងគោរបស់ខ្លួន មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងកាចក្នុងហ្វូងគោដទៃ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកញ៉ាំងបរិស័ទរបស់ខ្លួនឲ្យតក់ស្លុតផង ញ៉ាំងបរិស័ទអ្នកដទៃឲ្យតក់ស្លុតផង បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួនផង កាចក្នុងហ្វូងគោដទៃផងយ៉ាងនេះឯង គោបម្រើនោះ កាចក្នុងហ្វូងគោរបស់ខ្លួន ទាំងកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចគោមិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនញ៉ាំងបរិស័ទរបស់ខ្លួនឲ្យតក់ស្លុត ទាំងមិនញ៉ាំងបរិស័ទអ្នកដទៃ ឲ្យតក់ស្លុត បុគ្គលដូចគោមិនកាច ក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃយ៉ាងនេះឯង គោបម្រើនោះ មិនកាចក្នុងហ្វូងគោរបស់ខ្លួន ទាំងមិនកាចក្នុងហ្វូងគោដទៃ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយគោបម្រើតែងមានក្នុងលោក ។

[ ១២៣ ] បណ្ដាបុគ្គលទាំងនោះ បុគ្គល ៤ ពួក ប្រៀបដោយសត្វអាសិរពិស តើដូចម្ដេច ។ សត្វអាសិរពិសមាន ៤ ពួក គឺអាសិរពិស

មានពិសរួសរាន់ មានពិសមិនពន្លឹក ១ មានពិសដ៏ពន្លឹក មានពិសមិនរួសរាន់ ១ មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក ១ មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។

[ ១២៤ ] បុគ្គល ៤ ពួក ប្រៀបដោយសត្វអាសិរពិស តែងមានក្នុងលោក ក៏យ៉ាងនោះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ បុគ្គលដូចអាសិរពិស មានពិសរួសរាន់ មិនមានពិសដ៏ពន្លឹក ១ មានពិសដ៏ពន្លឹក មានពិសមិនរួសរាន់ ១ មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក ១ មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹក ១ ។ បុគ្គលដូចអាសិរពិស មានពិសរួសរាន់ មិនមានពិសដ៏ពន្លឹក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ក្រោធរឿយៗ តែសេចក្តីក្រោធនោះ របស់បុគ្គលនោះ មិនបានដេកត្រាំនៅអស់កាលយូរអង្វែងទេ បុគ្គលដូចអាសិរពិស មានពិសរួសរាន់ មិនមានពិសដ៏ពន្លឹក យ៉ាងនេះឯង សត្វអាសិរពិសនោះ មានពិសរួសរាន់ មិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចអាសិរពិស មានពិសដ៏ពន្លឹក មិនមានពិសរួសរាន់ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនសូវក្រេវក្រោធរឿយៗ ទេ តែសេចក្តីក្រោធនោះរបស់បុគ្គលនោះ ( កើតឡើងម្តងៗ ) តែងដេកត្រាំនៅអស់កាលយូរអង្វែង បុគ្គលដូចអាសិរពិស មានពិសដ៏ពន្លឹក មិនមានពិសរួសរាន់យ៉ាងនេះឯង សត្វអាសិរពិសនោះ មានពិសដ៏ពន្លឹក មិនមានពិសរួសរាន់ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះ

ដែរ ។ បុគ្គលដូចអាសិរពិស មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ តែងក្រោធរឿយៗ ថែមទាំងសេចក្តីក្រោធនោះ របស់បុគ្គលនោះ តែងដេកត្រាំនៅអស់កាលយូរអង្វែង បុគ្គលដូចអាសិរពិស មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក យ៉ាងនេះឯង សត្វអាសិរពិសនោះ មានពិសរួសរាន់ ទាំងមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចអាសិរពិស មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនក្រោធរឿយៗ ថែមទាំងសេចក្តីក្រោធនោះរបស់បុគ្គលនោះ ក៏មិនដេកត្រាំនៅ អស់កាលយូរអង្វែង បុគ្គលដូចអាសិរពិស មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹកយ៉ាងនេះឯង សត្វអាសិរពិសនោះ មិនមានពិសរួសរាន់ ទាំងមិនមានពិសដ៏ពន្លឹក មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយសត្វអាសិរពិស ៤ តែងមានក្នុងលោកនេះ ។

[ ១២៥ ] បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយពោលសរសើរបុគ្គលដែលគួរតិះដៀល តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពោលសរសើរពួកតិត្ថិយ និងពួកសាវករបស់តិត្ថិយ ដែលប្រតិបត្តិអាក្រក់ ប្រតិបត្តិខុស ថាជាអ្នកប្រតិបត្តិល្អដូច្នេះក្តី ថាជាអ្នកប្រតិបត្តិត្រូវដូច្នេះក្តី បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយពោលសរសើរបុគ្គល ដែលគួរតិះដៀល យ៉ាងនេះឯង ។ បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយពោលតិះដៀល

បុគ្គលដែលគួរសរសើរ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពោលតិះដៀលព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធ ដែលប្រតិបត្តិល្អ ប្រតិបត្តិត្រូវ ថាជាអ្នកប្រតិបត្តិអាក្រក់ដូច្នេះក្ដី ថាជាអ្នកប្រតិបត្តិខុសដូច្នេះក្ដី បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរសរសើរយ៉ាងនេះឯង ។ បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយសម្ដែងសេចក្ដីជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លា តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ញុំាងសេចក្ដីជ្រះថ្លាឲ្យកើតក្នុងផ្លូវប្រតិបត្តិអាក្រក់ ក្នុងផ្លូវប្រតិបត្តិខុស ថាជាអ្នកប្រតិបត្តិល្អដូច្នេះក្ដី ថាជាផ្លូវប្រតិបត្តិត្រូវដូច្នេះក្ដី បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយសម្ដែងសេចក្ដីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា យ៉ាងនេះឯង ។ បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយសម្ដែងសេចក្ដីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ញុំាងសេចក្ដីមិនជ្រះថ្លាឲ្យកើតក្នុងផ្លូវប្រតិបត្តិល្អ ក្នុងផ្លូវប្រតិបត្តិត្រូវ ថាជាផ្លូវប្រតិបត្តិអាក្រក់ដូច្នេះក្ដី ថាជាផ្លូវប្រតិបត្តិខុសដូច្នេះក្ដី បុគ្គលមិនពិចារណា មិនស្ទង់មើល ហើយសម្ដែងសេចក្ដីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា យ៉ាងនេះឯង ។

[ ១២៦ ] បុគ្គលពិចារណា ស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរតិះដៀល តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពោលតិះដៀលពួកតិរ្ថិយ និងពួកសាវករបស់តិរ្ថិយ ដែលប្រតិបត្តិអាក្រក់ ប្រតិបត្តិខុស ថាជាអ្នកប្រតិបត្តិអាក្រក់ដូច្នេះក្ដី ថាជាអ្នកប្រតិបត្តិខុសដូច្នេះក្ដី បុគ្គលពិចារណា ស្ទង់មើល ហើយពោលតិះដៀលបុគ្គលដែលគួរតិះដៀល យ៉ាងនេះ

ឯង ។ បុគ្គលពិចារណា ស្ទង់មើល ហើយពោលសរសើរបុគ្គល ដែលគួរសរសើរ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពោលសរសើរព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធដែលប្រតិបត្តិល្អ ប្រតិបត្តិត្រូវ ថាជាអ្នកប្រតិបត្តិល្អដូច្នេះក្តី ថាជាអ្នកប្រតិបត្តិត្រូវដូច្នេះក្តី បុគ្គលពិចារណា ស្ទង់មើល ហើយពោលសរសើរបុគ្គលដែលគួរសរសើរយ៉ាងនេះឯង ។ បុគ្គលពិចារណា ស្ទង់មើល ហើយសម្តែងសេចក្តីមិនជ្រះថ្លាក្នុងទីដែលមិនគួរជ្រះថ្លា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ញុំាងសេចក្តីមិនជ្រះថ្លាឲ្យកើតក្នុងផ្លូវប្រតិបត្តិអាក្រក់ ក្នុងផ្លូវប្រតិបត្តិខុស ថាជាផ្លូវប្រតិបត្តិអាក្រក់ដូច្នេះក្តី ថាជាផ្លូវប្រតិបត្តិខុសដូច្នេះក្តី បុគ្គលពិចារណា ស្ទង់មើល ហើយសម្តែងសេចក្តីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លាយ៉ាងនេះឯង ។ បុគ្គលពិចារណា ស្ទង់មើល ហើយសម្តែងនូវសេចក្តីជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ញុំាងសេចក្តីជ្រះថ្លា ឲ្យកើតក្នុងផ្លូវប្រតិបត្តិល្អ ក្នុងផ្លូវប្រតិបត្តិត្រូវ ថាជាផ្លូវប្រតិបត្តិល្អដូច្នេះក្តី ថាជាផ្លូវប្រតិបត្តិត្រូវដូច្នេះក្តី បុគ្គលពិចារណា ស្ទង់មើល ហើយសម្តែងសេចក្តីជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លាយ៉ាងនេះឯង ។

[ ១២៧ ] បុគ្គលពោលតិះដៀលនូវបុគ្គល ដែលគួរតិះដៀលពិតប្រាកដតាមកាលគួរ មិនពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរ តើដូចម្តេច ។ គុណគួរសរសើរក៏មាន ទោសគួរតិះដៀលក៏មាន បុគ្គលខ្លះ ក្នុងលោកនេះ ទោសគួរតិះដៀលណាមានក្នុងបុគ្គលនោះ ក៏ពោលនូវទោសនោះ ពិតប្រាកដតាមកាលគួរ គុណគួរសរសើរណាមានក្នុងបុគ្គល

នោះ ក៏មិនពោលនូវគុណនោះពិតប្រាកដ តាមកាលគួរទេ បុគ្គលពោលតិះដៀលនូវបុគ្គល ដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរ មិនពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរយ៉ាងនេះឯង ។ បុគ្គលពោលសរសើរនូវបុគ្គល ដែលគួរសរសើរពិតប្រាកដ តាមកាលគួរ មិនពោលតិះដៀលនូវបុគ្គលដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរ តើដូចម្តេច ។ គុណគួរសរសើរក៏មាន ទោសគួរតិះដៀលក៏មាន បុគ្គលខ្លះ ក្នុងលោកនេះ គុណគួរសរសើរណា មានក្នុងបុគ្គលនោះ ក៏ពោលនូវគុណនោះពិតប្រាកដ តាមកាលគួរ ទោសគួរតិះដៀលណា មានក្នុងបុគ្គលនោះ មិនពោលនូវទោសនោះពិតប្រាកដ តាមកាលគួរទេ បុគ្គលពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរ តែមិនពោលតិះដៀលនូវបុគ្គលដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរ យ៉ាងនេះឯង ។ បុគ្គលពោលតិះដៀលនូវបុគ្គលដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរផង ពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរផង តើដូចម្តេច ។ គុណគួរសរសើរក៏មាន ទោសគួរតិះដៀលក៏មាន បុគ្គលខ្លះ ក្នុងលោកនេះ ទោសគួរតិះដៀលណា មានក្នុងបុគ្គលនោះ ក៏ពោលនូវទោសនោះពិតប្រាកដ តាមកាលគួរ គុណគួរសរសើរណា មានក្នុងបុគ្គលនោះ ក៏ពោលនូវគុណនោះពិតប្រាកដ តាមកាលគួរ ជាអ្នកដឹងនូវកាលគួរ ដើម្បីព្យាករណ៍នូវបញ្ហានោះ ក្នុងដំណើរនោះ បុគ្គលពោលតិះដៀលនូវបុគ្គល ដែលគួរតិះដៀលពិតប្រាកដតាមកាលគួរផង ពោលសរសើរនូវបុគ្គលដែលគួរសរសើរ

ពិតប្រាកដ តាមកាលគួរផង យ៉ាងនេះឯង ។ បុគ្គលមិនពោលតិះដៀលនូវបុគ្គលដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរផង មិនពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរផង តើដូចម្តេច ។ គុណគួរសរសើរក៏មាន ទោសគួរតិះដៀលក៏មាន បុគ្គលខ្លះ ក្នុងលោកនេះ ទោសគួរតិះដៀលណា មានក្នុងបុគ្គលនោះ មិនពោលនូវទោសនោះ ពិតប្រាកដតាមកាលផង គុណគួរសរសើរណា មានក្នុងបុគ្គលនោះ មិនពោលនូវគុណនោះពិតប្រាកដ តាមកាលគួរផង ជាបុគ្គលមានឧបេក្ខា មានស្មារតីដឹងខ្លួន បុគ្គលមិនពោលតិះដៀលនូវបុគ្គល ដែលគួរតិះដៀលពិតប្រាកដ តាមកាលគួរផង មិនពោលសរសើរនូវបុគ្គលដែលគួរសរសើរពិតប្រាកដ តាមកាលគួរផង យ៉ាងនេះឯង ។

[ ១២៨ ] បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម មិនចិញ្ចឹមជីវិតដោយផលបុណ្យ តើដូចម្តេច ។ កាលបុគ្គលណា ខំសង្វាត ប្រឹងប្រែងព្យាយាម ការចិញ្ចឹមជីវិត ទើបកើតចម្រើនឡើង មិនមែនកើតចម្រើនឡើងដោយផលបុណ្យទេ នេះហៅថា បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម មិនចិញ្ចឹមជីវិតដោយផលបុណ្យ ។ បុគ្គលចិញ្ចឹមជីវិតដោយផលបុណ្យ មិនចិញ្ចឹមជីវិត ដោយផលនៃការព្យាយាម តើដូចម្តេច ។ សំដៅយកពួកបរនិម្មិតវសវត្តីទេវតា និងពួកទេវតាជាន់លើ នៃពួកបរនិម្មិតវសវត្តីទេវតានោះ ឈ្មោះថា បុគ្គលចិញ្ចឹមជីវិតដោយផលបុណ្យ មិនចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ។ បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងចិញ្ចឹម

ជីវិតដោយផលបុណ្យ តើដូចម្តេច ។ កាលបុគ្គលណាខំសង្វាត ប្រឹងប្រែង ព្យាយាម ការចិញ្ចឹមជីវិតទើបកើតចម្រើនឡើង ទាំងកើតចម្រើនឡើងដោយផលបុណ្យ នេះហៅថា បុគ្គលចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងចិញ្ចឹមជីវិត ដោយផលបុណ្យ ។ បុគ្គលមិនចិញ្ចឹមជីវិត ដោយផលនៃការព្យាយាម ទាំងមិនចិញ្ចឹមជីវិតដោយផលបុណ្យ តើដូចម្តេច ។ ពួកសត្វនរកឈ្មោះថា បុគ្គលមិនចិញ្ចឹមជីវិតដោយផលនៃការព្យាយាម ទាំងមិនចិញ្ចឹមជីវិតដោយផលបុណ្យ ។

[ ១២៩ ] បុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខ តើដូចម្តេច ។ បុគ្គល ខ្លះក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាលក្តី ត្រកូលអ្នកនេសាទក្តី ត្រកូលអ្នកត្បាញផែងក្តី ត្រកូលជាងរថក្តី ត្រកូលអ្នកចាក់សំរាមក្តី ជាត្រកូលខ្សត់មានបាយទឹក និងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ដែលជាត្រកូលរកបាយ និងសំពត់ស្លៀកដណ្តប់បានដោយក្រ បុគ្គលនោះឯង ជាមនុស្សមានសម្បុរអាក្រក់ លំបាកមើល ជាបុគ្គលទាបតឿ មានអាពាធច្រើន គឺខ្វាក់ ឬក្ញែង ខ្វក ឬខ្វិន ជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ និងគ្រឿងប្រទីប បុគ្គលនោះ ថែមទាំងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត បុគ្គលនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត និង

នរក បុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង ។ បុគ្គលងងឹត មានពន្លឺប្រព្រឹត្តទៅខាងមុខ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាលក្ដី ត្រកូលអ្នកនេសាទក្ដី ត្រកូលអ្នកត្បាញផែងក្ដី ត្រកូលជាងរថក្ដី ត្រកូលអ្នកចាក់សំរាមក្ដី ជាត្រកូលខ្សត់ មានបាយទឹក និងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតបានដោយលំបាក ដែលជាត្រកូលរកបាយ និងសំពត់ ស្លៀកដណ្ដប់បានដោយក្រ បុគ្គលនោះឯង ជាមនុស្សមានសម្បុរអាក្រក់ លំបាកមើល ជាបុគ្គលទាបតឿ មានអាពាធច្រើន គឺខ្វាក់ ឬក្លែង ខ្វក ឬខ្វិន ជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីប តែបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះលុះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិត ដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បុគ្គលងងឹតមានពន្លឺប្រព្រឹត្តទៅខាងមុខយ៉ាងនេះឯង ។ បុគ្គលភ្លឺ មានងងឹតប្រព្រឹត្តទៅខាងមុខ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពង់ខ្ពស់ គឺត្រកូលខត្តិយ-មហាសាលក្ដី ត្រកូលព្រាហ្មណមហាសាលក្ដី ត្រកូលគហបតិមហាសាលក្ដី ជាត្រកូលស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាស និងប្រាក់ច្រើន មានទ្រព្យ និងគ្រឿងប្រើប្រាស់ច្រើន មានទ្រព្យ និងស្រូវច្រើន បុគ្គលនោះមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរនៃសរីរៈល្អ

ក្រៃលែង ជាអ្នកបានបាយទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ និងគ្រឿងប្រទីប តែបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត បុគ្គលនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក បុគ្គលក្លី មានងងឹតប្រព្រឹត្តទៅខាងមុខ យ៉ាងនេះឯង ។ បុគ្គលក្លី មានពន្លឺប្រព្រឹត្តទៅខាងមុខ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពង់ខ្ពស់ គឺត្រកូលខត្តិយមហាសាលក្តី ត្រកូលព្រាហ្មណមហាសាលក្តី ត្រកូលគហបតិមហាសាលក្តី ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាស និងប្រាក់ច្រើន មានទ្រព្យ និងគ្រឿងប្រើប្រាស់ច្រើន មានទ្រព្យ និងស្រូវច្រើន បុគ្គលនោះ មានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរនៃសរីរៈល្អក្រៃលែង ជាអ្នកបានបាយទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ និងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត បុគ្គលនោះលុះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌-ទេវលោក បុគ្គលក្លី មានពន្លឺប្រព្រឹត្តទៅខាងមុខ យ៉ាងនេះឯង ។

[ ១៣០ ] បុគ្គលឱនចុះហើយ ឱនចុះទៀត តើដូចម្តេច ។បេ។ បុគ្គល

ឱនចុះហើយ ឱនចុះទៀតយ៉ាងនេះឯង ។ បុគ្គលឱនចុះហើយងើបឡើង តើដូចម្តេច ។បេ។ បុគ្គលឱនចុះហើយងើបឡើង យ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយ ឱនចុះទៅវិញ តើដូចម្តេច ។បេ។ បុគ្គលងើបឡើងហើយ ឱនចុះទៅវិញយ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយ ងើបឡើងទៀត តើដូចម្តេច ។បេ។ បុគ្គលងើបឡើងហើយ ងើបឡើងទៀតយ៉ាងនេះឯង ។

[ ១៣១ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៤ ពួកប្រៀបដោយដើមឈើ តើដូចម្តេច ។ ឈើមាន ៤ ពួក គឺឈើស្រាយ មានឈើខ្ទឹមជាបរិវារ ១ ឈើខ្ទឹមមានឈើស្រាយជាបរិវារ ១ ឈើស្រាយមានឈើស្រាយជាបរិវារ ១ ឈើខ្ទឹមមានឈើខ្ទឹមជាបរិវារ ១ ។

[ ១៣២ ] បុគ្គល ៤ ពួក ប្រៀបដោយដើមឈើនេះ រមែងមានក្នុងលោកយ៉ាងនេះឯង ។ បុគ្គល ៤ ពួក តើដូចម្តេច ។ គឺបុគ្គលដូចឈើស្រាយ មានឈើខ្ទឹមជាបរិវារ ១ បុគ្គលដូចឈើខ្ទឹម មានឈើស្រាយជាបរិវារ ១ បុគ្គលដូចឈើស្រាយ មានឈើស្រាយជាបរិវារ ១ បុគ្គលដូចឈើខ្ទឹម មានឈើខ្ទឹមជាបរិវារ ១ ។ បុគ្គលដូចឈើស្រាយ មានឈើខ្ទឹមជាបរិវារ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ តែបរិស័ទរបស់បុគ្គលនោះ មានសីលមានធម៌ល្អ បុគ្គលដូចឈើស្រាយ មានឈើខ្ទឹមជាបរិវារយ៉ាងនេះឯង ឈើនោះស្រាយ មានឈើខ្ទឹមជាបរិវារ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចឈើខ្ទឹម មានឈើស្រាយជាបរិវារ តើដូចម្តេច ។ បុគ្គល

ខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ តែបរិស័ទរបស់បុគ្គលនោះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ បុគ្គលដូចឈើខ្លឹម មានឈើស្រាយជាបរិវារយ៉ាងនេះឯង ឈើនោះខ្លឹម មានឈើស្រាយជាបរិវារ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលដូចឈើស្រាយ មានឈើស្រាយជាបរិវារ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ទាំងបរិស័ទរបស់បុគ្គលនោះ ក៏ជាអ្នកទ្រុសសីល មានធម៌អាក្រក់ដែរ បុគ្គលដូចឈើស្រាយមានឈើស្រាយជាបរិវារយ៉ាងនេះឯង ឈើនោះស្រាយ មានឈើស្រាយជាបរិវារ មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលដូចឈើខ្លឹម មានឈើខ្លឹមជាបរិវារ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសីល មានធម៌ល្អ ទាំងបរិស័ទរបស់បុគ្គលនោះ ក៏ជាអ្នកមានសីល មានធម៌ល្អដែរ បុគ្គលដូចឈើខ្លឹម មានឈើខ្លឹមជាបរិវារយ៉ាងនេះឯង ឈើនោះខ្លឹម មានឈើខ្លឹមជាបរិវារ មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ នេះបុគ្គល ៤ ពួក ប្រៀបដោយឈើ តែងមានក្នុងលោក ។

[ ១៣៣ ] បុគ្គលរាប់អានក្នុងរូប ជ្រះថ្លាព្រោះរូប តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញកម្ពស់ក្តី ឃើញទំហំក្តី ឃើញទ្រង់ទ្រាយក្តី ឃើញរូបដ៏ពេញលេញក្តី ក៏កាន់យកនូវសេចក្តីរាប់អានក្នុងចំណែក មានកម្ពស់ជាដើមនោះ ហើយញុំាងសេចក្តីជ្រះថ្លាឲ្យកើត នេះហៅថា បុគ្គលរាប់អានក្នុង

រូប ជ្រះថ្លាព្រោះរូប ។ បុគ្គលរាប់អានក្នុងសំឡេង ជ្រះថ្លាព្រោះសំឡេង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើមានការពណ៌នារបស់បុគ្គលដទៃ ការលើកតម្កើងរបស់បុគ្គលដទៃ ការសរសើររបស់បុគ្គលដទៃ ការនាំទៅនូវគុណរបស់បុគ្គលដទៃ ក៏កាន់យកនូវសេចក្ដីរាប់អានក្នុងចំណែក មានការពណ៌នារបស់បុគ្គលដទៃជាដើមនោះ ហើយញ៉ាំងសេចក្ដីជ្រះថ្លា ឲ្យកើត នេះហៅថា បុគ្គលរាប់អានក្នុងសំឡេង ជ្រះថ្លាព្រោះសំឡេង ។ បុគ្គលរាប់អានក្នុងវត្ថុសៅហ្មង ជ្រះថ្លាព្រោះវត្ថុសៅហ្មង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញចីវរសៅហ្មងក្ដី ឃើញបាត្រសៅហ្មងក្ដី ឃើញសេនាសនៈសៅហ្មងក្ដី ឃើញអំពើដែលគេធ្វើបានដោយកម្រ មានប្រការផ្សេងៗ ក្ដី ក៏កាន់យកសេចក្ដីរាប់អានក្នុងចំណែក មានចីវរសៅហ្មងជាដើមនោះ ហើយញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើត នេះហៅថា បុគ្គលរាប់អានក្នុងវត្ថុសៅហ្មង ជ្រះថ្លា ព្រោះវត្ថុសៅហ្មង ។ បុគ្គលរាប់អានក្នុងធម៌ ជ្រះថ្លាព្រោះធម៌ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ឃើញសីលក្ដី ឃើញសមាធិក្ដី ឃើញបញ្ញាក្ដី ក៏កាន់យកសេចក្ដីរាប់អាន ក្នុងគុណ មានសីលគុណជាដើមនោះ ហើយញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើត នេះហៅថា បុគ្គលរាប់អានក្នុងធម៌ ជ្រះថ្លាព្រោះធម៌ ។

[ ១៣៤ ] បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន តែមិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌សីលដោយខ្លួនឯង មិនបបួលអ្នកដទៃឲ្យបរិបូណ៌សីលផង បរិបូណ៌

សមាធិដោយខ្លួនឯង មិនបបួលអ្នកដទៃឲ្យបរិបូរណ៍សមាធិផង បរិបូរណ៍បញ្ញាដោយខ្លួនឯង មិនបបួលអ្នកដទៃឲ្យបរិបូរណ៍បញ្ញាផង បរិបូរណ៍វិមុត្តិដោយខ្លួនឯង មិនបបួលអ្នកដទៃឲ្យបរិបូរណ៍វិមុត្តិផង បរិបូរណ៍វិមុត្តិញាណ-ទស្សនៈ ដោយខ្លួនឯង មិនបបួលអ្នកដទៃឲ្យបរិបូណ៍វិមុត្តិញាណទស្សនៈផង បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង មិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ យ៉ាងនេះឯង ។ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនបរិបូរណ៍សីលដោយខ្លួនឯង បបួលអ្នកដទៃឲ្យបរិបូរណ៍សីល មិនបរិបូរណ៍សមាធិដោយខ្លួនឯង បបួលអ្នកដទៃឲ្យបរិបូរណ៍សមាធិ មិនបរិបូរណ៍បញ្ញាដោយខ្លួនឯង បបួលអ្នកដទៃឲ្យបរិបូរណ៍បញ្ញា មិនបរិបូរណ៍វិមុត្តិដោយខ្លួនឯង បបួលអ្នកដទៃឲ្យបរិបូរណ៍វិមុត្តិ មិនបរិបូរណ៍វិមុត្តិញាណទស្សនៈដោយខ្លួនឯង បបួលអ្នកដទៃឲ្យបរិបូរណ៍វិមុត្តិញាណទស្សនៈ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង យ៉ាងនេះឯង ។ បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូរណ៍សីលដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យបរិបូរណ៍សីលផង បរិបូរណ៍សមាធិដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យបរិបូរណ៍សមាធិផង បរិបូរណ៍បញ្ញាដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យបរិបូរណ៍បញ្ញាផង បរិបូរណ៍វិមុត្តិដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យបរិបូរណ៍វិមុត្តិផង បរិបូរណ៍វិមុត្តិញាណទស្សនៈដោយខ្លួនឯងផង បបួល

អ្នកដទៃឲ្យបរិបូរណ៍វិមុត្តិញាណទស្សនៈផង បុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯងផង ប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃផងយ៉ាងនេះឯង ។ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបរិបូរណ៍សីលដោយខ្លួនឯង ទាំងមិនបបួលអ្នកដទៃឲ្យបរិបូរណ៍សីល មិនបរិបូរណ៍សមាធិដោយខ្លួនឯង ទាំងមិនបបួលអ្នកដទៃឲ្យបរិបូរណ៍សមាធិ មិនបរិបូរណ៍បញ្ញាដោយខ្លួនឯង ទាំងមិនបបួលអ្នកដទៃ ឲ្យបរិបូរណ៍បញ្ញា មិនបរិបូរណ៍វិមុត្តិដោយខ្លួនឯង ទាំងមិនបបួលអ្នកដទៃ ឲ្យបរិបូរណ៍វិមុត្តិ មិនបរិបូរណ៍វិមុត្តិញាណទស្សនៈដោយខ្លួនឯង ទាំងមិនបបួលអ្នកដទៃឲ្យបរិបូរណ៍វិមុត្តិញាណទស្សនៈ បុគ្គលមិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនឯង ទាំងមិនប្រតិបត្តិដើម្បីប្រយោជន៍បុគ្គលដទៃ យ៉ាងនេះឯង ។

[ ១៣៥ ] បុគ្គលដុតកម្ដៅខ្លួនឯង ប្រកបនូវការព្យាយាមដុតកម្ដៅខ្លួនឯង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ គ្មានសំពត់ ( អាក្រាត ) លះបង់មារយាទល្អ ស៊ីលិទ្ធដៃ ( ទាំងជម្រះឧច្ចារៈដោយម្រាមដៃ ) បើមានគេហៅថា ចូរចូលមកក៏មិនមក បើគេឃាត់ថា ចូរឈប់ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងភត្តដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្តន៍ បុគ្គលនោះមិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្ត ដែលគេនាំមកកន្លងធរណីទ្វារ មិនទទួលភត្តដែលគេនាំមកកន្លងកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកកន្លងអង្រែ មិន

ទទួលភត្តរបស់មនុស្សពីរនាក់កំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្ត របស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តដែលអបេលកសាវ័ក អង្កាសមក មិនទទួលភត្តក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំដែលត្រាំដោយស្រូវទាំងពួង បុគ្គលនោះ ទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយមួយពុំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយពីរពុំនូតខ្លះ ។បេ។ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ៧ ពុំនូតខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ១ ភាជន៍តូចខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ២ ភាជន៍តូចខ្លះ ។បេ។ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្ត ៧ ភាជន៍តូចខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ។បេ។ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ បុគ្គលប្រកបនូវសេចក្តីព្យាយាមក្នុងការផ្លាស់ប្តូរនូវការបរិភោគភត្តរំលងកន្លះខែខ្លះ មានសភាពយ៉ាងនេះ ដូច្នេះឯង បុគ្គលនោះ មានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្គួយជាអាហារខ្លះ មានកម្ទេចស្បែក ( ចំនៀរស្បែក ) ជាអាហារខ្លះ មានស្លែ ឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោស្រស់ជាអាហារខ្លះ មានមើម និងផ្លែឈើក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែ

ឈើដែលជ្រុះឯងខ្លះ បុគ្គលនោះ ទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បំសុកូលខ្លះ ទ្រទ្រង់សំពត់សម្បកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវក្រងខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសម្បកក្រចៅខ្លះ ទ្រទ្រង់ចម្រៀកក្តារជាសំពត់ខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយកន្ទុយសេះខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់ និងពុកមាត់ប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាមទុកសក់ និងពុកមាត់ខ្លះ ឈរសម្រឹង ហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោង ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមអង្គុយច្រហោងខ្លះ ដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ បុគ្គលប្រកបនូវការព្យាយាមដុតកម្តៅកាយច្រើនប្រការ មានសភាពយ៉ាងនេះ ដូច្នេះឯង បុគ្គលដុតកម្តៅខ្លួនឯង ប្រកបនូវការព្យាយាមដើម្បីដុតកម្តៅខ្លួនឯង យ៉ាងនេះឯង ។ បុគ្គលដុតកម្តៅអ្នកដទៃ ប្រកបនូវការព្យាយាមដើម្បីដុតកម្តៅអ្នកដទៃ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ម្រឹគ សម្លាប់សត្វស្លាប ជាព្រានសម្លាប់ត្រី ជាចោរ ជាអ្នកសម្លាប់ចោរ សម្លាប់គោ ជានាយគុក ពុំនោះសោត បុគ្គលដទៃណាមួយជាអ្នកធ្វើការងារអាក្រក់ បុគ្គលដុតកម្តៅអ្នកដទៃ ប្រកបនូវការព្យាយាម ដើម្បីដុតកម្តៅអ្នកដទៃ យ៉ាងនេះឯង ។ បុគ្គលដុតកម្តៅខ្លួនឯង ប្រកបនូវការព្យាយាមដើម្បី

ដុតកម្ដៅខ្លួនឯង ដុតកម្ដៅអ្នកដទៃ ប្រកបនូវការព្យាយាម ដើម្បីដុតកម្ដៅអ្នកដទៃផង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាក្សត្រទ្រង់រាជ្យដែលបានមុទ្ធាភិសេករួចហើយក្ដី ជាព្រាហ្មណមហាសាលក្ដី ព្រះរាជា ឬព្រាហ្មណ៍នោះ ឲ្យគេសាងរោងសម្រាប់ទទួលភ្ញៀវថ្មី ក្នុងទិសខាងកើតនៃនគរ ហើយកោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកជណ្ដប់ស្បែកខ្លាទាំងក្រចក លាបប្រឡាក់កាយដោយទឹកដោះថ្លា និងប្រេង អេះខ្នងដោយស្នែងនៃម្រឹគ ហើយចូលទៅកាន់រោងសម្រាប់ទទួលភ្ញៀវ ព្រមទាំងមហេសី និងព្រាហ្មណ៍ជាបុរោហិត ព្រះរាជា ឬព្រាហ្មណ៍នោះ ក៏សម្រេចនូវការដេកលើផែនដី ប្រាសចាកកម្រាលដែលគេលាបពណ៌ខៀវក្នុងទីនោះ ទឹកដោះណាមានក្នុងដោះទី ១ នៃមេគោនុ៎ះ ដែលមានកូនខ្ចី ព្រះរាជាក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណាមានក្នុងដោះទី ២ មហេសី ក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណា មានក្នុងដោះទី ៣ ព្រាហ្មណ៍ជាបុរោហិត ក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណាមានក្នុងដោះទី ៤ ក៏បូជាភ្លើងដោយទឹកដោះនោះ ឯកូនគោចិញ្ចឹមជីវិតដោយទឹកដោះដ៏សេសសល់ ព្រះរាជា ឬព្រាហ្មណ៍នោះ មានវាចាយ៉ាងនេះថា គោឈ្មោលទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយញ្ញចុះ កូនគោឈ្មោលទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយញ្ញចុះ កូនគោញីទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយញ្ញចុះ ពពែទាំងប៉ុណ្ណោះ ចូរគេសម្លាប់ ដើម្បីយញ្ញចុះ ចៀមទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយញ្ញចុះ សេះទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយញ្ញចុះ ឈើទាំងប៉ុណ្ណោះ ចូរគេកាប់ដើម្បីយញ្ញចុះ ទ្រព្យទាំង

ប៉ុណ្ណោះ ចូរពុកផុយទៅដើម្បីលំបាក ( នៃម្ចាស់ទ្រព្យ ) មួយទៀត ពួកជនទាំងឡាយណាដែលជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាកម្មករក្តី របស់ព្រះរាជា ឬព្រាហ្មណ៍នោះ ជនទាំងនោះ ត្រូវអាជ្ញាគំរាម ត្រូវភ័យគំរាម មានមុខទទឹកដោយទឹកភ្នែក ទួញយំ ធ្វើបរិកម្ម បុគ្គលដុតកម្តៅខ្លួនឯង ប្រកបនូវការព្យាយាមដើម្បីដុតកម្តៅខ្លួនឯងផង ដុតកម្តៅអ្នកដទៃ ប្រកបនូវការព្យាយាមដើម្បីដុតកម្តៅអ្នកដទៃផង យ៉ាងនេះឯង ។ បុគ្គលមិនដុតកម្តៅខ្លួនឯង មិនប្រកបនូវការព្យាយាមដើម្បីដុតកម្តៅខ្លួនឯង ទាំងមិនដុតកម្តៅអ្នកដទៃ មិនប្រកបនូវការព្យាយាមដើម្បីដុតកម្តៅអ្នកដទៃ បុគ្គលនោះមិនដុតកម្តៅខ្លួនឯង មិនដុតកម្តៅអ្នកដទៃ ជាអ្នកមិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរម្ងត់ទុក្ខ ត្រជាក់ត្រជុំ ទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរ សម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន តើដូចម្តេច។ ព្រះតថាគតកើតឡើងក្នុងលោកនេះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបានដូចនាយសារថី ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ទ្រង់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមនៃព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក

នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និង មនុស្សដ៏សេសហើយប្រកាសបាន ព្រះអង្គសម្តែងធម៌ពីរោះបទដើម ពីរោះ បទកណ្តាល និងពីរោះបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ព្រមទាំងអត្ថ ទាំង ព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតិក្តី កូនគហបតិក្តី បុគ្គល កើតក្នុងត្រកូលណាមួយក្តី តែងស្តាប់ធម៌នោះ ។ លុះបុគ្គលនោះ ស្តាប់ធម៌ នោះហើយ តែងបានចំពោះនូវសទ្ធាក្នុងព្រះតថាគត ។ បុគ្គលនោះ ប្រកប ដោយការបានចំពោះនូវសទ្ធានោះហើយ ក៏ពិចារណាដូច្នេះថា ការនៅគ្រប់ គ្រងផ្ទះ ចង្អៀតចង្អល់ណាស់ ជាផ្លូវហូរមកនៃធូលី គឺកិលេស មានតែបព្វជ្ជា ទើបមានឱកាសទូលាយ បុគ្គលខ្លះ នៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្ត ព្រហ្មចរិយធម៌ឲ្យបរិបូរណ៍តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ឲ្យដូចជាស័ង្ខដែល គេខាត់បានឡើយ បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ និងពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះ សម័យខាងក្រោយមក បុគ្គលនោះ ក៏លះបង់គំនរភោគៈតិចក្តី លះបង់គំនរ ភោគៈច្រើនក្តី លះបង់ញាតិវង្សតិចក្តី លះបង់ញាតិវង្សច្រើនក្តី ហើយកោរ សក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូល ទៅកាន់ផ្នួស ។ កាលបើបុគ្គលនោះ បួសយ៉ាងនេះហើយ ក៏សមាទាននូវ សិក្ខា និងសាជីវៈ របស់ភិក្ខុទាំងឡាយ លះបង់នូវបាណាតិបាត វៀរចាក បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មាន សេចក្តីខ្មាសអៀន ដល់នូវសេចក្តីអាណិត ជាអ្នកអនុគ្រោះ ផ្តល់ប្រយោជន៍

ដល់សត្វទាំងអស់ លះបង់នូវអទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នានូវរបស់ដែលគេឲ្យ មិនមានចិត្តលួច មានខ្លួនស្អាត លះបង់នូវអព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ប្រព្រឹត្តល្អចៀសវាង វៀរចាកមេថុនដែលជាធម៌របស់អ្នកស្រុក លះបង់នូវមុសាវាទ វៀរចាកមុសាវាទ ជាអ្នកពោលនូវពាក្យពិត តនូវពាក្យពិត មានសម្តីខ្ជាប់ខ្ជួន ពោលនូវពាក្យគួរអ្នកផងជឿបាន មិនពោលបំភ្លាត់សត្វលោកឡើយ លះបង់បិសុណវាចា វៀរចាកបិសុណវាចា គឺឮពាក្យពីខាងនេះ មិនទៅប្រាប់ខាងនោះ ដើម្បីបំបែកជនទាំងនេះឡើយ ឬឮអំពីខាងនោះ មិនប្រាប់ដល់ជនទាំងឡាយខាងនេះ ដើម្បីបំបែកជនខាងនោះឡើយ ជាអ្នកផ្សះផ្សារនូវពួកជន ដែលបែកគ្នាហើយផង ជាអ្នកជួយផ្គុំផ្តើម ចំពោះពួកជនដែលបានប្រកបដោយប្រយោជន៍ហើយផង ជាអ្នករីករាយនឹងសេចក្តីព្រមព្រៀងត្រេកអរនឹងសេចក្តីព្រមព្រៀង ពេញចិត្តនឹងសេចក្តីព្រមព្រៀង ជាអ្នកពោលតែសម្តីដែលធ្វើសេចក្តីព្រមព្រៀង ជាអ្នកលះបង់ផរុសវាចា វៀរចាកផរុស-វាចា សម្តីណាជាសម្តីឥតទោស ជាសុខដល់ត្រចៀក គួរជាទីស្រឡាញ់តាំងនៅក្នុងហឫទ័យ ជាសម្តីអ្នកក្រុង ជាទីរីករាយនៃជនច្រើន ជាទីគាប់ចិត្តនៃជនច្រើន តែងពោលតែសម្តីមានសភាពដូច្នោះ លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ពោលតាមកាលគួរ ពោលពាក្យពិត ពោលតែអត្ថពោលតែធម៌ ពោលតែវិន័យ ពោលតែសម្តីដែលគួរកប់ទុកក្នុងហឫទ័យជាសម្តីប្រកបដោយហេតុ ប្រកបដោយគ្រឿងប្រៀបធៀប ដោយកាលគួរ

មានដើម មានចុង ប្រកបដោយប្រយោជន៍ ។ បុគ្គលនោះ វៀរចាកការផ្តាច់ផ្តិលនូវពីជគាម និងភូតគាម ជាអ្នកបរិភោគតែមួយពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរការបរិភោគក្នុងកាលខុស វៀរចាកការរាំ ច្រៀង ប្រគំ និងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់សាសនា ជាអ្នកវៀរចាកការប្រដាប់តាក់តែងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ វៀរចាកការដេកលើទីសេនាសនៈខ្ពស់ និងទីសេនាសនៈដ៏ប្រសើរ វៀរចាកការទទួលមាស និងប្រាក់ វៀរការទទួលធញ្ញជាតិស្រស់ វៀរចាកការទទួលសាច់ស្រស់ វៀរចាកការទទួលស្ត្រី និងនាងកុមារី វៀរចាកការទទួលខ្ញុំស្រី និងខ្ញុំប្រុស វៀរចាកការទទួលពពែ និងចៀម វៀរចាកការទទួលមាន់ និងជ្រូក វៀរចាកការទទួលដំរី គោ សេះឈ្មោល និងសេះញី វៀរចាកការទទួលស្រែ និងចម្ការ វៀរចាកកិរិយាប្រកបរឿយៗ នូវទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំរបស់គ្រហស្ថ វៀរចាកកិរិយាលក់ដូរ វៀរចាកការឆបោកដោយជញ្ជីង ឆបោកដោយភាជន៍មាស ឆបោកដោយរង្វាស់រង្វាល់ វៀរចាកកិរិយាស៊ីរើ បញ្ឆោតបន្លំ និងការកោងកាច វៀរចាកកិរិយាកាត់ សម្លាប់ ចាប់ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់កំហែងយកទ្រព្យ ។ បុគ្គលនោះ ជាអ្នកសន្តោសដោយចីវរ ជាគ្រឿងការពារកាយ សន្តោសដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បុគ្គលនោះ បើទៅក្នុងទីណា កាន់យកត្រឹមតែចីវរ និងបិណ្ឌបាតប៉ុណ្ណោះ បក្សីសកុណជាតិ បើហើរទៅក្នុងទីណាៗ មានតែទម្ងន់ស្លាបទៅក្នុងទីនោះៗ យ៉ាងណាមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរ ជាគ្រឿងរក្សាកាយ សន្តោស

ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ ភិក្ខុនោះ ទៅក្នុងទីណាៗ កាន់យកត្រឹមតែចីវរ និងបិណ្ឌបាតប៉ុណ្ណោះទៅយ៉ាងនោះដែរ ។ ភិក្ខុនោះប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលតែសេចក្តីសុខ ដែលមិនមានទោសក្នុងសន្តាន ។ ភិក្ខុនោះ ឃើញរូបដោយភ្នែក មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់បុគ្គលនុ៎ះ ដែលមិនសង្រួមចក្ខុន្ទ្រិយ ព្រោះហេតុនៃការមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ ភ្លក្សរសដោយអណ្តាត ។បេ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ។បេ។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ អភិជ្ឈា និងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់ភិក្ខុនុ៎ះ ដែលមិនសង្រួមមនិន្ទ្រិយ ព្រោះហេតុនៃការមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ ប្រកបដោយការសង្រួមនូវឥន្ទ្រិយដ៏ប្រសើរនេះហើយ រមែងទទួលនូវសេចក្តីសុខ ដែលមិនលាយឡំដោយកិលេសក្នុងសន្តាន ។ ភិក្ខុនោះ ជាអ្នកដឹងខ្លួនក្នុងការឈានទៅមុខ និងការឈានថយក្រោយ ជាអ្នកដឹងខ្លួនក្នុងការមើលទៅមុខ និងការមើលទៅទិសផ្សេងៗ ជាអ្នកដឹងខ្លួនក្នុងការបត់ដៃជើង ឬលាដៃជើង ជាអ្នកដឹងខ្លួនក្នុងការទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ ជាអ្នកដឹងខ្លួនក្នុងការស៊ី ផឹក ទំពាស៊ី ភ្លក្សរស ជាអ្នកដឹងខ្លួនក្នុង

ការបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ជាអ្នកដឹងខ្លួនក្នុងការដើរ ឈរ អង្គុយ ដេក លក់ ភ្ញាក់ឡើង និយាយ ឬនៅស្ងៀម ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបដោយការសង្រួមនូវឥន្ទ្រិយដ៏ប្រសើរនេះផង ប្រកបដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង ប្រកបដោយសេចក្តីសន្តោសដ៏ប្រសើរនេះផង តែងគប់រកតែទីសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះ លុះធាន់បិណ្ឌបាតហើយ ក្នុងវេលាក្រោយភត្ត ក៏អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ ផ្ចង់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះលះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចេញចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់ព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនប្រកបដោយព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សព្វសត្វ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទ ជាគ្រឿងប្រទូស្ត លះបង់ថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ មានចិត្តសម្គាល់ក្នុងពន្លឺ មានសតិសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មិនមានសេចក្តីរវើរវាយ មានចិត្តស្ងប់ស្ងាត់ក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា មានវិចិកិច្ឆាកន្លងហើយ មិនមានសេចក្តីងឿងឆ្ងល់ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។ ភិក្ខុនោះលះបង់នីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម្មជាតធ្វើបញ្ញាឲ្យមានកម្លាំងថយបានហើយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយ

វិចារ មានតែបីតិ និងសុខដែលកើតអំពីសេចក្ដីស្ងាត់ ហើយសម្រេចសម្រាន្ត នៅ ព្រោះរម្ងាប់នូវវិតក្ក និងវិចារអស់ហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្ដាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង ទាំងមានសតិ និងសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះថា ធម្មតាបុគ្គលដែលបានតតិយជ្ឈានហើយ រមែងប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះហេតុនៃតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅ ព្រោះលះបង់សុខផង លះបង់ទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅក្នុងកាលមុនផង ទើបបានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនទុក្ខមិនមែនសុខ គឺជាឧបេក្ខា មានស្មារតី បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅ ។ ភិក្ខុនោះ កាលបើចិត្តតាំងនៅមាំបរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញារឭកឃើញនូវខន្ធដែលអាស្រ័យនៅក្នុងកាលមុន ។ ភិក្ខុនោះ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ។ រឭកឃើញ ដូចម្ដេចខ្លះ ។ គឺរឭកឃើញបាន ១ ជាតិខ្លះ ២

ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អស់អនេកសំវដ្តកប្បខ្លះ អនេកវិវដ្តកប្បខ្លះ និងអនេកសំវដ្ត-វិវដ្តកប្បខ្លះ ថាអាត្មាអញបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ រងសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញ ច្យុតចាកទីនោះហើយបានទៅកើតក្នុងទីឯណោះទៀត អាត្មាអញទៅកើតក្នុងទីនោះ ក៏មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ រងសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ អាត្មាអញច្យុតអំពីទីនោះ ក៏បានមកកើតក្នុងទីនេះ ។ ភិក្ខុនោះរឭកឃើញនូវបុព្វេនិវាស ច្រើនប្រការ ព្រមទាំងអាការ គឺរូប និងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះ និងគោត្ត ដោយប្រការដូច្នេះ ។ ភិក្ខុនោះ កាលបើចិត្តតាំងនៅមាំ បរិសុទ្ធផូរផង់ ឥតមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ ទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ។ ភិក្ខុនោះ មានចក្ខុទិព្វដ៏បរិសុទ្ធវិសេស កន្លងចក្ខុរបស់មនុស្សធម្មតា តែងឃើញពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមយថាកម្មថា អើហ្ន៎ សត្វ

ទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់អំពើដែលខុស លុះសត្វទាំងអម្បាលនោះ បែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងកំណើតនៃតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកឯសត្វពួកនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសត្វមិនតិះដៀលនូវព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើដែលយល់ត្រូវ លុះសត្វទាំងអម្បាលនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ភិក្ខុនោះ ដែលមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា តែងឃើញនូវពួកសត្វកំពុងច្យុតកំពុងកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមយថាកម្ម ដោយប្រការដូច្នេះឯង ។ ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវធម៌ដែលធ្វើអាសវៈឲ្យអស់ទៅ ។ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាធម៌រម្ងាត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងាត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះអាសវៈ ដឹងច្បាស់តាមពិតថា នេះហេតុឲ្យកើតអាសវៈ

ដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់អាសវៈ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងត់អាសវៈ ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈផង ។ កាលបើចិត្តរួចផុតស្រឡះហើយ ប្រាជ្ញាញាណក៏កើតមានឡើងថា ចិត្តអាត្មាអញផុតស្រឡះហើយ ។ ភិក្ខុនោះ ដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បុគ្គលមិនដុតកម្ដៅខ្លួនឯង មិនប្រកបនូវការព្យាយាម ដើម្បីដុតកម្ដៅខ្លួនឯង ទាំងមិនដុតកម្ដៅអ្នកដទៃ មិនប្រកបនូវការព្យាយាមដើម្បីដុតកម្ដៅអ្នកដទៃ បុគ្គលនោះ មិនដុតកម្ដៅខ្លួនឯង មិនដុតកម្ដៅអ្នកដទៃ ជាអ្នកមិនមានសេចក្ដីស្រេកឃ្លាន មានតែសេចក្ដីរលត់ទុក្ខ ត្រជាក់ត្រជុំ ទទួលសេចក្ដីសុខ មានខ្លួនប្រសើរ សម្រេចសម្រាន្តនៅក្នុងបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ១៣៦ ] បុគ្គលប្រកបដោយរាគៈ តើដូចម្ដេច ។ បុគ្គលដែលមិនទាន់លះបង់រាគៈ ចេញបាន នេះហៅថា បុគ្គលប្រកបដោយរាគៈ ។ បុគ្គលប្រកបដោយទោសៈ តើដូចម្ដេច ។ បុគ្គលដែលមិនទាន់លះបង់ទោសៈ ចេញបាន នេះហៅថា បុគ្គលប្រកបដោយទោសៈ ។ បុគ្គលប្រកបដោយមោហៈ តើដូចម្ដេច ។ បុគ្គលដែលមិនទាន់លះបង់មោហៈ ចេញបាន នេះហៅថា បុគ្គលប្រកបដោយមោហៈ ។ បុគ្គលប្រកបដោយមានះ តើដូចម្ដេច ។

បុគ្គលដែលមិនទាន់លះបង់មានះ ចេញបាន នេះហៅថា បុគ្គលប្រកបដោយមានះ ។

[ ១៣៧ ] បុគ្គលជាអ្នកបានចេតោសមថៈ ក្នុងសន្តាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបានសមាបត្តិ ប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី តែមិនបានលោកុត្តរមគ្គ ឬលោកុត្តរផល បុគ្គលជាអ្នកបានចេតោសមថៈ ក្នុងសន្តាន តែមិនបានអធិប្បញ្ញាធម្មវិបស្សនាយ៉ាងនេះឯង ។ បុគ្គលជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនា តែមិនបានចេតោសមថៈ ក្នុងសន្តាន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបានលោកុត្តរមគ្គ ឬលោកុត្តរផល តែមិនបានសមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បុគ្គលជាអ្នកបានអធិប្បញ្ញាធម្មវិបស្សនា តែមិនបានចេតោសមថៈក្នុងសន្តាន យ៉ាងនេះឯង ។ បុគ្គលជាអ្នកបានចេតោសមថៈ ក្នុងសន្តាន ទាំងបានអធិប្បញ្ញាធម្មវិបស្សនា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកបានសមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី បានលោកុត្តរមគ្គ ឬលោកុត្តរផល បុគ្គលជាអ្នកបានចេតោសមថៈក្នុងសន្តានផង បានអធិប្បញ្ញាធម្មវិបស្សនាផង យ៉ាងនេះឯង ។ បុគ្គលជាអ្នកមិនបានចេតោ-សមថៈ ក្នុងសន្តាន ទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានសមាបត្តិប្រកបដោយរូបក្តី ប្រកបដោយអរូបក្តី ទាំងមិនបានលោកុត្តរមគ្គ ឬលោកុត្តរផល បុគ្គលជាអ្នកមិនបានចេតោសមថៈ ក្នុងសន្តាន ទាំងមិនបានអធិប្បញ្ញាធម្មវិបស្សនា យ៉ាងនេះ

ឯង ។

[ ១៣៨ ] បុគ្គលទៅបណ្តោយតាមខ្សែទឹក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ សេពកាមទាំងឡាយផង ធ្វើបាបកម្មផង នេះហៅថា បុគ្គលទៅបណ្តោយតាមខ្សែទឹក ។ បុគ្គលទៅច្រាសខ្សែទឹក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនសេពកាមទាំងឡាយផង មិនធ្វើបាបកម្មផង បុគ្គលនោះ ខំប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញ ទាំងប្រកបដោយទុក្ខខ្លះ ទាំងប្រកបដោយទោមនស្សខ្លះ ទាំងមានមុខទទឹកដោយទឹកភ្នែក ទួញយំខ្លះ នេះហៅថា បុគ្គលទៅច្រាសខ្សែទឹក ។ បុគ្គលមានខ្លួនតាំងនៅនឹង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះការអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ជាអ្នកបរិនិព្វានក្នុងសុទ្ធាវាស-ព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ នេះហៅថា បុគ្គលមានខ្លួនតាំងនៅនឹង ។ បុគ្គលឆ្លងទៅដល់ត្រើយ ជាព្រាហ្មណ៍ស្ថិតនៅលើគោក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តមខ្លួនឯង ក្នុងបច្ចុប្បន្នទូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ នេះហៅថា បុគ្គលឆ្លងទៅដល់ត្រើយ ជាព្រាហ្មណ៍ស្ថិតនៅលើគោក ។

[ ១៣៩ ] បុគ្គលជាអ្នកចេះដឹងតិច មិនប្រតិបត្តិតាមដោយការចេះដឹង តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ មាន

ប្រមាណតិច បុគ្គលនោះ មិនដឹងនូវអត្ថនៃពុទ្ធវចនៈ ដែលមានប្រមាណតិច នោះ មិនដឹងនូវធម៌ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ បុគ្គលជាអ្នកចេះដឹងតិច មិនប្រតិបត្តិតាមដោយការចេះដឹងយ៉ាងនេះឯង ។ បុគ្គលជាអ្នកចេះដឹងតិច តែប្រតិបត្តិតាមដោយការចេះដឹង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ មានប្រមាណតិច តែបុគ្គលនោះដឹងនូវអត្ថនៃពុទ្ធវចនៈ មានប្រមាណតិចនោះ ដឹងនូវធម៌ ហើយប្រតិបត្តិធម៌តាមសមគួរដល់ធម៌ បុគ្គលជាអ្នកចេះដឹងតិច តែប្រតិបត្តិតាមដោយការចេះដឹងយ៉ាងនេះឯង ។ បុគ្គលជាអ្នកចេះដឹងច្រើន តែមិនប្រតិបត្តិតាមដោយការចេះដឹង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ មានប្រមាណច្រើន តែបុគ្គលនោះមិនដឹងនូវអត្ថនៃពុទ្ធវចនៈ មានប្រមាណច្រើននោះ មិនដឹងនូវធម៌ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ បុគ្គលជាអ្នកចេះដឹងច្រើន តែមិនប្រតិបត្តិតាមដោយការចេះដឹង យ៉ាងនេះឯង ។ បុគ្គលជាអ្នកចេះដឹងច្រើន ទាំងប្រតិបត្តិតាមដោយការចេះដឹង តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានពុទ្ធវចនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ មានប្រមាណច្រើន ទាំងបុគ្គលនោះ ដឹងនូវអត្ថនៃពុទ្ធវចនៈ មានប្រមាណច្រើន ដឹងនូវធម៌ ហើយប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ បុគ្គលជាអ្នកចេះដឹងច្រើន ទាំងប្រតិបត្តិ

តាមដោយការបេះដឹង យ៉ាងនេះឯង ។

[ ១៤០ ] បុគ្គលជាសមណៈមិនកម្រើក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកដល់នូវសោតៈ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ព្រោះការអស់ទៅនៃសញ្ញោជនៈ ៣ នេះហៅថា បុគ្គលជាសមណៈមិនកម្រើក ។ បុគ្គលជាសមណៈ ដូចផ្កាឈូកក្រហម តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាសកទាគាមី មកកាន់លោកនេះអស់វារៈម្តងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះការអស់ទៅនៃសញ្ញោជនៈ ៣ ព្រោះភាពស្រាលស្តើងនៃរាគៈ ទោសៈ និងមោហៈ នេះហៅថា បុគ្គលជាសមណៈ ដូចផ្កាឈូកក្រហម ។ បុគ្គលជាសមណៈ ដូចផ្កាឈូក-ស តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ជាឱបបាតិកកំណើត ព្រោះការអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ជាអ្នកបរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញ នេះហៅថា បុគ្គលជាសមណៈ ដូចផ្កាឈូក-ស ។ បុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះការអស់ទៅនៃអាសវៈទាំងឡាយ នេះហៅថា បុគ្គលជាសមណៈ ចម្រើនដោយសុខក្នុងពួកសមណៈ ។

**ចតុក្កនិទ្ទេស ចប់**

# អដ្ឋកថា

## ចតុក្កនិទ្ទេស

[ ១០៤ ] ក្នុងចតុក្កនិទ្ទេស គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អសប្បុរិសោ** បានដល់ បុរសដ៏លាមក គឺបុរសដែលមិនមានធម៌ ។

បុគ្គលណា ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **បាណាតិបាតី** គឺអ្នកសម្លាប់សត្វ ។

បុគ្គលណា កាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អទិន្នាទាយី** គឺអ្នកលួចទ្រព្យ ។

បុគ្គលណា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **កាមេសុមិច្ឆាចារី** គឺអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

បុគ្គលណា រមែងពោលកុហក ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **មុសាវាទី** គឺអ្នកពោលពាក្យកុហក ។

បុគ្គលណា តាំងនៅក្នុងសេចក្តីប្រមាទ ដោយការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **សុរាមេរយមជ្ជប្បមា-ទដ្ឋាយី** គឺអ្នកផឹកសុរាមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ។

បទថា **បាណាតិបាតេ សមាទបេតិ** សេចក្តីថា ខ្លួនឯង រមែងញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងទៅ ដោយប្រការណា រមែងញុំាងអ្នកដទៃឲ្យកាន់យកនូវការញុំាងសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លងទៅនោះ ដោយប្រការនោះ ។ ក្នុងពាក្យដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **អសប្បុរិសេន អសប្បុរិសតរោ** ព្រោះខ្លួនប្រកបដោយភាពជាអ្នកទ្រុស្តសីល ដែលខ្លួនធ្វើឯងផង ហើយខ្លួនក៏ជាទាយាទនៃកម្មពាក់កណ្តាលអំពីកម្មដែលខ្លួនបបួលឲ្យអ្នកដទៃធ្វើផង ។

បទថា **សប្បុរិសោ** បានដល់ ឧត្តមបុរស ។

បទថា **សប្បុរិសេន សប្បុរិសតរោ** សេចក្តីថា ព្រោះខ្លួនប្រកបព្រមដោយភាពជាអ្នកមានសីលល្អ ដែលខ្លួនធ្វើហើយនោះឯងផង និងព្រោះខ្លួនជាទាយាទនៃកម្មពាក់កណ្តាលចាកកម្មដែលខ្លួនបបួលឲ្យអ្នកដទៃធ្វើផង ទើបឈ្មោះថា ឧត្តមបុរសក្រៃលែងជាងឧត្តមបុរស ។

[ ១០៥ ] បទថា **បាបោ** សេចក្តីថា បុគ្គលប្រកបដោយបាប ១០ ប្រការ គឺអកុសលកម្មបថ ។

បទថា **កល្យាណោ** សេចក្តីថា បុគ្គលប្រកបដោយកល្យាណធម៌ ១០ ប្រការ គឺកុសលកម្មបថ ជាបុគ្គលបរិសុទ្ធ ជាបុគ្គលចម្រើន ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលខាងដើមនោះឯង ។

[ ១០៦ ] ក្នុងនិទ្ទេសនៃបុគ្គលមានធម៌អាក្រក់ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ធម៌លាមក របស់បុគ្គលនោះមាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **បាបធម្មោ** ។ ធម៌ល្អរបស់បុគ្គលនោះមាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **កល្យាណធម្មោ** ។ ពាក្យដ៏សេស

ក្នុងទីនេះ មានអត្ថងាយយល់ហើយ ។

[ ១០៧ ] ក្នុងនិទ្ទេសនៃបុគ្គល ប្រកបដោយទោសជាដើម គប្បីជ្រាប វិនិច្ឆ័យដូចតទៅនេះ បទថា **សាវជ្ជោ** បានដល់ ប្រព្រឹត្តទៅជាមួយ ទោស ។ បទថា **សាវជ្ជេន កាយកម្មេន** បានដល់ ដោយកាយកម្មដែល មានទោស មានបាណាតិបាតជាដើម ។ ក្នុងបទទាំងឡាយក្រៅអំពីនេះ ក៏ មានន័យនេះដូចគ្នា ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **សាវជ្ជោ** ដូចប្រទេសដែលពេញដោយរបស់គួរខ្ពើម មានលាមក និងគម្រង់ ជាដើម ព្រោះភាពដែលកម្មប្រកបដោយទ្វារទាំង ៣ ជារបស់មានទោស ។

បទថា **សាវជ្ជេន ពហុលំ** សេចក្តីថា កាយកម្មនៃបុគ្គលណាមានទោស នោះឯង មានច្រើន ដែលមិនមានទោសមានតិច បុគ្គលនោះ ហៅថា ជាអ្នក ប្រកបច្រើន ដោយកាយកម្មមានទោស ប្រកបតិច ដោយកាយកម្មមិនមាន ទោស ។ ក្នុងពាក្យនេះ ក៏មានន័យនេះឯង ។ សួរថា បុគ្គលណា បែបនេះ ឆ្លើយថា បុគ្គលដែលសមាទាននូវឧបោសថសីល បំពេញសីលក្នុងកាលខ្លះ ក្នុងគ្រាខ្លះ តាមធម្មតារបស់អ្នកស្រុក ឬតាមធម្មតារបស់អ្នកនិគម ។

បទថា **អយំ វុច្ចតិ** សេចក្តីថា បុគ្គលនេះ គឺបុគ្គលបែបនេះ ហៅថា **វជ្ជពហុលោ** ព្រោះហេតុដែលទោសនោះឯង ជារបស់មានច្រើន ព្រោះជា កម្មដែលប្រកបក្នុងទ្វារទាំង ៣ ។

ប្រៀបដូចផ្កាទាំងឡាយ មានពណ៌មិនស្អាតផង មានក្លិនស្អុយផង បុគ្គល

ធ្វើឲ្យជាគំនរ មានក្នុងប្រទេសណាមួយ ផ្កាវំដួល ផ្កាម្លិះ ផ្កាប្រទៀងជាដើម គប្បីធ្លាក់ទៅលើគំនរផ្កា ដែលមានក្លិនស្អុយនោះ ក្នុងទីនោះៗ យ៉ាងណា បុគ្គលនេះ គឺបុគ្គលបែបនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ ដូចផ្កាវំដួល ផ្កាម្លិះ ផ្កាប្រទៀងជាដើម ដែលគេធ្វើឲ្យជាគំនរ ដែលមានក្នុងប្រទេសមួយ ផ្កាទាំងឡាយ មានផ្កាពុទ្រាជាដើម ដែលមានពណ៌មិនស្អាត មានក្លិនស្អុយ គប្បីធ្លាក់លើគំនរនៃផ្កាទាំងនោះ ក្នុងទីនោះៗ យ៉ាងណា បុគ្គលទី ៣ គឺបុគ្គលបែបនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ។ ចំណែកបុគ្គលទី ៤ បណ្ឌិតគប្បីឃើញដូចថាសមាស ដែលពេញហើយដោយមធុរស ៤ យ៉ាង ព្រោះកម្មដែលប្រកបដោយទ្វារទាំង ៣ ជារបស់មិនមានទោស ។

ន័យរបស់អដ្ឋកថាអង្គុត្តរនិកាយ អធិប្បាយដូច្នេះថា បណ្ដាបុគ្គលទាំង ៤ ពួកនោះ បុគ្គលពួកទី ១ ចាត់ជាអន្ធពាលបុថុជ្ជន ។ ពួកទី ២ ចាត់ជាលោកិយបុថុជ្ជន ដែលធ្វើកុសលក្នុងចន្លោះៗ ។ ពួកទី ៣ បានដល់ ព្រះសោតាបន្ន សូម្បីព្រះសកទាគាមី និងព្រះអនាគាមី ក៏សង្គ្រោះដោយបុគ្គលពួកទី ៣ នេះដូចគ្នា ។ ពួកទី ៤ បានដល់ ព្រះខីណាស្រព ។

ពិតហើយ ព្រះខីណាស្រពនោះ ឈ្មោះថា **អនវជ្ជោ** ដោយចំណែកមួយ ។

[ ១០៨ ] ក្នុងនិទ្ទេសនៃបុគ្គលដែលជាឧគ្ឃដិតញ្ញូជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការត្រាស់ដឹងឆាប់រួសរាន់ ឈ្មោះថា **ឧគ្ឃដិតំ** ក្នុងបទថា **ឧគ្ឃដិតញ្ញូ** នេះ អធិប្បាយថា រមែងត្រាស់ដឹងធម៌ គ្រាន់តែលើក

មាតិកាឡើងសម្ដែងប៉ុណ្ណោះ ដោយបញ្ញា ។

បទថា **សហ ឧទាហដវេលាយ** បានដល់ ក្នុងការធ្វើមាតិកា មកតាំងទុក គឺក្នុងខណៈត្រឹមតែលើកមាតិកាមកប៉ុណ្ណោះ ។

បទថា **ធម្មាភិសមយោ** បានដល់ ការត្រាស់ដឹងសច្ចធម៌ទាំង ៤ មួយអន្លើដោយញាណ ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលអាចបញ្ជូនញាណទៅតាមក្រសែនៃធម្មទេសនា ក្នុងកាលលោកតាំងបទមាតិកាដោយសង្ខេប ដោយន័យជាដើមថា សតិប្បដ្ឋាន ៤ ហើយកាន់យកអរហត្តបាន ហៅថា **ឧគ្ឃដិតញ្ញូ** ។

បុគ្គលណា រមែងដឹងអត្ថដែលលោកអធិប្បាយធ្វើឲ្យទូលំទូលាយ គឺឲ្យពិស្ដារ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **វិបញ្ចិតញ្ញូ** ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា បុគ្គលនេះ គឺបុគ្គលអាចសម្រេចអរហត្តក្នុងកាលដែលលោកតាំងបទមាតិកាដោយសង្ខេប ហើយចែកអត្ថដោយពិស្ដារ ហៅថា **វិបញ្ចិតញ្ញូ** ។

បុគ្គលណា ដែលអ្នកដទៃគប្បីដឹកនាំ ដោយបទទាំងឡាយ មានឧទ្ទេសជាដើម ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **នេយ្យោ** ។

បទថា **អនុបុព្វេន ធម្មាភិសមយោ ហោតិ** បានដល់ ការសម្រេចអរហត្តតាមលំដាប់ ។

បទនៃព្យញ្ជនៈនោះ ក្រៃលែងរបស់បុគ្គលនោះ ព្រោះហេតុនោះ ទើប

បុគ្គលនោះ ឈ្មោះថា **បទបរមោ** ។

បទថា **ន តាយ ជាតិយា ធម្មាភិសមយោ ហោតិ** អធិប្បាយថា បទបរមបុគ្គលនោះ មិនអាចធ្វើឈាន វិបស្សនា មគ្គ ផល ឲ្យកើតឡើង បានដោយអត្តភាពនោះ ។

[ ១០៩ ] ក្នុងនិទ្ទេសនៃបុគ្គលមានប្រាជ្ញាគួរជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ញាណក្តី ពាក្យដែលតាំងឡើង ព្រោះញាណក្តី ហៅថា បដិភាណ ។ បដិភាណនោះ ព្រះមានព្រះភាគ ទ្រង់បំណងយកក្នុងពាក្យថា បុគ្គលមានប្រាជ្ញាគួរនេះ ។

បដិភាណដែលសមគួរដល់ហេតុ និងសមគួរដល់ផលរបស់បុគ្គលនោះ មាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **យុត្តប្បដិភាណោ** ។ បដិភាណដែលមិនរហ័សរបស់បុគ្គលនោះមាន ព្រោះខ្លួនមិនអាចឆ្លើយបញ្ហា បានដោយរហ័សក្នុងខណៈដែលគេសួរបញ្ហានោះឯង ព្រោះហេតុនោះ ទើប បុគ្គលនោះ ឈ្មោះថា **នោ មុត្តប្បដិភាណោ** ។ បុគ្គលដ៏សេស បណ្ឌិត គប្បីជ្រាបដោយន័យនេះ ។

ក្នុងបុគ្គលទាំងនេះ បុគ្គលពួកទី ១ ពិចារណាបញ្ហា អស់កាលត្រឹមតែ តិចតួច ហើយសម្រឹងបញ្ហាបានត្រឹមត្រូវមួយរំពេច ដូចព្រះបូឡនាគត្ថេរអ្នក ទ្រទ្រង់ព្រះត្រៃបិដក ។ បានឮថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហា កំណត់ ហើយ ពោលហេតុនៃបញ្ហាបានត្រឹមត្រូវ និងសមគួរនោះឯង ។

បុគ្គលពួកទី ២ រមែងឃាត់នូវវាចាក្នុងរវាងពាក្យសួរ ពិចារណាហើយ

ក៏នៅតែឆ្លើយបញ្ហាមិនបានត្រឹមត្រូវ ដូចព្រះតិស្សត្ថេរជាអ្នកឈ្លាស ត្រឹមតែនិកាយ ៤ ។ បានឮថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហាហើយ មិនរង់ចាំឲ្យចប់ពាក្យសួរ ក៏ឆ្លើយរឿយៗ ទៅ តែលុះលោកពិចារណាសេចក្តីនៃពាក្យ ក៏មិនជួបនូវភាពច្បាស់លាស់ឡើយ ។

បុគ្គលពួកទី ៣ លោកសម្តែង គឺឆ្លើយបញ្ហាបានត្រឹមត្រូវ សមគួរដល់ពាក្យសួរនោះឯង គឺរមែងឆ្លើយបានក្នុងខណៈនោះឯង ដូចព្រះចូឡាភយត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ។ បានឮថា ព្រះថេរៈនោះ ត្រូវគេសួរបញ្ហាហើយ រមែងឆ្លើយបានដោយរហ័ស មានហេតុផលត្រឹមត្រូវ និងសមគួរទៀតផង ។

បុគ្គលពួកទី ៤ ត្រូវគេសួរបញ្ហាហើយ រមែងមិនសម្តែងបញ្ហា គឺឆ្លើយមិនបានត្រឹមត្រូវ និងមិនអាចពោលឆ្លើយភ្លាមៗ បាន ដូចបុគ្គលលិចចុះក្នុងទីងងឹត ដូចព្រះលាឡុទាយិត្ថេរ ។

[ ១១០ ] ក្នុងនិទ្ទេសនៃបុគ្គលជាធម្មកថិក គប្បីជ្រាបវិនិច្ឆ័យដូចតទៅ បទថា **អប្បញ្ច ភាសតិ** សេចក្តីថា រមែងពោលត្រឹមតែបន្តិចបន្តួច ដល់បរិស័ទដែលមកដល់ហើយ ។ បទថា **អសហិតញ្ច** សេចក្តីថា កាលពោល ក៏រមែងពោលឲ្យសមគួរដល់ហេតុផល ។

បទថា **បរិសា ចស្ស អកុសលា ហោតិ** អធិប្បាយថា បរិស័ទដែលអង្គុយប្រជុំគ្នាដើម្បីស្តាប់ធម៌ រមែងមិនដឹងវត្ថុដែលគួរ និងមិនគួរ មានហេតុ ឬមិនមានហេតុ ពីរោះ ឬមិនពីរោះ ។

បទថា **ឯវរូបោ** សេចក្តីថា ធម្មកថិកល្ងង់ខ្លៅនេះ គឺមានលក្ខណៈយ៉ាង

នេះ រមែងបានឈ្មោះថា ធម្មកថិករបស់បរិស័ទល្វង់ខ្លៅដែលមានលក្ខណៈយ៉ាងនោះប៉ុណ្ណោះ ។ បណ្ឌិតគប្បីជ្រាបអត្ថគ្រប់បទដោយន័យនេះ ។ ក្នុងធម្មកថិកទាំងនេះ ធម្មកថិក ២ ពួកប៉ុណ្ណោះ ឈ្មោះថា ជាធម្មកថិកពិត ឯធម្មកថិកក្រៅពីនេះ ទ្រង់ត្រាស់យ៉ាងនោះ ព្រោះនៅក្នុងរវាងនៃធម្មកថិកទាំងឡាយ ។

[ ១១១-១១២ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយមេឃ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វលាហកា** បានដល់ ដុំពពក ។ បទថា **គជ្ជិតា** បានដល់ ផ្គរគំរាម ។ ក្នុងសេចក្តីនោះ ឈ្មោះថា ផ្គរគំរាមហើយ ភ្លៀងមិនធ្លាក់ រមែងជារឿងអាក្រក់ ព្រោះថា កាលណាផ្គរ មនុស្សទាំងឡាយគិតថា មានភ្លៀងល្អ ទើបនាំគ្នាយកពូជចេញទៅព្រោះ កាលភ្លៀងមិនធ្លាក់ ពូជដែលមានក្នុងស្រែ ក៏វិនាសទៅក្នុងស្រែនោះឯង ពូជដែលមាននៅក្នុងស្រុក ក៏វិនាសទៅក្នុងស្រុកនោះឯង ព្រោះហេតុនោះ ក៏នឹងកើតទុព្ភិក្ខភ័យ ។ ភាវៈដែលផ្គរមិនគ្រហឹម តែភ្លៀងធ្លាក់ ក៏ជារឿងអាក្រក់ដូចគ្នា ព្រោះថា មនុស្សទាំងឡាយ រមែងធ្វើការសាបព្រោះពូជក្នុងស្រែជម្រៅនោះឯង ដោយគិតថា ពេលនេះ ភ្លៀងនឹងធ្លាក់តិច ពេលនោះ ភ្លៀងក៏ធ្លាក់ខ្លាំង នាំពូជទាំងឡាយទៅកាន់មហាសមុទ្ទ រមែងកើតទុព្ភិក្ខភ័យបានដូចគ្នា តែភាវៈដែលផ្គរហើយភ្លៀងធ្លាក់ រាប់ថា ជារឿងល្អ ព្រោះថា ពេលនោះ ជាពេលដែលមានកិច្ចការកបានងាយ ។ ភាវៈដែលផ្គរមិនគ្រហឹម ភ្លៀងក៏មិនធ្លាក់ ឈ្មោះថា ជារឿងអាក្រក់បំផុត ។

បទថា **ភាសិតា ហោតិ នោ កត្តា** សេចក្តីថា បុគ្គលពោលថា ឥឡូវនេះ ខ្ញុំនឹងបំពេញគន្ថធុរៈ ឬនឹងបំពេញវិបស្សនាធុរៈនោះឯង តែមិនរៀនឧទ្ទេស និងមិនចម្រើនកម្មដ្ឋាន ។

បទថា **កត្តា ហោតិ នោ ភាសិតា** សេចក្តីថា បុគ្គលមិនពោលថា ឥឡូវនេះ ខ្ញុំនឹងបំពេញគន្ថធុរៈ ឬនឹងបំពេញវិបស្សនាធុរៈ តែលុះដល់វេលាហើយ រមែងញុំាងប្រយោជន៍នោះ ឲ្យបរិបូណ៌ពេញលេញ ។ បណ្ឌិតគប្បីជ្រាបបុគ្គលក្រៅអំពីនេះដោយន័យនេះ ។ ពាក្យទាំងអស់នោះ លោកពោលដោយបុគ្គល ដែលឲ្យបច្ច័យបានដូចគ្នា ។ ពិតហើយ ទាយកម្នាក់និមន្តព្រះសង្ឃដោយពោលថា ខ្ញុំនឹងថ្វាយទានក្នុងថ្ងៃឈ្មោះនោះ កាលដល់ពេលហើយក៏មិនធ្វើ បុគ្គលនេះ រមែងសាបសូន្យចាកបុណ្យ ភិក្ខុសង្ឃក៏វិនាសចាកលាភ ប្រៀបដូចមានផ្ការ តែមិនមានក្លៀង ។ ទាយកមួយពួកទៀត មិននិមន្តព្រះសង្ឃឡើយ ធ្វើសក្ការៈ ហើយគិតថា អញនឹងនាំភិក្ខុមក រមែងមិនបានសង្ឃ ព្រោះសង្ឃទាំងអស់ត្រូវបុគ្គលដទៃនិមន្តទៅកាន់ទីដទៃហើយ បុគ្គលនេះ តែងសាបសូន្យចាកបុណ្យ សង្ឃក៏សាបសូន្យចាកលាភនោះ ប្រៀបដូចក្លៀងធ្លាក់ ផ្ការមិនគំរាម ។ ឯទាយកមួយពួកទៀត និមន្តសង្ឃមុនហើយចាត់ចែងសក្ការៈខាងក្រោយ ហើយទើបឲ្យទាន បុគ្គលនេះ ឈ្មោះថា រមែងធ្វើកិច្ចដែលត្រឹមត្រូវ ប្រៀបដូចផ្ការគំរាម ក្លៀងក៏ធ្លាក់ ។ បុគ្គលមួយពួកទៀត សង្ឃក៏មិននិមន្ត ទានក៏មិនថ្វាយ បុគ្គលនេះ បណ្ឌិតគប្បីជ្រាបថា ជាបាបបុគ្គល ប្រៀបដូចផ្ការមិនគ្រហឹម ក្លៀងក៏មិនធ្លាក់ ។

[ ១១៣-១១៤ ] ក្នុងនិទ្ទេសនៃបុគ្គល ប្រៀបដោយសត្វកណ្ដុរ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **គាធំ កត្តា ណោ វសិតា** សេចក្ដីថា កណ្ដុរពួកទី ១ រមែងកាយរន្ធ ឲ្យជាទីនៅអាស្រ័យរបស់ខ្លួន តែមិននៅក្នុងរន្ធនោះ ទៅនៅក្នុងទីមួយទៀត កាលបើដូច្នេះ កណ្ដុរនោះ រមែងទៅកាន់អំណាចរបស់សត្រូវ មានឆ្មាជាដើម បាលីថា **១ត្តា** ជីក ដូច្នេះក៏មាន ។ បទថា **វសិតា ណោ គាធំ កត្តា** សេចក្ដីថា កណ្ដុរពួកទី ២ មិនកាយរន្ធនៅឯង តែអាស្រ័យរន្ធដែលសត្វដទៃកាយ រមែងរក្សាជីវិតបាន ដោយអាការយ៉ាងនេះ ។ កណ្ដុរពួកទី ៣ ធ្វើកិច្ចទាំង ២ យ៉ាង រមែងរក្សាជីវិតបាន កណ្ដុរពួកទី ៤ មិនធ្វើកិច្ចទាំង ២ យ៉ាង កណ្ដុរនោះ រមែងទៅកាន់អំណាចរបស់សត្រូវ ។

បណ្ដាបុគ្គលទាំងឡាយដែលលោកឧបមាហើយ ដោយការប្រៀបធៀបនេះ បុគ្គលពួកទី ១ រៀនទូវពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា មានអង្គ ៩ ដូចគ្នានឹងកណ្ដុរដែលកាយរន្ធសម្រាប់នៅ ។ ម្យ៉ាងទៀត កណ្ដុរនោះមិននៅក្នុងរន្ធ ដែលខ្លួនកាយ តែទៅនៅក្នុងទីណាមួយនោះឯង រមែងទៅកាន់អំណាចរបស់សត្រូវ យ៉ាងណា បុគ្គលនេះ បញ្ជូនញាណទៅដោយអំណាចនៃការសិក្សារៀនសូធ្យ តែមិនចាក់ធ្លុះអរិយសច្ចទាំង ៤ កាលប្រព្រឹត្តបែបនេះក្នុងទី ( ដែលមាន ) លោកាមិសទាំងឡាយ បុគ្គលនោះ រមែងទៅកាន់អំណាចរបស់សត្រូវទាំងឡាយ ពោល គឺមច្ចុមារ កិលេសមារ និងទេវបុត្តមារក៏យ៉ាងនោះ ។ បុគ្គលពួកទី ២ មិនរៀនពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា

មានអង្គ ៩ ប្រៀបដូចកណ្ដុរនោះ មិនកាយរន្ធសម្រាប់នៅ ។ ម្យ៉ាងទៀត កណ្ដុរនោះ អាស្រ័យក្នុងរន្ធដែលកណ្ដុរដទៃកាយហើយ កណ្ដុរនោះ រមែងរក្សាជីវិតបាន យ៉ាងណា ភិក្ខុនេះ ស្ដាប់ធម្មកថារបស់អ្នកដទៃហើយ ក៏ចាក់ធ្លុះសច្ចធម៌ទាំង ៤ ឈានកន្លងអំណាចនៃមារទាំង ៣ បាន ក៏យ៉ាងនោះ ។ បណ្ឌិតគប្បីជ្រាបការឧបមា ក្នុងបុគ្គលពួកទី ៣ និងទី ៤ ដោយន័យនេះឯង ។

[ ១១៥-១១៦ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយផ្លែស្វាយ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អាមំ បក្កវណ្ណី** បានដល់ ខ្ចីខាងក្នុង តែខាងក្រៅដូចស្វាយទុំ ។ បទថា **បក្កំ អាមវណ្ណី** បានដល់ ខាងក្នុងទុំ តែខាងក្រៅដូចស្វាយខ្ចី ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងសេចក្ដីនោះ សម្រាប់ស្វាយដែលមិនទុំជារបស់ខ្ចី យ៉ាងណា សម្រាប់បុគ្គល ភាពជាបុថុជ្ជន ដូចគ្នានឹងផ្លែស្វាយខ្ចី ភាពជាព្រះអរិយៈ ក៏ដូចគ្នានឹងផ្លែស្វាយទុំ ក៏យ៉ាងនោះ ។ បណ្ឌិតគប្បីជ្រាបការប្រៀបធៀបដោយឧបមាក្នុងបុគ្គលដែលលោកឧបមាហើយ ដោយន័យនេះថា សម្រាប់ស្វាយនោះ ភាពដែលស្វាយនោះទុំ គឺមានពណ៌ជាស្វាយទុំ យ៉ាងណា ក្នុងបុគ្គលក៏យ៉ាងនោះ ភាពមានឥរិយាបថដូចគ្នានឹងឥរិយាបថ មានការឈានទៅមុខជាដើមរបស់ព្រះអរិយៈទាំងឡាយ គឺភាពជាបុគ្គលមានពណ៌ដូចស្វាយទុំ ។

[ ១១៧-១១៨ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយក្អម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **កុម្ភោ** បានដល់ ក្អម ។ បទថា **តុច្ឆោ** បានដល់

ខាងក្នុងទទេ ។ បទថា **បិហិតោ** បានដល់ ក្អមដែលគេបិទមាត់តម្កល់ទុក ។ បទថា **បុរោ** បានដល់ ខាងក្នុងពេញ ។ បទថា **វិវដោ** បានដល់ ក្អមដែលគេបើកមាត់តម្កល់ទុក ។ បណ្តាបុគ្គលដែលលោកឧបមាហើយ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា ជាបុគ្គលទទេ ព្រោះវៀរចាកសារៈ គឺគុណដែលមានខាងក្នុង និងឈ្មោះថា ជាបុគ្គលបិទ ព្រោះភាពជាអ្នកល្អខាងក្រៅ ។ ក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។

[ ១១៩-១២០ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយអន្លង់ទឹក គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា កាលទឹកជ្រៅមានប្រមាណត្រឹមក្បាលជង្គង់ តែអន្លង់ទឹក មើលមិនឃើញ ព្រោះជាទឹកមានពណ៌ដែលមានវត្ថុលាយឡំ ឬព្រោះជាទឹកល្អក់ ឈ្មោះថា ជាទឹករាក់មានស្រមោលជ្រៅ ។ សូម្បីងជម្រៅប្រមាណ ៣-៤ ជួរបុរស អន្លង់ទឹកមើលឃើញបាតដី មានផ្ទៃទឹកប្រាកដ ព្រោះជាទឹកថ្លា ឈ្មោះថា ជាទឹកជ្រៅមានស្រមោលរាក់ ។ បណ្ឌិតគប្បីជ្រាបអន្លង់ទឹកទាំង ២ ក្រៅអំពីនេះ ព្រោះកើតឡើងដោយហេតុ ២ យ៉ាង សូម្បីបុគ្គល ដែលប្រកបដោយឥរិយាបថទាំងឡាយ មានការឈានទៅខាងមុខជាដើម ដែលដូចគ្នានឹងបុគ្គលដែលមានគុណជ្រាលជ្រៅ តែព្រោះខ្លួនមានកិលេសក្រាស់ និងព្រោះមិនមានគុណធម៌ដែលជ្រាលជ្រៅ ទើបឈ្មោះថា ដូចទឹករាក់ ដែលមានស្រមោលជ្រៅ ។ បុគ្គលដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យនេះឯង ។

[ ១២១-១២២ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយគោបម្រើ គប្បីជ្រាប

វិនិច្ឆ័យដូចតទៅនេះថា គប្បីជ្រាបគោបម្រើមុន គោណារមែងបៀតបៀន គឺរមែងធ្វើហ្វូងគោរបស់ខ្លួនឲ្យខ្ចាច តែស្ងប់ស្ងៀម មានប្រក្រតីនៅសប្បាយក្នុងហ្វូងគោដទៃ គោនេះ ឈ្មោះថា គោបម្រើកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ។ បុគ្គលក៏យ៉ាងនោះ បៀតបៀនបរិស័ទរបស់ខ្លួន ហៅដោយពាក្យគ្រោតគ្រាត តែជាអ្នកស្ងប់ស្ងៀម ប្រព្រឹត្តឱនលំទោនក្នុងបរិស័ទដទៃ ឈ្មោះថា បុគ្គលដូចគោកាចក្នុងហ្វូងគោរបស់ខ្លួន មិនកាចក្នុងហ្វូងគោដទៃ ។ បុគ្គលដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យនេះ ។ ក្នុងនិទ្ទេសវារបទថា **ឧព្វេជិតា ហោតិ** នេះ បានដល់ ទ្រគោះបោះបោក បៀតបៀន គឺធ្វើឲ្យតក់ស្លុត ឲ្យខ្ចាចនោះឯង ។

[ ១២៣-១២៤ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយសត្វអាសិរពិស គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះថា គប្បីជ្រាបអាសិរពិសមុន ពិសរបស់ពស់ណាជ្រួតជ្រាបរហ័ស គឺផ្សាយទៅដោយរហ័ស តែមានពិសមិនខ្លាំងក្លា មិនបៀតបៀនយូរ ពស់នេះ ឈ្មោះថា មានពិសរួសរាន់ មានពិសមិនពន្លឹក[១] ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ការចែកបុគ្គល ក៏មានន័យងាយយល់ហើយ ។

[ ១២៥-១២៧ ] ក្នុងបទថា **អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសិតា ហោតិ** ជាដើម គប្បីជ្រាបដូចតទៅ

បទថា **អននុវិច្ច** បានដល់ មិនពិចារណា គឺមិនសម្ទឹងពិនិត្យ ។

១- ជ្រួតជ្រាបរហ័ស តែមានពិសមិនខ្លាំងក្លា ។

បទថា **អបរិយោគាហេត្វា** បានដល់ មិនពិចារណាគុណទាំងឡាយដោយបញ្ញា ។

បទថា **ភូតំ តច្ឆំ** បានដល់ ឈ្មោះថា **ភូតំ** ព្រោះជារបស់មាន ឈ្មោះថា **តច្ឆំ** ព្រោះជារបស់មិនវិបរិត ។ បទថា **កាលេន** បានដល់ តាមកាលដែលគួរ និងសមគួរ ។ បទថា **តត្រ**[១] **កាលញ្ញូ ហោតិ** សេចក្តីថា ក្នុងបទដែលលោកពោលថា **កាលេន** បុគ្គលណាជាអ្នកដឹងកាល គឺជាអ្នកដឹងពេលវេលា ដើម្បីប្រយោជន៍ដល់ការព្យាករណ៍បញ្ហានោះថា កាលនេះខ្ញុំត្រូវគេសួរបញ្ហាមិនគួរពោល ក្នុងកាលនេះគួរពោល បុគ្គលនេះ ឈ្មោះថា ពោលតាមកាល ។ បទថា **ឧបេក្ខកោ វិហរតិ** បានដល់ ដែលតាំងនៅក្នុងឧបេក្ខា ដែលមានភាពជាកណ្តាល ។ ក្នុងបទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។

[ ១២៨ ] ក្នុងនិទ្ទេសនៃបុគ្គលចិញ្ចឹមជីវិត ដោយផលនៃការព្យាយាមជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បុគ្គលណា ប្រើពេលវេលាកន្លងទៅអស់មួយថ្ងៃ ដោយសេចក្តីព្យាយាម គឺការព្យាយាមនោះឯង បានវត្ថុណាមួយដែលជាផលដែលកើតអំពីការព្យាយាមនោះ ហើយចិញ្ចឹមជីវិត តែបុគ្គលនោះ អាស្រ័យសេចក្តីព្យាយាមនោះ មិនបានផលនៃបុណ្យណាមួយទ្រទ្រង់សំដៅយកបុគ្គលនោះ ទើបត្រាស់ពាក្យថា **យស្ស បុគ្គលស្ស ឧដ្ឋ-ហានោ** ដូច្នេះជាដើម ។

---

១- បិដកខ្មែរជា តត្ថ ។

បទថា **តតូបរិ ទេវា** បានដល់ ទេវតាទាំងឡាយខាងលើអំពីនោះ មានពួកព្រហ្មជាដើម ។ ពិតហើយ ឈ្មោះថា កិច្ច គឺការងារដោយការប្រឹងប្រែងព្យាយាម រមែងមិនមានដល់ពួកទេវតាទាំងនោះ ពួកទេវតាទាំងនោះ អាស្រ័យផលបុណ្យប៉ុណ្ណោះរស់នៅ ។

បទថា **បុញ្ញវតោ** ច នេះ ទ្រង់ត្រាស់សំដៅដល់ជនទាំងឡាយដែលមានបុណ្យ មានក្សត្រមហាសាល ព្រាហ្មណមហាសាល និងទេវតាទាំងឡាយ ចាប់ពីភុម្មទេវតារហូតដល់ទេវតាជាន់និម្មានរតីជាទីបំផុត ព្រោះទេវតានិងមនុស្សទាំងនោះ សោយផលនៃការព្យាយាម និងផលនៃបុណ្យ ឯសត្វនរកទាំងឡាយ មិនអាចធ្វើអាជីវៈឲ្យកើតឡើងដោយសេចក្តីព្យាយាមបានទេ អាជីវៈណាមួយ ដែលកើតឡើងដល់សត្វនរកទាំងនោះ ដោយផលនៃបុណ្យ ក៏មិនមាន ។

[ ១២៩ ] ក្នុងនិទ្ទេសនៃបុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បុគ្គលណាប្រកបដោយងងឹត គឺកើតមកក្នុងត្រកូលថោកទាបជាដើម ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **តមោ** ។ បុគ្គលឈ្មោះថា **តមបរាយណោ** ព្រោះការចូលដល់នូវភាពងងឹតក្នុងនរកទៀត ដោយទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ។

បទថា **នេសាទកុលេ** បានដល់ ត្រកូលព្រានម្រឹគជាដើម ។ បទថា **វេនកុលេ** បានដល់ ត្រកូលជាងផែង ។ បទថា **រថការកុលេ** បានដល់ ត្រកូលជាងស្បែក ។ បទថា **បុក្កុសកុលេ** បានដល់ ត្រកូលអ្នកចោលផ្កា

គឺចាក់សំរាម ។ បទថា **កសិរវុត្តិកេ** បានដល់ មានភាពជាអ្នកលំបាក ។ បទថា **ទុព្វណ្ណោ** បានដល់ បុគ្គលនោះ មានពណ៌សម្បុរដូចជន្លត់ដែលត្រូវភ្លើងឆេះ ដូចបិសាចប្រឡាក់ធូលី ។ បទថា **ទុទ្ទសិកោ** បានដល់ សូម្បីតែម្ដាយបង្កើតឃើញហើយ ក៏មិនពេញចិត្ត ។ បទថា **ឱកោដិមកោ** បានដល់ ជាបុគ្គលតឿ ។ បទថា **កាណោ** បានដល់ មានភ្នែកខ្វាក់ម្ខាង ឬទាំងសងខាង ។ បទថា **កុណី** បានដល់ មានដៃក្ងែងម្ខាង ឬក្ងែងទាំងសងខាង ។ បទថា **ខញ្ជោ** បានដល់ មានជើងខ្ចកម្ខាង ឬទាំងសងខាង ។ បទថា **បក្ខហតោ** បានដល់ បុគ្គលត្រូវរោគកម្វាត់មួយចំហៀង គឺជាបុគ្គលខ្វិន ។ បទថា **បទីបេយ្យស្ស** បានដល់ ឧបករណ៍នៃប្រទីប មានប្រេង និងចង្កៀងជាដើម ។

ក្នុងបទថា **ឯវំ បុគ្គលោ តមោ ហោតិ តមបរាយណោ** នេះ លោកអធិប្បាយថា បុគ្គលមួយពួក មិនឃើញពន្លឺខាងក្រៅ ធ្វើកាលកិរិយាក្នុងផ្ទៃមាតានោះឯង ហើយទៅកើតក្នុងអបាយទាំងឡាយ បុគ្គលនោះរមែងអន្ទោលទៅអស់កប្បទាំងមូល បុគ្គលនោះឈ្មោះថា **តមោ តមបរាយណោ** នោះឯង បុគ្គលនោះ ជាកុហកបុគ្គល គឺបុគ្គលបោកប្រាស ឯការកើតនៃកុហកបុគ្គលនោះ មានសភាវៈបែបនេះ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ លោកសម្ដែងការវិបត្តិនៃការមក និងការវិបត្តិនៃបច្ច័យដែលកើតឡើងខាងដើមរបស់បុគ្គលនោះ ដោយបទថា **នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា** ដូច្នេះជាដើម ។ ទ្រង់សម្ដែង

ការវិបត្តិនៃបច្ច័យ ដោយពាក្យថា **ទលិទ្ទេ** ជាដើម ។ ទ្រង់សម្តែងការវិបត្តិនៃឧបាយជាគ្រឿងចិញ្ចឹមជីវិតដោយពាក្យថា **កសិវុត្តិកោ** ជាដើម ។ ទ្រង់សម្តែងការវិបត្តិនៃរូបដោយពាក្យថា **ទុព្វណ្ណោ** ជាដើម ។ ទ្រង់សម្តែងការប្រកបព្រមដោយហេតុនៃទុក្ខដោយពាក្យថា **ពហ្វាពាធោ** ជាដើម ។ ទ្រង់សម្តែងការវិបត្តិហេតុនៃសេចក្តីសុខ និងការវិបត្តិនៃគ្រឿងឧបភោគ ដោយពាក្យថា **ន លាភី** ជាដើម ។ ទ្រង់សម្តែងការប្រកបហេតុនៃងងឹត ប្រព្រឹត្តទៅខាងមុខ ដោយពាក្យថា **កាយេន ទុច្ចរិតំ** ជាដើម ។ ទ្រង់សម្តែងការចូលដល់នូវភាពងងឹតក្នុងភពខាងមុខ ដោយពាក្យថា **កាយស្ស ភេទា** ជាដើម ។ បណ្ឌិតគប្បីជ្រាបធម៌ចំណែក-ស ដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

ម្យ៉ាងទៀត ក្នុងអធិការនេះ ឈ្មោះថា **ជោតិ** ប្រកបដោយភាពរុងរឿង មានការត្រឡប់មកកើតក្នុងត្រកូល ដែលបរិបូណ៌ ៣ គឺខត្តិយមហាសាល ព្រាហ្មណមហាសាល និងគហបតិមហាសាលជាដើម មានពាក្យអធិប្បាយថា ជាបុគ្គលភ្លឺទូទៅ ។ ឈ្មោះថា **ជោតិបរាយណោ** ព្រោះការចូលដល់ភាពជាអ្នកភ្លឺស្វាងដោយការកើតឡើងក្នុងស្ថានសួគ៌ ដោយសុចរិតទាំងឡាយមានកាយសុចរិតជាដើម ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ខត្តិយមហាសាលកុលេ វា** ជាដើម ដូចតទៅនេះ បទថា **ខត្តិយមហាសាលា** បានដល់ ក្សត្រដែលមានទ្រព្យជាសារៈច្រើន គឺក្សត្រដែលដល់ព្រមដោយសារសម្បត្តិច្រើន ។

ក្សត្រទាំងឡាយណាមានទ្រព្យយ៉ាងតិច ១០០ កោដិកប់ទុក និងបានតាំងទ្រព្យ ៣ ក្អម ធ្វើឲ្យជាគំនរក្នុងផ្ទះ ដើម្បីជាប្រយោជន៍ដល់ការប្រើប្រាស់ ( មួយថ្ងៃ ) ក្សត្រទាំងនោះ ឈ្មោះថា ខត្តិយមហាសាល ព្រាហ្មណ៍ទាំងឡាយណា មានទ្រព្យ ៨០ កោដិកប់ទុក និងតម្កល់ទ្រព្យ ១ ក្អមកន្លះសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ព្រាហ្មណ៍ទាំងនោះ ឈ្មោះថា ព្រាហ្មណមហាសាល ។ គហបតីទាំងឡាយណា មានទ្រព្យ ៤០ កោដិសល់អំពីការប្រើប្រាស់ និងតម្កល់ទ្រព្យ ១ ក្អម ធ្វើឲ្យជាគំនរត្រង់កណ្តាលផ្ទះ ដើម្បីប្រើប្រាស់ក្នុងផ្ទះ គហបតីទាំងនោះ ឈ្មោះថា គហបតិមហាសាល អធិប្បាយថា បុគ្គលដែលរុងរឿង គឺបុគ្គលមកក្តីកើតក្នុងត្រកូលនៃជនទាំងនោះ ។

បទថា **អឌ្ឍោ** បានដល់ មានភាពជាឥស្សរៈ ។ ឈ្មោះថា **មហទ្ធនោ** ព្រោះមានទ្រព្យច្រើនកប់ទុក ។ ឈ្មោះថា **មហាភោគោ** ព្រោះមានគ្រឿងឧបភោគ មានភាជន៍មាស និងភាជន៍ប្រាក់ជាដើមច្រើន ។ ឈ្មោះថា **បហូតជាតរូបរជតោ** ព្រោះមានមាស និងប្រាក់ជាដើមកប់ទុកច្រើន ។ ឈ្មោះថា **បហូតវិត្តូបករណោ** ព្រោះឧបករណ៍នៃទ្រព្យជាគ្រឿងត្រេកអរនៃចិត្ត គឺហេតុនៃការត្រេកអរមានច្រើន ។ ឈ្មោះថា **បហូតធនធញ្ញោ** ព្រោះទ្រព្យគឺគោជាដើម និងធញ្ញាហារ ៧ ប្រភេទ[១] មានច្រើន ។ បទថា **អភិរូបោ** បានដល់ មានរូបស្អាត ។ បទថា **ទស្សនីយោ** បានដល់ សមគួរដែល

១- ស្រូវ ៧ ប្រការ គឺស្រូវសាលី ស្រូវខ្សាយ ស្រូវជំណើប ស្រងែ ថ្កា ស្កួយ ស្មៅគែលលក ។

បុគ្គលណាមួយ នឹងលះការងាររដទៃ រួចសម្លឹងមើលអស់ថ្ងៃ ។ បទថា **ចាសាទិកោ** បានដល់ នាំមកនូវការជ្រះថ្លានៃចិត្ត ដោយការឃើញនោះឯង ។ បទថា **បរមាយ** បានដល់ ឧត្តម ។ បទថា **វណ្ណបោក្ខរតាយ** បានដល់ មានរូបស្អាត ។ សរីរៈ ហៅថា បោក្ខរៈ អធិប្បាយថា ដល់ព្រមដោយពណ៌នៃសរីរៈនោះ ។ បទថា **សមន្នាគតោ** បានដល់ ចូលដល់ហើយ ។

[ ១៣០ ] ក្នុងនិទ្ទេសនៃបុគ្គលឱនចុះហើយឱនចុះទៀតជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ឈ្មោះថា **ឱណតោ** ព្រោះវៀរចាកសម្បត្តិ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិខាងមុខ អធិប្បាយថា ជាបុគ្គលថោកថយ គឺជាបុគ្គលលាមក ។ ឈ្មោះថា **ឧណ្ណតោ** ព្រោះមានសភាវៈផ្ទុយគ្នានឹងបុគ្គលថោកថយនោះ អធិប្បាយថា ខ្ពង់ខ្ពស់ គឺជាបុគ្គលប្រសើរ ។ ពាក្យដ៏សេសក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងពាក្យថា បុគ្គលងងឹតជាដើម ។ ម្យ៉ាងទៀត បទថា **ឱណតោណតោ** សេចក្តីថា ជាតិនេះជាបុគ្គលថោកថយ សូម្បីជាតិតទៅក៏នឹងជាបុគ្គលថោកថយទៀត ។ បទថា **ឱណតុណ្ណតោ** សេចក្តីថា ជាតិនេះជាបុគ្គលថោកថយ តែជាតិតទៅនឹងជាបុគ្គលឧត្តម ។ បទថា **ឧណ្ណតោណតោ** សេចក្តីថា ជាតិនេះជាបុគ្គលឧត្តម តែជាតិតទៅនឹងជាបុគ្គលថោកថយ ។ បទថា **ឧណ្ណតុណ្ណតោ** សេចក្តីថា ជាតិនេះជាបុគ្គលខ្ពង់ខ្ពស់ សូម្បីជាតិតទៅក៏នឹងជាបុគ្គលខ្ពង់ខ្ពស់ ។

[ ១៣១-១៣២ ] ក្នុងនិទ្ទេសនៃបុគ្គលប្រៀបដោយដើមឈើ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា គប្បីជ្រាបដើមឈើមុន បទថា **ផេគ្គុសារបរិវារោ**

បានដល់ ដើមឈើចម្រើនដែលធំបំផុតក្នុងព្រៃ ខ្ទនឯងជាឈើស្រោយ តែដើមឈើដែលជាបរិវារមានខ្លឹម ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យនេះ ។ ក្នុងបុគ្គលទាំងឡាយ បណ្ឌិតគប្បីជ្រាបថា បុគ្គលដែលប្រៀបដោយដើមឈើស្រោយ ព្រោះវៀរចាកសារៈ គឺសីល និងគប្បីជ្រាបថា បុគ្គលប្រៀបដូចដើមឈើមានខ្លឹម ព្រោះប្រកបដោយសារៈ គឺសីល ។

[ ១៣៣ ] ក្នុងនិទ្ទេសនៃបុគ្គលរាប់អានក្នុងរូបជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា បុគ្គលណា ធ្វើរូបដែលប្រកបដោយសម្បត្តិ ឲ្យជាប្រមាណ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រូបប្បមាណោ** ។ បុគ្គលណា រមែងញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតក្នុងរូបដែលប្រកបដោយសម្បត្តិនោះ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រូបប្បសន្នោ** ។ បុគ្គលណា ធ្វើសំឡេងដែលជាកិត្តិសព្ទ ឲ្យជាប្រមាណ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឃោសប្បមាណោ** ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អារោហំ វា** ជាដើម ដូចតទៅនេះ បទថា **អារោហំ** បានដល់ ខ្ពស់ឡើង ។ បទថា **បរិណាហំ** បានដល់ មានរូបសម្បត្តិដែលសមគួរប្រាសចាកការស្គម និងការធាត់ ។ បទថា **សណ្ឋានំ** បានដល់ ភាពដែលអវយវៈធំតូចទាំងឡាយយ៉ាងនោះ ក្នុងទីដែលគួរវែង ខ្លី និងមូលជាដើម ។ បទថា **ចារិប្ឫរឹ** បានដល់ ការមិនខ្វះខាតនៃអវយវៈទាំងឡាយ មានប្រការតាមដែលពោលហើយ ឬភាពជាអ្នកបរិបូណ៌ដោយលក្ខណៈ ។ បទថា **បរវណ្ណនាយ** បានដល់ ក្នុងការពណ៌នាគុណដែលអ្នកដទៃបន្ទឹក្នុងទីក្រោយខ្នង ។ បទថា **បរថោមនាយ**

បានដល់ ក្នុងការសរសើរដែលបុគ្គលដទៃ ពោលដោយចន្ទជាគាថាជាដើម ជាការសរសើរ ។ បទថា **បរបសំសនាយ** បានដល់ ក្នុងការសរសើរគុណដែលអ្នកដទៃ ពោលចំពោះមុខ ។ បទថា **បរវណ្ណហារិកាយ** បានដល់ ក្នុងការនាំការសរសើរគុណ ដែលអ្នកដទៃឲ្យប្រព្រឹត្តទៅ ដោយអំណាចនៃការសរសើរតៗ គ្នា ។ បទថា **ចីវរលូខំ** បានដល់ ភាពដែលចីវរជារបស់សៅហ្មងដោយការៈមានពណ៌មិនល្អជាដើម ។ បទថា **បត្តលូខំ** បានដល់ ភាពដែលភាជនៈជារបស់សៅហ្មងដោយពណ៌ សណ្ឋាន និងវត្ថុ ។ បទថា **សេនាសនលូខំ** បានដល់ ភាពដែលសេនាសនៈជារបស់សៅហ្មង ព្រោះវៀរចាកសម្បត្តិ មានអ្នករបាំជាដើម ។ បទថា **វិវិធំ** បានដល់ មានប្រការផ្សេងៗ ដោយភាពជារបស់អចេលកៈជាដើម ។ បទថា **ទុក្ករការិកំ** បានដល់ ការធ្វើសរីរៈរបស់ខ្លួនឲ្យក្តៅ ។ ន័យម្យ៉ាងទៀត បុគ្គល ៤ ពួកនេះ បុគ្គលដែលកាន់យកប្រមាណក្នុងរូប ហើយជ្រះថ្លា ឈ្មោះថា **រូបប្បមាណោ** ។ បទថា **រូបប្បសន្នោ** ក៏ជាពាក្យពង្រីកសេចក្តីរបស់ពាក្យថា **រូបប្បមាណោ** នោះឯង ។ បុគ្គលដែលកាន់យកសំឡេងជាប្រមាណ ហើយជ្រះថ្លា ឈ្មោះថា **ឃោសប្បមាណោ** ។ បុគ្គលដែលកាន់យកប្រមាណក្នុងចីវរដែលសៅហ្មង និងបាត្រដែលសៅហ្មង ហើយជ្រះថ្លា ឈ្មោះថា **លូខប្បមាណោ** ។ បុគ្គលកាន់យកធម៌ជាប្រមាណ ហើយក៏ជ្រះថ្លា ឈ្មោះថា **ធម្មប្បមាណោ** ។ ពាក្យក្រៅអំពីនេះ ជាពាក្យពង្រីកសេចក្តីរបស់បុគ្គលទាំងនោះឯង ។ បើចែកសត្វលោកទាំងអស់ជា ៣ ចំណែក បុគ្គលកាន់យក

រូបជាប្រមាណមាន ២ ចំណែក ដែលមិនកាន់យកមាន ១ ចំណែក ។ ចែកសត្វលោកទាំងអស់ជា ៥ ចំណែក បុគ្គលដែលកាន់យកសំឡេងជាប្រមាណមាន ៤ ចំណែក មិនកាន់យកមាន ១ ចំណែក ។ ចែកសត្វលោកទាំងអស់ជា ១០ ចំណែក បុគ្គលដែលកាន់យកភាពសៅហ្មងជាប្រមាណមាន ៩ ចំណែក ដែលមិនកាន់យកមាន ១ ចំណែក ។ ចែកសត្វលោកទាំងអស់ជា ១ សែនចំណែក ១ ចំណែកប៉ុណ្ណោះ កាន់យកធម៌ជាប្រមាណ ចំណែកដ៏សេសមិនកាន់យកធម៌ជាប្រមាណ លោកសន្និវាសនេះកាន់យកប្រមាណ ៤ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងលោកសន្និវាស មានប្រមាណ ៤ យ៉ាងនេះ បុគ្គលដែលមិនជ្រះថ្លាក្នុងព្រះពុទ្ធទាំងឡាយ មានប្រមាណតិច ដែលជ្រះថ្លាមានច្រើន ព្រោះថា បុគ្គលដែលកាន់យករូបជាប្រមាណ ឈ្មោះថា រូបដែលនាំមកនូវសេចក្តីជ្រះថ្លាក្រៃលែងជាងរូបរបស់ព្រះពុទ្ធមិនមាន ។

បុគ្គលដែលកាន់យកសំឡេង ជាប្រមាណ ឈ្មោះថា សំឡេងដែលនាំមកនូវសេចក្តីជ្រះថ្លាក្រៃលែងជាងសំឡេងប្រកាសកិត្តិគុណ របស់ព្រះពុទ្ធមិនមាន ។

បុគ្គលកាន់យកភាពសៅហ្មងជាប្រមាណ ឈ្មោះថា ការសៅហ្មងដទៃដែលនាំមកនូវសេចក្តីជ្រះថ្លាក្រៃលែង ជាងការសៅហ្មងរបស់ព្រះពុទ្ធមានព្រះភាគ ដែលលះសំពត់ទាំងឡាយដែលគេត្បាញក្នុងដែនកាសី លះកាជន៍មាសដែលមានតម្លៃច្រើន និងលះប្រាសាទដ៏ប្រសើរដែលប្រកបដោយសម្បត្តិ

ទាំងពួង ដែលសមគួរដល់រដូវកាលទាំង ៣ ហើយប្រើប្រាស់បង្សុកូលចីវរ បាត្រដែលសម្រេចដោយថ្ម និងសេនាសនៈ មានគល់ឈើជាដើមមិនមាន ។

បុគ្គលកាន់យកធម៌ជាប្រមាណ ឈ្មោះថា គុណមានសីលជាដើមដែលនាំមកនូវការជ្រះថ្លា ដែលក្រៃលែងជាងគុណ មានសីលជាដើម របស់ព្រះតថាគត ដែលមានសីលាទិគុណមិនញាប់ញ័រ ក្នុងលោកនេះ រហូតដល់ទេវលោក រមែងមិនមាន ដោយហេតុនេះ ទើបព្រះមានព្រះភាគ ទ្រង់តាំងនៅដូចកាន់យកលោកសន្និវាស មានប្រមាណ ៤ នេះ ទុកក្នុងកណ្តាប់ព្រះហស្ត ។

[ ១៣៤ ] ក្នុងនិទ្ទេសនៃបុគ្គលប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សីលសម្បន្នោ** បានដល់ ដែលសម្បូរដោយសីល គឺប្រកបដោយសីល ។ ក្នុងបុគ្គលដែលបរិបូណ៌ដោយសមាធិជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងទីនេះ សីលព្រះមានព្រះភាគ ត្រាស់ទាំងលោកិយសីល និងលោកុត្តរសីល ។ សមាធិ និងបញ្ញា ក៏ដូចគ្នា ។ វិមុត្តិ បានដល់ អរហត្តផលវិមុត្តិ ។ ញាណទស្សនៈ បានដល់ បច្ចវេក្ខណញ្ញាណ ១៩ ។ ក្នុងបទថា **នោ បរំ** ជាដើម មានអធិប្បាយថា បុគ្គលពោលជាមួយអ្នកដទៃថា លោកក៏សមគួរជាអ្នកដល់ព្រមដោយសីល ហើយសមាទានសីល ដោយប្រការណា មិនបបួល មិនឲ្យបុគ្គលដទៃកាន់យកសីលដោយប្រការនោះ ។ ក្នុងបទទាំងអស់ ក៏ន័យនេះដូចគ្នា ។ បណ្តាបុគ្គល ៤ ពួកនោះ បណ្ឌិតគប្បីជ្រាបថា បុគ្គលពួកទី ១ រមែងដូចគ្នានឹងព្រះថេរៈឈ្មោះ

វក្កលិ ពួកទី ២ ដូចគ្នានឹងព្រះឧបនន្ទសក្យបុត្ត ពួកទី ៣ ដូចគ្នានឹងព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរ ពួកទី ៤ ដូចគ្នានឹងភិក្ខុទេវទត្ត ។

[ ១៣៥ ] ក្នុងនិទ្ទេសនៃបុគ្គលដុតកម្តៅខ្លួនឯងជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បុគ្គលណា រមែងធ្វើបាបខ្លួន គឺធ្វើខ្លួនឲ្យដល់នូវសេចក្តីទុក្ខ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អត្តន្តបោ ។** ការប្រកបធ្វើខ្លួនឲ្យក្តៅក្រហាយរឿយៗ ឈ្មោះថា **អត្តបរិតាបនានុយោគំ ។**

បទថា **អចេលកោ** បានដល់ បុគ្គលមិនស្លៀកសំពត់ គឺបុគ្គលអាក្រាតកាយ ។ បទថា **មុត្តាចារោ** បានដល់ បុគ្គលមានអាចារបោះបង់ចោលហើយ ។ ក្នុងកិច្ច មានការបន្ទោបង់ឧច្ចារៈជាដើម ក៏ប្រាសចាកមារយាទរបស់កុលបុត្តក្នុងលោក ឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឈរទំពា ឈរបរិភោគនោះឯង ។ បទថា **ហត្ថាបលេខនោ** សេចក្តីថា កាលដុំបាយអស់ហើយ ក៏យកអណ្តាតលិទ្ធដៃ ។ម្យ៉ាងទៀត លោកសម្តែងថា បុគ្គលបន្ទោបង់ឧច្ចារៈហើយ ជាបុគ្គលមានសេចក្តីសម្គាល់ថា ដៃនោះឯងជាកំណាត់ឈើ ទើបយកដៃជូត ។ បានឮថា ជនទាំងនោះ រមែងបញ្ញត្តកំណាត់ឈើជាជាសត្វ ព្រោះហេតុនោះ កាលបុគ្គលនោះបំពេញបដិបទានៃជនទាំងនោះ ទើបធ្វើយ៉ាងនោះ ។ បុគ្គលណា ដែលបុគ្គលដទៃពោល ដើម្បីឲ្យទទួលភិក្ខាហារថា អ្នកដ៏ចម្រើនចូរមកក៏មិនមក ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឯហិភទ្ទន្តិកោ ។** បុគ្គលណា ដែលអ្នកដទៃពោលថា លោកដ៏ចម្រើន សូមលោកឈប់សិន ក៏មិនឈប់ ព្រោះហេតុនោះ ទើបបុគ្គលនោះ

ឈ្មោះថា **ឯតិដ្ឋកឧត្តិកោ** ។ តិរ្ថិយទាំងឡាយ រមែងមិនធ្វើតាមទាំង ២ យ៉ាង ដោយគិតថា ជាការធ្វើតាមពាក្យបញ្ជារបស់បុគ្គលនោះ ។ បទថា **អភិហដំ** បានដល់ ភិក្ខាដែលគេកាន់យកទៅមុនហើយនាំមកឲ្យ ។ បទថា **ឧទ្ទិស្សកតំ** បានដល់ ភិក្ខាដែលគេប្រាប់យ៉ាងនេះថា ភិក្ខានេះ ធ្វើចំពោះលោក ។ បទថា **ឯ និមន្តនំ** បានដល់ មិនត្រេកអរ និងមិនទទួលសូម្បីភិក្ខាដែលគេនិមន្តយ៉ាងនេះថា សូមលោកម្ចាស់ ចូលទៅកាន់ត្រកូល ឬផ្លូវ ឬស្រុកឈ្មោះនោះ ។ បទថា **ឯ កុម្ភិមុខា** បានដល់ មិនទទួលភិក្ខាដែលបុគ្គលដួសអំពីឆ្នាំង ហើយឲ្យ ។ ក្នុងបទថា **ឯ កឡោបិមុខា** ឆ្នាំង ឬល្អីឈ្មោះថា **កឡោបិ** បុគ្គលនោះ រមែងមិនទទួលអាហារអំពីកាជន៍នោះ ។ ព្រោះហេតុអ្វី ព្រោះឆ្នាំង និងល្អី ត្រូវវែកគោះ ។ បទថា **ឯ ឯឡកមន្តរំ** បានដល់ មិនទទួលកត្តដែលធ្វើធរណីទ្វារ ខណ្ឌត្រង់កណ្ដាល ( ឈរឲ្យធរណីទ្វារនៅត្រង់ប្រឡោះជើង ) ហើយឲ្យ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា ធរណីទ្វារនេះ អាស្រ័យអញហើយ ទើបគេធ្វើឲ្យនៅចន្លោះកណ្ដាល ។ ក្នុងកំណាត់ឈើ និងអង្រែក៏មានន័យនេះដូចគ្នា ។ បទថា **ទ្វិន្នំ** បានដល់ កាលជន ២ នាក់ កំពុងបរិភោគអាហារ បុគ្គលម្នាក់ក្រោកឡើងហើយឲ្យភិក្ខា មិនព្រមទទួល សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា នឹងមានអន្តរាយអំពីដុំបាយ គឺត្រូវបញ្ឈប់ការបរិភោគ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឯ គព្ភិនិយា** ជាដើម ដូចតទៅនេះថា រមែងមិនទទួល ដោយគិតថា ទារកនៅក្នុងផ្ទៃរបស់ស្រីមានគភ៌នឹងលំបាក ។ អន្តរាយនៃទឹកដោះ

រមែងមានដល់ទារករបស់ស្រីដែលឲ្យបៅដោះ ។ មិនព្រមទទួលភិក្ខា ដោយគិតថា អន្តរាយនៃការត្រេកអរ រមែងមានដល់ស្រីដែលកំពុងទៅកាន់ចន្លោះនៃបុរស ។ បទថា **ន សង្កិត្តីសុ** បានដល់ កត្តដែលរួមគ្នា ។ បានឮថា ក្នុងសម័យដែលភិក្ខារកបានលំបាក ពួកសាវករបស់អ្នកបួសអាក្រាតទាំងឡាយ នាំគ្នាប្រមូលអង្ករជាដើម អំពីទីនោះៗ មកដាំបាយ ដើម្បីប្រយោជន៍ដល់អ្នកបួសអាក្រាតទាំងឡាយ អ្នកបួសអាក្រាតដែលឧក្រិដ្ឋមិនព្រមទទួលភិក្ខាអំពីទីនោះ ។ បទថា **ន យត្ថ សា** បានដល់ ឆ្កែឈរយាម សម្លឹងមើលក្នុងទីណា ដោយតាំងចិត្តថា អញនឹងបានដុំបាយ រមែងមិនទទួលភិក្ខាដែលគេមិនទាន់ឲ្យដល់ឆ្កែក្នុងទីនោះ នាំមក ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគិតថា អន្តរាយនៃដុំបាយនឹងមានដល់ឆ្កែនោះ ។

បទថា **សណ្ឌសណ្ឌចារិនី** បានដល់ ការត្រាច់ទៅប្រជុំគ្នាជាពួកៗ បើពួកមនុស្សទាំងឡាយឃើញអ្នកបួសអាក្រាតហើយ ក៏ចូលផ្ទះដើម្បីកត្តដោយតាំងចិត្តថា អញនឹងប្រគេនភិក្ខាដល់អ្នកបួសអាក្រាតនេះ កាលមនុស្សទាំងនោះចូលទៅ ពួករុយដែលទំត្រង់មាត់កឡោបីជាដើម នាំគ្នាហើរឡើងទៅត្រាច់ទៅជាពួកៗ អ្នកបួសអាក្រាត រមែងមិនទទួលភិក្ខាដែលគេនាំមក អំពីកឡោបីនោះ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលនោះគិតថា ព្រោះអាស្រ័យអញ អន្តរាយនៃគោចររបស់រុយទាំងឡាយ ទើបកើត ។ បទថា **ថុសោទកំ** បានដល់ ទឹកត្រាំដែលគេធ្វើដោយគ្រឿងផ្សំអំពីស្រូវគ្រប់ប្រភេទ ។ ក្នុងទីនេះ សុរាប៉ុណ្ណោះរាប់ថាមានទោស តែអ្នកបួសអាក្រាតនេះ មានការ

សម្គាល់ក្នុងទឹកត្រាំនោះ ថាមានទោស ។ បទថា **ឯកាគារិកោ** បានដល់ បាននូវភិក្ខាក្នុងផ្ទះមួយខ្នងប៉ុណ្ណោះ ហើយក៏ត្រឡប់ទៅ ។ បទថា **ឯកា-លោបិកោ** បានដល់ បុគ្គលនោះ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយត្រឹមមួយពំនូត ។ ក្នុងបទថា **ទ្វាគារិកា** ជាដើមក៏ន័យនេះដូចគ្នា ។

បទថា **ឯកិស្សាបិ ទត្តិយា** បានដល់ របស់ដែលគេឲ្យមួយសម្រាប់ ។ ថាសតូចៗ មួយដែលគេដាក់ភិក្ខាដ៏ប្រសើរតម្កល់ទុក ឈ្មោះថា **ទត្តិ** ។

បទថា **ឯកាហិកំ** បានដល់ ភត្តដែលគេប្រគេនរំលងមួយថ្ងៃ ។ បទថា **អឌ្ឍមាសិកំ** បានដល់ ភត្តដែលគេប្រគេន រំលងកន្លះខែ ។ បទថា **បរិយាយភត្តភោជនំ** បានដល់ ការបរិភោគភត្តតាមវារៈ ។ ការបរិភោគភត្តដែលគេនាំមកដោយវារៈនៃថ្ងៃយ៉ាងនេះ គឺដោយវារៈ ១ ថ្ងៃ ២ ថ្ងៃ ៧ ថ្ងៃ កន្លះខែ ។ បទថា **សាកភក្ខោ** បានដល់ មានបន្លែស្រស់ជាអាហារ ។ បទថា **សាមាកភក្ខោ** បានដល់ មានអង្ករស្រងែជាអាហារ ។ ក្នុងពាក្យថាស្គួយជាដើម បានដល់ ស្រូវដែលកើតឯងក្នុងព្រៃ ឈ្មោះថា **នីវារា** ។ បទថា **ទទ្ទុលំ** បានដល់ មានចំនៀរស្បែកដែលជាងស្បែកកាត់ចោល ។ ជ័រក្តី សារាយក្តី ជ័រឈើ មានជ័រកណិការជាដើមក្តី ហៅថា **ហដំ** ។ បទថា **កណំ** បានដល់ កន្ទក់ ។ បទថា **អាចាមោ** បានដល់ បាយក្តាំងដែលជាប់ត្រង់បាតឆ្នាំងបាយ ។ បុគ្គលនោះ កាន់យកបាយក្តាំងនោះ ក្នុងទីដែលមនុស្សចោលហើយ មកទំពាស៊ី ។ អាចារ្យពួកខ្លះពោលថា បរិភោគទឹកបាយ ដូច្នេះក៏មាន ។ បទថា **បិញ្ញាក** ជាដើម មានសេចក្តីប្រាកដ

ច្បាស់ហើយ ។ បទថា **បវត្តផលភោជី** បានដល់ ដែលបរិភោគផ្លែឈើជ្រុះឯង ។

បទថា **សាណានិ** បានដល់ សំពត់ធ្វើអំពីសម្បកធ្មៃ ។ បទថា **មសាណានិ** បានដល់ សំពត់ដែលត្បាញលាយគ្នា ។ បទថា **ឆវទុស្សានិ** បានដល់ សំពត់រុំសាកសពដែលគេចោលហើយ ។ ម្យ៉ាងទៀត បានដល់ សំពត់ដែលគេធ្វើដោយស្មៅ មានស្លឹករំទឹកជាដើម ។ បទថា **បំសុកូលានិ** បានដល់ ចម្រៀកសំពត់ចាស់ ដែលគេចោលត្រង់ផែនដី ។ បទថា **តិរីដានិ** បានដល់ សំពត់ដែលគេត្បាញដោយសម្បកឈើ ។ បទថា **អជិនំ** បានដល់ ស្បែកខ្លា ។ បទថា **អជិនក្ខិបំ** បានដល់ ស្បែកខ្លានោះឯងដែលគេពុះត្រង់កណ្តាល អាចារ្យពួកខ្លះពោលថា សំពត់ស្លៀកដែលគេធ្វើដោយស្បែកខ្លាទាំងក្រចក ដូច្នេះក៏មាន ។ បទថា **កុសចីរំ** បានដល់ សំពត់ដែលគេត្បាញធ្វើដោយស្បូវភ្លាំង ក្នុងសំពត់ដែលត្បាញដោយសម្បកឈើ និងបន្ទះឈើជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **កេសកម្ពលំ** បានដល់ សំពត់កម្ពលដែលគេធ្វើដោយសក់មនុស្ស ដូចព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយតម្បាញ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ដូច្នេះ ។ បទថា **វាឡកម្ពលំ** បានដល់ សំពត់កម្ពល ដែលធ្វើដោយរោមកន្ទុយសេះជាដើម ។ បទថា **ឧលូកបក្ខំ** បានដល់ សំពត់ដែលគេធ្វើដោយស្លាបមៀម ។

បទថា **ឧត្តដ្ឋកោ** បានដល់ ឈរធ្វើឲ្យខ្ពស់ ( ចំអើតជើង ) ។ បទថា **ឧក្កុដិកប្បធានមនុយុត្តោ** សេចក្តីថា ដែលប្រកបព្យាយាមក្នុងការអង្គុយប្រហោង គ្រាទៅក៏ទៅទាំងប្រហោងនោះឯង គឺលោតទៅ ។ បទថា **កណ្ដកាបស្សយិកោ** សេចក្តីថា បោះដែកស្រួច ឬបន្លាស្រួចត្រង់ផែនដី ហើយក្រាលដោយស្បែកលើដែកស្រួច ឬបន្លានោះ ហើយធ្វើការឈរ ការដើរជាដើម ។ បទថា **សេយ្យំ** បានដល់ កាលដេកក៏សម្រេចការដេកលើបន្ទះស្បែកដែលក្រាលលើដែកស្រួចជាដើមនោះឯង ។ បុគ្គលនោះ មានពេលល្ងាចជាគម្រប់បី ព្រោះហេតុនោះ ឈ្មោះថា សាយតតិយៈ អធិប្បាយថា ប្រកបសេចក្តីព្យាយាមក្នុងការចុះងូតទឹក ដោយតាំងចិត្តថា អញនឹងបន្សាត់បាបមួយថ្ងៃ ៣ ដង គឺពេលព្រឹកម្តង ពេលថ្ងៃត្រង់ម្តង ពេលល្ងាចម្តង ។

បុគ្គលណា រមែងញុំាងបុគ្គលដទៃឲ្យក្តៅក្រហាយ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **បរន្តបោ** ។ ការប្រកបសេចក្តីព្យាយាម ដើម្បីធ្វើបុគ្គលដទៃ ឲ្យក្តៅក្រហាយ ឈ្មោះថា **បរបរិតាបនានុយោគំ** ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឱរព្ភិកោ** ជាដើម ដូចតទៅនេះថា ពពែ ឬចៀម លោកហៅថា **ឧរព្ភា** បុគ្គលណាសម្លាប់ពពែ ឬចៀម ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ឱរព្ភិកោ** ។ ក្នុងពាក្យថា អ្នកសម្លាប់ជ្រូកជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **លុទ្ទោ** បានដល់ បុគ្គលឃោរឃៅ រឹងត្អឹង គឺកាច ។ បទថា **មច្ឆឃាតកោ** បានដល់ អ្នកប្រមង់ អ្នកចាប់ត្រី ។ បទថា **ពន្ធនាគារិកោ** បានដល់ អ្នកយាមគុក ។ បទថា **កុរូរកម្មន្តា** បានដល់

បុគ្គលមានការងារគ្រោតគ្រាត ។

បទថា **មុទ្ធាវសិត្តោ** បានដល់ បុគ្គលដែលបានទទួលការអភិសេកលើក្បាលដោយការអភិសេកជាក្សត្រ ។ បទថា **បុរត្ថិមេន នគរស្ស** បានដល់ ក្នុងទិសខាងកើតនៃព្រះនគរ ។ បទថា **សន្ធាគារំ**[១] បានដល់ រោងយញ្ញ ។ បទថា **ខុរាជិនំ និវាសេត្វា** បានដល់ ស្លៀកដណ្ដប់ស្បែកខ្លាទាំងក្រចក ។ បទថា **សប្បិតេលេន** បានដល់ សប្បិផង ប្រេងផង ។ វៀរសប្បិចេញហើយ ជ័រណាមួយដ៏សេស ហៅថា **តេលំ** ។ បទថា **កណ្ឌុវមានោ** បានដល់ ព្រោះខ្នងកាត់ក្រចក ទើបយកស្នែងសត្វនោះអេះខ្នងក្នុងកាលដែលគួរអេះ ។ បទថា **អនន្តរហិតាយ** បានដល់ គេមិនបានក្រាលកម្រាល ។ បទថា **សរូបវច្ឆាយ** បានដល់ មានកូនគោដែលដូចមេគោ អធិប្បាយថា កូនគោ ដែលមានរូបយ៉ាងនេះ គឺបើមេគោ-ស កូនគោក៏សដែរ បើមេគោលឿង ឬក្រហម កូនគោក៏យ៉ាងនោះដូចគ្នា ។ បទថា **សោ ឯវមាហ** បានដល់ ព្រះរាជានោះត្រាស់យ៉ាងនេះ ។ បទថា **វច្ឆតរា** បានដល់ កូនគោជំទង់ ដែលមានកម្លាំងកន្លងនូវភាពជាកូនគោតូច ។ សូម្បីក្នុងកូនគោញី ក៏ន័យនេះដូចគ្នា ។ បទថា **ពរិហិសត្ថាយ** បានដល់ ដើម្បីការព័ទ្ធរបង និងដើម្បីការក្រាលក្នុងទីយញ្ញភូមិ ។

បទថា **និច្ឆាតោ ធម្មេ** បានដល់ ក្នុងអត្តភាពនេះឯង ។ តណ្ហា ហៅថា ឆាតៈ ក្នុងពាក្យនេះថា **និច្ឆាតោ** ។ តណ្ហានោះ របស់បុគ្គលនោះ មិនមាន

---

១- បិដកខ្មែរជា សន្ធាគារំ ។

ព្រោះហេតុនោះ ទើបឈ្មោះថា **ឆិច្ឆាតោ** ។ ឈ្មោះថា **និព្វុតោ** ព្រោះ កិលេសទាំងអស់រលត់ទៅហើយ ។ បុគ្គលណា ជាបុគ្គលត្រជាក់ ព្រោះមិន មានកិលេសជាគ្រឿងឲ្យក្ដៅខាងក្នុង ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះ ថា **សីតីភូតោ** ។ បុគ្គលណា សោយចំពោះសេចក្ដីសុខដែលកើតអំពីឈាន មគ្គ ផល និងព្រះនិព្វាន ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សុខប្ប-ដិសំវេទី** ។ បទថា **ព្រហ្មភូតេន អត្តនា** បានដល់ មានខ្លួនប្រសើរបំផុត ។ ដើម្បីទឹងសម្ដែងបុគ្គល ដែលប្រសើរបំផុតនេះ តាំងអំពីកាលកើតឡើងនៃ ព្រះសម្ពុទ្ធ ទើបទ្រង់ត្រាស់ពាក្យថា **៩ឪ តថាគតោ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **តថាគតោ** បណ្ឌិតគប្បីធ្វើការវិនិច្ឆ័យថា ព្រះមានព្រះភាគដែលទ្រង់ព្រះនាមថា **តថាគត** ដោយហេតុ ៨ ប្រការគឺ

**តថា អាគតោតិ តថាគតោ** ព្រះមានព្រះភាគយាងមកហើយយ៉ាង នោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ១ ។

**តថា គតោតិ តថាគតោ** ព្រះមានព្រះភាគយាងទៅយ៉ាងនោះ ព្រោះ ហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ១ ។

**តថលក្ខណំ អាគតោតិ តថាគតោ** ព្រះមានព្រះភាគយាងមកកាន់ លក្ខណៈដែលពិត ទើបទ្រង់ព្រះនាមថា តថាគត ១ ។

**តថធម្មេ យាថាវតោ អភិសម្ពុទ្ធោតិ តថាគតោ** ព្រះមានព្រះភាគ ត្រាស់ដឹងធម៌ទាំងឡាយតាមសេចក្ដីពិត ព្រោះហេតុនោះ ទើបទ្រង់ព្រះនាម ថា តថាគត ១ ។

**តថទស្សិតាយ តថាគតោ** ព្រះមានព្រះភាគទ្រង់ព្រះនាមថា តថាគត ព្រោះមានប្រក្រតីឃើញអារម្មណ៍ដែលពិតនោះ ១ ។

**តថាវាទិតាយ តថាគតោ** ទ្រង់ព្រះនាមថា តថាគត ព្រោះមានប្រក្រតីត្រាស់វាចាដែលពិត ១ ។

**តថាការិតាយ តថាគតោ** ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់មានប្រក្រតីធ្វើតាមព្រះតម្រាស់នោះ ១ ។

**អភិភវនដ្ឋេន តថាគតោ** ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់បាន ១ ។

បទថា **អរហំ សម្មាសម្ពុទ្ធោ** ជាដើម ខ្ញុំឲ្យពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។ បទថា **តំ ធម្មំ** បានដល់ រមែងស្តាប់ធម៌នោះ ដែលដល់ព្រមដោយពាក្យមានប្រការតាមដែលពោលហើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ លើកគហបតីឡើងសម្តែងមុន ក្នុងបទថា **សុណាតិ គហបតិ វា** ឆ្លើយថា ព្រោះគហបតីនោះ កម្ចាត់មានះបាន និងព្រោះមានចំនួនច្រើន ។ ពិតហើយ ដោយច្រើនជនដែលបួសមកអំពីខត្តិយ-ត្រកូល អាស្រ័យជាតិហើយប្រកាន់ខ្លួន ជនដែលបួសមកអំពីត្រកូលព្រាហ្មណ៍ អាស្រ័យមន្តហើយប្រកាន់ខ្លួន ដែលចេញអំពីត្រកូលទាបបួសហើយ ក៏មិនអាចធ្វើខ្លួនឲ្យខ្ពស់បាន ព្រោះភាពដែលខ្លួនមានជាតិ មានត្រកូលទាប ។ ចំណែកកូនរបស់គហបតីទាំងឡាយធ្វើការងារ មានញើសហូរចេញអំពីក្លៀកទាំងសងខាង មានខ្នងកកទៅដោយផ្កាអំបិល ធ្វើការភ្ជួរដី បុគ្គលនោះ មិន

*មានមានះ មិនមានការលើកតម្កើងខ្លួន ព្រោះមិនមានមានះបែបនោះ ។ កូនគហបតីទាំងនោះ បួសហើយ មិនធ្វើមានះ មិនធ្វើការតម្កើងខ្លួន រៀនពុទ្ធវចនៈតាមកម្លាំង ធ្វើវិបស្សនាកម្ម អាចតាំងនៅក្នុងអរហត្តបាន ។ ជនក្រៅអំពីត្រកូលទាំងនេះ មកបួសមិនមានច្រើនឡើយ គហបតីប៉ុណ្ណោះ មានច្រើន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់លើកគហបតី ឡើងសម្តែងមុន ព្រោះគហបតីជាអ្នកកម្ចាត់មានះបាន និងព្រោះមានចំនួនច្រើន ។*

*បទថា* **អញ្ញតរស្មឹ វា** *បានដល់ អ្នកកើតក្នុងត្រកូលណាមួយនៃត្រកូលទាំងឡាយក្រៅអំពីនេះ ។ បទថា* **បច្ចាជាតោ** *បានដល់ មានជាតិជាធំ ។ បទថា* **តថាគតេ សទ្ធំ បដិលភតិ** *សេចក្តីថា ស្តាប់ធម៌ដែលបរិសុទ្ធហើយបានចំពោះនូវសទ្ធាក្នុងព្រះតថាគត ដែលជាធម្មសាមី គឺជាម្ចាស់នៃធម៌ថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាព្រះសម្មាសម្ពុទ្ធហ្ន៎ ។ បទថា* **ឥតិ បដិសញ្ចិក្ខតិ** *បានដល់ រមែងពិចារណាយ៉ាងនេះ ។ បទថា* **សម្ពាធោ ឃរាវាសោ** *សេចក្តីថា បើជនទាំងពីរ គឺស្វាមី និងភរិយា កាលនៅគ្រប់គ្រងផ្ទះដែលមានទំហំ ៦០ ហត្ថ ឬរាប់រយយោជន៍ ទោះជាយ៉ាងនោះ ឃរាវាសក៏ឈ្មោះថាចង្អៀត ព្រោះអត្ថថា មានការប្រព្រឹត្តទៅដោយកិលេសដែលជាគ្រឿងស្អុតស្អាញ និងកិលេសដែលជាគ្រឿងកង្វល់ របស់ជនទាំងពីរនោះ ។ បទថា* **រជោបថោ** *លោកពោលក្នុងមហាអដ្ឋកថា ថាជាឋានៈ គឺជាទីតាំងឡើងនៃធូលី មានរាគៈជាដើម តែនឹងពោលថា ជាផ្លូវមកនៃធូលី ដូច្នេះក៏គួរ ។*

បព្វជ្ជា ឈ្មោះថា **អព្ភោកាសោ** ព្រោះអត្ថថា ដូចជាទីវាល ដោយអត្ថថា មិនមានទីជាប់ជំពាក់ ។ ពិតហើយ បុគ្គលដែលបួសហើយ ទោះបីនៅក្នុងប្រាសាទរតនៈដែលជាផ្ទះកំពូលក្តី នៅក្នុងទីទាំងឡាយ មានវិមានជាដើម ដែលបិទបាំងល្អហើយ គឺមានបន្ទបដែលបិទជិតល្អហើយក្តី លោករមែងមិនជាប់មិនជំពាក់ មិនទើសទាក់ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **អព្ភោកាសោ បព្វជ្ជា** ។

ម្យ៉ាងទៀត ឃរាវាស ឈ្មោះថា ចង្អៀតចង្អល់ណាស់ ព្រោះមិនមានឱកាសក្នុងការសាងកុសលបានតាមសប្បាយ ។ ឈ្មោះថា ជាផ្លូវហូរមកនៃធូលី ព្រោះជាទីប្រជុំនៃធូលី គឺកិលេសទាំងឡាយ ដូចគំនរសំរាម ដែលបុគ្គលមិនបានបិទបាំង ។ បព្វជ្ជា ឈ្មោះថា មានឱកាសទូលាយ ព្រោះមានឱកាសក្នុងការសាងកុសលតាមសប្បាយ ។

ក្នុងបទថា **នយិទំ សុករំ ។បេ។ បព្វជេយ្យំ** នេះ មានពាក្យពោលដោយសង្ខេបដូចតទៅនេះថា ព្រហ្មចរិយៈ គឺត្រៃសិក្ខានេះ ឈ្មោះថា **ឯកន្តបរិបុណ្ណំ** ព្រោះធ្វើមិនឲ្យដាច់ត្រឹមតែមួយថ្ងៃ រហូតដល់ចរិមកចិត្តបាន ព្រហ្មចរិយៈនេះ ឈ្មោះថា **ឯកន្តបរិសុទ្ធំ** ព្រោះធ្វើមិនឲ្យសៅហ្មងដោយកិលេសមន្ទិលសូម្បីត្រឹមមួយថ្ងៃ រហូតដល់ចរិមកចិត្ត ( ចិត្តចុងក្រោយ ) បាន ។ បទថា **សង្ខលិខិតំ** បានដល់ គប្បីប្រព្រឹត្តព្រហ្មចរិយៈ ឲ្យដូចគ្នានឹងស័ង្ខដែលធ្វើឲ្យរលីងហើយ គឺឲ្យមានចំណែកប្រៀបដូចស័ង្ខ ដែលខាត់ល្អហើយ ការប្រព្រឹត្តព្រហ្មចរិយៈនេះ បុគ្គលនៅគ្រប់គ្រងផ្ទះ គឺនៅកណ្តាលផ្ទះ ធ្វើមិន

បានងាយឡើយ មិនអាចប្រព្រឹត្តព្រហ្មចរិយៈឲ្យបរិបូណ៌ ដោយចំណែកមួយ ។បេ។ បើដូច្នោះ អាត្មាអញគប្បីកោរសក់ ពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ព្រោះភាពជាសំពត់ពណ៌លឿងដែលជ្រលក់ដោយទឹកម្ចត់ ដែលសមគួរដល់បព្វជិតអ្នកប្រព្រឹត្តព្រហ្មចរិយៈ ហើយចេញចាកផ្ទះ បួសជាបព្វជិតមិនមានផ្ទះ ដូច្នេះ ។

ក្នុងអធិការនេះ ព្រោះកម្ម មានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ការនៅគ្រប់គ្រងផ្ទះ ហៅថា អគារិយៈ កសិកម្មជាដើមនោះ មិនមានក្នុងបព្វជ្ជា ព្រោះហេតុនោះ បព្វជ្ជា បណ្ឌិតគប្បីជ្រាបថា ជាអនគារិយៈ ។ ទើបការបួសនោះ ជា **អនគារិយំ** ។ បទថា **បព្វជេយ្យំ** បានដល់ គប្បីបដិបត្តិ ។ បទថា **អប្បំ វា** សេចក្ដីថា គំនរភោគៈទាបជាង ១០០០ ឈ្មោះថា តិច តាំងពី ១០០០ ឡើងទៅ ឈ្មោះថា ច្រើន ។ ញាតិនោះឯង ឈ្មោះថា **ញាតិបរិវដ្ដោ** ព្រោះអត្ថថា ទាក់ទងគ្នា ញាតិនោះតិចជាង ២០ ឈ្មោះថា តិច ចាប់ពី ២០ ឡើងទៅ ឈ្មោះថា ច្រើន ។ បទថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** គប្បីជ្រាបវិគ្គហៈថា ភិក្ខុដល់ព្រមដោយការសិក្សាក្នុងសិក្ខា ពោល គឺអធិសីលរបស់ភិក្ខុទាំងឡាយផង ក្នុងអាជីវៈ ពោល គឺសិក្ខាបទដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្ត ដែលជាទីនៅរួមគ្នាចិញ្ចឹមជីវិតដូចគ្នា ប្រព្រឹត្តស្មើគ្នានៃភិក្ខុទាំងឡាយផង ព្រោះហេតុនោះ ទើបឈ្មោះថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** ។ បទថា **សមាបន្នោ** អធិប្បាយថា ភិក្ខុជាអ្នកញុំាងសិក្ខាឲ្យបរិបូណ៌ផង មិនឈានកន្លងសាជីវៈផង ហើយ

ចូលដល់នូវសិក្ខាសាជីវៈទាំង ២ យ៉ាងនោះ ។

កថាពោលដោយបាណាតិបាតជាដើម ក្នុងបទទាំងឡាយ មានបទថា **បាណាតិបាតំ បហាយ** ជាដើម ខ្ញុំឲ្យពិស្តារហើយ ខាងដើមនោះឯង ។ បទថា **បហាយ** បានដល់ លះនូវភាពជាបុគ្គលទ្រុស្តសីល ពោល គឺចេតនាជាគ្រឿងញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះកន្លងនេះ ។ បទថា **បដិវិរតោ ហោតិ** សេចក្តីថា ជាអ្នកវៀរហើយ គឺវៀរចាកហើយអំពីភាពជាអ្នកទ្រុស្តសីលនោះ តាំងអំពីកាលដែលលះបានហើយ ។ បទថា **និហិតទណ្ឌោ និហិតសត្ថោ** អធិប្បាយថា ឈ្មោះថា ជាអ្នកមានដំបង និងសស្ត្រា ដាក់ចុះហើយ ព្រោះការមិនកាន់យកដំបង ឬសស្ត្រា ដើម្បីការបៀតបៀនសត្វដទៃ ។ ក្នុងអធិការនេះ វៀរដំបងចេញហើយ ឧបករណ៍ដ៏សេសទាំងពួង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា សស្ត្រា ព្រោះជាគ្រឿងបៀតបៀនសត្វទាំងឡាយ ។ ភិក្ខុកាន់យកវត្ថុណា គឺទោះជាឈើច្រត់មនុស្សចាស់ ឬកាំបិតសម្រាប់កាត់ឈើស្ទន់ ឬកាំបិតតូចត្រាច់ទៅ វត្ថុនោះ មិនឈ្មោះថា សស្ត្រា ព្រោះមិនប្រព្រឹត្តទៅដើម្បីបៀតបៀនសត្វដទៃ ព្រោះហេតុនោះ ភិក្ខុទាំងឡាយនោះ រមែងដល់នូវការរាប់ថា ជាអ្នកមានដំបង និងសស្ត្រា ដាក់ចុះហើយ ។

បទថា **លជ្ជី** បានដល់ ដែលប្រកបដោយការខ្មាស មានការរង្កៀសបាបជាលក្ខណៈ ។ បទថា **ទយាបន្នោ** បានដល់ ដល់នូវការអាណិតអាសូរ គឺដែលមានចិត្តប្រកបដោយមេត្តា ។ បទថា **សព្វបាណភូតហិតានុកម្បី** បានដល់ ដែលអនុគ្រោះសត្វទាំងពួងដោយប្រយោជន៍ អធិប្បាយថា ឈ្មោះ

ថា **សព្វថាណភូតហិតានុកម្បី** ព្រោះភាពជាអ្នកដល់នូវការអាណិតអាសូរនោះ ។ បទថា **វិហរតិ** បានដល់ ផ្លាស់ប្តូរឥរិយាបថ គឺរមែងរក្សាអត្តភាព ។

បុគ្គលណា កាន់យករបស់ដែលគេឲ្យប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ទិន្នាទាយី** ។ បុគ្គលណា សង្ឃឹមរបស់ដែលគេឲ្យដោយចិត្តនោះឯង ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ទិន្នថាដិកង្ខី** ។ បុគ្គលណាលួច ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ថេនោ** បុគ្គលណាមិនលួច បុគ្គលនោះ ឈ្មោះថា **អថេនេន** ។ ឈ្មោះថា **សុចិភូតេន** ព្រោះភាពមិនជាចោរនោះឯង ។

បទថា **អត្តនា** បានដល់ អត្តភាព មានពាក្យអធិប្បាយថា ធ្វើអត្តភាពមិនឲ្យជាចោរ ឲ្យស្អាត ។ បទថា **អព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តធម៌ដែលមិនប្រសើរ ។ បុគ្គលណា រមែងប្រព្រឹត្តអាចារ គឺចរិយាដែលល្អស្អាតដែលប្រសើរបំផុត ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **ព្រហ្មចារី** ។ បទថា **អារាចារី** បានដល់ ប្រព្រឹត្តឆ្ងាយចាកព្រហ្មចរិយៈដែលមិនប្រសើរ ។

បទថា **មេថុនា** បានដល់ ចាកអសទ្ធម្ម ដែលដល់នូវការរាប់ថា ជាមេថុន ព្រោះការៈដែលបុគ្គលគប្បីសេពចំពោះ តាមវោហារនៃសត្វលោកដែលបានឈ្មោះថា **មេថុនកា** គឺអ្នកសេពមេថុនធម្ម ព្រោះជនទាំងពីរ ដូចគ្នាតែមួយដោយអំណាចនៃការគ្របសង្កត់របស់រាគៈ ។ បទថា **គាមធម្មា** បានដល់ ធម៌របស់អ្នកគ្រប់គ្រងផ្ទះ ។

បុគ្គលណា រមែងពោលពាក្យពិត ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សច្ចវាទី** ។ បុគ្គលណាជាប់ត គឺបន្តសច្ចវាចា ដោយសច្ចវាចា ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សច្ចសន្ធោ** អធិប្បាយថា មិនពោលកុហកក្នុងចន្លោះ បុគ្គលណា ជួនកាលនិយាយកុហក ជួនកាលនិយាយពិត ពាក្យរបស់បុគ្គលនោះ មិន-តសច្ចៈ និងសច្ចៈ ព្រោះពាក្យរបស់បុគ្គលនោះខណ្ឌដោយពាក្យកុហក ព្រោះហេតុនោះ ទើបមិនឈ្មោះថា **សច្ចសន្ធោ** ។ ចំណែកបុគ្គលនេះ មិនមែនដូច្នោះឡើយ មិនព្រមនិយាយកុហក ព្រោះហេតុសូម្បីតែជីវិត រមែងបន្តសច្ចៈដោយសច្ចៈប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបុគ្គលនេះ ឈ្មោះថា **សច្ចសន្ធោ** ។

បទថា **ថេតោ** បានដល់ មានពាក្យសម្តីមាំទាំ អធិប្បាយថា មានវាចាតាំងមាំ បុគ្គលម្នាក់មានវាចាមិនតាំងមាំ ប្រៀបដូចសំពត់ ដែលគេជ្រលក់ដោយរមៀត ដូចបង្គោលដែលដោតលើគំនរអង្កាម និងដូចត្រឡាចដាក់លើខ្នងសេះ ។ បុគ្គលម្នាក់មានវាចាមាំទាំ ដូចគំនូសលើថ្មថ្ម និងដូចសសរខឿន ទោះបីត្រូវកាត់ក្បាលដោយដាវ បុគ្គលនោះក៏មិនពោលពាក្យបែកជា ២ បុគ្គលនេះ លោកហៅថា **ថេតោ** ។

បទថា **បច្ចយិកោ** បានដល់ ដែលមានវាចាគួរជឿ គឺបុគ្គលដែលគួរជឿបាន ។ បុគ្គលខ្លះ ជាអ្នកជឿមិនបាន កាលបុគ្គលណាម្នាក់សួរថា ពាក្យនេះអ្នកណាពោល កាលមានគេប្រាប់ថា បុគ្គលឈ្មោះនោះ ជាអ្នកពោល បុគ្គលនោះរមែងដល់នូវភាវៈដែលបុគ្គលណាម្នាក់ គប្បីពោលថា ពួកអ្នកកុំ

ជឿពាក្យរបស់បុគ្គលនោះ ។ បុគ្គលណាមួយ ជាអ្នកមានវាចាកាន់យកបាន កាលបុគ្គលណាសួរថា ពាក្យនេះ អ្នកណាពោល កាលមានគេប្រាប់ថា បុគ្គលឈ្មោះនោះ ជាអ្នកពោល បុគ្គលនោះរមែងដល់នូវការៈ ដែលបុគ្គលណាមួយគប្បីពោលថា បើពាក្យរបស់បុគ្គលនោះពោល ពាក្យនោះឯង កាន់យកជាប្រមាណបាន ឥឡូវនេះ មិនចាំបាច់សាកសួរពាក្យនេះយ៉ាងនោះឯង ។ បុគ្គលនេះ ហៅថា **បច្ចយិកោ** ។

បទថា **អវិសំវាទកោ លោកស្ស** អធិប្បាយថា រមែងមិនបានពោលឲ្យឃ្លៀងឃ្លាត ព្រោះខ្លួនមានប្រក្រតីពោលពាក្យសច្ចៈនោះ ។ បទថា **ឥមេសំ ភេទាយ** បានដល់ វាចាដែលស្តាប់មកហើយ ក្នុងសម្នាក់របស់បុគ្គលពួកណា ដែលត្រូវពោលដល់ថា ស្តាប់មកហើយអំពីទីនេះ ដើម្បីនឹងទម្លាយបុគ្គលទាំងនោះ ។ បទថា **ភិន្នានំ វា សន្ធាតា** បានដល់ ការចូលទៅរកភាគីម្ខាង ក្នុងជនទាំង ២ ចំណែក គឺមិត្ត ឬបុគ្គលរួមឧបជ្ឈាយ៍ជាដើម ដែលបែកសាមគ្គីដោយហេតុណាមួយ ហើយពោលថា ការទាស់ទែងគ្នានេះ មិនសមគួរដល់លោកទាំងឡាយ ដែលកើតក្នុងត្រកូលបែបនេះ ដែលជាពហូសូតយ៉ាងនេះ ហើយធ្វើនូវការរាប់អានសាមគ្គីគ្នា ។ បទថា **អនុប្បទាតា** បានដល់ ដែលព្រមព្រៀងគ្នា អធិប្បាយថា ឃើញជនទាំង ២ មានការសាមគ្គីគ្នា ហើយពោលថា សេចក្តីនេះ សមគួរដល់លោកដែលកើតក្នុងត្រកូលបែបនេះ ដែលប្រកបដោយគុណទាំងឡាយបែបនេះ ហើយធ្វើឲ្យជាអ្នកមាំទាំ ។ ការត្រេកអរទូទៅក្នុងជនដែលព្រមព្រៀងគ្នានៃបុគ្គលនោះមាន

ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **សមគ្គារាមោ** អធិប្បាយថា ជនដែលព្រមព្រៀងគ្នាមិនមានក្នុងទីណា បុគ្គលនោះ មិនទៅនៅក្នុងទីនោះ ។ បាលីថា **សមគ្គរាមោ** ដូច្នេះក៏មាន ។ ពាក្យនេះមានន័យដូចគ្នា ។ បទថា **សមគ្គរតោ** អធិប្បាយថា បុគ្គលនោះ មិនចេញចាកជនដែលព្រមព្រៀងគ្នានោះ ហើយទៅក្នុងទីដទៃ ។ បុគ្គលណា ឃើញក្តី ឮក្តីនូវជនដែលព្រមព្រៀងគ្នា ហើយរមែងត្រេកអរ ព្រោះហេតុនោះ ទើបបុគ្គលនោះឈ្មោះថា **សមគ្គនន្ទី** ។ បទថា **សមគ្គករណី វាចំ ភាសិតា** សេចក្តីថា វាចាណារមែងធ្វើសត្វទាំងឡាយ ឲ្យជាអ្នកព្រមព្រៀងគ្នាប៉ុណ្ណោះ បុគ្គលនោះ រមែងពោលវាចានោះ ដែលសម្តែងដល់គុណនៃសាមគ្គីនោះឯង មិនពោលវាចាដទៃក្រៅអំពីនេះឡើយ ។

បុគ្គលណា ពោលក្នុងកាលដ៏សមគួរ ព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា **កាលវាទី** អធិប្បាយថា បុគ្គលនោះ កំណត់កាលដ៏សមគួរ ដល់ពាក្យដែលខ្លួនគប្បីពោលហើយ ទើបពោល ។

បុគ្គលណា រមែងពោលពាក្យពិត ពាក្យត្រឹមត្រូវ គឺពាក្យដែលជាសភាវៈប៉ុណ្ណោះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ភូតវាទី** ។

បុគ្គលណា ពោលពាក្យអាស្រ័យប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ក្នុងភពខាងមុខប៉ុណ្ណោះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អត្ថវាទី** ។

បុគ្គលណា ពោលពាក្យអាស្រ័យលោកុត្តរធម៌ ៩ ប្រការ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **ធម្មវាទី** ។

បុគ្គលណា ពោលពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **វិនយវាទី** ។

ឱកាសដែលជាទីតាំងនៃវាចានោះ លោកហៅថា **និធានំ** ។ ឱកាសជាទីតាំងនៃវាចានោះមាន ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **និធានវតី** អធិប្បាយថា ពោលវាចាដ៏សមគួរ ដល់ពាក្យដែលបុគ្គលគប្បីកប់ទុកក្នុងហឫទ័យ ។ បទថា **កាលេន** សេចក្តីថា កាលពោលវាចាបែបនេះ គិតថា អញនឹងពោលវាចាដែលមានគោល មិនពោលដោយកាលដែលមិនសមគួរ អធិប្បាយថា ពិចារណាកាលវេលាដ៏សមរម្យហើយ ទើបពោល ។ បទថា **សាបទេសំ** បានដល់ មានឧបមា អធិប្បាយថា មានហេតុ ។ បទថា **បរិយន្តវតី** សេចក្តីថា គោលកំណត់របស់វាចានោះ រមែងប្រាកដដោយប្រការណា រមែងសម្តែងកំណត់ ហើយពោលដោយប្រការនោះ ។ បទថា **អត្ថសំហិតំ** បានដល់ បរិបូរណ៍ដោយប្រយោជន៍ ដែលបុគ្គលណាមួយ ចែកដោយន័យមិនមែនតិច ក៏មិនអាចកំណត់បាន ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា រមែងពោលវាចា ដែលប្រកបដោយប្រយោជន៍ ព្រោះប្រកបទៅដោយប្រយោជន៍ដែលអ្នកពោលអត្ថនោះពោល គឺមិនលះបង់ពាក្យណាមួយ ពោលនូវពាក្យមួយទៀត ។

បទថា **ពីជគាមភូតគាមសមារម្ភា** បានដល់ ការធ្វើពីជគាម ៥ យ៉ាងឲ្យវិនាស គឺពូជកើតពីមើម ឬឫស ១ ពូជកើតពីដើម ១ ពូជកើតពីថ្នាំង ១ ពូជកើតពីចុង ឬគល់ ១ ពូជកើតពីពូជ ( គឺផ្លែ ) ១ និងការ

ទម្លាយភូតគាម មានរបស់ពណ៌ខៀវ និងដើមឈើជាដើមណាមួយ អធិប្បាយថា ជាអ្នកវៀរចាកនូវការទម្លាយដោយការៈ មានការកាត់ ការស្ងោរជាដើម ។ បទថា **ឯកភត្តិកោ** សេចក្តីថា ភត្ត ២ យ៉ាង គឺភត្តសម្រាប់ពេលព្រឹក និងភត្តសម្រាប់ពេលល្ងាច ។ ក្នុងភត្ត ២ យ៉ាងនោះ ភត្តដែលបរិភោគក្នុងវេលាព្រឹក លោកកំណត់ខាងក្នុងពេលថ្ងៃត្រង់ ភត្តដែលបរិភោគក្នុងពេលល្ងាច លោកកំណត់តាំងពីថ្ងៃត្រង់រហូតដល់អរុណរះ ព្រោះហេតុនោះ កាលភិក្ខុបរិភោគអាហារ ១០ ដង ក្នុងពេលថ្ងៃត្រង់ រមែងជាបុគ្គលឈ្មោះថាជាអ្នកបរិភោគតែមួយពេល ទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់ថា ជាអ្នកបរិភោគតែមួយពេល ។ ការបរិភោគភត្តក្នុងពេលយប់ ឈ្មោះថា **រត្តិ** បុគ្គលណា វៀរចាកការបរិភោគភត្ត ក្នុងពេលយប់នោះ ព្រោះហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **រត្តូបរតោ** ។ ការបរិភោគភត្តតាំងអំពីពេលថ្ងៃត្រង់កន្លងទៅហើយ រហូតដល់ព្រះអាទិត្យលិច ឈ្មោះថា **វិកាលភោជនំ** ។ ឈ្មោះថា **វិរតោ វិកាលភោជនា** ព្រោះជាបុគ្គលវៀរចាកការបរិភោគក្នុងវេលាវិកាលនោះ ។

ការមើលល្បែងដែលជាសត្រូវដែលជាបដិបក្ខចំពោះព្រហ្មចរិយៈ ព្រោះមិនប្រព្រឹត្តទៅតាមសាសនា ព្រោះហេតុនោះ ទើបឈ្មោះថា **វិសូកទស្សនំ** ។ ការរាំ ការច្រៀង និងការប្រគំ ដោយអំណាចនៃការរាំឯង ឬឲ្យអ្នកដទៃរាំជាដើមក្តី ការមើលនូវការរាំជាដើម ដែលប្រព្រឹត្តទៅ ដោយហោចមើលក្មេករាំជាដើម ដែលជាសត្រូវចំពោះព្រហ្មចរិយៈក្តី ព្រោះហេតុនោះ ទើប

ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនា** ។ ការដែលខ្លួនប្រកបនូវការរាំជាដើមក្តី ឲ្យបុគ្គលដទៃប្រកបក្តី ការមើលនូវការលេងដែលគេប្រកបហើយក្តី មិនសមគួរដល់ភិក្ខុ និងភិក្ខុនីឡើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **មាលា** ជាដើម ដូចតទៅនេះ បទថា **មាលា** បានដល់ ផ្កាណាមួយ ។ បទថា **គន្ធំ** បានដល់ គន្ធជាតិណាមួយ ។ បទថា **វិលេបនំ** បានដល់ ការប្រោះព្រំស្បែក ក្នុងអធិការនេះ បុគ្គលកាលប្រដាប់តាក់តែង ឈ្មោះថា ធារៈ ។ កាលបុគ្គលធ្វើវត្ថុដែលខ្វះខាតឲ្យបរិបូណ៌ ឈ្មោះថា មណ្ឌៈ ។ បុគ្គលត្រេកអរដោយគ្រឿងក្រអូបក្តី ដោយការលាបស្បែកក្តី ឈ្មោះថា វិភូសៈ ។ ហេតុហៅថា ឋានៈ អធិប្បាយថា មហាជន រមែងធ្វើនូវការទ្រទ្រង់ផ្កាជាដើមនោះ ដោយចេតនាជាគ្រឿងទ្រុស្តសីលឯណា បុគ្គលមានសីល រមែងជាអ្នកវៀរចាកចេតនា ជាគ្រឿងទ្រុស្តសីលនោះ ។

ទីដេកខ្ពស់ហួសប្រមាណ ហៅថា **ឧច្ចាសយនំ** ទីដេកដែលមិនសមគួរឈ្មោះថា **មហាសយនំ** អធិប្បាយថា អ្នកមានសីល ជាអ្នកវៀរចាកទីដេកទីអង្គុយនោះ ។

មាស ឈ្មោះថា **ជាតរូបំ** ។ កហាបណៈ លោហមាសកៈ គឺមាសកៈធ្វើដោយលោហៈ ជតុមាសកៈ គឺមាសកៈធ្វើដោយជ័រ ទារុមាសកៈ គឺមាសកៈធ្វើដោយឈើ ឬរបស់ឯណាមួយ ដែលដល់នូវវោហារ គឺចាយវាយបាន ឈ្មោះថា **រជតំ** អធិប្បាយថា លោកជាអ្នកវៀរចាកនូវការទទួលប្រាក់ និង

មាសទាំង ២ យ៉ាងនោះ គឺមិនទទួលឯងក្តី មិនឲ្យអ្នកដទៃទទួលក្តី មិនត្រេកអរនូវប្រាក់ និងមាសដែលគេទុកដាក់ក្តី ។

បទថា **អាមកធញ្ញបដិគ្គហណា** បានដល់ វៀរចាកការទទួលធញ្ញជាតិឆៅ ៧ ប្រភេទ គឺស្រូវសាលី ១ ស្រូវខ្សាយ ១ ស្រូវជំណើប ១ ស្រងែ ១ ថ្មៅ ១ ស្កួយ ១ ស្មៅគែលលក ១ ។ ការទទួលធញ្ញជាតិឆៅ ៧ ប្រភេទនោះ មិនគួរដល់ភិក្ខុទាំងឡាយប៉ុណ្ណោះក៏មិនមែន សូម្បីការប៉ះពាល់វត្ថុទាំងនោះ ក៏មិនគួរដូចគ្នា ។ ក្នុងបទថា **អាមកមំសបដិគ្គហណា** នេះ ការទទួលត្រីសាច់ឆៅ ក៏មិនគួរដល់ភិក្ខុទាំងឡាយ ក្រៅអំពីព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកដោយចំពោះប៉ុណ្ណោះ សូម្បីការពាល់ត្រូវត្រីសាច់ឆៅក៏មិនគួរ ។ ក្នុងបទថា **ឥត្ថិកុមារិកបដិគ្គហណា** នេះ ស្រីដែលទៅកាន់រវាងបុរស ( ស្រីដែលល្មមរៀបការបាន ) ឈ្មោះថា **ឥត្ថី** ស្រីក្រៅពីនេះឈ្មោះថា **កុមារិកា** ការទទួលក្តី ការពាល់ត្រូវក្តី នូវស្រីទាំងឡាយនោះជារបស់មិនគួរទាំងអស់ ។ ក្នុងបទថា **ទាសិទាសបដិគ្គហណា** នេះ ការទទួលស្រី និងប្រុសទាំងនោះសម្រាប់ជាទាសី ជាទាសា មិនសមគួរ ។ បើបុគ្គលណាមួយពោលយ៉ាងនេះថា ខ្ញុំសូមប្រគេនកប្បិយការកៈ គឺឧបដ្ឋាកខ្ញុំសូមប្រគេនអារាមិក គឺអ្នកបម្រើក្នុងវត្ត ដូច្នេះ ទោះបីទទួលក៏គួរ ។ ន័យដែលគួរ និងមិនគួរក្នុងសត្វទាំងឡាយ មានពពែ ចៀមជាដើម ក្នុងទីទាំងឡាយ មានស្រែ និងចម្ការជាទីបំផុត បណ្ឌិតគប្បីពិចារណាដោយអំណាចព្រះវិន័យ ។

ក្នុងទីទាំងនោះ ទីណាមានបុព្វណ្ណជាតិដុះ ទីនោះ ឈ្មោះថា ស្រែ ក្នុងទីណាមានអបរន្នជាតិដុះ ទីនោះ ឈ្មោះថា ចម្ការ ។ ម្យ៉ាងទៀត បុព្វណ្ណជាតិ និងអបរន្នជាតិទាំង ២ រមែងដុះក្នុងទីណា ទីនោះ ឈ្មោះថា ស្រែ ភូមិភាគដែលគេធ្វើហើយដើម្បីបុព្វណ្ណជាតិ និងអបរន្នជាតិនោះ ឈ្មោះថា ចម្ការ ។ ក្នុងអធិការនេះ លោកសង្គ្រោះយកបឹង និងត្រពាំងជាដើមផងដែរ ក្នុងមាតិកាថា ស្រែ និងចម្ការនោះឯង ។

ការងាររបស់ទូត ហៅថា **ទូតេយ្យំ** បានដល់ ការកាន់យកសំបុត្រ ឬដំណឹងដែលពួកគ្រហស្ថបញ្ជូនទៅ ហើយនាំទៅក្នុងទីនោះៗ ។ ការទទួលបម្រើបន្តិចបន្តួចដល់បុគ្គលដែលបញ្ជូនទៅកាន់ផ្ទះដទៃ ហៅថា **បហិណគមនំ** ។ ការធ្វើកិច្ចទាំង ២ យ៉ាងនោះ ឈ្មោះថា **អនុយោគោ** ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្តីក្នុងពាក្យនេះយ៉ាងនេះថា កិរិយាប្រកបរឿយៗនូវទូតកម្ម ឬនាំសំបុត្រ ឬពាក្យបណ្តាំរបស់គ្រហស្ថ ។ បទថា **កយវិក្កយា** បានដល់ ចាកការទិញ និងការលក់ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **តុលាកូដ** ជាដើម ដូចតទៅនេះ បទថា **កូដំ** បានដល់ ការបោកបញ្ឆោត ។ បណ្តាការបោកបញ្ឆោតទាំងនោះ ការបន្លំដោយជញ្ជីង មាន ៤ យ៉ាង គឺរូបកូដំ ១ អង្គកូដំ ១ គហណកូដំ ១ បដិច្ឆន្នកូដំ ១ ។ ក្នុងការបន្លំទាំងនោះ បុគ្គលធ្វើជញ្ជីងទាំង ២ ឲ្យមានសភាពដូចគ្នា កាលទិញចូល រមែងប្រើជញ្ជីងដែលថ្លឹងបានធ្ងន់ កាលលក់ចេញ រមែងថ្លឹងជញ្ជីងដែលថ្លឹងបានស្រាល ឈ្មោះថា **រូបកូដំ** គឺបន្លំដោយរូប ។ បុគ្គលកាលទិញចូល

រមែងប្រើដៃសន្ធត់ជញ្ជីងទុកក្នុងចំណែកខាងចុង កាលលក់ចេញរមែងប្រើដៃសន្ធត់ចំណែកខាងគល់ ឈ្មោះថា **អឌ្ឍកូដំ** គឺបន្លំដោយអវយវៈ ។ បុគ្គលកាលទិញចូល រមែងកាន់យកត្រង់ដើមខ្សែ កាលលក់ចេញរមែងចាប់ត្រង់ចុងខ្សែ ឈ្មោះថា **គហណកូដំ** គឺបន្លំដោយការចាប់កាន់ ។ បុគ្គលធ្វើជញ្ជីងឲ្យជាប្រហោង ហើយដាក់កម្ទេចដែកទុកខាងក្នុង កាលទិញចូលរមែងធ្វើកម្ទេចដែកនោះទុកក្នុងចំណែកខាងចុង កាលលក់ចេញ ក៏ធ្វើកម្ទេចដែកនោះ ទុកក្នុងចំណែកខាងគល់ ឈ្មោះថា **បដិច្ឆន្នកូដំ** គឺបន្លំដោយវត្ថុដែលបិទបាំង ។

ថាសដែលធ្វើដោយមាសហៅថា **កំសោ** ។ ការបន្លំដោយថាសមាសនោះ ឈ្មោះថា **កំសកូដំ** ។ សួរថា បន្លំដូចម្តេច ឆ្លើយថា ជនទាំងឡាយធ្វើថាសមាស ១ ធ្វើថាសក្លែងក្លាយ ២ ឬ ៣ បន្ទាប់អំពីនោះ ក៏ទៅកាន់ជនបទ ហើយចូលទៅកាន់ត្រកូលដែលស្តុកស្តម្ភណាមួយ ហើយពោលថា លោកទាំងឡាយ ចូរទិញថាសមាស កាលបុគ្គលណាមួយ សួរដល់តម្លៃបុគ្គលនោះបំណងនឹងឲ្យច្រើនជាងតម្លៃពិត ។ បន្ទាប់អំពីនោះ កាលជនទាំងនោះពោលថា ខ្ញុំគប្បីជ្រាបភាពជាភាជន៍មាសនៃថាសទាំងនេះ បានដូចម្តេច បុគ្គលនោះ ក៏យកថាសមាសដុសនឹងថ្ម ហើយពោលថា លោកទាំងឡាយសូមពិចារណាមើលជាមុនសិន ហើយសឹមកាន់យក ហើយឲ្យថាសទាំងអស់ គឺលក់ទាំងអស់ ហើយក៏ទៅ ។

រង្វាស់រង្វាល់មាន ៣ យ៉ាង គឺហទយភេទ វាល់ដោយការបន្ថយ ១

សិខាភេទ វាល់ដោយកំពូល ១ រជ្ជុភេទ វាស់ដោយខ្សែ ១ ។ ក្នុងការវាល់ទាំងនោះ ការវាល់ដោយបន្ទយ រមែងបានក្នុងពេលដែលគេវាល់សប្បិនិងប្រេងជាដើម បុគ្គលកាលទិញចូលសប្បិជាដើម ដោយខ្លួនឯង ដោយរង្វាល់ដែលមានរន្ធខាងក្រោម ក៏ពោលថា សូមចាក់សន្សឹមៗ ហើយក៏ឲ្យហូរចេញជាច្រើនទៅខាងក្នុងភាជនៈដែលនៅខាងក្រោម ហើយទើបកាន់យកកាលលក់ឲ្យអ្នកដទៃ ក៏បិទរន្ធនោះ ធ្វើឲ្យពេញដោយរហ័ស ហើយឲ្យ ។ វាល់ដោយកំពូល រមែងបានក្នុងកាលវាល់ល្ង និងអង្ករជាដើម កាលទិញចូលរបស់ទាំងនោះដោយខ្លួនឯង ក៏វាល់ឲ្យមានកំពូលសន្សឹមៗ ហើយកាន់យក កាលវាល់ឲ្យអ្នកដទៃ ក៏វាល់ឲ្យពេញដោយរហ័ស កៀសនូវកំពូលចោល ហើយឲ្យ ។ វាស់ដោយខ្សែ រមែងបានក្នុងពេលដែលវាស់ស្រែចម្ការបុគ្គលទាំងឡាយ កាលមិនបានសំណូក តែងវាស់ស្រែសូម្បីមិនធំឲ្យធំ ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧក្កោដនំ** ជាដើម ដូចតទៅនេះ ការធ្វើទ្រព្យ របស់បុគ្គលជាម្ចាស់ មិនឲ្យជាម្ចាស់ ហើយកាន់យកសំណូក ឈ្មោះថា **ឧក្កោដនំ** ។ ការបោកបញ្ឆោតអ្នកដទៃដោយឧបាយនោះៗ ឈ្មោះថា **វញ្ចនំ** ។ ក្នុងរឿងនេះ មានរឿងមួយជាឧទាហរណ៍ដូចតទៅ

បានឮថា ព្រានម្រឹគម្នាក់ចាប់បានមេម្រឹគ និងកូនម្រឹគធ្វើដំណើរមក អ្នកលេងម្នាក់និយាយនឹងព្រាននោះថា នែអ្នកដ៏ចម្រើន មេម្រឹគ និងកូនម្រឹគនេះតម្លៃប៉ុន្មាន កាលព្រានឆ្លើយថា មេម្រឹគតម្លៃ ២ កហាបណៈ ឯកូនម្រឹគតម្លៃ

១ កហាបណៈ ដូច្នេះហើយ អ្នកលេងក៏ឲ្យប្រាក់ ១ កហាបណៈ ហើយចាប់យកកូនម្រឹគទៅ កាលទៅបានបន្តិចក៏ត្រឡប់មកពោលថា អ្នកដ៏ចម្រើន ខ្ញុំមិនត្រូវការកូនម្រឹគ សូមអ្នកឲ្យមេម្រឹគដល់ខ្ញុំ ។ នាយព្រានពោលថា បើដូច្នោះ សូមឲ្យខ្ញុំ ២ កហាបណៈ ។ អ្នកលេងពោលថា អ្នកដ៏ចម្រើន ខ្ញុំឲ្យអ្នក ១ កហាបណៈមុនហើយ មិនមែនឬ កាលនាយព្រានឆ្លើយថា ត្រូវហើយ អ្នកឲ្យខ្ញុំ ១ កហាបណៈ អ្នកលេងក៏ពោលថា សូមអ្នកទទួលយកកូនម្រឹគនេះ កាលបើដូច្នោះ កហាបណៈនោះផង កូនម្រឹគនេះមានតម្លៃ ១ កហាបណៈផង រួមជា ២ កហាបណៈ ។ នាយព្រាននោះពិចារណាមើលថា អ្នកលេងនេះពោល មានហេតុផល ទើបទទួលយកកូនម្រឹគ ឲ្យមេម្រឹគដល់អ្នកលេងនោះទៅ ។

ការបញ្ឆោតបន្ទំ គឺធ្វើវត្ថុដែលមិនមែនសង្ខារ ឲ្យជាសង្ខារក្តី ធ្វើវត្ថុមិនមែនកែវមណីឲ្យដូចជាកែវមណីក្តី ធ្វើមាសក្លែងក្លាយឲ្យដូចមាសសុទ្ធក្តី ដោយអំណាចការប្រកប ឬដោយអំណាចកលមាយា ឈ្មោះថា **និកតិ** ។ ការប្រកបក្នុងការកោង ឈ្មោះថា **សាចិយោគ** ។ បទថា **សាចិយោគ** នេះ ជាឈ្មោះនៃការកោង មានការទទួលសំណូកជាដើមនោះឯង ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងអធិការនេះយ៉ាងនេះ គឺបុគ្គលប្រកបការកោងដោយការទទួលសំណូក បុគ្គលប្រកបការកោង ដោយការបោកបញ្ឆោត បុគ្គលប្រកបការកោងដោយរបស់ក្លែងក្លាយ ។ កេចិអាចារ្យពោលថា ការឲ្យមើលរបស់មួយហើយប្តូរជារបស់មួយទៀត ឈ្មោះថា **សាចិយោគ** ការធ្វើនេះ

សង្គ្រោះចូលក្នុងពាក្យថា **វញ្ចន** គឺឆបោកនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឆេទនំ** ជាដើម ដូចតទៅនេះ បទថា **ឆេទនំ** បានដល់ ការកាត់ដៃជាដើម ។ បទថា **វធោ** បានដល់ ការសម្លាប់ឲ្យស្លាប់ ។ បទថា **ពន្ធោ** បានដល់ ការចង មានការចងដោយខ្សែជាដើម ។ បទថា **វិបរាមោសោ** បានដល់ ការវាយដណ្តើម ។ ការវាយដណ្តើមមាន ២ យ៉ាង គឺ **ហិមវិបរាមោសោ** ការវាយដណ្តើម អាស្រ័យសន្សើម ១ **គុម្ពវិបរាមោសោ** ការវាយដណ្តើម អាស្រ័យគុម្ពឈើ ១ ។ ពិតហើយ ក្នុងសម័យណាដែលសន្សើមធ្លាក់ ពួកអ្នកលេងទាំងឡាយបិទបាំងខ្លួនដោយសន្សើមដែលធ្លាក់ ហើយក៏វាយដណ្តើមអ្នកដំណើរ ដូច្នេះ ឈ្មោះថា **ហិមវិបរាមោសោ** ។ ពួកអ្នកលេងអាស្រ័យគុម្ពឈើដើម្បីពួនហើយវាយដណ្តើមអ្នកដំណើរ ដូច្នេះ ឈ្មោះថា **គុម្ពវិបរាមោសោ** ។ ការប្លន់ស្រុក និងតំបន់ជាដើម ហៅថា **អាលោបោ** ។ ការចូលទៅកាន់ផ្ទះអ្នកដទៃដោយអាកប្បកិរិយាកាចសាហាវ ហើយយកសស្ត្រា ភ្ជង់ត្រង់ទ្រូងមនុស្ស រួចកាន់យកទ្រព្យដែលខ្លួនប្រាថ្នា ឈ្មោះថា **សហសាការោ** ។ បុគ្គលដែលមានសីលរមែងវៀរចាកការប្រទូស្ត មានការកាត់ជាដើមនោះ ដោយប្រការដូច្នេះ ។

បទថា **សោ សន្តុដ្ឋោ ហោតិ** សេចក្តីថា ភិក្ខុនោះជាអ្នកប្រកបដោយសន្តោសក្នុងបច្ច័យតាមមានតាមបាន ១២ យ៉ាង ក្នុងបច្ច័យ ៤ ។ បទថា **កាយបរិហារិកេន** បានដល់ ដោយបច្ច័យណាមួយដែលគ្រាន់តែជាគ្រឿងថែរក្សាកាយ ។ បទថា **កុច្ឆិបរិហារិកេន** បានដល់ ដោយបច្ច័យត្រឹមតែ

ជាគ្រឿងរក្សាផ្ទៃ ។ បទថា **សមាទាយេវ បក្កមតិ** សេចក្តីថា ភិក្ខុនោះកាន់យកបរិក្ខារ ៨ ដែលជាបរិក្ខារសម្រាប់ភិក្ខុប៉ុណ្ណោះធ្វើឲ្យទាក់ទងដោយកាយហើយក៏ទៅ ។ ភិក្ខុនោះ ជាអ្នកមិនជាប់ជំពាក់ មិនរសេមរសាមថា វិហាររបស់អញ បរិវេណរបស់អញ ឧបដ្ឋាករបស់អញ ភិក្ខុនោះ ប្រើប្រាស់សេនាសនៈដែលជាដងព្រៃ គល់ឈើ ព្រៃញៀតស្បាត ញកភ្នំ តាមប្រាថ្នាជាអ្នកឈរតែឯង អង្គុយតែឯងមិនមានសម្លាញ់ជាគម្រប់ ២ ក្នុងឥរិយាបថទាំងពួង ដូចព្រួញដែលផុតអំពីបន្ទោះធ្នូ ដូចដំរីចុះប្រេងលះហ្វូងដូច្នោះ ភិក្ខុនោះ រមែងដល់នូវភាពជាបុគ្គលដូចកុយរមាស ដែលលោកពណ៌នាពាក្យជាគាថាដូច្នេះថា

**ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ  សន្តុស្សមានោ ឥតរីតរេន**
**បរិស្សយានំ សហិតា អឆម្ភី  ឯកោ ចរេ ខគ្គវិសាណកប្បោ ។**

បុគ្គលជាអ្នកនៅជាសុខក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរ
ដោយបរិក្ខារតាមមានតាមបាន ជាអ្នកអត់ធន់ចំពោះអន្តរាយ
ទាំងឡាយ ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅតែម្នាក់ឯង
ដូចកុយរមាស ដូច្នោះ ។

ឥឡូវនេះ ព្រះសាស្តា កាលទ្រង់ញ៉ាំងសេចក្តីនោះ ឲ្យសម្រេចបរិបូរដោយពាក្យឧបមា ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បក្ខី សកុណោ** បានដល់ សត្វដែលប្រកបដោយស្លាប ។ បទថា **ឌេតិ** បានដល់ រមែងហើរទៅ ។ ក្នុងអធិការនេះមានសេចក្តីសង្ខេប

ដូចតទៅនេះ

ធម្មតាបក្សីទាំងឡាយដឹងថា ដើមឈើក្នុងប្រទេសឈ្មោះនោះ មានផ្លែទុំ ហើយក៏នាំគ្នាហើរអំពីទិសផ្សេងៗ ហើយបំផ្លាញ និងចឹកស៊ីនូវផ្លែឈើទាំងឡាយនៃដើមឈើនោះដោយក្រចក ស្លាប និងចំពុះជាដើម តែបក្សីទាំងនោះមិនមានការហួងហែងថា ផ្លែឈើនេះ មានប្រយោជន៍ដល់ពួកយើងក្នុងថ្ងៃនេះ ផ្លែឈើនេះ នឹងមានប្រយោជន៍ដល់ពួកយើងក្នុងថ្ងៃស្អែកនេះ ។ កាលផ្លែឈើអស់ហើយ ពួកបក្សីក៏មិនតាំងការរក្សាដើមឈើទុកឡើយ សេចក្ដីថា ពួកបក្សីទាំងនោះមិនយកស្លាប ឬក្រចក ឬចំពុះគូសដើមឈើ ដើម្បីរក្សាទុក ពេលនោះ ហ្វូងបក្សីមិនជាប់ជំពាក់ក្នុងដើមឈើនោះ បក្សីណាចង់ទៅទិសណា បក្សីនោះ មានតែស្លាប ២ ប៉ុណ្ណោះជាភារៈហើយក៏ហើរទៅ យ៉ាងណា ភិក្ខុនេះ ក៏យ៉ាងនោះដូចគ្នា ជាអ្នកមិនជាប់ជំពាក់ មិនអាឡោះអាល័យហើយ ក៏ចៀសចេញទៅ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កាន់យកត្រឹមតែចីវរ និងបិណ្ឌបាត ។ បទថា **អរិយេន** បានដល់ មិនមានទោស ។ បទថា **អជ្ឈត្តំ** បានដល់ ក្នុងអត្តភាពរបស់ខ្លួន ។ បទថា **អនវជ្ជសុខំ** បានដល់ សេចក្ដីសុខដែលប្រាសចាកទោស ។ បទថា **សោ ចក្ខុនា រូបំ ទិស្វា** អធិប្បាយថា ភិក្ខុនោះ ជាអ្នកប្រកបដោយសីលក្ខន្ធ មិនមានទោសនេះ ឃើញរូបដោយចក្ខុវិញ្ញាណហើយ ។ ក្នុងបទដ៏សេស ពាក្យណាដែលខ្ញុំគប្បីពោល ពាក្យទាំងនោះ ខ្ញុំបានពោលហើយខាងដើមនោះឯង ។ បទថា **អព្យាសេកសុខំ** បានដល់ នូវសេចក្ដីសុខដែលកិលេសទាំងឡាយ មិនរួប

រឹត ។ លោកពោលថា ជាសេចក្ដីសុខដែលមិនលាយឡំ ដូច្នេះក៏មាន ។ ពិតហើយ សេចក្ដីសុខក្នុងឥន្ទ្រិយសំវរៈ ឈ្មោះថា ជាសេចក្ដីសុខដែលមិនលាយឡំ ព្រោះប្រព្រឹត្តទៅដោយអំណាច ត្រឹមតែឃើញហើយជាដើមបណ្ដាអារម្មណ៍ទាំងឡាយដែលខ្លួនឃើញហើយជាដើម ។ បទថា **សោ អភិក្កន្តេ បដិក្កន្តេ** អធិប្បាយថា ភិក្ខុនោះ ប្រកបដោយការសង្រួមឥន្ទ្រិយទាំងឡាយដែលមានចិត្តជាគម្រប់ ៦ រមែងជាអ្នកធ្វើសម្បជញ្ញៈ ដោយអំណាចនៃសតិសម្បជញ្ញៈក្នុងឋានៈទាំងឡាយ ៧ មានការឈានទៅមុខ និងឈានថយក្រោយជាដើមនេះ ។ បណ្ដាបទទាំងនោះ បទណា ដែលខ្ញុំគប្បីពោលបទនោះ ខ្ញុំបានពោលហើយ ក្នុងឈានវិភង្គនោះឯង ។

សួរថា ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌អ្វីទុកដោយពាក្យថា **សោ ឥមិនា ច** ដូច្នេះ ឆ្លើយថា ទ្រង់សម្ដែងបច្ចយសម្បត្តិរបស់ភិក្ខុ ដែលនៅព្រៃ ព្រោះថា បច្ច័យទាំង ៤ នេះ គឺសីលក្ខន្ធ ១ ឥន្ទ្រិយសំវរៈ ១ សតិសម្បជញ្ញៈ ១ សេចក្ដីសន្ដោស ១ មិនមានដល់ភិក្ខុណា ការនៅព្រៃក៏មិនសម្រេចប្រយោជន៍ដល់ភិក្ខុនោះ ។ ភិក្ខុនោះ ត្រូវដល់នូវភាពជាបុគ្គលដែលបុគ្គលណាមួយ គប្បីពោលប្រៀបដោយសត្វតិរច្ឆាន និងព្រានព្រៃ ។ ទេវតាដែលអាស្រ័យនៅក្នុងព្រៃ រមែងឲ្យបានឮសំឡេង ដែលគួរខ្លាចថា ប្រយោជន៍អ្វីដោយការនៅព្រៃ របស់ភិក្ខុអាក្រក់បែបនេះ ពួកអមនុស្សទាំងឡាយ នាំគ្នាយកដៃខោកក្បាល ធ្វើអាការឲ្យភិក្ខុនោះគេចចេញទៅ ។ ការមិនមានយសនៃភិក្ខុនោះ រមែងផ្សាយទៅថា ភិក្ខុឈ្មោះនោះចូលទៅនៅព្រៃ

*ហើយ ធ្វើកម្មអាក្រក់យ៉ាងនេះៗ បច្ច័យទាំង ៤ នេះ មានដល់ភិក្ខុណា ការនៅព្រៃក៏រមែងសម្រេចប្រយោជន៍ដល់ភិក្ខុនោះ ព្រោះថា កាលភិក្ខុពិចារណាសីលរបស់ខ្លួន កាលមិនឃើញភាពពុះសពពាល ត្រឹមតែបន្តិចបន្តួច ក៏ញុាំងបីតិ និងបាមោជ្ជឲ្យកើតឡើង ហើយពិចារណានូវបីតិនោះដោយការអស់ទៅ សូន្យទៅ ហើយរមែងឈានចុះកាន់អរិយភូមិ ។ ទេវតាទាំងឡាយដែលស្ថិតនៅក្នុងព្រៃ មានចិត្តត្រេកអរ រមែងពោលសរសើរគុណ ដោយហេតុនេះ យសនៃភិក្ខុនោះ តែងផ្សាយទូលំទូលាយទៅ ដូចតំណក់ប្រេងដែលបុគ្គលបន្តក់ក្នុងទឹក រមែងផ្សាយទូលាយទៅដូច្នោះ ។ បទថា* **វិវត្តំ** *ជាដើម មានសេចក្តីដូចពាក្យដែលខ្ញុំពោលហើយខាងដើមនោះឯង ។ ពាក្យណាដែលគួរពោលក្នុងទីមានប្រមាណប៉ុណ្ណេះថា* **សោ ឯវំ សមាហិតេ ចិត្តេ ។បេ។ យថាកម្មូបគេ សត្តេ បជានាតិ** *ដូច្នេះ ពាក្យទាំងអស់ ខ្ញុំពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។*

*វិជ្ជាទី ៣ គឺអាសវក្ខយញ្ញាណ បណ្ឌិតគប្បីជ្រាបថា ចតុត្ថជ្ឈានចិត្តមានវិបស្សនាជាបាទ ក្នុងបទថា* **សោ ឯវំ សមាហិតេ ចិត្តេ** ។ *បទថា* **អាសវានំ ខយញ្ញាណាយ** *បានដល់ ដើម្បីជាប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ។ អរហត្តមគ្គដែលញុាំងអាសវក្កិលេសឲ្យវិនាស លោកហៅថា ប្រាជ្ញាជាគ្រឿងដឹងនូវធម៌ ដែលធ្វើអាសវៈឲ្យអស់ទៅ ។ ពិតហើយ បញ្ញាក្នុងអរហត្តមគ្គញ្ញាណនោះ លោកហៅថា ធ្វើអាសវៈឲ្យអស់ទៅ ព្រោះជាធម៌ដែលទាក់ទងក្នុងអាសវៈនោះ ។ បទថា* **ចិត្តំ អភិនិន្នាមេតិ** *បានដល់*

រមែងនាំវិបស្សនាចិត្តទៅ ។ ក្នុងបទទាំងឡាយ មានបទថា **សោ ឥទំ ទុក្ខំ** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះទុក្ខសច្ចទាំងពួងតាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា ទុក្ខមានប្រមាណប៉ុណ្ណេះ មិនក្រៃលែងជាងនេះឡើយ ។ ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះនូវតណ្ហា ដែលជាដែនកើតនៃទុក្ខនោះ តាមសេចក្តីពិតដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា នេះហេតុឲ្យកើតទុក្ខ ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះនូវឋានៈ ដែលទុក្ខ និងតណ្ហាទាំងពីរ ដល់ហើយ ក៏រលត់ទៅ គឺព្រះនិព្វាន ដែលមានសភាពមិនប្រព្រឹត្តទៅនៃធម៌ទាំងពីរនោះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា នេះការរម្ងត់ទុក្ខ ។ ភិក្ខុរមែងដឹងទូទៅ គឺរមែងចាក់ធ្លុះអរិយមគ្គដែលជាហេតុ ឲ្យដល់ព្រះនិព្វាននោះ តាមសេចក្តីពិត ដោយការចាក់ធ្លុះលក្ខណៈ ព្រមទាំងកិច្ចថា នេះជាបដិបទាឲ្យដល់ការរម្ងត់ទុក្ខ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសច្ចៈទាំងឡាយដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងសច្ចៈដោយបរិយាយដោយអំណាចនៃកិលេស ទើបទ្រង់ត្រាស់បទថា **ឥមេ អាសវា** ដូច្នេះជាដើម ។ បទថា **តស្ស ឯវំ ជានតោ ឯវំ បស្សតោ** សេចក្តីថា ព្រះមានព្រះភាគ ត្រាស់ប្រយោជន៍ដែលដល់ទីបំផុត មួយអន្លើដោយវិបស្សនាដល់ភិក្ខុនោះដែលដឹងយ៉ាងនេះ ដែលឃើញយ៉ាងនេះ ។ បទថា **កាមាសវា** បានដល់ រមែងផុតចាកកាមាសវៈ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងខណៈនៃមគ្គ ដោយបទនេះថា **វិមុច្ចតិ** ។ ទ្រង់សម្តែងខណៈនៃផល ដោយបទ

នេះថា **វិមុត្តស្មឹ** ។ ចិត្តក្នុងខណៈនៃមគ្គ ឈ្មោះថា រមែងរួចផុត ចិត្តក្នុងខណៈនៃផល ឈ្មោះថា រួចផុតហើយ ។ ទ្រង់សម្តែងបច្ចវេក្ខណញ្ញាណដោយបទនេះថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ** ។ ទ្រង់សម្តែងភូមិនៃព្រះខីណាស្រពនោះ ដោយបទថា **ខីណា ជាតិ** ជាដើម ។ ព្រះខីណាស្រពនោះ កាលពិចារណាដោយញាណនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយដូច្នេះជាដើម ។ បទថា **វុសិតំ** បានដល់ នៅហើយ នៅចប់ហើយ គឺធ្វើហើយ ប្រព្រឹត្តហើយ អធិប្បាយថា សម្រេចកិច្ចហើយ ។ បទថា **ព្រហ្ម-ចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ព្រះសេក្ខបុគ្គល ៧ ពួក និងកល្យាណបុថុជ្ជន ឈ្មោះថា រមែងនៅប្រព្រឹត្តព្រហ្មចរិយៈ ព្រះខីណាស្រពឈ្មោះថា មានការនៅប្រព្រឹត្តព្រហ្មចរិយៈចប់ហើយ ព្រោះហេតុនោះ ព្រះខីណាស្រពនោះ ពិចារណាការនៅប្រព្រឹត្តព្រហ្មចរិយៈរបស់ខ្លួន រមែងដឹងច្បាស់ថា ព្រហ្មចរិយៈ អញនៅចប់ហើយ ។ បទថា **កតំ ករណីយំ** អធិប្បាយថា កិច្ច ១៦ យ៉ាង ដោយអំណាចបរិញ្ញាកិច្ច បហានកិច្ច សច្ឆិ-កិរិយាកិច្ច និងភាវនាកិច្ចដោយមគ្គទាំង ៤ ក្នុងសច្ចៈ ៤ បានធ្វើស្រេចហើយ ។ ពិតហើយ កល្យាណបុថុជ្ជនជាដើម កំពុងធ្វើកិច្ចនោះ តែព្រះខីណាស្រព ធ្វើកិច្ចនោះស្រេចហើយ ព្រោះហេតុនោះ កាលព្រះខីណាស្រពពិចារណាកិច្ចរបស់ខ្លួន រមែងជ្រាបច្បាស់ថា សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ ។ បទថា **នាបរំ ឥត្ថត្តាយ** សេចក្តីថា ព្រះខីណាស្រពរមែងដឹងច្បាស់ថា ឥឡូវនេះ កិច្ចដោយការចម្រើនមគ្គដទៃទៀត ដើម្បីភាព

យ៉ាងនេះ គឺដើម្បីកិច្ច ១៦ ឬដើម្បីការអស់កិលេស រមែងមិនមាន ។

[ ១៣៦ ] ក្នុងនិទ្ទេសនៃបុគ្គលប្រកបដោយរាគៈជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អប្បហីនោ** សេចក្តីថា បុគ្គលប្រហាររាគៈមិនទាន់បានដោយវិក្ខម្ភនប្បហាន ឬដោយតទង្គប្បហាន ឬដោយសមុច្ឆេទប្បហាន ។

[ ១៣៧ ] ក្នុងនិទ្ទេសនៃបុគ្គល ជាអ្នកបានចេតោសមថៈជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **លាភី** បានដល់ បុគ្គលបាន គឺបានចំពោះហើយតាំងនៅ ។ បទថា **អជ្ឈត្តំ ចេតោសមថស្ស** បានដល់ ចេតោសមថៈដែលកើតឡើងក្នុងចិត្តរបស់ខ្លួន ពោល គឺប្រព្រឹត្តទៅខាងក្នុងរបស់ខ្លួនឯង ។ បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** សេចក្តីថា វិបស្សនាដែលប្រព្រឹត្តទៅ ដោយអំណាចនៃអនិច្ចលក្ខណៈជាដើម ក្នុងធម្មក្ខន្ធទាំងឡាយដែលបានដល់អធិប្បញ្ញា ។ បទថា **រូបសហគតានំ** បានដល់ រូបាវចរសមាបត្តិ ដែលមានរូបនិមិត្ត ជាអារម្មណ៍ ។ បទថា **អរូបសហគតានំ** បានដល់ អរូបាវចរសមាបត្តិ ដែលមិនមានរូបនិមិត្ត ជាអារម្មណ៍ ។ ក្នុងអធិការនេះ គប្បីជ្រាបថា បុគ្គលពួកទី ១ បានដល់ បុថុជ្ជនដែលបានសមាបត្តិ ៨ បុគ្គលពួកទី ២ បានដល់ ព្រះអរិយសាវកជាសុក្ខវិបស្សកៈ បុគ្គលពួកទី ៣ បានដល់ អរិយសាវកដែលបានសមាបត្តិ ៨ បុគ្គលពួកទី ៤ បានដល់ លោកិយបុថុជ្ជន ។

[ ១៣៨ ] ក្នុងនិទ្ទេសនៃបុគ្គលទៅបណ្តោយតាមខ្សែទឹកជាដើម គប្បី

ជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អនុសោតគាមី** គប្បីជ្រាបថា បាន ដល់ បុថុជ្ជនដែលទៅតាមក្រសែ គឺវដ្ដៈ ដែលលិចចុះក្នុងក្រសែ គឺវដ្ដៈ ។ បទថា **បដិសោតគាមី** បានដល់ បុគ្គលទៅច្រាសក្រសែ ។ ពាក្យនេះ ជាឈ្មោះរបស់លោកដែលមិនទៅតាមក្រសែ តែទៅច្រាសក្រសែ ។ បទថា **ចាបញ្ច កម្មំ ន ករោតិ** បានដល់ រមែងមិនធ្វើនូវការឈានកន្លងបញ្ញត្តិ ។ បទថា **សហាបិ ទុក្ខេន សហាបិ ទោមនស្សេន** សេចក្ដីថា កាលកិលេស ដែលជាបរិយុដ្ឋាននៅមាន មួយអន្លើដោយទុក្ខទោមនស្ស ដែលកើតឡើង ហើយ ។ បទថា **បរិបុណ្ណំ** បានដល់ បណ្ដាសិក្ខាទាំង ៣ មិនខ្វះខាត សូម្បីតែ ១ ។ បទថា **បរិសុទ្ធំ** បានដល់ មិនមានឧបក្កិលេស ។ បទថា **ព្រហ្មចរិយំ** បានដល់ ការប្រព្រឹត្តធម៌ដ៏ប្រសើរបំផុត ។ ព្រះមានព្រះភាគ ត្រាស់ព្រះសោតាបន្ន និងព្រះសកទាគាមីដោយវារៈនេះ ។ សួរថា បុគ្គល ទាំងនេះ យំប្រព្រឹត្តព្រហ្មចរិយធម៌ឬ ឆ្លើយថា ត្រូវហើយ បុគ្គលទាំងនេះ ឈ្មោះថា យំ ដោយការយំព្រោះកិលេស ក៏នៅប្រព្រឹត្តព្រហ្មចរិយៈ ។ ភិក្ខុ បុថុជ្ជនដែលសម្បូរដោយសីល ព្រះមានព្រះភាគទ្រង់សង្គ្រោះចូលក្នុងបុគ្គល ប្រភេទនេះ ។

បទថា **ឋិតត្តោ** បានដល់ បុគ្គលមានការតម្កល់ខ្លួនបានជាសភាវៈ ។ ព្រះអនាគាមី ឈ្មោះថា តម្កល់ខ្លួនបានជាសភាវៈ ព្រោះលោកជាអ្នកមានចិត្ត មិនញាប់ញ័រ ដោយកាមរាគៈ និងព្យាបាទ និងជាបុគ្គលមិនវិលត្រឡប់មក អំពីលោកនោះជាធម្មតា ។ បទថា **តិណ្ណោ** បានដល់ បុគ្គលឆ្លងក្រសែនៃ

តណ្ហាបានហើយ ។ បទថា **ឋារង្គតោ** បានដល់ បុគ្គលដល់នូវត្រើយ គឺព្រះនិព្វាន ។ បទថា **ថលេ តិដ្ឋតិ** បានដល់ ឈរលើគោក គឺអរហត្តផលសមាបត្តិ ។ បទថា **ចេតោវិមុត្តឹ** បានដល់ ផលសមាធិ ។ បទថា **បញ្ញាវិមុត្តឹ** បានដល់ ផលញ្ញាណ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា ព្រះខីណាស្រពនេះ ដែលឆ្លងក្រសែតណ្ហាទៅហើយដល់ត្រើយ គឺព្រះនិព្វាន ឈរលើគោក គឺអរហត្តផលសមាបត្តិ ហៅថា ជាព្រាហ្មណ៍ ។ ព្រះខីណាស្រពនេះឈ្មោះថាជាព្រាហ្មណ៍ ព្រោះលោកជាអ្នកមានបាបបន្សាត់ហើយ ។

[ ១៣៩ ] ក្នុងនិទ្ទេសនៃបុគ្គល ជាអ្នកចេះដឹងតិចជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ បទថា **អប្បកំ សុតំ ហោតិ** បានដល់ សុតៈ គឺការស្តាប់ ការរៀនក្នុងនវង្គសត្ថុសាសនៈ មានតិចតួច គឺមានបន្តិចបន្តួចប៉ុណ្ណោះ ។ បទថា **ន អត្ថមញ្ញាយ ន ធម្មញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ** សេចក្ដីថា ជាអ្នកចេះបាលី និងអដ្ឋកថា ហើយមិនជាអ្នកបដិបត្តិធម៌ដែលជាបដិបទាខាងដើម ដែលសមគួរដល់លោកុត្តរធម៌ ។ ក្នុងទីទាំងពួងបណ្ឌិតគប្បីជ្រាបអត្ថដោយន័យនេះ ។

[ ១៤០ ] ក្នុងនិទ្ទេសនៃបុគ្គលជាសមណៈមិនកម្រើកជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សមណមចលោ** កែជា **សមណអចលោ** ។ **ម** អក្ខរៈ ធ្វើនូវការភ្ជាប់បទ អធិប្បាយថា បុគ្គលជាសមណៈ ជាអ្នកមិនញាប់ញ័រ គឺជាសមណៈមាំទាំ ។ បទថា **អយំ វុច្ចតិ** សេចក្ដីថា ព្រះសោតាបន្នទេះ ហៅថា សមណៈមិនញាប់ញ័រ ព្រោះជាអ្នកមាំទាំដោយសទ្ធា

*ដែលជាឫសគល់ក្នុងសាសនា ចំណែកព្រះសកទាគាមីទ្រង់ត្រាស់ថា បុគ្គលជាសមណៈដូចផ្កាឈូកក្រហម ព្រោះកិលេសជាគ្រឿងត្រេកអរនៅមាន ។ មានពាក្យអធិប្បាយថា ឈ្មោះថា អត្ថនៃ* **បទុម** *សព្ទ ក្នុងបទថា* **សមណបទុមោ** *នេះ មានសេចក្តីត្រេកអរ ជាអត្ថ ។ ព្រះអនាគាមី ព្រះមានព្រះភាគត្រាស់ថា បុគ្គលជាសមណៈផ្កាឈូក-ស ព្រោះមិនមានកិលេសដែលជាគ្រឿងត្រេកអរ ពោល គឺកាមរាគៈ អធិប្បាយថា ឈ្មោះថា អត្ថនៃ* **បុណ្ឌរីក** *សព្ទ ក្នុងបទថា* **សមណបុណ្ឌរីកោ** *នេះ មានការស្អាត ជាអត្ថ ។ ព្រះខីណាស្រពទ្រង់ត្រាស់ថា ឈ្មោះថា បុគ្គលជាសមណៈចម្រើនដោយសុខក្នុងពួកសមណៈ ព្រោះជាអ្នកមិនមានកិលេសទាំងឡាយ ដែលធ្វើនូវការរឹងត្អឹង ។ ព្រះខីណាស្រពនេះ ឈ្មោះថា ជាសមណៈសុខុមាលដោយពិត ព្រោះអត្ថថា ជាអ្នកមានទុក្ខតិច ដូច្នេះ ។*

## អដ្ឋកថាចតុក្កនិទ្ទេស ចប់

# អភិធម្មបិដក

## បញ្ចកនិទ្ទេស

[ ១៤១ ] បណ្តាបុគ្គលទាំងនោះ បុគ្គលណាប្រព្រឹត្តល្មើសផង ជាអ្នកមានសេចក្តីក្តៅក្រហាយផង មិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញា-វិមុត្តិនោះ ដែលជាហេតុ ធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើង ហើយរលត់ទៅវិញ មិនមានសេសសល់ផង បុគ្គលនោះ គួរឲ្យគេស្តីបានយ៉ាងនេះថា លោកមានអាយុ មានអាសវៈទាំងឡាយដែលកើតអំពីការប្រព្រឹត្តល្មើស កើតមាន ទាំងមានអាសវៈទាំងឡាយដែលកើតអំពីសេចក្តីក្តៅក្រហាយ ចម្រើនដុះដាល ( ព្រោះហេតុនោះ ) សូមលោកមានអាយុ លះបង់នូវពួកអាសវៈដែលកើតអំពីការប្រព្រឹត្តល្មើស បន្ទោបង់នូវពួកអាសវៈ ដែលកើតអំពីសេចក្តីក្តៅក្រហាយចោលចេញហើយ ចម្រើននូវចិត្ត និងបញ្ញាតទៅ កាលបើយ៉ាងនេះ លោកមានអាយុនឹងជាអ្នកស្មើដោយបុគ្គលទី ៥ ឯណោះ ។ បណ្តាបុគ្គលទាំងនោះ បុគ្គលណាប្រព្រឹត្តល្មើស តែជាអ្នកមិនមានសេចក្តីក្តៅក្រហាយ ទាំងមិនដឹងតាមពិតនូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុ ធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើងហើយ រលត់ទៅវិញមិនមានសេសសល់ បុគ្គលនោះគួរឲ្យគេស្តីបានយ៉ាងនេះថា លោកមានអាយុ មានអាសវៈទាំងឡាយ ដែលកើតអំពីការប្រព្រឹត្តល្មើស កើតមាន តែមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ មិនចម្រើនដុះដាលទេ ( ព្រោះហេតុនោះ ) សូមលោកមានអាយុ លះបង់ពួកអាសវៈ ដែលកើតអំពីការ

ប្រព្រឹត្តល្មើសចេញ ហើយចម្រើននូវចិត្ត និងបញ្ញាតទៅ កាលបើយ៉ាងនេះ លោកមានអាយុ នឹងជាអ្នកស្មើដោយបុគ្គលទី ៥ ឯណោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមិនប្រព្រឹត្តល្មើសទេ តែមានសេចក្ដីក្ដៅក្រហាយ ទាំងមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះ ដែលកើតឡើងហើយ រលត់ទៅវិញមិនមានសេសសល់ បុគ្គលនោះ គួរឲ្យគេស្ដីបានយ៉ាងនេះថា លោកមានអាយុ មានអាសវៈទាំងឡាយ ដែលកើតអំពីការប្រព្រឹត្តល្មើស មិនកើតឡើងទេ តែមានអាសវៈទាំងឡាយដែលកើតអំពីសេចក្ដីក្ដៅក្រហាយចម្រើនដុះដាល ( ព្រោះហេតុនោះ ) សូមលោកមានអាយុ បន្ទោបង់ពួកអាសវៈ ដែលកើតអំពីសេចក្ដីក្ដៅក្រហាយចោលចេញ ហើយចម្រើននូវចិត្ត និងបញ្ញាតទៅ កាលបើយ៉ាងនេះ លោកមានអាយុនឹងជាអ្នកស្មើដោយបុគ្គលទី ៥ ឯណោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមិនប្រព្រឹត្តល្មើស មិនមានសេចក្ដីក្ដៅក្រហាយទេ តែមិនដឹងច្បាស់តាមពិតនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ ដែលជាហេតុ ធ្វើឲ្យពួកអកុសលធម៌ដ៏លាមកទាំងនោះ របស់បុគ្គលនោះដែលកើតឡើងហើយ រលត់ទៅវិញមិនមានសេសសល់ បុគ្គលនោះ គួរឲ្យគេស្ដីបានយ៉ាងនេះថា លោកមានអាយុ មានអាសវៈទាំងឡាយ ដែលកើតអំពីការប្រព្រឹត្តល្មើស មិនកើតមាន ទាំងមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្ដីក្ដៅក្រហាយក៏មិនចម្រើនដុះដាលឡើយ ( ព្រោះហេតុនោះ ) សូមលោកមានអាយុ ចម្រើននូវចិត្ត និងបញ្ញាតទៅ កាលបើយ៉ាង

នេះ លោកមានអាយុនឹងជាអ្នកស្មើដោយបុគ្គលទី ៥ ឯណោះ ។ នេះបុគ្គល ៤ ពួក ដែលបុគ្គលជាទី ៥ ឯណោះ កាលទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយតាមលំដាប់ ។

[ ១៤២ ] បុគ្គលឲ្យហើយត្រឡប់មើលងាយវិញ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជ-បរិក្ខារដល់បុគ្គលណា បុគ្គលអ្នកឲ្យនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថាអាត្មាអញឲ្យ ឯបុគ្គលនេះទទួលយក លុះឲ្យហើយត្រឡប់មើលងាយបុគ្គលនោះវិញ បុគ្គលឲ្យហើយត្រឡប់មើលងាយវិញ យ៉ាងនេះឯង ។ បុគ្គលមើលងាយព្រោះការនៅរួម តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ នៅរួមជាមួយនឹងបុគ្គលណា អស់ ២ ឆ្នាំក្តី អស់ ៣ ឆ្នាំក្តី ក៏មើលងាយបុគ្គលនោះព្រោះការនៅរួម បុគ្គលមើលងាយព្រោះការនៅរួម យ៉ាងនេះឯង ។ បុគ្គលមានមុខជឿងាយ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ កាលបើមានគេពោលគុណក្តី ទោសក្តីរបស់បុគ្គលដទៃ ក៏ចុះចិត្តជឿភ្លាមមួយរំពេច បុគ្គលមានមុខជឿងាយ យ៉ាងនេះឯង ។ បុគ្គលស៊ែះពក្លែះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មានជំនឿផ្តេសផ្តាស មានការសេពគប់ផ្តេសផ្តាស មានសេចក្តីស្រឡាញ់ផ្តេសផ្តាស មានសេចក្តីជ្រះថ្លាផ្តេសផ្តាស បុគ្គលស៊ែះពក្លែះ យ៉ាងនេះឯង ។ បុគ្គលល្ងង់ខ្លៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនដឹងនូវធម៌ជាកុសល និងអកុសល មិនដឹងនូវធម៌មានទោស និងធម៌មិនមានទោស មិនដឹងនូវធម៌ថោកទាប និងធម៌ខ្ពង់ខ្ពស់ មិនដឹងនូវធម៌មានចំណែក

ប្រៀបដោយវត្ថុមានពណ៌ខ្មៅ និងពណ៌ស បុគ្គលល្វង់ខ្មៅ យ៉ាងនេះឯង ។

[ ១៤៣ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៥ ពួកប្រៀបដោយទាហាន តើដូចម្តេច ។ ទាហានមាន ៥ ពួក គឺទាហានខ្លះ ក្នុងលោកនេះ គ្រាន់តែឃើញនូវចុងនៃធូលី ( ដែលហុយឡើង ) ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម ទាហានខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង នេះទាហានទី ១ រមែងមានក្នុងលោកនេះ ។ មួយទៀត ទាហានខ្លះក្នុងលោកនេះ អត់ទ្រាំនូវចុងនៃធូលីបាន តែដល់ឃើញចុងទង់ជ័យ ( នៃបច្ចាមិត្ត ) ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម ទាហានខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង នេះទាហានទី ២ រមែងមានក្នុងលោក ។ មួយទៀត ទាហានខ្លះ ក្នុងលោកនេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ ( នៃបច្ចាមិត្ត ) បានដែរ តែលុះឮសំឡេងហ៊ោក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម ទាហានខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង នេះទាហានទី ៣ រមែងមានក្នុងលោក ។ មួយទៀត ទាហានខ្លះ ក្នុងលោកនេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោបានដែរ តែត្រូវគេបៀតបៀន ក៏វិនាសស្លាប់ខ្ទួន ព្រោះការប្រហារបន្តិចបន្តួច ទាហានខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង នេះទាហានទី ៤ រមែងមានក្នុងលោក ។ មួយទៀត ទាហានខ្លះក្នុងលោកនេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោ អត់ទ្រាំនូវការប្រហារបាន ទាហាននោះ ឈ្នះសង្គ្រាមនោះ មាន

សង្គ្រាមឈ្នះស្រឡះហើយ ក៏នៅគ្រប់គ្រងក្បាលសង្គ្រាមនោះឯង ទាហានខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង នេះទាហានទី ៥ រមែងមានក្នុងលោក ។ នេះទាហាន ៥ ពួក រមែងមានក្នុងលោក ។

[ ១៨៤ ] បុគ្គល ៥ ពួក ប្រៀបដោយទាហាននេះ រមែងមានក្នុងពួកភិក្ខុក៏យ៉ាងនោះឯង ។ ភិក្ខុ ៥ ពួក តើដូចម្តេច ។ ភិក្ខុខ្លះ ក្នុងសាសនានេះ គ្រាន់តែឃើញចុងនៃធូលី ក៏រួញរាថយក្រោយ មិនតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ ។ ចុះអ្វីជាចុងនៃធូលីរបស់ភិក្ខុនោះ ។ ភិក្ខុក្នុងសាសនានេះ បានឮថា ក្នុងស្រុកក្តី ក្នុងនិគមក្តីឯណោះ មានស្រី ឬកុមារីមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌នៃសរីរៈដ៏ល្អក្រៃលែង ភិក្ខុនោះ លុះបានឮដំណឹងនោះហើយ ក៏រួញរាថយក្រោយ មិនតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ នេះឈ្មោះថាចុងនៃធូលីរបស់ភិក្ខុនោះ ។ ទាហាននោះ ឃើញនូវចុងនៃធូលីហើយ ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលខ្លះ ក្នុងលោកនេះ មានសភាពយ៉ាងនេះឯង ។ នេះបុគ្គលទី ១ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។ មួយទៀត ភិក្ខុខ្លះ ក្នុងសាសនានេះ អត់ទ្រាំនូវចុងនៃធូលីបាន តែលុះឃើញនូវចុងនៃទង់ជ័យហើយ ក៏រួញរាថយក្រោយ មិនហ៊ាន

តទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ ។ ចុះអ្វីជាចុងនៃទង់ជ័យរបស់ភិក្ខុនោះ ។ ភិក្ខុក្នុងសាសនានេះ មិនបានឮថា ក្នុងស្រុកក្តី ក្នុងនិគមក្តីឯណោះ មានស្រី ឬកុមារីមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌នៃសរីរៈដ៏ល្អក្រៃលែង ដូច្នេះទេ តែបានឃើញដោយខ្លួនឯងនូវស្រី ឬកុមារីដែលមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌នៃសរីរៈដ៏ល្អក្រៃលែង ភិក្ខុនោះ លុះបានឃើញនូវស្រី ឬកុមារីនោះហើយ ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំងក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ នេះឈ្មោះថា ចុងនៃទង់ជ័យរបស់ភិក្ខុនោះ ។ ទាហាននោះ អត់ទ្រាំនូវចុងនៃធូលីបានដែរ តែលុះបានឃើញនូវចុងនៃទង់ជ័យ ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលខ្លះ ក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង ។ នេះបុគ្គលទី ២ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។ មួយទៀត ភិក្ខុខ្លះ ក្នុងសាសនានេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យបានដែរ តែលុះបានឮសំឡេងហ៊ោ ( នៃបច្ចាមិត្ត ) ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ ។ ចុះអ្វីជាសំឡេងហ៊ោ របស់

ភិក្ខុនោះ ។ មាតុគ្រាម ចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយសើចល្បួង និយាយចែចង់ សើចខ្លាំង ចំអកចំអន់ ភិក្ខុនោះ កាលបើត្រូវមាតុគ្រាមសើចល្បួង និយាយចែចង់ សើចខ្លាំង ចំអកចំអន់ ក៏រួញរាថយក្រោយ មិនទប់ទល់ មិនអាចបន្តនូវព្រហ្មចរិយធម៌ ធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំង ក្នុងសិក្ខា លះបង់នូវសិក្ខា វិលត្រឡប់មកកាន់ភេទថោកទាបវិញ នេះឈ្មោះថា សំឡេងហ៊ោរបស់ភិក្ខុនោះ ។ ទាហាននោះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យបានដែរ តែលុះបានឮសំឡេងហ៊ោ ក៏រួញរាថយក្រោយ មិនហ៊ានតទល់ មិនអាចចូលកាន់សង្គ្រាម មានឧបមាយ៉ាងណាមិញ បុគ្គលនេះក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលខ្លះ ក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង ។ នេះបុគ្គលទី ៣ ប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។ មួយទៀត ភិក្ខុខ្លះ ក្នុងសាសនានេះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោបានដែរ តែត្រូវគេបៀតបៀនក៏វិនាសស្លាប់ខ្លួន ព្រោះការប្រហារ ( របស់បច្ចាមិត្ត ) ។ ចុះអ្វីជាការប្រហាររបស់ភិក្ខុនោះ ។ មាតុគ្រាមចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយអង្គុយកៀកកើយ ដេកជិត ឱបរឹត ភិក្ខុនោះ កាលបើត្រូវមាតុគ្រាមអង្គុយកៀកកើយ ដេកជិត ឱបរឹតហើយ ក៏មិនបានលះបង់នូវសិក្ខា មិនបានធ្វើឲ្យប្រាកដនូវភាពជាអ្នកថយកម្លាំងទេ ហើយសេពនូវមេថុនធម្ម ( នឹងមាតុគ្រាមនោះ ) នេះជាការប្រហាររបស់

ភិក្ខុនោះ ។ ទាហាននោះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហៅ ( នៃបច្ចាមិត្ត ) បានដែរ តែត្រូវគេបៀតបៀន ក៏វិនាសស្លាប់ខ្លួនក្នុងសង្គ្រាម មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បុគ្គលខ្លះ ក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង ។ នេះបុគ្គលទី ៤ ប្រៀបដោយទាហាន រមែងមាន ក្នុងពួកភិក្ខុ ។ មួយទៀត ភិក្ខុខ្លះ ក្នុងសាសនា អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហៅ អត់ទ្រាំនូវការប្រហារបាន ភិក្ខុនោះ ឈ្នះនូវសង្គ្រាមនោះ មានសង្គ្រាមឈ្នះស្រឡះហើយ ក៏នៅគ្រប់គ្រងក្បាលសង្គ្រាមជ័យនោះឯង ។ ចុះអ្វីជាការឈ្នះសង្គ្រាមរបស់ភិក្ខុនោះ ។ មាតុគ្រាមចូលទៅរកភិក្ខុក្នុងសាសនានេះ ដែលនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ហើយអង្គុយកៀកកើយ ដេកជិត ឱបរឹត ។ ភិក្ខុនោះកាលបើត្រូវមាតុគ្រាមអង្គុយកៀកកើយ ដេកជិត ឱបរឹតហើយ ក៏ប្រាទចេញ ដោះខ្លួនចៀសចេញទៅតាមប្រាថ្នា ។ ភិក្ខុនោះ គប់រកនូវទីសេនាសនៈស្ងាត់ គឺព្រៃគល់ឈើ ភ្នំ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងអង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ ផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះលះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់ព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនប្រកបដោយព្យាបាទ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ជម្រះចិត្តឲ្យ

ស្អាត ចាកព្យាបាទជាគ្រឿងប្រទូស្ត លះបង់ថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ មានសេចក្តីសម្គាល់នូវពន្លឺ មានសតិ និងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មានចិត្តមិនរវើរវាយ មានចិត្តស្ងប់ក្នុងសន្តានជម្រះចិត្តឲ្យស្អាត ចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា មានវិចិកិច្ឆាកន្លងបង់ហើយ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាត ចាកវិចិកិច្ឆា ។ ភិក្ខុនោះ លះបង់នីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម្មជាតធ្វើបញ្ញា ឲ្យមានកម្លាំងថយបានហើយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ បានដល់នូវបឋមជ្ឈានប្រកបដោយវិតក្ក និងវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់ហើយសម្រេចសម្រាន្តនៅ លុះរម្ងាប់នូវវិតក្ក និងវិចារអស់ហើយ ក៏បានដល់នូវទុតិយជ្ឈាន នូវតតិយជ្ឈាន នូវចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅ ។ ភិក្ខុនោះ កាលបើចិត្តតាំងនៅមាំ បរិសុទ្ធផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្មជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ ក៏បង្អោនចិត្តទៅដើម្បីញាណ ជាទីអស់ទៅនៃអាសវៈទាំងឡាយ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតទុក្ខដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះអាសវៈ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះធម៌រម្ងត់អាសវៈ

ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងាប់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈ ។ កាលបើចិត្តរួចផុតស្រឡះហើយ សេចក្តីដឹងថា ចិត្តរួចផុតស្រឡះហើយ ក៏កើតមានប្រាកដ ភិក្ខុនោះដឹងច្បាស់ថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញប្រព្រឹត្តហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គ-ភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ នេះឈ្មោះថា ការឈ្នះសង្គ្រាមរបស់ភិក្ខុនោះ ។ ទាហាននោះ អត់ទ្រាំនូវចុងនៃធូលី អត់ទ្រាំនូវចុងនៃទង់ជ័យ អត់ទ្រាំនូវសំឡេងហ៊ោ អត់ទ្រាំនូវការប្រហារ ( របស់បច្ចាមិត្ត ) បាន ទាហាននោះ បានឈ្នះនូវសង្គ្រាមនោះ មានសង្គ្រាមឈ្នះស្រឡះហើយ ក៏នៅគ្រប់គ្រងក្បាលសង្គ្រាមនោះឯង មានឧបមាយ៉ាងណាមិញ បុគ្គលនេះ ក៏មានឧបមេយ្យ យ៉ាងនោះដែរ ។ បុគ្គលក្នុងសាសនានេះ មានសភាពយ៉ាងនេះឯង នេះបុគ្គលទី ៥ ប្រៀបដោយទាហាន រមែងមានក្នុងភិក្ខុ ។ នេះបុគ្គល ៥ ពួកប្រៀបដោយទាហាន រមែងមានក្នុងពួកភិក្ខុ ។

[ ១៤៥ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តបិណ្ឌ-បាតិកធុតង្គ តើដូចម្តេច ។ ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ព្រោះភាពនៃខ្លួនជាបុគ្គលល្ងង់ ជាបុគ្គលវង្វេង ១ ភិក្ខុមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ១ ភិក្ខុប្រព្រឹត្ត

បិណ្ឌបាតិកធុតង្គ ព្រោះការច្អួត និងការវេរីវាយចិត្ត ១ ភិក្ខុ ប្រព្រឹត្តបិណ្ឌ-បាតិកធុតង្គដោយគិតថា បិណ្ឌបាតិកវត្ត ជាកិច្ចដែលព្រះពុទ្ធ និងពុទ្ធសាវក ទាំងឡាយសរសើរហើយ ១ មួយវិញទៀត ភិក្ខុអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យសេចក្តី ប្រតិបត្តិជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ១ ។ បណ្តាភិក្ខុ ទាំងនោះ បិណ្ឌបាតិកភិក្ខុណា អាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តី សន្តោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យសេចក្តីប្រតិបត្តិជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ បណ្តាបិណ្ឌបាតិកភិក្ខុទាំង ៥ ពួកនេះ ភិក្ខុនេះ លើសលុបផង វិសេសវិសាលផង ជាប្រធានផង ឧត្តុង្គឧត្តមផង ប្រសើរជាងគេផង ។ ទឹកដោះស្រស់កើតអំពីមេគោ ទឹកដោះជូរកើតអំពីទឹក ដោះស្រស់ ទឹកដោះខាប់កើតអំពីទឹកដោះជូរ ទឹកដោះរាវកើតអំពីទឹកដោះខាប់ ទឹកដោះថ្លាកើតអំពីទឹកដោះរាវ បណ្តាទឹកដោះទាំងនោះ ទឹកដោះថ្លាប្រាកដជា ប្រសើរជាង យ៉ាងណាមិញ បិណ្ឌបាតិកភិក្ខុណា ដែលអាស្រ័យសេចក្តី ប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យ ការប្រតិបត្តិ ជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ បណ្តា បិណ្ឌបាតិកភិក្ខុទាំង ៥ ពួកនេះ ភិក្ខុនេះលើសលុបផង វិសេសវិសាលផង ជាប្រធានផង ឧត្តុង្គឧត្តមផង ប្រសើរជាងគេផង ក៏យ៉ាងនោះដែរ ។ នេះ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ។

[ ១៨៦ ] បណ្តាបុគ្គលទាំងនោះ បុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តខលុបច្ឆា-

ភត្តិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តឯកាសនិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តរុក្ខមូលិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តអព្ភោកាសិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តយថាសន្ថតិកធុតង្គ តើដូចម្តេច ។ បណ្តាបុគ្គលទាំងនោះ បុគ្គល ៥ ពួកជាអ្នកប្រព្រឹត្តសោសានិកធុតង្គ តើដូចម្តេច ។ ភិក្ខុប្រព្រឹត្តសោសានិកធុតង្គ ព្រោះភាពនៃខ្លួនជាបុគ្គលល្ងង់ ជាបុគ្គលវង្វេង ១ ភិក្ខុមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកប្រព្រឹត្តសោសានិកធុតង្គ ១ ភិក្ខុប្រព្រឹត្តសោសានិកធុតង្គ ព្រោះការឆ្កួតចិត្ត និងការរវើរវាយចិត្ត ១ ភិក្ខុប្រព្រឹត្តសោសានិកធុតង្គដោយគិតថា សោសានិកធុតង្គនេះ ជាកិច្ចដែលព្រះពុទ្ធ និងពុទ្ធសាវកទាំងឡាយសរសើរហើយ ១ មួយវិញទៀត ភិក្ខុអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យសេចក្តីប្រតិបត្តិជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តសោសានិកធុតង្គ ១ ។ បណ្តាភិក្ខុទាំងនោះ សោសានិកភិក្ខុណាអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យសេចក្តីប្រតិបត្តិ ជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តសោសានិកធុតង្គ បណ្តាសោសានិកភិក្ខុទាំង ៥ ពួកនេះ ភិក្ខុនេះលើសលុបផង វិសេសវិសាលផង ជាប្រធានផង ឧត្តុង្គឧត្តមផង ប្រសើរជាងគេផង ។ ទឹកដោះស្រស់កើតអំពីមេគោ ទឹក

ដោះជូរកើតអំពីទឹកដោះស្រស់ ទឹកដោះខាប់កើតអំពីទឹកដោះជូរ ទឹកដោះរាវកើតអំពីទឹកដោះខាប់ ទឹកដោះថ្លាកើតអំពីទឹកដោះរាវ បណ្ដាទឹកដោះទាំងនោះ ទឹកដោះថ្លាប្រាកដជាប្រសើរជាង យ៉ាងណាមិញ សោសានិកភិក្ខុណា ដែលអាស្រ័យសេចក្ដីប្រាថ្នាតិច អាស្រ័យសេចក្ដីសន្ដោស អាស្រ័យការជុសខាត់ចិត្ត អាស្រ័យការប្រតិបត្តិជាប្រយោជន៍ ហើយជាអ្នកប្រព្រឹត្តសោសានិកធុតង្គ បណ្ដាសោសានិកភិក្ខុទាំង ៥ ពួកនេះ ភិក្ខុនេះ លើសលុបផង វិសេសវិសាលផង ជាប្រធានផង ឧត្ដុង្គឧត្ដមផង ប្រសើរជាងគេផង ក៏យ៉ាងនោះដែរ ។ នេះបុគ្គល ៥ ពួក ជាអ្នកប្រព្រឹត្តសោសានិកធុតង្គ ។

បញ្ចកនិទ្ទេស ចប់

# អដ្ឋកថា

## បញ្ចកនិទ្ទេស

[ ១៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ចកនិទ្ទេសដូចតទៅនេះ បទថា **តត្រ** បានដល់ បណ្តាបុគ្គលទាំងនោះ ដែលទ្រង់លើកឡើងសម្តែងខាងដើម ដោយន័យថា **អារភតិ ច វិប្បដិសារី ច ហោតិ** ប្រព្រឹត្តល្មើសផង ជាអ្នកមានសេចក្តីក្តៅក្រហាយផង ដូច្នេះជាដើម ។ បទថា **យ្វាយំ** កាត់បទជា **យោ អយំ** ។ **អារម្ភ** សព្ទ ក្នុងបទថា **អារភតិ** នេះ ប្រព្រឹត្តទៅក្នុងអត្ថថា កម្ម គឺការធ្វើ ១ ក្នុងកិរិយា គឺកិច្ច ១ ក្នុងហឹសនៈ គឺការបៀតបៀន ១ ក្នុងវិរិយៈ គឺសេចក្តីព្យាយាម ១ ក្នុងវិកោបនៈ គឺការទម្លាយ ១ ក្នុងអាបត្តិវីតិក្កម គឺការកន្លងអាបត្តិ ១ ។

ពិតហើយ **អារម្ភ** សព្ទនេះ មកក្នុងអត្ថថា កម្ម ដូចក្នុងប្រយោគជាដើមថា **យំកិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា** ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះសង្ខារជាបច្ច័យ ដូច្នេះ ។

**អារម្ភ** សព្ទនេះ មកក្នុងអត្ថថា កិរិយា ដូចក្នុងប្រយោគជាដើមថា **មហាយញ្ញា មហារម្ភា ន តេ ហោន្តិ មហប្ផលា** ( មហាយញ្ញទាំងឡាយ ) មានការរវល់ច្រើន យញ្ញទាំងនោះ មិនមែនមានផលច្រើនទេ ដូច្នេះ ។

**អារម្ភ** សព្ទនេះ មកក្នុងអត្ថថា **ហឹសន** គឺការបៀតបៀន ដូចក្នុងប្រយោគជាដើមថា **សមណំ គោតមំ ឧទ្ទិស្ស បាណំ អារភន្តិ** ពួកជនតែងសម្លាប់សត្វចំពោះព្រះសមណគោតម ដូច្នេះ ។

**អារព្ភ** សព្ទនេះ មកក្នុងអត្ថថា **វីរិយ** គឺសេចក្តីព្យាយាមដូចក្នុងប្រយោគជាដើមថា **អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ** អ្នកទាំងឡាយចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ដូច្នេះ ។

**អារព្ភ** សព្ទនេះ មកក្នុងអត្ថថា **វិកោបន** គឺការធ្វើឲ្យបែកធ្លាយ ដូចក្នុងប្រយោគជាដើមថា **ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ** ភិក្ខុវៀរស្រឡះចាកការធ្វើពីជគាម និងភូតគាមឲ្យវិនាស ដូច្នេះ ។

**អារព្ភ** សព្ទនេះ មកក្នុងអត្ថថា **អាបត្តិវីតិក្កម** គឺការប្រព្រឹត្តកន្លងអាបត្តិរបស់ភិក្ខុ ដូចក្នុងប្រយោគជាដើមថា **អារភតិ ច វិប្បដិសារី ច ហោតិ** គឺបុគ្គលខ្លះ ប្រព្រឹត្តល្មើស ( ត្រូវអាបត្តិ ) ផង មានសេចក្តីក្តៅក្រហាយផង ព្រោះហេតុនោះ ទើបមានអត្ថក្នុងទីនេះថា ភិក្ខុរមែងត្រូវអាបត្តិដោយអំណាចនៃការប្រព្រឹត្តកន្លងអាបត្តិផង រមែងជាអ្នកក្តៅក្រហាយ ព្រោះការត្រូវអាបត្តិនោះជាបច្ច័យផង ដូច្នេះ ។

បទថា **ចេតោវិមុត្តឹ** បានដល់ ផលសមាធិ ។ បទថា **បញ្ញាវិមុត្តឹ**[១] បានដល់ ផលញាណ ។ បទថា **យថាភូតំ នប្បជានាតិ** បានដល់ រមែងមិនដឹងតាមសេចក្តីពិត ព្រោះភាពដែលខ្លួនមិនទាន់សម្រេចគុណវិសេស ។ បទថា **យត្ថស្ស** បានដល់ ដល់បុគ្គលនោះក្នុងទីណា អធិប្បាយថា អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ដល់បុគ្គលនេះ រមែងរលត់ទៅដោយមិនសេសសល់ ព្រោះដល់នូវឋានៈណា ។

---

១- បទថា ចេតោវិមុត្តឹ និងបញ្ញាវិមុត្តឹនេះ ច្បាប់ឆដ្ឋសង្គាយនា មិនមាន ។

សួរថា អកុសលធម៌ទាំងនោះ ដល់នូវឋានៈណាហើយ ទើបរលត់ទៅដោយមិនសេសសល់ ឆ្លើយថា ដល់នូវឋានៈ គឺអរហត្តមគ្គ ទើបរលត់ទៅដោយឥតសេសសល់ ។

អកុសលធម៌ដ៏លាមករបស់ភិក្ខុដែលសម្រេចអរហត្តផលហើយ ឈ្មោះថា រលត់ឥតសេសសល់ កាលបើភាពយ៉ាងនោះមាន ផលចិត្តប៉ុណ្ណោះគប្បីជ្រាបថា លោកពោលហើយដោយអំណាចកិច្ចនៃមគ្គ ក្នុងទីនេះ ។ បទថា **អារម្ភជា** បានដល់ ដែលកើតអំពីការកន្លងអាបត្តិ ។ បទថា **វិប្បដិសារជា** បានដល់ ដែលកើតអំពីការក្តៅក្រហាយ ។ បទថា **បវឌ្ឍន្តិ** បានដល់ អាសវៈទាំងឡាយរមែងចម្រើនដោយការកើតឡើងរឿយៗ ។ បទថា **សាធុ** មានអត្ថថា សំណូមពរ មានពាក្យអធិប្បាយដូច្នេះថា អាវុសោ កម្មដែលខុសឆ្គង មានប្រមាណប៉ុនណាហ្ន៎ កាលបើភាពយ៉ាងនោះមាន ខ្ញុំសូមអង្វរលោកដ៏មានអាយុ សូមលោកដ៏មានអាយុ លះអាសវៈដែលកើតអំពីការត្រូវអាបត្តិដោយការសម្តែងអាបត្តិរបស់ភិក្ខុដែលគួរសម្តែង ដោយការចេញចាកអាបត្តិរបស់ភិក្ខុ ដែលគួរចេញចាកអាបត្តិ ដោយការធ្វើឲ្យជាក់ច្បាស់នូវអាបត្តិរបស់ភិក្ខុដែលគួរធ្វើឲ្យជាក់ច្បាស់ ហើយបន្ទោបង់នូវអាសវៈទាំងឡាយដែលកើតអំពីការក្តៅក្រហាយ ដោយការពិចារណាដល់ភាវៈដែលខ្លួនតាំងនៅក្នុងចំណែកនៃសេចក្តីបរិសុទ្ធ ហើយញ៉ាំងវិបស្សនាចិត្ត និងវិបស្សនាបញ្ញា ឲ្យចម្រើនចុះ ។

បទថា **អមុនា បញ្ចមេន បុគ្គលេន** បានដល់ ដោយបុគ្គលដែលជា

ព្រះនិព្វានស្រេច ជាគម្រប់ ៥ នោះ ។ បទថា **សមសមោ ភវិស្សតិ** អធិប្បាយថា ជាបុគ្គលដែលព្រះនិព្វានស្រេចគប្បីទូន្មាន យ៉ាងនេះថា នឹងជាបុគ្គលស្មើដោយភាពជាបុគ្គលស្មើគ្នា ដោយលោកុត្តរគុណនោះឯង ។ បទថា **អារភតិ ច វិប្បដិសារី ហោតិ** បានដល់ ត្រូវអាបត្តិ ក៏ដើម្បីសម្តែងអាបត្តិនោះ ទើបស្វែងរកភិក្ខុដែលត្រូវគ្នា ព្រោះហេតុនោះ ទើបលោកមិនជាអ្នកក្តៅក្រហាយ ។

អដ្ឋកថាចារ្យ បានពោលពាក្យអធិប្បាយ ក្នុងអង្គុត្តរនិកាយថា ភិក្ខុនោះរមែងជាអ្នកមិនក្តៅក្រហាយ ព្រោះចេញចាកអាបត្តិបានហើយ ដូច្នេះ ។ បទថា **ន អារភតិ វិប្បដិសារី ហោតិ** បានដល់ មិនត្រូវអាបត្តិ តែព្រោះលោកជាអ្នកមិនឈ្លាសក្នុងវិនយបញ្ញត្តិ ជាអ្នកមានការសម្គាល់អនាបត្តិ ថាជាអាបត្តិ ទើបមានសេចក្តីក្តៅក្រហាយ តែក្នុងអដ្ឋកថាអង្គុត្តរនិកាយ លោកពោលថា ភិក្ខុត្រូវអាបត្តិម្តង ចេញចាកអាបត្តិនោះហើយ ខាងក្រោយ មិនត្រូវអាបត្តិណាមួយក៏ពិត តែភិក្ខុនោះ ក៏មិនអាចផុតចាក ការក្តៅក្រហាយបាន ។

បទថា **ន អារភតិ ន វិប្បដិសារី ហោតិ** សេចក្តីថា មិនត្រូវអាបត្តិផង មិនក្តៅក្រហាយចិត្តផង ។ សួរថា បុគ្គលដែលមិនត្រូវអាបត្តិ និងមិនក្តៅក្រហាយនោះ ដូចម្តេច ឆ្លើយថា បុគ្គលដែលមានសេចក្តីព្យាយាមដែលលះបង់ហើយ អធិប្បាយថា បុគ្គលដែលមានសេចក្តីព្យាយាមលះបង់ហើយនោះ សូម្បីជាអ្នកមានសីលបរិសុទ្ធ រមែងមិនបំពេញបដិបទា ដោយការគិត

ថា ប្រយោជន៍អ្វីរបស់អញ ដោយការបរិនិព្វានក្នុងពុទ្ធកាលនេះ អញនឹងបរិនិព្វានក្នុងសម័យនៃព្រះមេត្តេយ្យសម្មាសម្ពុទ្ធ ក្នុងអនាគតកាល ។ គួរឲ្យឱវាទដល់ភិក្ខុនោះថា អាវុសោ ជាបុគ្គលប្រមាទ នៅដើម្បីប្រយោជន៍អ្វី ឈ្មោះថា គតិរបស់បុថុជ្ជន ជារបស់មិនទៀងទាត់ អាវុសោគប្បីបាន ឬមិនបានជួបព្រះមេត្តេយ្យសម្ពុទ្ធ ( ក៏ដឹងមិនបាន ) ព្រោះហេតុនោះ ចូរលោកចម្រើនវិបស្សនាដើម្បីអរហត្តចុះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

[ ១៤២ ] ក្នុងនិទ្ទេសនៃបុគ្គលឲ្យហើយ ត្រឡប់មើលងាយវិញជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ភិក្ខុមួយរូប មានបុណ្យច្រើន រមែងជាអ្នកមានប្រក្រតី បាននូវបច្ច័យ ៤ លោកបានបច្ច័យ ៤ មានចីវរជាដើមហើយ រមែងសួរដោយអើពើជាមួយនឹងភិក្ខុដទៃដែលមានបុណ្យតិច ។ ភិក្ខុអ្នកមានបុណ្យតិចនោះ កាលភិក្ខុមានបុណ្យច្រើនសួរដោយអើពើរឿយៗ ទើបទទួលយកបច្ច័យទាំងឡាយ មានចីវរជាដើម ។ តមក ភិក្ខុអ្នកមានបុណ្យច្រើនក្រោធនឹងភិក្ខុអ្នកមានបុណ្យតិចនោះបន្តិចបន្តួច បំណាងឲ្យភិក្ខុនោះខ្មាសអៀនទើបពោលថា ភិក្ខុនេះ មិនបានបច្ច័យទាំងឡាយ មានចីវរជាដើមតាមធម្មតារបស់ខ្លួន ព្រោះអាស្រ័យអញទើបបាន ទើបបុគ្គលនេះ ឈ្មោះថា ឲ្យហើយត្រឡប់មើលងាយវិញ ។ តែបុគ្គលម្នាក់ អាស្រ័យបុគ្គលម្នាក់អស់ពីរបីឆ្នាំ មានសេចក្តីគោរពក្នុងបុគ្គលនោះតែក្នុងគ្រាដំបូង លុះខាងក្រោយពេលវេលាកន្លងទៅ មិនធ្វើសេចក្តីគោរពកោតក្រែង ដូចជាមិនក្រោកអំពីអាសនៈខ្លះ

មិនទៅកាន់ទីបម្រើខ្លះ បុគ្គលបែបនេះ ឈ្មោះថា មើលងាយ ព្រោះការនៅរួម ។

បទថា **អាធេយ្យមុខោ** បានដល់ បុគ្គលជឿងាយអំពីខាងដើម អធិប្បាយថា បុគ្គលមានការសម្គាល់ហើយ ក្នុងពាក្យដំបូងប៉ុណ្ណោះ ។ បទថា **អធិមុច្ចិតា ហោតិ** បានដល់ ជាអ្នកមានសទ្ធា ។ ក្នុងបទថា **អធិមុច្ចិតា ហោតិ** នេះ មានន័យដូចតទៅនេះថា បុគ្គលម្នាក់ពោលដល់ភិក្ខុ ដែលមានសមណសារូបនោះឯងថា ភិក្ខុនេះមិនមានសមណសារូប បុគ្គលនោះ កាលស្តាប់ពាក្យនោះហើយ ជឿដោយចំណែកមួយ ។ ភិក្ខុដែលធ្លាប់គាប់ចិត្តនឹងគ្នាអន្លដទៃ ពោលថា ភិក្ខុនេះ មានសមណសារូប ក៏មិនជឿពាក្យរបស់ភិក្ខុនោះឡើយ បុគ្គលនោះ ពោលអះអាងថា ភិក្ខុរូបនោះប្រាប់ខ្ញុំ ថាភិក្ខុរូបនេះមិនមានសមណសារូប ដូច្នេះ ទើបជឿពាក្យរបស់ភិក្ខុរូបមុនប៉ុណ្ណោះ ។ សូម្បីបុគ្គលដទៃទៀតពោលដល់ភិក្ខុទ្រុស្តសីលថា ជាអ្នកមានសីល បុគ្គលនោះក៏ជឿពាក្យបុគ្គលនោះហើយ ទោះបីបុគ្គលដទៃទៀត ពោលថា ភិក្ខុនេះមិនមានសមណសារូប មិនគួរចូលទៅកាន់សម្នាក់របស់លោក ដូច្នេះ ក៏មិនជឿពាក្យរបស់បុគ្គលនោះ រមែងជឿពាក្យភិក្ខុរូបមុនប៉ុណ្ណោះ ។ បុគ្គលដទៃទៀត រមែងកាន់យកពាក្យដែលអ្នកដទៃពោលដល់សេចក្តីល្អខ្លះ សេចក្តីអាក្រក់ខ្លះនោះឯង បុគ្គលនេះ ឈ្មោះថា ជាអ្នកមានការជឿងាយ អធិប្បាយថា បុគ្គលជឿងាយ ស្តាប់ពាក្យណាមួយរមែងជាបុគ្គលតាំងសេចក្តីសម្គាល់ក្នុងពាក្យនោះៗ ។

*បទថា* **លោលោ** *សេចក្ដីថា ឈ្មោះថា* **លោលោ** *ព្រោះខ្លួនជាអ្នកញាប់ញ័រដោយភាពជាអ្នកមិនមានសទ្ធាជាដើម ព្រោះសទ្ធាជាដើមជាធម្មជាតតាំងនៅអស់កាលបន្តិចបន្តួច ។ បទថា* **ឥត្តរសទ្ធោ** *បានដល់ ជាអ្នកមានសទ្ធាតិច គឺមានសទ្ធាមិនបរិបូណ៌ ។ ក្នុងពាក្យដ៏សេស ក៏មានន័យនេះដូចគ្នា ។ បុគ្គលមានភក្តី គឺសទ្ធានេះ រមែងប្រព្រឹត្តទៅដោយអំណាចនៃការសេពគប់រឿយៗ ក្នុងអធិការនេះ ។ ឈ្មោះថា សេចក្ដីស្រឡាញ់ ព្រោះជាសេចក្ដីស្រឡាញ់ដែលកើតអំពីសទ្ធាក្ដី អំពីតណ្ហាក្ដី ក៏យកជាការបាន ។ សេចក្ដីជ្រះថ្លា គឺការជ្រះថ្លាដែលកើតអំពីសទ្ធានោះឯង ។ បទថា* **ឯវំ បុគ្គលោ លោលោ ហោតិ** *សេចក្ដីថា បុគ្គលយ៉ាងនេះ ឈ្មោះថា* **លោលោ** *ព្រោះខ្លួនជាអ្នកមានសទ្ធាមិនពិតប្រាកដជាដើម អធិប្បាយថា បុគ្គលឡេះឡោះនេះជាបុគ្គលមានឋានៈដែលមិនតាំងមាំ ដូចសំពត់ដែលជ្រលក់ដោយរមៀត ដូចបង្គោល ដែលបោះលើគំនរអង្កាម ដូចត្រឡាច ដែលគេដាក់លើខ្នងសេះ បុគ្គលនោះរមែងជ្រះថ្លាក្នុងកាលមួយរំពេច រមែងក្រោធក្នុងកាលមួយរំពេច ។*

*បទថា* **មន្ទោ មោមូហោ** *សេចក្ដីថា បុគ្គលឈ្មោះថា* **មន្ទោ** *ព្រោះមិនមានញាណ ឈ្មោះថា* **មោមូហោ** *ព្រោះជាអ្នកមិនឈ្លាស អធិប្បាយថា ជាបុគ្គលវង្វេងច្រើន ។*

*[ ១៤៣-១៤៤ ] វិនិច្ឆ័យក្នុងបុគ្គលប្រៀបដោយទាហាន ដូចតទៅនេះ បទថា* **យោធាជីវា** *បានដល់ បុគ្គលដែលចូលទៅអាស្រ័យការច្បាំងចិញ្ចឹមជីវិតរស់នៅ ។ បទថា* **រជគ្គំ** *បានដល់ គំនរធូលីដែលហុយឡើងអំពីផែនដី*

ដែលដីរសេះជាដើមជាន់ ។ បទថា **ឆ សន្ថម្ភតិ** បានដល់ រមែងមិនអាចប្រឈមមុខបាន ។ បទថា **សហតិ រជគ្គំ** សេចក្ដីថា ឃើញចុងធូលីដែលហុយឡើងអាចអត់ធន់បាន ។ បទថា **ធជគ្គំ** បានដល់ ចុងទង់ជ័យទាំងឡាយ ដែលគេលើកឡើងខាងលើខ្នងដំរី សេះ ឬលើរថ ។ បទថា **ឧស្សារណំ** បានដល់ សំឡេងខ្ទាំងរបស់ដំរី សេះ រថ និងពលនិកាយ ។ បទថា **សម្បហារេ** បានដល់ លុះមានការប្រហារ សូម្បីមានប្រមាណតិចតួចដែលមកដល់ហើយ ។ បទថា **ហញ្ញតិ** បានដល់ រមែងក្ដៅក្រហាយ គឺដល់នូវការរសាប់រសល់ ។ បទថា **ព្យាបជ្ជតិ** បានដល់ រមែងដល់នូវការវិបត្តិ គឺរមែងលះបកតិភាវៈ ។ បទថា **សហតិ សម្បហារំ** សេចក្ដីថា ទាហាននោះសូម្បីត្រូវប្រហារ ២-៣ ដង ក៏នៅតែអត់ធន់ គឺអត់ធន់បាន ។ បទថា **តមេវ សង្គាមសីសំ** បានដល់ ទីបោះបន្ទាយចម្បាំងដែលមានជ័យជម្នះនោះ ។ បទថា **អជ្ឈាវសតិ** បានដល់ រមែងនៅគ្រប់គ្រងប្រមាណ ៧ ថ្ងៃ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះដើម្បីរក្សារបួសរបស់ទាហានដែលត្រូវរបួស ដើម្បីជ្រាបសេចក្ដីល្អរបស់ពួកទាហាន ដែលធ្វើការច្បាំងហើយឲ្យឋានន្តរសក្តិ និងដើម្បីសោយសេចក្ដីសុខនៃភាពជាធំ ។ ព្រោះកិច្ចទាក់ទងនឹងអ្នកចម្បាំងទាំងឡាយ របស់ព្រះសាស្ដាមិនមាន តែឥឡូវនេះដើម្បីសម្ដែងបុគ្គល ៥ ពួកបែបនោះ ក្នុងសាសនានេះ ទើបទ្រង់ធ្វើសេចក្ដីឧបមានេះមក ព្រោះហេតុនោះ កាលទ្រង់សម្ដែងបុគ្គលទាំងនោះ ទើបត្រាស់បទថា **ឯវមេវ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **សំសីទតិ** បានដល់ កំពុងលិច គឺរមែង ធ្លាក់ទៅក្នុងមិច្ឆាវិតក្ក ។ បទថា **ន សក្កោតិ ព្រហ្មចរិយំ សន្ធារេតុំ** សេចក្ដីថា រមែងមិនអាចរក្សាការប្រព្រឹត្តព្រហ្មចរិយៈមិនឲ្យដាច់បាន ។ បទថា **សិក្ខាទុព្វល្យំ អាវិកត្វា** បានដល់ ប្រកាសភាពដែលសិក្ខាជាសភាវៈមានកម្លាំងខ្សោយ ។ បទថា **កិមស្ស វជគ្គស្មិំ** សេចក្ដីថា លោកពោលថា ឈ្មោះថា ចុងធូលីរបស់បុគ្គលនោះ ដូចម្ដេច ។ បទថា **អភិរូបា** បានដល់ មានរូបស្អាត ។ បទថា **ទស្សនីយា** បានដល់ គួរមើល ។ បទថា **បាសាទិកា** បានដល់ នាំការជ្រះថ្លាមកកាន់ចិត្ត ដោយការឃើញនោះឯង ។ បទថា **បរមាយ** បានដល់ ខ្ពង់ខ្ពស់បំផុត ។ បទថា **វណ្ណបោក្ខរតាយ** បានដល់ ដោយវណ្ណៈនៃសរីរៈ និងសណ្ឋាននៃអវយវៈ ។ បទថា **ឱហាសតិ** បានដល់ ញញឹម ។ បទថា **ឧល្លបតិ** បានដល់ រមែងពោល ។ បទថា **ឧជ្ជគ្ឃតិ** បានដល់ រមែងទះដៃ ហើយសើចខ្លាំង ។ បទថា **ឧប្បណ្ឌេតិ** បានដល់ រមែងពោលពាក្យចំអកចំអន់ ។ បទថា **អភិនិសីទតិ** បានដល់ ដែលអង្គុយក្បែរៗ លើអាសនៈតែមួយ ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ បទថា **អជ្ឈោត្ថរតិ** បានដល់ រមែងឱបរឹត ។ បទថា **វិនិវេឋេត្វា វិនិ-មោចេត្វា** បានដល់ រលាស់ និងដោះដៃរបស់មាតុគ្រាមនោះ អំពីទីដែលមាតុគ្រាមចាប់ហើយ ។ ពាក្យដ៏សេសក្នុងទីនេះមានអត្ថងាយយល់ហើយ ។

[ ១៤៥-១៤៦ ] វិនិច្ឆ័យក្នុងភិក្ខុ ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ដូចតទៅនេះ បទថា **មន្ទត្តា មោមូហត្តា** បានដល់ រមែងមិនស្គាល់ការ

សមាទាន និងមិនស្គាល់អានិសង្ស ។ ភិក្ខុជាអ្នកសមាទានទូវបិណ្ឌបាតជាវត្ត ដោយការមិនដឹងនោះឯង ព្រោះខ្លួន ជាបុគ្គលវង្វេង ។ បទថា **ចាបិច្ឆោ ឥច្ឆាបកតោ** សេចក្តីថា ជាអ្នកតាំងនៅក្នុងភាពប្រាថ្នាលាមក ហើយត្រូវ សេចក្តីប្រាថ្នាលាមកនោះគ្របសង្កត់យ៉ាងនេះថា កាលអញប្រព្រឹត្តបិណ្ឌបាត ជាវត្ត ជនទាំងឡាយនឹងធ្វើសក្ការៈដោយបច្ច័យ ៤ ដ្បិតថា ភិក្ខុនេះមានសតិ ជាអ្នកសមាទានបិណ្ឌបាតជាវត្ត ជនទាំងឡាយនឹងលើកតម្កើង ដោយគុណ ទាំងឡាយ មានគុណថា ភិក្ខុនេះជាអ្នកខ្មាស មានការប្រាថ្នាតិចដូច្នេះ ទើប សមាទានបិណ្ឌបាតជាវត្ត ។ ភិក្ខុកាលត្រាច់ទៅបិណ្ឌបាត ដោយភាពជា បុគ្គលឆ្កួត ឈ្មោះថា ភិក្ខុជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ព្រោះការឆ្កួត និង ការវង្វេងវង្វាយចិត្ត ។ បទថា **វណ្ណិតំ** សេចក្តីថា ភិក្ខុពិចារណាថា ធុតង្គ បិណ្ឌបាតិកធុតង្គនេះ ព្រះពុទ្ធទាំងឡាយ និងសាវករបស់ព្រះពុទ្ធទាំងឡាយ ពណ៌នា គឺសរសើរហើយ ទើបប្រព្រឹត្តបិណ្ឌបាតជាវត្ត ។ ក្នុងបទថា **អប្បិច្ឆតំយេវ និស្សាយ** ជាដើម គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះថា ភិក្ខុ សមាទានបិណ្ឌបាតជាវត្ត គិតថា អញនឹងជាអ្នកប្រាថ្នាតិច ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់អញនេះ នឹងប្រព្រឹត្តទៅដើម្បីភាពជាអ្នកប្រាថ្នា តិច អញនឹងជាអ្នកសន្តោស ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់ អញនេះ នឹងប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស អញនឹងជាបុគ្គលជុសខាត់ កិលេសទាំងឡាយ ព្រោះហេតុនេះ អង្គនៃបិណ្ឌបាតិកធុតង្គរបស់អញនេះ នឹងប្រព្រឹត្តទៅ ដើម្បីជុសខាត់កិលេស ។ បទថា **ឥធមត្ថិតំ** សេចក្តីថា

*អាស្រ័យសេចក្តីត្រូវការដោយកល្យាណបដិបទានេះ ឬអាស្រ័យសេចក្តីត្រូវការដោយហេតុត្រឹមតែបិណ្ឌបាតនេះ អធិប្បាយថា អាស្រ័យការៈ គឺការញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយវត្ថុណាមួយតាមមានតាមបាន ។ បទថា* **អគ្គោ** *បានដល់ ដែលចម្រើនបំផុត ។ ពាក្យដ៏សេសជាវេវចនៈនៃពាក្យថា* **អគ្គោ** *នោះឯង ។ បទថា* **គវា ខីរំ** *សេចក្តីថា ធម្មតាទឹកដោះរមែងកើតអំពីគោ វៀរមេគោហើយមិនមាន ។ ក្នុងបទថា* **ខីរម្ហា ទធិ** *ជាដើម ក៏ន័យនេះដូចគ្នា ។ បទថា* **ឯវមេវំ** *អធិប្បាយថា សប្បិប្រភេទថ្លា ប្រសើរជាងបញ្ចគោរសទាំងនេះយ៉ាងណា បណ្តាភិក្ខុដែលសមាទានបិណ្ឌបាតជាវត្ត ៥ ពួកនេះ ក៏យ៉ាងនោះដូចគ្នា ភិក្ខុណា អាស្រ័យភាពជាអ្នកប្រាថ្នាតិចជាដើម ហើយសមាទានបិណ្ឌបាតជាវត្ត ភិក្ខុនេះជាបុគ្គលកំពូល ជាបុគ្គលចម្រើនបំផុត ជាប្រធាន ជាបុគ្គលឧត្តម និងប្រសើរបំផុត ។ បណ្តាភិក្ខុដែលសមា-ទានបិណ្ឌបាតជាវត្ត ៥ ពួកនេះ ដែលសមាទានបិណ្ឌបាតជាវត្ត ដែលពិតប្រាកដមាន ២ ពួក មិនពិតប្រាកដមាន ៣ ពួក ។ បណ្ឌិតគប្បីជ្រាបបុគ្គល ៣ ពួកនេះថា ជាអ្នកសមាទានបិណ្ឌបាតជាវត្ត ត្រឹមតែឈ្មោះប៉ុណ្ណោះ ។*

*ក្នុងភិក្ខុដែលសមាទានខលុបច្ឆាភត្តិកៈជាវត្តជាដើម ក៏មានន័យនេះដូចគ្នា ។ល។*

**អដ្ឋកថាបញ្ចកនិទ្ទេស ចប់**

# អភិធម្មបិដក

## ជក្កនិទ្ទេស

[ ១៤៧ ] បណ្ដាបុគ្គលទាំងនោះ បុគ្គលណាត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន ក៏ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺព្រះសម្មាសម្ពុទ្ធដោយហេតុនោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន តែមិនដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង មិនដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺព្រះបច្ចេកសម្ពុទ្ធ ដោយហេតុនោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន តែជាអ្នកធ្វើនូវទីបំផុតនៃកងទុក្ខក្នុងបច្ចុប្បន្នផង ដល់នូវសាវកបារមីញាណផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺព្រះសារីបុត្ត និងព្រះមោគ្គល្លានដោយហេតុនោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណា មិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈ ក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន ជាអ្នកធ្វើនូវទីបំផុតនៃកងទុក្ខក្នុងបច្ចុប្បន្នបាន តែមិនដល់នូវសាវកបារមីញាណឡើយ បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺពួកព្រះអរហន្តដ៏សេស ដោយហេតុនោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណា មិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុនផង ជាអ្នកមិនទាន់ធ្វើនូវទីបំផុតនៃកងទុក្ខក្នុងបច្ចុប្បន្នផង ជាអនាគាមិបុគ្គល

ព្រោះមិនមកកាន់មនុស្សលោកនេះទៀតផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺអនាគាមិបុគ្គល ដោយហេតុនោះ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមិនត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈ ក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុនផង ជាអ្នកមិនទាន់ធ្វើនូវទីបំផុតនៃកងទុក្ខក្នុងបច្ចុប្បន្ន នៅវិលមកកាន់មនុស្សលោកនេះទៀតផង បណ្ឌិតគប្បីជ្រាបថា បុគ្គលនោះ គឺព្រះសោតាបន្នបុគ្គល និងព្រះសកទាគាមិបុគ្គល ដោយហេតុនោះ ។

ឆក្កនិទ្ទេស ចប់

# អដ្ឋកថា

## ចក្កនិទ្ទេស

[ ១៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចក្កនិទ្ទេសដូចតទៅនេះ បទថា **តត្រ** បានដល់ បណ្ដាបុគ្គលទាំង ៦ ពួកនោះ ។ បទថា **សម្មាសម្ពុទ្ធោ តេន ទដ្ឋព្វោ** សេចក្ដីថា បុគ្គលនោះ បណ្ឌិតគប្បីឃើញថា ជាព្រះសព្វញ្ញុពុទ្ធ ដោយព្រះសព្វញ្ញុតញ្ញាណនោះ ដែលទ្រង់ឲ្យកើតឡើង ដោយព្រះអង្គឯង មិនមានបុគ្គលណាមួយជាអាចារ្យ ។ ក្នុងបទថា **បច្ចេកសម្ពុទ្ធោ តេន** ជាដើម បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បុគ្គលនោះ បណ្ឌិតគប្បីឃើញថា ជាព្រះបច្ចេកសម្ពុទ្ធ ដោយបច្ចេកសម្ពោធិញ្ញាណនោះ ។ បុគ្គលទាំងនោះ បណ្ឌិតគប្បីឃើញថា ជាអគ្គសាវក គឺព្រះសារីបុត្ត និងព្រះមោគ្គល្លាន ដោយសាវកបារមីញាណនោះ ។ បុគ្គលទាំងនោះ បណ្ឌិតគប្បីឃើញថា ជាព្រះអរហន្តទាំងឡាយដ៏សេសដោយការធ្វើនូវទីបំផុតនៃទុក្ខនោះ ។ បុគ្គលនោះ បណ្ឌិតគប្បីឃើញថា ជាព្រះអនាគាមី ព្រោះមិនមកកាន់លោកនេះទៀត ។ បុគ្គលទាំងនោះ បណ្ឌិតគប្បីឃើញថា ជាព្រះសោតាបន្ន និងព្រះសកទាគាមី ព្រោះការមកកាន់លោកនេះនោះឯង ។៚

**អដ្ឋកថាចក្កនិទ្ទេស ចប់**

# អភិធម្មបិដក

## សត្តកនិទ្ទេស

[ ១៤៨ ] បុគ្គលមុជចុះតែម្តង ហើយចេះតែមុជចុះទៅទៀត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយអកុសលធម៌ខ្មៅតែម្យ៉ាង បុគ្គលមុជចុះតែម្តង ហើយចេះតែមុជចុះទៅទៀតយ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយមុជចុះទៅវិញ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសលប្រកបដោយសទ្ធាដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយវិរិយៈដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ តែសទ្ធានោះរបស់បុគ្គលនោះ មិននៅនឹង មិនចម្រើនឡើង តែងសាបសូន្យទៅវិញ ហិរិនោះរបស់បុគ្គលនោះ មិននៅនឹង មិនចម្រើនឡើង តែងសាបសូន្យទៅវិញ ឱត្តប្បៈនោះរបស់បុគ្គលនោះ មិននៅនឹង មិនចម្រើនឡើង តែងសាបសូន្យទៅវិញ វិរិយៈនោះរបស់បុគ្គលនោះ មិននៅនឹង មិនចម្រើនឡើង តែងសាបសូន្យទៅវិញ បញ្ញានោះរបស់បុគ្គលនោះ មិននៅនឹង មិនចម្រើនឡើង តែងសាបសូន្យទៅវិញ បុគ្គលងើបឡើងហើយ មុជចុះទៅវិញ យ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយស្ថិតនៅតើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ... ក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ក្នុងធម៌ជាកុសលប្រកបដោយវិរិយៈដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ សទ្ធានោះរបស់

បុគ្គលនោះមិនសាបសូន្យទៅ មិនចម្រើនឡើង ស្ថិតនៅនឹងដដែល ហិរិនោះរបស់បុគ្គលនោះ មិនសាបសូន្យ មិនចម្រើនឡើង ស្ថិតនៅនឹងដដែល ឱត្តប្បៈនោះរបស់បុគ្គលនោះ មិនសាបសូន្យ មិនចម្រើនឡើង ស្ថិតនៅនឹងដដែល វីរិយៈនោះរបស់បុគ្គលនោះ មិនសាបសូន្យ មិនចម្រើនឡើង ស្ថិតនៅនឹងដដែល បញ្ញានោះ របស់បុគ្គលនោះមិនសាបសូន្យ មិនចម្រើនឡើង ស្ថិតនៅនឹងដដែល បុគ្គលងើបឡើងហើយស្ថិតនៅយ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយ រមិលមើល ក្រឡេកមើល តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ... ក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយវីរិយៈដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះជាសោតាបន្ន ព្រោះអស់ទៅនៃសញ្ញោជនៈទាំង ៣ មានសភាព មិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ បុគ្គលងើបឡើងហើយ រមិលមើល ក្រឡេកមើល យ៉ាងនេះឯង ។ បុគ្គលងើបឡើងហើយហែលទៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើង ក្នុងធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ... ក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃក្នុងធម៌ជាកុសល ប្រកបដោយវីរិយៈដ៏ប្រពៃ ក្នុងធម៌ជាកុសលប្រកបដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះជាសកទាគាមី ព្រោះអស់ទៅនៃសញ្ញោជនៈទាំង ៣ ព្រោះស្រាលស្តើងនៃរាគៈ ទោសៈ និងមោហៈ នៅ

វិលមកកាន់លោកនេះអស់វារៈម្តងទៀត ទើបធ្វើនូវទីបំផុតនៃកងទុក្ខ បុគ្គលងើបឡើងហើយហែលទៅ យ៉ាងនេះឯង ។ បុគ្គលងើបឡើងដល់កំពង់ ហើយស្ថិតនៅ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ... ក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយវីរិយៈដ៏ប្រពៃ ក្នុងធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះជាឱបបាតិកកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ បរិនិព្វានក្នុងសុទ្ធាវាសព្រហ្មលោកនោះ មានសភាពមិនវិលត្រឡប់ចាកព្រហ្មលោកនោះវិញ បុគ្គលងើបឡើងដល់កំពង់ ហើយស្ថិតនៅ យ៉ាងនេះឯង ។ បុគ្គលងើបឡើងឆ្លងដល់ត្រើយ ជាព្រាហ្មណ៍ស្ថិតនៅលើគោក តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយសទ្ធាដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយហិរិដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយឱត្តប្បៈដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយវីរិយៈដ៏ប្រពៃ ងើបឡើងក្នុងធម៌ជាកុសល ប្រកបដោយបញ្ញាដ៏ប្រពៃ បុគ្គលនោះ ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ បុគ្គលងើបឡើងឆ្លងដល់ត្រើយជាព្រាហ្មណ៍ស្ថិតនៅលើគោក យ៉ាងនេះឯង ។

[ ១៤៩ ] បុគ្គលជាឧភតោភាគវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោក

នេះ បានទូវវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះក៏អស់រលីងព្រោះបានឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្ត ។ បុគ្គលជាបញ្ញាវិមុត្ត ជាកាយសក្ខី ជាទិដ្ឋិប្បត្តៈ ជាសទ្ធាវិមុត្ត ជាធម្មានុសារី តើដូចម្តេច ។ បុគ្គលជាសទ្ធានុសារី តើដូចម្តេច ។ បុគ្គលណា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានសទ្ធិន្ទ្រិយដ៏លើសលុប បុគ្គលនោះ ចម្រើននូវអរិយមគ្គ មានសទ្ធាជាគ្រឿងនាំទៅ មានសទ្ធាជាប្រធាន នេះហៅថា បុគ្គលជាសទ្ធានុសារី ។ បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ហៅថា សទ្ធានុសារី ។ បុគ្គលដែលតាំងនៅក្នុងផល ហៅថា សទ្ធាវិមុត្ត ។

**សត្តកនិទ្ទេស ចប់**

# អដ្ឋកថា

## សត្តកនិទ្ទេស

[ ១៤៨-១៤៩ ] វិនិច្ឆ័យក្នុងបុគ្គល ៧ ពួក ដូចតទៅនេះ បទថា **សកឹ និមុគ្គោ** បានដល់ បុគ្គលពួកខ្លះ លិចចុះហើយ អស់វារៈម្តង ៗ បទថា **ឯកន្តកាឡកេហិ** បានដល់ ដោយធម៌ គឺនិយតមិច្ឆាទិដ្ឋិទាំងឡាយ គឺនត្ថិកវាទ អហេតុកវាទ និងអកិរិយវាទ ដែលខ្មៅដោយចំណែកមួយប៉ុណ្ណោះ ៗ បទថា **ឯវំ បុគ្គលោ** សេចក្តីថា បុគ្គលលិចចុះអស់វារៈម្តង ដោយហេតុនេះ ហើយក៏លិចចុះ យ៉ាងនោះឯង ៗ អាចារ្យពួកខ្លះពោលថា ឈ្មោះថា ការចេញចាកកពរបស់និយតមិច្ឆាទិដ្ឋិបុគ្គលនោះ រមែងមិនមាន ៗ បុគ្គលនោះ ជាចំណីរបស់ត្រីងនរកទាំងឡាយខាងក្រោមនោះឯង ដូចគ្រូទាំងឡាយ មាន មក្ខលិគោសាលជាដើម ៗ បទថា **សាហុ សទ្ធា កុសលេសុ ធម្មេសុ** សេចក្តីថា រមែងផុសឡើងដោយឃើញថា ឈ្មោះថា សទ្ធាក្នុងកុសលធម៌ ទាំងឡាយ ជាហេតុឲ្យបានសេចក្តីល្អ ៗ បុគ្គលនោះ ឈ្មោះថា រមែងផុស ឡើងដោយកុសលធម៌ មានប្រមាណប៉ុណ្ណោះនោះឯង ៗ ក្នុងបទថា **សាធុ ហិរិ** ជាដើម ក៏មានន័យនេះដូចគ្នា ៗ បទថា **ហាយតិយេវ** សេចក្តីថា បុគ្គលនោះ រមែងជ្រះថ្លាដោយចំណែកមួយប៉ុណ្ណោះ ដូចទឹកដែលចាក់ក្នុង ភក់ ៗ បទថា **ឯវំ បុគ្គលោ** សេចក្តីថា និយតមិច្ឆាទិដ្ឋិបុគ្គលនោះ ផុស ឡើងអស់វារៈម្តង ដោយអំណាចនៃសទ្ធាជាដើមទាំងនេះដោយគិតថា សទ្ធា ជាគុណជាតិដ៏ប្រពៃយ៉ាងនេះហើយក៏លិចចុះ ព្រោះការវិនាសចាកធម៌ មាន

សទ្ធាជាដើមនោះឯងទៀត ដូចទេវទត្តភិក្ខុជាដើម ។ សេចក្តីសង្ខេបថា ទេវទត្តភិក្ខុធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើត ហើយក៏សាបសូន្យចាកគុណវិសេសទាំងនោះ ព្រោះភាពជាបដិបក្ខចំពោះព្រះសម្ពុទ្ធ ទើបធ្វើលោហិតុប្បាទកម្ម និងសង្ឃភេទកម្ម កាលកាយបែកធ្លាយ ទើបកើតក្នុងនរកដោយវារចិត្តទី ២ ។ កោកាលិកភិក្ខុពោលទោសអគ្គសាវកទាំង ២ ទើបកើតក្នុងបទុមនរក ។

បទថា **នេវ ហាយតិ នោ វឌ្ឍតិ** សេចក្តីថា ក្នុងពេលដែលខ្វះខាតសទ្ធាក៏មិនវិនាស ក្នុងពេលដែលបរិបូណ៌សទ្ធាក៏មិនចម្រើន សេចក្តីទាំងពីរនោះ បណ្ឌិតគប្បីសម្តែងដោយគ្រហស្ថផង ដោយបព្វជិតផង ។ គ្រហស្ថពួកខ្លះ ក្នុងពេលដែលខ្វនខ្វះខាត ក៏នៅតែឲ្យបក្ខិកភត្ត សលាកភត្ត និងសំពត់ងូតទឹកភ្លៀងរឿយៗ សូម្បីក្នុងវេលាដែលបរិបូណ៌ខាងក្រោយ ក៏នៅតែឲ្យត្រឹមតែបក្ខិកភត្តជាដើមប៉ុណ្ណោះ ។ ចំណែកបព្វជិត ខាងដើម ក្នុងវេលាដែលគុណធម៌នៅមានតិច រមែងរៀនឧទ្ទេស ឬធុតង្គ ក្នុងវេលាដែលសម្បត្តិគឺបញ្ញា ពល និងវីរិយៈ បរិបូណ៌ ក៏មិនធ្វើឲ្យក្រៃលែងជាងនោះ ។ បទថា **ឯវំ បុគ្គលោ** សេចក្តីថា បុគ្គលយ៉ាងនេះ ឈ្មោះថា បុគ្គលងើបឡើងហើយស្ថិតនៅ ដោយការតាំងនៅនៃធម៌ទាំងឡាយ មានសទ្ធាជាដើមនេះ ។

បទថា **ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ** សេចក្តីថា ព្រះសោតាបន្នឈ្មោះថា ងើបឡើងហើយសម្លឹងមើលផ្លូវ ដែលជាទីទៅខាងលើ ឬទិសដែលគួរទៅ ។ បទថា **ឧម្មុជ្ជិត្វា បតរតិ** សេចក្តីថា ព្រះសកទាគាមិបុគ្គល

*ឈ្មោះថា ងើបឡើងហើយទៅមុខ កាន់ទិសដែលគប្បីទៅ ព្រោះខ្លួនមានកិលេសស្តើង ។ បទថា* **បតិគាធប្បត្តោ ហោតិ** *សេចក្តីថា ព្រះអនាគាមិបុគ្គល ឈ្មោះថា ងើបឡើងសម្លឹងមើលទិសដែលគួរទៅ ហើយក៏ឆ្លងទៅដល់ទីមួយ ដែលជាទីពឹងហើយ សម្រាកសម្រាន្ត មិនត្រឡប់មកទៀត ។*

*បទថា* **តិណ្ណោ បារង្គតោ ថលេ តិដ្ឋតិ** *សេចក្តីថា ព្រះខីណាស្រព ឈ្មោះថា ឆ្លងអន្លង់ គឺកិលេសទាំងពួងហើយ ដល់ត្រើយនាយហើយ រមែងតាំងនៅលើគោក គឺព្រះនិព្វាន ។ បុគ្គល ៧ ពួកនេះ លោកសម្តែងការឧបមាដោយអន្លង់ទឹកជាឧទាហរណ៍ដូចតទៅនេះ*

*បានឮថា នាយជង្ឃពាណិជ្ជ គឺឈ្មួញលោហៈ ៧ នាក់ ធ្វើដំណើរផ្លូវឆ្ងាយដល់ស្ទឹងដែលមានទឹកព្រៀបប្រាំងក្នុងរវាងផ្លូវ បណ្តាឈ្មួញទាំងនោះ ឈ្មួញទី ១ ជាអ្នកខ្លាចទឹក ចុះមុនហើយ ក៏លិចក្នុងទីដែលចុះនោះឯង មិនអាចផុសឡើង ក្លាយជាចំណីរបស់ត្រី និងអណ្តើកក្នុងស្ទឹងនោះឯង ។ ឈ្មួញទី ២ លិចចុះក្នុងទីដែលចុះហើយ ផុសឡើងម្តងហើយ ក៏លិចចុះវិញ មិនអាចផុសឡើងបានទៀត ក៏ក្លាយជាអាហាររបស់ត្រី និងអណ្តើក ក្នុងស្ទឹងនោះដូចគ្នា ។ ឈ្មួញទី ៣ លិចចុះ ហើយផុសឡើង ហើយឈប់ត្រង់កណ្តាលស្ទឹង មិនអាចទៅកាន់ត្រើយអាយ មិនអាចមកកាន់ត្រើយនាយ ។ ឈ្មួញទី ៤ លិចចុះហើយ ផុសឡើងហើយ បណ្តែតខ្លួន សម្លឹងមើលកំពង់ជាទីឆ្លងទៅ ។ ឈ្មួញទី ៥ លិចចុះហើយ ផុសឡើង ហើយបណ្តែតខ្លួន សម្លឹងមើលកំពង់ជាទីឆ្លងទៅ ហើយក៏ឆ្លងទៅ ។ ឈ្មួញទី ៦ ( លិចចុះហើយ*

ផុសឡើងហើយ ) ឆ្លងទៅហើយដល់ត្រើយនាយ ហើយឈរក្នុងទឹកត្រឹមចង្កេះ ។ ឈ្នួញទី ៧ ( លិចចុះហើយ ... ) ដល់ត្រើយនាយហើយ ងូតទឹកជម្រះខ្លួនដោយលម្អិតក្រអូបជាដើម ដណ្ដប់សំពត់ដ៏ប្រសើរ ប្រោះព្រំដោយគ្រឿងក្រអូប ប្រដាប់ផ្កាឧប្បលខៀវជាដើម មួយអន្លើដោយគ្រឿងអលង្ការច្រើនប្រភេទ ហើយចូលទៅកាន់មហានគរ ឡើងកាន់ប្រាសាទបរិភោគនូវភោជនដ៏ឧត្ដម ។

ក្នុងសេចក្ដីនោះ បណ្ឌិតគប្បីជ្រាបពាក្យឧបមាដូចតទៅនេះថា គឺបុគ្គលទាំង ៧ ពួកនោះ ប្រៀបដូចឈ្នួញលោហៈ ៧ នាក់ វដ្ដៈ ប្រៀបដូចស្ទឹង ការលិចចុះក្នុងវដ្ដៈ របស់និយតមិច្ឆាទិដ្ឋិបុគ្គល បណ្ឌិតគប្បីជ្រាបថា ដូចគ្នានឹងការលិចចុះក្នុងកំពង់ដែលឆ្លង របស់ឈ្នួញទី ១ ដែលខ្លាចទឹក បុគ្គលដែលផុសឡើង ដោយហេតុត្រឹមតែការកើតឡើងនៃសទ្ធាជាដើម ហើយលិចចុះទៅ ព្រោះការវិនាសសទ្ធាជាដើមនោះ ដូចគ្នានឹងឈ្នួញ ដែលផុសឡើងម្ដង ហើយក៏លិចចុះទៅក្នុងស្ទឹង ។ បុគ្គលដែលតាំងនៅដោយការតាំងមាំនៃសទ្ធាជាដើម ដូចគ្នានឹងឈ្នួញដែលបណ្ដែតខ្លួនកណ្ដាលស្ទឹង ។ ព្រះសោតាបន្ន សម្លឹងមើលផ្លូវដែលខ្លួនគប្បីទៅ ឬទិសដែលគួរទៅ ដូចឈ្នួញដែលផុសឡើងសម្លឹងមើលកំពង់ជាទីឆ្លងទៅ ។ ព្រះសកទាគាមី ឈ្មោះថា ឆ្លងទៅ ព្រោះភាពដែលខ្លួនជាអ្នកមានកិលេសស្ដើង ប្រៀបដូចឈ្នួញដែលឆ្លងទៅ ។ ព្រះអនាគាមី ឈ្មោះថា ដែលតាំងនៅដោយភាពជាអ្នកមិនត្រឡប់មកកាន់កាមលោកនេះជាធម្មតា ដូចគ្នានឹងឈ្នួញ ដែលឆ្លងទៅ ហើយឈរ

ក្នុងទឹកត្រឹមចង្កេះ ។ ព្រះខីណាស្រេពជាព្រាហ្មណ៍ ឈានកន្លងឱឃៈទាំង ៤ ហើយឈរនៅលើគោក គឺព្រះនិព្វាន ដូចឈ្មួញដែលងូតទឹកជម្រះរាងកាយឲ្យស្អាត ហើយឡើងទៅកាន់ត្រើយនាយ ឈរលើគោក ។ បណ្ឌិតគប្បីជ្រាបថា ការដែលព្រះខីណាស្រេព ចូលផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ហើយឲ្យពេលវេលាកន្លងទៅ ដូចឈ្មួញដែលឈរលើគោកចូលទៅកាន់នគរ ឡើងកាន់ប្រាសាទដ៏ប្រសើរ ហើយបរិភោគអាហារដ៏ឧត្តម ។ ព្រះអរិយបុគ្គលទាំងឡាយ មានឧកតោភាគវិមុត្តបុគ្គលជាដើម ខ្ញុំបានពោលហើយ ខាងដើមនោះឯង ។៚

**អដ្ឋកថាសត្តកនិទ្ទេស ចប់**

# អភិធម្មបិដក

## អដ្ឋកនិទ្ទេស

[ ១៥០ ] បុគ្គល ៤ ពួកព្រមព្រៀងដោយមគ្គ បុគ្គល ៤ ពួកព្រមព្រៀងដោយផល តើដូចម្តេច ។ សោតាបន្នបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ សកទាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ អនាគាមិបុគ្គល ១ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ ព្រះអរហន្ត ១ បុគ្គលប្រតិបត្តិដើម្បីភាពជាព្រះអរហន្ត ១ ។ នេះបុគ្គល ៤ ពួក ព្រមព្រៀងដោយមគ្គ នេះបុគ្គល ៤ ពួក ព្រមព្រៀងដោយផល ។

អដ្ឋកនិទ្ទេស ចប់

## នវកនិទ្ទេស

[ ១៥១ ] បុគ្គលជាព្រះសម្មាសម្ពុទ្ធ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈ ក្នុងធម៌ទាំងឡាយដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន ទាំងដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងនោះផង ដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង នេះហៅថា បុគ្គលជាព្រះសម្មាសម្ពុទ្ធ ។ បុគ្គលជាព្រះបច្ចេកសម្ពុទ្ធ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ត្រាស់ដឹងដោយខ្លួនឯងនូវសច្ចៈ ក្នុងធម៌ទាំងឡាយ ដែលខ្លួនមិនធ្លាប់ឮក្នុងកាលមុន តែមិន

ដល់នូវសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងនោះផង មិនដល់នូវភាពស្ទាត់ក្នុងទសពលញ្ញាណផង នេះហៅថា បុគ្គលជាព្រះបច្ចេកសម្ពុទ្ធ ។ បុគ្គលជាឧភតោភាគវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាននូវវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈទាំងឡាយ របស់បុគ្គលនោះក៏អស់រលីង ព្រោះបានឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្ត ។ បុគ្គលជាបញ្ញាវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនបាននូវវិមោក្ខ ៨ ដោយនាមកាយឡើយ តែអាសវៈរបស់បុគ្គលនោះ អស់រលីង ព្រោះបានឃើញដោយបញ្ញា នេះហៅថា បុគ្គលជាបញ្ញាវិមុត្ត ។ បុគ្គលជាកាយសក្ខី តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ បាននូវវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់រលីង ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាកាយសក្ខី ។ បុគ្គលជាទិដ្ឋិប្បត្តៈ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងត់ទុក្ខ ទាំងពួកធម៌ដែលព្រះតថាគតទ្រង់សម្តែងហើយ បុគ្គលនោះ ក៏បានឃើញល្អ ប្រព្រឹត្តល្អដោយបញ្ញា ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់រលីង ព្រោះបានឃើញដោយបញ្ញា នេះហៅថា បុគ្គលជាទិដ្ឋិប្បត្តៈ ។ បុគ្គលជាសទ្ធាវិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិទៅកាន់ធម៌រម្ងត់ទុក្ខ ទាំងពួកធម៌ដែលព្រះតថាគតទ្រង់សម្តែងហើយ បុគ្គលនោះក៏បានឃើញល្អ ប្រព្រឹត្តល្អដោយបញ្ញា ទាំងអាសវៈពួកខ្លះរបស់

បុគ្គលនោះក៏អស់ទៅ ព្រោះបានឃើញដោយបញ្ញា តែមិនដូចជាទិដ្ឋិប្បត្ត-បុគ្គលទេ នេះហៅថា បុគ្គលជាសទ្ធាវិមុត្ត ។ បុគ្គលជាធម្មានុសារី តើដូចម្តេច ។ បុគ្គលណា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានបញ្ញិន្ទ្រិយដ៏លើសលុប បុគ្គលនោះ ចម្រើននូវអរិយមគ្គ មានបញ្ញាជាគ្រឿងនាំទៅ មានបញ្ញាជាប្រធាន នេះហៅថា បុគ្គលជាធម្មានុសារី ។ បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា ធម្មានុសារី ។ បុគ្គលដែលតាំងនៅក្នុងផល ឈ្មោះថា ទិដ្ឋិប្បត្តៈ ។ បុគ្គលជាសទ្ធានុសារី តើដូចម្តេច ។ បុគ្គលណា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល មានសទ្ធិន្ទ្រិយដ៏លើសលុប បុគ្គលនោះ ចម្រើននូវអរិយមគ្គ មានសទ្ធាជាគ្រឿងនាំទៅ មានសទ្ធាជាប្រធាន នេះហៅថា បុគ្គលជាសទ្ធានុសារី ។ បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា សទ្ធានុ-សារី ។ បុគ្គលដែលតាំងនៅក្នុងផល ឈ្មោះថា សទ្ធាវិមុត្ត ។៙

**នវកនិទ្ទេស ចប់**

# អដ្ឋកថា

## អដ្ឋកនិទ្ទេស និងនវកនិទ្ទេស

[ ១៥០-១៥១ ] ក្នុងអដ្ឋកនិទ្ទេសនិងនវកនិទ្ទេស បណ្ឌិតគប្បីជ្រាប ដោយន័យដែលខ្ញុំបានពោលហើយ ខាងដើមនោះឯង ។

**អដ្ឋកថាអដ្ឋកនិទ្ទេស និងនវកនិទ្ទេស ចប់**

# អភិធម្មបិដក

## ទសកនិទ្ទេស

[ ១៥២ ] បុគ្គល ៥ ពួក មានការសម្រេចក្នុងកាមាវចរភូមិនេះ តើដូចម្តេច ។ សត្តក្ខត្តុំបរមបុគ្គល ១ កោលំកោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ និងបុគ្គលដែលជាព្រះអរហន្តក្នុងបច្ចុប្បន្ន ១ នេះបុគ្គល ៥ ពួក មានការសម្រេចក្នុងកាមាវចរភូមិនេះ ។ បុគ្គល ៥ ពួក មានការសម្រេចព្រោះលះបង់នូវអត្តភាពក្នុងកាមាវចរភូមិនេះ តើដូចម្តេច ។ អន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ នេះបុគ្គល ៥ ពួក មានការសម្រេច ព្រោះលះបង់នូវអត្តភាពក្នុងកាមាវចរភូមិនេះ ។

ទសកនិទ្ទេស ចប់

បុគ្គលបញ្ញត្តិនៃបុគ្គលទាំងឡាយ មានប្រមាណប៉ុណ្ណោះ

បុគ្គលបញ្ញត្តិបករណៈ ឆភាណវារ ចប់

# អដ្ឋកថា

## ឧសភនិទ្ទេស

[ ១៥២ ] បទថា **ឥធ** បានដល់ ក្នុងកាមាវចរភូមិ ។ ព្រះអរិយបុគ្គលទាំងឡាយ មានសត្តក្ខត្តុបរមបុគ្គលជាដើម ដែលនៅក្នុងកាមាវចរភូមិ រមែងសម្រេចក្នុងកាមាវចរភូមិនោះឯង សេចក្ដីថា ការសម្រេចអរហត្តក្ដី ការសម្រេចអនុបាទិសេសនិព្វានក្ដី រមែងមានក្នុងអត្តភាព ដែលលោកកើតក្នុងកាមាវចរភូមិនោះឯង ។ បទថា **ឥធ វិហាយ** អធិប្បាយថា ព្រះអនាគាមិ-បុគ្គលដែលលះអត្តភាពក្នុងកាមាវចរភូមិនេះ ហើយតាំងនៅក្នុងអត្តភាពជាន់សុទ្ធាវាសភូមិ ទើបសម្រេចជាព្រះអរហន្ត ។ ព្រះអនាគាមី ៥ ពួក មានអន្តរាបរិនិព្វាយីជាដើម សម្រេចអនាគាមិផល ក្នុងកាមាវចរភូមិនេះហើយ លុះចុតិអំពីកាមាវចរភូមិ ក៏បដិសន្ធិក្នុងសុទ្ធាវាសភូមិ ទើបសម្រេចអរហត្តនិងអនុបាទិសេសនិព្វានធាតុដោយអត្តភាពនោះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ឥមេសំ បញ្ចន្នំ ឥធ វិហាយ និដ្ឋា** ជាដើម ដូច្នេះ ។

**អដ្ឋកថាឧសភនិទ្ទេស ចប់**

# និគមនកថា

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះសាស្តា មិនមានបុគ្គលប្រៀបផ្ទឹម ក្នុងលោក ទ្រង់សម្តែងហើយ នូវគម្ពីរបុគ្គលបញ្ញត្តិណា ក្នុងលំនៅនៃទេវតា នាស្ថានតាវត្តិង្ស ដោយមិនសង្ខេបពេក ។

អត្ថណាមួយ ក្នុងទីណាមួយ ដែលជាអដ្ឋកថានៃបុគ្គលបញ្ញត្តិនោះ រចនាដោយភាសាអ្នកកោះ ( សីហឡៈ ) និងដែលជាបាលី និងអដ្ឋកថាទាំងឡាយ ដែលចែកល្អហើយ មិនសាំញ៉ាំមាន ខ្ញុំសង្គ្រោះយកអត្ថនោះៗ អំពីទីនោះៗ កាត់នូវសេចក្តីពិស្តារពេកចោល ពាក្យដែលពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ខ្ញុំមិនកាន់យកពាក្យនោះ រចនាអដ្ឋកថានេះ ដោយន័យមិនសង្ខេបពេក មិនពិស្តារពេក ។

កុសលឯណា ដល់ព្រមដល់ខ្ញុំ អ្នករចនាអដ្ឋកថានេះ ដែលមាន ៧ ភាណវារ ដើម្បីការតាំងមាំនៃព្រះសទ្ធម្មអស់កាលយូរ ដោយភាពជាបែបផែន ដោយកុសលនោះ សូមសត្វទាំងឡាយឃើញ គឺសម្រេចនូវព្រះសទ្ធម្ម ដ៏សុខុមជ្រាលជ្រៅ ជាធម៌ផុតភ័យ ដោយធម្មចក្ខុដ៏បរិសុទ្ធហោង ។

## អដ្ឋកថាបុគ្គលបញ្ញត្តិប្បករណ៍ ចប់

# ក្បាលទី ៧០

# អភិធម្មបិដក បាលីប្រែ -៨៣

## ធាតុកថា

### *សន្ទឹកចង្អុលប្រាប់មាតិកា*

*មាតិកា* *លេខទំព័រ*


*អភិធម្មបិដក មាតិកា* ...... ...... ...... ...... ...... ...... ...... .. ២

*អារម្ភកថា* ...... ...... ...... .... ៤

*អដ្ឋកថាមាតិកា នយមាតិកាជាដើម* ...... ...... ...... ..... ៤

*អភិធម្មបិដក សង្គហាសង្គហបទនិទ្ទេស* ...... ...... ...... .... ១០

*អដ្ឋកថាសង្គហាសង្គហបទ* ...... ...... ...... ..... ១៤

*អភិធម្មបិដក អាយតនបទនិទ្ទេស* ...... ...... ...... ..... ១៧

*អភិធម្មបិដក ធាតុនិទ្ទេស* ...... ...... ...... ...... ...... ...... ...... ...... ១៩

*អដ្ឋកថាអាយតនបទជាដើម* ...... ...... ...... ...... ២១

*អភិធម្មបិដក សច្ចនិទ្ទេស* ...... ...... ...... ...... ...... ...... ...... ...... ២៣

*អដ្ឋកថាសច្ចបទ* ...... ...... ...... ...... ...... ...... ...... ...... ២៦

*អភិធម្មបិដក ឥន្ទ្រិយនិទ្ទេស* ...... ...... ...... ...... ២៧

*អដ្ឋកថាឥន្ទ្រិយបទ* ...... ...... ...... ...... ...... ...... ...... ...... ៣០

*អភិធម្មបិដក បដិច្ចសមុប្បាទនិទ្ទេសជាដើម* ...... ...... ...... ...... ៣១

*អដ្ឋកថាបដិច្ចសមុប្បាទជាដើម* ...... ...... ...... ...... ៣៥

*អភិធម្មបិដក តិកមាតិកានិទ្ទេស* ...... ...... ...... ...... ៣៨

*អដ្ឋកថាតិកបទ* ...... ...... ...... ...... ...... ...... ...... ...... ៥៩

*អភិធម្មបិដក សង្គហិតេន អសង្គហិតបទនិទ្ទេស* ...... ...... ...... ...... ៦០

អដ្ឋកថាសង្គហិតេនអសង្គហិតបទ ...... ...... ...... ...... ៦៣

អភិធម្មបិដក អសង្គហិតេន សង្គហិតបទនិទ្ទេស ...... ...... ...... ...... ៦៩

អដ្ឋកថាអសង្គហិតេនសង្គហិតបទ ...... ...... ...... ...... ៧៤

អភិធម្មបិដក សង្គហិតេន សង្គហិតបទនិទ្ទេស ...... ...... ...... ...... ៧៩

អដ្ឋកថាសង្គហិតេនសង្គហិតបទ ...... ...... ...... ...... ៨២

អភិធម្មបិដក អសង្គហិតេន អសង្គហិតបទនិទ្ទេស ...... ...... ...... ...... ៨៤

អដ្ឋកថាអសង្គហិតេនអសង្គហិតបទ ...... ...... ...... ...... ៩៩

អភិធម្មបិដក សម្បយោគវិប្បយោគបទនិទ្ទេស ...... ...... ...... ...... ១០៣

អដ្ឋកថាសម្បយោគវិប្បយោគបទ ...... ...... ...... ...... ១២១

អភិធម្មបិដក សម្បយុត្តេន វិប្បយុត្តបទនិទ្ទេស ...... ...... ...... ..... ១២៨

អដ្ឋកថាសម្បយុត្តេនវិប្បយុត្តបទ ...... ...... ...... ...... ១៣១

អភិធម្មបិដក វិប្បយុត្តេន សម្បយុត្តបទនិទ្ទេស ...... ...... ...... ...... ១៣៤

អដ្ឋកថាវិប្បយុត្តេនសម្បយុត្តបទ ...... ...... ...... ...... ១៣៥

អភិធម្មបិដកសម្បយុត្តេនសម្បយុត្តបទនិទ្ទេស ...... ...... ...... ...... ១៣៦

អដ្ឋកថាសម្បយុត្តេនសម្បយុត្តបទ ...... ...... ...... ...... ១៤៥

អភិធម្មបិដក វិប្បយុត្តេន វិប្បយុត្តបទនិទ្ទេស ...... ...... ...... ...... ១៤៨

អដ្ឋកថាវិប្បយុត្តេនវិប្បយុត្តបទ ...... ...... ...... ...... ១៦៣

អភិធម្មបិដក សង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ...... ...... ១៦៤

អដ្ឋកថាសង្គហិតេនសម្បយុត្តវិប្បយុត្តបទ ...... ...... ...... ១៦៩

អភិធម្មបិដក សម្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ...... ...... ១៧១

អដ្ឋកថាសម្បយុត្តេនសង្គហិតាសង្គហិតបទ ...... ...... ...... ១៧៩

អភិធម្មបិដក អសង្គហិតេន សម្បយុត្តវិប្បយុត្តបទនិទ្ទេស ...... ..... ១៨០

អដ្ឋកថាអសង្គហិតេនសម្បយុត្តវិប្បយុត្តបទ ...... ...... ...... ១៨៨

អភិធម្មបិដក វិប្បយុត្តេន សង្គហិតាសង្គហិតបទនិទ្ទេស ...... ...... ១៩០

អដ្ឋកថាវិប្បយុត្តេនសង្គហិតាសង្គហិតបទ ...... ...... ...... ...... ...... ២១២

## អភិធម្មបិដក បុគ្គលបញ្ញត្តិ

អភិធម្មបិដក ឧទ្ទេសវារ ...... ...... ...... ...... ...... ...... ២១៥

អភិធម្មបិដក ខន្ធបញ្ញត្តិជាដើម ...... ...... ...... ...... ...... ...... ២១៥

អភិធម្មបិដក ឯកកមាតិកាជាដើម ...... ...... ...... ...... ...... ...... ២១៧

អារម្ភកថា ...... ...... ...... ...... ...... ...... ...... ...... ២៣១

អដ្ឋកថាមាតិកា ...... ...... ...... ...... ...... ...... ២៣២

អភិធម្មបិដក ឯកកនិទ្ទេស ...... ...... ...... ...... ...... ...... ២៤៣

អដ្ឋកថាឯកកនិទ្ទេស ...... ...... ...... ...... ...... ...... ២៥៤

អភិធម្មបិដក ទុកនិទ្ទេស ...... ...... ...... ...... ...... ...... ៣០៧

អដ្ឋកថាទុកនិទ្ទេស ...... ...... ...... ...... ...... ...... ៣២៤

អភិធម្មបិដក តិកនិទ្ទេស ...... ...... ...... ...... ...... ...... ៣៣២

អដ្ឋកថាតិកនិទ្ទេស ...... ...... ...... ...... ...... ...... ៣៥៦

អភិធម្មបិដក ចតុក្កនិទ្ទេស ...... ...... ...... ...... ...... ...... ៣៩០

អដ្ឋកថាចតុក្កនិទ្ទេស ...... ...... ...... ...... ...... ...... ៤៣៩

អភិធម្មបិដក បញ្ចកនិទ្ទេស ...... ...... ...... ...... ...... ...... ៤៩៨

អដ្ឋកថាបញ្ចកនិទ្ទេស ...... ...... ...... ...... ...... ...... ៥១១

អត្ថរបស់ អារម្ភ សព្ទ ...... ...... ...... ...... ...... ...... ៥១១

អភិធម្មបិដក ឆក្កនិទ្ទេស ...... ...... ...... ...... ...... ...... ៥២២

អដ្ឋកថាឆក្កនិទ្ទេស ...... ...... ...... ...... ...... ...... ៥២៤

អភិធម្មបិដក សត្តកនិទ្ទេស ...... ...... ...... ...... ...... ...... ៥២៥
អដ្ឋកថាសត្តកនិទ្ទេស ...... ...... ...... ...... ...... ...... ៥២៩
អភិធម្មបិដក អដ្ឋកនិទ្ទេស ...... ...... ...... ...... ...... ...... ៥៣៤
អភិធម្មបិដក នវកនិទ្ទេស ...... ...... ...... ...... ...... ...... ៥៣៤
អដ្ឋកថាអដ្ឋកនិទ្ទេសនិងនវកនិទ្ទេស ...... ...... ...... ...... ...... ...... ៥៣៧
អភិធម្មបិដក ទសកនិទ្ទេស ...... ...... ...... ...... ...... ...... ៥៣៨
អដ្ឋកថាទសកនិទ្ទេស ...... ...... ...... ...... ...... ...... ៥៣៩